## សៀវភៅ មង្គលត្ថទីបនីប្រែ

ភាគទី២ នេះ

*ខ្ញុំអនុញ្ញាតឲ្យផ្សាយជាធម្មទានតាម វិបសាយ នេះ បានតាមត្រូវការ ។*

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក  ថ្ងៃ ១៥ កើត ខែមាឃ ព.ស.២៥៥៨


2630 N, Grand Ave.
Santa Ana, CA 92705
*(714) 771-7344*


*ធម្មទានឈ្នះអស់ទានទាំងពួង*

# មង្គលត្ថទីបនីប្រែ

## ភាគទី២

*ប្រែនិងរៀបរៀងដោយ*


**ភិក្ខុវិនយធរោ**

(មហាឃិន-នឿន


*ផ្សាយជាធម្មទាន*

លើកទី១

*ចំនួន ១២០០ ក្បាល*


**រក្សាសិទ្ធិ**


**ព.ស.២៥៣៨**

# មង្គលត្ថទីបនីប្រែ

## ភាគទី ២

ភិក្ខុវិនយធរោ

(មហាឃិន-ឡឿន)

ប្រែនិងរៀបរៀង

*ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា*

និង

*ផ្សាយជាធម្មទាន លើកទី ១*

ចំនួន ១.២០០ក្បាល

*រក្សាសិទ្ធិ*

ព.ស.២៥៣៨ គ.ស.១៩៩៥

ហាងលីញ-ណត់

# មង្គលត្ថទីបនី ប្រែ

## ភាគទី ២

~~~~~

ភិក្ខុវិនយធរោ
(មហាយិន-នឿន)

ប្រែនិងរៀបរៀង

ជំនួយដល់សមណសិស្សពុទ្ធិកមធ្យមសិក្សា

និង

ផ្សាយជាធម្មទាន លើកទី ១

ចំនួន ១.២០០ក្បាល

-----------

រក្សាសិទ្ធិ

ព.ស.២៥៣៨ គ.ស.១៩៩៥

ហាមទិញ-លក់
~~~~~

រក្សាសិទ្ធិគ្រប់យ៉ាង

**រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ។**

រូបរាងកាយរបស់សត្វទាំងឡាយតែងចាស់ជរាគ្រាំគ្រា ចំណែកឯនាមនិងគោត្រ មិនដែលចាស់ជរាឡើយ ។



**ភិក្ខុវិនយធរោ មហាឃិន-នៀន**

មានដើមកំណើតនៅ

*ភូមិខាងជើង ឃុំទួលព្រហ្ម ស្រុកមោងឫស្សី ខេត្តបាត់ដំបង*

**សៀវភៅមង្គលត្ថទីបនីប្រែ** ទាំង៤ភាគនេះ ខ្ញុំអ្នកប្រែ សូមបញ្ជាក់ថា កាលធ្វើជាលើកដំបូងនេះ គឺប្រៀបឧបមាដូចជាការទ្រួសត្រាយកាប់ឆ្ការផ្លូវទុកតែប៉ុណ្ណោះឯង ពុំទាន់ចាត់ថា បានធ្វើល្អត្រឹមត្រូវមួយរយភាគរយនោះទេ ព្រោះខ្ញុំមានចំណេះចេះដឹងខាងផ្នែកអក្សរសាស្ត្រខ្មែរ-បាលីតិចតួចស្តួចស្តើងណាស់ ។

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ២** នេះ

សម្រាប់តម្កល់ទុកជា **សម្បត្តិសង្ឃ** ក្នុង

**បណ្ណាល័យ**

វត្ត-----------------------------------

ឃុំ-----------------------------------

ស្រុក---------------------------------

ខេត្ត---------------------------------

នៅថ្ងៃ___កើត____រោច ខែ_______________

ឆ្នាំ___________________ព.ស.២៥៣___

*និងសម្រាប់ឲ្យសមណសិស្សពុទ្ធិកវិទ្យាល័យ ខ្ចីយកទៅសិក្សារៀនសូត្យស្រាវជ្រាវ រួចហើយត្រូវយកមកតម្កល់ទុកក្នុងបណ្ណាល័យវិញ ព្រោះជាសម្បត្តិសង្ឃ មួយទៀតព្រោះសៀវភៅនេះមានចំនួនតិចតួចពេកណាស់ ។*

អ្នកចែក_[signature]___

អ្នកទទួល______________________________

**បោះពុម្ពជំនួយសមណសិស្សពុទ្ធិកមធ្យមសិក្សា**
**និងចែកផ្សាយជាធម្មទាន**

ចេញអំពី

**មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ និង ពុទ្ធិកសមាគមន៍សង្ឃ**
**នៅតាមវត្តនានា ប្រចាំសហរដ្ឋអាមេរិក**

* * *

*សូមសមណសិស្សដែលបានខ្ចីសៀវភៅនេះ ទៅសិក្សារៀនសូត្រគ្រប់ៗរូប មេត្តាជួយថែរក្សាសៀវភៅនេះឱ្យបានល្អ កុំឱ្យសរសេរ កុំឱ្យមានការរហែកដាច់ដាចខូចខាត...ហើយ ពេលសិក្សាចប់ សូមមេត្តាយកទៅតម្កល់ទុកក្នុងបណ្ណាល័យវត្តដែលបានខ្ចីមកនោះដូចដើមវិញ ដើម្បីឱ្យសមណសិស្សជំនាន់ក្រោយខ្ចីយកទៅសិក្សាបន្តទៅទៀត ព្រោះសៀវភៅនេះមានតិចតួចណាស់ ។*

*សូមអរគុណ*


*សៀវភៅ* **មង្គលត្ថទីបនីប្រែ** *ទាំង ៤ ភាគនេះ បានបោះពុម្ពផ្សាយជាធម្មទាន លើកទី១ នៅថ្ងៃសៅរ៍ ១៥ កើត ខែវិសាខ ឆ្នាំកុរ សប្តស័ក ព.ស.២៥៣៨ ត្រូវនឹងថ្ងៃ ១៣ ខែឧសភា ១៩៩៥*

# ធម្មទានឈ្មោះអស់ទានទាំងពួង

~~~~~

បើអស់លោក លោកស្រី ឧបាសក ឧបាសិកា ដែលជាពុទ្ធសាសនិកជនមានបំណងចង់យកសៀវភៅនេះទៅចម្លងបោះពុម្ពចែកផ្សាយជាធម្មទាន សូមមេត្តាអញ្ជើញទាក់ទងនឹងខ្ញុំ (**ភិក្ខុវិនយធរោ មហាឃិន-នៀន**) ឬទាក់ទងនឹង **មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ** ហើយសូមបញ្ជាក់អំពីគោលបំណងអស់លោក ឱ្យបានច្បាស់លាស់ផង តាមអាស័យដ្ឋាន ដូចមានខាងក្រោមនេះស្រាប់ ។

~~~~~


**វត្តខេមរពុទ្ធិការាម**

*2100 W. Willow St.*
*Long Beach, CA 90810*
*U. S. A.*

ឬ

**មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ**

**វត្តត្រៃរតនារាម**

*21 Quigley Ave.*
*N. Chelmsford, MA 01863*
*U. S. A.*

# មាតិការឿង

----


*ឈ្មោះធម៌* | *ទំព័រ*

**១-អារម្ភកថារបស់អ្នកផ្ទុបនិងរៀបរៀង** ក

**២-(ពណ៌នាអំពីសេចក្ដីនៃគាថាទី ៣)**

*ពណ៌នាអំពីវិន័យ* ១

*ពណ៌នាអំពីវាចាជាសុភាសិត* ១៤៧

**៣-ពណ៌នាអំពីសេចក្ដីនៃគាថាទី ៤** ១៩៨

*ពណ៌នាអំពីការទំនុកបំរុងមាតាបិតា* ១៩៩

*ពណ៌នាអំពីការសង្គ្រោះបុត្រនិងភរិយា* ៣៥៧

*ពណ៌នាអំពីការងារដែលមិនច្របូកច្របល់* ៣៩១

# អារម្ភកថា

---

សៀវភៅ **មង្គលត្ថទីបនីប្រែ ភាគទី ២** នេះ គឺ ខ្ញុំ ភិក្ខុ **ទិនយធរោ មហាយិន - នឿន** បំរុងនឹងផ្តួចផ្តើមប្រែ រៀបរៀង មកជាភាសាខ្មែរយើង ជាយូរយារណាស់មកហើយ គឺតាំងពីពេលដែលខ្ញុំ កំពុងនៅសិក្សាមកម្ល៉េះ (ព. ស. ២៥២៤ គ. ស. ១៩៨១ ) តែឱកាសពុំបានហុចឱ្យ ព្រោះជាប់រវល់ខ្លាំងពេក ក្នុងការសិក្សាភាសាបាលី ឱ្យបានរីកចំរើនឡើងជាបន្ថែមតទៅទៀតផង និងក្នុងពេលនោះ នឹងរកឧបករណ៍ក្បួនច្បាប់ដែលជាភាសាខ្មែរសម្រាប់ជំនួយ ក៏គ្មានផងដែរ ។ គម្រោងការនេះ ខ្ញុំក៏ពុំបានបោះបង់ចោលដែរ ទោះបីជាខ្ញុំបានរសាត់អណ្តែតឆ្ងាយសែនឆ្ងាយ អំពីមាតុភូមិជាទីស្នេហា ហើយបានទៅរស់នៅឯបរទេស ជាប្រទេសដែលមិនកាន់ព្រះពុទ្ធសាសនា មានវប្បធម៌ ទំនៀមទំលាប់ ខុសប្លែកផ្សេងពីប្រទេសយើងក៏ដោយ ក៏គម្រោងការនេះនៅតែដក់ជាប់ក្នុងចិត្តខ្ញុំជានិច្ច ។

នៅក្នុងថ្ងៃពុធ ១១ រោច ខែពិសាខ ឆ្នាំវក ចត្វាស័ក

ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៧ ខែឧសភា ១៩៩២ ( ឆ្នាំដែលក្រុមអង្គការសហប្រជាជាតិ ចូលមកជួយរៀបចំធ្វើការបោះឆ្នោតនៅប្រទេសកម្ពុជា ) ខ្ញុំក៏បានវិលត្រឡប់ចូលមកទស្សនាមាតុភូមិរបស់ខ្ញុំផងដែរ ហើយបានចូលទៅពិនិត្យមើលការសិក្សាព្រះបរិយត្តិធម៌ ទាំងផ្នែកបាលី ទាំងផ្នែកព្រះធម្មវិន័យ ដែលព្រះសង្ឃកំពុងតែសិក្សានៅតាមវត្តនានា ដូចជាវត្តមហាមន្ត្រី វត្តលង្កា វត្តនិរោធរង្សីជាដើម ដោយមាន **សម្តេចព្រះមង្គលទេពាចារ្យ ( អ៊ុំ - ស៊ុំ )** អគ្គាធិការពុទ្ធិកសិក្សាបាននាំដំណើរជូនទៅផងដែរ ។

ពេលនោះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុត ដោយបានឃើញនូវព្រះសង្ឃអង្គសាមណេរ ខិតខំយកព្រះទ័យទុកដាក់ ក្នុងការសិក្សាព្រះបរិយត្តិធម៌ គឺបានឮព្រះភិក្ខុសង្ឃសាមណេរអង្គខ្លះកំពុងទន្ទេញបាលីវេយ្យាករណ៍ អង្គខ្លះទន្ទេញប្រជុំកងធម៌ អង្គខ្លះហាត់ប្រែធម្មបទ លោកគ្រូអាចារ្យខ្លះកំពុងបង្ហាត់ប្រែលោតប្រយោគ តាមបែបពីបូរាណ... គំហើញ និងការឮសូរស័ព្ទព្រះធម៌ដ៏ពីរោះត្រចៀកនេះ រឹតតែធ្វើឱ្យខ្ញុំរើប

ចិត្តឥតឧបមា ព្រោះនឹកសង្ឃឹម ថា ព្រះពុទ្ធសាសនា ដែលបាន
វិនាសសាបសូន្យ ស្ទើរតែរលត់អស់ ដោយសារភ្លើងសង្គ្រាម
ជាងពីរទសវត្សរ៍ មកហើយនោះ នឹងបានរីកចំរើនឡើងវិញ
ដោយពិត ហើយបានជំរុញខ្ញុំ ឱ្យរឹតតែមានសទ្ធាជ្រះថ្លាឡើង
ជាភិយ្យោភាព ...។ មួយទៀតសោត ធ្វើឲ្យខ្ញុំនឹកគិត ថា តើ
នឹងរកពិធីជួយ ដល់សមណសិស្សបែបណា? ខ្ញុំយល់ឃើញ
ថា សមណសិស្សដែលកំពុងសិក្សាពុទ្ធិកបឋមសិក្សា (ពេល
នោះ) ដូចជាពុំមានបញ្ហាឡើយ ព្រោះមានគ្រូ និងក្បួនច្បាប់
សម្រាប់ជួយច្រើន តែចំណែកតទៅឆ្នាំក្រោយ ៗ ទៀត នឹង
មានសមណសិស្សពុទ្ធិកមធ្យមសិក្សា ដោយពិត ឯគ្រូ និងក្បួន
ច្បាប់ ខ្ញុំយល់ឃើញ ថា ដូចជាមានបញ្ហាខ្វះខាតខ្លះ ៗ ។

ហេតុនេះហើយ ខ្ញុំមានគំនិតគិត ថា នឹងរកសៀវភៅ
**មង្គលត្ថទីបនី** ដែលនៅជាភាសាបាលីទាំង ៤ ភាគ មកបកប្រែ
ជាភាសាសម្រាយខ្មែរយើង ដើម្បីជាជំនួយ ដល់សមណសិស្ស
ពុទ្ធិកមធ្យមសិក្សា ដែលនឹងសិក្សានៅអនាគតកាល ហើយបាន
ដើរស្រាវជ្រាវរកសៀវភៅទាំងនោះ តែរកពុំបានឡើយ សូម្បី

តែ សម្តេចព្រះមង្គលទេពាចារ្យ ( អ៊ុំ - ស៊ុំ ) ក៏ព្រះអង្គពុំទាន់មានដែរ ព្រោះរោងពុម្ពជប៉ុនពុំទាន់បានបោះពុម្ពជាជំនួយ ។

ក្រោយមក នៅថ្ងៃអាទិត្យ ១១ កើត ខែស្រាពណ៍ ឆ្នាំវក ចត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ៩ ខែសីហា ឆ្នាំ ១៩៩២ ខ្ញុំទៅលេងផ្ទះ លោក **អ៊ុក-ម៉ៅ** ហើយបានឃើញសៀវភៅមួយក្បាល សៀតជាប់នៅក្រោមដំបូលខ្ទម ដ៏តូចមួយទើបបានឲ្យក្មេងទាញយកមកមើល ស្រាប់តែចំលើសៀវភៅ **មង្គលត្ថទីបនី ភាគទី ២** ដែលជាភាសាបាលីនេះតែម្តង ខ្ញុំមានសេចក្តីត្រេកអរជាទីបំផុត ហើយបានសុំខ្ចីលោក អ៊ុក-ម៉ៅ ដើម្បីយកមកបកប្រែជាភាសាសម្រាយខ្មែរយើង ។ លោក អ៊ុក-ម៉ៅ ក៏បានប្រគេនសៀវភៅនេះ មកដល់ខ្ញុំ ដោយទឹកចិត្តជ្រះថ្លាជាទីបំផុត ។

នៅថ្ងៃអង្គារ ១៣ កើត ខែ ឆ្នាំ ដែល ខ្ញុំក៏បានធ្វើដំណើរវិលត្រឡប់ទៅ **វត្តខេមរពុទ្ធិការាម** សហរដ្ឋអាមេរិកវិញ ហើយបានប្រញាប់ប្រញាល់យកសៀវភៅនេះ មកបកប្រែមុនគេបង្អស់ ព្រោះថា សៀវភៅមង្គលត្ថទីបនី ភាគទី ១ ទី ៣

និងទី ៤ ខ្ញុំរកពុំទាន់បាននៅឡើយ ហើយបានចាប់ផ្តើមបកប្រែ *នៅថ្ងៃសៅរ៍ ២ កើត ខែភទ្របទ ឆ្នាំវក ចត្វាស័ក ព.ស. ២៥៣៥ ត្រូវនឹងថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៩២* ហើយបានប្រែចប់សព្វគ្រប់ *នៅថ្ងៃសៅរ៍ ២ រោច ខែបុស្ស ឆ្នាំវក បញ្ចស័ក ព.ស. ២៥៣៦ ត្រូវនឹងថ្ងៃទី ៩ ខែមករា ឆ្នាំ ១៩៩៣ ។*

លុះប្រែចប់ហើយ ខ្ញុំក៏បានផ្ញើរសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេនព្រះតេជៈគុណព្រះ **ធម្មលិខិត លាស់-ឡាយ ឧត្តសន្តិកុសល ក្រុងភ្នំពេញ** ដើម្បីត្រួតពិនិត្យឱ្យបានត្រឹមត្រូវ ព្រះអង្គក៏បានជួយអនុគ្រោះ រហូតដល់បានសម្រេចជាស្ថាពរ ។

ក្នុងការបកប្រែពីភាសាមួយទៅភាសាមួយទៀតនេះ គឺពិតជាមានការពិបាកណាស់ ហើយពិតជាមានការភ្លាំងភ្លាត់ខុស ឃ្លាតចាកអំពីអត្ថន័យធម៌អាចខ្លះ ។ ដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ ជាពុំខានឡើយ ។ ក្នុងការប្រែនេះសោត គោលគំនិតរបស់ខ្ញុំ គឺប្រែរក្សាទុកភាសាបាលីភាគច្រើន មានន័យ ថា គឺមិនចង់ឱ្យឃ្លាតចាកអំពីភាសាបាលីច្រើន

ឡើយ ដើម្បីឱ្យអ្នកសិក្សាឆាប់រកស័ព្ទប្រែបានងាយ តែភាសាខ្មែរពិតជានឹងពិបាកស្តាប់បន្តិច ។

ហេតុដូច្នេះ ខ្ញុំអ្នកប្រែ សូមមេត្តាខន្តីអភ័យទោសអំពីសំណាក់ព្រះតេជៈគុណ និងអស់លោកដែលឆ្លៀវឆ្លាត ក្នុងអក្សរសាស្ត្របាលីក្តី ខ្មែរក្តី បើមានការខុសភ្លាំងភ្លាត់ត្រង់កន្លែងណានិមួយនោះ ហើយសូមមេត្តាជួយឱ្យយោបល់ និងជួយកែតម្រូវ ដើម្បីធ្វើសៀវភៅនេះ ឱ្យរឹតតែបានល្អប្រសើរឡើង ។ សង្ឃឹម ថា ព្រះតេជៈគុណ អស់លោក នឹងផ្តល់យោបល់ដ៏ល្អ ហើយអភ័យទោសដល់ខ្ញុំជាពុំខាន ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សា ឱ្យបានឆាប់ចេះឆាប់យល់ ឆ្លៀវឆ្លាតក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌នោះទៅផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនឡើងរៀងតទៅ ។

មួយទៀត សូមឱ្យការសិក្សា នូវព្រះធម្មវិន័យ របស់សមណសិស្សគ្រប់ ៗ រូប និងពុទ្ធបរិស័ទទាំងអស់ បានសម្រេច

សមដូចមនោរថ ដែលបានប្រាថ្នាហើយ កុំបីអាក់ខានឡើយ ។

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលកើតអំពីធម្មទាននេះ ជូនចំពោះបិតាឈ្មោះ **យិន - យឿម** មាតាឈ្មោះ **ហិង - អម** ព្រមទាំងជីដូនជីតា ញាតិកាទាំង ៧ សន្តាន និងសព្វសត្វទាំងអស់ ដែលបានចែកឋានទៅហើយនោះ សូមឱ្យវិញ្ញាណក្ខន្ធរបស់លោកអ្នកទាំងនោះ បានទទួលអនុមោទនា នូវបុណ្យកុសលដែលខ្ញុំបានឧទ្ទិសផ្សាយទៅឱ្យនេះ ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស ទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

**ចន្ទខេមរពុទ្ធិការាម**

2100 W. Willow Street

Long Beach, CA 90810

U. S. A.

*ថ្ងៃសៅរ៍ ១៥កើត ខែមាឃ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៦*

*ត្រូវនឹងថ្ងៃទី ៦ ខែកុម្ភៈ ១៩៩៣*

# សេចក្ដីថ្លែងអំណរព្រះគុណនិងអរគុណ

១ ◎ ១

ខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណដ៏ជ្រាលជ្រៅ

-ចំពោះ **សម្ដេចព្រះមង្គលទេពាចារ្យ អ៊ុំ - ស៊ុំ** អគ្គាធិការនៃពុទ្ធិកសិក្សា វត្តមហាមន្ត្រី ទីក្រុងភ្នំពេញព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គបានផ្ដល់ព្រះយោបល់ដ៏ល្អ ៗ និងបានផ្ដល់នូវក្បួនច្បាប់ផ្សេង ៗ មានសៀវភៅមង្គលត្ថទីបនីនេះ និងបទានុក្រមធម្មបទជាដើម តាមសេចក្ដីត្រូវការ ។

-ចំពោះព្រះតេជះគុណ **ព្រះធម្មលិខិត លាស់- ឡាយ** វត្តសន្សំកុសល ទីក្រុងភ្នំពេញ ដែលបានចំណាយពេលវេលា ជួយត្រួតពិនិត្យ កែសម្រួលពាក្យពេចន៍ និងអត្ថន័យផ្សេង ៗ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អប្រសើរឡើង តាំងអំពីដើម រហូតដល់ចប់សព្វគ្រប់ ។

-ចំពោះ ព្រះតេជះគុណ **គង់ - ឈាន** ចៅអធិការ **វត្តខ្មែរ ខេមរពុទ្ធិការាម** ទីក្រុងឡុងបិច សហរដ្ឋអាមេរិក

ដែលបានជួយផ្តល់យោបល់និងគំនិតផ្សេង ៗ ។

-ចំពោះ ភិក្ខុ **ប៊ូ - ហួយ** ដែលបានឱ្យខ្ចីសៀវភៅ មង្គលត្ថទីបនីភាគទី ៣ និងភាគទី ៤ ដើម្បីយកមកប្រែ ។

-ចំពោះ ភិក្ខុ **អ៊ុខ - អ៊ិន** វត្តព្រោះស្ទ ក្រុងព្រោះស្ទ សហរដ្ឋអាមេរិក, ភិក្ខុ **ប្រាជ្ញ - សារ៉ាន** វត្តឧណ្ណាលោម កុដិលេខ ៤២ ទីក្រុងភ្នំពេញ និងលោកបណ្ឌិតកវីនិពន្ធ **ហៀម - គឿន** ដែលបានជួយយកសំណៅមង្គលត្ថទីបនីនេះ ទៅប្រគេន **ព្រះធម្មលិខិត លាស់ - ឡាយ** ដើម្បីត្រួតពិនិត្យ ឱ្យបានល្អត្រឹមត្រូវឡើង ។

-ចំពោះ ភិក្ខុ **មហា សោម - សុតា** វត្តធម្មចក្ការាម ស៊ីអាថុល វ៉ាស៊ីងតោនស្តេត និង ព្រះតេជះគុណ **ឯម-គឿខ អតិបញ្ញោ មេគណ ខេត្តកំពត** ដែលបានជួយត្រួតពិនិត្យនូវ អក្ខរាវិរុទ្ធ និងពាក្យពេចន៍ ដើម្បីធ្វើសៀវភៅនេះ ឱ្យបានល្អ ល្អប្រសើរឡើង ។

-ចំពោះ ភិក្ខុ **ព្រះមហា សម - សក្តិ** សុវណ្ណរតនោ

ដែលបានជួយយកសៀវភៅមង្គលត្ថទីបនីនេះ ទៅចូលរោងពុម្ព ដើម្បីបោះពុម្ពឱ្យបានសម្រេច តាមសេចក្តីត្រូវការ ។

-ចំពោះ លោក **យឹម- ជ័យ** និងលោក **ឃុំ - ឆយ** ដែលបានជួយកែសម្រួល និងជួយដំឡើងគ្រឿងកុំព្យូទ័រដោយយកចិត្តទុកដាក់ជាទីបំផុត ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរព្រះគុណនិងអរគុណជាទីបំផុត ចំពោះព្រះតេជះគុណ ព្រះថេរានុថេរៈ អស់លោក លោកស្រី ព្រមទាំងញាតិញោមជាពុទ្ធបរិស័ទទាំងអស់ ដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ ឱ្យបានសម្រេចជាស្ថាពរ ។

សូមប្រគេនមគ្គផល ដែលកើតពីធម្មទានានិសង្សនេះ ដល់ព្រះតេជះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមឱ្យព្រះអង្គមានព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាទីពឹង របស់ពុទ្ធសាសនិកជនទាំងឡាយ តរៀងទៅហោង ។

សូមឱ្យញាតិញោមទាំងឡាយ បានទទួលនូវបុណ្យកុសលនេះ ស្មើ ៗគ្នា និងសូមឱ្យបានជួបប្រទះតែនឹងសេចក្តី

សុខ-ចម្រើនគ្រប់ប្រការ កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ជាទីកំសត់ ឆាប់បាន ទទួលនូវសុខសន្តិភាព ដែលប្រកបដោយព្រះធម៌ នៃអង្គព្រះ សម្មាសម្ពុទ្ធបរមគ្រូ ដោយពិត, សូមឱ្យរាជរដ្ឋាភិបាលគ្រប់ជាន់ ថ្នាក់ និងគ្រប់គណៈបក្សទាំងអស់ ដឹកនាំប្រទេសជាតិ ព្រះ រាជាណាចក្រកម្ពុជា ប្រកបដោយសម្មាទិដ្ឋិ ដើម្បីជោគជ័យ សេចក្ដីសុខ-ចម្រើន និងសុភមង្គល ជូនដល់ប្រជានុរាស្ត្រ ទូទាំងប្រទេស ដែលកំពុងក្រីក្រលំបាក ស្រេកឃ្លាន នូវសេចក្ដី សុខសន្តិភាព និងស្ងប់ខ្ពើមបំផុតនូវសង្គ្រាម សព្វថ្ងៃនេះ ។

សូមឧទ្ទិសកុសលនេះផងដែរ ដល់ពួកបញ្ញវន្ត អ្នក ស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋ អ្នកស្លូតត្រង់គ្រប់ជាន់ គ្រប់ស្រទាប់ ដែលបានបូជាជីវិតដើម្បីមាតុភូមិ ដោយចិត្ត ស្មោះស្ម័គ្រ គ្រប់កាលៈទេសៈ សូមបានទទួលកុសលដែលកើត អំពីធម្មទាននេះ ហើយសូមឱ្យវិញ្ញាណក្ខន្ធ នៃអ្នកបានសោយ សុខដ៏ប្រសើរ ក្នុងសុគតិភព កុំបីខានឡើយ ។

๏ ๏ ๏

សៀវភៅ "មង្គលត្ថទីបនីប្រែ" ទាំង៤ភាគ
នេះ ខ្ញុំបានបកប្រែចេញពីភាសាបាលីមកជា
ខេមរភាសា នៅថ្ងៃសៅរ៍ ២កើត ខែកត្តិក
ឆ្នាំវក ចត្វាស័ក ព.ស.២៥៣៥ ត្រូវនឹងថ្ងៃ
ទី ២៩ វិច្ឆិកា ឆ្នាំ ១៩៩២ ហើយបាន
ប្រែចប់សព្វគ្រប់ នៅថ្ងៃសុក្រ ១៥កើត
ខែមាឃ ឆ្នាំច ឆស័ក ព.ស.២៥៣៧ ត្រូវ
នឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៤ អស់រយៈ
ពេល ១ ឆ្នាំ ៥ខែ ២៨ ថ្ងៃ ។

---

ដោយអំណាចផលានិសង្សនៃកម្មបាន
ដែលកើតឡើងពីការព្យាយាមប្រឹងប្រែង
ប្រែនូវមង្គលត្ថទីបនីនេះ ខ្ញុំសូមប្រាថ្នាបាន
អស់ទៅនូវអាសវក្កិលេស ក្នុងអនាគតជាតិ
កុំបីខានឡើយ ។

---

# មង្គលត្ថទីបនី ប្រែ

## *ភាគទី២*

### ពណ៌នាអំពីវិន័យ

(១) ឈ្មោះថាវិន័យ មាន ២ យ៉ាង គឺ អនាគារិយវិន័យ ១, អគារិយវិន័យ ១ ។

**( អនាគារិយវិន័យ )**

បណ្ដាវិន័យទាំង ២ យ៉ាងនោះ ការមិនត្រូវអាបត្តិទាំង ៧ កង ឈ្មោះថា អនាគារិយវិន័យ ( វិន័យរបស់បព្វជិត )

អនាគារិយវិន័យនោះ ឈ្មោះថាគឺបព្វជិត សិក្សាល្អហើយ ព្រោះមិនត្រូវទោសគ្រឿងសៅហ្មង និងព្រោះធ្វើខ្លួនឲ្យតាំងនៅក្នុងគុណ គឺមារយាទ ឈ្មោះថាជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខ ក្នុងលោកទាំង ២ ។ ក៏នៅក្នុងវិន័យកថានុ៎ះ ពាក្យថា " ការមិនត្រូវអាបត្តិទាំង ៧ កង ឈ្មោះថា អនាគារិយវិន័យ " ខ្ញុំពោលហើយដោយអំណាចអនាគារិយវិន័យយ៉ាងឧក្រិដ្ឋ ។ ព្រោះហេតុនោះ បណ្ដាកងនៃអាបត្តិទាំង ៧ កងនៃអាបត្តិណា ៗ ដែលភិក្ខុរូបណាបានក្លែងឱ្យត្រូវហើយ, កងនៃអាបត្តិនោះ ៗ គឺភិក្ខុនោះត្រូវតែធ្វើតប ដោយវុដ្ឋានវិធី ( បរិវាសកម្ម ) និងទេសនាវិធី (សំដែងអាបត្តិ) តែម្ដង ៗ ព្រោះថា កងនៃអាបត្តិសូម្បីភិក្ខុត្រូវហើយ គឺភិក្ខុនៅបរិវាសកម្មហើយក្ដី សំដែងហើយក្ដី ទើបឈ្មោះថាមិនធ្វើនូវសេចក្ដីអន្តរាយ ។

## ( អន្តរាយិកធម៌ )

ហេតុនោះ នៅក្នុងអដ្ឋកថាអរិដ្ឋសិក្ខាបទ លោកសំដែងថា " ធម៌ទាំងឡាយណា ធ្វើសេចក្ដីអន្តរាយដល់ផ្លូវសួគ៌និងព្រះនិព្វាន ហេតុនោះធម៌ទាំងឡាយនោះ ឈ្មោះថា អន្តរាយិកធម៌ (ធម៌ធ្វើសេចក្ដីអន្តរាយ)ៗ អន្តរាយិធម៌ទាំងឡាយនោះ មាន ៥ យ៉ាងគឺ កម្ម, កិលេស, វិបាក, ឧបវាទៈ និងអាណាវីតិក្កមៈ ៗ ក្នុងអន្តរាយិកធម៌ទាំង ៥ យ៉ាងនោះ ធម៌ដែលឲ្យផលក្នុងភពជាលំដាប់ ៥ យ៉ាង ឈ្មោះថា អន្តរាយិកធម៌ គឺកម្ម ៗ កម្មរបស់អ្នកប្រទូសរ៉ាយដល់នាងភិក្ខុនី ក៏ដូចគ្នាដែរ ៗ ប៉ុន្តែភិក្ខុនីទូសកកម្មនោះ ធ្វើសេចក្ដីអន្តរាយដល់ព្រះនិព្វានតែម៉្យាងប៉ុណ្ណោះ មិនធ្វើសេចក្ដីអន្តរាយដល់ផ្លូវសួគ៌ឡើយ ៗ ធម៌គឺមិច្ឆាទិដ្ឋិដ៏តឹងតែងឈ្មោះថា អន្តរាយិកធម៌គឺកិលេស ៗ ធម៌គឺបដិសន្ធិរបស់ពួកបណ្ឌកៈ សត្វតិរច្ឆាន និងឧភតោព្យញ្ជនក ឈ្មោះថា អន្តរាយិកធម៌ គឺវិបាក ៗ ចេតនាធម៌ជាហេតុតិះដៀលព្រះអរិយៈ ឈ្មោះថាអន្តរាយិកធម៌គឺឧបវាទៈ ក៏ឧបវាទន្តរាយិកធម៌ទាំងនោះ តែងធ្វើសេចក្ដីអន្តរាយ របួតវេលាដែលអ្នកតិះដៀលទាំងឡាយ មិនទាន់បានញុំាងព្រះអរិយៈទាំងឡាយឲ្យអត់ទោសឲ្យប៉ុណ្ណោះ បន្ទាប់ពីបានញុំាងព្រះអរិយៈទាំងឡាយ ឲ្យអត់ទោសហើយនោះ ទើបមិនធ្វើសេចក្ដីអន្តរាយ ៗ អាបត្តិទាំងឡាយដែលភិក្ខុបានក្លែងឲ្យត្រូវហើយ ឈ្មោះថាអន្តរាយិកធម៌ គឺអាណាវីតិក្កមៈ ៗ

សូម្បីអាបត្តិទាំងអស់នោះ ធ្វើសេចក្តីអន្តរាយ រហូតវេលាដែលភិក្ខុត្រូវអាបត្តិហើយនៅតែប្តេជ្ញាខ្លួនថាជាភិក្ខុក្តី មិនព្រមនៅបរិវាសកម្មក្តី មិនសំដែងចេញក្តីប៉ុណ្ណោះ បន្ទាប់អំពីវេលាដែលអាបត្តិ គឺភិក្ខុធ្វើតបដោយបច្ច័យនោះ ក៏គ្មានធ្វើសេចក្តីអន្តរាយបានឡើយ ។

(២) ន័យដែលមកក្នុងអដ្ឋកថាអរិដ្ឋសិក្ខាបទនោះ ថា " សភាវៈណាដល់ គឺមក ក្នុងចន្លោះ គឺចំកណ្តាល នៃសន្តានរបស់សត្វ ដោយអំណាចរារាំងដល់សម្បត្តិនោះ ៗ ហេតុនោះ សភាវៈនោះ ឈ្មោះថាអន្តរាយ គឺសេចក្តីវិនាសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នជាដើម ៗ ធម៌ដែលមានប្រក្រតីធ្វើសេចក្តីអន្តរាយនោះ ឈ្មោះថា អន្តរាយិកធម៌ ៗ ចេតនាធម៌ដែលឲ្យផលក្នុងភពជាលំដាប់ជាសភាព ឈ្មោះថា អនន្តរិយ-ធម៌ ៗ អន្តរាយិកធម៌ គឺកម្ម ឈ្មោះថា កម្មន្តរាយិកធម៌ ៗ ពាក្យថា "ភិក្ខុនីទូសកកម្ម មិនធ្វើសេចក្តីអន្តរាយដល់ផ្លូវសួគ៌ " ព្រះអដ្ឋកថាចារ្យសំដែងហើយ ព្រោះមិនមានលក្ខណៈនៃមិច្ឆាចារ, ដោយហេតុថា ភាវៈនៃនាងភិក្ខុនីជាអ្នកគឺធម៌រក្សាមិនមាន ៗ ក៏ពាក្យនេះ លោកសំដែងទុកហើយ ដោយអំណាចនាងភិក្ខុនីដែលតាំងនៅជាប្រក្រតី ៗ តែភិក្ខុនី-ទូសកកម្ម ដែលបុគ្គលប្រព្រឹត្ត ចំពោះនាងភិក្ខុនីជាព្រះអរិយៈ ជាកម្មឲ្យប្រព្រឹត្តទៅក្នុងអបាយដោយពិត ៗ ក៏ក្នុងសេចក្តីនេះ មាននន្ទមាណពជាឧទាហរណ៍ ៗ ម្យ៉ាងទៀត ព្រះអដ្ឋកថាចារ្យ មិនពោលភាវៈនៃភិក្ខុនី-

ទុសកកម្ម ជាកម្មធ្វើសេចក្ដីអន្តរាយដល់ផ្លូវសួគ៌ ក៏ដោយអំណាចនៃជន ទាំងពីរនាក់មានឆន្ទៈរួមគ្នា, តែលោកពោល ភាវៈនៃភិក្ខុនីទូសកកម្ម ជាកម្មធ្វើសេចក្ដីអន្តរាយ ដល់ព្រះនិព្វាន ក៏ព្រោះការប្រទូសរ៉ាយ ដល់សេចក្ដីប្រតិបត្តិ ។ អាចារ្យពួកខ្លះពោលថា "ក៏សូម្បីភាវៈនៃភិក្ខុនី-ទូសកកម្ម ជាកម្មធ្វើអន្តរាយដល់ផ្លូវសួគ៌ ក្នុងការប្រព្រឹត្តិរំលោភ អ្នកណា ក៏មិនអាចហាមឃាត់បានឡើយ" ។ អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ និងនត្ថិកទិដ្ឋិ ដែលដល់ភាវៈជាទិដ្ឋិដ៏តឹងរឹង ឈ្មោះថា និយតមិច្ឆាទិដ្ឋិធម៌ ។ ចេតនាធម៌ញុំាងបដិសន្ធិចិត្តឲ្យកើតឡើង ឈ្មោះថា បដិសន្ធិធម៌ ។ ក៏សព្វមានបណ្ឌកៈសព្វជាដើម ក្នុងពាក្យថា "**បណ្ឌកតិរច្ឆានគតឧភតោ-ព្យញ្ជនានំ**" នុ៎ះ គ្រាន់តែជាឧទាហរណ៍ ព្រោះបដិសន្ធិរបស់អហេតុក-សត្វ សូម្បីទាំងអស់ ជាអន្តរាយិកធម៌គឺវិបាក ។ ចេតនាជាហេតុតិះដៀលព្រះអរិយៈទាំងឡាយ ឈ្មោះថា អរិយុបវាទៈ ។ ២ បទ ថា "**តតោ បរំ**" គឺ បន្ទាប់អំពីញុំាងព្រះអរិយៈឲ្យអត់ទោសឲ្យ ។ ២ បទ ថា "**អាបន្នា អាបត្តិយោ**" បានដល់ អាបត្តិទាំង ៧ កង ដែលភិក្ខុបានក្លែងល្មើសហើយ ។ ក៏ទោសដែលភិក្ខុក្លែងល្មើសហើយ ដោយហោចទៅ សូម្បីទុក្កដនិងទុព្ភាសិត តែងធ្វើសេចក្ដីអន្តរាយដល់ផ្លូវសួគ៌ និងមគ្គផលបាន ។ អាណាវីតិក្កមន្តរាយិកធម៌ ធ្វើសេចក្ដីអន្តរាយ រហូតវេលាដែលភិក្ខុត្រូវអាបត្តិបារាជិកហើយ នៅតែប្ដេជ្ញាខ្លួនថាជាភិក្ខុ ត្រូវ

គរុកាបត្តិក្រៅនោះហើយ ក៏មិនព្រមនៅបរិវាសកម្ម ត្រូវលហុកាបត្តិហើយ ក៏មិនទាន់សំដែងចេញប៉ុណ្ណោះ, បន្ទាប់ពីវេលាដែលអាបត្តិ គឺភិក្ខុធ្វើតបហើយ ដោយបច្ច័យនោះ មិនធ្វើសេចក្ដីអន្តរាយឡើយ "។

(៣) ដីកាសមថក្ខន្ធកៈ ក្នុងគម្ពីរចុល្លវគ្គ ថា " ក៏អាបត្តាធិករណ៍ណា ជាអកុសល, អាបត្តាធិករណ៍នោះឯង គឺភិក្ខុអ្នកត្រូវអាបត្តិសំដែងហើយក្ដី នៅបរិវាសកម្មហើយក្ដី មិនធ្វើសេចក្ដីអន្តរាយបានឡើយ ។ ដូចជា កម្មគឺចេតនាជាហេតុតិះដៀលព្រះអរិយៈ សូម្បីជាអកុសល រមែងឈ្មោះថា ជាអហោសិកម្ម ដែលដល់នូវភាវៈជាកម្មរកវិបាកគ្មានជាធម្មតា ព្រោះភាវៈនៃកម្មនោះមានប្រយោគសម្បត្តិ គឺការសំដែងទោស ដែលមាននៅ ហើយញុំាងព្រះអរិយៈឲ្យអត់ទោស ហាមបានហើយ យ៉ាងណាមិញ, សូម្បីអាបត្តាធិករណ៍នេះ ក៏យ៉ាងនោះដែរ គឺភិក្ខុអ្នកត្រូវអាបត្តិសំដែងហើយក្ដី នៅបរិវាសកម្មហើយក្ដី ឈ្មោះថាមិនធ្វើសេចក្ដីអន្តរាយ ព្រោះអាបត្តាធិករណ៍នោះ ឈ្មោះថាជាអហោសិកម្ម ព្រោះជាកម្មដែលគ្មានវិបាកជាធម្មតា ព្រោះហេតុនៃកម្មនោះមានប្រយោគសម្បត្តិ គឺការសំដែងក្ដី ការនៅបរិវាសិកម្មក្ដីហាមទៅហើយ ។ ដោយហេតុនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ភាវៈនៃភិក្ខុអ្នកមានអាបត្តិប៉ុណ្ណោះត្រូវធ្លាក់ទៅអបាយ ថា " ម្នាលភិក្ខុទាំងឡាយ ! តថាគត ពោលនរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ សំរាប់ភិក្ខុអ្នកមានអាបត្តិ " ។

ក្នុងសេចក្ដីនោះ មានរឿងនេះ ( ជាឧទាហរណ៍ )

( រឿងឯរកបត្តនាគរាជ )

(៤) ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ, មានភិក្ខុកម្លោះ ១ អង្គ បំពេញសមណធម៌ក្នុងព្រៃ អស់រយៈវេលា ២ ម៉ឺនឆ្នាំ, ថ្ងៃមួយ បាន ឡើងជិះទូកទៅតាមទន្លេគង្គា បានចាប់ស្លឹករំពេទឹកត្រង់គុម្ពនៃរំពេទឹក, កាល ទូករសាត់ទៅដោយល្បឿនលឿន, ក៏មិនលែង (ដៃ)ចេញ ៗ ស្លឹក រំពេទឹក ក៏បានដាច់ទៅ ៗ ភិក្ខុនោះ គិត ថា "ទោសនុ៎ះ មានប្រមាណតិច តួច" ដូច្នេះហើយ មិនបានសំដែងអាបត្តិ វេលាជិតធ្វើមរណៈ ដូចជា ស្លឹករំពេទឹកមកជំពាក់ ត្រង់ក សូម្បីមានបំណងនឹងសំដែងអាបត្តិនោះ ក៏រកភិក្ខុដទៃ (សំដែងពុំបាន) ដែរ ហើយកើតសេចក្ដីក្ដៅក្រហាយ ថា "សីលរបស់អញ មិនបរិសុទ្ធឡើយ" ដូច្នេះហើយ លុះច្យុត (ពីអត្តភាព នោះ) បានទៅកើតជានាគរាជ មានអត្តភាពប៉ុនទូកកម្រោល ៗ នាគរាជនោះ បានឈ្មោះថា "ឯរកប័ត្ត" ៗ ឯរកបត្តនាគរាជនោះ គិត ថា "អញនឹងបានស្ដាប់ ការកើតឡើងនៃព្រះពុទ្ធ ដោយឧបាយនេះ ពិតប្រាកដ" ដូច្នេះ ហើយឲ្យធីតារបស់ខ្លួនរៀនច្រៀង ហើយធ្វើពពារ ដ៏ធំ (បណ្ដែតខ្លួន) លើផ្ទៃទឹកទន្លេគង្គា បានលើកធីតាដាក់លើពពារ នោះ ហើយឲ្យច្រៀង ក្នុងថ្ងៃឧបោសថ រាល់កន្លះខែ (ម្ដង) ៗ ធីតា នោះ រាំច្រៀងនៅលើពពារនុ៎ះ ៗ ប្រជាជនជម្ពូទ្វីបទូទៅ មានប្រាថ្នា

នឹងចាប់នាងនាគមាណវិកា ទើបច្រៀងតប តាមកម្លាំងបញ្ញារៀង ៗ ខ្លួន ៗ នាគរាជ បដិសេធ ចម្រៀងតបនោះ ៗ កាលនាងនាគមាណ-វិកានោះ ច្រៀងយ៉ាងនេះ រាល់កន្លះខែ (ម្តង), ចន្លោះនៃព្រះពុទ្ធមួយ ក៏កន្លងទៅហើយ ៗ កាលនោះ ព្រះសាស្តា ទ្រង់ឧបត្តិឡើងក្នុងលោក កាលទ្រង់ប្រមើលមើលសត្វលោក ក្នុងវេលាជិតភ្លឺថ្ងៃមួយ ទ្រង់ជ្រាបហេតុនោះហើយ ស្តេចយាងទៅគង់ក្រោមដើមច្រេស ១ ដើម ទៀបក្រុងពារាណសី ទ្រង់ទតព្រះនេត្រឃើញឧត្តរមាណព កំពុងតែដើរទៅដើម្បីច្រៀងតប ទើបត្រាស់ហៅថា " អ្នកចូរមក ខាងនេះសិន " ៗ មាណពនោះ បានចូលទៅរកព្រះសាស្តា ត្រូវព្រះសាស្តាត្រាស់សួរ ទើបក្រាបទូលចម្រៀងតប របស់ខ្លួន ៗ ព្រះសាស្តា ទ្រង់ត្រាស់ ថា " ម្នាលឧត្តរ ! នុ៎ះមិនមែនចម្រៀងតបទេ " ដូច្នេះហើយ ទ្រង់បង្រៀនឲ្យគេរៀនចម្រៀងតប ៗ គេកំពុងតែរៀនចម្រៀងតបនោះ ស្រាប់តែបានសំរេចព្រះសោតាបន្ន ហើយទើបបានធ្វើដំណើរទៅ ៗ ពេលនោះ នាងនាគមាណវិកា ច្រៀងដោយគាថា ២ បទ ថា ÷

(៥) " បុគ្គលជាធំលើអ្វីហ្ន៎ ឈ្មោះថា ព្រះរាជា ?, យ៉ាងណាហ្ន៎ ព្រះរាជា ឈ្មោះថា មានធូលីលើព្រះសិរៈ ?, យ៉ាងណាហ្ន៎ ឈ្មោះថា មានធូលីទៅប្រាសហើយ ?, យ៉ាងណាហៅថា បុគ្គលពាល ?, បុគ្គលពាល ត្រូវអ្វីនាំទៅ ?,

បណ្ឌិត រមែងនាំទុកបាន យ៉ាងណា ?, បុគ្គល
មានធម៌ជាគ្រឿងក្សេមចាកយោគៈ យ៉ាងណា ? ,
អ្នកត្រូវខ្ញុំសួរហើយ ចូរប្រាប់សេចក្ដីនោះ ដល់ខ្ញុំ " ។

បណ្ដាបទទាំងនោះ ពាក្យ ថា " កឹ សុ " មានសេចក្ដី ថា បុគ្គលជាអធិបតីនៃអ្វី ឈ្មោះថាព្រះរាជា ។ ពាក្យ ថា " កឹ សុ " មានសេចក្ដីថា យ៉ាងណាហ្ន៎ ព្រះរាជាឈ្មោះថាមានធូលីលើសិរសី ។ ពាក្យ ថា " កថិ សុ " មានសេចក្ដី ថា យ៉ាងណាហ្ន៎ ព្រះរាជាអង្គនោះ ឈ្មោះថាមានធូលីទៅប្រាសហើយ ។ ពាក្យ ថា " កថំ " មានសេចក្ដីថា បុគ្គលលោកហៅថា ពាល ដោយហេតុយ៉ាងណា ។ បទ ថា " វុយ្ហតិ " មានសេចក្ដីថា បុគ្គលពាល ត្រូវធម៌អ្វីដឹកនាំទៅ ។ បទ ថា " នុទតិ " មានសេចក្ដីថា បណ្ឌិតបន្ទោបង់នូវអ្វី ដោយធម៌អ្វី ។ បុគ្គលឈ្មោះថា មានធម៌ជាទីក្សេមចាកយោគៈ ព្រោះធម៌អ្វី ។ នាងនាគមាណវិកា ពោលសំដៅយកបុគ្គលដែលនៅចំពោះមុខ ថា " អក្ខាហិ " ។

លំដាប់នោះ ឧត្តរមាណពច្រៀងតប ដោយគាថា ២ បទ ថា ÷

(៦) " បុគ្គលជាអធិបតីនៃទ្វារទាំង ៦ ឈ្មោះថាព្រះរាជា , ព្រះរាជាដែលមានសេចក្ដីត្រេកត្រអាល ឈ្មោះថា មានធូលីលើសិរសី ,
អ្នកដែលគ្មានសេចក្ដីត្រេកត្រអាល ឈ្មោះថា មានធូលីទៅប្រាសហើយ , អ្នកត្រេកត្រអាល ឈ្មោះថា បុគ្គលពាល , បុគ្គលពាល

ត្រូវឱឃៈដឹកនាំទៅ, បណ្ឌិតបន្ទោបង់បាន ដោយសេចក្តីព្យាយាម, អ្នកដែលមិនប្រកបដោយយោគៈទាំងពួង ឈ្មោះថា មានធម៌ជាទីក្សេមចាកយោគៈ " ។

បណ្តាបទទាំងនោះ បទ ថា " **ឆទ្វារាធិបតី** " មានសេចក្តី ថា បុគ្គលជាអធិបតីនៃទ្វារទាំង ៦ ព្រោះទ្វារទាំងនោះ គឺអារម្មណ៍ទាំងឡាយមានរូបជាដើម គ្របសង្កត់មិនបាន ឈ្មោះថា ព្រះរាជា ។ បទ ថា " **រជមានោ** " មានសេចក្តីថា ព្រះរាជាដែលត្រេកត្រអាល ក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ឈ្មោះថា មានធូលីលើព្រះសិរសី ។ បទ ថា " **អរជំ** " បានសេចក្តីថា មិនត្រេកត្រអាល ក្នុងអារម្មណ៍ទាំងឡាយនោះឯង ។ បទថា " **រជំ** " ប្រែថា កាលត្រេកត្រអាល ។ បទ ថា " **ឱឃេន** " បានដល់ ឱឃៈ ៤ យ៉ាង មានកាមោឃៈជាដើម ។ ពីរបទថា " **យោគា នុទតិ** " មានសេចក្តី ថា បណ្ឌិតបន្ទោបង់ឱឃៈនោះបាន ដោយសេចក្តីព្យាយាមពោលគឺសម្មប្បធាន ។ បទ ថា " **សព្វយោគ-វិសំយុត្តោ** " បានដល់ មិនប្រកបដោយយោគៈទាំងពួង មានកាមយោគៈជាដើម ។

(៧) នាគរាជ គ្រាន់តែបានឮចម្រៀងគបនោះ ក៏មានចិត្តត្រេកអរថា " អញមិនដែលបានឮបទយ៉ាងនេះ អស់មួយពុទ្ធន្តរហើយ, ម្នាលអ្នកដ៏ចំរើន ! ព្រះពុទ្ធ ទ្រង់បានឧប្បត្តិឡើង ក្នុងលោកហើយហ្ន៎ ! " ដូច្នេះ

ហើយ ក៏ឡើងអំពីទឹក ទៅកាន់សំណាក់នៃព្រះសាស្តា មួយអន្លើដោយឧត្តរមាណព បានថ្វាយបង្គំព្រះសាស្តាហើយក៏ស្រែកយំ ក្រាបទូលភាវៈនៃខ្លួនអាស្រ័យកម្ម ត្រឹមតែធ្វើស្លឹករំទឹកឲ្យដាច់ ត្រូវបានទៅកើត ក្នុងកំណើតនៃសត្វតិរច្ឆាន ហើយក្រាបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន ! ទូលព្រះបង្គំ មិនបានភាពជាមនុស្ស មិនបានស្តាប់ព្រះធម៌ មិនបានឃើញព្រះពុទ្ធដូចជាព្រះអង្គ អស់១ពុទ្ធន្តរហើយ " ។ ព្រះសាស្តា ទ្រង់ត្រាស់ថា " មហារាជ ឈ្មោះថា ភាពជាមនុស្សជាដើម សត្វបានដោយកម្រពេកណាស់ " ដូច្នេះហើយ កាលទ្រង់សំដែង (ធម៌) ទ្រង់ត្រាស់នូវព្រះគាថានេះ ក្នុងពុទ្ធវគ្គ នៃធម្មបទ ថា ÷

(៨) "ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ,
ការរស់នៅ របស់សត្វទាំងឡាយ បានដោយកម្រ,
ការស្តាប់ធម៌ របស់សប្បុរស បានដោយកម្រ, ការកើត
ឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ " ។

បណ្តាបទទាំងនោះ បទ ថា " **កិច្ឆោ** " មានសេចក្តីថា ឈ្មោះថាបានដោយកម្រ គឺបានដោយលំបាក ព្រោះត្រូវបានដោយកុសលច្រើន ។ បទ ថា " **មនុស្សប្បដិលាភោ** " ប្រែថា ការត្រឡប់បានមកជាមនុស្ស ។ បទ ថា " **កិច្ឆំ** " ឈ្មោះថាបានដោយលំបាក ព្រោះត្រូវប្រកបកិច្ចការមានកសិកម្មជាដើម ហើយបន្តការចិញ្ចឹមជីវិត ឲ្យប្រព្រឹត្តទៅស្មាំស្មើផង

ព្រោះជីវិតនោះតាំងនៅបានអស់កាលតិចតួចផង ៗ ២ បទ ថា “ មច្ចាន ជីវិតំ ” គឺ សូម្បីជីវិតនៃសត្វទាំងឡាយ ៗ បទ ថា “ កិច្ឆំ ” មានសេចក្ដីថា សូម្បីការបានស្ដាប់ព្រះសទ្ធម្ម ឈ្មោះថាបានដោយកម្រ ព្រោះបុគ្គលអ្នកសំដែងធម៌រកបានដោយកម្រ ក្នុងកប្បមិនចេះតិចឡើយ ៗ បទ ថា “កិច្ឆោ” អធិប្បាយថា ‘សូម្បីការកើតឡើងនៃព្រះពុទ្ធទាំងឡាយ ក៏ឈ្មោះថាបានដោយកម្រ គឺបានដោយលំបាកពេកណាស់ ព្រោះអភិនិហារនឹងសម្រេចបាន ដោយសេចក្ដីព្យាយាមធំផង ព្រោះបុគ្គលអ្នកដែលបានសម្រេចអភិនិហារហើយកើតឡើង រកបានដោយកម្រ ដោយរាប់ពាន់កោដិកប្បជាអនេកផង ’ ៗ

នាគរាជ បានស្ដាប់ព្រះធម៌ទេសនាហើយ, គួរតែបានសម្រេចផលទី ១ ( គឺសោតាបត្តិផល ) នៅក្នុងថ្ងៃនោះ, តែត្រឡប់ជាមិនបានវិញព្រោះខ្លួនជាសត្វតិរច្ឆាន ៗ នាគរាជនោះ បានដល់ភាពមិនលំបាក ក្នុងឋានៈ ទាំងឡាយ ៥ គឺ ចាប់បដិសន្ធិ ១, សកស្បែក ១, សំរេចការដេកលក់ស្រួល ១, សេពមេថុនធម្ម ជាមួយនាងនាគមានជាតិស្មើគ្នា ១, ចុតិ ១ ដូចជាពួកនាគដទៃដែរ ហើយបានដើម្បីត្រេចទៅ ដោយរូបនៃមាណពដូចគ្នាដែរ ៗ

រឿងឯរកបត្តនាគរាជ ចប់

(៩) ហេតុនោះ ភិក្ខុត្រូវអាបត្តិណា ៗ គួរតែបដិបត្តិ (ឲ្យបាន

ត្រឹមត្រូវ ) តាមធម៌ក្នុងអាបត្តិនោះ ៗ តែម្តង ៗ ព្រោះថា បើភិក្ខុបដិបត្តិយ៉ាងនេះ នឹងអាចសម្រេចទាំងមគ្គផលបានដោយពិត ៗ ពិតមែនហើយ ព្រះសាស្តាកាលស្តេចចរិកទៅ ក្នុងទីក្រុងកោសល ទ្រង់ទតព្រះនេត្រទៅឃើញដើមឈើធំមានប្រហោង ត្រង់ចន្លោះផ្លូវ ត្រូវភ្លើងឆេះហើយ ទ្រង់មានបំណងនឹងសំដែងធម៌ ប្រៀបធៀបដោយកងភ្លើង ទ្រង់គង់នៅទៀបគល់ឈើមួយដើម ហើយទ្រង់សំដែងអគ្គិក្ខន្ធោបមសូត្រ ក្នុងគម្ពីរអង្គុត្តរនិកាយ សត្តកនិបាត មានន័យជាអាទិ៍ ថា " **ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយ ឃើញគំនរភ្លើងដ៏ធំនោះ ដែរឬទេ ?** ។

## ( រឿងភិក្ខុ ៣ ពួក )

(១០) ន័យដែលមកក្នុងអដ្ឋកថាចូឡច្ឆរាសង្ឃាតសូត្រ ក្នុងគម្ពីរឯកនិបាត អង្គុត្តរនិកាយ ថា " នាមកាយរបស់ភិក្ខុទាំង ៦០ រូប ចាប់ក្តៅរោលរាលហើយ ព្រោះបានស្តាប់ធម៌ទេសនានោះ, បើនាមកាយក្តៅរោលរាលហើយ , ករជកាយក៏ក្តៅរោលរាលដែរ, បើករជកាយក្តៅរោលរាលហើយ, លោហិតក្តៅឧណ្ហរួមគ្នាហើយ សំផុលចេញមកអំពីមាត់ ៗ បានឮថា ភិក្ខុទាំងនោះ ត្រូវអាបត្តិបារាជិក ៗ ភិក្ខុ ៦០ រូប គិត ថា "ការប្រព្រឹត្តិព្រហ្មចារ្យ ឲ្យបរិសុទ្ធ បរិបូណ៌ រហូតអស់មួយជីវិត នៅក្នុងព្រះពុទ្ធសាសនា ធ្វើបានដោយកម្រណាស់ " ហើយក៏

នាំគ្នាសឹកអស់ទៅ ។ បានឮថា ពួកភិក្ខុទាំងនោះ បានប្រព្រឹត្តញាំញីនូវសិក្ខាបទតូចតាចទាំងឡាយ ។ ភិក្ខុ ៦០ រូប (ក្រៅនេះ) បានបញ្ជូនញាណាត្រង់ឆ្ពោះព្រះធម៌ទេសនា របស់ព្រះសាស្តា ហើយបានលុះនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។ បានស្តាប់មក ថា ពួកភិក្ខុទាំងនោះ បានជាអ្នកមានសីលបរិសុទ្ធ ។ ព្រះធម៌ទេសនានេះ មានផលដល់ភិក្ខុទាំង ៣ ពួកនេះ យ៉ាងដូច្នេះឯង ។ សួរ ថា " ព្រះធម៌ទេសនានេះ សម្រេចផល ដល់ភិក្ខុដែលបានលុះព្រះអរហត្ត ចូរស្លេះទុកមួយអន្លើសិនចុះ, ( ចំណែក ) ដែលមានផល ដល់ភិក្ខុក្រៅអំពីនេះ តើយ៉ាងណាដែរ ? ។ ឆ្លើយ ថា " ក៏ប្រសិនបើ ពួកភិក្ខុទាំងនោះ មិនគប្បីបានស្តាប់ព្រះធម៌ទេសនានេះទេ, ក៏គប្បីជាអ្នកប្រមាទហើយមិនអាចនឹងលះបង់ឋានៈបានឡើយ, ព្រោះហេតុដូច្នេះនោះ បាបនោះកាលចំរើនឡើងដល់ភិក្ខុទាំងនោះ គប្បីឲ្យធ្លាក់ចុះទៅក្នុងអបាយ តែម៉្យាងប៉ុណ្ណោះឯង, តែពួកភិក្ខុទាំងនោះ បានស្តាប់ព្រះធម៌ទេសនានេះហើយ កើតសេចក្តីតក់ស្លុត បានលះបង់ឋានៈ ហើយតាំងនៅក្នុងភូមិនៃសាមណេរ បំពេញសីល ១០ ប្រកបខ្វល់ខ្វាយ ក្នុងយោនិសោមនសិការ ពួកខ្លះ បានជាព្រះសោតាបន្ន, ពួកខ្លះ បានជាព្រះសកទាគាមី, ពួកខ្លះ បានជាព្រះអនាគាមី, ពួកខ្លះ បានទៅកើតក្នុងពួកទេវតា, ព្រះធម៌ទេសនានេះ បានមានផលដល់ពួកភិក្ខុ ដែលត្រូវអាបត្តិបារាជិក ដោយ

ប្រការដូច្នេះឯង ។ សូម្បីពួកភិក្ខុក្រៅពីនេះ បើមិនគប្បីស្តាប់ព្រះធម៌ទេសនានេះទេ, បើពេលវេលាកន្លងទៅ ៗ, ក៏គប្បីត្រូវអាបត្តិសង្ឃាទិសេសខ្លះ បារាជិកខ្លះ, ប៉ុន្តែ ពួកភិក្ខុទាំងនេះបានស្តាប់ព្រះធម៌ទេសនាគិត ថា "ឱ! ព្រះពុទ្ធសាសនា ប្រព្រឹត្តទៅដោយសេចក្តីផូរផង់, ពួកយើង មិនអាចបំពេញសេចក្តីបដិបត្តិនេះ ឲ្យបរិបូណ៌ អស់មួយជីវិតបានឡើយ, ពួកយើងនឹងសឹកទៅបំពេញធម៌របស់ឧបាសក ហើយដោះខ្លួនឲ្យរួចផុតអំពីសេចក្តីទុក្ខ ដូច្នេះហើយ ក៏សឹកទៅតាំង(ខ្លួន) ក្នុងព្រះត្រ័យសរណៈ និងបញ្ចសីល បំពេញធម៌របស់ឧបាសក, ពួកខ្លះបានជាព្រះសោតាបន្ន, ពួកខ្លះបានជាព្រះសកទាគាមី, ពួកខ្លះបានជាព្រះអនាគាមី, ពួកខ្លះបានទៅកើតក្នុងពួកទេវតា, ព្រះធម៌ទេសនានេះ មានប្រយោជន៍ដល់ពួកភិក្ខុទាំងអស់នេះ ដូចបានពណ៌នាមកនេះឯង" ។

ដីកាចូឡវគ្គរាសង្ឃាតសូត្រនោះ ថា "ដើម្បីនឹងសំដែង ថា 'បើករជកាយ កំរើកដោយសេចក្តីក្តៅក្រហាយជាខាងក្រោយ ដ៏មានកម្លាំងសេចក្តីក្តៅក្រហាយដ៏ធ្ងន់ធ្ងរ ក៏កើតឡើង' ទើប ព្រះអដ្ឋកថាចារ្យសំដែង ថា 'បើនាមកាយក្តៅរោលរាលហើយ, ករជកាយ ក៏ក្តៅរោលរាលដែរ' ។ ពាក្យ ថា "**និធានគតិ**" ព្រះអដ្ឋកថាចារ្យពោលសំដៅយកលោហិតដែលគកហើយ ។ ២ បទ ថា "**ឧណ្ហំ លោហិតំ**" មានសេចក្តីថា លោហិតដែលក្តៅឧណ្ហ សំផុលចេញមក ។ បទ ថា

"ឋានំ" គឺ សេចក្ដីប្ដេជ្ញាខ្លួនថាជាភិក្ខុ ៗ ២ បទថា "តំ បាបំ" មានសេចក្ដីថា បាបនោះ ឈ្មោះថាចំរើន យ៉ាងដូច្នោះ ក៏ព្រោះមិនលះសេចក្ដីប្ដេជ្ញាខ្លួនថាជាភិក្ខុ ៗ ព្រះអដ្ឋកថាចារ្យ កាលសំដែង ថា " យោនិសោមនសិការ គឺពួកភិក្ខុសូម្បីត្រូវអន្តិមវត្ថុ ( គឺបារាជិក ) ហើយ ឲ្យប្រព្រឹត្តទៅដោយឧបាយ ក៏ជាគុណនាំប្រយោជន៍មកដល់ឲ្យបានដោយពិត " ដូច្នេះហើយ ទើបសំដែង ថា ' កើតសេចក្ដីតក់ស្លុតហើយ ' ដូច្នេះជាដើម ៗ ពាក្យ ថា " **អហោ សល្លេខិតំ** " មានសេចក្ដីថា ព្រះពុទ្ធសាសនានេះប្រព្រឹត្តទៅដោយសេចក្ដីជូរជង់ក្រៃពេក " ៗ

អាបត្តិទាំងឡាយ សូម្បីភិក្ខុបានក្លែងឲ្យត្រូវហើយ គឺភិក្ខុនៅកម្មហើយក្ដី សំដែងចេញហើយក្ដី តែងមិនធ្វើសេចក្ដីអន្តរាយ ដូច្នេះឯង ៗ មិនចាំបាច់និយាយដល់ទៅអាបត្តិទាំងឡាយ ដែលភិក្ខុមិនបានក្លែងឲ្យត្រូវឡើយ ៗ

## ( អនាគារិយវិន័យ ម៉្យាងទៀត )

(១១) ម៉្យាងទៀត ចតុប្បារិសុទ្ធិសីល ឈ្មោះថា អនាគារិយ-វិន័យ ៗ អនាគារិយវិន័យនោះ គឺភិក្ខុកំពុងសិក្សា ដោយប្រការដែលតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះហើយ លុះព្រះអរហត្ត បានឈ្មោះថាសិក្សាល្អហើយ គប្បីជ្រាប ថា ជាមង្គល ព្រោះជាហេតុសម្រេចសេចក្ដីសុខជាលោកិយ និងលោកុត្តរៈ ៗ

## ( បាដិមោក្ខសំវរសីល )

ក្នុងចតុបារិសុទ្ធិសីលនោះ បាដិមោក្ខសំវរសីល បរិសុទ្ធបាន, បើភិក្ខុមិនត្រូវអាបត្តិណាមួយ, បាដិមោក្ខសំវរសីលនោះ ឈ្មោះថា គឺភិក្ខុដែលមិនត្រូវអាបត្តិនោះ សិក្សាល្អហើយ ។ បាដិមោក្ខសំវរសីលនោះ តែងនាំលោកុត្តរសុខមកឲ្យផងដែរ ដូចជាសីលរបស់ព្រះបធានិយត្ថេរ ។

(១២) បានឮថា ពស់មានពិសដ៏ពន្លឹក ខាំព្រះថេរៈលោកកំពុងតែស្តាប់អរិយវង្សបដិបទា ក្នុងផ្ទះជាទីបំពេញសេចក្តីព្យាយាម ក្បែរដើមកណិការ ក្នុងខណ្ឌបេលវិហារ ។ ព្រះថេរៈសូម្បីដឹងហើយ ក៏នៅតែមានចិត្តជ្រះថ្លា គង់ស្តាប់ព្រះធម៌យ៉ាងប៉ុណ្ណោះ ។ កម្លាំងពិស បានឡើងខ្លាំងក្លាហើយ ។ លោកបានពិចារណាមើលសីល តាំងតែពីមណ្ឌលនៃឧបសម្បទមក ហើយធ្វើបីតិឲ្យកើតឡើង ថា " អាត្មាអញ មានសីលបរិសុទ្ធ " ។ ពិសបាន (សាប) ត្រឡប់ចូលដីវិញទៅ ព្រមជាមួយគ្នានឹងចិត្តុប្បាទ ។ ព្រះថេរៈ បានឯកគ្គតាចិត្តហើយ ចំរើនវិបស្សនា ក៏បានសម្រេចព្រះអរហត្ត ក្នុងទីនោះឯង ។

រឿងព្រះបធានិយត្ថេរ មកក្នុងអដ្ឋកថាសព្វាសវសូត្រជាដើម ។

(១៣) ពាក្យនេះ ខ្ញុំពោល ដោយអំណាចបាដិមោក្ខសំវរសីលយ៉ាងឧក្រិដ្ឋ ។ ក៏ក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថារូបិយសិក្ខាបទជាដើម លោកពោល ថា " បាដិមោក្ខសំវរសីល ឈ្មោះថា

ទេសនាសុទ្ធិ ៗ ពិតមែន បាដិមោក្ខសំវរសីលនោះ លោកហៅថា ‘ ទេសនាសុទ្ធិ ’ ព្រោះបរិសុទ្ធបាន ដោយការសំដែង ” ៗ ក្នុងដីការូបិយសិក្ខាបទនោះ និងដីកាបករណ៍វិសេសវិសុទ្ធិមគ្គ លោកបានសំដែង ថា “ សីលបរិសុទ្ធបាន ដោយគុណជាតនុ៎ះ ហេតុនោះ គុណជាតនុ៎ះ ឈ្មោះថា គ្រឿងបរិសុទ្ធិ ៗ គុណជាតគ្រឿងបរិសុទ្ធិ គឺការសំដែងតាមធម៌ ឈ្មោះថា ទេសនាសុទ្ធិ ៗ ម្យ៉ាងទៀត គប្បីឃើញសេចក្ដីសង្គ្រោះ សូម្បីវុដ្ឋានវិធី (ការនៅបរិវាសកម្ម) ដោយការសំដែងឲ្យបានច្បាស់ ក្នុងពាក្យ ថា “ **ទេសនាសុទ្ធិ** ” នេះ ៗ ចំណែកការសំដែងអាបត្តិដែលជាមូល លោកសង្គ្រោះ ដោយអំណាចប្ដេជ្ញា ថា មិនមែនជាភិក្ខុ ” ៗ ក្នុងដីកាថ្មី លោកសំដែង ថា “ ការនៅបរិវាសកម្មក្ដី ការប្ដេជ្ញាថាមិនមែនជាភិក្ខុ របស់ភិក្ខុអ្នកមានមូលខាតហើយក្ដី លោកសង្គ្រោះដោយទេសនាសព្ទ ក្នុងពាក្យ ថា ‘ **ទេសនាសុទ្ធិ** ’ នេះ ៗ ព្រោះថា សីលរបស់ភិក្ខុ សូម្បីគឺភិក្ខុដែលមានមូលខាតហើយ កំណត់រក្សាយ៉ាងទាប ដោយការឲ្យចេញពីអាបត្តិបារាជិក ឈ្មោះថា ជាសីលបរិសុទ្ធបាន, សូម្បីការបានមគ្គ តែងសម្រេចដល់ភិក្ខុទាំងនោះ ដោយសីលដែលបរិសុទ្ធនោះ ” ៗ ព្រោះហេតុដូច្នោះ សូម្បីសីលរបស់ភិក្ខុដែលត្រូវ (អាបត្តិ) ហើយចេញដោយទេសនាវិធីជាដើម តែងនាំសេចក្ដីសុខមកឲ្យ ដូចជាសីលរបស់ព្រះសុធម្មត្ថេរ ៗ

## ( រឿងព្រះសុធម្មត្ថេរ )

បានឮមកថា ព្រះសុធម្មត្ថេរនោះ បានជេរចិត្តគហបតី ដោយវាទៈ ថា នំផ្សំល្ង ហើយទៅសំណាក់នៃព្រះសាស្តា ទទួលឱវាទព្រះសាស្តា ហើយ ត្រឡប់មកសំដែងអាបត្តិនៅត្រង់ទីចំពោះមុខនៃចិត្តគហបតី បាន ញ៉ាំងចិត្តគហបតីនោះឲ្យអត់ទោសឲ្យហើយ កាលនៅក្នុងអម្ពាដការាម នាទីក្រុងមិច្ឆិកាសណ្ឌនោះឯង ក៏បានសម្រេចព្រះអរហត្ត ព្រមទាំង បដិសម្ភិទា ដោយមិនយូរថ្ងៃប៉ុន្មានឡើយ ។

រឿងព្រះសុធម្មត្ថេរ មកក្នុងពាលវគ្គនៃធម្មបទ ។

(១៤) ម្យ៉ាងទៀត ភិក្ខុអ្នកបំពេញបាដិមោក្ខសំវរសីល គប្បី ដូចជាព្រះថេរៈ ដែលត្រូវពួកចោរចងទុក នៅក្នុងព្រៃដូច្នោះ ។

## ( រឿងព្រះថេរៈមួយអង្គ )

បានឮមកថា ពួកចោរ ក្នុងព្រៃ ខាងហិមវន្តបព៌ត បានយកវល្លិ៍ខ្មៅ ជាច្រើនដើម មកចងព្រះថេរៈមួយអង្គ មិនប្រាកដនាមនិងគោត្រ ហើយ បានឲ្យព្រះថេរៈសិង ដោយភ័យខ្លាច ថា " ព្រះថេរៈនិមន្តមកហើយ នឹង ប្រាប់ដល់អ្នកណាម្នាក់ " ។ ព្រះថេរៈនោះ លោកសិងតាមដែលពួក ចោរវាចងហ្នឹងឯង ខំចំរើនវិបស្សនា អស់មួយសប្តាហ៍ បានជាព្រះ អនាគាមី ចុតិក្នុងទីនោះឯង ហើយបានទៅកើតនៅឯព្រហ្មលោក ។

( រឿងព្រះថេរៈមួយអង្គ )

(១៥) ពួកចោរមួយក្រុមទៀត បានយកវល្លិ៍ផោម មកចងព្រះថេរៈមួយអង្គ ហើយឲ្យលោកសិង នៅក្នុងព្រៃ ក្នុងតម្ពបណ្ណិទ្វីប ។ ព្រះថេរៈមួយអង្គនោះ, កាលភ្លើងព្រៃ (ឆេះ) រាលមកដល់, ក៏មិនបានផ្តាច់វល្លិ៍ចេញឡើយ ខំចំរើនវិបស្សនា បានជាព្រះថេរៈមានព្រះអរហត្តផលស្មើដោយជីវិត ហើយទើបបានបរិនិព្វាន ។ ព្រោះហេតុនោះ កុលបុត្រ អ្នកមានសទ្ធាក្រៅនេះក្តី

កាលបើញាំងបាដិមោក្ខសំវរសីលឲ្យបរិសុទ្ធ គួរដាច់ចិត្តលះបង់ជីវិត មិនគួរទំលាយសីលសំវរៈ ដែលព្រះលោក-នាថ ទ្រង់បញ្ញត្តិទុកឡើយ ។

( ឥន្ទ្រិយសំវរសីល )

(១៦) ចំណែក ឥន្ទ្រិយសំវរសីល រមែងបរិសុទ្ធបាន, កាលបើភិក្ខុពិចារណាឃើញទោសក្នុងការមិនសង្រួម និង អានិសង្សក្នុងការសង្រួមតាមប្រក្រតី ។ ពិតមែន ភិក្ខុនោះ ឃើញអានិសង្ស (ក្នុងការសង្រួម) ដោយភាវៈជារបស់ក្សេម និងទោស (ក្នុងការមិនសង្រួម) ដោយភាវៈជាភ័យ ទើបបំពេញ សិក្សាល្អ នូវឥន្ទ្រិយសំវរសីលនោះ ។

ក៏ទោស និង អានិសង្ស ( ក្នុងការសង្រួមនិងការមិនសង្រួម )

ព្រះមានព្រះភាគសំដែង ក្នុងបឋមសង្គេយ្យសូត្រ ក្នុងសឡាយតនវគ្គ យ៉ាងនេះ ថា "ម្នាលភិក្ខុទាំងឡាយ ! ហេតុឲ្យកើតផស្សៈ ទាំង ៦ នេះ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។ ម្នាលភិក្ខុទាំងឡាយ ! ហេតុឲ្យកើតផស្សៈ ទាំង ៦ នេះ តើដូចម្តេចខ្លះ ? ។

ម្នាលភិក្ខុទាំងឡាយ ! ចក្ខុ ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! សោតៈជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! ឃានៈ ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! ជិវ្ហា ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! កាយ ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គល

មិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! ចិត្ត ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គល មិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! នេះឯង ជាហេតុឲ្យកើតផស្សៈ ទាំង ៦ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបាន សង្រួមហើយ តែងនាំមកនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! ហេតុឲ្យកើតផស្សៈ ទាំង ៦ នេះ ដែល បុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំ មកនូវសេចក្តីសុខដ៏ក្រៃលែង ។ ហេតុឲ្យកើតផស្សៈ ទាំង ៦ នេះ តើដូចម្តេចខ្លះ ? ។ (ហេតុឲ្យកើតផស្សៈ ទាំង ៦ នេះ គឺ ÷)

ម្នាលភិក្ខុទាំងឡាយ ! ចក្ខុជាហេតុឲ្យកើតផស្សៈ ដែលបុគ្គល ទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមក នូវសេចក្តីសុខដ៏ក្រៃលែង ។ ។ល។

ម្នាលភិក្ខុទាំងឡាយ ! ចិត្ត ជាហេតុឲ្យកើតផស្សៈ ដែលបុគ្គល ទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមក នូវសេចក្តីសុខដ៏ក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ! នេះឯង ជាហេតុឲ្យកើតផស្សៈ ទាំង ៦ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសេចក្តីសុខដ៏ក្រៃលែង " ។

(១៧) ហេតុនៃផស្សៈទាំងឡាយ អធិប្បាយ ថា " ហេតុជាទីតាំងនៃការកើតឡើង នៃសម្ផស្សទាំងឡាយមានចក្ខុសម្ផស្ស ជាដើម បានដល់អាយតនៈខាងក្នុងមានភ្នែកជាដើម " ឈ្មោះថា ហេតុឲ្យកើតផស្សៈ ក្នុងបឋមសង្គេយ្យសូត្រនោះ ។ បទ ថា " **អទន្តា** " ប្រែថា មិនបានទូន្មានហើយ ។ បទ ថា " **អសំវុតា** " បានដល់មិនបិទហើយ ។ បទ ថា " **ទុក្ខាធិវាហា** " បានដល់ នាំមកនូវទុក្ខដ៏ក្រៃលែង ផ្សេងដោយទុក្ខ មានទុក្ខរបស់សត្វនរកជាដើម ។ បាលី ថា " **ទុក្ខាធិវាវហា** " ក៏មាន ។ ឯសេចក្តី ក៏ដូចគ្នាដែរ ។ បទ ថា " **សុខាធិវាហា** " បានដល់ នាំមកនូវសេចក្តីសុខដ៏ក្រៃលែង ផ្សេងដោយសេចក្តីសុខ មានសេចក្តីសុខកើតពីឈាននិងមគ្គផលជាដើម ។

(១៨) ក៏ទោស (ក្នុងការមិនសង្រួមឥន្ទ្រីយ៍ ) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងទុកហើយ ក្នុងអាទិត្តបរិយាយសូត្រ ក្នុងសឡាយតនវគ្គនោះឯង យ៉ាងដូច្នេះ ថា " ម្នាលភិក្ខុទាំងឡាយ ! ចក្ខុន្ទ្រីយ៍ ដែលបុគ្គលអាល ដោយបន្ទះដែក ដ៏ក្តៅ ដែលភ្លើងកំពុងឆេះ

រុងរោចន៍ សន្ធោសន្ធៅ ប្រសើរជាង ។ ការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈ ក្នុងរូបដែលបុគ្គលគប្បីដឹងដោយចក្ខុ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្ដេកផ្ដួលទៅរកសេចក្ដីត្រេកអរ ក្នុងនិមិត្ត ឬ ផ្ដេកផ្ដួលទៅរកសេចក្ដីត្រេកអរ ក្នុងអនុព្យញ្ជនៈ កាលតាំងនៅគប្បីតាំងនៅបាន បើបុគ្គលនោះ ធ្វើមរណកាលក្នុងសម័យនោះទៅ ។ បណ្ដាគតិទាំងពីរ បុគ្គលនោះ គប្បីទៅកាន់គតិណាមួយ គឺនរក ឬក៏កំណើតតិរច្ឆាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ សោតិន្ទ្រិយ៍ដែលបុគ្គលខ្វារ ដោយកង្វារដែកដ៏មុត ដែលភ្លើងកំពុងឆេះ រុងរោចន៍ សន្ធោសន្ធៅ ប្រសើរជាង ការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈ ក្នុងសំឡេងដែលបុគ្គលគប្បីដឹងដោយសោតៈ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្ដេកផ្ដួលទៅរកសេចក្ដីត្រេកអរចំពោះនិមិត្ត ឬផ្ដេកផ្ដួលទៅរកសេចក្ដីត្រេកអរចំពោះអនុព្យញ្ជនៈ កាលឋិតនៅ គប្បីឋិតនៅ បើបុគ្គលនោះធ្វើមរណកាលក្នុងសម័យនោះទៅ ។ បណ្ដាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយ គឺនរក ឬ កំណើតតិរច្ឆាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ឃានិន្ទ្រីយ៍ដែលបុគ្គលខ្វេះ ដោយក្រចកដែកដ៏មុត ដែលភ្លើងកំពុងឆេះ រុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ។ល។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯងបានជាពោលយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ជិវ្ហិន្ទ្រីយ៍ដែលបុគ្គលកាត់ ដោយកាំបិតកោរដ៏មុត ដែលភ្លើងកំពុងឆេះ រុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ។ល។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯងបានជាពោលយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ កាយិន្ទ្រីយ៍ដែលបុគ្គលពន្លះ ដោយកាំបិតដ៏មុត ដែលភ្លើងកំពុងឆេះ រុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ។ ការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈ ក្នុងផោដ្ឋព្វៈដែលបុគ្គលគប្បីដឹងដោយកាយ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះនិមិត្ត ឬផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះអនុព្យញ្ជនៈ កាលតាំងនៅ គប្បីតាំងនៅបាន ប្រសិនបើបុគ្គលនោះធ្វើមរណកាល ក្នុងសម័យនោះទៅ ។ បណ្តាគតិទាំងពីរ បុគ្គលនោះ គប្បីទៅកាន់គតិណាមួយ គឺនរក ឬកំណើតតិរច្ឆាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ភាវៈនៃបុគ្គលដេកលក់ ប្រសើរជាង ។ ប៉ុន្តែ តថាគតពោលភាវៈនៃបុគ្គលដេកលក់ថាជាធម្មជាតអសា ដល់បុគ្គល

ដែលមានជីវិត, តថាគតពោលភាវៈនៃបុគ្គលដេកលក់ ថា ជារបស់មិនមានផល ដល់បុគ្គលដែលមានជីវិត, តថាគតពោលភាវៈនៃបុគ្គលដេកលក់ ថា ជារបស់វង្វេងវង្វន់ដល់បុគ្គលដែលមានជីវិត, ភិក្ខុលុះអំណាចនៃអគតិ មានប្រការដូចម្ដេច គប្បីទំលាយសង្ឃ ភិក្ខុមិនគួរត្រិះរិះនូវវិតក្កមានប្រការដូច្នោះឡើយ, ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង ទើបពោលយ៉ាងនេះ " ។

(១៩) ដីកាបករណ៍វិសេសវិសុទ្ធិមគ្គ ថា " បណ្ដាបទទាំងនោះ បទ ថា " **វរំ** " ប្រែថា ប្រសើរ ។ បទ ថា " **តត្តាយ** " គឺ ត្រូវភ្លើងឆេះហើយ ។ បទ ថា " **អាទិត្តាយ** " គឺ ឆេះឡើងហើយ តាំងអំពីដើមមក ។ បទ ថា " **សម្បជ្ជលិតាយ** " គឺ រុងរោចន៍ទូទៅហើយដោយជុំវិញ ។ បទ ថា " **សញ្ជោតិភូតាយ** " គឺ មានអណ្ដាតដូចគ្នាតែមួយ ។ បទ ថា " **សម្បលិមដ្ឋំ** " គឺ ដែលបុគ្គលពាល់ត្រូវហើយ អធិប្បាយថា អាលហើយ គ្រប់យ៉ាង ។ គប្បីនាំមកផ្សំបញ្ចូលគ្នា ថា " **ន ត្វេវ វរំ** " ដូច្នេះ ។ ការកាន់យកនិមិត្ត មានសុភនិមិត្តជាដើម ដោយអំណាចញ៉ាំងកិលេសទាំងឡាយ ឲ្យប្រាកដឡើងរឿយ ៗ បានដល់ដោយអំណាចធ្វើឲ្យប្រាកដ ដោយឲ្យកើតឡើង ឈ្មោះថា ការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈ ។ ម្យ៉ាងទៀត បទ ថា " **អនុព្យញ្ជនសោ** " គឺ ដោយការបំបែកកាន់យកអវយវៈ មានដៃនិងជើង

ជាដើម ។ ការកាន់យកសុភនិមិត្ត ក្នុងរូបមានរូបបុរសនិងស្ត្រីជាដើម ឈ្មោះថា ការកាន់យកនិមិត្ត " ។

(២០) ន័យដែលមកហើយក្នុងអដ្ឋកថាអាទិត្តបរិយាយសូត្រ ថា " ការកាន់យកដោយអនុព្យញ្ជនៈនិងការកាន់យកដោយនិមិត្ត ថា ' ដៃល្អ ជើងល្អ ' ដូច្នេះជាដើម ឈ្មោះថាការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ។ ម៉្យាងទៀត ការរួបកាន់យក ឈ្មោះថា ការកាន់យកដោយនិមិត្ត ។ ការបំបែកគ្នាកាន់យក ឈ្មោះថា ការកាន់យក ដោយអនុព្យញ្ជនៈ ។ ការរួបកាន់យក រមែងកាន់យករូបគ្រប់បែបយ៉ាង ដូចជាក្រពើ (ត្របាក់លេប), ការបំបែកកាន់យក រមែងបំបែកកាន់យកចំណែកនោះៗក្នុងអវយវៈទាំងឡាយ មានដៃនិងជើង ជាដើម ។ បទ ថា " និមិត្តស្សាទគធិតំ " គឺ ដែលឈ្លក់ហើយ បានដល់ជាប់ជំពាក់ហើយដោយសេចក្ដីត្រេកអរចំពោះនិមិត្ត ។ កម្មវិញ្ញាណ ឈ្មោះថា វិញ្ញាណ ។ បទ ថា " **អាទីនវំ** " គឺ សេចក្ដីទុក្ខដែលគប្បីសោយ ក្នុងនរក ជាច្រើនសែនឆ្នាំ ។ បទ ថា " **អយោសង្កុនា** " ប្រែថា ដោយកង្វារដែក ។ សោតិន្ទ្រីយ៍ ឈ្មោះថា បុគ្គលខ្វារហើយ ដោយអំណាចចោះរន្ធត្រចៀកទាំងពីរ ហើយដំកំទេច លើផែនដី ។ ឃានិន្ទ្រីយ៍ ឈ្មោះថា គឺ បុគ្គលខ្វេះហើយ ដោយអំណាចស៊កកាំបិតកាត់ក្រចកហើយ គាស់ឡើងកាត់ទម្លាក់ចុះ ព្រមគ្នាជាមួយក្តោងច្រមុះ ។ ជិវ្ហិន្ទ្រីយ៍ ឈ្មោះថា គឺបុគ្គល

កាត់ហើយ ដោយអំណាចកាត់គល់ដែលតជាប់គ្នា ហើយឲ្យធ្លាក់ចុះ ។ បទ ថា "**សត្តិយា**" មានសេចក្តីថា កាយិន្ទ្រីយ៍ ឈ្មោះថា គឺបុគ្គលពន្លះហើយ ដោយអំណាចពន្លះនូវកាយប្រសាទ ដោយកាំបិតព្រាដ៏ធំហើយ ធ្វើឲ្យធ្លាក់ចុះ ។ ការដេកលក់ ឈ្មោះថា ភាវៈនៃបុគ្គលដែលដេកលក់ ។ ភាវៈគឺវិតក្កៈទាំងឡាយ នាំបាបកម្មមក រហូតដល់ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង ដោយបទនេះ ថា '**សង្ឃំ ភិន្ទេយ្យ**' ដូច្នេះ" ។

(២១) សូម្បីការដល់នូវសេចក្តីវិនាស ក្នុងបច្ចុប្បន្ន ក៏ចាត់ថាជាទោស ។ ក្នុងសេចក្តីនោះ មានរឿងនេះ (ជាឧទាហរណ៍) ។

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វ បានកើតជាព្រាហ្មណ៍មានទ្រព្យសម្បត្តិ ៨០ កោដិ នៅក្នុងក្រុងពារាណសី ។ ក៏ព្រោះតែព្រះពោធិសត្វនោះ មានសម្បុរដូចជាមាស ទើបមាតាបិតា ដាក់ឈ្មោះឲ្យ ថា "**ហារិត**" ។ ដោយអស់ពីមាតាបិតាទៅ ព្រះពោធិសត្វនោះ ចេញទៅបួស ក្នុងព្រៃហេមពាន្ត ក្នុងថ្ងៃទី ៧ បានញុាំងឈាននិងអភិញ្ញាឲ្យកើតឡើង ហើយនៅក្នុងទីនោះ អស់កាលដ៏យូរ ព្រោះប្រាថ្នាសេពរសជាតិប្រៃនិងជូរ ទើបទៅកាន់ឧទ្យានព្រះរាជា ក្រុងពារាណសី ហើយរស់នៅ (ក្នុងទីនោះ) ។ ហារិតតាបសនោះ នៅឆាន់ (ភោជនាហារ) ជាប់ជានិច្ច ក្នុងព្រះរាជវាំងនៃព្រះរាជា អស់រយៈ

វេលា ១២ ឆ្នាំ ៗ ព្រះរាជា កាលយាងទៅបង្ក្រាបបច្ចន្តជនបទ ទ្រង់មានព្រះរាជឱង្ការនឹងព្រះនាងទេវី ថា " ចូរព្រះអគ្គមហេសី កុំបី ធ្វេសប្រហែសនឹងបុញ្ញក្ខេត្ត របស់យើងឡើយ " ដូច្នេះហើយ ទើប បានស្តេចយាងទៅ ៗ ចាប់តាំងពីនោះមក ព្រះនាងទេវីនោះ ទ្រង់ អង្គាសព្រះមហាសត្វ ដោយព្រហស្តព្រះនាងផ្ទាល់ ៗ ក្រោយមកថ្ងៃ មួយ ព្រះនាងទេវីនោះ, កាលព្រះមហាសត្វនោះ (មក) យឺតយូរ, ក៏យាងទៅស្រង់ទឹក ស្រេចហើយទ្រង់ព្រះភូសាសាច់ម៉ដ្ឋ ទ្រង់ឲ្យបើក បង្អួចហើយ ទ្រង់ផ្ទំឲ្យខ្យល់ផាត់រំហើយព្រះកាយ ទ្រង់ព្រះសណ្ដាប់នូវ សំឡេងសំពត់សំបកឈើព្រះពោធិសត្វ ទើបប្រញាប់ប្រញាល់ស្ទុះក្រោក ឡើងភ្លាម ៗ ព្រះភូសាសាច់ម៉ដ្ឋ បានរបូតហើយ ៗ ព្រះមហាសត្វ ឃើញវិសភាគារម្មណ៍ហើយ ក៏កើតកិលេសដាច់ឈាន នៅក្នុងខណៈ នោះឯង មិនអាចតាំងសតិស្មារតីបាន ហើយបានសេពអសទ្ធម្ម ជាមួយ នឹងព្រះនាងទេវី ឆាន់ភត្តាហារស្រេចហើយ ក៏ដើរទៅកាន់ឧទ្យាន ៗ តាំងអំពីពេលនោះមក ព្រះមហាសត្វនោះ ក៏បានធ្វើយ៉ាងដូច្នោះឯង ជារៀងរាល់ថ្ងៃ ៗ ព្រះមហាសត្វនោះ ដល់នូវសេចក្ដីវិនាសក្នុងទិដ្ឋធម្ម ព្រោះហេតុតែមិនបានសង្រួមឥន្ទ្រីយ៍ ដោយប្រការដូច្នេះឯង ៗ ហើយ កម្មរបស់ព្រះមហាសត្វនោះ ក៏បានព្យាសុះសាយ ពេញក្នុងព្រះនគរ ៗ ពួកអាមាត្យ បានបញ្ជូនព្រះរាជសាសន៍ទៅថ្វាយព្រះរាជា មានសេចក្ដីថា

"ហារិតតាបស បានធ្វើយ៉ាងដូច្នេះ" ។ ព្រះរាជាមិនទាន់ជឿឡើយ ទ្រង់បង្ក្រាបបច្ចន្តជនបទ រាបទាបហើយ ទើបស្ដេចត្រឡប់មកវិញហើយ យាងចូលទៅកាន់ព្រះឧទ្យាន ទ្រង់បានត្រាស់សួរព្រះពោធិសត្វ ។ ព្រះពោធិសត្វនោះ ទូល (សារភាព) តាមរឿងពិត ព្រោះជាអ្នកធ្លាប់តែនិយាយពាក្យពិតត្រង់ ហើយទូល ថា "បពិត្រព្រះមហារាជ ចូរព្រះអង្គប្រោសធ្វើឱកាសឱ្យអាត្មាភាពបានបន្តិចសិន" ដូច្នេះហើយ ក៏ចូលទៅកាន់បណ្ណសាលា ពិចារណាមណ្ឌលនៃកសិណហើយ ញ៉ាំងឈានឱ្យកើតឡើងម្ដងទៀតហើយ ចេញពីបណ្ណសាលា អង្គុយលើអាកាសបានសំដែងធម៌ដល់ព្រះរាជាហើយ (វិលត្រឡប់) ទៅកាន់ព្រៃហេមពាន្តវិញ រំលែងសាបសូន្យចាកឈានហើយ បានចូលទៅដល់ព្រហ្មលោក ។

រឿងហារិតតាបស មកក្នុងអដ្ឋកថាហារិតជាតក ក្នុងនវកនិបាត ។

(២២) រឿងលោមសកស្សបតាបស មកក្នុងអដ្ឋកថាលោមសកស្សបជាតក ក្នុងនវកនិបាតនោះឯងក្ដី រឿងនៃជនទាំងឡាយ ៥ នាក់ ជាអ្នកមានរូប និងសំឡេងជាអារម្មណ៍ជាដើម ត្រូវពួកនាងយក្ខិនីចាប់ស៊ីហើយ ព្រោះហេតុតែមិនបានសង្រួមឥន្ទ្រីយ៍ និងរឿងនៃព្រះរាជឱរសនៃព្រះរាជាក្រុងពារាណសីទាំង ២ ព្រះអង្គ ជាអ្នកមិនខ្ចីក្រឡេកមើល សូម្បីនូវរូបដែលជាទិព្វ ដែលពួកនាងយក្ខិនីប្រែក្រឡា ដោយអំណាចទំលាយឥន្ទ្រីយ៍ហើយ ញ៉ាំងកិលេសឱ្យកើតឡើង ស្ដេចយាង

ទៅដល់ក្រុងតក្កសីលាហើយ គ្រងរាជ្យសម្បត្តិ ដែលមកក្នុងអដ្ឋកថាតក្កសីលាជាតក និងបញ្ចាគុរុជាតក ក្នុងវគ្គទី ១០ និង វគ្គទី ១៤ តាមលំដាប់ នៃឯកនិបាតក្តី ក៏គប្បីប្រមូលមក ។

(២៣) ម្យ៉ាងទៀត សូម្បីការវិនាសចាកគោចររបស់ខ្លួន ក៏ចាត់ថាជាទោស ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ទូន្មាននូវពួកភិក្ខុដែលមិនបានសង្រួមឥន្ទ្រិយ៍ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាភិក្ខុកាន់យកនូវនិមិត្ត ក្នុងរូបជាដើម ដោយអំណាចសុភនិមិត្ត មិនសមគួរឡើយ, ក៏ប្រសិនបើ ភិក្ខុនោះ ធ្វើនូវមរណកាល ក្នុងសម័យនោះ, ក៏នឹងទៅកើត ក្នុងអបាយមាននរកជាដើម, ព្រោះហេតុនោះ អ្នកទាំងឡាយ កុំកាន់យកសុភនិមិត្ត ក្នុងរូបជាដើមឡើយ " ដូច្នេះហើយ ទ្រង់មានព្រះបំណងនឹងត្រាស់សំដែងព្រះធម៌ទេសនា ព្រមទាំងឧបមា ម្តងទៀត ទើបទ្រង់ត្រាស់ ថា " ពេលដែលអ្នកទាំងឡាយសំឡឹងមើលរូបក្តី ពេលដែលអ្នកទាំងឡាយមិនបានសំឡឹងមើល (រូប) ក្តី តែងមាន, (ប៉ុន្តែ) នៅពេលដែលសំឡឹងមើល មិនគួរសំឡឹងមើល ដោយអំណាចសុភនិមិត្ត គួរសំឡឹងមើលដោយអំណាចអសុភនិមិត្ត, ធ្វើយ៉ាងនេះ ទើបអ្នកទាំងឡាយ នឹងមិនសាបសូន្យ អំពីគោចររបស់ខ្លួន ។ ក៏អ្វីទៅ ជាគោចរ របស់អ្នកទាំងឡាយ ? ។ គឺ សតិបដ្ឋាន ៤, សម្មប្បធាន ៤, អរិយមគ្គមានអង្គ ៨,

លោកុត្តរធម៌ ៩ (នេះជាគោចររបស់អ្នកទាំងឡាយ) ៗ ព្រោះថា បើអ្នកទាំងឡាយប្រព្រឹត្តក្នុងគោចរនុ៎ះ, មារនឹងមិនបាននូវឱកាស ៗ ប៉ុន្តែប្រសិនបើអ្នកទាំងឡាយ ជាអ្នកលុះក្នុងអំណាចកិលេសហើយនឹងសំឡឹងមើល (រូបជាដើម) ដោយអំណាចសុភនិមិត្ត, អ្នកទាំងឡាយ នឹងវិនាសចាកគោចររបស់ខ្លួន ដូចជាឆ្កែចចកឈ្មោះបូតិមំសៈ ដូច្នោះឯង" ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក (សំដែង) ថា ÷

## (រឿងឆ្កែចចក ឈ្មោះបូតិមំសៈ)

(២៤) បានឮមកថា ក្នុងអតីតកាល នៅក្នុងហិមវន្តប្រទេស មានសត្វពពែជាច្រើនរយក្បាល នៅក្បែររូងភ្នំ ៗ ក្នុងចំណោមនៃពពែទាំងនោះ មានមេពពែមួយ ឈ្មោះមេណ្ឌមាតា ជាសត្វឆ្លាត ឈ្លាសវាងវៃក្នុងឧបាយកល ៗ ឆ្កែចចកឈ្មោះបូតិមំសៈ ព្រមទាំងភរិយាឈ្មោះវេណី បានរស់នៅក្នុងគូហាមួយ មិនឆ្ងាយពីទីនៅ នៃសត្វពពែទាំងនោះ ៗ ឆ្កែចចកនោះ ព្រមទាំងភរិយា បានខាំពពែស៊ីអស់ជាច្រើនដោយឧបាយកល ហើយប្រាថ្នាចង់ខាំមេពពែ ឈ្មោះមេណ្ឌមាតានោះស៊ីម្តងទៀត ទើបប្រាប់ភរិយា ថា " អូនឯង ចូរធ្វើជាសំឡាញ់ ជាមួយនឹងមេពពែនោះ, បើសេចក្តីស្និទ្ធស្នាលកើតមានហើយ, បងនឹងដេកធ្វើពុតជាស្លាប់, ចូរអូនទៅរកមេពពែនោះហើយប្រាប់ ថា ' ប្តីរបស់

ខ្ញុំស្លាប់ហើយ, ខ្ញុំគ្មានទីពឹងឡើយ, ក្រៅអំពីគាត់ អ្នកដទៃដែលត្រូវជាញាតិ របស់ខ្ញុំក៏មិនមានដែរ, ចូរអ្នកអញ្ជើញមក (ទៅផងគ្នា) យើងនឹងជួយធ្វើសរីរកិច្ច របស់គាត់ ដូច្នេះហើយ ចូរនាំមក, បើអូនឯងនាំមេពពៃនោះមកដល់ហើយ, បងនឹងលោតទៅស្រង់ខាំវា ត្រង់កឲ្យស្លាប់ " ។ មេឆ្កែចចកនោះ បានធ្វើដូច្នោះ, បើសេចក្ដីស្និទ្ធស្នាលកើតមានហើយ, ក៏បានប្រាប់មេពពៃនោះ ដូច្នោះឯង ។ មេពពៃបាននិយាយ ថា " ពួកញាតិរបស់ខ្ញុំ ត្រូវប្ដីអ្នកចាប់ស៊ីហើយ, ខ្ញុំភ័យខ្លាចគាត់, ខ្ញុំមិនអាចទៅបានឡើយ " ។ មេឆ្កែចចកពោល ថា " អ្នកកុំភ័យខ្លាចអ្វីឡើយ, គាត់ស្លាប់ហើយ នឹងធ្វើអ្វីកើត " ដូច្នេះហើយ ក៏បាននាំមេពពៃនោះមក ។ ឆ្កែចចកជាប្ដី បានឮសំឡេងជើងនៃប្រពន្ធនិងមេពពៃនោះហើយ ក៏អើតក្បាលងើបមើល ដោយនឹកគិត ថា " មេពពៃ មកហើយ ឬក៏មិនមកហ្ន៎ ? " ។ មេពពៃបានឃើញឆ្កែចចកនោះ កំពុងធ្វើយ៉ាងដូច្នោះ ទើបពោលតិះដៀល ថា " ឆ្កែចចកប្ដីអ្នកនេះ អាក្រក់ណាស់ ដេកធ្វើពុតជាស្លាប់ ព្រោះប្រាថ្នាចង់បោកបញ្ឆោតខ្ញុំមក ហើយខាំសម្លាប់" ដូច្នេះហើយ ក៏បានគេចត្រឡប់ទៅវិញ ។ មេឆ្កែចចកមិនអាចឲ្យមេពពៃនោះត្រឡប់មកវិញបាន ទើបចូលទៅរកឆ្កែចចកដែលជាប្ដី កាលតិះដៀលឆ្កែចចកនោះ បានពោលគាថានេះ ថា ៖

(២៥) នែសំឡាញ់ គាត់ឯងបញ្ឆោតធ្វើពុតជាស្លាប់

ហើយក្រឡេកមើល (មេពពៃ) ខុសកាល, គាត់ឯង
ទេតើ ជាសត្វឆ្កួត ល្ងង់ខ្លៅ មិនចេះពិចារណាអ្វីសោះ" ។

បណ្ដាបទទាំងនោះ បទ ថា " **អវិចក្ខណោ** " បានដល់ ប្រាស
ចាកបញ្ញាគ្រឿងពិចារណា ។ បាទគាថា ថា "**អកាលេន វិបេក្ខសី**"
មានសេចក្ដីថា កាលមេពពៃមិនទាន់មកដល់សំណាក់ របស់ខ្លួននោះឯង
បានអើតមើលហើយ ។

ព្រះដ៏មានព្រះភាគ លុះនាំអតីតនិទានមកសំដែងយ៉ាងនេះហើយ
ទ្រង់ត្រាស់គាថានេះ ក្នុងបូតិមំសជាតក ក្នុងនវកនិបាត ថា ÷

" អ្នកប្រាជ្ញមិនគប្បីក្រឡេកមើល ក្នុងកាលមិនគួរទេ,
គប្បីក្រឡេកមើលតែក្នុងកាលដ៏គួរ, បុគ្គលណាក្រឡេក
មើលក្នុងកាលមិនគួរ, បុគ្គលនោះរមែងសញ្ជប់សញ្ជឹង
ដូចជាឆ្កែចចក ឈ្មោះបូតិមំសៈ យ៉ាងនោះឯង " ។

បណ្ដាបទទាំងនោះ បទ ថា " **អកាលេ** " បានដល់ ក្នុងកាល
ប្រារព្ធកាមគុណ ហើយញុាំងចិត្តឲ្យកើតឡើង ដោយអំណាចសុភនិមិត្ត ។
កាលនេះឯង ឈ្មោះថា ជាកាលដែលភិក្ខុ មិនគួរសំឡឹងមើលរូប ។
បទ ថា " **កាលេ** " បានដល់ ក្នុងពេលដែលកាន់យករូប (ជាអារម្មណ៍)
ដោយអំណាចអសុភកម្មដ្ឋាន អនុស្សតិកម្មដ្ឋាន និងកសិណ ។ កាល

នេះឯង ឈ្មោះថាជាកាលសមគួរ ដែលភិក្ខុគួរក្រឡេកមើលរូបបាន ។ បាទគាថា ថា "សុភានុបស្សឹ វិហរន្តំ" មានសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ចចកបូតិមំសៈ ក្រឡេកមើលមេពពែ ក្នុងកាលមិនគួរ វិនាសចាកគោចរ ( ចំណី ) របស់ខ្លួនហើយ សញ្ជប់សញ្ជឹង យ៉ាងណា, ភិក្ខុក្រឡេកមើលរូប ក្នុងកាលមិនគួរ ដោយអំណាចសុភនិមិត្ត វិនាសចាកគោចរមានសតិបដ្ឋានជាដើមហើយ រមែងសញ្ជប់សញ្ជឹង គឺតែងលំបាកទាំងក្នុងទិដ្ឋធម្ម ទាំងក្នុងសម្បរាយភព ក៏យ៉ាងដូច្នោះដែរ " ។

រឿង ចចកឈ្មោះបូតិមំសៈ ចប់ ។

(២៦) ព្រោះហេតុនោះ ឈ្មោះថាភិក្ខុមិនគួរកាន់យកអារម្មណ៍មានរូបជាដើម ដោយអំណាចការកាន់យកដោយអនុព្យញ្ជនៈ និងដោយនិមិត្ត កាន់យកតែអារម្មណ៍តាមដែលបានឃើញ បានស្ដាប់ បានឮមកហើយប៉ុណ្ណោះ គប្បីដូចជាព្រះមហាតិស្សត្ថេរ អ្នកនៅចំរើនអសុភកម្មដ្ឋាន ដែលនៅក្នុងចេតិយបព៌ត យ៉ាងដូច្នោះ ។

## ( រឿងព្រះមហាតិស្សត្ថេរ )

បានឮថា ព្រះមហាតិស្សត្ថេរនោះ ជាអ្នកបានចំរើនអដ្ឋិកកម្មដ្ឋានជាប្រក្រតី ។ សម័យថ្ងៃមួយ ព្រះថេរៈនោះចេញពីចេតិយបព៌ត និមន្តទៅអនុរាធបុរី ដើម្បីបិណ្ឌបាត ។ គ្រានោះ មានស្ត្រីម្នាក់ឈ្មោះគ្នា

ជាមួយប្តី ហើយចេញពីអនុរាធបុរីទៅកាន់ផ្ទះរបស់ញាតិ តាំងពីព្រលឹម ចួបព្រះថេរៈក្នុងពាក់កណ្តាលផ្លូវ មានចិត្តវិបលាសហើយសើចយ៉ាងខ្លាំង ព្រះថេរៈកំពុងតែនិមន្តទៅដោយមនសិការនូវអដ្ឋិកកម្មដ្ឋានបណ្តើរ ៗ នឹកថា " នុ៎ះជាសំឡេងអ្វី " ហើយក្រឡេកមើលទៅតាមសូរស័ព្ទសំឡេងដែលសើច ព្រោះមនសិការដែលជាចំណែកខាងដើមមានសំឡេងដូចជាសឹកសត្រូវ ហើយត្រឡប់បានអដ្ឋិកសញ្ញា នៅក្នុងឆ្អឹងធ្មេញនៃស្ត្រីនោះឈរនៅតាមដើមនោះឯង ក៏បានសម្រេចបឋមជ្ឈានហើយ ញ៉ាំងវិបស្សនាឲ្យកើតឡើង ហើយលុះនូវព្រះអរហត្ត ។

រឿងព្រះតិស្សត្ថេរ អ្នកចំរើនអសុភកម្មដ្ឋាន មកក្នុងសីលនិទ្ទេសនៃគម្ពីរឈ្មោះវិសុទ្ធិមគ្គ ។

(២៧) សូម្បីពាក្យនេះ ក៏ខ្ញុំពោលហើយ ដោយអំណាចនៃឥន្ទ្រិយសំវរសីលយ៉ាងឧក្រិដ្ឋ ។ ឈ្មោះថាចិត្តនុ៎ះ ប្រព្រឹត្តទៅឆាប់រហ័ស, ព្រោះហេតុនោះ ភិក្ខុបន្ទោបង់នូវរាគៈដែលកើតឡើង ដោយមនសិការដល់អសុភកម្មដ្ឋានហើយ គប្បីញ៉ាំងឥន្ទ្រិយសំវរសីលឲ្យដល់ព្រម គប្បីដូចព្រះវង្គីសត្ថេរ អ្នកបួសថ្មី ។

## ( រឿងព្រះវង្គីសត្ថេរ )

បានឮថា ព្រះវង្គីសត្ថេរនោះ កាលនិមន្តទៅបិណ្ឌបាត ជាមួយនឹង

ព្រះអានន្ទត្ថេរ ឃើញស្រីម្នាក់ ក៏កើតរាគៈ បានប្រាប់រឿងនោះ ដល់ព្រះអានន្ទត្ថេរ ហើយពោល ថា " សូមលោកម្ចាស់ ជួយប្រាប់នូវឧបាយសម្រាប់រម្ងាប់រាគៈ ដល់ខ្ញុំផង " ។ ព្រះអានន្ទត្ថេរ បានប្រាប់ឧបាយ ថា " បើដូច្នោះ អ្នកកុំធ្វើនូវសុភនិមិត្ត ដែលជាហេតុកើតរាគៈ ទុកក្នុងចិត្តឡើយ ចូរអប់រំចិត្ត ដោយអសុភភាវនា " ។ ព្រះវង្គីសត្ថេរនោះ បានបន្ទោបង់រាគៈ ដោយការធ្វើយ៉ាងនោះឯងហើយ និមន្តទៅបិណ្ឌបាត ។ ក្រោយមក ឯព្រះវង្គីសត្ថេរនោះ ក៏បានលុះនូវព្រះអរហត្ត ។

(២៨) ពិតមែន ឥន្ទ្រិយសំវរសីល ព្រះអដ្ឋកថាចារ្យទាំងឡាយសំដែង ថា " **សំវរសុទ្ធិ** " ព្រោះបរិសុទ្ធបាន ដោយអំណាចអធិដ្ឋាននូវចិត្ត ថា ' អាត្មាអញនឹងមិនធ្វើយ៉ាងនេះទៀត " ។ ព្រះដីកាចារ្យអ្នកកែអដ្ឋកថានោះសំដែង ថា " ព្រះអដ្ឋកថាចារ្យសំដែងសព្ទ ថា ' ឯវំ ' ក្នុងពាក្យ ថា " ន បុនេវំ " នុ៎ះ សំដៅយកការទំលាយសំវរៈ " ។ ព្រោះហេតុនោះ សូម្បីភិក្ខុដទៃទំលាយនូវសំវរៈហើយ ក៏គប្បីធ្វើនូវសំវរៈឲ្យដល់ព្រមសាជាថ្មី ។ ម្យ៉ាងទៀត ភិក្ខុអ្នកបំពេញឥន្ទ្រិយសំវរសីល គប្បីដូចជាព្រះចិត្តគុត្តត្ថេរ ដែលនៅក្នុងរូងភ្នំ ឈ្មោះកុរណ្ឌកៈ ។

## ( រឿងព្រះចិត្តគុត្តត្ថេរ )

បានឮមកថា រូបគំនូររឿងការចេញអភិនេស្រ្កមន៍ របស់ព្រះពុទ្ធ

ទាំង ៧ ព្រះអង្គ ដែលជាទីមនោរម្យ បានមានហើយ ក្នុងរូងភ្នំឈ្មោះ កុរណ្ឌកៈ ។ ព្រះថេរៈនៅក្នុងរូងភ្នំនោះ ជាង ៦០ ឆ្នាំ (តែ) លោក មិនដែលបានបើកភ្នែក ក្រឡេកងើយមើលរូងភ្នំសោះ ព្រោះលោក ក្រឡេកមើលត្រឹមតែរយៈជួរនឹម, ព្រោះហេតុនោះ ព្រះថេរៈ ទើបមិន ដឹងថារូបគំនូរមាននៅ ក្នុងរូងភ្នំនោះផង ។ សួរ ថា " វត្តគឺការជំរះ សេនាសនៈ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា 'ភិក្ខុគប្បីបោសនូវពីងពាង ចេញពីពិដាន ជាមុន' ដូច្នេះ មិនមែនទេឬ ?, ព្រះថេរៈមិនជំរះនូវ សេនាសនៈទេឬ ?" ។ ឆ្លើយ ថា " មែនហើយ ព្រះថេរៈមិនជំរះ ខ្លួនឯងទេ, តែ ពួកអន្តេវាសិកជាដើមទេតើ ជំរះសេនាសនៈ របស់ លោក" ។ ក្រោយមក ថ្ងៃមួយ មានភិក្ខុជាច្រើនរូប ចារិកទៅក្នុង សេនាសនៈ ឃើញចិត្តកម្មក្នុងរូងភ្នំនោះហើយ បានប្រាប់ ថា " លោក ដ៏ចំរើន ចិត្តកម្មជាទីមនោរម្យក្រៃលែង" ។ ព្រះថេរៈពោល ថា " អ្នក ដ៏មានអាយុ ខ្ញុំនៅក្នុងទីនេះឯង អស់រយៈពេលប៉ុណ្ណោះ ក៏មិនដឹងឡើយ, ទើបថ្ងៃនេះឯង ខ្ញុំដឹងព្រោះអាស្រ័យពួកលោក ដែលមើលឃើញ" ។ ម្យ៉ាងទៀត ត្រង់ទ្វាររូងភ្នំនៃព្រះថេរៈនោះ ក៏មានដើមខ្នុំធំផងដែរ ។ ឯដើមខ្នុំធំនោះសោត ក៏ព្រះថេរៈមិនដែលងើយមើលខាងលើឡើយ ។ បានឮថា ជារៀងរាល់ឆ្នាំ ព្រះថេរៈឃើញកេសរផ្កាខ្នុំនោះជ្រុះធ្លាក់មក លើផែនដីនោះឯង ទើបដឹងថា ដើមខ្នុំនោះមានផ្ការីកហើយ ។ ព្រះ

រាជាទ្រង់ព្រះសណ្ដាប់ នូវគុណសម្បត្តិនៃព្រះថេរៈហើយ ទ្រង់មានព្រះបំណងនឹងថ្វាយបង្គំ ទ្រង់បញ្ជូន (ព្រះរាជសាសន៍) ទៅ អស់វារៈ ៣ ដង, កាលព្រះថេរៈមិននិមន្តមក, ទ្រង់ព្រះរាជបញ្ជាឲ្យរុំដោះស្រ្តីទាំងឡាយ ដែលមានកូនខ្ចី ក្នុងមហាគ្រាម ដោយសំពត់ចងដោះហើយ ទ្រង់ព្រះរាជបញ្ជាឲ្យប្រថាប់ត្រា ដោយព្រះរាជសង្ហា ដោយព្រះរាជឱង្ការ ថា "ព្រះថេរៈមិនទាន់និមន្តមក ដរាបណា, ទារកទាំងឡាយកុំបាន (បៅ) ដោះ ដរាបនោះ" ។ ព្រះថេរៈបាននិមន្តទៅមហាគាម ដើម្បីអនុគ្រោះដល់ទារកទាំងឡាយ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពត៌មាននោះហើយ ទ្រង់ព្រះរាជបញ្ជាឲ្យនាំព្រះថេរៈមក ក្នុងព្រះរាជបុរី ទ្រង់ថ្វាយបង្គំ ឲ្យព្រះថេរៈឆាន់ហើយ ទ្រង់ត្រាស់ ថា "ព្រះគុណម្ចាស់ដ៏ចំរើន ថ្ងៃនេះ មិនមានឱកាសឡើយ, ថ្ងៃស្អែក ខ្ញុំព្រះករុណា នឹងទទួលសីល" ដូច្នេះហើយ ទ្រង់ទទួលបាត្រស្ដេចជូនដំណើរបន្តិច ទ្រង់ថ្វាយបង្គំហើយ ស្ដេចយាងត្រឡប់ទៅវិញ មួយអន្លើដោយព្រះទេវី ។ ស្អែកឡើងទៀត ព្រះរាជាទ្រង់ថ្វាយទានដូច្នោះដែរ ទ្រង់ត្រាស់ (ប្ដូរ) ថា "ថ្ងៃស្អែក ខ្ញុំព្រះករុណានឹងទទួលសីល" ដូច្នេះហើយ ទ្រង់ញ៉ាំងពេលវេលាឲ្យកន្លងទៅ អស់មួយសប្ដាហ៍ ដោយឧបាយនោះ ។ ចំណែកព្រះថេរៈ ក្នុងពេលដែលព្រះរាជានិងព្រះរាជទេវីទ្រង់ថ្វាយបង្គំ កំណត់ត្រឹមអាការថាគ្រាន់តែជាសត្វ, តែមិនបានធ្វើនូវកិរិយាចែកផ្សេងគ្នាថា

ជាស្ត្រី ឬបុរស ", ព្រោះដូច្នោះ នៅពេលដែលព្រះរាជានិងព្រះទេវីនោះទ្រង់ថ្វាយបង្គំ ព្រះថេរៈបានពោលធ្វើដូចគ្នាតែមួយ ថា " សូមទ្រង់មានសេចក្តីសុខចុះ មហាបពិត្រ " ។ ព្រះថេរៈនោះនៅក្នុងមហាគ្រាមមួយសប្តាហ៍ ត្រូវព្រះរាជាអនុញ្ញាតឲ្យនិមន្តត្រឡប់ទៅវិញ ដោយព្រះតម្រិះ ថា " ការនៅក្នុងទីនេះ ជាការលំបាកដល់ព្រះថេរៈ " និមន្តទៅដល់រូងភ្នំរបស់ខ្លួនហើយ នៅវេលាយប់ បានឡើងទៅចង្ក្រម ។ ពួកទេវតាដែលស្ថិតនៅលើដើមខ្ទឹងគិត ថា " ឱ ! ព្រះគុណម្ចាស់អង្គនេះមានសីលបរិសុទ្ធហ្ន៎ " ហើយបានឈរទ្រោលប្រទីប ។ ព្រះថេរៈកំពុងចង្ក្រម ដោយមនសិការដល់កម្មដ្ឋាននោះឯង ធ្វើភ្នំទាំងមូលឲ្យកំរើក រំពើក លុះព្រះអរហត្ត ក្នុងចន្លោះនៃមជ្ឈិមយាម ។

រឿងព្រះចិត្តគុត្តត្ថេរ មកក្នុងសីលនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

## ( អាជីវបារិសុទ្ធិសីល )

(២៩) ក៏អាជីវបារិសុទ្ធិសីល រមែងបរិសុទ្ធបាន បើភិក្ខុមានការចិញ្ចឹមជីវិតប្រពៃ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុក ក្នុងមហាសតិបដ្ឋានសូត្រ ថា " ម្នាលភិក្ខុទាំងឡាយ ក៏ការចិញ្ចឹមជីវិតប្រពៃ ដូចម្តេច ?, ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវ័កក្នុងធម្មវិន័យនេះ លះការចិញ្ចឹមជីវិតខុស ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ

ម្នាលភិក្ខុទាំងឡាយ ! នេះតថាគតឲ្យឈ្មោះថា **សម្មាអាជីវៈ** " ៗ

ក្នុងអដ្ឋកថាមហាសតិបដ្ឋានសូត្រនោះ លោកសំដែង ថា " បទ ថា ' **មិច្ឆាអាជីវំ** ' បានដល់ ទុច្ចរិតដោយកាយវាចា ដែលឲ្យប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់បច្ច័យទាំងឡាយ មានខាទនីយៈនិងភោជនីយៈ ជាដើម ៗ បទ ថា ' **សម្មាអាជីវេន** ' គឺ ដោយអាជីវៈដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរហើយ " ៗ

(៣០) ភាវៈនៃមិច្ឆាអាជីវៈ មាន ២ យ៉ាង ដោយចំណែកជា មិច្ឆាអាជីវៈខាងផ្លូវកាយ និងខាងផ្លូវវាចា លោកសំដែងហើយ ដោយ កាយសច្ចនិងវចីសច្ច ក្នុងបទ ថា " **កាយវចីទុច្ចរិតំ** " នោះ ៗ ក៏ មិច្ឆាអាជីវៈ ទាំង ២ យ៉ាងនោះ គប្បីដឹងដោយន័យដែលលោកបាន សំដែងហើយ ក្នុងអដ្ឋកថាចម្មក្ខន្ធកៈនោះឯង ថា " អំពើទាំងឡាយ មានកិរិយាស្លប្រេង និងការស្លថ្នាំឈ្មោះអរិដ្ឋៈជាដើម ដោយអំណាច អនេសនកម្ម មានវេជ្ជកម្មដែលធ្វើឲ្យ ដល់អ្នកដែលទ្រង់ហាម ជាដើម ឈ្មោះថា មិច្ឆាអាជីវៈខាងផ្លូវកាយ ៗ កិច្ចមានការទទួល និងប្រាប់នូវ ដំណឹងជាដើម របស់ពួកគ្រហស្ថ ឈ្មោះថា មិច្ឆាអាជីវៈខាងផ្លូវវាចា " ៗ

(៣១) ភេសជ្ជៈដែលភិក្ខុធ្វើឲ្យដល់អ្នកដែលទ្រង់ហាម គឺបុគ្គល ដែលមិនទ្រង់អនុញ្ញាត ដែលត្រូវពោល ថា " បុគ្គលដទៃ " ឈ្មោះថា វេជ្ជកម្មដែលធ្វើដល់បុគ្គលដែលទ្រង់ហាម ក្នុងបទ ថា " **បដិក្ខិត្តវេជ្ជ-**

កម្មាទិវសេន " នោះ ។ ពិតយ៉ាងនោះ ព្រះអដ្ឋកថាចារ្យសំដែង ថា " ភិក្ខុមិនគួរធ្វើថ្នាំ ដល់អ្នកដទៃដែលមកហើយសូម, កាលបើធ្វើ ត្រូវអាបត្តិទុក្កដ " ដូច្នេះហើយ ទើបសំដែងពិធីវេជ្ជកម្ម ដោយពិស្តារ ក្នុងអដ្ឋកថាភេសជ្ជករណវត្ថុ តតិយបារាជិក ។ អ្នកដែលប្រាថ្នា (ចង់ដឹង) វេជ្ជកម្មពិធីនោះ គប្បីយកពីអដ្ឋកថានោះចុះ ។ ក៏សេចក្ដីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ ដូច្នេះ ÷

បុគ្គល ១០ ពួក គឺ សហធម្មិក ៥, បណ្ឌុបលាស ១, វេយ្យាវច្ចករបស់ខ្លួន ១, មាតាបិតា ២, បុគ្គលទំនុកបំរុងមាតាបិតា ១, ញាតិ ១០ ពួក គឺ បងប្រុស ១, ប្អូនប្រុស ១, បងស្រី ១, ប្អូនស្រី ១, ម្ដាយមីង ១, អ៊ុំស្រី ១, ឪពុកមា ១, ឪពុកធំ ១, ម្ដាយមីង (ខាងមាតា) ១, ឪពុកមា (ខាងមាតា) ១, បុគ្គល ៥ ពួក គឺ អ្នកដែលមកថ្មី ១, ចោរ ១, អ្នកច្បាំងចាញ់គេ ១, ឥស្សរជន ១, បុគ្គលដែលត្រូវពួកញាតិកាត់កាល់ចោលហើយត្រូវតែទៅ ១, ជាអ្នកឈឺចាប់ មកកាន់វត្ត, ភិក្ខុគប្បីធ្វើភេសជ្ជៈដល់បុគ្គលដែលទ្រង់អនុញ្ញាតទាំង ២៥ ពួកនេះ ។

(៣២) ក៏សូម្បីតែអនុជន មានកូន ចៅ ជាដើម របស់ញាតិទាំងនោះ ដែលជាប់ទាក់ទងគ្នា តាំងតែអំពីត្រកូលទី ៧ មក ក៏ឈ្មោះថាជាញាតិ របស់ភិក្ខុដូចគ្នាដែរ ព្រោះជាប់ទាក់ទងគ្នានឹងភិក្ខុនោះ ព្រោះ

ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបសង្គ្រោះកូនចៅ ជាដើមនោះផងដែរ ក្នុងពាក្យ ថា "**ទស ញាតកា**" នោះ ។ ក៏ភិក្ខុធ្វើភេសជ្ជៈដល់អ្នកទាំងនោះផង ក៏គួរ ។ ជនទាំងឡាយ គឺ ភរិយារបស់បងប្រុស - ប្អូនប្រុស, ស្វាមីរបស់បងស្រី-ប្អូនស្រី, ស្វាមីរបស់ម្ដាយមីង (ខាងម្ដាយ), ភរិយារបស់ឪពុកមា (ខាងម្ដាយ) ទាំងនេះជាដើមជាអ្នកមានជម្ងឺ, ប្រសិនបើ ជនទាំងនោះជាញាតិ (របស់ភិក្ខុ), ភិក្ខុធ្វើនូវភេសជ្ជៈ ដល់ញាតិទាំងនោះផង ក៏គួរ ។ បើសិនជា ជនទាំងនោះមិនមែនជាញាតិ, ភិក្ខុគប្បីធ្វើឲ្យដល់ញាតិទាំងឡាយ មានបងប្រុសជាដើម ដោយប្រាប់ ថា "អ្នកទាំងឡាយ ចូរឲ្យក្នុងទីប្រតិបត្តិនៃអ្នកទាំងឡាយ" ឬគប្បីឲ្យ (ភេសជ្ជៈ) ដល់កូនទាំងឡាយ របស់អ្នកទាំងនោះ ដោយប្រាប់ ថា "អ្នកទាំងឡាយ ចូរឲ្យដល់មាតាបិតា របស់ពួកអ្នកផង " ។ ចំណែក ជនដទៃក្រៅពីជនទាំងឡាយដែលពោលមកហើយនោះ ឈ្មោះថា ជនដទៃ, ភេសជ្ជៈដែលភិក្ខុធ្វើឲ្យ ដល់ជនដទៃនោះ ឈ្មោះថា វេជ្ជកម្មដែលធ្វើឲ្យដល់បុគ្គលដែលទ្រង់ហាម ។ ក៏ភិក្ខុសូម្បីកាលធ្វើភេសជ្ជៈ ឲ្យដល់បុគ្គលដែលទ្រង់អនុញ្ញាត គប្បីធ្វើឲ្យដល់បុគ្គល ១០ ពួកក្នុងខាងដើម ដោយរបស់នៃពួកជនទាំងនោះ, បើរបស់នៃពួកជនទាំងនោះ មិនមានទេ, គប្បីធ្វើឲ្យដោយរបស់ខ្លួន, បើរបស់នៃខ្លួននោះ ក៏មិនមានផងដែរ, គប្បីស្វែងរកដោយភិក្ខាចារវត្ត, បើមិនបានដោយ

អាការៈយ៉ាងនោះទេ, គប្បីស្វែងរកអំពីទីនៃញាតិ និងបុគ្គលបវារណា របស់ខ្លួនឬ ឬថារបស់ជនទាំងនោះ, សូម្បីមិនបានដោយអាការៈ យ៉ាងនោះក៏ដោយ គប្បីស្វែងរកសូម្បីដោយអកតវិញ្ញត្តិ ។ កិរិយាសូម ក្នុងទីដែលគេមិនបានធ្វើការបវារណា យ៉ាងនេះ ថា " បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ត្រូវការដោយបច្ច័យ សូមប្រាប់ចុះ " ដូច្នេះ ឈ្មោះថា **អកតវិញ្ញត្តិ** ។ ក៏ភិក្ខុកាលនឹងធ្វើឲ្យ ដល់ពួកញាតិក្រៅពីនោះ គប្បីធ្វើដោយរបស់នៃពួកគេប៉ុណ្ណោះ, បើរបស់នៃជនទាំងនោះ មិនមានទេ, គប្បីឲ្យរបស់នៃខ្លួន ឲ្យជារបស់ខ្ចី, បើជនទាំងនោះឲ្យវិញ, គប្បីទទួលយក, តែបើជនទាំងនោះ មិនបានឲ្យវិញទេ, មិនគប្បីនឹងទាមទារឡើយ, ព្រោះថា ភិក្ខុសូម្បីសូមរបស់នៃពួកញាតិហើយទទួលយក ក៏សមគួរ, ព្រោះដូច្នោះ ភិក្ខុកាលនាំចតុប្បច្ច័យ របស់ពួកញាតិទាំងនោះមក ក៏មិនជាអកតវិញ្ញត្តិ ធ្វើភេសជ្ជៈ ក៏មិនមែនជាវេជ្ជ-កម្ម ឬកាលឲ្យរបស់ដើម្បីនឹងសង្គ្រោះដល់ត្រកូល ក៏មិនមានអាបត្តិព្រោះប្រទូសរ៉ាយត្រកូល ។ តែភិក្ខុកាលបើមិនប្រាថ្នាចំពោះលាភ គប្បីធ្វើថ្នាំឲ្យដល់ជន ៥ ពួក មានជនដែលទើបនឹងមកជាដើម សូម្បីដោយរបស់នៃខ្លួន ។

(៣៣) សូម្បីក្នុងអនុដីកាវិមតិវិនោទនី លោកបានសំដែង ថា " សូម្បីភិក្ខុកាលនឹងធ្វើភេសជ្ជៈ ឲ្យដល់ជនដែលទើបមកថ្មី និងចោរ

ជាដើម មិនប្រាថ្នាលាភអំពីជនទាំងនោះដើម្បីខ្លួន គប្បីធ្វើដោយតាំងចិត្ត ថា "ឈ្មោះថាពួកមនុស្សជាអ្នកធ្វើឧបការៈដល់គ្នា" ។ ក៏បើភិក្ខុធ្វើ ដោយប្រាថ្នាផលតបមកវិញ រមែងមានទោសព្រោះអនេសនកម្ម មានវេជ្ជកម្ម និងកុលទូសនកម្មជាដើម ។ តែមិនមានទោសព្រោះធ្វើដោយតាំងចិត្ត ថា "កាលបើអាត្មាអញធ្វើឧបការៈយ៉ាងនេះ, ពួកជនទាំងឡាយដឹងគុណព្រះពុទ្ធសាសនាហើយ តែងតែជ្រះថ្លា ឬក៏ជាអ្នកធ្វើនូវឧបការៈដល់ព្រះសង្ឃ" ។

(៣៤) ភេសជ្ជៈយ៉ាងពិសេស ឈ្មោះថា **អរិដ្ឋៈ** ក្នុងបទ ថា **អរិដ្ឋបចនំ** នុំ ។ ក្នុងអដ្ឋកថាសុរាបានសិក្ខាបទ លោកសំដែង ថា "បានព្ថា ជនទាំងឡាយធ្វើថ្នាំឈ្មោះអរិដ្ឋៈ ដោយរសជាតិនៃផ្លែឈើទាំងឡាយ មានផ្លែកន្ទួតព្រៃជាដើម, ថ្នាំឈ្មោះអរិដ្ឋៈនោះ មានពណ៌ក្លិន និងរសជាតិដូចជាទឹកស្រវឹង, ប៉ុន្តែ មិនមែនជាទឹកស្រវឹងឡើយ" ។

(៣៥) របស់ណាកើតឡើង ព្រោះអាស្រ័យអនេសនកម្ម មានវេជ្ជកម្មដែលធ្វើ ដល់អ្នកដែលទ្រង់ហាមជាដើម, របស់ទាំងពួងនោះជាអកប្បិយៈទាំងអស់ ។ ដោយហេតុនោះ នៅក្នុងអដ្ឋកថាបឋមបវារណាសិក្ខាបទ លោកសំដែង ថា "អកប្បិយភោជនៈ ដែលកើតឡើងពីកុលទូសនកម្ម វេជ្ជកម្ម ការអួតឧត្តរិមនុស្សធម្ម និងអកប្បិយវត្ថុមានរូបិយៈដែលភិក្ខុត្រេកអរហើយជាដើម ឈ្មោះថាអកប្បិយភោជនៈ

ដែលកើតឡើង ព្រោះអនេសនា ដែលព្រះពុទ្ធទ្រង់តិះដៀលហើយ ”។

(៣៦) ចំណែក កម្មរបស់ភិក្ខុដែលជាទូតនៃពួកគ្រហស្ថ គប្បីជ្រាបដោយពិស្តារ ក្នុងអដ្ឋកថាកុលទូសកសិក្ខាបទចុះ ។ ចំណែកសេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានដូចតទៅនេះ ÷

ភិក្ខុទទួលក្តី ប្រាប់ក្តី នូវដំណឹង របស់បុគ្គលទាំង ៩ ពួកនេះ គឺ សហធម្មិក ៥, បណ្ឌុបលាសៈ ១, វេយ្យាវច្ចករ របស់ខ្លួន ១, និង មាតាបិតា ២ ទើបសមគួរ ។ ចំណែក របស់បុគ្គលដទៃ ជាដំណឹងដែលជាកប្បិយៈប៉ុណ្ណោះ ទើបសមគួរ ។ ព្រោះហេតុនោះ ភិក្ខុមិនត្រូវធ្វើសេចក្តីសង្ស័យ ក្នុងដំណឹងទាំងឡាយដូច្នេះ ថា “អ្នកទាំងឡាយចូរថ្វាយបង្គំព្រះបាទា នៃព្រះដ៏មានព្រះភាគ តាមពាក្យរបស់ខ្ញុំ” ដូច្នេះក្តី “អ្នកទាំងឡាយ ចូរថ្វាយបង្គំព្រះចេតិយ ព្រះបដិមាករ ដើមពោធិ៍ ព្រះសង្ឃត្ថេរ” ដូច្នេះក្តី “អ្នកទាំងឡាយ ចូរធ្វើការបូជា ដោយគ្រឿងក្រអូប និងផ្កាកម្រង ក្នុងព្រះចេតិយ” ដូច្នេះក្តី “អ្នកទាំងឡាយ ចូរឲ្យភិក្ខុទាំងឡាយ ប្រជុំគ្នា, យើងខ្ញុំទាំងឡាយ នឹងថ្វាយទាន នឹងស្តាប់ព្រះធម៌ទេសនា” ដូច្នេះក្តី ។ ព្រោះថា ដំណឹងទាំងនោះ ជាដំណឹងដែលជាកប្បិយៈ មិនជាប់ទាក់ទងនឹងគិហិកម្ម ។ ក៏ភិក្ខុរូបណា ទទួលដំណឹងដទៃក្រៅពីដំណឹងដែលជាកប្បិយៈ របស់ជនទាំងឡាយដទៃទៀតដើរទៅ, ភិក្ខុរូបនោះ ត្រូវអាបត្តិទុក្កដ គ្រប់ៗ ជំហានជើង, ភិក្ខុរូប

នោះ សូម្បីឆាន់ភោជនៈដែលបានមក ព្រោះអាស្រ័យកម្មនោះ ក៏ត្រូវអាបត្តិទុក្កដ រាល់ ៗ ប្រយោគដែលលេបចូលទៅ, ពិតមែន បច្ច័យដែលកើតឡើង ព្រោះកុលទូសកកម្ម មិនសមគួរ ដល់សហធម្មិកទាំង ៥ ជាបច្ច័យប្រាកដស្មើដោយ បច្ច័យដែលកើតឡើង ព្រោះពោលអួតនូវឧត្តរិមនុស្សធម៌ដែលមិនពិត និងផ្លាស់ប្តូរដោយរូបិយៈពិត ៗ ក៏ភិក្ខុរូបណា បរិភោគបច្ច័យដែលកើតឡើង ព្រោះអនេសនកម្ម មានទូតកម្ម និងវេជ្ជកម្មជាដើម, អាជីវៈរបស់ភិក្ខុរូបនោះ ឈ្មោះថា មិនបរិសុទ្ធ ៗ ព្រោះហេតុនោះ ភិក្ខុកាលប្រើប្រាស់ បច្ច័យដែលមានសេចក្តីកើតឡើងបរិសុទ្ធតែម្យ៉ាង គប្បីលះបង់ បច្ច័យដែលមានសេចក្តីកើតឡើង មិនបរិសុទ្ធ ដូចជាអាសិរពិស ៗ

(៣៧) ក៏បច្ច័យទាំង ២ នោះ លោកសំដែងទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា "បច្ច័យទាំងឡាយដែលកើតឡើងអំពីសង្ឃ ឬគណៈរបស់ភិក្ខុដែលមិនបានកំណត់កាន់យកនូវធុតង្គ និងកើតឡើងពីសំណាក់នៃពួកគ្រហស្ថ ដែលជ្រះថ្លា ដោយគុណទាំងឡាយ របស់ភិក្ខុរូបនោះ មានការសំដែងធម៌ជាដើម ឈ្មោះថា បច្ច័យដែលមានសេចក្តីកើតឡើងដ៏បរិសុទ្ធ, ចំណែក បច្ច័យដែលកើតឡើងអំពីសមណវត្ត មានការដើរបិណ្ឌបាតជាដើម ឈ្មោះថា បច្ច័យដែលមានសេចក្តីកើតឡើង ដ៏បរិសុទ្ធក្រៃលែងតែម្តង, បច្ច័យដែលកើតឡើងពីសមណវត្ត របស់ភិក្ខុ

ដែលកំណត់កាន់យកនូវធុតង្គ និងកើតឡើងពីសំណាក់ នៃពួកគ្រហស្ថ ដែលជ្រះថ្លាហើយ ក្នុងធុតង្គគុណរបស់ភិក្ខុនោះ ដោយអនុលោមការ កំណត់ធុតង្គ ឈ្មោះថា បច្ច័យមានសេចក្តីកើតឡើងដ៏បរិសុទ្ធ " ។

(៣៨) ន័យដែលមក ក្នុងដីកាបករណ៍វិសេសវិសុទ្ធិមគ្គនោះ ថា " ភាវៈនៃគុណមានការសំដែងធម៌ជាដើម ជាគុណជាតអាស្រ័យសេចក្តីបរិសុទ្ធិជាសមុដ្ឋាន ព្រះពុទ្ធឃោសាចារ្យសំដែងដោយពោលដល់បច្ច័យដែលមានសេចក្តីកើតឡើងដ៏បរិសុទ្ធ ព្រោះហេតុនោះ ទើបលោកសំដែង ថា '**ធម្មទេសនាទីហិ ចស្ស គុណេហិ**' ដូច្នេះ ។ ភាវៈជាពហុស្សុត ការបំពេញវត្ត និងការដល់ព្រម ដោយឥរិយាបថ ជាដើម លោកកំណត់យក ដោយអាទិស័ព្ទ ។ សូម្បីក្នុងពាក្យ ថា " **ធុតគុណេ ចស្ស** " នេះ ក៏ន័យនេះដូចគ្នាដែរ ។ មិត្រសំឡាញ់ និងវត្តមានការប្រព្រឹត្តិបំសុកូលជាដើម លោកកំណត់យកហើយ ដោយអាទិស័ព្ទ ថា " **បិណ្ឌបាតចរិយាទីហិ** " ។ បទ ថា " **ធុតង្គនិយមានុលោមេន**" គឺ ដោយអំណាចអនុលោម បានដល់ ដោយអំណាចមិនរារាំង ដល់សេចក្តីប្រតិបត្តិ ដែលនិយមតាមធុតង្គនោះ ។ " ។

(៣៩) ក៏អាជីវបារិសុទ្ធិសីល ព្រះអដ្ឋកថាចារ្យទាំងឡាយ បានសំដែង ថា " **បរិយេដ្ឋិសុទ្ធិ** " ព្រោះបរិសុទ្ធបាន ដោយការស្វែងរករបស់ភិក្ខុដែលលះបង់អនេសនាហើយ ញ៉ាំងបច្ច័យទាំងឡាយឲ្យកើត

ឡើង ដោយធម៌ ដោយស្មើ " ។

បណ្ដាបទទាំងនោះ បទ ថា " **អនេសនំ** " គឺការស្វែងរកដែលមិនសមគួរ បានដល់ ការស្វែងរកបច្ច័យដែលមិនប្រពៃ ដោយអំណាចអនេសនកម្មមានវេជ្ជកម្ម ដែលបានសំដែងមកហើយជាដើម និងដោយអំណាចវចីទុច្ចរិតមានពោលកុហកជាដើម ។ បទ ថា " **បហាយ** " ប្រែថា លះបង់ហើយ, អធិប្បាយថា មិនធ្វើ ។ ព្រោះហេតុនោះឈ្មោះថា ភិក្ខុកាលធ្វើអាជីវបារិសុទ្ធិសីល ឲ្យបរិសុទ្ធ សូម្បីអត់អាហារក៏មិនគួរញុាំងសូម្បីចិត្ត ក្នុងការស្វែងរកដែលមិនសមគួរ ឲ្យកើតឡើងឡើយ, មិនចាំបាច់ពោលដល់ការក្រវល់ក្រវាយ ខាងផ្លូវកាយ និងវាចាធ្វើអ្វី, ភិក្ខុគប្បីដូចជាព្រះមហាតិស្សត្ថេរ ដែលនៅក្នុងចិរគុម្ពវិហារ ។

## ( រឿងព្រះមហាតិស្សត្ថេរ )

(៤០) បានឮថា នៅពេលកើតទុរភិក្ស ព្រះមហាតិស្សត្ថេរនោះនិមន្តទៅកាន់ផ្លូវ មានកាយលំបាកអស់កម្លាំង ព្រោះអត់អាហារ និងព្រោះលំបាកនៅតាមផ្លូវ ទើប (ឈប់) សិងក្រោមគល់ស្វាយមួយដើមដែលមានផ្លែ ។ ផ្លែស្វាយជាច្រើន ក៏ជ្រុះធ្លាក់មក ក្នុងទីនោះ ៗ ។ គ្រានោះ មានឧបាសកចាស់ម្នាក់បានឃើញព្រះថេរៈហើយ ដឹងថាព្រះថេរៈរហិតរហៃហើយ ទើបឲ្យព្រះថេរៈឆាន់ទឹកស្វាយហើយ លើកដាក់លើ

ខ្នងរបស់ខ្លួន ហើយនាំទៅកាន់ទីលំនៅ ៗ ព្រះថេរៈ ទូន្មានខ្លួន ថា

" ឧបាសកនេះ មិនមែនជាបិតា, មិនមែនជាមាតា, មិនមែនជាញាតិ, មិនមែនជាផៅពង្ស របស់អ្នកទេ, គេធ្វើកិច្ចយ៉ាងនោះ ព្រោះហេតុតែអ្នកមានសីល "

ដូច្នេះហើយ ក៏ចំរើនវិបស្សនា នៅលើខ្នងនៃឧបាសកនោះឯង ហើយបានសម្រេចនូវព្រះអរហត្ត ៗ

រឿងព្រះមហាតិស្សត្ថេរ អ្នកឆាន់ផ្លែស្វាយ មកក្នុងដីកាបករណ៍វិសេសវិសុទ្ធិមគ្គ ៗ

(៤១) ចំណែក បច្ច័យសន្និស្សិតសីល ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដែង ថា " **បច្ចវេក្ខណសុទ្ធិ** " ព្រោះបរិសុទ្ធបាន ដោយការពិចារណា ៗ ព្រោះហេតុនោះ ភិក្ខុកាលបើឃើញព្រមនូវទោសក្នុងការបរិភោគបច្ច័យ ដែលមិនទាន់បានពិចារណា គប្បីពិចារណាបច្ច័យទាំងឡាយ ៗ

បានឮថា កាលពីដើម ពួកភិក្ខុ ភាគច្រើន មិនបានពិចារណាហើយប្រើប្រាស់បច្ច័យ ៤ ទើបមិនបានរួចផុតពីនរក និងកំណើតនៃសត្តិរច្ឆាន ៗ ព្រះសាស្ដាទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុមិនបានពិចារណា (ជាមុន)

ហើយ ប្រើប្រាស់បច្ច័យ ៤ មិនគួរ, ព្រោះហេតុនោះ តាំងពីពេលនេះតទៅ អ្នកទាំងឡាយ គប្បីពិចារណា (ជាមុន) ហើយចាំប្រើប្រាស់ " ដូច្នេះហើយ កាលទ្រង់សំដែងបច្ចវេក្ខណាវិធី ទ្រង់តាំងបែបយ៉ាងទុកដោយន័យជាអាទិ៍ ថា "ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុ ក្នុងធម្មវិន័យនេះពិចារណា ដោយបញ្ញាហើយ ទើបប្រើប្រាស់នូវចីវរ..." ដូច្នេះហើយទ្រង់ត្រាស់ (ទៀត) ថា " ឈ្មោះថា ការប្រើប្រាស់បច្ច័យដែលមិនទាន់បានពិចារណាហើយ ដូចជាការបរិភោគថ្នាំពិសដ៏ខ្លាំងក្លាពន្លឹក, សូម្បីពួកមនុស្សជំនាន់មុន មិនបានពិចារណាហើយ មិនដឹងទោស បរិភោគថ្នាំពិស បានទទួលនូវទុក្ខដ៏ធំ " ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា ÷

## ( រឿងអ្នកលេងបាសកាកោង បរិភោគថ្នាំពិស )

(៤២) ក្នុងអតីតកាល ព្រះពោធិសត្វ បានជាអ្នកលេងបាសកាមានទ្រព្យសម្បត្តិច្រើន នៅក្នុងក្រុងពារាណសី ។ គ្រានោះ អ្នកលេងបាសកាកោងម្នាក់ទៀត កំពុងលេង (បាសកា) ជាមួយនឹងព្រះពោធិសត្វនោះ, កាលជ័យជំនះមានដល់ខ្លួន, ក៏មិនបំផ្លាញវង់ល្បែង, តែនៅពេលខ្លួនបរាជ័យ ក៏ដាក់កូនបាសកាក្នុងមាត់ ហើយធ្វើជាពោលថា " កូនបាសកាបាត់ហើយ " បានទំលាយវង់ល្បែងហើយ គេចចេញទៅ ។ ព្រះពោធិសត្វ ដឹងរឿងនោះហើយ បានកាន់យកកូនបាសកា

ដើរទៅផ្ទះហើយ ជ្រលក់ដោយថ្នាំពិសដ៏ខ្លាំងក្លា ហាលហើយ ហាលទៀតឲ្យស្ងួត បានយកកូនបាសកាទាំងនោះទៅសំណាក់ នៃអ្នកលេងកូនបាសកាកោងនោះហើយលេង (ជាមួយគ្នា) ។ អ្នកលេងបាសកាកោងនោះ កំពុងតែលេង ក្នុងពេលដែលខ្លួនបរាជ័យ ក៏ញាត់កូនបាសកាមួយទៅក្នុងមាត់ហើយ បានសន្លប់ព្រោះកម្លាំងថ្នាំពិស ភ្នែកត្រឡប់ រមួលគ ដួលចុះហើយ ។ ព្រះពោធិសត្វ ប្រាថ្នានឹងឲ្យជីវិតដល់គេ ទើបបានឲ្យថ្នាំជាគ្រឿងក្អួត ដែលត្រាំដោយឱសថ ឲ្យក្អួតចេញមកហើយ បានធ្វើឲ្យគេជារោគហើយ បានឲ្យឱវាទ ថា "សូមអ្នកកុំធ្វើយ៉ាងដូច្នេះ តទៅទៀតឡើយ " ។

រឿង ការបរិភោគដោយមិនបានពិចារណា មកហើយក្នុងអដ្ឋកថាលិត្តជាតក ត្រង់ទសមវគ្គ ឯកនិបាត ។

(៤៣) ភិក្ខុទាំងឡាយ ដោយភាគច្រើន សូម្បីឯទៀត ជាអ្នកទុកចិត្ត មិនពិចារណាហើយ ប្រើប្រាស់បច្ច័យ ៤ ដែលពួកញាតិ មានមាតាបិតា បងស្រី ប្អូនស្រីជាដើម ប្រគេនហើយ ដោយតាំងចិត្ត ថា "នៅពេលដែលយើងនៅជាគ្រហស្ថក្តី នៅពេលដែលយើងជាបព្វជិតក្តី ញាតិទាំងឡាយនេះ ជាអ្នកសមគួរនឹងប្រគេន " ។ ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាភិក្ខុគួរពិចារណា (ជាមុន) ហើយ ចាំប្រើប្រាស់បច្ច័យ ៤ សូម្បីដែល

ញាតិប្រគេនហើយ, ព្រោះថា ភិក្ខុកាលបើមិនពិចារណា (ជាមុន) ហើយប្រើប្រាស់ ធ្វើមរណកាលហើយ នឹងមិនរួចផុតពីអត្តភាពនៃយក្ស និងប្រេតឡើយ, ក៏ឈ្មោះថា ការប្រើប្រាស់បច្ច័យ ដែលមិនទាន់បានពិចារណាហើយ ដូចជាការបរិភោគនូវថ្នាំពិស, ព្រោះថា ថ្នាំពិស ដែលបុគ្គលអ្នកស្និទ្ធស្នាលក្តី មិនស្និទ្ធស្នាលក្តី ឲ្យហើយ រមែងញុំាងអ្នកបរិភោគឲ្យស្លាប់បានទាំងអស់, សូម្បីក្នុងកាលមុន រាជសីហ៍មួយស៊ីថ្នាំពិសដែលបុគ្គលអ្នកស្និទ្ធស្នាលឲ្យហើយ បានដល់ហើយនូវសេចក្តីស្លាប់" ដូច្នេះហើយ ទ្រង់នាំនូវអតីតនិទានមក (សំដែង) ថា ÷

## ( រឿងរាជសីហ៍ស៊ីថ្នាំពិស )

(៤៤) ក្នុងអតីតកាល ព្រះពោធិសត្វ បានកើតជាសេដ្ឋីអ្នកមានទ្រព្យសម្បត្តិច្រើន ក្នុងក្រុងពារាណសី ។ អ្នកចិញ្ចឹមគោម្នាក់ របស់ព្រះពោធិសត្វនោះ ក្នុងសម័យដែល (ផ្លូវ) ចង្អៀតដោយស្រូវ បានគៀងគោទៅព្រៃហើយ ធ្វើរោងគោ នៅថែរក្សាក្នុងព្រៃនោះ ។ គ្រានោះ រាជសីហ៍មួយ មានចិត្តបដិព័ទ្ធក្នុងមេម្រឹគមួយ ទើបនៅក្បែររោងគោនៃបុគ្គលចិញ្ចឹមគោនោះ ។ កាលមេគោទាំងឡាយស្គាំងស្គមទៅព្រោះភ័យខ្លាចចំពោះរាជសីហ៍, ទឹកដោះក៏បានមានតិច ។ ចំណេរកាលមកខាងក្រោយ សេដ្ឋីបានដឹងរឿងនោះហើយ ទើបបង្គាប់ឲ្យបុគ្គល

អ្នកចិញ្ចឹមគោ ថា " បើដូច្នោះ អ្នកចូរចាប់មេម្រឹគនោះមក ដោយឧបាយហើយ ជ្រលក់រោមលើសរីរៈនៃមេម្រឹគនោះដោយថ្នាំពិស ហើយយកទៅហាលហើយ ហាលទៀតឲ្យស្ងួត កន្លងទៅបាន ២-៣ ថ្ងៃ ហើយចាំលែងមេម្រឹគនោះទៅ " ។ អ្នកចិញ្ចឹមគោនោះ ក៏បានធ្វើដូច្នោះ ។ រាជសីហ៍ បានឃើញមេម្រឹគនោះហើយ ក៏លិទ្ធសរីរៈមេម្រឹគនោះ ដោយសេក្តីស្នេហា ហើយបានធ្វើកាលៈទៅ ។

រឿង ការបរិភោគថ្នាំពិសដោយអំណាចសេចក្តីស្និទ្ធស្នាល មកក្នុងអដ្ឋកថាវិសុទ្ធាសភោជនជាតក ក្នុងទសមវគ្គ ឯកនិបាតដូចគ្នាដែរ ។

(៤៥) ក្នុងអដ្ឋកថាទាំងឡាយ មានអដ្ឋកថារូបិយសិក្ខាបទ ជាដើម លោកសំដែង ថា " ការបរិភោគបច្ច័យ ដែលមិនបានពិចារណារបស់ភិក្ខុអ្នកមានសីល ឈ្មោះថា បរិភោគដោយបំណុល " ។

ដីការូបិយសិក្ខាបទនោះ ថា " ដូចជា កូនបំណុល តែងមិនបានទៅកាន់ប្រទេសដែលខ្លួនប្រាថ្នាទៅ តាមសេចក្តីពេញចិត្ត របស់ខ្លួនបានយ៉ាងណា, ភិក្ខុអ្នកប្រកបដោយការបរិភោគដោយបំណុល ក៏មិនបានដើម្បីនឹងរលាស់ (ខ្លួន) ចេញផុតពីលោកបានឡើយ យ៉ាងនោះដែរ " ។

(៤៦) ព្រោះហេតុនោះ ភិក្ខុកាលឃើញទោស ដូចបានពោលមកហើយ គប្បីពិចារណាបច្ច័យទាំងឡាយដោយពិត ៗ ប៉ុន្តែ បើនឹងពិចារណា គប្បីពិចារណា ក្នុងកាលទាំង ៣ ។ ក្នុងកាលទាំង ៣ នោះ

ក្នុងកាលដែលកំពុងបានឬកំពុងទទួល ភិក្ខុគប្បីពិចារណា សូម្បីមួយគ្រា ដោយធាតុប្បច្ចវេក្ខណៈ ជាអាទិ៍ ថា "សំពត់ចីវរឯណានេះ, សំពត់ចីវរនុ៎ះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ..." ដូច្នេះ ក៏បាន ដោយបដិកូលបច្ចវេក្ខណៈជាអាទិ៍ ថា "ក៏សំពត់ចីវរទាំងឡាយ ទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ..." ដូច្នេះ ក៏បាន ។ មែនពិត ការបរិភោគប្រើប្រាស់បច្ច័យដែលបានពិចារណា យ៉ាងនោះហើយ រក្សាទុក បន្ទាប់ពីការបានមក គ្មានទោសឡើយ ដូចជាការប្រើប្រាស់នូវបាត្រនិងចីវរ ដែលបានអធិដ្ឋានហើយ រក្សាទុកយ៉ាងនោះ ។ ការពិចារណាក្នុងកាលដែលបាននោះ ជាការសំដែងនូវសេចក្ដីបរិសុទ្ធិពង៏ខាងដើម នៃសតិគ្រឿងពិចារណាជាត្រីមុខ, មិនមែនហាមឃាត់ការពិចារណា ក្នុងកាលបរិភោគប្រើប្រាស់ជាត្រីមុខឡើយ, ហេតុនោះ ភិក្ខុគួរពិចារណា ក្នុងកាលបរិភោគប្រើប្រាស់ ម្ដងទៀត ។ ក៏ក្នុងកាលដែលបរិភោគប្រើប្រាស់នោះ ភិក្ខុគប្បីពិចារណា ព្រមដោយការបរិភោគ ដោយតំខណិកប្បច្ចវេក្ខណៈ ជាអាទិ៍ ថា "អាត្មាអញពិចារណា ដោយឧបាយហើយ ទើបបរិភោគប្រើប្រាស់នូវសំពត់ចីវរនេះ..." ដូច្នេះ ។

(៤៧) ក៏ក្នុងអដ្ឋកថាទាំងឡាយ លោកសំដែង ថា "សំពត់ចីវរ ភិក្ខុគប្បីពិចារណា រាល់ៗខណៈដែលបរិភោគប្រើប្រាស់, បិណ្ឌបាត ភិក្ខុគប្បីពិចារណា រាល់ៗពំនូត, សេនាសនៈ ភិក្ខុគប្បីពិចារណា

រាល់ ៗ ខណៈដែលបរិភោគប្រើប្រាស់ ” ដូច្នេះ ។

ក្នុងដីកាបករណ៍វិសេសវិសុទ្ធិមគ្គ លោកសំដែង ថា “ សំពត់ចីវរ ភិក្ខុគប្បីពិចារណា ក្នុងខណៈដែលដោះចេញពីកាយហើយ បរិភោគប្រើប្រាស់, សេនាសនៈ ភិក្ខុគប្បីពិចារណា រាល់ ៗ ខណៈដែលបរិភោគប្រើប្រាស់ គឺ រាល់ ៗ ខណៈដែលចូលទៅ ” ។

ចំណែក ក្នុងអនុដីកាវិមតិវិនោទនី នៃរូបិយសិក្ខាបទ លោកបាន សំដែង ថា “បទ ថា **បរិភោគេ** គឺក្នុងខណៈដែលដោះចេញអំពីកាយ ហើយបរិភោគប្រើប្រាស់ ។ បទ ថា **បរិភោគេ** គឺក្នុងខណៈដែល ចូលទៅឰដ៏ខាងក្នុង អំពីជម្រៀងផ្ទះ និងខណៈដែលអង្គុយ និងដេក ” ។

(៤៨) ប្រសិនបើ ភិក្ខុណា មិនអាចដើម្បីពិចារណា ក្នុងកាល ដែលកំពុងបរិភោគប្រើប្រាស់បានទេ, ក្នុងកាលជាខាងក្រោយ អំពីកាល ដែលបរិភោគប្រើប្រាស់ ភិក្ខុនោះ គប្បីពិចារណាសូម្បីមួយដង ដោយ អតីតបច្ចវេក្ខណៈ ជាអាទិ៍ ថា “ សំពត់ចីវរ ឯណា ដែលអាត្មាអញ មិនបានពិចារណាហើយ ប្រើប្រាស់ហើយ ក្នុងថ្ងៃនេះ...” ដូច្នេះ ។

ក៏ក្នុងដីកាបករណ៍វិសេសវិសុទ្ធិមគ្គ លោកសំដែង ថា “ ភិក្ខុបើ មិនអាចពិចារណាបាន យ៉ាងនោះទេ គប្បីពិចារណា មួយថ្ងៃ ៤ ដង ៣ ដង ២ ដង ឬ ១ ដង ក៏បានដែរ ដោយអំណាចកាលវិសេសដែល បានពោលមកហើយ ” ដូច្នេះ ។

(៤៩) បណ្ដាបទទាំងនោះ បទ ថា " **តថា** " មានសេចក្ដីថា ដើម្បីពិចារណា ក្នុងកាលដែលបរិភោគប្រើប្រាស់ ៗ មុនពេលឆាន់ក្ដី ក្រោយពេលឆាន់ហើយក្ដី យាម ៣ នៃរាត្រីក្ដី ក្រៅអំពីកាលបរិភោគប្រើប្រាស់ ឈ្មោះថា កាលវិសេសតាមដែលបានពោលរួចមកហើយ ៗ ក៏អតីតប្បច្ចវេក្ខណៈនេះ សមគួរ ក្នុងបច្ច័យដែលសេសសល់ទាំងឡាយ ៗ ចំណែក ភេសជ្ជៈ ក្នុងបដិលាភកាល ភិក្ខុពិចារណាក្ដី មិនពិចារណាក្ដី ក្នុងកាលដែលកំពុងបរិភោគប្រើប្រាស់ ត្រូវតែពិចារណាឲ្យបានតែម្ដង ៗ ដោយហេតុនោះ ក្នុងអដ្ឋកថាទាំងឡាយ លោកសំដែង ថា " ភាវៈជាអ្នកមានសតិជាបច្ច័យ ទាំងក្នុងកាលដែលទទួល ទាំងក្នុងកាលដែលប្រើប្រាស់ភេសជ្ជៈ ទើបសមគួរ, សូម្បីកាលបើមានភាវៈជាអ្នកមានសតិជាបច្ច័យ យ៉ាងនោះ, បើភិក្ខុធ្វើសតិ ក្នុងកាលទទួល មិនធ្វើក្នុងកាលបរិភោគប្រើប្រាស់សោះ ត្រូវអាបត្តិ, តែ ភិក្ខុមិនធ្វើសតិ ក្នុងកាលទទួលធ្វើ ក្នុងកាលបរិភោគប្រើប្រាស់ មិនត្រូវអាបត្តិ " ៗ

(៥០) អនុដីកាវិមតិវិនោទនី ថា " ពាក្យថា '**សតិបច្ចយតាវដ្ដតិ**' មានសេចក្ដីថា ភិក្ខុបានភាវៈដែលសតិ ជាគ្រឿងពិចារណា ជាបច្ច័យ ទើបសមគួរ ៗ ព្រះអដ្ឋកថាចារ្យ សំដែង ថា 'ភិក្ខុគួរបានសតិជាគ្រឿងពិចារណា ទាំងក្នុងកាលដែលកំពុងទទួល ទាំងក្នុងកាលដែលបរិភោគប្រើប្រាស់ ដោយពិត' ៗ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ

ពោល ថា ‘ ធ្វើសតិ ’ ដូច្នេះ ជាដើម ” ។

សូម្បី ក្នុងដីកាបករណ៍ វិសេសវិសុទ្ធិមគ្គ លោកក៏បានពោល ថា ដូច្នោះដែរ ហើយពោលយ៉ាងនេះទៀត ថា “ពាក្យថា **ឯវំ សន្តេបិ** មាន សេចក្តីថា សតិជាគ្រឿងពិចារណា ក្នុងឋានៈទាំង ២ សមគួរហើយ ក៏ពិតមែន, សូម្បីកាលបើមានភាវៈជាអ្នកមានសតិជាបច្ច័យយ៉ាងនោះ ក៏ដោយ ។ ចំណែក អាចារ្យពួកខ្លះ បានពោល ថា “ បទ ថា **សតិបច្ចយតា** គឺ បើភាវៈនៃសតិជាបច្ច័យ អធិប្បាយថា បើបច្ច័យ នៃ ការបរិភោគប្រើប្រាស់ភេសជ្ជៈមាន ។ ពាក្យថា “ **ឯវំ សន្តេបិ** ” គឺសូម្បីបើបច្ច័យមាន ។ ពាក្យនោះ គ្រាន់តែជាមតិនៃអាចារ្យទាំង នោះ ។ ពិតមែនយ៉ាងនោះ បច្ចយសន្និស្សិតសីល រមែងបរិសុទ្ធបាន ព្រោះសតិជាគ្រឿងពិចារណា, មិនមែនបរិសុទ្ធបាន ដោយហេតុត្រឹមតែ ការកើតឯងនៃបច្ច័យឡើយ ” ។

ក្នុងអនុដីកាវិមតិវិនោទនី លោកពោល ថា “ ក៏ក្នុងពាក្យថា **សតិ បច្ចយតា** ដូច្នេះ, អាចារ្យពួកខ្លះ ពោលសេចក្តីថា ‘បទ ថា **សតិ បច្ចយតា** គឺ បើបច្ច័យមាន គឺបើហេតុនៃការបរិភោគភេសជ្ជៈមាន យ៉ាងនេះក៏មាន ’ ។ គប្បីកាន់យកសេចក្តី នៃអាចារ្យពួកខ្លះទាំងនោះ យ៉ាងនេះ ថា ‘បទថា **បច្ចយេ** គឺ បើលក្ខណៈសភាវៈ បច្ច័យមាន ដូច្នេះ ព្រោះសីល មិនបរិសុទ្ធបាន ដោយហេតុត្រឹមតែការកើតឯង នៃបច្ច័យ ។

គប្បីជ្រាបនូវការធ្វើផ្សេងៗគ្នា នៃការខាតសីលទាំងនេះ យ៉ាងនេះ គឺដោយពាក្យថា **បរិភោគេ អកវោន្តស្សេវ អាបត្តិ** នេះ ព្រះអដ្ឋកថាចារ្យ សំដែងការខាតនៃបាដិមោក្ខសំវរសីល, មិនបានសំដែងការខាតនៃបច្ចយសន្និស្សិតសីលឡើយ ព្រោះបច្ចយសន្និស្សិតសីលនោះ បរិសុទ្ធបាន ដោយសតិជាគ្រឿងពិចារណាបច្ច័យដែលកន្លងទៅហើយ, ក៏ព្រះអដ្ឋកថាចារ្យ សំដែងការខាត នៃបច្ចយសន្និស្សិតសីលនោះឯង ក្នុងភេសជ្ជៈនុ៎ះ និងក្នុងបច្ច័យដែលសេសសល់ ដោយពោលដល់ការបរិភោគដោយបំណាល ជាដើម ” ។

(៥១) ក៏ក្នុងការខាត និងមិនខាត នៃបាដិមោក្ខសំវរសីលនោះ មានសេចក្ដីសន្និដ្ឋាន ដូចតទៅនេះ “ តំខណិកប្បច្ចវេក្ខណៈ ក្នុងភេសជ្ជៈរមែងរក្សាសីលបាន សូម្បីទាំង ២ ប្រការ ចាកការខាត, ចំណែកអតីតប្បច្ចវេក្ខណៈ ក្នុងភេសជ្ជៈនោះ រមែងរក្សាបានតែបច្ចយសន្និស្សិតសីល ម្យ៉ាងប៉ុណ្ណោះ ។ បច្ចវេក្ខណៈទាំង ២ ប្រការ ក្នុងបច្ច័យដែលសេសសល់ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ប្រសិនបើ ភិក្ខុធ្វើនូវតំខណិកប្បច្ចវេក្ខណៈ ក្នុងបច្ច័យទាំង ៤ ហើយនោះ, សូម្បីជាមិនធ្វើនូវអតីតប្បច្ចវេក្ខណៈ ក៏សមគួរ ។ ប្រសិនបើ ភិក្ខុមិនបានធ្វើតំខណិកប្បច្ចវេក្ខណៈទេ, ក៏គួរធ្វើនូវអតីតប្បច្ចវេក្ខណៈ ដោយពិត ដើម្បីជម្រះសីលក្រៅអំពីនេះ ឲ្យបានបរិសុទ្ធ ។ ក៏បាដិមោក្ខសំវរសីល ដែលខាត

ព្រោះហេតុតែមិនបានធ្វើតំខណិកប្បច្ចវេក្ខណៈ ក្នុងភេសជ្ជៈ រមែងបរិសុទ្ធបាន ដោយការសំដែង (អាបត្តិចេញ) ។ ប្រសិនបើ ភិក្ខុមិនបានធ្វើបច្ចវេក្ខណៈ សូម្បីណាមួយឡើយ ក្នុងចតុប្បច្ច័យហើយ ញុំាងអរុណឲ្យរះឡើងមក, សីលតែងខាត ដោយន័យដែលពោលមកហើយ, ហើយភិក្ខុនោះឈ្មោះថា តាំងនៅ ក្នុងឋានៈនៃការបរិភោគដោយបំណុល " ។

(៥២) ក៏ភិក្ខុ អ្នកបំពេញបច្ចយសន្និស្សិតសីល គប្បីដូចជាភាគិនេយ្យសង្ឃរក្ខិតសាមណេរ ។ ក៏ភាគិនេយ្យសង្ឃរក្ខិតសាមណេរនោះ ពិចារណា ដោយត្រឹមត្រូវហើយ ទើបបរិភោគប្រើប្រាស់ ។ ព្រោះហេតុនោះ ភាគិនេយ្យសង្ឃរក្ខិតសាមណេរនោះ បានពោល ថា

" ព្រះឧបជ្ឈាយ៍ ប្រាប់ខ្ញុំអ្នកឆាន់បាយស្រូវសាលី ដែលត្រជាក់ល្អក ថា ' នែសាមណេរ អ្នកកុំជាអ្នកមិនសង្រួមហើយ ញុំាងអណ្ដាតរបស់ខ្លួន ឲ្យភ្លើងឆេះឡើយ ' ។ ខ្ញុំបានស្ដាប់ពាក្យរបស់ព្រះឧបជ្ឈាយ៍ហើយ បានសេចក្ដីសង្វេគតក់ស្លុត ក្នុងកាលនោះ គង់លើអាសនៈតែមួយ បានសម្រេចហើយនូវព្រះអរហត្ត, ខ្ញុំនោះ មានសេចក្ដីត្រិះរិះបរិបូណ៌ហើយ បីដូចជាព្រះចន្ទ ថ្ងៃពេញបូរមី មានអាសវៈទាំងពួងអស់ហើយ, ឥឡូវនេះ ភពថ្មីលែងមាន ទៀតឡើយ " ។

ព្រះសង្ឃរក្ខិតត្ថេរ ជាឪពុកមា របស់សាមណេរនោះឯង ឈ្មោះថា ព្រះឧបជ្ឈាយ៍ ក្នុងគាថានោះ ។ បទ ថា "**សាលិកុរំ**" ប្រែថា បាយស្រូវសាលី ។ បទ ថា "**សុនិពុតំ**" ប្រែថា ត្រជាក់ល្អ ។ លោកពោល ថា "**អសញ្ញតោ**" ដូច្នេះ សំដៅយកការមិនពិចារណា ។

ព្រោះហេតុនោះ កុលបុត្រដទៃទៀត កាលប្រាថ្នាសេចក្ដីអស់ទៅនៃទុក្ខ គប្បីពិចារណា ដោយធ្វើទុកក្នុងចិត្ត (ជាមុន) ហើយទើបបរិភោគនូវបច្ច័យទាំងឡាយ ដូច្នេះ ។

អនាគារិយវិន័យ ពោលគឺចតុប្បារិសុទ្ធិសីល រមែងឈ្មោះថាជាវិន័យ គឺបព្វជិតអ្នកធ្វើសីលឲ្យបរិសុទ្ធ សិក្សាល្អហើយ យ៉ាងនេះ ដូចបានពណ៌នាមកហើយនុ៎ះឯង, អនាគារិយវិន័យនោះ ជាវិន័យអាច ដើម្បីនឹងនាំមក សូម្បីផលដ៏ប្រសើរ ដល់បព្វជិតនោះ ដូចព្រះតិស្សត្ថេរ អ្នកអាស្រ័យនៅក្នុងញកភ្នំ យ៉ាងនោះឯង ។

រឿងព្រះថេរៈនោះ គប្បីទាញយកមក អំពីគាថាវណ្ណនា ក្នុងព្រាហ្មណវគ្គ ថា "**អសំសដ្ឋំ គហដ្ឋេហិ...**" ដូច្នេះ ជាដើមចុះ ។

## ( អាគារិយវិន័យ )

(៥៣) ការវៀរចាក អកុសលកម្មបថ ១០ ប្រការ ឈ្មោះថា

អាគារិយវិន័យ (វិន័យរបស់គ្រហស្ថ) ។ អាគារិយវិន័យនោះ ឈ្មោះថា គឺគ្រហស្ថសិក្សាល្អហើយ ព្រោះមិនត្រូវទោសគ្រឿងសៅហ្មង ក្នុងអកុសលកម្មបថ ១០ ប្រការនោះ និងព្រោះធ្វើខ្លួនឲ្យតាំងនៅក្នុងគុណគឺមារយាទ ឈ្មោះថា ជាមង្គល ព្រោះនាំប្រយោជន៍សុខមកផ្ដល់ឲ្យ ក្នុងលោកទាំង ២ ។

## ( អកុសលកម្មបថ ១០ ប្រការ )

ក្នុងអាគារិយវិន័យនោះ បាបធម៌ទាំងឡាយនេះ គឺ បាណាតិបាត, អទិន្នាទាន, កាមេសុមិច្ឆាចារ, មុសាវាទ, បិសុណវាចា, ផរុសវាចា, សម្ផប្បលាបៈ, អភិជ្ឈា, ព្យាបាទ, មិច្ឆាទិដ្ឋិ ឈ្មោះថា អកុសលកម្មបថ ១០ ប្រការ ។ ក្នុងអកុសលកម្មបថ ១០ ប្រការនោះ បាណាតិបាត លោក បានពណ៌នាហើយ ដោយពិស្ដារ ក្នុងអដ្ឋកថាតតិយបារាជិក ។ អទិន្នាទាន លោកបានពណ៌នាហើយ ក្នុងអដ្ឋកថាទុតិយបារាជិក ។ កាមេសុ មិច្ឆាចារ លោកបានពណ៌នាហើយ ក្នុងអដ្ឋកថាសញ្ចរិតសិក្ខាបទ និងក្នុងអដ្ឋកថាសង្គីតិសូត្រ ក្នុងបាដិកវគ្គ ។ អកុសលកម្មបថ ៧ ប្រការ ខាងដើម លោកពណ៌នាហើយ ក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ។ អកុសលកម្មបថ ៣ ប្រការ ខាងចុង លោកពណ៌នាទុក ក្នុងអដ្ឋកថាសង្គីតិសូត្រ និងក្នុងអដ្ឋកថាសាលេយ្យកសូត្រ ក្នុងមូលបណ្ណាសកៈ ។ អកុសលកម្មបថ ទាំង ១០ ប្រការ លោកពណ៌នាទុកហើយ ក្នុង

អដ្ឋកថាសម្មាទិដ្ឋិសូត្រនុ៎ះឯង និងក្នុងអដ្ឋកថាអដ្ឋសាលិនី ៗ ព្រោះហេតុនោះ ខ្ញុំនឹងទាញយកន័យដែលលោកពោលហើយ ក្នុងអដ្ឋកថានោះ ៗ មកហើយ ពណ៌នាកម្មបថកថា ។

## ( បាណាតិបាត )

(៥៤) ចេតនាអ្នកសម្លាប់ របស់បុគ្គលអ្នកមានសេចក្ដីសំគាល់ក្នុងសត្វមានជីវិត ថាសត្វមានជីវិត ដែលញ៉ាំងសេចក្ដីព្យាយាមជាហេតុចូលទៅកាត់ផ្ដាច់ នូវជីវិតិន្ទ្រីយ៍ឲ្យតាំងឡើង ដែលប្រព្រឹត្តទៅខាងផ្លូវកាយនឹងវាចា ផ្លូវណាមួយ ឈ្មោះថា បាណាតិបាត បណ្ដាអកុសលកម្មបថ ១០ ប្រការនោះ ៗ ក៏ពាក្យថា " **បាណៈ** " ក្នុងបទថា **បាណាតិបាតោ** នេះ ដោយវោហារ បានដល់សត្វ, ដោយបរមត្ថ បានដល់ជីវិតិន្ទ្រីយ៍ ២ ប្រការ ។

ពិតមែនហើយ សូម្បីក្នុងអដ្ឋកថាគតិយបារាជិក លោកពោល ថា " រូបជីវិតិន្ទ្រីយ៍ និងអរូបជីវិតិន្ទ្រីយ៍ ឈ្មោះថា ជីវិតិន្ទ្រីយ៍ ។ កាលបើរូបជីវិតិន្ទ្រីយ៍ កំរើកហើយ, សូម្បីអរូបជីវិតិន្ទ្រីយ៍ក្រៅនេះ ក៏កំរើកដែរ ព្រោះជាប់ទាក់ទងជាមួយគ្នា នឹងអរូបជីវិតិន្ទ្រីយ៍នោះ " ។

## ( ទោសរបស់បាណាតិបាត )

បណ្ដាសត្វមានជីវិតដែលប្រាសចាកគុណ មានសត្វតិរច្ឆានជាដើម

បាណាតិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះសត្វតូច, ឈ្មោះថាមានទោសច្រើន ព្រោះសត្វធំ ៗ ព្រោះហេតុអ្វី ? ។ ព្រោះប្រយោគធំ ៗ សូម្បីមានប្រយោគស្មើគ្នា ក៏ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុធំ ៗ បណ្ដាសត្វដែលមានគុណ មានមនុស្សជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ព្រោះសត្វមានគុណតូច, ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានគុណធំ ៗ កាលបើភាវៈនៃសរីរៈ និងគុណ មានស្មើគ្នា, ក៏ឈ្មោះថា មានទោសតិច ព្រោះភាវៈនៃកិលេស និងសេចក្ដីព្យាយាមទន់ខ្សោយ, ឈ្មោះថា មានទោសច្រើន ព្រោះភាវៈនៃកិលេស និងសេចក្ដីព្យាយាមខ្លាំងក្លា ។

(៥៥) ក្នុងដីកាព្រហ្មជាលសូត្រ លោកពោល ថា "គប្បីជ្រាបភាវៈ នៃបាណាតិបាតនោះ ឈ្មោះថា មានទោសច្រើន ព្រោះបច្ច័យទាំងឡាយ មានភាវៈនៃប្រយោគ និងវត្ថុធំជាដើម ហេតុតែភាវៈនៃចេតនាដែលកើតឡើង ព្រោះបច្ច័យទាំងនោះមានកម្លាំង ។ មែនពិត ភាវៈនៃប្រយោគ ឈ្មោះថាធំ ក៏ដោយអំណាចចេតនាជាហេតុឲ្យសម្រេច ដែលញ៉ាំងកិច្ចឲ្យសម្រេច ដោយអំណាចញ៉ាំងប្រយោគ តាមដែលបុគ្គលអ្នកសម្លាប់ប្រាថ្នា ឲ្យសម្រេចទៅ យ៉ាងឆាប់រហ័ស និងដែលមានអាសេវនៈដែលបានហើយ អំពីជវនចិត្តដែលប្រព្រឹត្តទៅ ច្រើនលើកច្រើនគ្រា ។ សូម្បីកាលបើភាវៈនៃប្រយោគ មានស្មើគ្នា ព្រោះសត្វតូចក្ដី ព្រោះ

សត្វធំក្តី ក្នុងកាលខ្លះ ចេតនារបស់អ្នកសម្លាប់សត្វធំ រមែងកើតឡើង យ៉ាងខ្លាំងក្លា ព្រោះហេតុនោះ វត្ថុទើបឈ្មោះថាធំ ៗ ប្រយោគនិង វត្ថុសូម្បីទាំង ២ យ៉ាងនោះ នឹងឈ្មោះថាធំ ក៏ដោយភាវៈនៃចេតនា មានកម្លាំងតែម្យ៉ាង ដោយប្រការៈដូច្នេះ ៗ បើភាវៈនៃសត្វដែលត្រូវ គេសម្លាប់ មានគុណច្រើន យ៉ាងដូច្នោះ (គឺចេតនារបស់អ្នកសម្លាប់ កើតឡើងខ្លាំងក្លា) ៗ សូម្បីចេតនាមិនមានឧបការៈ ដើម្បីញ៉ាំង ខេត្តវិសេសឱ្យសម្រេច រមែងកើតឡើងមានកម្លាំង និងខ្លាំងក្លា ដូចជា ចេតនាមានឧបការៈក្នុងសត្វដែលមានគុណនោះ ព្រោះហេតុនោះ គប្បី ឃើញភាវៈនៃបាណាតិបាតនោះ មានទោសច្រើន ៗ ព្រោះហេតុនោះ សូម្បីកាលបើភាវៈនៃបច្ច័យ មានប្រយោគនិងវត្ថុជាដើមមិនធំ, គប្បី ជ្រាបភាវៈនៃបាណាតិបាត ឈ្មោះថាមានទោសច្រើន ក៏ដោយអំណាច ភាវៈនៃចេតនា ឈ្មោះថាមានកម្លាំង ព្រោះបច្ច័យមានភាវៈនៃសត្វដែល ត្រូវគេសម្លាប់មានគុណច្រើនជាដើម ជាដើមអាទិ៍នុ៎ះឯង " ៗ

ដីកាសម្មាទិដ្ឋិសូត្រ ថា " គប្បីជ្រាបភាវៈនៃបាណាតិបាត ឈ្មោះថា មានទោសច្រើន ព្រោះបច្ច័យទាំងឡាយមានភាវៈនៃប្រយោគ និងវត្ថុធំ ជាដើម ហេតុតែចេតនាដែលកើតឡើង ព្រោះបច្ច័យនោះ ៗ ជារបស់ មានកម្លាំង ៗ (សេចក្តីដូចគ្នានឹងព្រហ្មជាលសូត្រ) ៗល។ សូម្បី ប្រយោគនិងវត្ថុទាំង ២ យ៉ាងនោះ នឹងឈ្មោះថាធំ ក៏ដោយភាវៈនៃ

ចេតនាមានកម្លាំងតែម្យ៉ាង ដោយប្រការដូច្នេះ ៗ ហេតុនោះ គប្បីជ្រាបភាវៈនៃបាណាតិបាត មានទោសច្រើន ព្រោះភាវៈនៃចេតនា មានកម្លាំង ព្រោះបច្ច័យនោះ ៗ សូម្បីក្នុងបរិយាយដែលខុសចាកពីបច្ច័យតាមដែលបានពោលមកហើយ ៗ មែនពិត សូម្បីបើមានបច្ច័យទាំងឡាយ មានប្រយោគ និងវត្ថុជាដើមមិនធំ, ភាវៈនៃបាណាតិបាត នឹងឈ្មោះថាមានទោសច្រើន ក៏ព្រោះភាវៈនៃសត្វដែលត្រូវគេសម្លាប់ជាសត្វមានគុណ និងឈ្មោះថា មានទោសតិច ក៏ព្រោះខុសប្លែកចាកអំពីនោះ, គប្បីឃើញដូចជាបាណាតិបាតដែលឈ្មោះថា មានទោសច្រើន និង មានទោសតិច ព្រោះវត្ថុធំនិងមិនធំ ៗ គប្បីប្រកបភាវៈ នៃបាណាតិបាតឈ្មោះថា មានទោសតិច ព្រោះកិលេស សេចក្ដីព្យាយាម និង ទាំង ២ យ៉ាង ទន់ខ្សោយ និងឈ្មោះថា មានទោសច្រើន ព្រោះកិលេស សេចក្ដីព្យាយាម និង ទាំង ២ យ៉ាង ខ្លាំងក្លា " ៗ

## ( អង្គនៃបាណាតិបាត )

(៥៦) បាណាតិបាតនោះ មានអង្គ ៥ គឺ សត្វមានជីវិត ១ សេចក្ដីសម្គាល់ថា សត្វមានជីវិត ១ ចិត្តជាហេតុគិតនឹងសម្លាប់ ១ សេចក្ដីព្យាយាម ១ សត្វស្លាប់ ព្រោះសេចក្ដីព្យាយាមនោះ ១ ៗ

ក្នុងដីកាព្រហ្មជាលសូត្រជាដើម លោកពោល ថា "ភាវៈជាអ្នក

សម្គាល់ថា សត្វមានជីវិត និងចិត្តគិតនឹងសម្លាប់ រមែងជាអង្គខាងដើម, សេចក្តីព្យាយាម ជាសភាពញ៉ាំងវធកចេតនាឲ្យតាំងឡើង ។ ព្រោះចេតនាដែលជាហេតុធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង មានអង្គ ៥ ហេតុនោះ បាណាតិបាតចេតនានោះ គប្បីឃើញថា មិនផុតស្រឡះចាកអង្គ ៥ ” ។

( អទិន្នាទាន )

(៥៧) ចេតនាជាហេតុគិតនឹងលួច របស់បុគ្គលអ្នកមានសេចក្តីសម្គាល់ ក្នុងវត្ថុដែលអ្នកដទៃហួងហែងរក្សា ថាជាវត្ថុដែលអ្នកដទៃហួងហែងរក្សាហើយ ដែលញ៉ាំងសេចក្តីព្យាយាម ជាហេតុកាន់យកនូវវត្ថុដែលអ្នកដទៃហួងហែង រក្សានោះឲ្យតាំងឡើង ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ឈ្មោះថា អទិន្នាទាន ។ ភណ្ឌៈ គឺជនដទៃ គឺម្ចាស់របស់ភណ្ឌៈទាំងឡាយ ហួងហែងរក្សាហើយ មិនលះបង់ឲ្យថែរក្សា គ្រប់គ្រងទុកហើយ មិនបានឲ្យដោយកាយ ឬវាចា របស់ខ្លួន ឈ្មោះថា វត្ថុដែលអ្នកដទៃហួងហែងរក្សាហើយ ក្នុងពាក្យថា “ **បរបរិគ្គហិតេ បរបរិគ្គហិតសញ្ញិនោ** ” នោះ ។

( ទោសនៃអទិន្នាទាន )

អទិន្នាទាននោះ ឈ្មោះថា មានទោសតិច ព្រោះវត្ថុនៃជនដទៃ

ថោកទាប ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុនៃជនដទៃ ប្រណីត ៗ ព្រោះហេតុអ្វី ? ។ ព្រោះវត្ថុប្រណីត ។ សូម្បីកាលបើវត្ថុស្មើគ្នា, ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុ នៃជនអ្នកមានគុណធំ, ឈ្មោះថា មានទោសតិច ព្រោះវត្ថុនៃជនអ្នកមានគុណថោកទាប ជាងបុគ្គលអ្នកមានគុណធំនោះៗ ព្រោះប្រៀបផ្ទឹមនឹងបុគ្គលអ្នកមានគុណធំនោះ ៗ ។ ម្យ៉ាងទៀត អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះវត្ថុនៃជនដទៃតូចតាច, ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុនៃជនដទៃធំ ។ ព្រោះហេតុអ្វី ? ។ ព្រោះប្រយោគធំ ។ ក៏សូម្បីកាលបើភាវៈ នៃវត្ថុនិងគុណ ស្មើគ្នា, អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះកិលេសនិងសេចក្តីព្យាយាមទន់ខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេសនិងសេចក្តីព្យាយាមខ្លាំងក្លា " ។

## ( អង្គនៃអទិន្នាទាន )

អទិន្នាទាននោះ មានអង្គ ៥ គឺ វត្ថុដែលអ្នកដទៃហួងហែងរក្សា ១ ភាវៈជាអ្នកមានសេចក្តីសម្គាល់ថា ជារបស់ដែលអ្នកដទៃហួងហែងរក្សា ១ ចិត្តគិតនឹងលួច ១ សេចក្តីព្យាយាម ១ លួចបានមកដោយសេចក្តីព្យាយាមនោះ ១ ។

## ( កាមេសុ មិច្ឆាចារៈ )

(៥៨) ក៏ក្នុងអដ្ឋកថាសង្គីតិសូត្រ លោកពោល ថា "បទ ថា **កាមេសុ** គឺក្នុងមេថុនសមាចារ ម្យ៉ាងទៀត ក្នុងសត្វដែលជាទីតាំងនៃមេថុនធម៌ទាំងឡាយ ។ មារយាទដ៏លាមក ដែលបណ្ឌិតតិះដៀលហើយដោយចំណែកមួយ ឈ្មោះថា មិច្ឆាចារ ។ ក៏ដោយលក្ខណៈ ចេតនាជាហេតុកន្លងនូវឋានៈ ដែលបុគ្គលមិនគប្បីដល់ ដែលប្រព្រឹត្តទៅខាងកាយទ្វារ ដោយបំណងអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** " ។

ដីកាសង្គីតិសូត្រនោះ ថា "បទ ថា **មេថុនសមាចារេសុ** បានដល់ ក្នុងមេថុនសមាចារ ២ យ៉ាង ដោយអំណាចការសន្ថោស ដោយភរិយារបស់ខ្លួន និងការគប់រកដោយភរិយានៃជនដទៃ ។ ក៏មេថុនសមាចារ ទាំង ២ យ៉ាងនោះ ឈ្មោះថា កាម ព្រោះជាធម៌ដែលបុគ្គលគប្បីត្រេកត្រអាល ។ ក្នុងពពួកសត្វដែលជាវត្ថុនៃមេថុនធម៌ ។ មារយាទដែលបណ្ឌិតគប្បីតិះដៀល ឈ្មោះថា មិច្ឆាចារ ។ ភាវៈនៃមិច្ឆាចារនោះ ឈ្មោះថា គឺបណ្ឌិតគប្បីតិះដៀល ព្រោះភាវៈនៃមិច្ឆាចារនោះ ជាធម៌ដ៏លាមក ដោយចំណែកមួយប៉ុណ្ណោះ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា 'មារយាទដ៏អាក្រក់លាមក ដែលបណ្ឌិតតិះដៀល ដោយចំណែកមួយ' ។ បទ ថា "**អសទ្ធម្មាធិប្បាយេន**"

គឺ ដោយបំណង ក្នុងការសេពអសទ្ធម្ម " ។

ស្ត្រី ២០ ពួក មានស្ត្រីដែលមាតារក្សាជាដើម ឈ្មោះថា អគមនីយដ្ឋានរបស់ពួកបុរស ក្នុងបទ ថា **អគមនីយដ្ឋានវីតិក្កមចេតនា** នោះ ។ ស្ត្រី ២០ ពួកនោះ នឹងមានប្រាកដ នៅក្នុងមង្គល ថា " **ការសង្គ្រោះ បុត្រនិងភរិយា**..." នុ៎ះ ។

ព្រោះហេតុនោះ ក្នុងអនុដីកាវិមតិវិនោទនី នៃសញ្ចរិត្ត-សិក្ខាបទ លោកពោល ថា " មែនពិត បុរសទាំងឡាយ តែងមិនបាន គប់រកនូវស្ត្រី ដែលអ្នកគ្រប់គ្រងណាមួយ គ្រប់គ្រង រក្សាហើយ, ព្រោះហេតុនោះ កាលបុរសទាំងនោះ គប់រក ក្នុងស្ត្រី ៨ ពួក មាន ស្ត្រីដែលមាតារក្សាហើយជាដើម ទើបជាមិច្ឆាចារពិត ព្រោះស្ត្រី ទាំងនោះ គឺអ្នកគ្រប់គ្រងរក្សាហើយ ដោយប្រការដែលពួកនាង នឹង សម្រេចការនៅរួមជាមួយនឹងបុរសមិនបាន ។ កាលពួកបុរសដល់ ក្នុងស្ត្រី ១២ ពួកក្រៅពីស្ត្រី ៨ ពួកនោះ ជាមិច្ឆាចារ (ដូចគ្នាដែរ) ព្រោះចូលទៅ ក្នុងឋានៈដែលមិនមែនជារបស់ខ្លួន ដែលបុគ្គលដទៃ ហាមប្រាមហើយ " ។

ដីកាសារត្ថទីបនី ថា " ជាមិច្ឆាចារ ព្រោះស្ត្រីទាំងនោះ ត្រូវ បុរសលួចយកផស្សៈ ដែលជនដទៃរក្សា គ្រប់គ្រង ប៉ះពាល់ហើយ " ។

(៥៩) ក៏ក្នុងស្ត្រី ២០ ពួក ពួកបុរសដទៃ ឈ្មោះថា ជា

អគ្គមនីយដ្ឋាន របស់ស្ត្រី ១២ ពួក មានស្ត្រីដែលមានការរក្សាជាដើម ៗ ព្រោះថា ពួកស្ត្រីដែលបុរសណាមួយ យកដោយភាវៈជាភរិយាប៉ុណ្ណោះ តែងមិនបានដើម្បីនឹងគប់រកនូវបុរសដទៃ, ព្រោះហេតុនោះ ស្ត្រី ១២ ពួកទាំងនោះប៉ុណ្ណោះ ឈ្មោះថាជាមិច្ឆាចារ ក្នុងការគប់រកបុរសដទៃ ព្រោះខ្លួនជាអ្នកមានស្វាមី ៗ មែនពិតពួកស្ត្រីទាំងនោះ លួចផស្សៈដែលជារបស់ស្វាមីហើយ ញាំងសេចក្តីត្រេកអរក្រៃលែងឲ្យកើតឡើង ដល់ពួកបុរសដទៃ ព្រោះហេតុនោះ ស្ត្រីទាំងនោះ ទើបជាមិច្ឆាចារ ៗ ចំណែក ស្ត្រី ៨ ពួកក្រៅពីនេះ មានស្ត្រីដែលមាតារក្សាជាដើម ឈ្មោះថាមិនមែនជាមិច្ឆាចារ ក្នុងការគប់រកបុរសដទៃ ព្រោះខ្លួនមិនទាន់មានស្វាមី ៗ ម្យ៉ាងទៀត ស្ត្រីទាំងនោះ មិនឈ្មោះថាជាមិច្ឆាចារ ព្រោះភាវៈនៃស្ត្រីទាំងនោះ មានផស្សៈ ដែលបុរសណាមួយ ហួងហាមមិនបាន និងព្រោះភាវៈនៃខ្លួនជាម្ចាស់នៃផស្សៈខ្លួនឯង ៗ ក៏អ្នកគ្រប់គ្រងទាំងឡាយ មានមាតាជាដើម ថែរក្សាស្ត្រីទាំងនោះ ដើម្បីនឹងរមិលមើលនូវផស្សៈនៃស្ត្រីទាំងនោះ ដោយខ្លួនឯង ក៏មិនមែនដែរ, អ្នកគ្រប់គ្រងទាំងនោះការពារនូវអនាចារ តែម្យ៉ាង ទើបហាមការគប់រកនូវបុរសដទៃ នៃស្ត្រីទាំងនោះ, ព្រោះហេតុនោះ អ្នកគ្រប់គ្រងទាំងឡាយ មានមាតាជាដើម ទើបមិនឈ្មោះថា ជាធំលើផស្សៈនៃស្ត្រីទាំងនោះឡើយ" ៗ

## ( ទោសនៃកាមេសុមិច្ឆាចារ )

កាមេសុមិច្ឆាចារនោះ ឈ្មោះថា មានទោសតិច ព្រោះអគ្គមនីយដ្ឋាន ដែលប្រាសចាកគុណមានសីលជាដើម, ឈ្មោះថាមានទោសច្រើន ព្រោះអគ្គមនីយដ្ឋានដែលដល់ព្រមដោយគុណមានសីលជាដើម ៗ ម្យ៉ាងទៀត កាមេសុមិច្ឆាចារ ដែលបុគ្គលប្រព្រឹត្តរំលោភ សូម្បីក្នុងអគ្គមនីយដ្ឋាន ដែលប្រាសចាកគុណ ក៏ឈ្មោះថាមានទោសច្រើន ៗ សូម្បីបើជនទាំង ២ នាក់នោះ មានឆន្ទៈរួមគ្នា, កាមេសុមិច្ឆាចារនោះ ក៏ឈ្មោះថាមានទោសតិច ព្រោះកិលេសនិងសេចក្ដីព្យាយាមទន់ខ្សោយ, ឈ្មោះថាមានទោសច្រើន ព្រោះកិលេសនិងសេចក្ដីព្យាយាមខ្លាំងក្លា ៗ

## ( អង្គនៃកាមេសុមិច្ឆាចារ )

កាមេសុមិច្ឆាចារនោះ មានអង្គ ៤ គឺ វត្ថុដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ១ ចិត្តគិតនឹងសេពមេថុនធម៌ក្នុងវត្ថុដែលមិនគួរគប់រក គឺស្ត្រីនោះ ១ សេចក្ដីព្យាយាមក្នុងការសេព ១ ញុំាងមគ្គឲ្យដល់មគ្គហើយឈប់នៅ ១ ៗ

(៦០) ក្នុងដីកាព្រហ្មជាលសូត្រ លោកពោល ថា " អាចារ្យពួកខ្លះ ពោល ថា 'សូម្បីមានការញុំាងមគ្គឲ្យដល់មគ្គឈប់នៅ ក្នុង

ការប្រព្រឹត្តិរំលោភកន្លងលើ, បុរសត្រូវស្ត្រីរំលោភលើ មិនចាត់ជាមិច្ឆាចារទេ ព្រោះមិនមានសេចក្ដីព្យាយាមជាប់គគ្នា ក្នុងការសេពដែលកើតឡើងជាមុន ៗ អាចារ្យមួយពួកទៀត ពោល ថា បើមានចិត្តគិតនឹងសេព, សេចក្ដីព្យាយាមមិនមាន មិនជាប្រមាណព្រោះភាគច្រើន ស្ត្រីមិនមានសេចក្ដីព្យាយាមក្នុងការសេព, បើមានយ៉ាងដូច្នោះ, សូម្បីស្ត្រីមានចិត្តគិតនឹងសេពប្រាកដឡើងមុនគេក៏មិនគប្បីជាមិច្ឆាចារ ព្រោះមិនមានសេចក្ដីព្យាយាមក្នុងការសេព ៗ ព្រោះហេតុនោះ គប្បីឃើញសន្និដ្ឋាន ថា 'អង្គ ៤ យ៉ាង លោកពោល យ៉ាងឧក្រិដ្ឋ ដោយអំណាចបុរស' យ៉ាងដូច្នេះ ដោយមានបំណង ថា 'បើនឹងកាន់យកដោយប្រការៈដទៃវិញ នៅពេលដែលស្ត្រីធ្វើនាទីជាបុរស សូម្បីបុរសក៏មិនគប្បីជាមិច្ឆាចារដែរ ព្រោះមិនមានសេចក្ដីព្យាយាមក្នុងការសេព' ៗ ក៏ក្នុងអធិការនៃអង្គនៃកាមេសុមិច្ឆាចារនេះ មានសន្និដ្ឋាន ដូចតទៅនេះ ÷

មិច្ឆាចារដែលឲ្យប្រព្រឹត្តទៅ តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន មានអង្គ ៣ ដែលឲ្យប្រព្រឹត្តទៅ ដោយពលការ មានអង្គ ៣ ហេតុនោះ គប្បីឃើញ ថា មានអង្គ ៤ ព្រោះកាន់យកដោយមិនមានសេសសល់ " ដូច្នេះ ៗ

អដ្ឋកថាឥតិវុត្តកៈ ថា " ក្នុងមិច្ឆាចារទាំងនោះ មិច្ឆាចារ

ដែលឲ្យប្រព្រឹត្តទៅ តាមសេចក្តីគាប់ចិត្ត របស់ខ្លួន មានអង្គ ៣, ដែលឲ្យប្រព្រឹត្តទៅ ដោយពលការ មានអង្គ ៣, ហេតុនោះ គប្បីឃើញថា មានអង្គ ៤ ព្រោះកាន់យកមិនឲ្យមានសេសសល់ ។ តែដោយអង្គ ៣ យ៉ាងប៉ុណ្ណោះ ក៏សម្រេចប្រយោជន៍បានដែរ ”។

## ( កាយកម្មដែលប្រព្រឹត្តទៅតាមទ្វារទាំង ២ )

(៦១) ន័យដែលមកក្នុងអដ្ឋកថា អដ្ឋសាលិនី ថា “ ក៏កម្ម តាមដែលពោលមកនោះ ជាកាយកម្ម ៣ យ៉ាង ។ ក្នុងកាយកម្ម ៣ យ៉ាងនោះ កាយកម្ម ២ យ៉ាង មានបាណាតិបាតជាដើម ប្រព្រឹត្តទៅខាងកាយទ្វារ និងវចីទ្វារ មិច្ឆាចារ ប្រព្រឹត្តទៅខាងកាយទ្វារ ។ ក៏កាយកម្ម ដែលជាអកុសល រមែងកើតឡើង ក្នុងកាយទ្វារ និង វចីទ្វារ, មិនមែនកើតឡើងក្នុងមនោទ្វារទេ ។ មែនពិត កាលបើ បុគ្គលសម្លាប់សត្វ កាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ ដោយដៃ របស់ខ្លួន ប្រព្រឹត្តមិច្ឆាចារ, សូម្បីកម្ម ក៏ជាកាយកម្ម, សូម្បីទ្វារ ក៏ជាកាយទ្វារ ។ តែកាលបើបុគ្គលបញ្ជា ថា “ចូរអ្នកទៅផ្តាច់ផ្តិល បុគ្គលមានឈ្មោះយ៉ាងនេះ ចាកជីវិត, អ្នកចូរលួច នូវភណ្ឌៈមាន ឈ្មោះយ៉ាងនេះមក ” កម្ម ជាកាយកម្ម, ចំណែក ទ្វារ ជាវចីទ្វារ ។ កាយកម្ម ដែលជាអកុសល រមែងកើតឡើង ក្នុងកាយទ្វារ និង

វចីទ្វារនោះឯង ដោយប្រការដូច្នេះ ។ ចំណែក អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងជាបក្ខពួកនៃចេតនាខ្លះ ជាធម្មជាតិមិនប្រកបដោយការហៅខ្លះ ” ។

(៦២) ដីកានៃអដ្ឋកថាអដ្ឋសាលិនីនោះ ថា “ អកុសលធម៌មានអភិជ្ឈាជាដើម ឈ្មោះថាប្រព្រឹត្តទៅ ក្នុងបក្ខពួកនៃចេតនា ដោយអំណាចសេចក្ដីខ្វល់ខ្វាយ ដែលប្រព្រឹត្តទៅ ថា ‘ សត្វទាំងនេះ ចូរក្ដៅក្រហាយ ’ ដូច្នេះជាដើម ព្រោះបានវោហារថា កាយកម្មខ្លះ, ឈ្មោះថា ជាធម្មជាតិមិនប្រកបដោយការហៅខ្លះ ព្រោះវៀរចាកវោហារថា មនោកម្មខ្លះ, ក្នុងរឿងនុ៎ះ សភាវៈទាំងឡាយ មានអាបោធាតុជាដើម ក្នុងធាតុទាំងឡាយ មានបឋវីធាតុ ដែលផ្សំគ្នាជាដើម ជាឧទាហរណ៍ ” ។

អនុដីកា នៃអដ្ឋកថាអដ្ឋសាលិនីនោះ ថា “ សេចក្ដីខ្វល់ខ្វាយ ដែលប្រព្រឹត្តទៅ ជាកម្មបថ ដោយប្រការណា, ដើម្បីនឹងសំដែងនូវប្រការនោះ ទើបលោកសំដែងសេចក្ដីប្រព្រឹត្តទៅ នៃសេចក្ដីខ្វល់ខ្វាយ ថា ‘ សត្វទាំងនេះ ចូរក្ដៅក្រហាយ ’ ដូច្នេះ ជាដើម ។ អកុសលធម៌មានអភិជ្ឈាជាដើម ឈ្មោះថា ប្រព្រឹត្តទៅក្នុងបក្ខពួកនៃចេតនា ព្រោះបានវោហារ ថា កាយកម្ម ព្រោះភាវៈនៃចេតនាដែលប្រព្រឹត្តទៅខាងកាយទ្វារ ជាហេតុធ្វើរួមគ្នាជាប្រក្រតី ។ ឈ្មោះថា

ជាធម្មជាតិមិនប្រកបដោយការហៅខ្លះ ព្រោះប្រាសចាកវោហារថា មនោកម្ម ព្រោះភាវៈនៃអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើម មិនប្រព្រឹត្តទៅ ដោយអំណាចបង្អោនរបស់នៃបុគ្គលដទៃមក ដើម្បីខ្លួន និងដោយសេចក្ដីខ្វល់ខ្វាយ ថា 'សត្វទាំងនេះ ចូរក្ដៅក្រហាយ" ដូច្នេះ ជាដើម ៗ ម្យ៉ាងទៀត អកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ឈ្មោះថាជាអព្វោហារិក ដោយអំណាចកាយកម្ម មានបាណាតិបាតជាដើម, អធិប្បាយ ថា ' អកុសលធម៌មានអភិជ្ឈាជាដើមនោះ គឺអ្នកណាមួយ មិនគួរពោល ដោយភាវៈនៃកាយកម្មមានបាណាតិបាតជាដើម ' ព្រោះគ្មានចេតនាដោយពិតប្រាកដ ៗ បទ ថា " ឯត្ថ " ប្រែថា ក្នុងភាវៈនៃអកុសលធម៌មានអភិជ្ឈាជាដើម ដែលប្រព្រឹត្តទៅក្នុងបក្ខពួកនៃចេតនា ជាអព្វោហារិក " ៗ

កថាសំដែងអំពីកាយកម្ម ចប់ ។

## វចីកម្ម

## ( មុសាវាទ )

(៦៣) វចីបយោគ ឬកាយបយោគ ដែលកាច់បំផ្លាញនូវប្រយោជន៍ របស់បុរសអ្នកពោលឲ្យខុសផ្លាតជាត្រីមុខ ឈ្មោះថា មុសាវាទ ៗ

បណ្ដាពាក្យទាំងនោះ ពាក្យ ថា " ដែលកាច់បំផ្លាញនូវប្រយោជន៍ " លោកពោលហើយ ដើម្បីសំដែងនូវមុសាវាទ ដែលដល់ភាពជាកម្មបថ ។ លោកសំដែងភាវៈនៃមុសាសព្ទ ជាប្រធាននៃកិរិយា ដោយសព្ទមានវចីប្រយោគជាដើម ។ ចេតនារបស់បុគ្គលនោះ ដែលញុំាងកាយប្រយោគនិងវចីប្រយោគដែលជាគ្រឿងពោលឲ្យខុសផ្លាតដល់បុគ្គលដទៃ ឲ្យតាំងឡើង ដោយបំណងនឹងពោលឲ្យខុសផ្លាត ហៅថា មុសាវាទ ព្រោះវិគ្រោះ ថា " បុគ្គលរមែងពោលមុសា ដែលជាប្រយោគតាមដែលពោលហើយ គឺឲ្យអ្នកដទៃដឹងច្បាស់នូវមុសា ឬញុំាងមុសាឲ្យតាំងឡើង ដោយចេតនានុ៎ះ " ។ ក៏ សេចក្ដីបំណងនឹងពោលឲ្យខុសផ្លាត តែងបាន ទាំងក្នុងខណៈជាខាងដើម (គឺមុននឹងនិយាយ) ទាំងក្នុងខណៈនោះ (គឺក្នុងពេលកំពុងតែនិយាយ) ។ មែនពិត ព្រះឧបាលីពោលពាក្យនេះ ថា " មុន (ពេលនិយាយ) ភិក្ខុមានសេចក្ដីដឹងខ្លួន ថា 'អាត្មាអញនឹងពោលមុសា' កាលកំពុងនិយាយ រមែងមានសេចក្ដីដឹងខ្លួន ថា 'អាត្មាអញកំពុងពោលមុសា" ដូច្នេះ ។ សេចក្ដីដឹងខ្លួនទាំង ២ យ៉ាងនុ៎ះឯង ជាអង្គ, ចំណែក អង្គក្រៅអំពីនេះ នឹងមានក្ដី មិនមានក្ដី, រឿងនុ៎ះ មិនមែនជាហេតុ ។

(៦៤) ន័យម្យ៉ាងទៀត ។ រឿងដែលមិនពិត មិនប្រាកដ

ឈ្មោះថា មុសា ។ កិរិយាញុាំងអ្នកដទៃឲ្យដឹងនូវរឿងដែលមិនពិតនោះ ដោយភាវៈជារឿងពិត រឿងប្រាកដ ឈ្មោះថា វាទៈ ។ ក៏ចេតនា ដែលញុាំងវិញ្ញត្តិយ៉ាងនោះ ឲ្យតាំងឡើង របស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងញុាំងអ្នកដទៃឲ្យដឹងនូវរឿង ដែលមិនពិត ដោយភាវៈជារឿងពិត ហៅថា មុសាវាទ ព្រោះវិគ្រោះ ថា " ពាក្យកុហក ដែលបុគ្គលតែងពោល គឺនិយាយ ដោយចេតនានុ៎ះ " ។ ក៏ក្នុងមុសាវាទនុ៎ះ គប្បីឃើញសន្និដ្ឋាន ថា " លោកពោលន័យទី ២ ដើម្បីសំដែងនូវលក្ខណៈនោះ ឲ្យបរិបូណ៌ ព្រោះភាវៈនៃលក្ខណៈនៃមុសាវាទ ក្នុងន័យមុន មិនទាន់ជ្រួតជ្រាប និងព្រោះភាវៈនៃមុសាវាទស័ព្ទ មានស័ព្ទដែលប្រាប់សេចក្តី ដែលគប្បីពោលឲ្យខុសផ្លាត " ។

## ( ទោសនៃមុសាវាទ )

មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលមុសាវាទីបុគ្គលបំបាក់តូច, ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ ដែលមុសាវាទីបុគ្គលបំបាក់ច្រើន ។ ម្យ៉ាងទៀត ឈ្មោះថា មានទោសតិច ព្រោះភាវៈនៃបុគ្គល ដែលត្រូវមុសាវាទីបុគ្គលបំបាក់ប្រយោជន៍នោះ ជាអ្នកមានគុណតិច, ឈ្មោះថា មានទោសច្រើន ព្រោះភាវៈនៃបុគ្គលនោះ ជាអ្នកមានគុណច្រើន ។

ឈ្មោះថា មានទោសតិច ព្រោះកិលេសទន់ខ្សោយ, ឈ្មោះថាមាន ទោសច្រើន ព្រោះកិលេសខ្លាំងក្លា ។

(៦៥) ន័យមួយទៀត ។ សម្រាប់ពួកគ្រហស្ថ មុសាវាទ ដែលប្រព្រឹត្តទៅ ដោយន័យជាដើម ថា " មិនមាន " ព្រោះភាវៈ ជាអ្នកមិនប្រាថ្នាដើម្បីនឹងឲ្យវត្ថុរបស់ខ្លួន ឈ្មោះថាមានទោសតិច, មុសាវាទ ដែលមុសាវាទីបុគ្គលជាសាក្សី ពោលដើម្បីបំបាក់នូវ ប្រយោជន៍ ឈ្មោះថាមានទោសច្រើន ។ សម្រាប់ពួកបព្វជិត មុសាវាទដែលប្រព្រឹត្តទៅ ដោយបូរណកថាន័យជាដើម ថា " ថ្ងៃ នេះ ប្រេងក្នុងផ្ទះ ហូរទៅទល់នឹងទន្លេ " ព្រោះបានប្រេងនិងទឹក ដោះ តិចតួចហើយ ប្រាថ្នាសើចលេង ឈ្មោះថាមានទោសតិច, តែ មុសាវាទ របស់ពួកបព្វជិតទាំងនោះ អ្នកពោលនូវវត្ថុដែលខ្លួនមិនបាន ឃើញនុ៎ះឯង ដោយន័យជាអាទិ៍ ថា " ពួកយើងឃើញ " ឈ្មោះថា មានទោសច្រើន ។ កថាដែលប្រព្រឹត្តទៅ ដោយអំណាចធ្វើរឿង ដែលខ្វះខាត ព្រោះតិចតួច ឲ្យពេញ ឈ្មោះថា បូរណកថា ។ វចីភេទ ដែលប្រព្រឹត្តទៅ ព្រោះភាវៈជាអ្នកមិនប្រាថ្នានឹងឲ្យនូវវត្ថុ របស់ខ្លួនក្តី ដោយបូរណកថាន័យក្តី ឈ្មោះថាមុសាវាទ របស់ មុសាវាទីបុគ្គល អ្នកប្រាថ្នានឹងពោលឲ្យខុសផ្លាតជាខាងដើម ក៏ពិត មែនហើយ, ទោះជាយ៉ាងនោះក៏ដោយ ចេតនាក្នុងមុសាវាទនោះ

ជាធម្មជាតិមិនមានកម្លាំង ព្រោះហេតុនោះ ទើបលោកពោល ថា មានទោសតិច ។

មុសាវាទនោះ មានអង្គ ៤ គឺ រឿងមិនពិត ១ ចិត្តគិតនឹងពោលឲ្យខុស ១ សេចក្ដីព្យាយាមដែលកើតអំពីចិត្តនោះ ១ អ្នកដទៃដឹងរឿងនោះ ១ ។

បណ្ដាបទទាំងនោះ បទ ថា "**តជ្ជោ**" គឺសមគួរដល់ចិត្តនោះ, អធិប្បាយថា សមគួរដល់ការពោលឲ្យខុសផ្ទាត ។ ដោយបទ ថា "**វាយាមោ**" លោកពោលនូវប្រយោគ ដោយលើកវាយាមៈជាប្រធាន ។ លោកពោលថា អ្នកដទៃដឹងរឿងនោះ ជាអង្គមួយ ព្រោះ សូម្បីកាលបើមុសាវាទីបុគ្គល ធ្វើសេចក្ដីព្យាយាម ដោយប្រាថ្នានឹងពោលឲ្យខុស, តែបើអ្នកដទៃ មិនដឹងរឿងនោះហើយ ការពោលឲ្យខុសក៏មិនសម្រេចដែរ ។ ចំណែក អាចារ្យពួកខ្លះពោល ថា "មុសាវាទ មានអង្គ ៣ គឺ ពាក្យមិនពិត ១ ចិត្តគិតនឹងពោលឲ្យខុស ១ អ្នកដទៃដឹងរឿងនោះ ១ " ។

## ( បិសុណាវាចា )

(៦៦) ចេតនា របស់បុគ្គលអ្នកមានចិត្តសៅហ្មងហើយ ដែលញ៉ាំងកាយប្រយោគ និងវចីប្រយោគឲ្យតាំងឡើង ដើម្បីបំបែក

ដល់ជនដទៃក្តី ដើម្បីប្រាថ្នានឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់ នៃជនដទៃក្តី ឈ្មោះថា បិសុណវាចា ព្រោះវិគ្រោះ ថា " បិសុណវាចីបុគ្គល រមែងពោលពាក្យស៊កសៀត ដោយចេតនានុ៎ះ " ។

បណ្តាបទទាំងនោះ បទ ថា " **សង្កិលិដ្ឋចិត្តស្ស** " បានដល់ របស់អ្នកដែលមានចិត្ត ត្រូវលោភៈ ឬទោសៈ ដុតរោលរាលហើយ, អធិប្បាយថា របស់អ្នកដែលមានចិត្តត្រូវលោភៈ ឬទោសៈប្រទូស-រ៉ាយហើយ ។

## ( ទោសនៃបិសុណាវាចា )

បិសុណវាចានោះ ឈ្មោះថា មានទោសតិច ព្រោះភាវៈនៃបុគ្គលដែលត្រូវបិសុណវាចីបុគ្គល ធ្វើនូវការបំបែកគ្នា ជាអ្នកមានគុណតូច, ឈ្មោះថា មានទោសច្រើន ព្រោះភាវៈនៃបុគ្គលនោះជាអ្នកមានគុណច្រើន ។ ម្យ៉ាងទៀត បិសុណវាចីបុគ្គល ធ្វើជនណាមួយឲ្យបែកគ្នា អំពីជនណាមួយ, បើជនទាំង ២ នាក់នោះមិនបែកគ្នាទេ, បិសុណវាចានោះ ឈ្មោះថា មានទោសតិច, បើជនទាំង ២ នាក់នោះបែកគ្នា, ឈ្មោះថា មានទោសច្រើន ។ មួយទៀត បិសុណវាចានោះ ឈ្មោះថាមានទោសតិច និងមានទោសច្រើន ព្រោះសេចក្តីផ្សេងគ្នានៃភាវៈ នៃកិលេសទាំងឡាយជាធម្មជាត ទន់ខ្សោយ និងខ្លាំងក្លា ។

## ( អង្គនៃបិសុណវាចា )

បិសុណវាចានោះ មានអង្គ ៤ គឺ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ១ ភាវៈជាអ្នកប្រាថ្នាដើម្បីនឹងបំបែក ដោយបំណង ថា " ជនទាំងនេះ ជាអ្នកបែកផ្សេង ៗ គ្នា ដោយឧបាយយ៉ាងនេះ " ដូច្នេះ ជាត្រីមុខ ឬ ភាវៈជាអ្នកប្រាថ្នា ដើម្បីនឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់ ដោយបំណង ថា "អញនឹងជាទីស្រឡាញ់ ជាអ្នកស្និទ្ធស្នាល ដោយឧបាយយ៉ាងនេះ " ដូច្នេះ ១ សេចក្ដីព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ ១ អ្នកដទៃដឹងរឿងនោះ ១ ។

បណ្ដាអង្គទាំងនោះ ដោយអង្គ ថា " **តទត្ថវិជ្ជាននំ** " ដូច្នេះ លោកសំដែង ថា " បិសុណវាចីបុគ្គល បង្ហាននាំពាក្យស៊កសៀតទៅដល់អ្នកណា, អ្នកនោះ បែកបាក់គ្នាក្ដី មិនបែកបាក់គ្នាក្ដី, កិរិយាញុំាងអ្នកដទៃ ឲ្យដឹងនូវរឿងនោះឯង គឺជាប្រមាណ " ។ ប៉ុន្ដែ បើអ្នកដទៃ មិនបែកបាក់គ្នាទេ, ការខាតនៃកម្មបថ ក៏មិនមាន, (លុះត្រាតែ) បើអ្នកដទៃនោះ បែកបាក់គ្នា, ការខាតនៃកម្មបថ នឹងមាន ។

## ( ផរុសវាចា )

(៦៧) ចេតនាដ៏អាក្រក់ដោយចំណែកមួយ ដែលញុំាងកាយប្រយោគនិងវចីប្រយោគ ដែលជាហេតុកាត់ផ្ដាច់នូវពាក្យជាទី

ស្រឡាញ់ នៃជនដទៃឲ្យតាំងឡើង ឈ្មោះថា ផរុសវាចា ព្រោះ វិគ្រោះ ថា “ផរុសវាចីបុគ្គល ពោលពាក្យអាក្រក់ ដោយចេតនានុ៎ះ”

ក្នុងដីកាព្រហ្មជាលសូត្រ លោកពោល ថា “បើពាក្យមិនស្មាំស្មើទាំងឡាយណា គ្រាន់តែត្រូវផរុសវាចាពាល់ត្រូវហើយ, ចិត្តដែលទោសៈប្រទូសរ៉ាយ និងសេចក្តីមិនគាប់ចិត្តប៉ះទង្គិចត្រូវហើយ ជាធម្មជាតប្រសប់សេចក្តីទុក្ខហួសពីប្រមាណ, ពាក្យមិនស្មាំស្មើនោះ ឈ្មោះថាពាក្យជាទីស្រឡាញ់ ។ ក៏ពាក្យជាទីស្រឡាញ់ទាំងនោះ គឺជាអ្វី ? ។ គឺអក្កោសវត្ថុទាំងឡាយ មានជាតិជាដើម ។ ពាក្យជាទីស្រឡាញ់ទាំងនោះ ខាតក្តី បែកបាក់គ្នាក្តី ដោយកាយប្រយោគនិងវចីប្រយោគណា, កាយប្រយោគនិងវចីប្រយោគនោះ ឈ្មោះថា ជាហេតុកាត់ផ្តាច់នូវពាក្យជាទីស្រឡាញ់”។

(៦៨) សួរ ថា “ក៏ចេតនាដែលអាក្រក់ដោយចំណែកមួយរមែងមាន ដូចម្តេច ?” ។ ឆ្លើយ ថា “រមែងមាន ព្រោះជាអ្នកមានចិត្តត្រូវទោសៈប្រទូសរ៉ាយហើយ” ។ ដើម្បីនឹងប្រកាសភាវៈជាអ្នកមានចិត្ត ត្រូវទោសៈប្រទូសរ៉ាយ នឹងសំដែងរឿងនេះដូចតទៅនេះ ÷

បានឮថា ក្មេងម្នាក់ មិនជឿពាក្យម្តាយហើយ ចូលទៅក្នុងព្រៃ ។ ម្តាយកាលមិនអាចដើម្បីនឹងញាំងក្មេងនោះឲ្យត្រឡប់មក

វិញបាន ទើបជេរ ថា "សូមមេក្របីកាច ដេញតាម(ផល់)វា" ។ គ្រានោះ មេក្របីក្នុងព្រៃ ប្រាកដដល់ក្មេងនោះ យ៉ាងដូច្នោះឯង ។ ក្មេង បានធ្វើសច្ចកិរិយា ថា "ម្ដាយរបស់ខ្ញុំ ពោលរឿងណា ដោយមាត់, សូមរឿងនោះកុំបីមាន, ម្ដាយរបស់ខ្ញុំគិតរឿងណា ដោយចិត្ត, សូមរឿងនោះកើតមានឡើង" ។ មេក្របី បានឈរនៅ (នឹង) ដូចជាគេចង ក្នុងទីនោះឯង ។

វចីប្រយោគ សូម្បីជាហេតុកាត់ផ្ដាច់ នូវពាក្យជាទីស្រឡាញ់ យ៉ាងដូច្នោះ ក៏មិនទាន់ឈ្មោះថាជាផរុសវាចា ព្រោះភាវៈជាអ្នកមានចិត្តទន់ ។ មែនពិត ពេលខ្លះ មាតាបិតា តែងនិយាយ នឹងកូនទាំងឡាយ យ៉ាងនេះ ថា "ពួកចោរ ចូរធ្វើ ពួកគេ ឲ្យកើតជាកំណាត់តូច-ធំ" ប៉ុន្តែ មាតាបិតា មិនប្រាថ្នា សូម្បីឲ្យត្របកនៃផ្កាឧប្បល ធ្លាក់មកលើកូនទាំងនោះឡើយ ។ ម្យ៉ាងទៀត ពេលខ្លះ អាចារ្យ និងព្រះឧបជ្ឈាយ៍ទាំងឡាយ តែងនិយាយនឹងពួកនិស្សិត យ៉ាងនេះ ថា "ពួកនិស្សិតទាំងនេះ ជាអ្នកមិនមានហិរិ មិនមានឱត្តប្បៈ និយាយរឿងអ្វី, អ្នកទាំងឡាយ ចូរបណ្ដេញពួកគេចេញទៅ" ដូច្នេះ, ប៉ុន្តែ អាចារ្យនិងព្រះឧបជ្ឈាយ៍ទាំងនោះ តែងប្រាថ្នានូវសេចក្ដីដល់ព្រម ដោយបរិយត្តិបដិបត្តិនិងបដិវេធ ដើម្បីពួកនិស្សិតទាំងនោះ ។

(៦៩) ចំណែក ក្នុងដីកាព្រហ្មជាលសូត្រ លោកពោល ថា “ វចីប្រយោគ ដែលប្រព្រឹត្តទៅ ព្រោះភាវៈជាអ្នកមានចិត្តទន់ មិនឈ្មោះ ថាជាផរុសវាចាឡើយ ព្រោះមិនទាន់ដល់ភាវៈជាកម្មបថ, ប៉ុន្តែគ្មានអ្នកណាមួយ អាចហាមភាវៈជាកម្មបានឡើយ ” ។

ដូចជា វចីប្រយោគដែលប្រព្រឹត្តទៅ ដោយភាវៈជាអ្នកមានចិត្តទន់ មិនឈ្មោះថាជាផរុសវាចា យ៉ាងណា, វចីប្រយោគដែលប្រព្រឹត្តទៅ ដោយភាវៈជាអ្នកមានពាក្យសំដីទន់ភ្លន់ មិនឈ្មោះថាជាផរុសវាចា ក៏មិនបានដែរ យ៉ាងនោះ ។ មែនពិត ពាក្យសំដីរបស់អ្នកដែលប្រាថ្នាចង់ឲ្យគេស្លាប់ ថា “ អ្នកទាំងឡាយ ចូរញុំាងអ្នកនេះ ឲ្យដេកជាសុខចុះ ” ដូច្នេះ មិនឈ្មោះថា ផរុសវាចា ក៏មិនបានដែរ, តាមពិត វាចានោះគឺជាផរុសវាចាដោយពិត ព្រោះភាវៈជាអ្នកមានចិត្តអាក្រក់ ។

## ( ទោសនៃផរុសវាចា )

ផរុសវាចានោះ ឈ្មោះថាមានទោសតិច ព្រោះបុគ្គលដែលត្រូវផរុសវាចីបុគ្គល ប្រាថ្នាដល់ ឲ្យប្រព្រឹត្តទៅ ជាអ្នកមានគុណតិច, ឈ្មោះថាមានទោសច្រើន ព្រោះអ្នកនោះ ជាអ្នកមានគុណច្រើន ។ម្យ៉ាងទៀត ផរុសវាចាដែលមិនដល់ភាវៈជាកម្មបថ ឈ្មោះថាមាន

ទោសតិច, ដែលដល់ភាវៈជាកម្មបថ ឈ្មោះថាមានទោសច្រើន ។ ម្យ៉ាងទៀត ផរុសវាចា ឈ្មោះថាមានទោសតិចនិងមានទោសច្រើន ព្រោះសេចក្តីខុសផ្សេងគ្នានៃកិលេសទន់ខ្សោយ និងខ្លាំងក្លា ។

(៧០) ក៏អាចារ្យពួកខ្លះពោល ថា "ផរុសវាចា ដែលប្រកប ចំពោះមុខបុគ្គលដែលខ្លួនប៉ងប្រាថ្នាឲ្យប្រព្រឹត្តទៅនុ៎ះឯង ទើបដល់ទីបំផុត " ។ អាចារ្យមួយពួកទៀត ពោល ថា "ផរុសវាចាដែលប្រកប សូម្បីកំបាំងមុខ ក៏ចាត់ជាផរុសវាចា បានដូចគ្នា " ។ ក្នុងពាក្យនៃអាចារ្យទាំង ២ ពួកនោះ គប្បីប្រកបអធិប្បាយ ដូច្នេះ ថា " អ្នកណាក៏អាចដឹងបាន ថា 'ចេតនាគប្បីមានកម្លាំង ព្រោះការមិនគោរពជាដើមមានកម្លាំង និងអ្នកដទៃដឹងរឿងនោះ ក្នុងការប្រកបចំពោះមុខ, នឹងគប្បីយ៉ាងដូច្នោះ ក្នុងការប្រកបកំបាំងមុខ ក៏មិនមែនដែរ ។ ដូចជាការសូមខមាទោសដែលអរិយុវាទកបុគ្គលធ្វើក្នុងទីស្មសាន នាកាលព្រះអរិយៈដែលខ្លួនជេរប្រទេច និព្វានហើយ រមែងហាមឃាត់ នូវឧបវាទន្តរាយបាន យ៉ាងណា, ផរុសវាចាសូម្បីបុគ្គលប្រកប ក្នុងទីកំបាំងមុខ ក៏ចាត់ជាផរុសវាចាបាន ដូចគ្នាយ៉ាងនោះដែរ " ។

## ( អង្គនៃផរុសវាចា )

ផរុសវាចានោះ មានអង្គ ៣ គឺ អ្នកដទៃដែលមានរូប គឺខ្លួន

គប្បីជេរប្រទេច ១ ចិត្តខឹងរន្ធត់ ១ ការជេរប្រទេចគេ ១ ។

ក្នុងអង្គទាំង ៣ នោះ លោកសំដៅយកចិត្តក្រោធខឹង ដោយប្រាថ្នាក្នុងការជេរប្រទេចប៉ុណ្ណោះ, មិនបានសំដៅយកចិត្តក្រោធខឹងដោយប្រាថ្នាក្នុងការចង់ឲ្យគេស្លាប់ឡើយ ។ ព្រោះថា បើមានចិត្តក្រោធខឹង ដោយប្រាថ្នាចង់ឲ្យគេស្លាប់ ក៏រមែងក្លាយទៅជាព្យាបាទទៅវិញ ។

## ( សម្ផប្បលាប )

(៧១) អកុសលចេតនា ដែលញុំាងកាយប្រយោគ និងវចីប្រយោគ ដែលជាគ្រឿងញុំាងអ្នកដទៃឲ្យដឹង នូវរឿងដែលមិនមែនជាប្រយោជន៍ ឲ្យតាំងឡើង ឈ្មោះថាសម្ផប្បលាប ព្រោះវិគ្រោះ ថា " សម្ផប្បលាបីបុគ្គល តែងពោលនូវពាក្យរោយរាយឥតប្រយោជន៍ ដោយចេតនានុ៎ះ " ។

## ( ទោសនៃសម្ផប្បលាប )

សម្ផប្បលាបនោះ ឈ្មោះថា មានទោសតិច ព្រោះអាសេវនៈតិច, ឈ្មោះថា មានទោសច្រើន ព្រោះអាសេវនៈច្រើន ។ ការអប់រំការធ្វើឲ្យច្រើន ឈ្មោះថា អាសេវនៈ ។ មួយទៀត សម្ផប្បលាបនោះ ដែលសម្ផប្បលាបីបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីនឹងឲ្យអ្នក

ណាមួយ កាន់យកតាម, បើអ្នកនោះ មិនកាន់យក, ឈ្មោះថាមានទោសតិច, បើអ្នកនោះ កាន់យក, ឈ្មោះថាមានទោសច្រើន ។ ម្យ៉ាងទៀត សម្ផប្បលាបនោះ ឈ្មោះថាមានទោសតិច និងឈ្មោះថាមានទោសច្រើន ព្រោះសេចក្ដីខុសផ្សេងគ្នានៃកិលេសជាទោសជាតទន់ខ្សោយ និងខ្លាំងក្លា " ។

( អង្គនៃសម្ផប្បលាប )

សម្ផប្បលាបនោះ មានអង្គ ២ គឺ ភាវៈជាអ្នកប្រាថ្នាដើម្បីនឹងពោលរឿងដែលឥតប្រយោជន៍ មានរឿងចម្បាំង នៃមហាភារតៈ និងរឿងរាពណ៍លួចនាំនាងសិតាយកទៅជាដើមជាត្រីមុខ ១ ការពោលនូវពាក្យឥតប្រយោជន៍មានសភាពដូច្នោះ ១ ។ បើអ្នកដទៃមិនទាន់កាន់យកនូវរឿងនោះទេ, កម្មបថ ក៏មិនទាន់ខាត, បើអ្នកនោះ កាន់យកនុ៎ះឯង, កម្មបថ ទើបខាត ។

ក្នុងដីកាសម្មាទិដ្ឋិសូត្រ លោកពោល ថា " ក៏សម្ផប្បលាបគ្រប់យ៉ាង រមែងសម្រេចបាន ដោយអង្គ ២ ប្រការ " ។

( វចីកម្មប្រព្រឹត្តទៅតាមទ្វារ ២ )

(៧២) ន័យមកក្នុងអដ្ឋកថាអដ្ឋសាលិនី ថា " ក៏កម្មតាមដែលពោលមកនុ៎ះ ជាវចីកម្ម ៤ យ៉ាង ប្រព្រឹត្តទៅតាមទ្វារ ២ ។

មែនពិត កាលបុគ្គលពោលវចីទុច្ចរិត មានមុសាវាទជាដើម ដោយដៃនិងសីរសៈ, កម្មជាវចីកម្ម, ចំណែកទ្វារជាកាយទ្វារ ។ តែកាលបុគ្គលបញ្ចេញវចីភេទ ពោលវចីទុច្ចរិតទាំងនោះ, សូម្បីកម្មក៏ជាវចីកម្ម, សូម្បីទ្វារក៏ជាវចីទ្វារដូចគ្នាដែរ ។ វចីកម្មដែលជាអកុសល រមែងតាំងឡើង ក្នុងកាយទ្វារនិងវចីទ្វារតែប៉ុណ្ណោះ, មិនដែលតាំងឡើង ក្នុងមនោទ្វារឡើយ ដោយប្រការដូច្នេះ ។ ចំណែកអភិជ្ឈា ព្យាបាទនិងមិច្ឆាទិដ្ឋិទាំងឡាយ ដែលកើតព្រមជាមួយនឹងចិត្តទាំងនោះ រមែងប្រព្រឹត្តទៅ ក្នុងបក្ខពួកនៃចេតនាខ្លះ ជាធម្មជាតមិនប្រកបដោយការហៅខ្លះ " ។

ក៏អកុសលធម៌ មានអភិជ្ឈាជាដើម ក្នុងវចីកម្មនោះឈ្មោះថាប្រព្រឹត្តទៅ ក្នុងបក្ខពួកនៃចេតនា ព្រោះបានវោហារថា វចីកម្ម, ឈ្មោះថាជាអព្វោហារិក ព្រោះវៀរចាកវោហារថា មនោកម្ម ។ ម្យ៉ាងទៀត អកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ឈ្មោះថាអព្វោហារិក ដោយអំណាចវចីកម្មមានមុសាវាទជាដើម, អធិប្បាយថា អ្នកណា ក៏មិនគួរពោល ដោយភាវៈជាវចីកម្ម មានមុសាវាទជាដើម ព្រោះមិនមែនជាសភាពពិតប្រាកដជាក់ស្តែង ។

កថាសំដែងអំពីវចីកម្ម ចប់ ។

## មនោកម្ម

## ( អភិជ្ឈា )

(៧៣) ធម្មជាតិដែលឈ្មោះថា អភិជ្ឈា ព្រោះអត្ថថាសំឡឹងរំពៃ អធិប្បាយថា ប្រព្រឹត្តទៅដោយភាវៈជាអ្នកមានមុខចំពោះទៅរកភណ្ឌៈរបស់អ្នកដទៃហើយ បង្អោនទៅក្នុងភណ្ឌៈនោះ ។

ក្នុងដីកាសង្គីតិសូត្រ លោកពោល ថា " ស័ព្ទ គឺធាតុទាំងឡាយជាស័ព្ទច្រើនតែប្រាប់ នូវសេចក្តីប្លែកគ្នា ដោយអំណាចនៃឧបស័គ្គហេតុនោះ ទើបលោកពោលសេចក្តីនៃបទ ថា " **អភិជ្ឈាយតិ** " ដោយពាក្យជាអាទិ៍ ថា " **បរភណ្ឌាភិមុខី** " ដូច្នេះ ។

បណ្តាបទទាំងនោះ ក្នុងបទ ថា " **តន្និន្នតាយ** " នេះ គប្បីដឹងអធិប្បាយ យ៉ាងនេះ ថា 'ដោយភាវៈជាអ្នកបង្អោនចូលទៅ ដោយអំណាចសេចក្តីលោភលន់ ក្នុងភណ្ឌៈនៃអ្នកដទៃនោះ' ។ ស័ព្ទ គឺ **ឈា** ធាតុ សូម្បីមាន **អភិ** ជាបុព្វបទ គប្បីឃើញថា ជាស័ព្ទដែលព្រះអដ្ឋកថាចារ្យលើកឡើង ក្នុងសេចក្តីថាល្មោភ, ម្យ៉ាងទៀតស័ព្ទគឺធាតុទាំងឡាយ ជាស័ព្ទច្រើនតែប្រាប់នូវសេចក្តីប្លែកគ្នា ដោយអំណាចនៃឧបស័គ្គនុ៎ះឯង " ។

## ( ទោសនៃអភិជ្ឈា )

គប្បីឃើញភាវៈនៃអភិជ្ឈានោះ មានទោសតិច និងមាន

ទោសច្រើន ដូចជាអទិន្នាទាន ដោយន័យជាអាទិ៍ ថា "អភិជ្ឈានោះ ឈ្មោះថា មានទោសតិច ព្រោះភាវៈនៃបុគ្គល ដែលអភិជ្ឈាលុបុគ្គល សំឡឹងរំពៃនូវភណ្ឌៈ ជាអ្នកមានគុណតិច, ឈ្មោះថា មានទោសច្រើន ព្រោះអ្នកនោះជាអ្នកមានគុណច្រើន " ។

## ( អង្គនៃអភិជ្ឈា )

អភិជ្ឈានោះ មានអង្គ ២ គឺ ទ្រព្យជារបស់អ្នកដទៃ ១ ការបង្អោនមក ដើម្បីខ្លួន ១ ។

ក្នុងដីកាសង្គីតិសូត្រ លោកពោល ថា "ការបង្អោនមកដើម្បីខ្លួន គប្បីដឹង ថា 'កើតមានព្រោះចិត្តប៉ុណ្ណោះ" ។

មែនពិត បើសេចក្ដីលោភលន់ ដែលមានភណ្ឌៈ របស់អ្នកដទៃជាទីតាំង សូម្បីកើតឡើងហើយ, អភិជ្ឈាលុបុគ្គល មិនទាន់បង្អោនមក ដើម្បីខ្លួន ដោយគិតថា "ធ្វើដូចម្ដេចហ្ន៎ ទ្រព្យរបស់នេះ នឹងគប្បីមកជាទ្រព្យរបស់អញ" ដរាបណា, កម្មបថ ក៏មិនទាន់ខាត ដរាបនោះ ។

## ( ព្យាបាទ )

( ៧៤ ) សភាពដែលឈ្មោះថា **ព្យាបាទ** ព្រោះអត្ថ ថា " ញុំាងប្រយោជន៍សុខ ឲ្យវិនាសបាត់បង់ទៅ " ។

ក្នុងដីកាសង្គីតិសូត្រ លោកពោល ថា “បទ ថា ព្យាបាទយតិ មានសេចក្តីថា សេចក្តីព្យាយាម របស់បុគ្គល ដែលញុំាងសេចក្តីព្យាយាមនោះឲ្យកើតឡើង, កាលបើមានការផ្សព្វផ្សាយទៅ, រមែងញុំាងប្រយោជន៍សុខ ឲ្យវិនាសបាត់បង់ទៅ ” ។

## ( ទោសនៃព្យាបាទ )

គប្បីឃើញភាវៈនៃព្យាបាទនោះ មានទោសតិច និងមានទោសច្រើន ដូចជាផរុសវាចា ដោយន័យជាអាទិ៍ ថា “ ព្យាបាទនោះ ឈ្មោះថា មានទោសតិច ព្រោះភាវៈ នៃបុគ្គលដែលវិបន្នចិត្តបុគ្គល ញុំាងប្រយោជន៍ ឲ្យបាត់បង់ទៅ ជាអ្នកមានគុណតិច, ឈ្មោះថា មានទោសច្រើន ព្រោះអ្នកនោះជាអ្នកមានគុណច្រើន ” ។

## ( អង្គនៃព្យាបាទ )

ព្យាបាទនោះ មានអង្គ ២ គឺ សត្វដទៃ ១ គិតគុំគួនប្រុងនឹងឲ្យអ្នកនោះ ដល់នូវសេចក្តីវិនាស ដោយហេតុនោះ ៗ ១ ។

ក៏បើសេចក្តីក្រោធខឹង ដែលមានសត្វដទៃជាទីតាំង សូម្បីកើតឡើងហើយ, វិបន្នចិត្តបុគ្គល នៅមិនទាន់គិតសេចក្តីវិនាសដល់សត្វនោះ ថា “ ធ្វើដូចម្តេចហ្ន៎ សត្វនេះគប្បីខាតសូន្យ វិនាសទៅ ” ដរាបណា, កម្មបថក៏មិនទាន់ខាត ដរាបនោះដែរ ។

ក្នុងដីកាសង្គីតិសូត្រនិងសម្មាទិដ្ឋិសូត្រ លោកពោលថា " ព្រះអដ្ឋកថាចារ្យ សំដែងនូវការគិតដល់សេចក្ដីវិនាសតែម្យ៉ាង ចំពោះសត្វដទៃ ដោយសព្ទនេះ ថា " **អហោ វត** " ដូច្នេះ ។ ក៏បើយ៉ាងដូច្នោះ, ព្យាបាទនោះ រមែងដល់នូវភាវៈជាកម្មបថ ព្រោះកិរិយាប្រព្រឹត្តិទៅដ៏អាក្រក់លាមក " ។

## ( មិច្ឆាទិដ្ឋិ )

(៧៥) ធម្មជាតិណា យល់ឃើញខុស ព្រោះមិនមានការកាន់យក តាមសភាវៈពិត ហេតុនោះ ធម្មជាតិនោះ ឈ្មោះថា អ្នកយល់ឃើញខុស ។

ក្នុងដីកាសង្គីតិសូត្រជាដើម លោកបានពោល ថា " បទ ថា **យថាភុច្ចគ្គហណាភាវេន** មានសេចក្ដីថា ព្រោះមិនមានការកាន់យក តាមសភាវៈពិត បានដល់ ព្រោះកាន់យកសភាពមិនទៀងទាត់ជាដើម ដោយភាវៈជាសភាពទៀងទាត់ជាដើម ។ ពាក្យថា " **មិច្ឆា បស្សតិ** " គឺ យល់ឃើញមិនពិតប្រាកដ " ។

## ( ទោសនៃមិច្ឆាទិដ្ឋិ )

មិច្ឆាទិដ្ឋិនោះ ឈ្មោះថា មានទោសតិច ព្រោះអាសេវនៈតិច, ឈ្មោះថា មានទោសច្រើន ព្រោះអាសេវនៈច្រើន ។ ម្យ៉ាងទៀត

មិច្ឆាទិដ្ឋិ ដែលមិនតឹងរ៉ឹង ឈ្មោះថា មានទោសតិច, ដែលតឹងរ៉ឹង ឈ្មោះថា មានទោសច្រើន ៗ

## ( អង្គនៃមិច្ឆាទិដ្ឋិ )

មិច្ឆាទិដ្ឋិនោះ មានអង្គ ២ គឺ ភាវៈនៃវត្ថុវិបរិត្តចាកអាការ ដែលមិច្ឆាទិដ្ឋិកាន់យក ១ កិរិយាប្រាកដនៃវត្ថុនោះ ព្រោះមិនមាន ដោយប្រការដែលមិច្ឆាទិដ្ឋិនោះប្រកាន់យក ១ ៗ

ក្នុងដីកាសង្គីតិសូត្រជាដើម លោកបានពោល ថា “ បទ ថា **គហិតាការវិបរីតតា** ប្រែថា ភាវៈនៃវត្ថុវិបរិត្តចាកអាការ ដែល មិច្ឆាទិដ្ឋិប្រកាន់យកហើយ ៗ ព្រះអដ្ឋកថាចារ្យ ពោលសភាព ដែលពិតប្រាកដ នៃវត្ថុនោះ ដោយបទ ថា “ **វត្ថុនោ** ” ៗ បទ ថា “ **តថាភាវេន** ” មានសេចក្ដីថា កិរិយាប្រាកដ នៃទិដ្ឋិនោះ ឬនៃ វត្ថុនោះ ដោយអាការវិបរិត្តចាកអាការ ដែលមិច្ឆាទិដ្ឋិនោះប្រកាន់ យកហើយនុ៎ះឯង ថា “ រឿងនេះ យ៉ាងដូច្នេះ, មិនមែន ដោយ ប្រការដទៃ អំពីនេះទេ ” ៗ

អដ្ឋកថាអដ្ឋសាលិនី ថា “ក្នុងមិច្ឆាទិដ្ឋិនោះ កម្មបថ រមែងខាត ព្រោះនត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិតែប៉ុណ្ណោះ, មិនមែន ខាត ព្រោះទិដ្ឋិដទៃឡើយ ” ៗ

## ( មនោកម្មប្រព្រឹត្តទៅតាមត្រៃទ្វារ )

(៧៦) ន័យដែលមក ក្នុងអដ្ឋកថាអដ្ឋសាលិនី ថា " ក៏កម្ម តាមដែលពោលមកហើយនុ៎ះ ជាមនោកម្ម ៣ យ៉ាង ប្រព្រឹត្តទៅតាមត្រៃទ្វារ ៗ ក៏ក្នុងពេលណា បុគ្គលមានចិត្តប្រកបព្រមដោយអភិជ្ឈា ញុំាងអង្គគឺកាយឲ្យកម្រើក ធ្វើកាយកម្មមានចាប់ដោយដៃជាដើម, មានចិត្តប្រកបព្រមដោយព្យាបាទ ញុំាងអង្គគឺកាយឲ្យកម្រើក ធ្វើកាយកម្មមានចាប់យកកំណាត់ឈើជាដើម, មានចិត្តប្រកបព្រមដោយមិច្ឆាទិដ្ឋិ ញុំាងអង្គគឺកាយឲ្យកម្រើក ធ្វើកាយកម្មមានការអភិវាទ និងការប្រណមអញ្ជលីចំពោះព្រះខន្ធកុមារ និងព្រះសិវៈទាំងឡាយនោះ ដោយមនសិការ ថា "ព្រះជាម្ចាស់ទាំងឡាយមានព្រះខន្ធកុមារនិងព្រះសិវៈជាដើម ជាអ្នកប្រសើរបំផុត " និងការប្រោះព្រំតាំងភូតជាដើម, ក្នុងពេលនោះ កម្ម ជាមនោកម្ម, ចំណែក ទ្វារ ជាកាយទ្វារ ៗ មនោកម្មដែលជាអកុសល រមែងតាំងឡើង ក្នុងកាយទ្វារ ដោយប្រការដូច្នេះ ៗ ក៏ចេតនា ក្នុងមនោទ្វារដែលប្រព្រឹត្តទៅ តាមកាយទ្វារនេះ ជាអព្វោហារិក ៗ ម្យ៉ាងទៀត នៅពេលណា បុគ្គលមានចិត្តប្រកបព្រមដោយអភិជ្ឈា ញុំាងអង្គគឺវាចាឲ្យកម្រើក សំឡឹងរំពៃនូវវត្ថុគ្រឿងឧបករណ៍ដល់ទ្រព្យគ្រឿងគាប់ចិត្ត នៃបុគ្គលដទៃ ថា " ធ្វើដូចម្តេចហ្ន៎ ទ្រព្យណា

ជារបស់អ្នកដទៃ, ទ្រព្យនោះគប្បីជារបស់អាត្មាអញ" មានចិត្តប្រកបព្រមដោយព្យាបាទ ញុាំងអង្គគឺវាចាឲ្យកម្រើក ពោល ថា "ចូរសត្វទាំងនេះ កើតក្តៅក្រហាយ, ចូរត្រូវគេសម្លាប់ ឬសូមកុំបានមានឡើយ" មានចិត្តប្រកបព្រមដោយមិច្ឆាទិដ្ឋិ ញុាំងអង្គគឺវាចាឲ្យកម្រើក ពោល ថា "ទានដែលពួកទាយកឲ្យហើយគ្មានផល" ដូច្នេះជាដើម, ក្នុងពេលនោះ កម្មជាមនោកម្ម, ចំណែក ទ្វារជាវចីទ្វារ ។ មនោកម្មដែលជាអកុសល រមែងតាំងឡើង ក្នុងវចីទ្វារយ៉ាងនេះ, ក៏ចេតនា ក្នុងមនោកម្មដែលប្រព្រឹត្តទៅតាមវចីទ្វារនេះជាអព្វោហារិក ។ មួយ៉ាងទៀត ក្នុងពេលណា បុគ្គលមិនបានញុាំងអង្គគឺកាយ និងអង្គគឺវាចាឲ្យកម្រើកហើយ អង្គុយក្នុងទីកំបាំងហើយញុាំងចិត្តដែលប្រកបព្រមដោយអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិឲ្យកើតឡើង, ក្នុងពេលនោះ ទាំងកម្មក៏ចាត់ជាមនោកម្ម, ទាំងទ្វារក៏ចាត់ជាមនោទ្វារដូចគ្នាដែរ ។ មនោកម្ម ដែលជាអកុសលរមែងតាំងឡើង ក្នុងមនោទ្វារ ដោយប្រការដូច្នេះ ។ ក៏ក្នុងទីនេះចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី រមែងតាំងឡើង ក្នុងមនោទ្វារ តែម្យ៉ាងប៉ុណ្ណោះ ។ មនោកម្មដែលជាអកុសល រមែងតាំងឡើង ក្នុងទ្វារទាំង ៣ ដូចបានពណ៌នាមកនេះឯង" ។

(៧៧) ដីកានៃអដ្ឋកថាអដ្ឋសាលិនី ថា "គប្បីដឹងវិនិច្ឆ័យ

ក្នុង ២ បទ ថា "**ខន្ធសិរាទយោ សេដ្ឋា**" ដូច្នេះ, 'ទេវកុមារទាំងឡាយ ឈ្មោះថា **ខន្ធៈ**, ព្រះជាម្ចាស់ដែលជាធំ ឈ្មោះថា **សិរៈ** ។ គប្បីដឹង ថា "ព្រះអដ្ឋកថាចារ្យ ពោល ២ បទ ថា **ខន្ធសិរាទយោ សេដ្ឋា** នេះ ដើម្បីសំដែងនូវមិច្ឆាទិដ្ឋិ"។ តាមពិត ទិដ្ឋិ ៣ យ៉ាង មាននត្ថិកទិដ្ឋិជាដើមនេះឯងដែលដល់ភាវៈជាកម្មបថឈ្មោះថាកម្ម ។ ច្រើនបទ ថា "**ចេតនា បនេត្ថ អព្វោហារិកា**" មានសេចក្ដីថា ចេតនា សូម្បីតាំងឡើង ក្នុងកាយទ្វារ និងវចីទ្វារ ក៏មិនបានវោហារថា កាយកម្ម និងវចីកម្ម ព្រោះភាវៈនៃចេតនានោះ មានអកុសលធម៌មានអភិជ្ឈាជាដើមជាប្រធាន ។ ក៏ចេតនានោះ ដោយសភាពនុ៎ះឯង ឈ្មោះថា មនោកម្ម ព្រោះបាលី ថា "ម្នាលភិក្ខុទាំងឡាយ ! មនោសញ្ចេតនា ៣ យ៉ាង ហៅថា មនោកម្ម ផ្នែកខាងអកុសល" ដូច្នេះ, ចេតនានោះ មិនមែនជាបក្ខពួក នៃអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើមឡើយ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបមិនបានពោល ថា '**អភិជ្ឈាទិបក្ខិកា**' ដូច្នេះ ។ ពាក្យថា **ឥមស្មឹ បន ឋានេ** នេះ មានសេចក្ដីថា ក្នុងពេលដែលមិនញ៉ាំងអង្គគឺកាយនិងអង្គគឺវាចាឲ្យកម្រើកហើយគិត ចេតនាក្ដី ធម៌ដែលសម្បយុត្តដោយចេតនាក្ដី រមែងតាំងឡើង ក្នុងមនោទ្វារ តែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ភាវៈនៃចេតនាជាអព្វោហារិក នឹង

មានយ៉ាងដូចម្ដេចហ្ន៎ ? អធិប្បាយថា មិនមានឡើយ " ។

(៧៨) អនុដីកានៃអដ្ឋកថាអដ្ឋសាលិនីនោះ ថា " អាចារ្យពួកខ្លះពោល ថា ' ព្រះអដ្ឋកថាចារ្យពោល ថា ' បុគ្គលមានចិត្តប្រកបព្រមដោយមិច្ឆាទិដ្ឋិ ញុំាងអង្គគីកាយឲ្យកម្រើក ធ្វើកាយកម្មមានការអភិវាទ និងការប្រណមអញ្ជលី ចំពោះព្រះខន្ទកុមារ និងព្រះសិវៈនោះ ដោយមនសិការ ថា ' ព្រះជាម្ចាស់ទាំងឡាយ មានព្រះខន្ទកុមារនិងព្រះសិវៈជាដើម ជាអ្នកប្រសើរបំផុត ' និងការប្រោះព្រំតាំងភូតជាដើម ' ដូច្នេះ ដោយអំណាចនៃបុគ្គលអ្នកកាន់យក (លទ្ធិ) ថា ' ការកើតឡើង ក្នុងសុគតិនិងទុគ្គតិទាំងឡាយមិនមាន ព្រោះកម្មដែលធ្វើល្អ និងអាក្រក់ឡើយ, តែរមែងមានព្រោះព្រះជាម្ចាស់ទាំងឡាយមានព្រះខន្ទកុមារនិងព្រះសិវៈជាដើម " ដូច្នេះហើយ ប្រកាន់យក ដោយន័យជាអាទិ៍ ថា ' ទានដែលពួកទាយកឲ្យហើយ មិនមានផលឡើយ ' ដូច្នេះ " ។ ដោយបទ ថា **អភិជ្ឈាទិប្បធានត្តា** នេះ ព្រះដីកាចារ្យសំដែង ថា ' ទោះជាមានអកុសលធម៌ទាំងឡាយមានអភិជ្ឈា និងព្យាបាទជាដើម, ក្នុងពេលណា ចេតនា ក្នុងកាយទ្វារនិងវចីទ្វារ មានកម្លាំង, អកុសលធម៌ទាំងឡាយមានអភិជ្ឈា និង ព្យាបាទជាដើមក្រៅនេះ នឹងមិនមានកម្លាំង យ៉ាងដូច្នោះឡើយ, ក្នុងពេលនោះ ចេតនា រមែងបាននូវ

វោហារថា កាយកម្ម និងវចីកម្ម ព្រោះភាវៈនៃចេតនាជាប្រធាន ៗ ក៏ភាវៈនៃចេតនានោះ ជាប្រធាននុ៎ះឯង គេនឹងដឹងបាន ព្រោះសេចក្ដីសម្រេច នៃកាយកម្ម និងវចីកម្ម មានបាណាតិបាតជាដើម ៗ ក៏ក្នុងពេលណា អកុសលធម៌មានអភិជ្ឈាជាដើម ក្នុងទ្វារទាំងនោះនុ៎ះឯង មានកម្លាំង, ចេតនា មិនមានកម្លាំង ដូច្នោះឡើយ, ក្នុងពេលនោះ ចេតនា ទោះជាមានក្នុងទ្វារទាំងនោះ ក៏មិនបានវោហារថាកាយកម្ម និងវចីកម្មឡើយ ព្រោះភាវៈនៃចេតនានោះ មិនមែនជាប្រធាន ៗ ចំណែក អកុសលធម៌មានអភិជ្ឈាជាដើម សូម្បីមានការញុំាងអង្គគឺកាយ និងអង្គគឺវាចាឲ្យកម្រើកក៏ដោយ លោកក៏នៅតែហៅថា មនោកម្ម ដដែល តាមលក្ខណៈកំណត់របស់ខ្លួននុ៎ះឯង ព្រោះខ្លួនជាប្រធាន ' ៗ ព្រះដីកាចារ្យ ធ្វើទុកក្នុងចិត្ត នូវការសាកសួរថា " ប្រសិនបើ ចេតនា មានអកុសលធម៌មានអភិជ្ឈាជាដើម ជាប្រធាន, ក៏បើយ៉ាងដូច្នោះ អកុសលធម៌មានអភិជ្ឈាជាដើម ក្នុងទ្វារទាំងនោះ ចាត់ជាកម្ម, មិនមែនជាចេតនា, ចេតនានោះ គប្បីជាបក្ខពួកនៃអកុសលធម៌ មានអភិជ្ឈាជាដើមមែនឬ ? ' ដូច្នេះហើយ ទើបពោលបាលី ថា ' **តិវិធា ភិក្ខវេ** ' ដូច្នេះជាដើម ៗ ព្រោះអធិប្បាយថា ' ពាក្យថា ចេតនាក្ដី ធម៌ដែលសម្បយុត្តដោយចេតនាក្ដី រមែងតាំងឡើង ក្នុងមនោទ្វារតែម្យ៉ាង ' នេះ

ជាពាក្យសំដែងនូវភាវៈនៃចេតនា ក្នុងមនោទ្វារ ជាមួយនឹងអកុសលធម៌ មានអភិជ្ឈាជាដើមមិនខុសប្លែកគ្នា ក្នុងភាវៈជាមនោកម្ម ” ដូច្នេះ ព្រះដីកាចារ្យ ទើបពោល ថា ‘ ភាវៈនៃចេតនាជាធម្មជាតិមិនប្រកបដោយការហៅ នឹងមានយ៉ាងដូចម្តេច ? អធិប្បាយថាមិនមាន ’ ។ មែនពិត ពាក្យនេះ ថា ‘ ចេតនាជាចេតនាកម្ម, អកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ជាកម្មដែលសម្បយុត្តដោយចេតនា ’ ដូច្នេះ តែប៉ុណ្ណោះនុំះ ជាពាក្យប្លែកគ្នា ក្នុងភាវៈនៃចេតនាជាមនោកម្មនេះ ។ ម្យ៉ាងទៀត ក្នុងភាវៈនៃចេតនា ជាមនោកម្មនេះ គប្បីឃើញសន្និដ្ឋាន ថា ‘ ព្រះអដ្ឋកថាចារ្យ មិនបានពោលថា ជាអព្វោហារិក ព្រោះមិនមានសេចក្តីសង្ស័យ ថា ភាវៈនៃចេតនា ជាកាយកម្ម និងវចីកម្ម គប្បីមាន និងព្រោះភាវៈ នៃកាយកម្ម និងវចីកម្ម ជាអកុសល មិនកើតឡើង ក្នុងមនោទ្វារ ” ។

កថាសំដែងអំពីមនោកម្ម ចប់ ។

(៧៩) ឥឡូវនេះ ខ្ញុំនឹងពោលអំពីវាទៈ ៣ យ៉ាង មានអកិរិយវាទៈជាដើម ដើម្បីភាវៈនៃបុគ្គលជាអ្នកឆ្លាត ក្នុងមិច្ឆាទិដ្ឋិដែលមកហើយ ក្នុងកថាសំដែងអំពីមនោកម្ម ។

( អកិរិយវាទៈ )

បណ្តាវាទៈទាំង ៣ យ៉ាងនោះ គ្រូអ្នកធ្វើលទ្ធិ ដូចជាកំពង់ឈ្មោះថាបូរណៈ ពោលអកិរិយវាទៈ មានជាអាទិ៍ យ៉ាងនេះ ថា " កាលបើបុគ្គលធ្វើខ្លួនឯង (ឬ) ប្រើឲ្យគេធ្វើ កាត់ខ្លួនឯង (ឬ) ប្រើឲ្យគេកាត់ បៀតបៀនខ្លួនឯង (ឬ) ប្រើឲ្យគេបៀតបៀនសៅសោកខ្លួនឯង (ឬ) ធ្វើឲ្យគេសៅសោក លំបាកខ្លួនឯង (ឬ) ធ្វើឲ្យគេលំបាក ក្តៅក្រហាយខ្លួនឯង (ឬ) ធ្វើឲ្យគេក្តៅក្រហាយ ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង កាន់យកទ្រព្យសម្បត្តិដែលម្ចាស់គេមិនបានឲ្យ (ដោយកាយ ឬ វាចា ) កាត់ទីត ប្លន់រឹបជាន់យកទ្រព្យគេ ធ្វើការប្លន់ស្រុកមួយ ចាំស្ទាក់ប្លន់ត្រង់ផ្លូវស្ទាត់គប់រកភរិយាអ្នកដទៃ ពោលពាក្យមុសា កាលបើបុគ្គលធ្វើ ( យ៉ាងដូច្នេះ ) បាបមិនឈ្មោះថា គឺបុគ្គលធ្វើ " ។ ហើយគ្រូលទ្ធិបូរណៈនោះ ឈ្មោះថា ជាអ្នកមានវាទៈថាមិនធ្វើ ។

( អហេតុកទិដ្ឋិ )

គ្រូអ្នកធ្វើលទ្ធិ ដូចជាកំពង់ ឈ្មោះថា មក្ខលិ ពោលអហេតុកវាទៈ មានជាអាទិ៍ យ៉ាងនេះ ថា " ហេតុមិនមាន បច្ច័យមិនមានដើម្បីសេចក្តីសៅហ្មងនៃសត្វទាំងឡាយ, សត្វទាំងឡាយ មិនមាន

ហេតុ មិនមានបច្ច័យ សៅហ្មងខ្លួនឯង, ហេតុមិនមាន បច្ច័យមិនមាន ដើម្បីសេចក្ដីបរិសុទ្ធិ នៃសត្វទាំងឡាយ, សត្វទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ បរិសុទ្ធដោយខ្លួនឯង " ។ ហើយគ្រូអ្នកធ្វើលទ្ធិដូចកំពង់ ឈ្មោះថា មក្ខលិនោះ ជាអ្នកមានសេចក្ដីយល់ឃើញនូវសេចក្ដីបរិសុទ្ធិ នៃសំសារវដ្ដ ទើបពោលសេចក្ដីសៅហ្មងនិងសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ថា មិនមានហេតុ ។

( នត្ថិកទិដ្ឋិ )

គ្រូអ្នកធ្វើលទ្ធិ ដូចជាកំពង់ ឈ្មោះថា អជិតៈ ពោលនត្ថិកទិដ្ឋិមានជាអាទិ៍ យ៉ាងនេះ ថា " ទានដែលពួកទាយកឲ្យហើយ ឥតមានផល, ការបូជាដែលបុគ្គលបូជាហើយ ឥតមានផល " ។ ហើយគ្រូអ្នកធ្វើលទ្ធិ ឈ្មោះថា អជិតៈនោះ ឈ្មោះថា ជាអ្នកមានវាទៈថាមិនមាន ។ គ្រូអ្នកធ្វើលទ្ធិអជិតៈនោះនុ៎ះឯង ជាអ្នកមានវាទៈថាខាតសូន្យខ្លះ, ពិតមែនយ៉ាងនោះ គ្រូអ្នកធ្វើលទ្ធិនោះពោលសេចក្ដីខាតសូន្យ យ៉ាងនេះ ថា " សត្វទាំងឡាយ លុះទំលាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងខាតសូន្យ រមែងវិនាសសាបសូន្យទៅ រមែងមិនមាន " ។

(៨០) អដ្ឋកថាសាមញ្ញផលសូត្រ ថា " បណ្ដាបទទាំងនោះ

បទ ថា “ **ករតោ** ” បានដល់ ធ្វើដោយដៃរបស់ខ្លួនឯង ។ បទ ថា “**ការយតោ**” បានដល់ ឲ្យគេធ្វើដោយអាជ្ញា ។ បទ ថា “**ឆិន្ទតោ**” បានដល់ កាត់អវយវៈទាំងឡាយ មានដៃជាដើម នៃជនដទៃ ។ បទ ថា “ **បចតោ** ” បានដល់ បៀតបៀនអ្នកដទៃ ដោយអាជ្ញា ។ ២ បទ ថា “ **សោចតោ សោចាបយតោ** ” មានសេចក្ដីថា ធ្វើខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យធ្វើខ្លះ នូវសេចក្ដីសោក ដោយទុច្ចរិត មានការលួចទ្រព្យសម្បត្តិរបស់អ្នកដទៃជាដើម ។ ២ បទ ថា “**កិលមតោ កិលមាបយតោ** ” មានសេចក្ដីថា លំបាកដោយខ្លួនឯងខ្លះ ធ្វើឲ្យអ្នកដទៃលំបាកខ្លះ ដោយទារុណកម្ម មានការបង្អត់អាហារ និងឃុំឃាំងទុកនៅក្នុងពន្ធនាគារជាដើម ។ ២ បទ ថា “ **ផន្ទតោ ផន្ទាបយតោ** ” មានសេចក្ដីថា ក្នុងវេលាដែលចងសត្វដទៃ ដែលកំពុងតែក្ដៅក្រហាល់ក្រហាយ, ក្ដៅក្រហល់ក្រហាយដោយខ្លួនឯងខ្លះ ញុំាងសត្វនោះ ឲ្យក្ដៅក្រហល់ក្រហាយខ្លះ ។ ពាក្យថា “ **បាណមតិបាតាបយតោ** ” បានដល់ សម្លាប់ខ្លួនឯងក្ដី ប្រើអ្នកដទៃឲ្យសម្លាប់ក្ដី នូវសត្វមានជីវិត ។ គប្បីដឹងសេចក្ដី ដោយអំណាចធ្វើខ្លួនឯង និងញុំាងអ្នកដទៃឲ្យធ្វើ ដូចគ្នាគ្រប់ៗបទ ដូច្នេះ ។ បទ ថា “ **សន្ធឹ** ” បានដល់ ទីតនៃផ្ទះ ។ បទ ថា “ **និល្លោបំ** ” បានដល់ ប្លន់ដ៏ធំ ។ បទ ថា “ **ឯកាគារិកំ** ” បានដល់ ការលោម

ព័ទ្ធផ្ទះមួយប៉ុណ្ណោះ ហើយប្លន់ ៗ បទ ថា " **បរិបន្ថេ** " បានដល់ ឈរចាំស្ទាក់ លើផ្លូវ ដើម្បីដណ្តើមយក ជនអ្នកដែលត្រាច់ចរមក ហើយ ៗ ៗ ដោយបទ ថា " **ករោតោ ន ករិយតិ បាបំ** " គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថា បូរណៈ សំដែង ថា " បើបុគ្គលសូម្បីធ្វើ ដោយសេចក្តីសម្គាល់ ថា 'អាត្មាអញកំពុងធ្វើបាបណាមួយ' ដូច្នេះ បាបមិនឈ្មោះថាគឺបុគ្គលធ្វើ, បាបមិនមាន, ប៉ុន្តែ សត្វជាអ្នក មានសេចក្តីសម្គាល់យ៉ាងនេះ ថា 'យើងទាំងឡាយធ្វើ" ដូច្នេះ ៗ គ្រូអ្នកធ្វើលទ្ធិឈ្មោះថា បូរណៈនោះ តែងបដិសេធនូវកិរិយាធ្វើបាប និងបុណ្យ សូម្បីដោយប្រការទាំងពួងតែម្តង ៗ

គប្បីដឹងសេចក្តីវិនិច្ឆ័យ ក្នុងវាទៈនៃគ្រូអ្នកធ្វើលទ្ធិ ឈ្មោះថា មក្ខលិ ដូចតទៅនេះ ÷ បច្ច័យ ជាវេវចនៈនៃហេតុនុ៎ះឯង ៗ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាមក្ខលិនោះ បដិសេធបច្ច័យ នៃសង្កិលេស មានកាយទុច្ចរិត និងបច្ច័យនៃវិសុទ្ធិ មានកាយសុចរិតជាដើម ដែល មាននៅនុ៎ះឯង ដោយពាក្យថា ហេតុនិងបច្ច័យទាំង ២ យ៉ាង ៗ

ចំណែក សេចក្តីនៃពាក្យទាំងឡាយ មានពាក្យ ថា " **នត្ថិ ទិន្នំ** " ដូច្នេះជាដើម គប្បីទាញយក អំពីអដ្ឋកថាសាមញ្ញផលសូត្រ សាលេយ្យកសូត្រ និងនិក្ខេបកណ្ឌ ៗ

(៨១) ដីកាសាមញ្ញផលសូត្រនោះ ថា " បទ ថា **សហត្ថា**

គឺ ធ្វើដោយដៃ របស់ខ្លួនឯង ៗ ក្នុងបទ ថា **សហត្ថា** នេះ សូម្បី ប្រយោគទាំងឡាយមាននិស្សគ្គិយប្រយោគ និង ថាវរប្រយោគ ជាដើម ព្រះអដ្ឋកថាចារ្យ សង្គ្រោះហើយ ដោយកិរិយាធ្វើ ដោយដៃខ្លួនឯងនុ៎ះឯង ៗ បទ ថា "**ហត្ថាទីនិ**" គឺ នូវអវយវៈ មានដៃជើង ត្រចៀកនិងច្រមុះជាដើម ៗ កិរិយាដុត កិរិយាបៀតបៀន ឈ្មោះ ថាកិរិយាបៀតបៀន ហេតុនោះ ព្រះអដ្ឋកថាចារ្យពោល ថា 'បៀតបៀន ដោយអាជ្ញា' ៗ

ម្យ៉ាងទៀត ក្នុងអដ្ឋកថាបញ្ចសូទនី លោកពោលសេចក្តី ថា 'សម្លុត' ៗ តែក្នុងទីនេះ ព្រះអដ្ឋកថាចារ្យ សង្គ្រោះការសម្លុត ការជេរប្រទេច ដោយអាជ្ញាតែម្យ៉ាង ហើយបានពោល ថា 'បៀតបៀន ដោយអាជ្ញា' ដូច្នេះប៉ុណ្ណោះ ៗ ច្រើនបទ ថា "**សោកំ សយំ ករោន្តស្ស**" មានសេចក្តីថា ធ្វើហេតុនៃសេចក្តីសៅសោក ដល់អ្នកដទៃដោយខ្លួនឯង ឬ ញុំាងសេចក្តីសៅសោក ឲ្យកើតឡើង ឬក៏ ញុំាងអ្នកដទៃ គឺអ្នកធ្វើតាមពាក្យរបស់ខ្លួន (ឲ្យធ្វើសេចក្តីសៅសោកដល់អ្នកដទៃ) ៗ ពាក្យនេះ ថា "**សយម្បិ ផន្ទតោ**" មានសេចក្តីថា ក្តៅក្រហល់ក្រហាយ សូម្បីដោយខ្លួនឯង ដោយសេចក្តីព្យាយាមក្នុងការបៀតបៀនអ្នកដទៃ ៗ បទ ថា "**អតិបាតាបយតោ**" រមែងប្រព្រឹត្តទៅ ក្នុងអត្ថនៃកត្តុវាចកៈស្មោះ និងក្នុង

អត្ថនៃហេតុកត្តុវាចកៈ ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា 'សម្លាប់ខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យសម្លាប់ក្តី' ។ បទ ថា "**ការណាវសេន**" ប្រែថា ដោយអំណាចញុំាងអ្នកដទៃឲ្យធ្វើ ។ ជញ្ជាំងផ្ទះដែលមានទីត ស្ថិតនៅទាំងខាងក្នុង ទាំងខាងក្រៅ ឈ្មោះថាទីតនៃផ្ទះ ។ ការប្លន់ដែលគ្មានសេសសល់ ព្រោះមិនឲ្យមានសេសសល់វត្ថុអ្វីមួយ ឈ្មោះថាការប្លន់រឹបជាន់យក ។ ការប្លន់ដែលប្រកបគឺធ្វើ ក្នុងផ្ទះ១ខ្នង ឈ្មោះថាការប្លន់ផ្ទះ១ខ្នង ។ ការប្រទូសរ៉ាយគ្នា លើផ្លូវជុំវិញ គឺគ្រប់ទិសទី ឈ្មោះថា ការប្លន់ត្រង់ផ្លូវស្ងាត់ ។ បាបមិនឈ្មោះថា គឺបុគ្គលធ្វើ ព្រោះបាបនោះមិនមាន ក្នុងកាលមុនអ្នកណាមួយ ក៏មិនអាច ដើម្បីនឹងឲ្យកើតឡើងបាន ព្រោះហេតុនោះបាបទើបមិនមាន ។ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាបូរណៈ ធ្វើទុកក្នុងចិត្តនូវការសាកសួរ ថា 'ប្រសិនបើយ៉ាងដូច្នោះ, សត្វទាំងឡាយ នឹងប្រព្រឹត្តទៅ ក្នុងបាបបានយ៉ាងដូចម្តេច ?' ដូច្នេះហើយ ពោល ថាតែសត្វជាអ្នកមានសេចក្តីសម្គាល់ យ៉ាងនេះ ថា 'យើងទាំងឡាយធ្វើ' ។ បានឮថា គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាបូរណៈនោះមានសេចក្តីយល់ឃើញយ៉ាងនេះ ថា 'អំពើ មានការបៀតបៀន សត្វទាំងឡាយនេះជាដើម នឹងមិនដល់ខ្លួន ព្រោះខ្លួននោះមិនមានវិការ ព្រោះជាសភាពទៀង ។ ចំណែក សរីរៈមិនមានចេតនា ប្រៀបបាននឹង

អង្កត់ខុស, បើសរីរៈនោះ សូម្បីគឺបុគ្គលឲ្យកម្រើកហើយ, បាបអ្វីៗ ក៏មិនមានដែរ ៗ បទថា "**សព្វថាបិ**" គឺ ដោយប្រការទាំងពួង ដែលគ្រូបូរណៈកស្សបៈ ពោលជាអាទិ៍ ថា '**ករតោ**' ដូច្នេះ ៗ អវធារណស័ព្ទ (គឺឯវ) ក្នុងបទ ថា "**កិរិយមេវ**" ដូច្នេះ មានការហាមនូវវិបាកឲ្យត្រឡប់មកវិញជាអត្ថ ៗ មែនពិត គ្រូអ្នកធ្វើលទ្ធិណាហាមកម្ម, ដោយសេចក្ដី គ្រូអ្នកធ្វើលទ្ធិនោះ ក៏ឈ្មោះថាហាមដល់វិបាកដោយពិត ៗ ពិតយ៉ាងនោះ ព្រះអដ្ឋកថាចារ្យ នឹងពោលថា 'សូម្បីហាមកម្ម' ដូច្នេះជាដើម ៗ បទ ថា "**ឧភយេន**" ប្រែថា ដោយពាក្យថាហេតុនិងបច្ច័យ ៗ បទ ថា "**សង្កិលេស-ប្បច្ចយំ**" គឺ នូវហេតុនៃសង្កិលេស បានដល់ ហេតុនៃធម៌ជាគ្រឿងសៅហ្មង ៗ បទ ថា "**វិសុទ្ធិប្បច្ចយំ**" គឺ នូវហេតុនៃសេចក្ដីបរិសុទ្ធិ គឺ នៃសេចក្ដីផូរផង់ចាកសង្កិលេស " ៗ

(៨២) វាទៈទាំងនេះ មកហើយ ក្នុងសាមញ្ញផលសូត្រ ក្នុងសីលក្ខន្ធវគ្គ ដោយពិស្ដារ តាមលំដាប់នេះ ដោយប្រការដូច្នេះ ៗ ចំណែក ក្នុងអបណ្ណកសូត្រ ក្នុងបឋមវគ្គ មជ្ឈិមបណ្ណាសកៈ មកហើយ តាមលំដាប់នេះ គឺ នត្ថិកទិដ្ឋិ អកិរិយទិដ្ឋិ អហេតុកទិដ្ឋិ ៗ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ កាលពណ៌នាព្រមនូវសេចក្ដី តាមសមគួរដល់លំដាប់នៃវាទៈនោះ ទើបពោលទុក

ក្នុងអដ្ឋកថាអបណ្ណកសូត្រនោះ ថា “ ក៏បណ្ដាទិដ្ឋិ ៣ យ៉ាងនោះ នត្ថិកទិដ្ឋិ ហាមវិបាក, អកិរិយទិដ្ឋិ ហាមកម្ម, អហេតុកទិដ្ឋិ ហាមទាំង ២ យ៉ាង ” ដូច្នេះជាដើម ។

(៨៣) អដ្ឋកថាសាមញ្ញផលសូត្រ ថា “ បណ្ដាគ្រូទាំង ៣ នាក់នោះ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាបូរណៈ ពោល ថា ‘ កាលបុគ្គលកំពុងធ្វើបាប, បាបមិនឈ្មោះថាគឺបុគ្គលធ្វើ ’ ដូច្នេះ ឈ្មោះថា ហាមកម្ម ។ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាអជិតៈ ពោល ថា ‘ សត្វទាំងឡាយលុះទំលាយរាងកាយ បន្ទាប់ពីសេចក្ដីស្លាប់ រមែងខាតសូន្យ ’ ដូច្នេះ ឈ្មោះថា ហាមវិបាក ។ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាមក្ខលិ ពោល ថា ‘ សត្វទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ សៅហ្មងខ្លួនឯង បរិសុទ្ធខ្លួនឯង ’ ដូច្នេះ ឈ្មោះថា ហាមទាំង ២ យ៉ាង ។ បណ្ដាកម្មនិងវិបាកទាំង ២ យ៉ាងនោះ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាបូរណៈ សូម្បីហាមតែកម្ម ក៏ឈ្មោះថាជាអ្នកហាមវិបាកផងដែរ ។ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាអជិតៈ សូម្បីហាមតែវិបាក ក៏ឈ្មោះថាជាអ្នកហាមកម្មផងដែរ ។ ដោយសេចក្ដី គ្រូអ្នកធ្វើលទ្ធិទាំងអស់នោះ ដោយហេតុហាមកម្មនិងវិបាកទាំង ២ យ៉ាង ទើបឈ្មោះថា អហេតុកវាទៈ អកិរិយវាទៈ និង នត្ថិកវាទៈ ដោយប្រការដូច្នេះ ” ។

(៨៤) ដីកាសាមញ្ញផលសូត្រនោះ ថា “ គ្រូអ្នកធ្វើលទ្ធិ

ឈ្មោះថាបូរណៈ ឈ្មោះថាហាមនូវកម្ម ព្រោះជាអ្នកមានវាទៈថា មិនគឺបុគ្គលធ្វើ ៗ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាអជិតៈ ឈ្មោះថាហាមនូវវិបាក ព្រោះបដិសេធការកើតឡើង តទៅទៀតទាំងអស់ ដោយប្រការទាំងពួង ៗ គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាមក្ខលិ ឈ្មោះថាហាមនូវកម្មនិងវិបាកទាំង ២ យ៉ាង ព្រោះសូម្បីផលគឺគ្រូអ្នកធ្វើលទ្ធិអ្នកហាមហេតុ ដោយប្រការទាំងពួងនុ៎ះឯង ហាមទៅហើយ ៗ ម្យ៉ាងទៀត បទ ថា "**ឧភយំ**" ប្រែថា ទាំង ២ យ៉ាង គឺ កម្មនិងវិបាក ៗ មែនពិត គ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាមក្ខលិនោះ ពោល ថា 'សត្វទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ រមែងសៅហ្មងខ្លួនឯង និងបរិសុទ្ធខ្លួនឯង' ដូច្នេះ ឈ្មោះថាហាមកម្ម និងវិបាក ទាំង ២ យ៉ាងនោះ ព្រោះពោលការមិនមាន សូម្បីនៃវិបាកជាបច្ច័យ នៃសង្កិលេសនិងវិសុទ្ធិទាំងឡាយ ដូចជាកម្ម ៗ វិបាក ឈ្មោះថា គឺគ្រូអ្នកធ្វើលទ្ធិឈ្មោះថា បូរណៈនោះហាមហើយ ព្រោះ បើកម្មមិនមាន, វិបាកក៏មិនមានដែរ ៗ កម្ម ឈ្មោះថា គឺគ្រូអ្នកធ្វើលទ្ធិ ឈ្មោះថាអជិតៈនោះ ហាមហើយ ព្រោះ បើវិបាកមិនមាន, កម្មក៏ដល់នូវភាវៈជាកម្មដែលរកប្រយោជន៍គ្មានឡើយ ៗ បទ ថា "**អត្ថតោ**" គឺដោយសរុប ៗ បទ ថា "**ឧភយប្បដិពាហកា**" មានសេចក្តីថាព្រោះ វាទៈទាំងឡាយនោះ មកហើយក្នុងបាលី ដោយភាវៈជាវាទៈ

សំដែងនូវទិដ្ឋិ ៣ យ៉ាង ផ្សេង ៗ គ្នា ហេតុនោះ ទិដ្ឋិ ៣ យ៉ាងនុ៎ះឯង ចំពោះតែទិដ្ឋិមួយ ៗ ឈ្មោះថាហាមកម្មនិងវិបាកទាំង ២ ។ ក៏ពាក្យថា " **ឧភយប្បដិពាហកា** " នេះ ជាពាក្យដែលសំដែងនូវហេតុ ។ ពាក្យថា "**អហេតុកវាទា ចេវ**" ដូច្នេះជាដើម ជាពាក្យសំដែងនូវការប្រព្រឹត្តទៅ ។ មែនពិត គ្រូអ្នកធ្វើលទ្ធិណា ជានត្ថិកទិដ្ឋិក៍ មានវាទៈថាខាតសូន្យ ព្រោះហាមនូវវិបាក, គ្រូអ្នកធ្វើលទ្ធិនោះដោយសេចក្តី គឺជាអកិរិយទិដ្ឋិក៍ ព្រោះហាមនូវកម្ម, និងជាអហេតុកទិដ្ឋិក៍ ព្រោះហាមនូវកម្មនិងវិបាកទាំង ២ យ៉ាង ។ ន័យសូម្បីក្នុងគ្រូអ្នកធ្វើលទ្ធិ ២ នាក់ដែលសេសសល់ក៏យ៉ាងនេះដែរ ។

(៨៥) សូម្បីក្នុងដីកានិក្ខេបកណ្ឌ លោកលុះសំដែងវាទៈ ៣ យ៉ាងហើយ ទើបពោលទៀតថា " សេចក្តីប្លែកផ្សេងគ្នា នៃវាទៈទាំង ៣ យ៉ាងនោះ យ៉ាងនេះ គឺ បណ្តាវាទៈ ៣ យ៉ាងនោះ វាទៈទី ១ បដិសេធហេតុនៃសេចក្តីសៅហ្មងជាគ្រឿងចងរឹត និងវិសុទ្ធិជាគ្រឿងរួចផុត, វាទៈ ទី ២ បដិសេធនូវកម្ម, វាទៈ ទី ៣ បដិសេធនូវវិបាក " ។

អនុដីកានិក្ខេបកណ្ឌនោះ ថា " ព្រះដីកាចារ្យពោលពាក្យជាអាទិ៍ ថា ' **បុរិមវាទោ** ' ដូច្នេះ ដើម្បីនឹងសំដែងនូវសេចក្តីប្លែកផ្សេងគ្នា នៃវាទៈទាំងឡាយមានអហេតុកវាទៈជាដើម ។ ក៏កម្ម

ព្រមទាំងសម្ភារៈ ដោយផ្សេងគ្នាជាកម្មដែលមិននាំសត្វចេញចាកទុក្ខ និងកម្មដែលនាំសត្វឲ្យចេញចាកទុក្ខ ឈ្មោះថា ជាហេតុនៃសេចក្ដីសៅហ្មងនិងសេចក្ដីបរិសុទ្ធិ ហេតុនោះ វាទៈទី ១ សូម្បីកាលហាមហេតុនៃការសៅហ្មងនិងសេចក្ដីបរិសុទ្ធិ ក៏ឈ្មោះថាហាមកម្មដែរ ។

ចំណែក ក្នុងអដ្ឋកថាសុមង្គលវិលាសិនី លោកពោល ថា " សូម្បីវិបាក ក៏ជាហេតុនៃសង្កិលេសនិងវិសុទ្ធិ ព្រោះវិបាកជាហេតុនៃសង្កិលេសនិងវិសុទ្ធិ ដូចជាកម្ម ហេតុនោះ គ្រូមក្ខលិ កាលពោលថា 'សត្វទាំងឡាយមិនមានហេតុ' ដូច្នេះជាដើម ឈ្មោះថាហាមសូម្បីកម្មនិងវិបាកទាំង ២ យ៉ាង " ។

(៨៦) អដ្ឋកថាសាមញ្ញផលសូត្រ និងអដ្ឋកថាទសមសូត្រ ក្នុងតតិយវគ្គ ចតុក្កនិបាត អង្គុត្តរនិកាយ ថា " ក៏ពួកជនណា កាន់យកលទ្ធិនៃគ្រូទាំង ៣ នាក់នោះ ហើយអង្គុយស្វាធ្យាយ ពិចារណា ក្នុងទីជាទីនៅក្នុងពេលយប់ និងទីជាទីសម្រាក ក្នុងពេលថ្ងៃ, កាលបើជនទាំងនោះ ស្វាធ្យាយ ពិចារណានូវលទ្ធិនោះ ថា 'កាលបុគ្គលធ្វើបាបមិនឈ្មោះថាគឺបុគ្គលធ្វើ, ហេតុមិនមាន, បច្ច័យមិនមាន, សត្វស្លាប់ទៅហើយ រមែងខាតសូន្យ' ដូច្នេះ, សេចក្ដីរលឹកខុសរមែងស្ថិតនៅខ្ជាប់ ក្នុងអារម្មណ៍នោះ, ចិត្តជាធម្មជាតមានអារម្មណ៍តែមួយ, ជវនចិត្តទាំងឡាយ រមែងស្ទុះទៅ ។ ក្នុងជវនចិត្តទី ១

មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ជាអ្នកដែលបណ្ឌិតកែបាន, ក្នុងជវនចិត្ត ទី ២ ជាដើម ក៏យ៉ាងដូច្នោះដែរ ។ ក្នុងជវនចិត្ត ទី ៧ មិច្ឆាទិដ្ឋិក-បុគ្គលទាំងនោះ សូម្បីព្រះពុទ្ធទាំងឡាយ ក៏មិនអាចកែបាន មិនអាចឲ្យត្រឡប់មកវិញបាន រមែងជាអ្នកប្រាកដស្មើដោយ អរិដ្ឋភិក្ខុនិងកណ្ឌកសាមណេរ ។ បណ្តាមិច្ឆាទស្សនៈទាំងនោះ បុគ្គលខ្លះ ចុះកាន់ទស្សនៈ ១, បុគ្គលខ្លះ ២ ទស្សនៈ, បុគ្គលខ្លះ ៣ ទស្សនៈ ។ កាលបើចុះកាន់ទស្សនៈ ១ ក្តី, ចុះកាន់ទស្សនៈ ២ -៣ ក្តី, បុគ្គលនោះ ជានិយតមិច្ឆាទិដ្ឋិកបុគ្គល ដោយពិត, បុគ្គលនោះ ដល់នូវការហាមផ្លូវសួគ៌ និងការហាមផ្លូវនិព្វាន ជាអ្នកមិនគួរនឹងទៅសូម្បីកាន់ឋានសួគ៌ ក្នុងលំដាប់នៃអត្តភាពនោះ, មិនចាំបាច់ពោលទៅដល់ព្រះនិព្វានឡើយ ។ សត្វនេះ ជាអ្នកក្រាំងនៅលើផែនដី ឈ្មោះថា ជាគំណាក្នុងវដ្តៈ ។ ភាគច្រើន ការចេញចាកភព របស់សត្វនេះ មិនមានឡើយ " ។

(៨៧) អដ្ឋកថាអបណ្ណកសូត្រ ថា "ក៏បុគ្គលទាំងឡាយណា កាន់យកនូវលទ្ធិនៃគ្រូទាំង ៣ នាក់នោះ ។ល។ សត្វនេះ ជាអ្នកក្រាំងនៅលើផែនដី ឈ្មោះថាជាគំណា ក្នុងវដ្តៈ ។ សួរថា 'ក៏សត្វនេះ ជាអ្នកទៀងទាត់ ក្នុងអត្តភាពតែមួយប៉ុណ្ណោះ ឬក៏ សូម្បីក្នុងអត្តភាពដ៏ទៃទៀតដែរ ? ' ។ ឆ្លើយ ថា ' សត្វនេះ រមែង

ជាអ្នកទៀងទាត់ តែក្នុងអត្តភាពមួយប៉ុណ្ណោះ ៗ ប៉ុន្តែ ដោយអំណាចនៃអាសេវនៈ សូម្បីក្នុងភពដទៃ សត្វនេះ តែងចូលចិត្តនូវទិដ្ឋិនោះៗ ដូចគ្នាដែរ, ក៏ដោយភាពច្រើន ឈ្មោះថា ការចេញចាកភព របស់សត្វបែបនេះ មិនមានឡើយ " ។

(៨៨) ន័យមកក្នុងអដ្ឋកថាអបណ្ណកសូត្រនោះ ថា "បទ ថា **សជ្ឈាយន្តិ** គឺ រមែងរៀននូវគម្ពីរដែលសំដែងទិដ្ឋិនោះហើយសូត្រ ៗ បទ ថា " **វីមំសន្តិ** " គឺ រមែងពិចារណានូវសេចក្តីនៃគម្ពីរនោះ ៗ ពាក្យ ថា " **តេសំ** " ជាដើម ជាពាក្យសំដែងនូវអាការៈគឺការពិចារណា ៗ ២ បទ ថា " **តស្មឹ អារម្មណេ** " មានសេចក្តីថា ក្នុងអារម្មណ៍ នៃលទ្ធិដែលប្រព្រឹត្តទៅ ដោយន័យជាអាទិ៍ ថា ' កាលបើបុគ្គលធ្វើ បាបមិនឈ្មោះថា គឺបុគ្គលធ្វើ ' ដែលសំដែងការមិនមានផល នៃកម្មតាមដែលគ្រូនោះកំណត់ទុកហើយ ៗ បទ ថា " **មិច្ឆាសតិ** " បានដល់ តណ្ហាដែលដល់ព្រមដោយលទ្ធិនោះ ដែលមិច្ឆាវិតក្កៈដឹកនាំបានដោយងាយ ដែលមិច្ឆាវាយាមៈឧបត្ថម្ភហើយ កាន់យកនូវធម៌ដែលមិនមែនជាធម៌ មានហេតុនោះជាសភាព ថា ជាធម៌ដែលមានហេតុនោះជាសភាព ដែលបានឈ្មោះថា **មិច្ឆាសតិ** ៗ ២ បទ ថា " **ចិត្តំ ឯកគ្គំ** " មានសេចក្តីថា មិច្ឆាសមាធិ ដែលមានអារម្មណ៍តែមួយ ដូចជាច្បាស់លាស់ ព្រោះ

លះនូវភាពជាចិត្តដែលមានអារម្មណ៍ច្រើន ហេតុថា តាំងនៅស៊ប់ក្នុងអារម្មណ៍នោះ ដោយការបានបច្ច័យមានវិតក្កៈជាដើម តាមដែលពោលមកហើយ ព្រះអដ្ឋកថាចារ្យពោល ដោយសំដៅយកចិត្ត ។ បទ ថា "**ជវនានិ**" មានសេចក្ដីថា បើវារៈនៃជវនចិត្ត ដែលជាចំណែកខាងដើម ប្រព្រឹត្តទៅដោយអាការនោះច្រើនដង, ជវនចិត្ត ៧ ដួង រមែងស្ទុះទៅ ក្នុងវារៈនៃជវនចិត្ត ដែលមានក្នុងទីបំផុតនៃជវនចិត្តទាំងពួង ។ ពាក្យថា "**បឋមេ ជវនេ សតេកិច្ឆា ហោតិ តថា ទុតិយាទីសុ**" នុ៎ះ គ្រាន់តែជាពាក្យសំដែងនូវសភាវធម៌ ។ តែក្នុងខណៈនោះ អ្នកណាមួយ ក៏មិនអាចធ្វើជនទាំងនោះ ឲ្យបានដល់នូវភាវៈជាអ្នកគួរនឹងកែបានឡើយ ។ បទ ថា "**តត្ថ**" បានដល់បណ្ដាមិច្ឆាទស្សនៈ ៣ យ៉ាងនោះ ។ ២ បទ ថា "**ឯកំ ទស្សនំ**" មានសេចក្ដីថា ការប្រកាន់ខ្ជាប់ និងការសេពគប់ គឺបុគ្គលណាមួយឲ្យប្រព្រឹត្តទៅ ក្នុងមិច្ឆាទស្សនៈមួយប៉ុណ្ណោះ, បុគ្គលនោះ ឈ្មោះថាចុះកាន់នូវមិច្ឆាទស្សនៈមួយប៉ុណ្ណោះ, តែការប្រកាន់ខ្ជាប់ និងការសេពគប់ជ្រុល គឺបុគ្គលណាមួយ ឲ្យប្រព្រឹត្តទៅ ក្នុង ២ ទស្សនៈ ឬសូម្បី ៣ ទស្សនៈ, បុគ្គលនោះ ឈ្មោះថាចុះកាន់ដល់ ២ ទស្សនៈ (ឬ) សូម្បី ៣ ទស្សនៈ ។ ដោយពាក្យថា "**ឯកំ ទស្សនំ**" នេះ ព្រះអដ្ឋកថាចារ្យ សំដែង ថា 'ភាវៈនៃបុគ្គលជាអ្នកមានទិដ្ឋិគ្រប់

យ៉ាង ឯណា ដែលសម្រេចដោយសេចក្តី សំដែងដោយមុខគឺភាវៈជាទិដ្ឋិដែលហាមនូវកម្មនិងវិបាកទាំង ២ យ៉ាង ខាងដើម, ភាវៈនៃបុគ្គលជាអ្នកមានទិដ្ឋិគ្រប់យ៉ាងនោះ ជាបុព្វភាគ, តែកាលបើមានការចុះកាន់ដល់ការកំណត់ភាវៈជាធម៌ខុស, ទិដ្ឋិទាំងពួងទាំងឡាយមិនច្របូកច្របល់គ្នាបានឡើយ ព្រោះមិនកើតឡើង ក្នុងខណៈជាមួយគ្នា ដូចគុណវិសេសដែលគួរសម្រេច មានអារម្មណ៍ផ្សេង ៗ គ្នាព្រោះការប្រជុំសម្រេចបាន តាមបច្ច័យរបស់ខ្លួន ៗ ដោយពាក្យថា '**ឯកស្មឹ ឱក្កន្តេបិ**' ជាដើម ព្រះអដ្ឋកថាចារ្យ សំដែងភាវៈនៃទិដ្ឋិទាំង ៣ យ៉ាង មានកម្លាំងស្មើគ្នានិងមានផលស្មើគ្នា ៗ ព្រោះហេតុនោះ ក៏ទិដ្ឋិទាំង ៣ យ៉ាងនោះ កើតឡើងដល់បុគ្គលម្នាក់ហើយក៏មិនច្របូកច្របល់គ្នាបានឡើយ ៗ កាលបើទិដ្ឋិ ១ ឲ្យផលហើយ, ទិដ្ឋិក្រៅនេះ ក៏រមែងតាមបន្ថែម ឲ្យមានកម្លាំង ៗ ពាក្យថា "**វដ្ដខាណុ នាម**" នេះ ជាពាក្យដែលមានសេចក្តី គឺបណ្ឌិតគប្បីនាំទៅ មិនមែនមានសេចក្តីគឺបណ្ឌិតនាំទៅហើយទេ ហេតុនោះដើម្បីនឹងបើកសំដែងនូវពាក្យនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា '**កិម្បនេសោ**' ដូច្នេះជាដើម ៗ ធម្មតាអកុសលនេះ មិនមានកម្លាំង មានកម្លាំងខ្សោយ មិនមានកម្លាំងច្រើន ដូចជាកុសលទេហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោល ថា '**ឯកស្មឹយេវ អត្តភាវេ**

និយតោ ' ។ ព្រះអដ្ឋកថាចារ្យធ្វើទុកក្នុងចិត្តដោយឧបាយ នូវពាក្យសួរ ថា ' បើប្រកាន់យកសេចក្តីដោយប្រការដទៃ សូម្បីការកំណត់នូវភាវៈថាជាធម៌ខុស ក៏គប្បីប្រព្រឹត្តទៅដល់ទីបំផុត ដូចការកំណត់នូវភាវៈថាជាធម៌ត្រូវ, ប៉ុន្តែ ការកំណត់នូវភាវៈថាជាធម៌ខុស មិនគប្បីប្រព្រឹត្តទៅដល់ទីបំផុតឡើយ, ប្រសិនបើ យ៉ាងដូច្នោះមែន, វាចាគ្រឿងចោទថាជាតំណក្នុងវដ្តៈ នឹងគប្បីមាន យ៉ាងដូចម្តេច ? ' ទើបពោល ថា ' **អាសេវនវសេន បន** ' ជាដើម ។ ព្រោះហេតុនោះ គប្បីដឹងវាចាជាគ្រឿងចោទថាជាតំណ ក្នុងវដ្តៈ ដូចជាព្រះពុទ្ធដីកា ដែលព្រះដ៏មានព្រះភាគត្រាស់ ថា ' បុគ្គលពាលធ្លាក់ចុះទៅហើយតែម្តង ក៏ឈ្មោះថាធ្លាក់ចុះទៅហើយដោយពិត យ៉ាងដូច្នោះឯង ' ។ បុគ្គលណា ក៏មិនគួរពោល ថា ' តាមពិត និយតមិច្ឆាទិដ្ឋិកបុគ្គលនេះ អាស្រ័យបច្ច័យបែបណាហើយ ចុះកាន់ដល់ទស្សនៈនោះ, ក្នុងកាលដងណា គេអាស្រ័យបច្ច័យ ដែលជាសត្រូវដល់បច្ច័យបែបនោះ ក៏នឹងងើបក្បាលឡើងផុត អំពីទស្សនៈនោះ ពុំបានឡើយ ' ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា ' **យេភុយ្យេន** ' ដូច្នេះ " ។

## ( ទោសនៃមិច្ឆាទិដ្ឋិ )

(៨៩) ដូច្នេះ និយតមិច្ឆាទិដ្ឋិ គប្បីដឹងថា មានទោសច្រើន

ជាងអនន្តរិយកម្មទៅទៀត ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ ក្នុងឯកនិបាតអង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ ! តថាគត មិនសំឡឹងឃើញនូវធម៌ដទៃ សូម្បីតែធម៌មួយ ដែលមានទោសច្រើន ដូចជាមិច្ឆាទិដ្ឋិនេះឡើយ, ម្នាលភិក្ខុទាំងឡាយ ! ទោសទាំងឡាយ មានមិច្ឆាទិដ្ឋិដ៏ក្រៃលែង" ។

អដ្ឋកថាឯកនិបាតអង្គុត្តរនិកាយនោះ ថា " មិច្ឆាទិដ្ឋិ ដ៏ក្រៃលែង នៃទោសទាំងឡាយនោះ ហេតុនោះ ទោសទាំងឡាយនោះ ឈ្មោះថា មានមិច្ឆាទិដ្ឋិដ៏ក្រៃលែង ។ អធិប្បាយថា ក៏អនន្តរិយកម្ម ៥ យ៉ាង ឈ្មោះថា មានទោសច្រើន, (ប៉ុន្តែ) មិច្ឆាទិដ្ឋិប៉ុណ្ណោះ មានទោសច្រើន ជាងអនន្តរិយកម្មទាំងនោះ ។ ព្រោះហេតុអ្វី ? ។ ព្រោះអនន្តរិយកម្មទាំងនោះ មានកំណត់ ។ មែនពិត អនន្តរិយកម្ម ៤ យ៉ាង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា 'ញ៉ាំងបុគ្គលឲ្យទៅកើត ក្នុងនរក' ដូច្នេះ, សូម្បីកម្មគឺការញ៉ាំងសង្ឃឲ្យបែកគ្នា ក៏ជាកម្ម ញ៉ាំងបុគ្គលអ្នកធ្វើ ឲ្យស្ថិតនៅក្នុងនរក អស់កប្បប៉ុណ្ណោះឯង ។ អនន្តរិយកម្មទាំងនោះ មានកំណត់, ទីបំផុត ក៏ប្រាកដ យ៉ាងដូច្នោះ ។ ចំណែក និយតមិច្ឆាទិដ្ឋិ មិនមានកំណត់ ។ ព្រោះ និយតមិច្ឆាទិដ្ឋិនោះ ជាមូលនៃវដ្តៈ, ការចេញចាកភព នៃបុគ្គលអ្នកប្រកបដោយនិយតមិច្ឆាទិដ្ឋិនោះ មិនមានឡើយ ។ ជនទាំងឡាយណា សម្គាល់

នូវពាក្យរបស់និយតមិច្ឆាទិដ្ឋិកបុគ្គលនោះថាគួរស្តាប់, និយតមិច្ឆាទិដ្ឋិកបុគ្គល រមែងញុំាងជនទាំងនោះឲ្យប្រតិបត្តិខុស, ក៏បុគ្គលអ្នកប្រកបព្រមដោយនិយតមិច្ឆាទិដ្ឋិនោះ មិនមានឋានសួគ៌ មិនមានមគ្គឡើយ ។ ក្នុងវេលាកប្បវិនាស សូម្បីមហាជនកើត នៅក្នុងព្រហ្មលោក, ក៏និយតមិច្ឆាទិដ្ឋិកបុគ្គលនេះមិនទៅកើត ក្នុងព្រហ្មលោកនោះទេ បែរជាទៅកើត លើខ្នងនៃចក្រវាល ។ សួរថា 'ក៏ខ្នងនៃចក្រវាល តើភ្លើងមិនឆេះទេឬ ?" ។ ឆ្លើយថា 'ភ្លើងឆេះ' ។ អាចារ្យខ្លះពោល ថា 'សូម្បីបើខ្នងនៃចក្រវាលនោះ ត្រូវភ្លើងឆេះ, និយតមិច្ឆាទិដ្ឋិកបុគ្គលនេះ ក៏ត្រូវភ្លើងឆេះ ក្នុងឱកាសមួយ ឰដ៏អាកាសនុ៎ះឯង" ។

(៩០) ដីកាឯកនិបាតអង្គុត្តរនិកាយនោះ ថា "បទថា **បរមា** ប្រែថា ដ៏ក្រៃលែង អធិប្បាយថា ដល់នូវភាវៈជាទោសយ៉ាងឧក្រិដ្ឋ ព្រោះភាវៈនៃមិច្ឆាទិដ្ឋិនោះមានទោសច្រើន ។ បទថា **តេសំ** បានដល់ អនន្តរិយកម្មទាំងឡាយ ។ ការបញ្ចប់ ដោយអំណាចនៃវិបាក ឈ្មោះថាការកំណត់ ។ និយតមិច្ឆាទិដ្ឋិនោះ ជាមូលនៃវដ្តៈ, ដោយហេតុនោះ បុគ្គលអ្នកប្រកបដោយនិយតមិច្ឆាទិដ្ឋិនោះ ទើបបានឈ្មោះថាជាតំណក្នុងវដ្តៈ ហេតុដូច្នោះនុ៎ះ ព្រះអដ្ឋកថាចារ្យពោលថា '**តាយ**' ដូច្នេះជាដើម ។ ព្រះអដ្ឋកថាចារ្យពោល ថា 'ការចេញចាកភពមិនមាន' ដូច្នេះ ព្រោះប្រសិនបើ និយតមិច្ឆាទិដ្ឋិកបុគ្គល

នោះនៅមិនទាន់លះបង់នូវការប្រកាន់នោះ ៗ ទេ ក៏ជាហេតុនាំភាវៈនៃនិយតមិច្ឆាទិដ្ឋិនោះមកវិញ សូម្បីម្តងទៀតបាន, ប៉ុន្តែ លោកក៏មិនបានពោល ព្រោះមិនមានការចេញ (ចាកភព) ដោយប្រការទាំងពួងឡើយ ៗ អ្នកណា ក៏មិនគួរពោល ថា 'ពិតមែនហើយ និយតមិច្ឆាទិដ្ឋិកបុគ្គលនេះ អាស្រ័យបច្ច័យបែបណាហើយ ចុះមកកាន់ទស្សនៈនោះ, ក្នុងកាលដងណា គេអាស្រ័យបច្ច័យដែលជាសត្រូវដល់បច្ច័យបែបនោះហើយ ក៏ងើបក្បាលឡើងឲ្យផុតអំពីទស្សនៈនោះមិនបានទៀតឡើយ' ដូច្នេះ ៗ បទ ថា "**បិដ្ឋិចក្កវាឡេ**" គឺ ខាងខ្នងនៃចក្រវាលដែលភ្លើងកំពុងឆេះ ៗ ២ បទថា "**ឯកស្មឹ ឱកាសេ**" គឺ ក្នុងឱកាសមួយ ដែលដូចគ្នានឹងចន្លោះនៃចក្រវាល ដែលភ្លើងកំពុងឆេះ និងភ្លើងពុំទាន់ឆេះ ដែលមានឈ្មោះថា ជាលោកន្តរិកនរក ៗ អាចារ្យពួកខ្លះពោល ថា 'បទ ថា **បច្ចតិយេវ** បានដល់ បើចក្រវាលត្រូវភ្លើងឆេះក្តី មិនទាន់ឆេះក្តី, និយតមិច្ឆាទិដ្ឋិកបុគ្គលនេះ រមែងត្រូវភ្លើងឆេះ ព្រោះកម្លាំងនៃកម្មរបស់ខ្លួនដោយពិត " ៗ

(៩១) អដ្ឋកថានិក្ខេបកណ្ឌ ថា "ពាក្យថា **យា ច មិច្ឆាទិដ្ឋិនិយតា** មានសេចក្តីថា បណ្តាអហេតុកវាទៈ អកិរិយវាទៈ និងនត្ថិកវាទៈ មិច្ឆាទិដ្ឋិណាមួយ ៗ មែនពិត សូម្បីព្រះពុទ្ធ ១០០ ព្រះអង្គក្តី ១.០០០ ព្រះអង្គក្តី ក៏មិនអាចនឹងញ៉ាំងបុគ្គលដែលកាន់យក

នូវទិដ្ឋិនោះហើយស្ថិតនៅ ឲ្យយល់បានឡើយ " ។

ក៏ដោយ ២ បទ ថា " គហេត្វា ឋិតំ " នោះ ព្រះអដ្ឋកថាចារ្យ ពោល ថា ' ប្រសិនបើ មិច្ឆាទិដ្ឋិកបុគ្គលលះបង់នូវទិដ្ឋិនោះបាន, សូម្បី មគ្គក៏មិនហាមដល់គេដែរ ' ។ ព្រោះហេតុដូច្នោះឯង ក្នុងអដ្ឋកថា ដែលមកទាំងឡាយ លោកពោល ថា ' ដោយភាគច្រើន ការចេញ ចាកភពមិនមាន ' ។ ដូច្នេះ និយតមិច្ឆាទិដ្ឋិកបុគ្គល គឺបុគ្គលដែល ប្រាថ្នានូវសេចក្ដីចំរើន គួរវៀរចាកឲ្យបានឆ្ងាយ ព្រោះភាវៈនៃ និយតមិច្ឆាទិដ្ឋិកបុគ្គលនោះ ធ្វើសេចក្ដីអន្តរាយ សូម្បីដល់បុគ្គលដែល សេពគប់នឹងគេ ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ជាដើម លោកបានពោល ថា ÷

> " ព្រោះហេតុនោះ កុលបុត្រអ្នកប្រាថ្នាសេចក្ដីចំរើន
> មានបញ្ញាជាគ្រឿងពិចារណា គប្បីវៀរចាកនូវ
> អកល្យាណជន ឲ្យបានឆ្ងាយ ដូចជាបុគ្គលដែលវៀរ
> ចាកពស់ដែលមានពិសពូជដ៏ចង្កូម យ៉ាងដូច្នោះ " ។

ដីកាសាមញ្ញផលសូត្រ ជាដើមនោះ ថា " បទ ថា តស្មា មានសេចក្ដីថា ព្រោះហេតុដែលអកល្យាណជន ជាបច្ច័យ សូម្បីនៃ ភាវៈជាតំណក្នុងសំសារវដ្ដៈ យ៉ាងដូច្នោះ ។ បទ ថា " ភូតិកាមោ "

មានសេចក្ដីថា អ្នកប្រាថ្នានូវសេចក្ដីចំរើន ដោយគុណទាំងឡាយ ដើម្បីខ្លួន ដោយអំណាច នៃទិដ្ឋធម្មិកប្រយោជន៍ សម្បរាយិក-ប្រយោជន៍និងបរមត្ថប្រយោជន៍ " ។

## ( កម្មបថខាតព្រោះទិដ្ឋិ ៣ យ៉ាង )

(៩២) ដូច្នោះ កម្មបថខាត ព្រោះទិដ្ឋិ ៣ យ៉ាងនេះ តែប៉ុណ្ណោះ, មិនមែនខាត ព្រោះទិដ្ឋិដទៃឡើយ ។ ទុកណាជាយ៉ាងនេះ អ្នកណាក៏មិនគួរកាន់យកសូម្បីទិដ្ឋិណាមួយឡើយ ព្រោះភាវៈនៃទិដ្ឋិជាធម្មជាតិញុំាងសត្វឲ្យដល់អបាយ ។ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ក្នុងឯកនិបាតអង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកសត្វ ដែលទំលាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ចូលកាន់អបាយ ទុគ្គតិ វិនិបាត នរក ដូចជាមិច្ឆាទិដ្ឋិនេះឡើយ, ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រកបព្រមដោយមិច្ឆាទិដ្ឋិ លុះទំលាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ រមែងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក " ដូច្នេះ ។

## ( មិច្ឆាទិដ្ឋិរារាំងឋានសួគ៌និងមគ្គ )

(៩៣) អដ្ឋកថាឯកនិបាត អង្គុត្តរនិកាយនោះ ថា " មិច្ឆាទិដ្ឋិខ្លះ ជាទោសជាតិរារាំងទាំងឋានសួគ៌ រារាំងទាំងមគ្គ ។ ខ្លះរារាំង

មគ្គតែម្យ៉ាង មិនរារាំងឋានសួគ៌ ។ ខ្លះមិនរារាំងឋានសួគ៌ មិនរារាំងមគ្គឡើយ ។ បណ្តាមិច្ឆាទិដ្ឋិទាំងនោះ មិច្ឆាទិដ្ឋិ ៣ យ៉ាងនេះ គឺ អហេតុកទិដ្ឋិ អកិរិយទិដ្ឋិ នត្ថិកទិដ្ឋិ រារាំងទាំងឋានសួគ៌ រារាំងទាំងមគ្គ ។ មិច្ឆាទិដ្ឋិដែលប្រកាន់ថាលោកមានទីបំផុត មានវត្ថុ ១០ រារាំងមគ្គតែម្យ៉ាង មិនរារាំងឋានសួគ៌ ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិនរារាំងឋានសួគ៌ មិនរារាំងមគ្គឡើយ ។ ក៏លោកស្ទេះវិធីនេះទុកសិនហើយ ពោល ថា 'ឈ្មោះថាទិដ្ឋិ ដោយហោចទៅ សំដៅយកសក្កាយទិដ្ឋិ មានវត្ថុ ២០ ឈ្មោះថា អាចដើម្បីនឹងនាំមិច្ឆាទិដ្ឋិកបុគ្គលទៅកាន់ឋានសួគ៌បានមិនមានឡើយ, (គឺមានតែ) ធ្វើឲ្យធ្លាក់ចុះទៅ ក្នុងនរកដោយចំណែកមួយ ម្យ៉ាងប៉ុណ្ណោះ' ព្រោះព្រះបាលីក្នុងព្រះសូត្រនេះ ថា 'ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ប្រកបព្រមហើយ ដោយមិច្ឆាទិដ្ឋិ' ដូច្នេះជាដើម ។ ប្រៀបឧបមាដូចជា ដុំថ្មនិងគ្រាប់ក្រួស សូម្បីមានទំហំប៉ុនសំណែកខៀវ និងសំណែករាជមាស ដែលបុគ្គលទំលាក់ចោលទៅក្នុងទឹក ឈ្មោះថា អណ្តែតមកលើវិញ មិនមានឡើយ, ដុំថ្មនិងគ្រាប់ក្រួសនោះ រមែងធ្លាក់ចុះទៅពួដីខាងក្រោម ដោយចំណែកមួយប៉ុណ្ណោះ យ៉ាងណាមិញ, មិច្ឆាទិដ្ឋិ ដោយហោចទៅ សូម្បីសក្កាយទិដ្ឋិ ឈ្មោះថាអាចដើម្បីនឹងនាំមិច្ឆាទិដ្ឋិកបុគ្គលទៅកាន់ឋានសួគ៌បាន មិនមានឡើយ, រមែង

ធ្វើឲ្យធ្លាក់ចុះទៅ ក្នុងអបាយទាំងឡាយ ដោយចំណែកមួយ តែម៉្យាង ប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ” ។

(៩៤) ដីកាឯកនិបាតអង្គុត្តរនិកាយនោះ ថា “ ព្រះអដ្ឋកថា-ចារ្យពោល ថា ‘ មិច្ឆាទិដ្ឋិ ៣ យ៉ាងនេះ រារាំងទាំងឋានសួគ៌ ’ ដូច្នេះ ព្រោះភាវៈនៃមិច្ឆាទិដ្ឋិ ៣ យ៉ាងនោះ មានទោសច្រើន ដោយហេតុ ដល់នូវភាវៈជាកម្មបថ ។ បើមិច្ឆាទិដ្ឋិ ៣ យ៉ាងនោះ ជាទោសជាតិ រារាំងឋានសួគ៌, ក៏មិនមានពាក្យដែលគួរនឹងពោល ក្នុងភាវៈនៃ មិច្ឆាទិដ្ឋិ នឹងមិនរារាំងចំពោះមគ្គឡើយ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ពោល ថា ‘ រារាំងទាំងមគ្គ ’ ។ អធិប្បាយថា មិច្ឆាទិដ្ឋិដែល ប្រកាន់យកទីបំផុត មានវត្ថុ ១០ ដែលយល់ឃើញថា លោកទៀង ជាដើម ឈ្មោះថារារាំងមគ្គតែម៉្យាង ព្រោះភាវៈនៃមិច្ឆាទិដ្ឋិនោះ ជាអ្នកយល់ឃើញខុស, ប៉ុន្តែ មិនឈ្មោះថា រារាំងឋានសួគ៌ឡើយ ព្រោះមិនដល់ភាវៈជាកម្មបថ ” ។ គប្បីដឹងវិនិច្ឆ័យ ក្នុងពាក្យថា “ **ឥទម្បន វិធានំ** ” ដូចតទៅនេះ ÷ ព្រះអាចារ្យបដិសេធនូវវិធី ដូចជាព្រះអដ្ឋកថាចារ្យពោលហើយ ដោយបំណង ថា ‘ ពាក្យថា ‘ ក៏ធម្មតាការយល់ឃើញខុស មិនរារាំងឋានសួគ៌ មិនរារាំងមគ្គ ឡើយ ’ ដូច្នេះ នេះ ជាពាក្យខុស ព្រោះខុសធម៌ ។ មែនពិត បើ យ៉ាងដូច្នោះ ការសម្រេចនូវមគ្គ គប្បីមាន ដោយទាំងសក្កាយទិដ្ឋិ

ដែលមិនទាន់លះបង់អស់នុ៎ះឯង ដូច្នេះ' កាលបដិសេធនូវវាទៈនោះ ថា 'ឈ្មោះថាសូម្បីភាវៈនៃទិដ្ឋិនាំមកនូវមគ្គ គឺព្រះអដ្ឋកថាចារ្យទាំងឡាយ កាលពោលនូវភាវៈនៃមិច្ឆាទិដ្ឋិមិនរារាំងចំពោះការចូលកាន់ឋានសួគ៌ ថា 'មិនរារាំងឋានសួគ៌'ដូច្នេះ រមែងជាធម្មជាតិគឺព្រះអដ្ឋកថាចារ្យអនុញ្ញាតហើយ' ដូច្នេះ ទើបពោល ថា 'ធម្មតាទិដ្ឋិ ដែលឈ្មោះថាអាចដើម្បីនឹងនាំមិច្ឆាទិដ្ឋិកបុគ្គលទៅកាន់ឋានសួគ៌មិនមាន' ដូច្នេះ ។ ព្រោះហេតុអ្វី ? ។ ព្រោះភាវៈនៃមិច្ឆាទិដ្ឋិនោះ មានទោសធ្ងន់ដោយចំណែកមួយ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោល ថា '(គឺមានតែ) ធ្វើឲ្យធ្លាក់ចុះទៅក្នុងនរកដោយចំណែកមួយប៉ុណ្ណោះឯង" ដូច្នេះជាដើម ។

## ( សក្កាយទិដ្ឋិ ២០ )

(៩៥) ចំណែក ក្នុងអដ្ឋកថានិក្ខេបកណ្ឌ លោកពោលនូវសេចក្ដីនេះ ថា "ទិដ្ឋិក្នុងរូបក្ខន្ធ មាន ៤ គឺ ឧច្ឆេទទិដ្ឋិ ១ គឺ រមែងតាមឃើញនូវរូប ដោយភាវៈថាជាខ្លួន, សស្សតទិដ្ឋិ ៣ គឺ រមែងតាមឃើញនូវខ្លួនថាមានរូប ១ រមែងតាមឃើញនូវរូបក្នុងខ្លួន ១ រមែងតាមឃើញនូវខ្លួនក្នុងរូប ១, ក្នុងវេទនាខន្ធជាដើម ក៏ន័យនេះដូចគ្នាដែរ, សរុបទៅ សក្កាយទិដ្ឋិមានវត្ថុ ២០ យ៉ាងនេះឯង"

ដូច្នេះហើយ ពោលទៀត ថា "សក្កាយទិដ្ឋិទាំងនោះ សូម្បីទាំងពួង រារាំងមគ្គ (តែម្យ៉ាង) មិនរារាំងឋានសួគ៌ គឺមគ្គទី ១ គប្បីសម្លាប់ចេញ " ដូច្នេះ ៗ

ការសំដែងអំពីវាទៈ ៣ មានអកិរិយវាទៈជាដើម ចប់ ។

## ( អារម្មណ៍នៃអកុសលកម្មបថ )

(៩៦) ឥឡូវនេះ នឹងសំដែង ការពណ៌នាអំពីអារម្មណ៍ នៃអកុសលកម្មបថ មានបាណាតិបាតជាដើម ៗ

ក្នុងអដ្ឋកថាខុទ្ទកបាឋៈ លោកពោលដោយអំណាចពៀរ ៥ យ៉ាង ថា "ក៏បណ្ដាពៀរ ៥ យ៉ាងនោះ បាណាតិបាតមានជីវិតិន្ទ្រិយ៍ជាអារម្មណ៍, អទិន្នាទាន អព្រហ្មចរិយៈនិងសុរាមេរយមជ្ជប្បមាទដ្ឋាន មានបណ្ដាអរូបធម៌ទាំងឡាយ មានសង្ខារមានរូបាយតនៈជាដើម ណាមួយ ជាអារម្មណ៍, មុសាវាទ ឈ្មោះថា មានសត្វជាអារម្មណ៍ ព្រោះប្រារព្ធនូវបុគ្គលដែលត្រូវមុសាវាទីបុគ្គល ពោលកុហកឲ្យប្រព្រឹត្តទៅ ៗ អាចារ្យពួកមួយពោល ថា 'សូម្បីអព្រហ្មចរិយៈ ក៏មានសត្វជាអារម្មណ៍ ' ៗ អាចារ្យពួកខ្លះពោល ថា ' ក៏អទិន្នាទាន ក៏ឈ្មោះថាមានសត្វជាអារម្មណ៍ ព្រោះក្នុងកាលដែលសត្វ ត្រូវអទិន្នាទាយីបុគ្គលគប្បីលួចទៅ ៗ ក៏ប៉ុន្តែថា

ក្នុងសង្ខារនិងបញ្ញត្តិទាំង ២ យ៉ាងនោះ អទិន្នាទាយីបុគ្គលទាំងឡាយ រមែងប្រារព្ធសត្វទាំងឡាយ ដោយអំណាចនៃសង្ខារ មិនមែនប្រារព្ធ ដោយអំណាចនៃបញ្ញត្តិឡើយ " ។

(៩៧) អដ្ឋកថាអដ្ឋសាលិនី អដ្ឋកថាសម្មាទិដ្ឋិសូត្រ និងសង្គីតិសូត្រ ថា "បាណាតិបាត ឈ្មោះថា មានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រីយ៍ជាអារម្មណ៍, អទិន្នាទាន មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអាម្មណ៍ខ្លះ, មិច្ឆាចារៈ មានសង្ខារជាអារម្មណ៍ ដោយអំណាចភារៈជាសភាពគឺបុគ្គលគប្បីពាល់ត្រូវ, អាចារ្យពួកមួយពោល ថា 'មានសត្វជាអារម្មណ៍' ដូច្នេះខ្លះ, មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ, បិសុណវាចា ក៏យ៉ាងដូច្នោះ, ផរុសវាចា មានសត្វជាអារម្មណ៍ តែម៉្យាង, សម្ផប្បលាបៈ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ដោយអំណាច នៃរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍, អភិជ្ឈា ក៏យ៉ាងដូច្នោះ, ព្យាបាទ មានសត្វជាអារម្មណ៍តែម៉្យាង, មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងត្រ័យភូមិខ្លះ មានសត្វជាអារម្មណ៍ ដោយអំណាចនៃបញ្ញត្តិខ្លះ " ។

(៩៨) ដីកាសម្មាទិដ្ឋិសូត្រ និងសង្គីតិសូត្រ ថា "ពាក្យថា

‘ អទិន្នាទាន មានសត្វជាអារម្មណ៍ ’ នេះ រមែងខុស ចាកបាលីនៃអ្នកសួរបញ្ហានេះ ថា ‘ សិក្ខាបទ ទាំង ៥ សុទ្ធតែមានកាមាវចរធម៌ជាអារម្មណ៍ ដោយពិត ” ។ ដោយហេតុថា វត្ថុណា ជាអារម្មណ៍នៃទោសគ្រឿងទ្រុស្តសីល មានបាណាតិបាតជាដើម, វត្ថុនោះឯងជាអារម្មណ៍ នៃចេតនាជាគ្រឿងវៀរចាក ទោសគ្រឿងទ្រុស្តសីលនោះ ។, មែនពិត ចេតនាជាគ្រឿងវៀរចាកវត្ថុ ដែលបុគ្គលគប្បីកន្លងនុ៎ះឯង ឈ្មោះថា វិរតិ ។ ម្យ៉ាងទៀត បទ ថា “ **សត្តារម្មណំ** ” ព្រះអដ្ឋកថាចារ្យពោលហើយ ព្រោះទាញយក នូវភាវៈនៃអទិន្នាទានមានសង្ខារ ពោលគឺសត្វជាអារម្មណ៍ដូចគ្នា ព្រោះហេតុនោះ ទើបមិនមានសេចក្តីខុសអ្វីឡើយ ។

ពិតដូច្នោះមែន លោកពោល ក្នុងអដ្ឋកថាសម្មោហវិនោទនីថា “សិក្ខាបទទាំងឡាយណា គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយក្នុងវិភង្គនៃសិក្ខាបទនេះ ថា ‘មានសត្វជាអារម្មណ៍’ សិក្ខាបទទាំងឡាយនោះ រមែងធ្វើសង្ខារទាំងឡាយ ដែលរាប់ថាជា សត្វនុ៎ះឯងឲ្យជាអារម្មណ៍ ’ ។ សូម្បីក្នុងសិក្ខាបទដទៃក្រៅពីអទិន្នាទាននេះក៏ន័យនេះ (ដែរ) ។ អាចារ្យពួកមួយពោល ថា ‘ មិច្ឆាចារៈឈ្មោះថា មានសត្វជាអារម្មណ៍ ព្រោះភាវៈនៃវត្ថុដែលជាសត្រូវគឺបុគ្គលគប្បីប្រកាន់យកថា ស្ត្រី បុរស ’ ដូច្នេះ ។ សម្ពប្បលាបៈ

មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ដោយអំណាចនៃរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ព្រោះការពោលពាក្យរាយមាយឥតប្រយោជន៍ ដោយន័យជាអាទិ៍ ថា 'ខ្ញុំបានឃើញមនុស្សម្នាក់, បានឮទាំង ២ សំឡេង' ។ តថា ស័ព្ទ ក្នុងពាក្យថា **តថា អភិជ្ឈា** នេះ រមែងប្រមូលមក សូម្បីនូវសេចក្ដីនេះ ថា 'ដោយអំណាចនៃរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍' ប៉ុន្តែរមែងមិនប្រមូលមកនូវភាវៈ នៃអភិជ្ឈា មានសត្វនិងសង្ខារ ជាអារម្មណ៍ប៉ុណ្ណោះទេ ព្រោះសំឡឹងរំពៃបាន ដោយអំណាចនៃកិច្ចមានការឃើញជាដើម ។ ព្រះអដ្ឋកថាចារ្យ ពោលភាវៈនៃមិច្ឆាទិដ្ឋិនោះ មានសង្ខារជាអារម្មណ៍ ដោយបំណង ថា 'មិច្ឆាទិដ្ឋិ សូម្បីកំពុងតែប្រព្រឹត្តទៅ ថា 'សត្វទាំងឡាយដែលជាឧបបាតិកៈ មិនមាន' ដូច្នេះ សុទ្ធតែជាទោសជាតិមានត្រៃភូមិធម៌ ជាអារម្មណ៍មែនពិត" ។

សួរ ថា 'ក៏ធម៌ដែលប្រព្រឹត្តទៅ ក្នុងត្រៃភូមិ ទាំងពួង រមែងជាអារម្មណ៍នៃមិច្ឆាទិដ្ឋិ យ៉ាងដូចម្ដេច ?' ។ ឆ្លើយ ថា 'ដោយទូទៅ ដោយសេចក្ដី សូម្បីធម៌ដែលជារូបាវចរៈ និងអរូបាវចរៈទាំងឡាយ ជាធម្មជាតគឺមិច្ឆាទិដ្ឋិដែលប្រព្រឹត្តទៅ ថា 'ផលវិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើល្អនិងអាក្រក់ មិនមានឡើយ' ដូច្នេះ ប្រកាន់យកហើយ ដោយពិត" ។

កថាពណ៌នាពីអារម្មណ៍នៃអកុសលកម្មបថមានបាណាតិបាតជាដើមចប់ ។

## ( វិនិច្ឆ័យកម្មបថ )

(៩៩) ចំណែក សេចក្ដីនៃកម្មបថស័ព្ទ លោកពោលហើយក្នុងអដ្ឋកថាសង្គីតិសូត្រ ថា "កម្មទាំងឡាយនុ៎ះឯង ឈ្មោះថាកម្មបថ ព្រោះជាគន្លងនៃទុគតិនិងសុគតិទាំងឡាយ " ។

ដីកានៃសង្គីតិសូត្រនោះ ថា "បទ ថា **បថភូតត្តា** គឺ ព្រោះឈ្មោះថាជាផ្លូវ ដោយហេតុថា ជាឧបាយគ្រឿងប្រព្រឹត្តិទៅ នៃទុគតិនិងសុគតិទាំងឡាយនោះ " ។

ដីកានៃសង្គីតិសូត្រជាដើមនោះ ថា 'សួរ ថា ចេតនា គឺព្រះដ៏មានព្រះភាគ មិនបានត្រាស់ហើយ ក្នុងកម្មបថទាំងឡាយ ក្នុងព្រះអភិធម្ម ហេតុនោះ ភាវៈនៃចេតនាទាំង ៧ ជាកម្មបថ ដោយលំដាប់ មិនសមគួរ មិនមែនទេឬ ?' ។ ឆ្លើយ ថា 'មិនមែនមិនសមគួរទេ ព្រោះការមិនទ្រង់ត្រាស់ទុក មានព្រះបំណងដទៃទៀតជាហេតុ ។ មែនពិត ការមិនទ្រង់ត្រាស់ចេតនា ក្នុងកងនៃកម្មបថក្នុងព្រះអភិធម្មនោះ ព្រោះភាវៈនៃចេតនានោះ មិនមែនជាកម្មបថក៏ទេ ។ តែក្នុងកាលខ្លះ ចេតនារមែងបានជាកម្មបថ, មិនបានជាកម្មបថក្នុងកាលទាំងពួងទេ ហេតុនោះ ការមិនទ្រង់ត្រាស់ ព្រោះ

ភាវៈនៃចេតនាជាកម្មបថជាសភាពមិនទៀងទាត់ៗ ក៏ក្នុងពេលណា ចេតនាជាកម្មបថ, ក្នុងពេលនោះ ការសង្គ្រោះចេតនាថា ជាកម្មបថ លោកក៏មិនបានហាមៗ ព្រះអាចារ្យអ្នកចោទពោល ក្នុងអធិការនៃកម្មបថនេះ ថា 'ប្រសិនបើ ភាវៈនៃចេតនាជាកម្មបថ ឈ្មោះថាមិនទៀងទាត់ ព្រោះមិនមានភាវៈជាកម្មបថសព្វៗកាល ហេតុនោះទើបមិនទ្រង់ត្រាស់ចេតនាទុក ក្នុងកងនៃកម្មបថ, ភាវៈសូម្បីនៃអកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ជាកម្មបថ ក៏ឈ្មោះថាមិនទៀតទាត់ ព្រោះភាវៈនៃអកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ដែលមិនទាន់ដល់នូវភាវៈជាកម្មបថក៏មាន ហេតុនោះ ការមិនទ្រង់ត្រាស់សូម្បីអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើមនោះ ក្នុងកងនៃកម្មបថ ក៏រមែងសមគួរ មិនមែនទេឬ ?'ៗ ព្រះអាចារ្យអ្នកឆ្លើយ ក៏គប្បីឆ្លើយ ថា 'មិនសមគួរ ព្រោះអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើមនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយក្នុងព្រះអភិធម្មនោះ ព្រោះជាកម្មបថខ្លះ ព្រោះមានចំណែកស្មើនឹងកម្មបថនោះខ្លះ'ៗ ព្រះអាចារ្យអ្នកចោទគប្បីពោល ថា 'ប្រសិនបើយ៉ាងដូច្នោះ, សូម្បីចេតនាក៏គួរត្រាស់ ក្នុងព្រះអភិធម្មនោះ'ៗ ព្រះអាចារ្យអ្នកឆ្លើយ គប្បីឆ្លើយ ថា 'ពាក្យនុ៎ះជាពាក្យពិត, ក៏ប៉ុន្តែចេតនានោះ ជាអកុសលចេតនាមានបាណាតិបាតជាដើម ហេតុនោះ

ភាវៈនៃចេតនានោះ ជាកម្មបថ ប្រាកដហើយ ហេតុនោះ ចេតនានោះ ទើបមិនគួរនឹងត្រាស់ ។ មែនពិត ភាវៈនៃចេតនាជាកម្ម ប្រាកដហើយ ដោយព្រះបាលី ថា ‘ ម្នាលភិក្ខុទាំងឡាយ តថាគតពោលចេតនាថា ជាតួកម្ម, ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា មាន ៣ យ៉ាង ជាកម្ម ផ្នែកខាងអកុសល ’ ដូច្នេះជាដើម, កម្មនុ៎ះឯង ដែលប្រព្រឹត្តទៅ ដោយភាវៈជាគន្លង នៃសុគតិនិងទុគតិ និងនៃសុខនិងទុក្ខនៃសត្វដែលកើត ក្នុងសុគតិនិងទុគតិនោះ ទើបហៅថា កម្មបថ ហេតុនោះ ភាវៈនៃចេតនានោះ ជាគន្លង (កម្មបថ) ប្រាកដហើយ, ចំណែក ភាវៈនៃអកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ជាសុចរិត និងទុច្ចរិត ក៏ព្រោះមានចេតនាជាទីប្រជុំ និងភាវៈនៃអកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ជាគន្លងនៃសុគតិនិងទុគតិ និងនៃសុខនិងទុក្ខ នៃសត្វដែលកើត ក្នុងសុគតិនិងទុគតិនោះ ក៏ព្រោះភាវៈជាធម៌ គឺចេតនាឲ្យកើតនិងឲ្យចំរើនឡើងហើយ ហេតុនោះ ភាវៈនៃអកុសលធម៌មានអភិជ្ឈាជាដើម ជាកម្មបថ ទើបមិនប្រាកដ ដូច្នោះ ហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ចេតនាទុក ក្នុងព្រះអភិធម្ម ដោយភាវៈជាកងនៃកម្មបថ ដើម្បីទ្រង់សំដែង នូវអកុសលធម៌ទាំងឡាយមានអភិជ្ឈាជាដើមនោះ នុ៎ះឯង តាមសភាពនោះ ៗ ម្យ៉ាងទៀត គប្បីយល់សន្និដ្ឋាន ថា ‘ព្រះដ៏មានព្រះភាគ មិនទ្រង់ត្រាស់

ចេតនាជាមួយនឹងអកុសលធម៌មានអភិជ្ឈាជាដើមនោះ ក៏ព្រោះភាវៈនៃចេតនានោះ មានជាតិមិនពិតប្រាកដ " ។

កថាពណ៌នាអំពីអកុសលកម្មបថ ចប់ ។

## ( កុសលកម្មបថ )

(១០០) ការវៀរចាកអកុសលកម្មបថ ១០ ប្រការ នោះដោយសេចក្ដី បានដល់ កុសលកម្មបថ ១០ ប្រការនុ៎ះឯង ដែលព្រះសារីបុត្តត្ថេរជាដើម ពោលហើយ ក្នុងសម្មាទិដ្ឋិសូត្រជាដើម យ៉ាងនេះ គឺ ចេតនាជាហេតុវៀរចាកបាណាតិបាត ១ ចាកអទិន្នាទាន ១ ចាកកាមេសុមិច្ឆាចារៈ ១ ចាកមុសាវាទ ១ ចាកបិសុណវាចា ១ ចាកផរុសវាចា ១ ចេតនាជាហេតុវៀរចាក សម្ផប្បលាបៈ ១ អនភិជ្ឈា ១ អព្យាបាទៈ ១ សម្មាទិដ្ឋិ ១ ។ ក្នុងអកុសលកម្មបថ កុសលកម្មបថនោះ ខ្ញុំបានពោលអកុសលកម្មបថ មានបាណាតិបាតជាដើម រួចមកហើយ ។

(១០១) ក្នុងអដ្ឋកថាកូដទន្តសូត្រសីលក្ខន្ធវគ្គ លោកពោលថា " វិរតិ ឈ្មោះថា វេរមណី ក្នុងសិក្ខាបទទាំងឡាយ មាន **បាណាតិបាតា វេរមណី** ជាដើម " ដូច្នេះហើយ ពោលភាវៈនៃវេរមណីនោះ មាន ៣ ប្រការ ។

ដីកាកូដទន្តសូត្រនោះ ថា “បាបធម៌មានបាណាតិបាត ជាដើម លោកហៅថា ពៀរ ព្រោះភាវៈនៃបាបធម៌នោះ ជាហេតុនៃពៀរ ។ គុណជាតិណា បណ្តេញ គឺធ្វើដូចជាគម្រាម ថា ‘បើអញឋិតនៅក្នុងទីនេះ, អ្នកឯងនឹងមកបានដូចម្តេច’ ដូច្នេះ កំចាត់បង់នូវពៀរនោះ ហេតុនោះ គុណជាតិនោះ ឈ្មោះថាវេរមណី (អ្នកកំចាត់បង់នូវពៀរ) ។ ម្យ៉ាងទៀត កាលបើព្រះអាចារ្យគប្បីពោល ថា ‘វិរមណី’ ព្រោះវិគ្រោះ ថា ‘បុគ្គលរមែងវៀរចាកបាបធម៌នោះដោយគុណជាតិនុ៎ះ’ ដូច្នេះ, លោកពោល ថា ‘វេរមណី’ ព្រោះផ្លាស់ ឥ អក្សរ ឲ្យទៅជា ឯ អក្សរ តាមន័យមកក្នុងនិរុត្តិបករណ៍”។

(១០២) សូម្បីក្នុងអដ្ឋកថាសម្មាទិដ្ឋិសូត្រ លោកពោល ថា “គុណជាតិណា រមែងបណ្តេញនូវពៀរ អធិប្បាយថា រមែងលះបង់នូវពៀរ ហេតុនោះ គុណជាតិនុ៎ះ ឈ្មោះថា វេរមណី ។ ម្យ៉ាងទៀត បុគ្គលតែងវៀរចាកពៀរ ដោយគុណជាតិនុ៎ះ ដែលជាហេតុ ហេតុនោះ គុណជាតិនុ៎ះ ឈ្មោះថា វេរមណី សូម្បីព្រោះផ្លាស់ វិ អក្សរ ឲ្យទៅជា វេ អក្សរ” ដូច្នេះហើយ ពោលភាវៈនៃវេរមណីនោះ មាន ៣ ប្រការ ” ។

ដីកាសម្មាទិដ្ឋិសូត្រនោះ ថា “បទថា វេរំ បានដល់ បាបធម៌មានបាណាតិបាតជាដើម ។ មែនពិត បាបធម៌នោះ លោកហៅថា

'ពៀរ' ព្រោះភារៈនៃបាបធម៌នោះជាហេតុនៃពៀរ ។ គុណជាតិណា បណ្ដេញ គឺធ្វើដូចជាគម្រាមគំហែង ថា 'កាលបើអញឋិតនៅក្នុងទីនេះ, អ្នកឯងនឹងមកបាន ដូចម្ដេច' ដូច្នេះ ហាមនូវពៀរនោះ ហេតុនោះ គុណជាតិនុ៎ះ ឈ្មោះថា វេរមណី ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យពោល ថា 'តែងលះបង់' ដូច្នេះ ។ បើព្រះអាចារ្យគប្បីពោល ថា '**វិរមណី**' លោកពោល ថា '**វេរមណី**' ព្រោះផ្លាស់ ( **វិ** អក្សរ ) ឲ្យទៅជា **វេ** អក្សរ តាមន័យមកក្នុងនិរុត្តិបករណ៍ " ។

(១០៣) សេចក្ដីនៃវេរមណីស័ព្ទ សូម្បីក្នុងអដ្ឋកថាខុទ្ទកបាឋៈ ក៏ដូចគ្នានោះដែរ ។ ក៏ក្នុងសេចក្ដីនៃវេរមណីស័ព្ទនុ៎ះ គប្បីយល់សន្និដ្ឋាន ដូចតទៅនេះ ÷

២ បទ ថា " **វិការស្ស វេការំ** " បើប្រកាន់យកសេចក្ដីថា 'ឥ អក្សរ ជាទីអាស្រ័យនៅនៃ **វ** ស័ព្ទ ជា **វិ** អក្សរ, **ឯ** អក្សរ ជាទីអាស្រ័យនៅនៃ **វ** ស័ព្ទ ជា **វេ** អក្សរ ក៏រមែងដូចគ្នា ដោយ ២ បទនេះ ថា '**ឥការស្ស ឯការំ**' ។ ព្រះអដ្ឋកថាចារ្យញុំាងកុលបុត្រ ឲ្យយល់ នូវកិរិយាមិនធ្វើ ដោយ **បិ** ស័ព្ទ ថា '**កត្វាបិ**' ។ ព្រោះហេតុនោះ ទើបសំរេចសេចក្ដីថា បាលីទាំង ២ ត្រឹមត្រូវហើយ ។

ពិតដូច្នោះមែន ក្នុងអដ្ឋកថាខុទ្ទកបាឋៈ លោកពោលហើយ ថា

ពុទ្ធបរិស័ទទាំងឡាយ តែងធ្វើការស្វាធ្យាយ ដោយ ២ បទ ថា " **វេរមណី សិក្ខាបទំ, វិរមណី សិក្ខាបទំ** " ដូច្នេះ ។

## ( វិរ័តិ ៣ យ៉ាង )

(១០៤) លោកិយវិរ័តិ ២ យ៉ាង គឺ សម្បត្តវិរ័តិ សមាទានវិរ័តិ ស្មើគ្នាតែមួយ ក្នុងអដ្ឋកថាទាំងពួង ៗ ចំណែក លោកុត្តរវិរ័តិ ក្នុងអដ្ឋកថាកូដទន្តសូត្រ លោកហៅថា " **សេតុឃាតវិរ័តិ** ", ក្នុងអដ្ឋកថាដទៃក្រៅអំពីអដ្ឋកថាកូដទន្តសូត្រនោះ លោកហៅថា " **សមុច្ឆេទវិរ័តិ** " ។

ដីកានៃសូត្រទាំងពួងនោះ ថា " ចេតនាគ្រឿងវៀរ ចាកវត្ថុដែលបានជួបប្រទះ គឺចាកវត្ថុដែលគប្បីកន្លង តាមដែលមកប្រាកដនៃបុគ្គលអ្នកដែលមិនបានសមាទានសីល ឈ្មោះថា **សម្បត្តវិរ័តិ** ។ ចេតនាគ្រឿងវៀរ ដែលកើតឡើង ដោយអំណាចនៃការសមាទាន ឈ្មោះថា **សមាទានវិរ័តិ** " ។

ដីកាកូដទន្តសូត្រ ថា " អរិយមគ្គ ឈ្មោះថា **សេតុ**, វិរ័តិ ដែលរាប់ចូលក្នុងអរិយមគ្គ ដែលឈ្មោះថាសេតុនោះ ជាគ្រឿងសម្លាប់នូវបាបធម៌ទាំងឡាយបាន ដោយអំណាចនៃសមុច្ឆេទបហានៈ ឈ្មោះថា **សេតុឃាតវិរ័តិ** " ។

ដីកាសម្មាទិដ្ឋិសូត្រ ថា " វិរ័តិ ដែលប្រព្រឹត្តទៅ ដោយអំណាចរំលើងកិលេសទាំងឡាយបាន ឈ្មោះថា **សមុច្ឆេទវិរ័តិ** ។

(១០៥) អដ្ឋកថាសម្មាទិដ្ឋិសូត្រ ថា "ក៏ដោយសេចក្ដី វិរ័តិដែលសម្បយុត្តដោយកុសលចិត្ត ឈ្មោះថា **វេរមណី** " ។

អដ្ឋកថាអដ្ឋសាលិនី ក៏យ៉ាងដូច្នោះដែរ ។ សូម្បីក្នុងអដ្ឋកថាទាំង ២ នោះ លោកសំដែងលោកិយវិរ័តិនិងលោកុត្តរវិរ័តិហើយ ។

ចំណែក ក្នុងអដ្ឋកថាខុទ្ទកបាឋៈ លោកលើកលែងសមុច្ឆេទវិរ័តិពោលគឺលោកុត្តរវិរ័តិហើយ ពោលតែវិរ័តិ ២ យ៉ាង ក្រៅអំពីលោកុត្តរវិរ័តិប៉ុណ្ណោះ យ៉ាងនេះ ថា "ឈ្មោះថា **វេរមណី** នោះសូម្បីជាលោកុត្តរក៏មាន ក៏ពិតមែនហើយ, ទោះបីជាយ៉ាងនោះក៏ដោយ វេរមណីនោះ ដែលវៀរចាកការប្រព្រឹត្តិ ដោយអំណាចការសមាទានមិនមាន ព្រោះអ្នកសមាទានពោល ថា '**សមាទិយាមិ**' ក្នុងវេលាសមាទានសិក្ខាបទទាំងពួងនេះ ហេតុនោះ វិរ័តិដែលសម្បយុត្តដោយកាមាវចរកុសលចិត្ត ទើបឈ្មោះថា **វេរមណី** " ។

វិរ័តិទាំង ៣ នោះ ព្រមដោយវិភាគនៃបកិណ្ណកៈមានអារម្មណ៍ជាដើម នឹងមានប្រាកដក្នុងមង្គល ថា "**អារតី វិរតី បាបា**" នេះ ។

## ( កុសលកម្មបថប្រព្រឹត្តទៅក្នុងត្រ័យទ្វារ )

(១០៦) ក៏កុសលកម្មបថ តាមដែលពោលមកហើយនោះ

ជាកាយកម្ម វចីកម្ម និងមនោកម្ម ផ្នែកខាងកុសល ប្រព្រឹត្តទៅក្នុងត្រៃទ្វារ ។ ក៏ក្នុងកាលណា បុគ្គលអ្នកសមាទានកាលមិនអាចដើម្បីនឹងពោលបាន រមែងទទួលយកសិក្ខាបទទាំង ៣ ដោយដៃនិងសិរសីថា "អាត្មាអញនឹងវៀរចាកបាណាតិបាត ចាកអទិន្នាទាន ចាកកាមេសុមិច្ឆាចារៈ" ដូច្នេះ, ក្នុងកាលនោះ សូម្បីកម្មជាកាយកម្ម, សូម្បីទ្វារ ក៏ជាកាយទ្វារ ។ មួយទៀត ក្នុងកាលណា អ្នកដែលសមាទាន បញ្ចេញនូវសំឡេង ហើយទទួលយក, ក្នុងកាលនោះកម្ម ជាកាយកម្ម, ចំណែក ទ្វារ ជាវចីទ្វារ ។ មួយទៀត ក្នុងកាលណា បុគ្គលអ្នកសមាទាន មិនបានញុំាងអង្គគឺកាយនិងអង្គគឺវាចាឲ្យកំរើក ហើយទទួលយក ដោយចិត្តតែម្យ៉ាង, ក្នុងកាលនោះកម្ម ជាកាយកម្ម, ឯទ្វារ ជាមនោទ្វារ ។ សូម្បីបុគ្គលអ្នកដែលសមាទាន ទទួលយកប្រជុំ ៤ នៃវចីកម្មដែលជាកុសល មានចេតនាគ្រឿងវៀរចាកមុសាវាទជាដើម ដោយទ្វារទាំងឡាយមានកាយទ្វារជាដើម តាមន័យដែលព្រះអដ្ឋកថាចារ្យពោលហើយនុ៎ះឯង ក៏ន័យនេះ ដូចគ្នាដែរ ។ កាយកម្មនិងវចីកម្ម ដែលជាកុសល រមែងតាំងឡើង ក្នុងទ្វារទាំង ៣ ដូច្នេះឯង ។ ចំណែក កុសលធម៌មានអនភិជ្ឈាជាដើម ដែលប្រកបព្រម ដោយចិត្តទាំងនោះ ជាគុណធម៌ដែលប្រព្រឹត្តទៅ ក្នុងបក្ខពួកនៃចេតនាខ្លះ ជាអព្វោហារិកខ្លះ ។

(១០៧) ក្នុងដីកាធម្មសង្គណី លោកពោល ថា “ចេតនាដែលជាសត្រូវដល់អកុសលធម៌មានបាណាតិបាតជាដើម ដ៏វិសេសចាកវិរតិនោះ ឈ្មោះថាវិរតិចាកបាណាតិបាតជាអាទិ៍ ព្រោះព្រះបាលី ថា ‘ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ យ៉ាង ជាកាយកម្ម ខាងកុសល’ ដូច្នេះជាដើម ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលថា ‘ប្រព្រឹត្តទៅក្នុងបក្ខពួកនៃចេតនាខ្លះ’ ដូច្នេះ មិនបានពោលថា ‘ប្រព្រឹត្តទៅក្នុងបក្ខពួកនៃវិរតិ’ ឡើយ” ។

(១០៨) ន័យមកក្នុងអដ្ឋកថាអដ្ឋសាលិនី ព្រមទាំងដីកានិងអនុដីកា ថា “ក៏កាលបើបុគ្គល មានចិត្តប្រកបព្រម ដោយកុសលមានអនភិជ្ឈាជាដើម ញុំាងអង្គគឺកាយឲ្យកំរើកហើយ ធ្វើកិច្ចមានការបោសសំអាតលានព្រះចេតិយ បូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម និងថ្វាយបង្គំព្រះចេតិយជាអាទិ៍, កម្ម ជាមនោកម្ម, ចំណែក ទ្វារ ជាកាយទ្វារ ។ កាលបើបុគ្គល មានចិត្តប្រកបព្រមដោយអនភិជ្ឈា ញុំាងអង្គគឺវាចាឲ្យកំរើក មិនសំឡឹងរំពៃ ថា ‘ធ្វើដូចម្តេចហ្ន៎ វត្ថុគ្រឿងឧបករណ៍ដល់ទ្រព្យគ្រឿងពេញចិត្តណារបស់អ្នកដទៃ, វត្ថុគ្រឿងឧបករណ៍ដល់ទ្រព្យគ្រឿងពេញចិត្តនោះ កុំគប្បីមកជាទ្រព្យ របស់អាត្មាអញឡើយ’ ដូច្នេះ, មានចិត្តប្រកបព្រមដោយអព្យាបាទ ពោល ថា ‘សត្វទាំងឡាយទាំងពួងចូរកុំឲ្យមានពៀរ

កុំបីបៀតបៀនគ្នា កុំបីមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សាខ្លួនចុះ ' ដូច្នេះ, មានចិត្តប្រកបព្រមដោយសម្មាទិដ្ឋិ បញ្ចេញសំឡេងមានជាអាទិ៍ ថា ' ទានដែលទាយកឲ្យហើយ មានផល ' ដូច្នេះ, កម្មជាមនោកម្ម, ចំណែក ទ្វារ ជាវចីទ្វារ ។ មនោកម្ម ដែលជាកុសល រមែងតាំងឡើង ក្នុងកាយទ្វារនិងវចីទ្វារ យ៉ាងដូច្នេះឯង ។ ចំណែកចេតនា ក្នុងមនោកម្មដែលប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារនេះ ជាអព្វោហារិក, អធិប្បាយថា ចេតនានោះ សូម្បីតាំងឡើង ក្នុងកាយទ្វារនិងវចីទ្វារ ក៏មិនបានវោហារថា កាយកម្មនិងវចីកម្ម ព្រោះចេតនានោះមានកុសលធម៌ មានអនភិជ្ឈាជាដើម ជាប្រធាន ។ ក៏ចេតនានោះ ជាមនោកម្ម ដោយសភាពតែម្ដង មិនមែនប្រព្រឹត្តទៅក្នុងបក្ខពួកនៃកុសលធម៌មានអនភិជ្ឈាជាដើមឡើយ ព្រោះព្រះបាលី ថា ' ម្នាលភិក្ខុទាំងឡាយ មនោសញ្ចេតនា ៣ យ៉ាង ជាមនោកម្ម ផ្នែកខាងកុសល ' ដូច្នេះជាដើម ។ ព្រោះហេតុនោះ សូម្បីក្នុងអដ្ឋកថាអដ្ឋសាលិនី លោកក៏មិនបានពោល ថា ' ប្រព្រឹត្តទៅក្នុងបក្ខពួកនៃកុសលធម៌មានអនភិជ្ឈាជាដើម ' ដូច្នេះឡើយ ។

ក៏កាលបើបុគ្គល មិនញ៉ាំងអង្គគឺកាយ និងអង្គគឺវាចា ឲ្យកំរើកហើយអង្គុយក្នុងទីកំបាំង ញ៉ាំងចិត្តដែលប្រកបព្រមដោយកុសលធម៌មានអនភិជ្ឈាជាដើម ឲ្យកើតឡើង ដោយចិត្តតែម្យ៉ាង, សូម្បីកម្ម

ក៏ជាមនោកម្ម, ចំណែក ទ្វារ ក៏ជាមនោទ្វារដូចគ្នា ។ មនោកម្ម ដែលជាកុសល រមែងតាំងឡើង ក្នុងមនោទ្វារ យ៉ាងដូច្នេះឯង ។ ក៏ចេតនាក្តី ធម៌ដែលសម្បយុត្តដោយចេតនាក្តី ក្នុងទីនេះ រមែងតាំងឡើង ក្នុងមនោទ្វារតែម្យ៉ាង ។ ព្រោះហេតុនោះ ភាវៈនៃចេតនាជាអព្វោហារិក ទើបមិនមាន ។ ដោយហេតុថា សូម្បីចេតនា ក្នុងទីនេះនោះ រមែងបានវោហារថា មនោកម្ម ។ ក៏ពាក្យមានប្រមាណប៉ុណ្ណេះ ថា 'ចេតនា ជាចេតនាកម្ម, កុសលធម៌មានអនភិជ្ឈា ជាដើម ជាកម្មដែលសម្បយុត្តដោយចេតនា' ដូច្នេះ ជាសេចក្តីខុសប្លែកគ្នា ក្នុងភាវៈនៃចេតនា នឹងកុសលធម៌មានអនភិជ្ឈាជាដើម ជាមនោកម្ម ក្នុងមនោទ្វារ " ។

(១០៩) ក្នុងអធិការនៃកុសលកម្មបថនេះ អាចារ្យអ្នកចោទពោល ថា "ការវៀរចាកបាប ព្រះដ៏មានព្រះភាគទ្រង់កាន់យក ក្នុងមង្គល ថា '**វិនយោ ច សុសិក្ខិតោ**' នេះ មិនមែនទេឬ ?, ព្រះអង្គនឹងទ្រង់ត្រាស់មង្គល ថា '**អារតី វិរតី បាបា**' ដូច្នេះទៀត ដើម្បីប្រយោជន៍អ្វី ?" ។ អាចារ្យអ្នកឆ្លើយ ឆ្លើយថា "បាបធម៌ទាំងឡាយ មានបាណាតិបាតជាដើមណា ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយភាវៈជាកម្មបថ, ការវៀរចាកបាបធម៌មានបាណាតិបាតជាដើមនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ

ក្នុងមង្គល ថា ' **វិនយោ ច សុសិក្ខិតោ** ' នេះ ។ បាបធម៌ទាំងឡាយមានបាណាតិបាតជាដើមណា ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដោយអំណាចនៃពៀរ ៥ យ៉ាង, ការវៀរចាកបាបធម៌ទាំងឡាយ មានបាណាតិបាតជាដើមនោះ ព្រះអង្គទ្រង់ត្រាស់ហើយ ក្នុងមង្គល ថា ' **អារតី វិរតី បាបា** ' នោះ ។

ម្យ៉ាងទៀត បណ្ដាពៀរ ៥ ពៀរ ៤ ខាងដើម ព្រះអង្គទ្រង់ត្រាស់ហើយ ក្នុងសិគាលសូត្រ ថា ជាកម្មកិលេស, ការផឹកទឹកស្រវឹងទ្រង់ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាស នៃភោគៈទាំងឡាយ, ព្រោះហេតុនោះ គប្បីឃើញ ថា ' ពាក្យថា ' **អារតី វិរតី បាបា** ' ជាដើម ព្រះអង្គទ្រង់ត្រាស់ហើយ ដើម្បីនឹងទ្រង់សំដែងការវៀរចាកបាប ដោយអំណាចនៃការទេសនា ក្នុងសិគាលសូត្រ " ។

សូម្បីព្រះអដ្ឋកថាចារ្យទាំងឡាយ ប្រាថ្នាចង់ឲ្យកុលបុត្រយល់នូវសេចក្ដីនេះ ទើបសំដែងបាលី ក្នុងសិគាលសូត្រ ថា " ម្នាលបុត្រគហបតី កម្មកិលេស គឺបាណាតិបាត " ដូច្នេះជាដើម ក្នុងមង្គល ថា ' **អារតី វិរតី បាបា** ' នោះ ។ បាលីក្នុងសិគាលសូត្រនោះនឹងមានប្រាកដ ពួដ៏ខាងមុខ ។

អាចារ្យអ្នកចោទសួរ ថា " ពាក្យដែលលោកពោលហើយយ៉ាងនោះ ចូរស្លេះទុកសិនចុះ, បុគ្គលណាវៀរចាកអកុសលកម្មបថ,

ដោយសេចក្តី បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តធម៌ គឺកុសលកម្មបថ ។ បុគ្គលណា ប្រព្រឹត្តធម៌គឺកុសលកម្មបថនោះ, ដោយសេចក្តី បុគ្គលនោះ ឈ្មោះថា វៀរចាកអកុសលកម្មបថ មិនមែនទេឬ ? ។ បើយ៉ាងដូច្នោះ, ព្រះដ៏មានព្រះភាគនឹងទ្រង់ត្រាស់ នូវការប្រព្រឹត្តធម៌ក្នុងមង្គលនេះ ថា ' **ទានញ្ច ធម្មចរិយា ច** ' ដូច្នេះទៀត ដើម្បីជាប្រយោជន៍អ្វី ? " ។ អាចារ្យអ្នកឆ្លើយ ឆ្លើយ ថា " **វេរមណី** គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ថា **វិន័យ** ដើម្បីទ្រង់សំដែងភាវៈនៃវិរ័តិនុ៎ះឯង ជាមង្គល ក្នុងមង្គលនេះ ថា ' **វិនយោ ច សុសិក្ខិតោ** " ដូច្នេះ ។ ចំណែក **វេរមណី** ដែលព្រះអង្គទ្រង់ត្រាស់ ថា **ការប្រព្រឹត្តិធម៌** ដើម្បីទ្រង់សំដែងការប្រព្រឹត្តិធម៌ថាជាមង្គល ក្នុងមង្គល ថា ' **ទានញ្ច ធម្មចរិយា ច** " នោះ ។

ម៉្យាងទៀត ដោយសេចក្តី ធម៌គឺកុសលកម្មបថ ១០ ប្រការនុ៎ះឯង ឈ្មោះថា ធម្មចរិយា ។ មែនពិត ធម៌គឺកុសលកម្មបថ ១០ ប្រការនោះ ក្នុងព្រះសូត្រទាំងឡាយ មានសាលេយ្យកសូត្រជាដើម ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ យ៉ាងដូច្នោះ ។ ព្រោះហេតុនោះ គប្បីឃើញ ថា ' ពាក្យថា ' **ធម្មចរិយា** ' នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចការទេសនា ក្នុងសាលេយ្យក-សូត្រជាដើម ។

ក្នុងអធិការនៃការប្រព្រឹត្តិត្រូវតាមធម៌នោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ សំដែងបាលីក្នុងសាលេយ្យកសូត្រជាអាទិ៍ ថា “ ព្រាហ្មណ៍និងគហបតីទាំងឡាយ ! សត្វពួកខ្លះ ក្នុងលោកនេះ លុះទំលាយរាងកាយស្លាប់ទៅ រមែងចូលដល់សុគតិ សួគ៌ ទេវលោក ព្រោះហេតុប្រព្រឹត្តត្រូវតាមធម៌ ប្រព្រឹត្តស្មើ ” ដូច្នេះជាដើម ។

(១១០) ក៏បណ្ដាកម្មបថទាំង ២ នោះ កុសលកម្មបថ ហៅថាសុចរិតខ្លះ, អកុសលកម្មបថក្រៅនេះ ហៅថា ទុច្ចរិតខ្លះ ។ បណ្ដាសុចរិតនិងទុច្ចរិតទាំង ២ យ៉ាងនោះ ទុច្ចរិត បុគ្គលមិនគួរធ្វើ ព្រោះជាអករណីយកិច្ច, សុចរិតក្រៅនេះ បុគ្គលគួរធ្វើ ព្រោះជាករណីយកិច្ច ។ មែនពិត បុគ្គលកាលធ្វើកិច្ចដែលគួរធ្វើ រមែងមិនដល់នូវទោសមានការតិះដៀលខ្លួនជាដើម, កាលធ្វើនូវកិច្ចដែលមិនគួរធ្វើ រមែងដល់នូវទោសមានការតិះដៀលខ្លួនជាដើមនោះ ។

ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងអានន្ទ-សូត្រ ទុកនិបាត អង្គុត្តរនិកាយ ថា “ ម្នាលអានន្ទ តថាគតសំដែងថាបុគ្គលមិនគួរធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត សោះឡើយ ។ ម្នាលអានន្ទ ដែលតថាគតសំដែង ថា បុគ្គលមិនគួរធ្វើ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតនេះ សោះឡើយ, កាលបើបុគ្គលធ្វើ ត្រង់អំពើដែលមិនគួរធ្វើនោះ, នឹងបានទទួលទោស ដូច្នេះ គឺ ÷ ខ្លួនឯង

រមែងតិះដៀលខ្លួនឯងបានផង, ពួកបណ្ឌិតពិចារណាហើយ រមែងតិះដៀលបានផង, កិត្តិស័ព្ទដ៏អាក្រក់ រមែងល្បីទូទៅផង, វង្វេងធ្វើកាលកិរិយាផង, លុះទំលាយរាងកាយ បន្ទាប់អំពីមរណៈ រមែងទៅកើត ក្នុងអបាយ ទុគតិ វិនិបាត នរក ផង " ដូច្នេះ, ម្នាលអានន្ទ តថាគតសំដែងថា បុគ្គលគួរធ្វើកាយសុចរិត វចីសុចរិត មនោសុចរិត តែមួយយ៉ាង, អានន្ទ ដែលតថាគតសំដែងថា បុគ្គលគួរធ្វើតែកាយសុចរិត វចីសុចរិត មនោសុចរិត មួយយ៉ាងនេះ, កាលបើបុគ្គលធ្វើ ត្រង់អំពើដែលគួរធ្វើនោះ, នឹងបានទទួលអានិសង្ស ដូច្នេះ គឺ ÷ ខ្លួនឯងនឹងតិះដៀលខ្លួនឯងមិនបានផង, ពួកបណ្ឌិត ពិចារណាហើយ តែងសរសើរផង, កិត្តិស័ព្ទដ៏ល្អ ក៏ល្បីទូទៅផង, មិនវង្វេងស្លាប់ទៅផង, លុះទំលាយរាងកាយ បន្ទាប់អំពីមរណៈ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោកផង " ដូច្នេះ ។

(១១១) ក្នុងអដ្ឋកថា លោកសំដែងវិន័យ ២ យ៉ាង ដោយអំណាចវិន័យរបស់គ្រហស្ថនិងបព្វជិត ដូចបានពណ៌នាមកនេះឯង ។ ម្យ៉ាងទៀត សេចក្ដីថា " វិន័យ " បានដល់ វិន័យ គឺ អាចារបញ្ញត្តិក៏ត្រឹមត្រូវ ។ ដើម្បីប្រកាសនូវសេចក្ដីនោះ គប្បីឃើញរឿងនៃតាបស ២ នាក់ ( ដូចតទៅនេះ ) ÷

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វ បានជាតាបសឈ្មោះ

គន្ធារៈ ជាអ្នកបានឈាននិងអភិញ្ញា ។ ព្រះពោធិសត្វនោះ មានសំឡាញ់ម្នាក់ជាតាបសឈ្មោះថាវេទេហៈ ។ បណ្ដាតាបសទាំង ២ រូបនោះ វេទេហតាបស បានធ្វើការសន្សំអំបិលទុក ។ គន្ធារតាបសដឹងរឿងនោះហើយ តិះដៀលវេទេហតាបសនោះ ជាអនេកប្រការ ។ វេទេហតាបសនោះ អត់ទ្រាំនូវការតិះដៀលនោះមិនបាន ក៏ក្រោធខឹងចំពោះព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វ កាលឱវាទវេទេហតាបសនោះ បានសំដែងនូវគាថា ២ នេះ ក្នុងគន្ធារជាតក ក្នុងសត្តកនិបាត ថា

" ប្រសិនបើ បញ្ញារបស់ខ្លួន ឬ វិន័យដែលសិក្សាល្អហើយ មិនគប្បីមានទេ, ជនជាច្រើន ក៏គប្បីត្រាច់ចរទៅ ដូចជាក្របីខ្វាក់ដើរទៅ ក្នុងព្រៃដូច្នោះ, ក៏ប៉ុន្តែព្រោះសត្វពួកខ្លះក្នុងលោកនេះ ជាអ្នកសិក្សាល្អហើយ ក្នុងសំណាក់នៃអាចារ្យ ព្រោះហេតុនោះ សត្វទាំងនោះ ជាអ្នកមានបញ្ញា មានវិន័យ គឺអាចារ្យដឹកនាំល្អហើយ មានចិត្តតម្កល់ល្អ តែងត្រាច់ចរទៅ " ។

(១១២) សេចក្ដីនៃគាថានោះ ថា " នែសំឡាញ់ វេទេហៈ ប្រសិនបើ បញ្ញារបស់ខ្លួន ឬ វិន័យ គឺអាចារបញ្ញត្តិ ដែលសិក្សាល្អហើយ ព្រោះអាស្រ័យបណ្ឌិតអ្នកឲ្យឱវាទ នឹងមិនគប្បីមាន ដល់សត្វ

ទាំងនេះទេ, កាលបើដូច្នោះ, ជនជាច្រើនដូចជាអ្នក ក៏គប្បីត្រាច់ចរទៅ ដូចជាក្របីខ្វាក់ មិនដឹងទីដែលមានអាហារនិងមិនមានអាហារ និងទីមានអន្តរាយ និងមិនមានអន្តរាយ ដើរទៅក្នុងព្រៃដែលជាសំបុកនៃស្មៅនិងវល្លិ៍ជាដើម ដូច្នោះ ៗ ក៏ប៉ុន្តែ ព្រោះសត្វពួកខ្លះក្នុងលោកនោះ រៀរចាកបញ្ញារបស់ខ្លួន សិក្សាល្អហើយ ក្នុងអាចារ-បញ្ញត្តិ ក្នុងសំណាក់នៃអាចារ្យ ដូច្នោះ សត្វទាំងនោះ ឈ្មោះថាមានវិន័យគឺអាចារ្យដឹកនាំហើយ ព្រោះជាអ្នកគឺអាចារ្យទាំងឡាយដឹកនាំហើយ ក្នុងវិន័យដែលសមគួរដល់ខ្លួន ជាអ្នកមានចិត្តតង់វង់ គឺមានចិត្តមានអារម្មណ៍តែមួយ ត្រាច់ចរទៅ " ៗ ព្រះពោធិសត្វសំដែង ថា " ក៏សត្វនេះ ជាគ្រហស្ថ គួរសិក្សាការសិក្សា ដែលសមគួរដល់ត្រកូលរបស់ខ្លួន, ជាបព្វជិត គួរសិក្សាការសិក្សា ដែលសមគួរដល់បព្វជ្ជា ៗ ព្រោះថា សូម្បីគ្រហស្ថទាំងឡាយ អ្នកសិក្សាល្អហើយ ក្នុងកិច្ចការទាំងឡាយ មានកសិកម្ម និងគោរក្ខកម្ម ជាដើមដ៏សមគួរដល់ត្រកូលរបស់ខ្លួន ជាអ្នកមានអាជីវៈបរិបូណ៌ ឈ្មោះថាអ្នកជាមានចិត្តតង់វង់ ត្រាច់ចរទៅ, សូម្បីបព្វជិតជាអ្នកសិក្សាល្អហើយ ក្នុងមារយាទមានការដើរទៅមុខ និងថយក្រោយជាដើម ដែលនាំមកនូវសេចក្ដីជ្រះថ្លា និងក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខា ដែលសមគួរដល់បព្វជ្ជា ឈ្មោះថា ជាអ្នកមានចិត្ត

តាំងមាំល្អហើយ ត្រាច់ចរទៅ ។

"ក៏ភារៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយប្រពៃ ១ សិល្បសាស្ត្រ ១ វិន័យ ដែលបុគ្គលសិក្សាល្អហើយ ១ វាចា ដែលជាសុភាសិត ១ ទាំង ៤ យ៉ាងនេះ ជាមង្គលដ៏ឧត្តម ក្នុងលោក" ។

វេទេហតាបស បានស្តាប់ឱវាទនោះហើយ ក៏តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វនោះ ហើយបានធ្វើបរិកម្មក្នុងកសិណ ដោយន័យដែលព្រះពោធិសត្វនោះប្រាប់ហើយ ជាអ្នកបានឈាននិងអភិញ្ញា ។ តាបសទាំង ២ រូបនោះ បានទៅកើតក្នុងព្រហ្មលោក ។ សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានតែប៉ុណ្ណោះ ។ ចំណែក សេចក្តីពិស្តារ អ្នកសិក្សាទាំងឡាយ គប្បីទាញយក អំពីគន្ធារជាតក ក្នុងសត្តកនិបាតនោះចុះ ។

រឿងតាបស ២ រូប ចប់ ។

កថាសំដែងអំពីបទថាវិន័យ ចប់ ។

---

ប្រែចប់ នៅថ្ងៃសុក្រ ៥ កើត ខែកត្តិក ឆ្នាំរក ចត្វាស័ក ព.ស.២៥៣៥
៣០ តុលា ៩២

# សុភាសិតវាចាកថា

(១១៣) ក៏គប្បីដឹងវិនិច្ឆ័យ ក្នុងមង្គល ថា " **វាចាដែលជាសុភាសិត ១** " នេះ ដូចតទៅនេះ ÷

ក្នុងអដ្ឋកថាសុភាសិតសូត្រ សុត្តនិបាត និងក្នុងដីកាសុភាសិតសូត្រ បញ្ចកនិបាត អង្គុត្តរនិកាយ លោកពោល ថា " វាចាដែលនិយាយគ្នា តែងមកក្នុងការនិយាយ មានជាអាទិ៍ យ៉ាងនេះ ថា ' វាចាដែលនិយាយ វាចាដែលពោល ពាក្យជាគន្លង ' ដូច្នេះក្តី, ' វាចាដែលមិនមានទោស វាចាដែលសប្បាយត្រចៀក ' ដូច្នេះក្តី, ឈ្មោះថាវាចា ។ តែវិញ្ញត្តិវាចាយ៉ាងនេះ ថា ' បើកម្មដែលបុគ្គលធ្វើហើយ ដោយវាចា ' ដូច្នេះក្តី, វិរតិវាចា យ៉ាងនេះ ថា ' ការវៀរចាកវចីទុច្ចរិត ៤ យ៉ាង ។ល។ នេះ ហៅថាសម្មាវាចា ' ដូច្នេះក្តី, ចេតនាវាចា យ៉ាងនេះ ថា ' ម្នាលភិក្ខុទាំងឡាយ វាចាអាក្រក់ ដែលបុគ្គលសេព ចំរើន ធ្វើឲ្យច្រើនហើយ រមែងញ៉ាំងនរកឲ្យប្រព្រឹត្តទៅព្រម ' ដូច្នេះក្តី, នេះណា រមែងមកដោយឈ្មោះថា ' វាចា ' វិញ្ញត្តិវាចាជាដើមនោះ ព្រះអង្គមិនទ្រង់សំដែង ក្នុងបទ ថា ' **វាចា** ' នេះទេ ។ ព្រោះហេតុអ្វី? ។ ព្រោះមិនមែនជាវាចាដែលគេនិយាយគ្នា " ។

(១១៤) បណ្ដាពាក្យទាំងនោះ ២ ពាក្យថា “ **វាចា គិរា** ” នេះ បើពោលសំដៅយកវាចាដែលមកហើយ ក្នុងនិទ្ទេសនៃវចីវិញ្ញត្តិ ក៏ត្រូវដែរ, បើពោលសំដៅយកវាចាដែលមកហើយ ក្នុងវិភង្គនៃមុសាវាទសិក្ខាបទ ក៏មិនត្រូវដែរ, ព្រោះថា ក្នុងវិភង្គនៃមុសាវាទ-សិក្ខាបទនោះ ចេតនា តែងបានឈ្មោះថា វាចា ។ ព្រោះហេតុនោះ ក្នុងអដ្ឋកថានៃសិក្ខាបទនោះ លោកពោលថា “ចេតនាដែលរាប់ចូលក្នុងមិច្ឆាវាចា ដែលញុំាំងពាក្យពោលឲ្យតាំងឡើង ឈ្មោះថា វាចា ” ។

សូម្បីក្នុងដីកានៃសិក្ខាបទនោះ លោកពោល ថា “ ជនរមែងពោល ដោយចេតនានោះ ហេតុនោះ ចេតនានោះ ឈ្មោះថា វាចា, បានដល់ ចេតនាដែលញុំាំងពាក្យឲ្យតាំងឡើង ” ។ ក៏វាចាសព្ទដែលជាករណសាធនៈ តែងប្រព្រឹត្តទៅ ក្នុងចេតនា ។

ព្រោះហេតុនោះ ក្នុងដីកាព្រហ្មជាលសូត្រ លោកពោល ថា ចេតនា ឈ្មោះថា បិសុណាវាចា ព្រោះវិគ្រោះ ថា “ ជន រមែងពោល នូវពាក្យស៊កសៀតញុះញង់ ដោយចេតនានោះ ” ។

បណ្ដាបទទាំងនោះ បទ ថា “ **វត្តិ** ” អធិប្បាយថា រមែងពោល ។ ដោយហេតុនោះ ក្នុងសទ្ទនីតិបករណ៍ ព្រះអគ្គវង្សាចារ្យពោល ថា “ **វច** ធាតុ ប្រព្រឹត្តទៅ ក្នុងផ្លូវវាចាដែលជាហេតុឲ្យគេ

ដឹងបាន, បទកិរិយា ថា ' វត្តិ វទតិ វទន្តិ វទសិ ' ដូច្នេះជាដើម ជាកត្តុវាចកៈ ។ បណ្ដាបទទាំងនោះ បទ ថា ' វត្តិ ' ប្រែថា រមែងពោល, ហើយនិង បទ ថា ' វត្តិ ' នេះ ជាអាខ្យាតបទ " ។ វាចាសព្ទដែលជាករណសាធនៈនោះ ព្រះដ៏មានព្រះភាគ មិនទ្រង់ប្រាថ្នា ក្នុងមង្គលនេះទេ ។ ចំណែក វាចាសព្ទដែលជាកម្មសាធនៈ រមែងប្រព្រឹត្តទៅ ក្នុងសំឡេង, វាចាសព្ទដែលជាកម្មសាធនៈនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាហើយ ក្នុងមង្គលនេះ ។ វាចាសព្ទ ដែលជាកម្មសាធនៈនោះ ខ្ញុំពោលហើយ ពួដ៏ខាងក្រោយ ។

(១១៥) ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលគាថានេះ ក្នុងវិស័យជាទីកំណត់វចីកម្ម ថា ÷

" បើកម្មដែលបុគ្គលធ្វើហើយ ដោយវាចា កម្មនោះ
លោកហៅថា ' វចីកម្ម ' វចី និងវចីកម្ម លោក
កំណត់ហើយដល់គ្នានិងគ្នា " ។

ព្រោះហេតុដូច្នេះនោះ គប្បីដល់នូវសេចក្ដីសម្រេចចិត្ត ក្នុងមង្គលនេះ ថា " សំឡេងប៉ុណ្ណោះឯង ឈ្មោះថា វាចា, មិនមែនជា ចេតនាទេ " ។

ក៏ពាក្យណា ដែលលោកពោលហើយ ក្នុងអដ្ឋកថាអដ្ឋសាលិនី ក្នុង

ការសំដែងអំពីវចីកម្មទ្វារ ថា "វាចាដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងយ៉ាងនេះ ថា 'ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថាជាវាចាសុភាសិត, មិនមែនជាទុព្ភាសិត, ជាវាចាមិនប្រកបដោយទោសផង, ដែលអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង' ឈ្មោះថា ចេតនាវាចា" ។ ពាក្យនោះ រមែងខុសចាកអដ្ឋកថា តាមដែលលោកពោលហើយ ។

(១១៦) ចំណែក លក្ខណៈនៃសុភាសិត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងសុភាសិតសូត្រ ចតុត្ថបណ្ណាសកៈ នៃបញ្ចកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថាជាវាចាសុភាសិត, មិនមែនជាទុព្ភាសិតទេ, ជាវាចាមិនប្រកបដោយទោសផង, ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។ វាចាដែលប្រកប ដោយអង្គ ៥ តើដូចម្តេច ? ។ គឺ ជាវាចាដែលពោលប្រកប តាមកាល ១ វាចាដែលពោលពិត ១ វាចាដែលពោលទន់ភ្លន់ ១ វាចាដែលពោលប្រកបព្រមដោយប្រយោជន៍ ១ វាចាដែលពោលប្រកបដោយមេត្តាចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ នេះឯង ។ ល ។ ដែលពួកអ្នកប្រាជ្ញមិនគប្បីតិះដៀលផង" ដូច្នេះ ។ ក្នុងអដ្ឋកថានៃសូត្រនោះ លោកក៏មិនបានពោល ពាក្យអ្វីសោះឡើយ ។

(១១៧) ដីកានៃសុភាសិតសូត្រនោះ ថា "បទ ថា **អង្គេហិ** ប្រែថា ដោយការណ៍ទាំងឡាយ ៗ ធម្មជាតទាំងឡាយណា ដែលបុគ្គលតែងកំណត់ គឺតែងដឹង ដោយភាវៈជាហេតុ ហេតុនោះ ធម្មជាតទាំងឡាយនោះ ឈ្មោះថា អង្គ បានដល់ ការណៈៗ ក៏អង្គស័ព្ទ តែងប្រព្រឹត្តទៅ ក្នុងអត្ថ ថា ការណៈ ៗ ពាក្យថា "**បញ្ចហិ**" ជាបញ្ចមីវិភត្តិ ចុះក្នុងហេតុ ៗ បទ ថា "**សមន្នាគតា**" ប្រែថា មកតាមព្រមហើយ គឺ ប្រព្រឹត្តទៅហើយ ៗ វាចាដែលនិយាយគ្នា ឈ្មោះថា វាចា ៗ បទ ថា "**អនវជ្ជា**" គឺ វៀរចាកទោស គឺកិលេសមានរាគៈជាដើម ៗ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវសេចក្តីបរិសុទ្ធិ នៃហេតុ និងភាវៈមិនមានទោស ព្រោះលុះអំណាចមានដល់នូវអគតិជាដើម នៃវាចានោះ ដោយបទនេះ ៗ ព្រោះថា ការលុះក្នុងអគតិ គឺបុគ្គលពោលវាចាដែលរួចផុតរាគៈទោសៈ លើកបានឆ្ងាយតែម្តង ព្រោះវៀរចាកការត្រេកអរ និងមិនត្រេកអរ ៗ បទ ថា "**អននុវជ្ជា**" គឺ រួចចាកការតិះដៀល ៗ ដោយបទនេះ ព្រះអង្គទ្រង់សំដែង ថា 'ភាវៈនៃវាចានោះ មិនត្រូវគេតិះដៀល ក៏ព្រោះដល់ព្រម នៃអាការៈទាំងពួង' ៗ បទ ថា "**វិញ្ញូនំ**" គឺ បណ្ឌិតទាំងឡាយ ៗ ព្រះអង្គទ្រង់ត្រាស់សំដែង ដោយបទនោះ ថា 'ជនពាលទាំងឡាយ មិនជាប្រមាណ ក្នុងការនិន្ទានិងសរសើរ' ៗ

ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវអង្គទាំងនោះ ដោយច្បាស់លាស់ ទើបទ្រង់ត្រាស់បញ្ជាក់នូវវាចានោះ ដោយព្រះពុទ្ធដីកាជាអាទិ៍ថា "ឥមេហិ ខោ" ដូច្នេះ ។ មួ៉ាងទៀត ព្រះអង្គទ្រង់បដិសេធ សូម្បីវាចាមានមុសាវាទជាដើម ដែលប្រកបព្រមដោយអវយវៈមានការប្តេជ្ញាជាដើម ដោយបទមាននាមជាដើម និងដោយសម្បត្តិ គឺ លិង្គ វចនៈ វិភត្តិ កាល និងការកៈ ដែលជនដទៃបញ្ញត្តិថាជាសុភាសិត ។ តាមពិត វាចាប្រាកដដូច្នោះ សូម្បីប្រកបដោយគុណមានអវយវៈជាដើម រមែងជាទុព្ភាសិត ដោយពិត ព្រោះភាវៈនៃវាចានោះ ជាវាចានាំមកនូវសេចក្តីវិនាស ដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង " ។

(១១៨) លក្ខណៈនៃសុភាសិត ព្រះអង្គទ្រង់ត្រាស់ ដោយចំណែក ៥ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ដូចបានពណ៌នាហើយ ។ ចំណែក ក្នុងសុភាសិតសូត្រ ក្នុងតតិយវគ្គ សុត្តនិបាត ទ្រង់ត្រាស់ហើយ ដោយចំណែក ៤ ។

ដូចជាព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយក្នុងសុភាសិតសូត្រនោះ ថា " ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៤ ជាវាចាសុភាសិត, មិនមែនជាទុព្ភាសិតទេ, ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញមិនគប្បីតិះដៀលផង ។

វាចាដែលប្រកប ដោយអង្គ ៤ តើដូចម្តេច ? ។  ម្នាលភិក្ខុទាំងឡាយ  ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ  ពោលតែពាក្យដែលជាសុភាសិតប៉ុណ្ណោះ, មិនពោលពាក្យដែលជាទុព្ភាសិត,  ពោលតែពាក្យដែលប្រកបដោយធម៌ ប៉ុណ្ណោះ,  មិនពោលពាក្យដែលមិនប្រកបដោយធម៌, ពោលតែពាក្យដែលជាទីស្រឡាញ់ប៉ុណ្ណោះ, មិនពោលពាក្យដែលមិនជាទីស្រឡាញ់, ពោលតែពាក្យសច្ចៈប៉ុណ្ណោះ,  មិនពោលពាក្យឡេះឡោះ,  ម្នាលភិក្ខុទាំងឡាយ  វាចាដែលប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថាជាវាចាសុភាសិត,  មិនមែនជាទុព្ភាសិត, ជាវាចាមិនប្រកបដោយទោសផង  ដែលពួកអ្នកប្រាជ្ញ មិនគប្បីនឹងតិះដៀលផង ” ។  ក៏ព្រះដ៏មានព្រះភាគ  លុះត្រាស់ដូច្នេះហើយ ទ្រង់ត្រាស់នូវគាថានេះ  ដែលសំដែងសេចក្តីនោះទៀត ថា ÷

“ សប្បុរស ពោលនូវពាក្យដែលជាសុភាសិត ថាជាពាក្យប្រសើរបំផុត,  ភិក្ខុគប្បីពោលនូវពាក្យ ដែលប្រកបដោយធម៌,  មិនគប្បីពោលនូវពាក្យ ដែលមិនប្រកបដោយធម៌,  នោះជាខទី ២,  គប្បីពោលពាក្យដែលជាទីស្រឡាញ់,  មិនគប្បីពោលនូវពាក្យដែលមិនជាទីស្រឡាញ់,  នោះជាខទី ៣,  គប្បី

ពោលពាក្យសត្យ, មិនគប្បីពោលពាក្យឡេះឡោះ, នោះ ជា ខ ទី ៤ ” ។

(១១៩) អដ្ឋកថាសុភាសិតសូត្រនោះ ថា “ បណ្ដាបទទាំងនោះ បទ ថា **អង្គេហិ** គឺ ដោយហេតុ, ម្យ៉ាងទៀត ដោយអវយវៈ ។ ក៏អង្គ ៤ មានចេតនាជាហេតុវៀរចាកមុសាវាទជាដើម ជាហេតុនៃវាចាជាសុភាសិត, អាការៈ ៤ មានការពោលពាក្យសត្យជាដើម ជាអវយវៈ ។ ក៏អង្គសព្ទ ចុះក្នុងអត្ថ ថា **ហេតុ** ។ បទថា **ចតូហិ** ជាបញ្ចមីវិភត្តិ, អង្គសព្ទ ចុះក្នុងអត្ថ ថា **អវយវៈ**, បទ ថា **ចតូហិ** ជាតតិយាវិភត្តិ ។ បទ ថា “ **សមន្នាគតា** ” ប្រែថា មកតាមព្រមហើយ គឺ ប្រព្រឹត្តទៅ និងប្រកបហើយ ។ បទ ថា **សុភាសិតា** ប្រែថា ពោលដោយល្អហើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ភាវៈនៃវាចាជាសុភាសិតនោះ នាំមកនូវប្រយោជន៍ ដោយបទ ថា **សុភាសិតា** នោះ ។ បទ ថា **ន ទុព្ភាសិតា** ប្រែថា មិនពោលអាក្រក់ឡើយ ។ ព្រះអង្គទ្រង់សំដែង នូវភាវៈនៃវាចាជាទុព្ភាសិតនោះ នាំមកនូវសេចក្ដីវិនាស ដោយបទ ថា **ន ទុព្ភាសិតា** នោះ ។ បទ ថា **អនវជ្ជា** គឺ វៀរចាកទោស មានរាគៈជាដើម ។ ព្រះអង្គទ្រង់សំដែងសេចក្ដីបរិសុទ្ធិនៃហេតុ និងភាពមិនមានទោស ព្រោះ

លុះអំណាចមានការដល់អគតិជាដើម នៃវាចានោះ ដោយបទ ថា **អនវជ្ជា** នោះ ។ បទ ថា “**អននុវជ្ជា ច**” គឺ រួចផុតអំពីការតិះដៀល ។ ព្រះអង្គទ្រង់សំដែងការដល់ព្រមដោយអាការៈទាំងពួងនៃវាចានោះ ដោយបទ ថា **អននុវជ្ជា ច** នោះ ។ បទ ថា **វិញ្ញូនំ** ប្រែថា បណ្ឌិតទាំងឡាយ ។ ទ្រង់សំដែង ថា ‘ជនពាលទាំងឡាយមិនជាប្រមាណ ក្នុងការនិន្ទា និងសរសើរ’ ដោយបទ ថា **វិញ្ញូនំ** នោះ ។ បទ ថា **ឥធ** ប្រែថា ក្នុងព្រះសាសនានេះ ។ ពាក្យថា **សុភាសិតំយេវ ភាសតិ** នេះ ជាពាក្យសំដែងអង្គ ៤ យ៉ាង អង្គណាមួយ ដោយទេសនាជាបុគ្គលាធិដ្ឋាន ។ ពាក្យថា **នោ ទុព្ភាសិតំ** នេះ ជាពាក្យហាមការពោលបដិសេធ ដល់អង្គនោះប៉ុណ្ណោះ ។ ទ្រង់បដិសេធការយល់ឃើញ ថា ‘អកុសលធម៌ទាំងឡាយ សូម្បីមានមុសាវាទជាដើម បុគ្គលគួរនិយាយ ក្នុងកាលខ្លះ’ ដោយបទ ថា **នោ ទុព្ភាសិតំ** នោះ ។ម្យ៉ាងទៀត ទ្រង់សំដែងការលះបង់មិច្ឆាវាចា ដោយបទ ថា **នោ ទុព្ភាសិតំ** នេះ ។ ទ្រង់សំដែងនូវលក្ខណៈនៃពាក្យ ដែលសប្បុរសអ្នកមានមិច្ឆាវាចាលះបង់បានហើយគប្បីពោល ដោយបទ ថា **សុភាសិតំ** នេះ ដូចជាទ្រង់សំដែងនូវកិរិយាមិនធ្វើបាប និងកិរិយាញ៉ាំងកុសលឲ្យដល់ព្រម ដូច្នោះឯង ។ តែដើម្បីនឹងកំណត់សំដែងអង្គ ព្រះដ៏មានព្រះភាគ មិនទ្រង់ត្រាស់

នូវវាចាដែលមិនគួរពោលជាមុនហើយ ទ្រង់ត្រាស់ចំពោះតែវាចាដែលគួរពោលប៉ុណ្ណោះ ។ សូម្បីក្នុងបទទាំងឡាយ មានបទ ថា **ធម្មំយេវ** ជាដើម ក៏ន័យនេះ ។ ក៏បណ្ដាអង្គទាំង ៤ យ៉ាងនោះ ព្រះដ៏មានព្រះភាគទ្រង់សំដែង ពាក្យដែលសំដែងហេតុដោយត្រង់ដែលវៀរចាកទោស មានវាចានិយាយស៊កសៀតជាដើម ដោយបទថា ' **សុភាសិតំយេវ ភាសតិ នោ ទុព្ភាសិតំ** ' នេះ ។ ព្រះអង្គទ្រង់ត្រាស់ពាក្យដែលបុគ្គលពោលដោយបញ្ញា ដែលវៀរចាកទោស គឺការពោលពាក្យរាយមាយឥតប្រយោជន៍ មិនប្រាសចាកធម៌ ដោយបទ ថា ' **ធម្មំយេវ ភាសតិ នោ អធម្មំ** ' នេះ ។ ព្រះអង្គទ្រង់ត្រាស់ពាក្យជាទីស្រឡាញ់ និងពាក្យស័ត្យ ដែលវៀរចាកវាចាអាក្រក់និងពាក្យឡេះឡោះ ដោយ ២ បទក្រៅអំពីនេះ ។ ២ បទ ថា **អាហុ សន្តោ** មានសេចក្ដីថា សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់ត្រាស់ គឺសរសើរពាក្យដែលជាសុភាសិត ថា ' ឧត្ដម គឺ ប្រសើរបំផុត ' ។ ពាក្យថា ' **ទុតិយំ តតិយំ ចតុត្ថំ** ' នេះ ព្រះអង្គទ្រង់ត្រាស់ សំដៅយកនូវលំដាប់ នៃអង្គដែលព្រះអង្គទ្រង់សំដែងចេញ ក្នុងកាលមុន " ។

(១២០) វចីសុចរិត ៤ យ៉ាង មានចេតនាជាហេតុវៀរចាកមុសាវាទជាដើម គប្បីឃើញ ថា ' ជាអង្គ គឺហេតុ ' នៃវាចាដែល

ជាសុភាសិត, វចីសុចរិត ៤ យ៉ាង មានការពោលពាក្យសុភាសិតជាដើម ក៏គប្បីឃើញ ថា 'ជាអង្គ គឺ អវយវៈ' (នៃវាចាដែលជាសុភាសិតនោះ) ។

សូម្បីក្នុងដីកានៃវចីកម្មទ្វារកថា លោកក៏ពោលអង្គ គឺ អវយវៈ ៤ យ៉ាង គឺ "វាចាមិនស៊កសៀត ពោលគឺការពោលពាក្យដែលជាសុភាសិត ១, ការមិនពោលពាក្យរាយមាយឥតប្រយោជន៍ ពោលគឺការពោលពាក្យដែលប្រកបដោយធម៌ ១, ការមិនពោលពាក្យអាក្រក់ ពោលគឺការពោលពាក្យដែលជាទីស្រឡាញ់ ១, ការមិននិយាយកុហក ពោលគឺការពោលតែពាក្យទៀងត្រង់ ១ " ។

(១២១) ហេតុនោះ ជនអ្នកឃើញទោសនៃវចីទុច្ចរិត មានមុសាវាទជាដើម គប្បីពោលតែពាក្យដែលជាសុភាសិតប៉ុណ្ណោះ ។ ក៏ទោសនោះ មកហើយសូម្បីក្នុងសព្វលហុសូត្រ ក្នុងអដ្ឋកនិបាត អង្គុត្តរនិកាយ ។

មែនពិត ក្នុងសព្វលហុសូត្រនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះតម្រាស់នេះ ថា "ម្នាលភិក្ខុទាំងឡាយ មុសាវាទ ដែលបុគ្គលសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាទោសដែលប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីបិតិវិស័យ, ផលនៃមុសាវាទណា ដែលស្រាលជាងផល

ទាំងពួង, ផលនៃមុសាវាទនោះ ជាផលដែលប្រព្រឹត្តទៅ ដើម្បីគេពោលបង្កាច់ ដោយពាក្យមិនពិត ដល់អ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ វាចាស៊កសៀត ដែលបុគ្គលសេពហើយ បានចំរើនហើយ ធ្វើឲ្យច្រើនហើយ ។ ល ។ ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ, ផលនៃបិសុណាវាចាណា ដែលស្រាលជាងផលទាំងពួង, ផលនៃបិសុណាវាចានោះ ជាផលប្រព្រឹត្តទៅដើម្បីបែកបាក់មិត្រ ដល់អ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ វាចាអាក្រក់ ដែលបុគ្គលសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ។ ល ។ ប្រព្រឹត្តទៅដើម្បីបិត្តិវិស័យ, ផលនៃផរុសវាចាណា ដែលស្រាលជាងផលទាំងពួង, ផលនៃផរុសវាចានោះ ជាផលប្រព្រឹត្តទៅដើម្បីសំឡេងមិនជាទីគាប់ចិត្ត ដល់អ្នកកើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការនិយាយពាក្យរាយមាយ ឥតប្រយោជន៍ ដែលបុគ្គលសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ។ ល ។ ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ, ផលនៃសម្ផប្បលាបៈណា ដែលស្រាលជាងផលទាំងពួង, ផលនៃសម្ផប្បលាបៈនោះ ជាផលប្រព្រឹត្តទៅដើម្បីពាក្យដែលមិនគួរកាន់យក ដល់អ្នកកើតជាមនុស្ស " ។

(១២២) អដ្ឋកថាសព្វលហុសូត្រនោះ ថា " បណ្ដាបទទាំងនោះ បទ ថា **សព្វលហុសោ** ប្រែថា ស្រាលជាងផលទាំងពួង ។

បទ ថា " **អភូតព្ភក្ខានសំវត្តនិកោ** " មានសេចក្ដីថា មុសាវាទ រមែងញុំាងការនិយាយមួលបង្កាច់ ដែលមិនពិត ឲ្យប្រព្រឹត្តទៅព្រម គឺ កម្មដែលបុគ្គលណាមួយធ្វើហើយ រមែងធ្លាក់ទៅលើបុគ្គលនោះ ឯង ។ បទ ថា " **មិត្តភេទសំវត្តនិកោ** " មានសេចក្ដីថា វាចាស៊ិកសៀត រមែងញុំាងការបែកចាកមិត្រ ឲ្យប្រព្រឹត្តទៅព្រម គឺ តែងធ្វើបុគ្គលណា ៗ ឲ្យជាមិត្រ, បុគ្គលនោះ ៗ រមែងបែកបាក់គ្នា ដោយពិតប្រាកដ ៗ បទ ថា " **អមនាបសទ្ទសំវត្តនិកោ** " មាន សេចក្ដីថា វាចានោះណា ជាវាចាកាច អាក្រក់ ក្ដៅក្រហាយ ចាក់ដោត កាត់ផ្ដាច់នូវសេចក្ដីស្រឡាញ់, ផរុសវាចីបុគ្គលស្ដាប់តែ វាចានោះប៉ុណ្ណោះ ក្នុងទីកន្លែងដែលខ្លួនទៅហើយ ៗ, មិនបាន ស្ដាប់សំឡេងដែលជាទីពេញចិត្តឡើយ ៗ ក៏ផលប្រាកដដូច្នេះ ឈ្មោះ ថាជាផ្លូវទៅនៃផរុសវចា ៗ បទ ថា "**អនាទេយ្យវាចសំវត្តនិកោ**" មានសេចក្ដីថា រមែងញុំាងពាក្យដែលអ្នកណាមួយ មិនគប្បីជឿ ឲ្យ ប្រព្រឹត្តទៅព្រម ៗ សម្ផប្បលាបីបុគ្គលនោះ រមែងដល់នូវភាវៈ ជាអ្នកគឺអ្នកដទៃគប្បីពោល ថា 'អ្នកឯងពោល ព្រោះហេតុអ្វី, អ្នក ណានឹងជឿពាក្យរបស់អ្នក ' ដូច្នេះ ៗ ផលនេះ ជាផ្លូវទៅនៃវាចា ដែលជាសម្ផប្បលាបៈ " ៗ

(១២៣)ម្យ៉ាងទៀត ទោសនៃបិសុណាវាចា គប្បីសំដែង

ដោយរឿងនៃសូករប្រេត ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាម កស្សបៈ ព្រះថេរៈ ២ រូប គឺ ព្រះមហាថេរៈមានវស្សា ៦០ ព្រះអនុត្ថេរៈ មានវស្សា ៥៩ នៅព្រមព្រៀងគ្នា ដូចជាបងប្អូន នៅក្នុងផ្ទៃនៃមាតាជាមួយគ្នា ក្នុងអាវាស ក្បែរផ្ទះមួយ ៗ គ្រានោះ ភិក្ខុជាធម្មកថិក មួយរូប និមន្តមកកាន់អាវាសនោះហើយ ឃើញការដល់ព្រមនៃភិក្ខាចារវត្ត ចង់ធ្វើឲ្យព្រះថេរៈទាំង ២ រូបនោះ រត់ចេញអំពីអាវាសនោះហើយ ចំណែកខ្លួនឯងនឹងនៅ ក្នុងអាវាសនោះ ទើបពោល ថា “ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ចាប់ដើមតាំងពីថ្ងៃដែលខ្ញុំមកហើយ ព្រះអនុត្ថេរៈពោលយ៉ាងនេះ ថា ‘សប្បុរស លោកជាកុលបុត្រ, ព្រះមហាថេរៈនេះ ជាអលជ្ជី មានសីលមិនជាទីស្រឡាញ់, លោកកាលធ្វើនូវការគប់រក ជាមួយនឹងព្រះមហាថេរៈនោះ គប្បីពិចារណាហើយ ទើបធ្វើ ” ដូច្នេះហើយ នាំពាក្យញុះញង់ ដល់ព្រះមហាថេរៈហើយ នាំពាក្យញុះញង់ សូម្បីដល់ព្រះអនុត្ថេរៈ យ៉ាងដូច្នោះទៀត ។ ព្រះថេរៈទាំង ២ រូបនោះ បែកបាក់គ្នាហើយ ក៏ចៀសចេញអំពីអាវាសនោះ មិននិមន្តទៅតាមផ្លូវជាមួយគ្នាឡើយ នៅក្នុងទីកន្លែងដែលខ្លួនពេញចិត្ត ក្រោយមក ដោយកាលកន្លងទៅបាន ១០០ ឆ្នាំ បានមករួមប្រជុំគ្នា ក្នុងវត្តជាមួយគ្នា ក្នុងសេនាសនៈជាមួយគ្នាដែរ

សំដែងទោស ដល់គ្នានិងគ្នាហើយ ជាអ្នកព្រមព្រៀងគ្នា ក្នុងថ្ងៃនោះ ហើយប្រឹក្សាគ្នា ថា "ពួកយើងមកចុះ, ពួកយើង នឹងបណ្តេញ នូវព្រះធម្មកថិករូបនោះ ចេញអំពីវត្តនោះ" ដូច្នេះហើយ ក៏និមន្តទៅវត្តនោះហើយ ចង្អុលម្រាមដៃជាសញ្ញាឲ្យដឹង ថា "អ្នកឯងជាអ្នកមិនសមគួរ ដើម្បីនឹងនៅ ក្នុងវត្តនេះបានទេ" ដូច្នេះ ។

ព្រះធម្មកថិកនោះ កាលមិនអាចដើម្បីនឹងនៅ ក្នុងវត្តនោះបាន ក៏ចៀសចេញទៅ ។ គ្រានោះ សមណធម៌ដែលព្រះធម្មកថិកនោះ បានធ្វើហើយ អស់រយៈពេល ២ ម៉ឺន ឆ្នាំ ក៏មិនអាចនឹងទ្រទ្រង់ព្រះធម្មកថិកនោះបានឡើយ ។ ព្រះធម្មកថិកនោះ ច្យុតចាកអត្តភាពនោះហើយ ឆេះក្នុងអវចីនរក អស់ ១ ពុទ្ធន្តរ ហើយក៏បានមកកើតជាសូករប្រេត លើកំពូលភ្នំគិជ្ឈកូដ ក្នុងពេលនេះ ។ សរីរៈរបស់ប្រេតនោះ មាន ៣ គាវុត ដូចជាសរីរៈ របស់មនុស្ស, ក្បាល ដូចជាក្បាលនៃជ្រូក ។ កន្ទុយកើតនៅ ត្រង់មាត់ របស់ប្រេតនោះ, ពួកដង្កូវ វារចេញអំពីមាត់នោះឯង ។

រឿងនេះ មកក្នុងមគ្គវគ្គ នៃធម្មបទ ។

(១២៤) ព្រោះហេតុនោះ បុគ្គលគប្បីលះបង់វាចាស៊កសៀតពោលគឺ វាចាទុព្ភាសិតចេញហើយ និយាយតែវាចាមិនស៊កសៀត

ពោលគឺវាចាសុភាសិតប៉ុណ្ណោះ ។ សូម្បីព្រះវង្គីសត្ថេរ កាលញ៉ាំងកុលបុត្រឲ្យដឹងរឿងនេះឯង ទើបពោលគាថានេះ ដែលរាប់ចូលក្នុងសុភាសិតសូត្រ ក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ថា÷

**" បុគ្គលគប្បីពោលវាចា ដែលជាហេតុមិនធ្វើខ្លួនឲ្យក្តៅក្រហាយ និងមិនជាហេតុបៀតបៀនអ្នកដទៃ, វាចានោះឯង ជាវាចាសុភាសិត " ។**

បណ្តាបទទាំងនោះ បទ ថា " **ន តាបយេ** " គឺ មិនគប្បីឲ្យក្តៅក្រហាយ ព្រោះវិបដិសារៈ ។ បទ ថា " **ន វិហឹសេយ្យ** " គឺ កាលបញ្ចេញនូវវាចា ក៏មិនគប្បីបៀតបៀន ដល់គ្នានិងគ្នា ។ បទ ថា " **សា វេ វាចា** " គឺ វាចានោះ ជាវាចាសុភាសិត តែម៉្យាងប៉ុណ្ណោះ ។

(១២៥) ចំណែក បុគ្គលណា ពោលពាក្យរោយរាយ ឥតប្រយោជន៍, បុគ្គលនោះ ឈ្មោះថា អធម្មវាទី ។ មួយទៀត បុគ្គលអ្នកនិយាយមិនប្រកបដោយធម៌ ឈ្មោះថា ញ៉ាំងព្រះសទ្ធម្ម ឲ្យអន្តរធានទៅ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ក្នុងឯកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុទាំងឡាយនោះណា សំដែងនូវសភាពដែលមិនមែនជាធម៌ ថា 'ជាធម៌'

ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនោះ ឈ្មោះថា ប្រតិបត្តិ ដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្ដីទុក្ខ ដល់ជនច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវភារៈមិនជាបុណ្យដ៏ច្រើន, មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះ ឲ្យអន្តរធានទៅ " ។ ព្រោះហេតុដូច្នេះនោះ បុគ្គលគប្បីលះបង់នូវវាចារោយរាយ គ្មានប្រយោជន៍ ពោលគឺការពោលពាក្យ ដែលមិនមែនជាធម៌ចោលចេញហើយ ពោលតែពាក្យមិនរោយរាយ គ្មានប្រយោជន៍ ពោលគឺ ការពោលពាក្យដែលប្រកបដោយធម៌ប៉ុណ្ណោះ ។

## ( រឿងត្រីឈ្មោះថាកបិល )

ក៏ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ មានភិក្ខុ ១ រូប ឈ្មោះកបិល បានជាពហុស្សូត ចេះចាំព្រះត្រៃបិដក មានបរិវារច្រើន និងមានលាភច្រើន ។ ព្រះកបិលនោះ ស្រវឹងដោយសេចក្ដីស្រវឹងក្នុងភាពជាពហុស្សូត ត្រូវសេចក្ដីប្រាថ្នាក្នុងលាភ គ្របសង្កត់ហើយ គិតថាខ្លួនជាបណ្ឌិត ពោលនូវកប្បិយវត្ថុ ដែលពួកជនដទៃពោល ថា " ជាអកប្បិយវត្ថុ " សូម្បីត្រូវពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់

ជាស់តឿន ថា "នែកបិល ដ៏មានអាយុ លោក កុំពោលយ៉ាងនេះឡើយ" ដូច្នេះ ក៏នៅតែសម្លុត កំហែង ដោយពាក្យទាំងឡាយមានពាក្យជាអាទិ៍ ថា "ពួកអ្នកដូចជាមនុស្សដែទទេ នឹងចេះដឹងអ្វី ?" កាលបើភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ មិនជឿពាក្យរបស់ខ្លួន, ក៏បានជេរប្រទេចផ្តាសា ដោយពាក្យអាក្រក់ ៗ ព្រះកបិលនោះ ច្យុតចាកអត្តភាពនោះហើយ បានទៅកើត ក្នុងអវចីនរក ឆេះក្នុងអវចីនរកនោះ អស់ ១ ពុទ្ធន្តរ ដោយផលនៃកម្មដែលសេសសល់ បានមកកើតជាត្រី មានសម្បុរដូចជាមាស ក្នុងស្ទឹងអចិរវតី ៗ ព្រះកបិលនោះ បានជេរ ប្រទេចផ្តាសា ពួកភិក្ខុទាំងឡាយ ក្នុងកាលមុន ដោយផលនៃកម្មណា, មាត់របស់ត្រីនុ៎ះ មានក្លិនស្អុយ ព្រោះផលនៃកម្មនោះ ៗ ត្រីនោះ ច្យុតពីអត្តភាពនោះហើយ បានទៅកើត ក្នុងអវចីនរក ដូចដើមទៀត ៗ

រឿង ត្រីឈ្មោះកបិល មកក្នុងអដ្ឋកថាកបិលសូត្រជាដើម ៗ

(១២៦) ព្រោះហេតុនោះ បុគ្គលគួរលះបង់វាចាអាក្រក់ពោលគឺពាក្យមិនជាទីស្រឡាញ់ហើយ ពោលតែពាក្យមិនអាក្រក់ពោលគឺ ពាក្យជាទីស្រសស្រឡាញ់តែប៉ុណ្ណោះ ៗ សូម្បីព្រះសាស្តា ក៏ទ្រង់តិះដៀលពួកភិក្ខុឆព្វគ្គិយ៍ អ្នកពោលពាក្យអាក្រក់ហើយ ត្រាស់

ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាវាចាអាក្រក់ ជាវាចាធ្វើសេចក្តីវិនាស មិនជាទីពេញចិត្ត សូម្បីនៃសត្វតិរច្ឆានទាំងឡាយសោះឡើយ, សូម្បីក្នុងកាលមុន សត្វតិរច្ឆាន ១ បានញ៉ាំងម្ចាស់ ដែលហៅខ្លួនដោយពាក្យមិនពិរោះ ឲ្យបរាជ័យ ដោយទ្រព្យ ១ ពាន់ " ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ថា ÷

## ( រឿងគោឈ្មោះនន្ទិវិសាល )

ក្នុងអតីតកាល ព្រះពោធិសត្វ បានកើតក្នុងកំណើតនៃគោ ក្នុងក្រុងតក្កសីលា ។ គ្រានោះ ព្រាហ្មណ៍ម្នាក់ បានគោនោះ ក្នុងសំណាក់នៃបុគ្គលអ្នកឲ្យទក្ខិណាទាន ក្នុងពេលនៅជាកូនគោតូចខ្ចីនុ៎ះឯង បានដាក់ឈ្មោះ ថា " **នន្ទិវិសាល** " តាំងទុកក្នុងតំណែងដូចជាកូនហើយ បានចិញ្ចឹមដោយយាគូនិងភត្តជាដើម ។

គោនន្ទិវិសាលនោះ ធំពេញវ័យហើយ នឹកស្រណោះព្រាហ្មណ៍ទើបពោល ថា "បពិត្រព្រាហ្មណ៍ សូមម្ចាស់អញ្ជើញទៅចុះ, សូមម្ចាស់ប្រាប់ ថា 'គោពលិព័ទ្ធរបស់ខ្ញុំ នឹងអូសរទេះចំនួន ១០០ រទេះ ដែលគេចងជាប់គ្នាបាន' ដូច្នេះហើយ សូមធ្វើនូវការភ្នាល់ ដោយទ្រព្យ ១ ពាន់ ជាមួយនឹងគោវិន្ទសេដ្ឋីចុះ " ។

ចំណែកខាងព្រាហ្មណ៍ បានទៅប្រាប់ដូច្នោះហើយ ផ្ទុករទេះ

មួយរយ ពេញដោយខ្សាច់ ក្រួស និងដុំថ្មជាដើមហើយ តម្រៀបគ្នា តាមលំដាប់ បានយកខ្សែចងជាប់ជាមួយគ្នាហើយ ដាក់ឈើកំណល់ ក្រោមកង់ យកខ្សែចងចុងនឹមមួយ ត្រង់ទូករទេះខាងមុខ ហើយ ញាត់ឈើកំណល់ ដោយប្រការដែល កាលបើគោមួយអូសទៅ ចុងនឹមនឹងមិនកម្រើក ទៅខាងនេះខាងនោះបានហើយ ទឹមនូវគោ នន្ទិវិសាល ត្រង់ចុងនឹមមួយ អង្គុយលើកូនគ្រែរទេះ លើកខ្សែតី ស្រែកបង្អើលហៅគោនន្ទិវិសាលនោះ ដែលជាគោមិនគៀច ដោយ វាទៈ ថាគោគៀច ថា " នែគោគៀច ! ចូរអ្នកទៅ, នែគោ គៀច ! ចូរអ្នកអូសទាញទៅ " ដូច្នេះ ។

គោនន្ទិវិសាល ឮសំឡេងមិនជាទីពេញចិត្តហើយ ក៏បានឈរ នៅស្ងៀម ក្នុងទីនោះឯង ។ ព្រាហ្មណ៍ក៏ចាញ់គេ អស់ទ្រព្យ ១ ពាន់ហើយ ក៏បានទៅផ្ទះ ដេកសោកសៅ ។ គោនន្ទិវិសាល ដើរទៅមក ឃើញព្រាហ្មណ៍នោះសោកសៅហើយ ទើបពោល ថា " បពិត្រព្រាហ្មណ៍ សូមម្ចាស់ទៅចុះ, សូមម្ចាស់ធ្វើការភ្នាល់ ដោយទ្រព្យ ២ ពាន់ ជាមួយនឹងគោវិន្ទសេដ្ឋី, តែសូមម្ចាស់ កុំ ហៅខ្ញុំ ដោយវាទៈថាគោគៀចឡើយ " ។ ព្រាហ្មណ៍បានទៅ ប្រាប់ដូច្នោះឯងហើយ ក៏ពោល ថា " នែគោដ៏ចំរើន ! អ្នកចូរទៅ, នែគោដ៏ចំរើន ! អ្នកចូរអូសទៅ " ។ គោនន្ទិវិសាល បានពន្លូវ

សំឡេងជាទីពេញចិត្តហើយ អូសរទេះ ១០០ ដែលគេចងជាប់គ្នាទៅដោយកម្លាំងតែមួយ ដាក់រទេះដែលឋិតនៅខាងក្រោយ ក្នុងទីដែលរទេះខាងមុខឋិតនៅ ៗ កាលបើកាំដល់ទីនៃកាំដែលឋិតនៅមុនទៀតហើយ, រទេះ ១០០ ជារទេះដែលប្រព្រឹត្តទៅបាន ក៏ពិតមែនហើយ, ទោះបីដូច្នោះក៏ដោយ ព្រះពោធិសត្វ ឲ្យរទេះខាងក្រោយឋិតនៅ ក្នុងទីដែលរទេះខាងមុខឋិតនៅហើយ ញុំាងរទេះឲ្យទៅដល់ទីដែលមានរទេះចំនួន ១០០ ៗ មែនពិត ឈ្មោះថាកិរិយាធ្វើធុរថយ នៃព្រះពោធិសត្វទាំងឡាយ មិនមានឡើយ ៗ

ព្រះដ៏មានព្រះភាគ លុះទ្រង់នាំអតីតនិទានមក ដូច្នេះហើយទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាវាចាអាក្រក់ ជាវាចាដែលមិនជាទីពេញចិត្ត នៃអ្នកណាមួយឡើយ" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវព្រះគាថានេះ ក្នុងនន្ទិវិសាលជាតក ក្នុងកតិយវគ្គ នៃឯកនិបាត ថា ÷

(១២៧) " បុគ្គលគប្បីនិយាយពាក្យ ជាទីគាប់ចិត្ត
តែម្យ៉ាង, មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្ត ក្នុង
កាលណាឡើយ, កាលព្រាហ្មណ៍និយាយពាក្យជា
ទីគាប់ចិត្ត, គោនន្ទិវិសាល បានទាញភារៈដ៏ធ្ងន់រួច

ញ៉ាំងព្រាហ្មណ៍នោះ ឱ្យបានទ្រព្យផង ជាសត្វ
មានចិត្តរីករាយ ដោយការញ៉ាំងព្រាហ្មណ៍នោះ
ឱ្យបានទ្រព្យផង " ។

បណ្ដាបទទាំងនោះ បទ ថា "**មនុញ្ញមេវ**" មានសេចក្ដីថា បុគ្គលកាលនិយាយ ជាមួយនឹងអ្នកដទៃ គប្បីនិយាយតែវាចា ដែលជាទីស្រឡាញ់ ពិរោះ ជាទីគាប់ចិត្ត ផ្អែមល្ហែម ទន់ភ្លន់ ដែលវៀរចាកទោស ៤ ប្រការ ។ បទ ថា "**ឧទទ្ធរិ**" មានសេចក្ដីថា គោនន្ទិវិសាល, កាលព្រាហ្មណ៍និយាយពាក្យមិនជាទីគាប់ចិត្ត, ក៏មិនបានទាញភារៈទៅ, ក្រោយមក កាលព្រាហ្មណ៍និយាយពាក្យជាទីគាប់ចិត្ត, ទើបទាញភារៈដ៏ធ្ងន់ហើយ បានទៅដល់ (ទីកន្លែង) ។ ក៏ **ទ** អក្សរ ក្នុងពាក្យថា "**ឧទទ្ធរិ**" នេះ ធ្វើការតបទ ដោយអំណាចព្យញ្ជនសន្ធិ ។

ក្នុងអដ្ឋកថាបាចិត្តិយ៍ លោកពោល ថា "បាទគាថា ថា **តេន ចត្តមនោ អហុ** មានសេចក្ដីថា គោនន្ទិវិសាលនោះ ជាសត្វមានចិត្តត្រេកអររីករាយហើយ ដោយការបានទ្រព្យនៃព្រាហ្មណ៍ និងដោយកម្មរបស់ខ្លួននោះ" ។ ចំណែក ក្នុងគម្ពីរព្រះវិន័យ លោកបានសរសេរ ថា ÷

"មនាបមេវ ភាសេយ្យ នាមនាបំ កុទាចនំ
មនាបំ ភាសមានស្ស " ដូច្នេះ ។

រឿង គោនន្ទវិសាល ចប់ ។

(១២៨) ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលភិក្ខុទាំងនោះ ហើយ ទ្រង់ត្រាស់រឿងគោសារម្ភៈ ថែមទៀត ថា ÷

## ( រឿង គោសារម្ភៈ )

ក្នុងអតីតកាល ព្រះពោធិសត្វបានកើតជាគោពលិព័ទ្ធ ឈ្មោះ សារម្ភៈ នៃព្រាហ្មណ៍ម្នាក់ ក្នុងក្រុងតក្កសីលា ដូច្នេះជាដើម ។ រឿងទាំងអស់ ដូចគ្នានឹងរឿងមុនដែរ ។

ព្រះដ៏មានព្រះភាគ លុះត្រាស់អតីតនិទានហើយ ទើបត្រាស់ គាថានេះ ក្នុងសារម្ភជាតក ក្នុងនវមមគ្គ នៃឯកនិបាតនោះនុ៎ះឯង ថា÷

" បុគ្គលគប្បីបញ្ចេញវាចាល្អ តែម្យ៉ាង, មិនគប្បី
បញ្ចេញវាចាអាក្រក់ឡើយ, ការបញ្ចេញវាចាល្អ
ជាការប្រសើរ, ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់
រមែងក្តៅក្រហាយ " ។

បណ្តាបទទាំងនោះ បទថា "កល្យាណិមេវ" មានសេចក្តីថា គប្បីបញ្ចេញ គឺគប្បីលះ បានដល់ គប្បីពោលវាចាដែលល្អ គឺដែល

មិនមានទោស វៀរចាកទោស ៤ យ៉ាង តែម្យ៉ាង ៗ បទ ថា "បាបិកំ" មានសេចក្តីថា មិនគប្បីបញ្ចេញ គឺ មិនគប្បីពោលវាចាលាមក គឺ មិនជាទីស្រឡាញ់ បានដល់ មិនជាទីគាប់ចិត្តនៃជនដទៃឡើយ ៗ បាទគាថា ថា "**មោក្ខោ កល្យាណិយា សាធុ**" បានដល់ ការពោលវាចាល្អប៉ុណ្ណោះ ជាការប្រសើរ គឺ ចំរើន ៗ បាទគាថា ថា "**មុត្វា តប្បតិ បាបិកំ**" មានសេចក្តីថា បុគ្គលបញ្ចេញ គឺពោលវាចាលាមក គឺ អាក្រក់ រមែងក្តៅក្រហាយ គឺលំបាក ៗ

រឿង គោសារម្ភៈ ចប់ ៗ

(១២៩) មួយវិញទៀត បុគ្គលអ្នកពោលពាក្យដែលជាទីស្រឡាញ់ ជាអ្នកបានលាភដ៏លើសលប់ ជាងជនទាំងឡាយដទៃ ៗ ក្នុងសេចក្តីនោះ មានរឿងនេះ ( ជាឧទាហរណ៍ )

## ( រឿង សេដ្ឋីបុត្រ ៤ នាក់ )

ក្នុងអតីតកាល សេដ្ឋីបុត្រ ៤ នាក់ ក្នុងទីក្រុងពារាណសី បានចេញពីនគរ ទៅអង្គុយក្នុងទីមួយហើយ ឃើញព្រានម្រឹគម្នាក់ បានសាច់ជាច្រើន ដាក់ពេញរទេះ កំពុងមកកាន់នគរ ដើម្បីនឹងលក់ ទើបសុំដុំសាច់នោះ ៗ បណ្តាសេដ្ឋីបុត្រទាំងនោះ សេដ្ឋីបុត្រម្នាក់ បានពោល ថា "នែព្រាន វ៉ឺយ អ្នកចូរឲ្យដុំសាច់ ដល់ខ្ញុំ (ខ្លះមក)" ៗ

នាយព្រានតប ថា " ធម្មតាបុគ្គលអ្នកសុំនូវវត្ថុអ្វីមួយ នឹងអ្នកដទៃ គួរនិយាយ ដោយពាក្យដែលជាទីស្រឡាញ់,

វាចារបស់អ្នកអាក្រក់ណាស់, អ្នកជាអ្នកសុំសាច់
តែវាចាប្រហែលនឹងវារ់, នែសំឡាញ់ យើងនឹង
ឲ្យវារដល់អ្នក " ដូច្នេះហើយក៏បានឲ្យដុំសាច់វារ ដែលមិន

មានរសជាត (ដល់សេដ្ឋីទី ១នោះ) ៗ សេដ្ឋីបុត្រ ទី២ ពោល ថា " ម្នាលបងប្រុស សូមបងឲ្យដុំសាច់ ដល់ខ្ញុំ (ខ្លះផង) " ដូច្នេះ ៗ

នាយព្រាន ពោល ថា " ម្នាលសំឡាញ់ !
ពាក្យដែលថា ' ជនជាបង ប្អូន ' នេះ គេទុក
ជាអវយវៈ របស់មនុស្សទាំងឡាយ ក្នុងលោក,
វាចារបស់អ្នក ប្រហែលនឹងអវយវៈ, នែសំឡាញ់
យើងនឹងឲ្យនូវសាច់អវយវៈ ដល់អ្នក " ដូច្នេះ ៗ

សេចក្តីអធិប្បាយ នៃគាថានោះ ថា (នាយព្រាន) ពោល ថា " ពាក្យថា ' បងប្រុស, បងស្រី ' នេះ គេទុកជាអវយវៈ ព្រោះ ពាក្យនោះដូចជាអវយវៈ របស់មនុស្សទាំងឡាយ ក្នុងលោកនេះ, ព្រោះហេតុនោះ វាចារបស់អ្នកនុ៎ះ ប្រហែលនឹងអវយវៈ ព្រោះហេតុ នោះ យើងនឹងឲ្យសាច់អវយវៈដែលសមគួរដល់វាចានុ៎ះឯង " ដូច្នេះ ហើយ ក៏បានឲ្យសាច់អវយវៈ (ដល់សេដ្ឋីបុត្រទី ២ នោះ ) ៗ

សេដ្ឋីបុត្រ ទី ៣ ពោល ថា “បពិត្រលោកឳពុក សូមលោកឳពុកឲ្យនូវដុំសាច់ ដល់ខ្ញុំ ( ខ្លះផង ) ” ដូច្នេះ ។ នាយព្រាន ពោល ថា “ អ្នកនឹងបាននូវដុំសាច់ដ៏សមគួរដល់វាចារបស់អ្នក ” ដូច្នេះហើយ ពោលគាថានឹងសេដ្ឋីបុត្រ ទី ៣ ថា ÷

(១៣០) “កូនកាលហៅបិតា ថា ‘ ឳពុក ។ ’ ដូច្នេះ
រមែងធ្វើបេះដូងនៃបិតាឲ្យកម្រើក, វាចារបស់អ្នក
ប្រហែលគ្នានឹងបេះដូង, នៃសំឡាញ់ យើងនឹងឲ្យ
នូវបេះដូង ដល់អ្នក ” ដូច្នេះហើយ ក៏បានឲ្យសាច់ដ៏ឆ្ងាញ់

មួយអន្លើនឹងសាច់បេះដូងទៅ ។ សេដ្ឋីបុត្រ ទី ៤ ពោល ថា “ នៃសំឡាញ់ សូមសំឡាញ់ឲ្យដុំសាច់ ដល់ខ្ញុំ (ខ្លះផង) ” ដូច្នេះ ។

នាយព្រាន ពោល ថា “អ្នកនឹងបានសាច់ ដ៏សមគួរដល់វាចារបស់អ្នក ” ដូច្នេះហើយ ពោលគាថា នឹងសេដ្ឋីបុត្រ ទី ៤ ថា ÷

“ សំឡាញ់របស់បុរសណា មិនមានក្នុងស្រុក, ទី
លំនៅរបស់បុរសនោះក្នុងស្រុកនោះឯង ដូចជាព្រៃ,
វាចាអ្នក ប្រហែលនឹងសម្បត្តិទាំងពួង, នៃសំឡាញ់
យើងនឹងឲ្យសាច់ទាំងអស់ ដល់អ្នក ” ។

សេចក្តីនៃគាថានោះ ថា (ព្រានព្រៃ) ពោលថា "សំឡាញ់របស់បុរសណា មិនមានក្នុងស្រុក, ផ្ទះនោះរបស់បុរសនោះ ក៏ដូចជាព្រៃ ដែលគ្មានមនុស្សនៅ៎ះឯង ហេតុនោះ វាចារបស់អ្នកនេះ ដូចជាសម្បត្តិដែលមាននៅរបស់ខ្លួនទាំងអស់, ព្រោះហេតុនោះ យើងនឹងឲ្យសាច់ដែលជារបស់មាននៅ របស់យើងនេះ ព្រមទាំងយានតូចទាំងអស់ ដល់អ្នកតែម្តង" ដូច្នេះហើយ ទើបបរយានតូច ទៅផ្ទះសេដ្ឋីបុត្រ ទី ៤ នោះ មួយអន្លើនឹងគាត់ហើយ បានឲ្យហើយ ។

ឯសេដ្ឋីបុត្រ បានធ្វើសក្ការៈ និងការរាប់អាន ដល់ព្រាននោះ បានឲ្យបុរសទៅហៅបុត្រនិងភរិយា របស់ព្រាននោះមកហើយ បាននាំចេញពីការងារព្រានព្រៃ ឲ្យគាត់នៅក្នុងកណ្តាល នៃគំនរទ្រព្យរបស់ខ្លួន បានជាសំឡាញ់អ្នកមិនបែកបាក់គ្នា មួយអន្លើនឹងព្រានព្រៃនោះ រហូតអស់មួយជីវិត ។

រឿងសេដ្ឋីបុត្រ មកក្នុងមំសលាភិជាតក ក្នុងទុតិយវគ្គនៃចតុក្កនិបាត ។

## ( រឿង ព្រះវង្គីសត្ថេរ )

(១៣១) ព្រោះហេតុនោះ បុគ្គលគប្បីពោលវាចាដែលជាទីស្រឡាញ់ តែម្យ៉ាងប៉ុណ្ណោះ ។ សូម្បីព្រះវង្គីសត្ថេរ កាលញ៉ាំងកុលបុត្រឲ្យដឹងនូវសេចក្តីនេះឯង ទើបពោលគាថានេះ ដែលរាប់

បញ្ចូលក្នុងសុភាសិតសូត្រ ចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគ ថា

" បុគ្គលគប្បីពោលវាចាដែលជាទីស្រឡាញ់ តែម្យ៉ាង, វាចាណាដែលបណ្ឌិតលើកដំកើង, បុគ្គលកាលពោលពាក្យណា មិនប្រកាន់ពាក្យអាក្រក់ របស់ពួកជនដទៃហើយ ពោលវាចាដែលជាទីស្រឡាញ់នោះ " ។

បណ្ដាបទទាំងនោះ បទ ថា " **បដិនន្ទិតា** " មានសេចក្ដីថា គឺជនទាំងឡាយ ទៅកាន់ទីចំពោះមុខហើយ ស្រឡាញ់ស្និទ្ធស្នាល ដោយហឫទ័យ ដ៏រីករាយ ។ ២ បទ ថា " **យំ អនាទាយ** " មានសេចក្ដីថា បុគ្គលកាលពោលពាក្យណា មិនប្រកាន់យកពាក្យអាក្រក់ មិនជាទីស្រឡាញ់ គួរខ្ពើមរអើម បានដល់ ពាក្យអាក្រក់លាមក របស់ពួកជនដទៃហើយ ពោលពាក្យដែលជាទីស្រឡាញ់ដែលពិរោះ ដោយអត្ថនិងព្យញ្ជនៈ មែនពិត, បុគ្គលគប្បីពោលវាចាដែលជាទីស្រឡាញ់នោះ តែម្យ៉ាង " ដូច្នេះ ។

(១៣២) មួយទៀត បុគ្គលអ្នកចូលចិត្តពោលពាក្យកុហក រមែងសាបសូន្យ ចាកលាភដែលខ្លួនបានហើយខ្លះ ចាកលាភដែលខ្លួនគប្បីបានខ្លះ និងតែងជួបប្រទះនូវសេចក្ដីទុក្ខ ។ ក៏ក្នុងរឿងនេះ មានព្រាហ្មណ៍អ្នកចេះមន្តសែកផ្លែស្វាយជាដើម ជាឧទាហរណ៍ ។

( រឿងព្រាហ្មណ៍អ្នកចេះមន្តសែកផ្លែស្វាយ )

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតជាមនុស្សចណ្ឌាល ក្នុងផ្ទះមនុស្សចណ្ឌាល ក្នុងនគរដែលតាំងនៅជាយដែន ជាបណ្ឌិតឆ្លាតវាងវៃ ចេះមន្តសម្រាប់ធ្វើស្វាយឲ្យមានផ្លែ ក្នុងសម័យមិនមែនជារដូវកាល ៗ ព្រះពោធិសត្វនោះ ទៅព្រែតាំងពីព្រលឹមស្រាងឈរនៅទីបំផុតអំពីដើមស្វាយប្រមាណ ៧ ជំហានហើយ រាយនូវមន្ត ក្បង់ទឹកមួយកំបង់ ស្រោចគល់ (ស្វាយ) ៗ នៅក្នុងខណៈនោះឯង ស្លឹកចាស់ ៗ ក៏ជ្រុះធ្លាក់មក និងសន្លឹកថ្មី ៗ ក៏លាស់ឡើង, បុប្ផាទាំងឡាយ បានរីកហើយ ក៏ជ្រុះធ្លាក់មក, ផ្លែទាំងឡាយកើតឡើងហើយ ទុំមួយរំពេចនុ៎ះឯង មានរសជាតផ្អែម មានឱជារសដូចជាផ្លែឈើទិព្វ ធ្លាក់ចុះមក ៗ ព្រះពោធិសត្វនោះ បរិភោគតាមសេចក្ដីត្រូវការហើយ រើសដោយអង្រែកមកផ្ទះ លក់ចិញ្ចឹមបុត្រនិងភរិយា ៗ គ្រានោះ ព្រាហ្មណ៍ម្នាក់រៀនមន្តនោះ ក្នុងសំណាក់នៃព្រះពោធិសត្វនោះ ត្រូវព្រះពោធិសត្វប្រាប់ ថា " នែអ្នក មន្តនេះរកតម្លៃដាក់គ្មានឡើយ, អ្នកអាស្រ័យមន្តនេះហើយ នឹងបានទ្រព្យដ៏ច្រើន, អ្នកត្រូវបុគ្គលណាមួយសួរហើយ ចូរកុំបិតបាំងខ្ញុំឡើយ ចូរប្រាប់ ថា 'ខ្ញុំរៀនមន្តមក អំពីសំណាក់ នៃជនចណ្ឌាល' ដូច្នេះ, បើអ្នកខ្មាសអៀន នឹងប្រាប់ ដោយប្រការដទៃវិញ, អ្នកនឹងមិនបាន

ផលនៃមន្ត " ដូច្នេះហើយ ទទួល ថា " សាធុ " ហើយថ្វាយបង្គំព្រះពោធិសត្វនោះ ទៅដល់ក្រុងពារាណសី ដោយលំដាប់ ឧបដ្ឋាកព្រះរាជា ដោយផ្លែស្វាយប្រាកដដូច្នោះ បានហើយនូវទ្រព្យដ៏ច្រើន ៗ ក្រោយមក ថ្ងៃមួយ ព្រះរាជាត្រាស់សួរ ថា " នែមាណព អ្នកឯងរៀនមន្ត ក្នុងសំណាក់នៃអ្នកឯណា ? " ៗ ព្រាហ្មណ៍នោះអៀនខ្មាស ដើម្បីនឹងទូល ថា " ក្នុងសំណាក់ នៃជនចណ្ឌាល " ទើបបានក្រាបទូលកុហក ថា " ក្នុងសំណាក់ នៃអាចារ្យទិសាបាមោក្ខ ក្នុងទីក្រុងតក្កសីលា " ៗ ក្នុងខណៈនោះឯង មន្តក៏អន្តរធានបាត់ទៅ ៗ ព្រាហ្មណ៍នោះមិនដឹងសោះឡើយ ថ្ងៃមួយ ត្រូវព្រះរាជាស្ដេចយាងទៅឧទ្យាន ត្រាស់សួរ ថា "នែមាណព អ្នកចូរនាំយកផ្លែស្វាយមក" ដូច្នេះហើយ ទើបរាយមន្ត, កាលបើមន្តមិនប្រាកដ, ក៏ដឹងថាមន្តវិនាសអស់ហើយ កើតខ្មាសអៀន ត្រូវព្រះរាជាត្រាស់សួរញយ ៗ មិនអាចនឹងកន្លងបាន ក៏ក្រាបទូល តាមសេចក្ដីពិត ៗ ព្រះរាជាទ្រង់ព្រះពិរោធហើយ ត្រាស់ ថា "អ្នកទាំងឡាយ ចូរចាប់បុរសនេះត្រង់ក ហើយ អូសចេញទៅក្រៅ " ៗ ពួករាជបុរស បានធ្វើហើយដូច្នោះ ហើយពោល ថា " អ្នកចូរទៅរកអាចារ្យ របស់អ្នកហើយ ធ្វើឲ្យគាត់ប្រោសប្រណី, ប្រសិនបើ អ្នកបានមន្តថ្មីហើយ, ចាំអញ្ជើញមក ក្នុងទីនេះ, បើអ្នកមិនបានមន្តទេ, សូមកុំមក ក្នុង

ទីនេះឡើយ " ។ ព្រាហ្មណ៍នោះ ជាអ្នកគ្មានទីពឹង ចូលទៅរកព្រះពោធិសត្វហើយ សុំមន្តនោះម្តងទៀត ត្រូវព្រះពោធិសត្វនោះប្រាប់ ថា " ខ្ញុំមិនឲ្យមន្ត ដល់បុគ្គលអ្នកនិយាយកុហក ដូចជាអ្នកឡើយ, មន្តនឹងមានមកពីណា ?, អ្នកចូរទៅចុះ, ខ្ញុំមិនចូលចិត្តអ្នកទេ " ដូច្នេះហើយគិត ថា " ប្រយោជន៍អ្វី ដល់អញ ដោយការរស់នៅ " ដូច្នេះហើយ ក៏ចូលទៅព្រៃ ដល់នូវសេចក្តីស្លាប់ ដោយគ្មានទីពឹង ។

រឿង ព្រាហ្មណ៍អ្នកចេះមន្តសែកផ្លែស្វាយ មកក្នុងអដ្ឋកថាអម្ពជាតក ក្នុងតេរសនិបាត ។

## ( រឿង សេដ្ឋីបុត្រ ៣ នាក់ )

(១៣៣) ក្នុងអតីតកាល បានមានសេដ្ឋីបុត្រ ៣ នាក់ ក្នុងក្រុងពារាណសី ។ ក៏ផ្កាឈូកទាំងឡាយ ក្នុងស្រះមួយ ពន្លឺខាងក្នុងនគរ រីក (ស្គុះស្គាយ) ។ ហើយបុរសកញ្ឆតច្រមុះម្នាក់ ថែរក្សាស្រះនោះ ។ ក្រោយមក ថ្ងៃមួយ សេដ្ឋីបុត្រទាំងនោះ ប្រាថ្នាចង់ប្រដាប់ផ្កាកម្រង លេងមហោស្រព ទើបប្រឹក្សាគ្នា ថា " ពួកយើងនឹងពោលសរសើរបុរសកញ្ឆតច្រមុះ ដោយពាក្យមិនពិត ហើយសុំផ្កា(ឈូក) " ដូច្នេះហើយ ក៏ចូលទៅរកបុរសនោះ បានឈរហើយ ។ បណ្តាសេដ្ឋីបុត្រទាំងនោះ សេដ្ឋីបុត្រម្នាក់កាលសុំ ពោលគាថានេះ ថា

" សក់ក្តី ពុកមាត់ក្តី ដែលគេកោរកាត់ហើយ រមែង ដុះឡើងវិញ យ៉ាងណា, សូមឲ្យច្រមុះ របស់អ្នក ដុះឡើងវិញ យ៉ាងនោះដែរ, អ្នកត្រូវពួកយើងសុំហើយ ចូរឲ្យនូវផ្កាឈូក ( ដល់ពួកយើង ) " ។

សេដ្ឋីបុត្រ ទី ២ កាលនឹងសុំ ពោលគាថានេះ ថា ÷

" ពូជក្នុងរដូវរំហើយ ដែលគេព្រោះក្នុងស្រែ រមែង លូតលាស់ យ៉ាងណាមិញ, សូមឲ្យច្រមុះ របស់អ្នក ដុះឡើងវិញ យ៉ាងនោះដែរ, អ្នកត្រូវពួកយើងសុំហើយ ចូរឲ្យនូវផ្កាឈូក ( ដល់ពួកយើង ) " ។

បណ្តាបទទាំងនោះ បទ ថា " សារទិកំ " បានដល់ ពូជដែលបរិបូណ៌ដោយសារៈ ដែលគេប្រមូលមកទុក ក្នុងសារទសម័យ ។ បុរសនោះ ក្រោធហើយ មិនបានឲ្យផ្កាឈូកដល់សេដ្ឋីបុត្រទាំងនោះ ។

គ្រានោះ សេដ្ឋីបុត្រ ទី ៣ កាលសុំពោលគាថានេះ ថា ÷

" ជនទាំង ២ នាក់នេះ និយាយកុហក ដោយគិតថា ធ្វើដូចម្តេចហ្ន៎ បុរសនេះនឹងឲ្យផ្កាឈូកទាំងឡាយខ្លះ, ទោះជនទាំង ២ នាក់នោះ ពោលក្តី មិនពោលក្តី

ការដុះឡើងនៃច្រមុះគ្មានទេ, ម្នាលសំឡាញ់ សូម
អ្នកឲ្យផ្កាឈូកទាំងឡាយ, អ្នកត្រូវយើងសុំហើយ
ចូរឲ្យនូវផ្កាឈូកទាំងឡាយ ដល់យើងនោះ " ។

បណ្ដាបទទាំងនោះ បទ ថា " **ឧភោបិ បលបន្តេតេ** " មាន សេចក្ដីថា ឯជនទាំង ២ នាក់នុ៎ះ ពោលកុហក ។ ពាក្យថា " **អបិ បទ្មានិ** " មានសេចក្ដីថា ដោយគិតថា ' បុរសនេះនឹងឲ្យ នូវផ្កាឈូកទាំងឡាយ ដល់ពួកយើង ខ្លះមិនខាន ' ទើបពោលយ៉ាង នេះ ។ បាទគាថា ថា " **វឌ្ឍ វា តេ ន វា វឌ្ឍ** " មានសេចក្ដីថា ជនទាំងនោះ នឹងគប្បីពោលក្ដី មិនគប្បីពោលក្ដី យ៉ាងនេះ ថា ' សូម ឲ្យច្រមុះរបស់អ្នក ដុះឡើងវិញ ' ដូច្នេះ, ឈ្មោះថា ពាក្យពោល របស់ជនទាំងនោះ មិនជាប្រមាណ, ការដុះឡើង នៃច្រមុះ នឹងមិន មាន សូម្បីដោយប្រការទាំងពួង, ប៉ុន្តែ ខ្ញុំមិនអាស្រ័យនូវច្រមុះ របស់អ្នក ពោលពាក្យអ្វីឡើយ, ខ្ញុំសុំតែម្យ៉ាង, ម្នាលសំឡាញ់ អ្នកត្រូវខ្ញុំសុំហើយ ចូរឲ្យផ្កាឈូកទាំងឡាយ ដល់ខ្ញុំនោះចុះ ។

បុរសនោះ ស្ដាប់ពាក្យនោះហើយពោល ថា " បុគ្គលទាំង ២ នាក់នុ៎ះ ពោលកុហក, លោកពោលតែពាក្យពិត, ខ្ញុំឲ្យផ្កាឈូក ទាំងឡាយ ដ៏សមគួរ ដល់លោក " ដូច្នេះហើយ ក៏បានឲ្យនូវបាច់

នៃផ្កាឈូកយ៉ាងធំ ដូច្នេះឯង ។

រឿងសេដ្ឋីបុត្រ មកក្នុងអដ្ឋកថាបទុមជាតក ក្នុងទុតិយវគ្គ នៃតិកនិបាត ។

(១៣៤) ក្នុងពាក្យថា " និងជួបប្រទះនូវសេចក្តីទុក្ខ " នេះ គប្បីពោលនូវកក្ការុជាតក ក្នុងចតុក្កនិបាត និងចេតិយជាតក ក្នុងអដ្ឋកនិបាត ។ ព្រោះហេតុនោះ បុគ្គលគប្បីភ័យខ្លាច អំពីការពោលពាក្យកុហក ដូចជាកិន្នរ ១ គូ ក្នុងអតីតកាល យ៉ាងដូច្នោះ ។

បានឮថា ព្រានព្រៃ អ្នកនៅក្នុងក្រុងពារាណសីម្នាក់ ទៅព្រៃហេមពាន្ត នាំកិន្នរ ២ ញីឈ្មោលមកថ្វាយ ចំពោះព្រះរាជាក្រុងពារាណសី ត្រូវព្រះរាជាអង្គនោះត្រាស់សួរ ថា " កិន្នរទាំងនេះតើមានគុណដូចម្តេចខ្លះ ? " ដូច្នេះហើយ ក៏ក្រាបទូល ថា " បពិត្រព្រះសម្មតិទេព កិន្នរទាំង ២ នេះ តែងច្រៀង ដោយសំឡេងដ៏ពីរោះ និងរាំ គួរជាទីគាប់ចិត្ត, សូម្បីមនុស្សទាំងឡាយ ក៏មិនចេះច្រៀង និងរាំបាន យ៉ាងនេះដែរ " ។ ព្រះរាជាទ្រង់សព្វព្រះហឫទ័យ ទ្រង់ព្រះរាជទានទ្រព្យជាច្រើន ដល់ព្រានព្រៃហើយ ទ្រង់ត្រាស់ នឹងកិន្នរថា " អ្នកទាំងឡាយ ចូរច្រៀង ចូររាំចុះ " ។ កិន្នរទាំងនោះគិត ថា " ប្រសិនបើ ពួកយើងច្រៀង ក៏មិនអាចនឹងធ្វើនូវព្យញ្ជនៈ ឲ្យពេញបរិបូណ៌បានឡើយ, ការច្រៀងមិនពិរោះក៏មាន, ព្រះរាជានឹងទ្រង់

គិះដៀល ទ្រង់សម្លាប់ពួកយើងចោល, ក៏កាលបើពួកយើងពោល ច្រើនពេក, ក៏នឹងទៅជាមុសាវាទ" ដូច្នេះហើយ សូម្បីត្រូវព្រះរាជា ត្រាស់សួរញយៗ ក៏មិនច្រៀង មិនរាំ ព្រោះភ័យអំពីមុសាវាទ ។ ព្រះរាជាទ្រង់ព្រះពិរោធ ហើយត្រាស់ ថា "អ្នកទាំងឡាយ ចូរសម្លាប់ កិន្នរទាំងនេះហើយ អាំងសាច់នាំយកមក" ។ កិន្នរី បានឮព្រះ តម្រាស់នោះហើយ ក៏គិត ថា "ព្រះរាជាទ្រង់ព្រះពិរោធ នឹងទ្រង់ សម្លាប់ពួកយើងចោល ដោយពុំមានសង្ស័យឡើយ, គួរតែពួកយើង និយាយ ក្នុងពេលនេះ" ដូច្នេះហើយ ទើបពោលគាថានេះ ថា ÷

(១៣៥) "ពាក្យជាទុព្ភាសិត ១ សែនម៉ាត់ ក៏មិន
ដល់មួយចំណិត នៃពាក្យជាសុភាសិតឡើយ, បុគ្គល
កាលវង្វៀស នឹងពាក្យជាទុព្ភាសិត រមែងលំបាក,
ហេតុនោះ កិន្នរនៅស្ងៀម មិនមែនព្រោះល្ងង់ទេ" ។

បណ្ដាបទទាំងនោះ បទ ថា "**សង្កមានោ**" មានសេចក្ដីថា វង្វៀសពាក្យជាទុព្ភាសិត យ៉ាងនេះ ថា "អាត្មាអញ កាលនឹងពោល គប្បីពោលពាក្យជាទុព្ភាសិត ក្នុងកាលដងណា" ដូច្នេះ ។ បទ ថា "**កិលេសេ**" បានដល់ រមែងមួរហ្មង គឺលំបាក ។ បទ ថា "**តស្មា**" មានសេចក្ដីថា ព្រោះហេតុនោះ ទើបមិនច្រៀងថ្វាយ ដល់ព្រះអង្គ ។

បទ ថា " ន ពាល្យា " ប្រែថា ព្រោះភាវៈជាអ្នកល្ងង់ខ្លៅក៏ទេ ។

ព្រះរាជាទ្រង់សព្វព្រះទ័យ ចំពោះកិន្នរីហើយ ទ្រង់ត្រាស់ ថា " អ្នកទាំងឡាយ ចូរលែងកិន្នរីទៅចុះ, ចូរនាំកិន្នរីទៅភ្នំហេមពាន្ត, ចូរចំអិនកិន្នរ ក្នុងវេលាបាយព្រឹក អំពីព្រឹកព្រលឹម "។ កិន្នរបានស្តាប់ នូវព្រះតម្រាស់នោះហើយ ក៏គិត ថា " ព្រះរាជាអង្គនេះនឹងទ្រង់សម្លាប់អាត្មាអញអ្នកមិននិយាយ ដោយពិត, គួរអាត្មាអញក្រាបទូល នៅពេលនេះ" ដូច្នេះហើយ ទើបពោលគាថាក្រៅនេះ ថា

> " ពួកសត្វចិញ្ចឹម មានមេឃជាទីពឹង, ពួកមនុស្សនេះ
> មានសត្វចិញ្ចឹមជាទីពឹង, បពិត្រមហារាជ ទូលព្រះបង្គំ
> មានព្រះអង្គជាទីពឹង, ឯភរិយារបស់ទូលព្រះបង្គំមាន
> ខ្លួនទូលព្រះបង្គំជាទីពឹង, ក្នុងរវាងទូលព្រះបង្គំទាំង ២
> នាក់ សូមឲ្យអ្នកដែលរួច (អំពីមរណៈ) ដឹងថា អ្នក
> ណាមួយ ( ស្លាប់ ) ហើយ សឹមទៅភ្នំ " ។

សេចក្តីអធិប្បាយនៃគាថានោះ ថា បពិត្រព្រះមហារាជ ធម្មតាពួកសត្វចិញ្ចឹម មានស្មៅជាចំណី មានមេឃជាទីពឹង, ចំណែកខាងពួកមនុស្ស ឈ្មោះថា មានសត្វចិញ្ចឹមជាទីពឹង ព្រោះអាស្រ័យនូវបញ្ចគោរសចិញ្ចឹមជីវិត, ចំណែក ទូលព្រះបង្គំមានព្រះអង្គជាទីពឹង,

ព្រះអង្គជាទីពឹង របស់ទូលព្រះបង្គំ, ឯភរិយានៃទូលព្រះបង្គំ ក៏មានទូលព្រះបង្គំជាទីពឹង, ទូលព្រះបង្គំជាទីពឹងរបស់ភរិយានោះ, ក៏ទូលព្រះបង្គំទាំងឡាយ កាលរស់នៅ ក៏មិនលះបង់ នូវគ្នានឹងគ្នាឡើយ, ព្រោះហេតុនោះ បើព្រះអង្គទ្រង់ប្រាថ្នា ដើម្បីនឹងបញ្ជូននូវភរិយារបស់ទូលព្រះបង្គំទៅព្រៃហេមពាន្ត, សូមព្រះអង្គសម្លាប់ទូលព្រះបង្គំ ជាមុនហើយ ចាំទ្រង់បញ្ជូនភរិយាទៅ ជាខាងក្រោយ " ។

ព្រះរាជាទ្រង់សព្វព្រះទ័យ ចំពោះកិន្នរផងដែរ ហើយទ្រង់ញ៉ាំងកិន្នរទាំង ២ នោះ ឲ្យចាប់ទំ ក្នុងទ្រុងមាស ទ្រង់ត្រាស់បញ្ជាឲ្យហៅព្រានព្រៃនោះឯងមកហើយ ត្រាស់ ថា "អ្នកចូរទៅ, ចូរដោះលែងក្នុងទីដែលអ្នកចាប់មក " ។ ព្រានព្រៃនោះ បានធ្វើហើយ តាមព្រះរាជតម្រាស់នោះ ។ កិន្នរញីឈ្មោលទាំង ២ នោះ មិនពោលពាក្យទុព្ភាសិត ព្រោះភ័យខ្លាច អំពីមុសាវាទ អាស្រ័យពាក្យជាសុភាសិតរបស់ខ្លួនពិតហើយ រួចផុតអំពីសេចក្ដីទុក្ខ គឺមរណៈ ដូច្នេះឯង ។

" ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញាល្អ ប្រាថ្នាឲ្យ
រួចផុតអំពីសេចក្ដីស្លាប់ គប្បីលះបង់ពាក្យឡេះឡោះ
ចោលចេញហើយ ពោលតែពាក្យទៀងត្រង់ " ។

រឿងកិន្នរ មកក្នុងអដ្ឋកថាតក្ការិយជាតក ក្នុងតេរសនិបាត ។

(១៣៦) សូម្បីព្រះវង្គីសត្ថេរ កាលញុំាងកុលបុត្រ ឲ្យយល់នូវសេចក្ដីនេះឯង ទើបបានពោលគាថានេះ ដែលរាប់បញ្ចូល ក្នុងសុភាសិតសូត្រ នៅទីចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគ ថា ÷

**“ ពាក្យសច្ចៈហ្នឹងឯង ជាពាក្យមិនចេះស្លាប់, នេះជាធម៌ចាស់ពីបូរាណ, សប្បុរសទាំងឡាយ បានតាំងនៅស៊ប់ហើយ ក្នុងពាក្យសច្ចៈ ដែលជាប្រយោជន៍ផងដែលជាធម៌ផង ” ។**

បណ្ដាបទទាំងនោះ បទ ថា “ **អមតា** ” មានសេចក្ដីថា ពាក្យស័ត្យ ឈ្មោះថា ជាវាចាមិនចេះស្លាប់ ព្រោះជាវាចាដែលញុំាងប្រយោជន៍ឲ្យសម្រេចបាន ។ សមដូចជាព្រះពុទ្ធដីកា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងអាឡវកសូត្រ ថា “ **ពាក្យស័ត្យហ្នឹងឯង ញុំាងប្រយោជន៍ឲ្យសម្រេច ជាងរសទាំងឡាយ...** ” ។ បាទគាថា ថា “ **ឯស ធម្មោ សនន្តនោ** ” មានសេចក្ដីថា ធម៌ដែលឈ្មោះថា វាចាស័ត្យនេះ ជាធម៌ គឺ ចរិយា បានដល់ ប្រពៃណីអំពីបូរាណ ។ មែនពិត ពាក្យស័ត្យនេះឯង បូរាណទាំងឡាយលោកបានប្រព្រឹត្តមកហើយ, ដោយហេតុថា ជនបូរាណទាំងនោះមិនដែលពោលពាក្យឡេះឡោះឡើយ, ព្រោះហេតុនោះឯង ទើប

ព្រះវង្គីសត្ថេរ ពោល ថា “សប្បុរសទាំងឡាយ បានតាំងនៅស៊ប់ហើយ ក្នុងពាក្យស័ត្យ ដែលជាប្រយោជន៍ផង ដែលជាធម៌ផង ”។ សប្បុរសទាំងនោះ គប្បីដឹង ថា “បណ្ដាប្រយោជន៍ និងធម៌ទាំងនោះ ជាអ្នកឈ្មោះថា តាំងនៅស៊ប់ហើយ ក្នុងប្រយោជន៍ របស់ខ្លួននិងពួកជនដទៃ ក៏ព្រោះតាំងនៅស៊ប់ហើយ ក្នុងពាក្យស័ត្យនុ៎ះឯង និងឈ្មោះថា ជាអ្នកតាំងនៅស៊ប់ហើយ ក្នុងធម៌ ក៏ព្រោះជាអ្នកតាំងនៅស៊ប់ហើយ ក្នុងប្រយោជន៍នុ៎ះឯង ”។

មួយទៀត ទាំង ២ បទ ជាបទវិសេសនៈ នៃសច្ចៈ ។ ពួកសប្បុរស តាំងនៅស៊ប់ហើយ ក្នុងពាក្យស័ត្យ ។ ក្នុងពាក្យស័ត្យដូចម្ដេច ? ។ ក្នុងពាក្យស័ត្យ ដែលជាប្រយោជន៍ផង ដែលជាធម៌ផង ។ ពាក្យស័ត្យ ឈ្មោះថា ជាប្រយោជន៍ ព្រោះមិនទៅប្រាសចាកប្រយោជន៍ របស់បុគ្គលដទៃ ។ មានពាក្យអធិប្បាយ ថា “ រមែងធ្វើនូវសេចក្ដីមិនខុសឆ្គង ”។ ឈ្មោះថា ជាធម៌ ក៏ព្រោះសូម្បីកាលបើពាក្យស័ត្យធ្វើសេចក្ដីមិនខុស ក៏មិនទៅប្រាសចាកធម៌ ។ មានពាក្យអធិប្បាយ ថា “ ពាក្យស័ត្យ រមែងញុំាំងកិច្ចដែលប្រកបដោយធម៌ប៉ុណ្ណោះ ឲ្យសម្រេចបាន ”។

(១៣៧) ក៏ឈ្មោះថា បុគ្គលអ្នកពោលពាក្យស័ត្យ ជាអ្នកនាំប្រយោជន៍មកឲ្យ ដល់ខ្លួនផង ដល់ពួកជនដទៃផង ដូចជាសាមណោរ

អធិមុត្តកៈ និងមហាសុតសោមបណ្ឌិតជាដើម ។ បណ្ដាបុគ្គលទាំង ២ នាក់នោះ រឿងអធិមុត្តកសាមណេរ ខ្ញុំពោលហើយ ក្នុងអធិការនៃការសេពគប់បណ្ឌិត ។ រឿងមហាសុតសោមបណ្ឌិត គប្បីត្រួតមើល ក្នុងអសីតិនិបាត ។

## ( រឿងស្ត្រីអ្នករក្សាពាក្យសច្ចៈ )

បានឮថា ក្នុងកាលមុន ស្ត្រីម្នាក់ មិនបានថ្វាយទាន, មិនបានធ្វើការបូជា មិនបានស្ដាប់ធម៌សោះ ។ នាងរក្សាត្រឹមតែពាក្យសច្ចៈម្យ៉ាង ធ្វើមរណកាលហើយ ក៏បានទៅកើតក្នុងទេវលោក ។ ក្នុងគ្រានោះ ព្រះមហាមោគ្គល្លានៈដ៏មានអាយុ ចារិកទៅកាន់ទេវលោក ឈរនៅត្រង់ទ្វារនៃវិមាន របស់នាងទេវធីតានោះហើយ សួរនាងទេវធីតានោះដែលកំពុងមក កាន់សំណាក់ របស់ខ្លួន ថា “ សម្បត្តិនាងមានច្រើន, តើនាងធ្វើកុសលអ្វី ទើបបានសម្បត្តិនេះ ? ” ។ នាងទេវធីតានោះ ខ្មាសអៀន ព្រោះសម្បត្តិនោះ នាងបានមកដោយកម្មដ៏តិចតួច សូម្បីមិនប្រាថ្នានឹងប្រាប់ ក៏ត្រូវព្រះថេរៈ សួរញយ ៗ កាលមិនអាចនឹងបិតបាំងបាន ទើបពោល ថា “នាងខ្ញុំ រក្សាត្រឹមតែពាក្យស័ត្យ ” ។ ព្រះថេរៈឮពាក្យនោះហើយ មកក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ក្នុងវត្តជេតពន ក្រាបទូលសួរ ថា “ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលអាចបាននូវសម្បត្តិទិព្វ ដោយហេតុត្រឹមតែពោល

ពាក្យស័ក្យបានដែរឬទេ ? ”។ ព្រះសាស្តា ទ្រង់ត្រាស់ថា “ ម្នាលមោគ្គល្លាន អ្នកសួរ តថាគតធ្វើអ្វី ?, ក្រែងនាងទេវធីតា បានប្រាប់សេចក្តីនេះ ដល់អ្នករួចហើយ មិនមែនទេឬ ? ”ដូច្នេះហើយ ទើបទ្រង់ត្រាស់ ថា “សត្វទាំងឡាយ សូម្បីពោលត្រឹមតែពាក្យស័ក្យ ក៏រមែងទៅកាន់ទេវលោកបានដូចគ្នាដែរ ” ។ រឿងនេះ មកក្នុងគាថាវណ្ណនា ថា “ **បុគ្គលគប្បីពោលពាក្យសច្ចៈ, បុគ្គលមិនគប្បីក្រោធខឹង...**” ដូច្នេះជាដើម ក្នុងកោធវគ្គនៃធម្មបទ ។

## ( វាចាសុភាសិតជាមង្គល )

(១៣៨) ដូច្នោះ វាចាដែលប្រកបដោយអង្គ គឺអវយវៈ ៤ យ៉ាង មានការពោលពាក្យជាសុភាសិតជាដើម ទើបបានឈ្មោះថាជាវាចាសុភាសិត ។ វាចាជាសុភាសិតនោះ ឈ្មោះថាជាមង្គល ព្រោះនាំលោកិយសុខ និងលោកុត្តរសុខមកប្រគល់ឲ្យ ។

ហេតុនោះ ទើបលោកពោល ក្នុងអដ្ឋកថាសុភាសិតសូត្រ ថា “ព្រះដ៏មានព្រះភាគកាលទ្រង់ត្រាស់ ថា ‘ ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៤ យ៉ាងនេះឯង ជាវាចាសុភាសិត ” ដូច្នេះ ឈ្មោះថាទ្រង់បដិសេធវាចា ដែលប្រកបដោយអវយវៈមានការប្តេជ្ញាជាដើម និងដោយសម្បត្តិ គឺនាម លិង្គ វចនៈ វិភត្តិ កាល

និងការក ដែលបុគ្គលដទៃបញ្ញត្ត ដល់បុគ្គលដទៃ ថា "ជាសុភាសិត" ដោយធម៌ ៗ មែនពិត វាចាដែលប្រកបដោយទុច្ចរិតមានពោលពាក្យស៊កសៀតជាដើម សូម្បីដល់ព្រមដោយអវយវៈជាដើម ក៏ឈ្មោះថាជាវាចាទុព្ភាសិត ព្រោះនាំសេចក្តីវិនាសមក ដល់ខ្លួនឯងផង ដល់អ្នកដទៃផង ៗ

ចំណែក វាចាដែលប្រកបព្រមដោយអង្គ ៤ យ៉ាងនេះ សូម្បីជាវាចា រាប់ចូលក្នុងភាសា របស់ជនមិលក្ខៈ ឬរាប់ចូលក្នុងភ្លេងចម្រៀង របស់ក្មេងស្រីជាអ្នកដឹកពាងទឹក ក៏ពិតមែនហើយ, ទោះជាដូច្នោះ ក៏ឈ្មោះថាជាវាចាសុភាសិតនុ៎ះឯង ព្រោះនាំមកនូវលោកិយសុខ និងលោកុត្តរសុខ ៗ

ក៏ក្នុងសេចក្តីនេះ មានពួកភិក្ខុអ្នករៀនវិបស្សនា ចំនួន ៦០ រូប កំពុងនិមន្តទៅតាមផ្លូវ បានឮក្មេងស្រីជនជាតិសីហឡ នាងចាំរក្សាស្រូវសន្ទូង ក្បែរផ្លូវ ក្នុងកោះសីហឡ កំពុងតែច្រៀងនូវចម្រៀងដែលប្រកបដោយជាតិ ជរា ព្យាធិ និងមរណៈ ដោយភាសាអ្នកជនជាតិសីហឡនុ៎ះឯងហើយ បានសម្រេចព្រះអរហត្ត ជាឧទាហរណ៍ ៗ

ឧទាហរណ៍មួយទៀត ភិក្ខុឈ្មោះថាតិស្សៈ ជាអ្នកប្រារព្ធវិបស្សនា កំពុងតែនិមន្តទៅ តាមផ្លូវក្បែរស្រះបទុម បានស្តាប់ក្មេងស្រីកំពុងតែកាច់ផ្កាបទុម ក្នុងស្រះបទុម ច្រៀងចម្រៀងនេះ ថា ÷

(១៣៩) "ផ្កាបទុម ឈ្មោះកោកនទ រីកហើយក្នុងពេលព្រឹក ត្រូវរស្មីនៃព្រះអាទិត្យកម្ដៅ (ឡើស្វិតស្រពោន) យ៉ាងណា, សត្វទាំងឡាយអ្នកដល់នូវភាពជាមនុស្ស ក៏រមែងស្វិតស្រពោនទៅព្រោះកម្លាំងនៃជរា ក៏យ៉ាងនោះឯង"

ដូច្នេះហើយ ក៏បានសម្រេចព្រះអរហត្ត ៗ

មួយទៀត បុរសម្នាក់ ក្នុងពុទ្ធន្តរ បានត្រឡប់មកអំពីព្រៃព្រមជាមួយនឹងកូន ៧ នាក់ បានស្ដាប់ចម្រៀង របស់ស្ត្រីម្នាក់ដែលកំពុងតែយកអង្រែមកបុកអង្ករ យ៉ាងនេះ ថា ÷

"សរីរៈនេះ អាស្រ័យស្បែក មានសម្បុរក្រៀមស្វិតត្រូវជរាគ្របសង្កត់ហើយ, សរីរៈនេះ ដល់នូវភាពជាអាមិស គឺជាចំណី របស់មច្ចុរាជ រមែងបែកធ្លាយទៅ ព្រោះមរណៈ, សរីរៈនេះ ជាទីអាស្រ័យនៅនៃពួកដង្កូវ ពោរពេញដោយសាកសពផ្សេង ៗ, សរីរៈនេះ ជាភាជនៈ សំរាប់ផ្ទុកនូវរបស់មិនស្អាត, សរីរៈនេះ ប្រាកដស្មើដោយអង្កត់ឧស"

ដូច្នេះហើយ ពិចារណា ក៏បានសម្រេចបច្ចេកពោធិញ្ញាណ មួយអន្លើ

ដោយកូនទាំងឡាយ ៗ សូម្បីកុលបុត្រទាំងឡាយឯទៀត សម្រេចអរិយភូមិ ដោយឧបាយដូច្នេះ ជាឧទាហរណ៍ ៗ ភិក្ខុ ៥០០ រូប ស្តាប់នូវគាថា ដែលព្រះដ៏មានព្រះភាគ ព្រះអង្គជាអ្នកឆ្លាតវាងវៃក្នុងអាសយានុសយញ្ញាណ ទ្រង់ត្រាស់សំដែង ដោយន័យ ជាអាទិ៍ ថា " សង្ខារទាំងឡាយទាំងពួង ជារបស់មិនទៀង " ដូច្នេះហើយ បាន សម្រេចព្រះអរហត្ត និងទេវតានិងមនុស្សទាំងឡាយជាអនេក ស្តាប់ កថាពណ៌នា ដែលប្រកបដោយខន្ធអាយតនៈជាដើម ក្នុងព្រះសូត្រ ហើយ សម្រេចព្រះអរហត្ត ដោយហេតុណា, ហេតុនុ៎ះ មិនជាការអស្ចារ្យឡើយ " ៗ

បណ្តាបទទាំងនោះ បទ ថា " **អនច្ឆរិយំ បនេតំ យំ** " មាន សេចក្តីថា ការដែលស្តាប់ព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ សម្រេចព្រះអរហត្ត ដោយហេតុណា, ហេតុនុ៎ះ មិនជាការអស្ចារ្យឡើយ ៗ ឯការដែលស្តាប់ភ្លេងចម្រៀង ដែលក្មេងស្រីជាដើមច្រៀងហើយ សម្រេចព្រះអរហត្តណា, ការស្តាប់ ចម្រៀងហើយសំរេចព្រះអរហត្តនុ៎ះ ទើបជាការអស្ចារ្យក្រៃលែង ៗ អធិប្បាយថា រឿងនុ៎ះ រមែងញុំាងកុលបុត្រទាំងឡាយ ឲ្យដឹងនូវ ភាវៈសូម្បីនៃភ្លេងចម្រៀងដូច្នោះ ក៏ជាសុភាសិត ៗ

(១៤០) ក៏ព្រោះសំឡេងនុ៎ះឯង ឈ្មោះថាវាចា ដោយ

ន័យដែលពោលហើយ ព្ធដ៏ខាងក្រោយ ក្នុងមង្គល ថា "សុភាសិតា
ច យា វាចា " នេះ, មិនមែនជាចេតនានិងវិរ័តិឡើយ ដូច្នោះ
វាចានេះ ទើបមិនរាប់ចូលក្នុងមង្គល ថា "វិន័យ " នេះ ។ ព្រោះ
ក្នុងអាគារិយវិន័យ ចេតនាមានចេតនាជាហេតុវៀរចាក មុសាវាទ
ជាដើមក្តី វិរ័តិក្តី ទើបគួរ, សំឡេងមិនគួរ ។ សេចក្តីនេះ សូម្បី
ក្នុងអដ្ឋកថាអដ្ឋសាលិនី លោកក៏ពោលហើយ ។ ព្រោះហេតុនោះ
វាចាជាសុភាសិត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយភាវៈ
ជាមង្គលមួយផ្នែក ។ ប៉ុន្តែ ពាក្យណា ដែលលោកពោលហើយ
ក្នុងអដ្ឋកថា ថា " ក៏ព្រោះ វាចាជាសុភាសិតនេះ រាប់បញ្ចូលក្នុង
វិន័យនុ៎ះឯង ហេតុនោះ ព្រះដ៏មានព្រះភាគ ទើបមិនទ្រង់សង្គ្រោះ
វាចាសុភាសិតនុ៎ះ ដោយវិន័យស័ព្ទ គប្បីសង្គ្រោះតែវិន័យ "ដូច្នេះ,
បណ្តាពាក្យទាំង ២ យ៉ាងនោះ ក្នុងពាក្យថា "រាប់បញ្ចូលក្នុងវិន័យ"
គប្បីស្វែងរកហេតុ ។ ព្រះអដ្ឋកថាចារ្យ សំដែងភាវៈនៃវាចាជា
សុភាសិតនោះ ជាវាចាគឺព្រះដ៏មានព្រះភាគ គប្បីត្រាស់ ដោយ
ភាពជាមង្គលមួយផ្នែក ដោយពាក្យនេះ ថា "ឯតំ អសង្គណ្ហិត្វា "។
២ បទ ថា "វិនយោ សង្គហេតព្វោ" មានសេចក្តីថា គប្បី
សង្គ្រោះ វិន័យ ២ យ៉ាង ដូចបានពោលមកហើយនុ៎ះឯង ដោយ
វិន័យស័ព្ទ, មិនគួរសង្គ្រោះវាចាសុភាសិត ។ គប្បីឃើញសន្និដ្ឋាន

ថា " ព្រះអដ្ឋកថាចារ្យ សំដែងសូម្បីភាវៈ នៃវាចាសុភាសិតនោះ មិនរាប់ចូលក្នុងវិន័យ ដោយ ២ បទនេះ " ។ ចំណែក ក្នុងអដ្ឋកថា លោកពោលពាក្យមានប្រមាណប៉ុណ្ណេះនុ៎ះឯង ថា " សូម្បីវាចាជាសុភាសិតនេះ គប្បីដឹងថា ជាមង្គល ព្រោះនាំប្រយោជន៍សុខ ក្នុងលោកទាំង ២ មកឲ្យ " ។

ការពណ៌នា ក្នុងន័យទី ១ ចប់ ។

## ( ន័យទី ២ )

(១៤១) ម្យ៉ាងទៀត វាចាជាគ្រឿងសំដែងធម៌ ដល់ពួកជនដទៃ គប្បីដឹងថា ជាវាចាសុភាសិត ក្នុងមង្គលនេះ ។ មែនពិត វាចាសុភាសិតនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា " ជាមង្គល " ព្រោះជាបច្ច័យនៃប្រយោជន៍សុខ ក្នុងលោកទាំង ២ និងសម្រេចនូវព្រះនិព្វាន នៃសត្វទាំងឡាយ ដូចជាកិរិយារស់នៅ ក្នុងប្រទេសដ៏សមគួរ យ៉ាងដូច្នោះឯង ។ មែនពិត ព្រះពុទ្ធវចនៈ លោកក៏ពោលថា " ជាសុភាសិត " ព្រោះជាវាចាដែលប្រសើរបំផុត នៃវាចាទាំងពួង ដោយភាវៈជាវាចាដ៏ក្សេម ។

សូម្បីព្រះវង្គីសត្ថេរ កាលញុំាងកុលបុត្រឲ្យយល់នូវសេចក្ដីនេះឯង ទើបពោលគាថានេះ ដែលរាប់ចូលក្នុងសុភាសិតសូត្រ ចំពោះ

ព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ថា ÷

" ព្រះពុទ្ធទ្រង់ត្រាស់ ព្រះវាចាណាដ៏ក្សេម ដើម្បីលុះព្រះនិព្វាន ដើម្បីធ្វើទីបំផុតនៃទុក្ខ, ព្រះវាចានោះឯងជាព្រះវាចាដ៏ខ្ពង់ខ្ពស់នៃវាចាទាំងពួង "។

ន័យមកក្នុងអដ្ឋកថាសុភាសិតសូត្រនោះ ថា " បណ្ដាបទទាំងនោះ បទ ថា **ខេមំ** គឺ មិនមានភ័យ បានដល់ ប្រាសចាកឧបទ្រព ។ ដើម្បីឆ្លើយពាក្យចោទសួរ ថា " ព្រោះហេតុអ្វី " លោកពោល ថា ព្រះនិព្វានជាដើម ។ អធិប្បាយថា ឈ្មោះថា ក្សេម ព្រោះវាចានោះ ឲ្យសម្រេចកិលេសនិព្វាន និងប្រព្រឹត្តទៅដើម្បីធ្វើទីបំផុត នៃសេចក្ដីទុក្ខ ។ ម្យ៉ាងទៀត ព្រះពុទ្ធទ្រង់ត្រាស់ព្រះវាចាណា ឈ្មោះថាក្សេម ព្រោះទ្រង់ប្រកាសមគ្គដ៏ក្សេម ។ ព្រះអង្គទ្រង់ត្រាស់ដើម្បីប្រយោជន៍អ្វី ? ។ ព្រះអង្គទ្រង់ត្រាស់ ដើម្បីសម្រេចព្រះនិព្វាន គឺដើម្បីដល់កិលេសនិព្វាន និងដើម្បីធ្វើទីបំផុត នៃសេចក្ដីទុក្ខ គឺ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអមតនិព្វាន ដែលរាប់ថាទីបំផុតនៃទុក្ខក្នុងវដ្ដៈ ។ វាចានោះឯង ជាវាចាខ្ពង់ខ្ពស់ គឺប្រសើរបំផុត នៃវាចាទាំងពួង មួយយ៉ាងមែនពិត " ។

(១៩២) ន័យមកក្នុងអដ្ឋកថា ឯកនិបាតអង្គុត្តរនិកាយ ថា

" ព្រហ្ម ១៨ កោដិ ព្រមដោយព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ស្ដាប់នូវព្រះធម្មចក្កប្បវត្តនសូត្រហើយ ផឹកនូវទឹកអម្រឹត ៗ ក្នុងថ្ងៃទី ៥ ព្រះបញ្ចវគ្គិយត្ថេរ ស្ដាប់អនត្តលក្ខណសូត្រហើយ តាំងនៅក្នុងព្រះអរហត្ត ៗ បុរសទាំងឡាយ ៥៥ នាក់ មានយសកុលបុត្រជាដើម ស្ដាប់ព្រះធម្មទេសនា នៃព្រះសាស្ដាហើយ តាំងនៅក្នុងព្រះអរហត្ត ៗ ភទ្ទវគ្គីយ៍ ៣០ នាក់ ស្ដាប់ព្រះធម្មទេសនា នៃព្រះសាស្ដា ក្នុងមាត់ព្រៃកប្បាសហើយ ក៏តាំងនៅក្នុងផលទាំង ៣ ថ្នាក់ខាងក្រោម ៗ ជដិល ១.០០០ នាក់ ស្ដាប់អាទិត្តបរិយាយសូត្រ ក្នុងគយាសីសប្រទេសហើយ តាំងនៅក្នុងព្រះអរហត្ត ៗ ពួកព្រាហ្មណ៍និងគហបតី ១១ ម៉ឺន មានព្រះបាទពិម្ពិសារ ជាប្រធាន ស្ដាប់ព្រះធម្មទេសនា នៃព្រះសាស្ដា ក្នុងសួនព្រៃត្នោតហើយ តាំងក្នុងសោតាបត្តិផល, មួយម៉ឺននាក់ តាំងនៅ ក្នុងព្រះត្រៃសរណៈ ៗ សត្វ ៨៤.០០០ បានផឹកទឹកអម្រឹត ក្នុងវេលាចប់ នៃអនុមោទនាដោយតិរោកុឌ្ឌសូត្រ ៗ ក្នុងសមាគមនៃនាយសុមនមាលាការ ក៏ដូច្នោះដែរ ៗ ក្នុងសមាគមនៃដំរីឈ្មោះធនបាល សត្វ ១០.០០០ បានផឹកហើយ នូវទឹកអម្រឹត ៗ ក្នុងសមាគមនៃខទិរង្គជាតក ក្នុងសមាគមនៃជម្ពុកាជីវក និងក្នុងសមាគមនៃអានន្ទសេដ្ឋី សត្វ ៨៤.០០០ បានផឹកហើយ នូវទឹកអម្រឹត ៗ ក្នុងថ្ងៃដែលព្រះពុទ្ធ

ជាម្ចាស់ទ្រង់សំដែងនូវបារាយនសូត្រ សត្វ ១៤ កោដិ ។ ក្នុងថ្ងៃទ្រង់សំដែងយមកបាដិហារិយ៍ សត្វ ២០ កោដិ ។ កាលព្រះបរម-សាស្តាទ្រង់សំដែងព្រះអភិធម្ម ក្នុងភពតាវតឹង្ស សត្វ ៨០ កោដិ ។ ក្នុងថ្ងៃដែលព្រះអង្គទ្រង់យាងចុះ ពីទេវលោក សត្វ ៣០ កោដិ ។ ក្នុងសក្កបញ្ហាសូត្រ ទេវតា ៨០.០០០ ផឹកហើយ នូវទឹកអម្រឹត ។ ក្នុងស្ថានទីទាំង ៤ នេះ គឺ ÷ ក្នុងមហាសម័យសូត្រ ១ ក្នុងមង្គល-សូត្រ ១ ក្នុងចូឡរាហុលោវាទសូត្រ ១ ក្នុងសមចិត្តបដិបទាសូត្រ ១ សត្វដែលបានសម្រេចអភិសម័យ កំណត់ត្រារាប់ពុំបានឡើយ " ។

(១៤៣) អដ្ឋកថាធម្មចក្កប្បវត្តនសូត្រ ក្នុងមហាវគ្គសំយុត្តនិកាយ ថា " ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ តាំងនៅហើយ ក្នុងសោតាបត្តិផល ព្រមជាមួយនឹងព្រហ្ម ១៨ កោដិ " ។

អដ្ឋកថាមហាសម័យសូត្រ ថា " ទេវតាប្រមាណ មួយសែនកោដិ បានសម្រេច ព្រះអរហត្ត, ទេវតាដែលសម្រេចមគ្គ ទាំង ៣ ហួសនឹងគណនា " ។ អដ្ឋកថាមង្គលសូត្រ ក៏ដូច្នោះដែរ ។

អដ្ឋកថាចូឡរាហុលោវាទសូត្រ ក្នុងឧបរិបណ្ណាសកៈ ថា "ទេវតាពួកខ្លះ បានជាព្រះសោតាបន្ន, ពួកខ្លះ បានជាព្រះសកទាគាមី, ពួកខ្លះ បានជាព្រះអនាគាមី, ពួកខ្លះ បានជាព្រះខីណាស្រព ។ ក៏ការកំណត់រាប់ នូវទេវតាទាំងនោះ ថា " មានប្រមាណប៉ុណ្ណោះ "

មិនបានសោះឡើយ ” ។ អដ្ឋកថារាហុលសូត្រ ក្នុងឯកនិបាត អង្គុត្តរនិកាយ ថា “ ក្នុងវេលាចប់ព្រះធម្មទេសនា ព្រះរាហុលត្ថេរ សម្រេចព្រះអរហត្ត ជាមួយនឹងទេវតាប្រមាណ ១ សែនកោដិ ។ ទេវតាដែលជាព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រាប់មិនអស់ឡើយ ” ។

អដ្ឋកថាសមចិត្តសូត្រ ក្នុងទុកនិបាត អង្គុត្តរនិកាយ ថា “ ក្នុងពេលចប់ព្រះធម្មទេសនា ទេវតាប្រមាណ ១ សែនកោដិ សម្រេចព្រះអរហត្ត ។ ទេវតាដែលជាព្រះសោតាបន្នជាដើម រាប់មិនបានសោះឡើយ ។ ក៏ទេវតា ១ សែនកោដិ សម្រេចព្រះអរហត្ត ក្នុងមហាសម័យសូត្រ ក្នុងមង្គលសូត្រ និងក្នុងចូឡរាហុលោវាទសូត្រ ក្នុងសមាគមនេះ ក៏ដូច្នោះដែរ ។ ទេវតា និងមនុស្សទាំងឡាយ ដែលបានសម្រេចព្រះសោតាបន្នជាដើម កំណត់រាប់មិនអស់ទេ ” ។

(១៤៤) អដ្ឋកថាបរាភវសូត្រ ក្នុងបឋមវគ្គ សុត្តនិបាត ថា “ ក្នុងវេលាចប់ព្រះធម្មទេសនា ពួកទេវតា ដែលស្តាប់ផ្លូវនៃសេចក្តីវិនាសទាំងឡាយហើយ ផ្តើមតាំងសេចក្តីព្យាយាម ដោយបញ្ញាតាមសមគួរដល់សេចក្តីសង្វេគ ដែលកើតឡើងហើយ សម្រេចព្រះសោតាបត្តិផល សកទាគាមិផលនិងអនាគាមិផល ហួសនឹងគណនា ។ ដូចជាលោកពោលហើយ ថា ÷

" ទេវតាប្រជុំគ្នា ក្នុងស្ថានទីទាំងនោះគឺ ក្នុងមហាសម័យសូត្រ ១ ក្នុងមង្គលសូត្រ ១ សមចិត្តសូត្រ ១ រាហុលោវាទសូត្រ ១ ក្នុងធម្មចក្កប្បវត្តនសូត្រ ១ បរាភវសូត្រ ១ យ៉ាងច្រើន រាប់ប្រមាណមិនបាន, ក៏ការសម្រេចធម៌ ក្នុងស្ថានទីទាំងនេះ អ្នកណាក៏មិនគួររាប់ដោយចំនួនបានឡើយ "។

ព្រោះហេតុនោះ ព្រះពុទ្ធវចនៈមានធម្មចក្កប្បវត្តនសូត្រជាដើម តាមដែលពោលមកហើយ គប្បីយល់ថា " ជាវាចាសុភាសិត " ដោយពិសេស ដូច្នេះឯង ។ ន័យទី ២ ចប់ ។

ការពណ៌នាអំពីវាចាជាសុភាសិត ចប់ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់មង្គល ៤ ប្រការ គឺ " ភាវៈជាអ្នកបានស្ដាប់ច្រើន ១ សិប្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ វាចាជាសុភាសិត ១ " ដោយគាថានេះ ដូចបានពណ៌នាមកហើយនេះឯង ។ សូម្បីពាក្យជាគាថានេះ ក៏ជាបឋ្យាវត្ត ដូច្នេះឯង ។

ការពណ៌នាសេចក្ដីនៃគាថាទី ៣ ចប់ ។

---

ប្រែចប់ថ្ងៃសុក្រ ៤ រោច ខែកត្ដិក ឆ្នាំវក ចត្វាស័ក ព.ស.២៥៣៥
១៣ វិច្ឆិកា ១៩៩២

(១៤៥) គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី៤ ។ ការទំនុកបំរុង មាតាបិតា ឈ្មោះថា មាតាបិតុឧបដ្ឋាន ។ ពាក្យថា "**បុត្តទារស្ស**" ជាចតុត្ថីវិភត្តិ ចុះក្នុងសម្បទាន ។ អាចារ្យពួកខ្លះ ពោល ថា "ជាឆដ្ឋីវិភត្តិ ចុះក្នុងកម្ម" ដូច្នេះ ក៏មាន ។ លោកពោលហើយ ក្នុងអដ្ឋកថា ថា "**បុត្តានញ្ច ទារានញ្ច**" ដើម្បីសំដែង ថា 'សូម្បីក្នុងគាថា ថា '**បុត្តទារស្ស**' នេះ គប្បីប្រកាន់យកសេចក្ដី ថា '**បុត្តទារានំ**' ដូចជាក្នុងប្រយោគនេះ ថា '**បុព្វេ សុចិណ្ណានិ កត្វា តំ បច្ចវេក្ខតិ**' លោកកាន់យកសេចក្ដី ក្នុងអត្ថនៃពហុវចនៈ ថា '**តានិ**' ដោយអំណាចនៃឯកវចនៈ ថា '**តំ**' ដូច្នោះឯង ។ ការសង្គ្រោះ ឈ្មោះថា សង្គហៈ ។ បទ ថា "**អនាកុលា**" បាន ដល់ ដែលវៀរចាកភារៈជាការងារ មិនច្របូកច្របល់ ។ កម្មទាំងឡាយនុ៎ះឯង ឈ្មោះថា កម្មន្តៈ ។ បទ ថា "**ឯតំ**" មានសេចក្ដី ថា ម្នាលទេវតា អ្នកចូរប្រកាន់យក ថា 'ការបំរុងមាតាបិតា ១ ការសង្គ្រោះបុត្រនិងភរិយា ១ ការងារដែលមិនច្របូកច្របល់ ១ កម្ម ៣ យ៉ាង មានបំរុងមាតាបិតាជាដើមនេះ ជាមង្គលដ៏ឧត្តម' ដូច្នេះ" ។ សេចក្ដីសង្ខេប ក្នុងគាថាទី ៤ នេះ តែប៉ុណ្ណោះឯង ។

ឯសេចក្ដីពិស្ដារ ក្នុងគាថាទី ៤ នេះ មានដូចតទៅនេះ ÷

## ការពណ៌នាពីការចំនុកបំរុងមាតាបិតា

(១៤៦) ស្ត្រីដែលញុំាងបុត្រឲ្យកើត ឈ្មោះថា **មាតា** ។ បុរសដែលញុំាងបុត្រឲ្យកើត ឈ្មោះថា **បិតា** ។ បណ្ដាមាតានិងបិតាទាំងនោះ មាតាប៉ុណ្ណោះ ជាអ្នកធ្វើកិច្ចការដែលគេធ្វើបានដោយកម្រ, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលកើតជាតាបសព្រះនាមសោណបណ្ឌិត កាលទ្រង់ប្រកាសភាវៈនៃមាតាជាអ្នកធ្វើកិច្ចការ ដែលគេធ្វើបានដោយកម្រ ថ្វាយដល់ព្រះរាជា ក្នុងជម្ពូទ្វីបទាំងមូល ទើបពោលគាថាទាំងនេះ ក្នុងសោណនន្ទជាតក ក្នុងសត្តតិនិបាត ថា ÷

( ឧបការគុណនៃមាតា )

" មាតាកាលប្រាថ្នាចង់បានផ្លែ គឺកូន តែងនមស្ការទេវតា សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលោងស្នាតហើយ, សត្វក៏ចុះមកកាន់គភ៌សិប, ដោយហេតុនោះ មាតាជាស្ត្រី មានសេចក្ដីចាញ់ផ្ទៃ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា ( មានដួងហឫទ័យល្អ )។ មាតារក្សា (ផ្ទៃ) អស់

មួយឆ្នាំ ឬថយពីមួយឆ្នាំហើយ ទើបប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅ មាតានោះ ថា ជនយន្តី ផង ជនេត្តី ផង ( អ្នកបង្កើតកូន ) ។ មាតាញុំាងកូន ដែលកំពុងយំឱ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី ( អ្នកញុំាងកូនឱ្យត្រេកអរ ) ។ តអំពីនោះមក មាតាធ្វើនូវសេចក្ដីស្រឡាញ់ រាប់អានហើយ ក្រឡេកមើលទារក ដែលនៅពុំទាន់ដឹងក្ដី ក្នុងទីមានខ្យល់ និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា បោសេន្តី (អ្នកចិញ្ចឹមកូន ) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង, មាតាគ្រប់គ្រងទ្រព្យទាំងពីរចំណែកនុ៎ះ ដើម្បីកូននោះ (ដោយបំណងថា) 'ទ្រព្យនេះត្រូវមានដល់បុត្រ របស់យើង'។ មាតា រមែងលំបាក ដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា 'ម្នាលកូន (ឯងចូរកុំប្រមាថក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន ( ឯងចូរធ្វើការ ) ឯណោះ'។

កាលបើកូនមានវ័យ ចំរើនឡើងហើយ, មាតា
(បានដឹង) ថា កូនប្រមាទ ក្នុងប្រពន្ធនៃអ្នកដទៃ
ក្នុងពេលអាធ្រាត្រហើយ មិនត្រឡប់មក ក្នុងពេល
ល្ងាច ក៏រមែងលំបាកចិត្ត ដោយប្រការដូច្នេះ"។

(១៤៧) បណ្ដាបទទាំងនោះ បទ ថា "**បុត្តផលំ**" បានដល់ផល គោលគឺបុត្រ ។ បាទគាថា ថា "**ទេវតាយ នមស្សតិ**" មានសេចក្ដីថា មាតា រមែងធ្វើការនមស្ការ គឺបួងសួងចំពោះទេវតា ថា "សូមឲ្យបុត្រ កើតមានដល់យើងខ្ញុំ" ។ ២ បទ ថា "**នក្ខត្តានិ បុច្ឆតិ**" មានសេចក្ដីថា មាតា រមែងសួរនូវនក្ខត្តប្ញក្ស យ៉ាងនេះ ថា "បុត្រកើត ដោយនក្ខត្តប្ញក្សណា ទើបមានអាយុវែង? ដោយនក្ខត្តប្ញក្សណា ទើបមានអាយុខ្លី?" និងសួរនូវរដូវ និងឆ្នាំទាំងឡាយ យ៉ាងនេះ ថា "បណ្ដារដូវទាំង ៦ បុត្រកើត ក្នុងរដូវណា និងឆ្នាំណា ទើបមានអាយុវែង? ក្នុងរដូវនិងឆ្នាំណា ទើបមានអាយុខ្លី?" ។ ២ បទ ថា "**ឧតុសិ នហាតាយ**" មានសេចក្ដីថា បើរដូវកើតឡើងហើយ, ឈ្មោះថា មានរដូវលាងស្អាតហើយ ។ បទ ថា "**គព្ភស្ស**" បានដល់ សត្វដែលកើតក្នុងគភ៌ ។ បទ ថា "**អវក្កមោ**" បានដល់ ការចុះកាន់ គឺការកើត តែងមាន ។

អធិប្បាយថា គតិរមែងតាំងនៅ ក្នុងផ្ទៃ ។ ក្នុងបទថា **អវក្កមោ** នេះ គប្បីជ្រាបសេចក្ដី ដោយន័យដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងមហាតណ្ហាសង្ខេយសូត្រ ថា " ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះ បច្ច័យ ៣ យ៉ាង ប្រជុំគ្នាហ្នឹងឯង ការចុះកាន់ នៃសត្វដែលកើត ក្នុងគតិ រមែងមាន " ។ បទ ថា " **តេន** " មានសេចក្ដីថា ដោយ សត្វដែលកើត ក្នុងគតិនោះ មាតានោះ ទើបជាស្ត្រីមានសេចក្ដី ចាញ់ផ្ទៃ ។ បទ ថា " **តេន** " មានសេចក្ដីថា ក្នុងកាលនោះ សេចក្ដី ស្នេហា ក្នុងសត្វដែលកើត ក្នុងផ្ទៃនៃមាតានោះ រមែងកើតឡើង ដោយហេតុនោះ បានជាបណ្ឌិតហៅថា **សុហទា** ។ បទ ថា " **តេន** " មានសេចក្ដីថា ដោយហេតុនោះ មាតានោះ បានជាបណ្ឌិតហៅថា **ជនយន្តី** និង **ជនេត្តី** ។ បាទគាថា ថា " **ថនក្ខីរេន គីតេន** " មានសេចក្ដីថា ដោយទឹកក្សីរ ពោលគឺទឹកដែលកើតមកអំពីស្តន និង ភ្លេងចម្រៀង ។ បទ ថា " **អង្គបាវុរណេន** " មានសេចក្ដីថា ហើយនិងមាតាកាលឲ្យបុត្រដេក ត្រង់ចន្លោះនៃស្តន ហើយញុំាង សម្ផស្សនៃសរីរៈ ឲ្យផ្សព្វផ្សាយទៅ ឈ្មោះថា រមែងឲ្យត្រេកអរ ដោយការឱបក្រសោប ពោលគឺអវយវៈ ។ បទ ថា " **តោសេតិ** " មានសេចក្ដីថា កាលញុំាងបុត្រឲ្យយល់ព្រម ឈ្មោះថា ឲ្យត្រេកអរ ។ បទ ថា " **មម្មំ កត្វា** " មានសេចក្ដីថា មាតាលាន់មាត់ ថា " អញ "

ដូច្នេះហើយ ធ្វើសេចក្ដីស្រឡាញ់រាប់អាន យ៉ាងនេះ ថា "ខ្យល់បក់, កំដៅថ្ងៃជះមកចំលើកូន របស់អញ" ដូច្នេះហើយ ទន្ទឹងចាំមើល (តែផ្លូវ) ដោយដួងចិត្តដ៏ជិតស្និទ្ធ (គួរស្រឡាញ់) ។

បទ ថា "**ឧភយមេវ្យតស្ស**" មានសេចក្ដីថា មាតាមិនបាន បង្ហាញទ្រព្យទាំង ២ ផ្នែកនោះ ដល់ជនដទៃឡើយ តែងគ្រប់គ្រង ក្នុងទីស្ថានទាំងឡាយ មានបន្ទប់ដែលល្អជាដើម ដើម្បីប្រយោជន៍ ដល់បុត្រនុ៎ះ ។ ពាក្យថា "**ឯវំ បុត្ត អទុំ បុត្ត**" នេះ មាន សេចក្ដីថា មាតាកាលញុំាងបុត្រឲ្យសិក្សា ថា "នែកូន អ្នកល្ងង់ខ្លៅ ឯងកុំប្រមាទ ក្នុងត្រកូលទាំងឡាយ មានរាជត្រកូលជាដើម យ៉ាង នេះ, និងកូនឯង ចូរធ្វើការងារ យ៉ាងនុ៎ះ" ដូច្នេះហើយ ឈ្មោះថា រមែងក្ដៅក្រហាយ គឺលំបាក ដោយប្រការដូច្នេះ ។ កាលបុត្រធំ ពេញវ័យហើយ, មាតាដឹងថា កូននោះ ស្រវឹងក្នុងភរិយា របស់ជន ដទៃ ក្នុងវេលាអាធ្រាត្រ មិនត្រឡប់មក ក្នុងវេលាល្ងាច មានភ្នែក ទាំងគូ ពោរពេញទៅដោយទឹកភ្នែក ទន្ទឹងចាំមើលបុត្រ ឈ្មោះថា រមែងក្ដៅក្រហាយ ដោយប្រការដូច្នេះ ។

## ( មាតាបិតាជាព្រះព្រហ្មរបស់បុត្រធីតា )

(១៤៨)ម្យ៉ាងទៀត មាតាបិតាទាំង ២ នាក់នោះ បណ្ឌិត

លោកហៅថា " ព្រហ្ម បុព្វទេវា បុព្វាចារ្យ និង អាហុនេយ្យ-បុគ្គល " ( របស់បុត្រធីតា ) ។ ប្រៀបឧបមាដូចជា មហាព្រហ្ម តែងមិនលះបង់ភាវនាទាំង ៤ ប្រការ ក្នុងពពួកសត្វ យ៉ាងណាមិញ, មាតាបិតា ក៏មិនបានលះបង់ភាវនាទាំង ៤ ប្រការ ក្នុងបុត្រទាំងទាំងឡាយ យ៉ាងដូច្នោះដែរ ។ មែនពិត កាលបុត្រ នៅក្នុងផ្ទៃ, មាតាបិតានោះ កើតចិត្តប្រកបដោយមេត្តា ក្នុងបុត្រ ថា "កាលណាហ្ន៎ ! យើងនឹងបានឃើញកូនតូច ដែលគ្មានរោគ " ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងកាលណា បុត្រនុ៎ះ នៅក្មេងខ្ចី ដេកផ្ងារ ត្រូវសត្វទាំងឡាយ មានចៃជាដើមខាំ ឬត្រូវការដេកជាទុក្ខ បៀតបៀន រមែងទ្រហ៊ុំយំ, ក្នុងកាលនោះ មាតាបិតាទាំង ២ នោះ កើតសេចក្ដីករុណាឡើង ព្រោះបានឮសំឡេង នៃបុត្រនោះ ។ ម្យ៉ាងវិញទៀត ក្នុងវេលាដែលបុត្រចេះរត់ទៅរត់មក លេងបានក្ដី ក្នុងវេលាដែលបុត្រស្ថិតនៅ ក្នុងវ័យគួរជាទីស្រឡាញ់ក្ដី មាតាបិតាទាំង ២ នោះ ក៏មានចិត្តទោរទន់ សប្បាយ រីករាយ ព្រោះសំឡឹងមើលកូនតូច, ក្នុងកាលនោះ មាតាបិតាទាំង ២ នោះ តែងបានសេចក្ដីត្រេកអរគាម ។

ម្យ៉ាងទៀត ក្នុងកាលណា បុត្រនោះធ្វើនូវការចិញ្ចឹមភរិយា នៅគ្រប់គ្រងផ្ទះដោយឡែក, ក្នុងកាលនោះ មាតាបិតាទាំង ២ នុ៎ះ

ក៏កើតឧបេក្ខាឡើង ថា "ពេលនេះ កូនតូច របស់យើង អាចដើម្បី នឹងចិញ្ចឹមជីវិត បានតាមធម្មតា របស់ខ្លួនហើយ" ក្នុងកាលនោះ លោកទាំង ២ នោះ តែងបានឧបេក្ខា (ការតាំងចិត្តជាកណ្តាលៗ) ។

មាតាបិតា ទាំង ២ នាក់នោះ បណ្ឌិតហៅថា "ព្រហ្ម" ព្រោះគាត់ទាំង ២ នោះ ប្រព្រឹត្តបីដូចជាព្រហ្ម ដោយហេតុថាបាន ព្រហ្មវិហារធម៌ ក្នុងបុត្រទាំងឡាយ គ្រប់ទាំង ៤ ប្រការ តាមកាល ដូច្នេះឯង ។

## ( មាតាបិតាជាបុព្វទេព្វរបស់បុត្រ )

ប្រៀបឧបមាដូចជា វិសុទ្ធិទេវតា ពោលគឺព្រះខីណាស្រព មិនគិតដល់សេចក្តីខុស ដែលពួកជនពាល បានធ្វើហើយ ប្រាថ្នាតែ សេចក្តីសាបសូន្យទៅនៃសេចក្តីវិនាស និងការកើតឡើងនៃសេចក្តី ចំរើនប៉ុណ្ណោះ ប្រតិបត្តិដើម្បីប្រយោជន៍ ដល់ជនពាលទាំងនោះ តែម្យ៉ាងពិត និងតែងនាំនូវភារៈ នៃសក្ការៈទាំងឡាយ របស់ ជនទាំងនោះ មានផលានិសង្សច្រើនមកឲ្យ ព្រោះជាទក្ខិណេយ្យ-បុគ្គល យ៉ាងណាមិញ, មាតានិងបិតាទាំង ២ នោះ ក៏ដូច្នោះដែរ មិនគិតដល់សេចក្តីខុសឆ្គង របស់បុត្រទាំងឡាយ ប្រតិបត្តិដើម្បី ប្រយោជន៍សុខ ដល់បុត្រទាំងនោះ តែម្យ៉ាងគត់ប៉ុណ្ណោះ ជាអ្នក សមគួរដល់ទក្ខិណា រមែងនាំនូវភារៈ នៃសក្ការៈដែលបុត្រទាំង

ឡាយនោះ បានធ្វើហើយលើខ្លួន ជាសក្ការៈ មានផលានិសង្សច្រើន, ព្រោះហេតុនោះ មាតានិងបិតាទាំង ២ នោះ ទើបឈ្មោះថា **ទេព្វ** ព្រោះជាអ្នកប្រព្រឹត្តដូចជាទេព្វ ។

ម្យ៉ាងទៀត ព្រោះបុត្រទាំងឡាយ ស្គាល់ទេវតាដទៃ ដោយអំណាចមាតាបិតាទាំង ២ នោះមុនហើយ ប្រតិបត្តិរមែងទទួលនូវផលនៃការប្រតិបត្តិ ដូច្នោះ សម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេពដទៃ ទើបឈ្មោះថា **ជាបច្ឆាទេព្វ** ។ ចំណែក មាតាបិតា បានជាបណ្ឌិតហៅថា **បុព្វទេព្វ** ក៏ព្រោះមាតាបិតាទាំងនោះ ជាអ្នកមានឧបការគុណមុនគេ ជាងទេព្តាដទៃ ។

## ( មាតាបិតាជាបុព្វាចារ្យរបស់បុត្រ )

ម្យ៉ាងទៀត ព្រោះមាតាបិតាទាំង ២ នោះ ញុំាងបុត្រឲ្យប្រកាន់យក ឲ្យសិក្សា ចាប់ដើមតាំងពីបុត្រកើតមក ដោយន័យជាអាទិ៍ថា "កូនឯង ចូរអង្គុយ យ៉ាងនេះ, ចូរឈរ យ៉ាងនេះ" និងថា " អ្នកនេះ កូនឯងចូរហៅថា 'ឪ" ដូច្នេះ ក្រោយមក ពួកអាចារ្យដទៃ ទើបឲ្យសិក្សា សិល្បៈទាំងឡាយ មានសិល្បៈព្រោះដំរីជាដើម, អាចារ្យដទៃទៀត ឲ្យសរណៈនិងសីល, អាចារ្យដទៃទៀត បំបួសឲ្យ, ដទៃទៀត ឲ្យរៀននូវព្រះពុទ្ធវចនៈ, ដទៃទៀត

ឲ្យឧបសម្បទ, ដទៃទៀត ឲ្យបានសម្រេចមគ្គផល, អាចារ្យសូម្បី ទាំងអស់នោះ ឈ្មោះថា **ជាបច្ឆាចារ្យ** ដោយប្រការដូច្នេះ, ព្រោះ ហេតុនោះ មាតាបិតាទាំងឡាយ បានជាបណ្ឌិតហៅថា **បុព្វាចារ្យ** ព្រោះមាតាបិតាទាំងនោះ ជាអាចារ្យមុនគេទាំងអស់ ។

## ( មាតាបិតាជាអាហុនេយ្យបុគ្គលរបស់បុត្រ )

ម្យ៉ាងទៀត ព្រោះមាតាបិតាទាំងនោះ រមែងសមគួរនូវវត្ថុ មានបាយនិងទឹកជាដើម ដែលបុត្រទាំងឡាយនាំមកបូជា ទទួល ចាត់ចែង គឺជាអ្នកសមគួរ ដើម្បីនឹងទទួល នូវបាយនិងទឹកជាដើមនោះ ដូច្នោះ មាតាបិតាទាំងនោះ បណ្ឌិតហៅថា **អាហុនេយ្យបុគ្គល** ។

ហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងសព្រហ្មកសូត្រ ក្នុងតិកនិបាត និងចតុក្កនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ ពាក្យថា "**ព្រហ្ម**" នុ៎ះ ជាឈ្មោះមាតាបិតា, ពាក្យថា "**បុព្វទេព**... ពាក្យថា " **បុព្វាចារ្យ**... ពាក្យថា " **អាហុនេយ្យបុគ្គល** " នុ៎ះ ជាឈ្មោះមាតាបិតា ។ ដំណើរនោះព្រោះហេតុអ្វី ? ។ ម្នាលភិក្ខុ ទាំងឡាយ ព្រោះមាតាបិតា ជាអ្នកមានឧបការៈច្រើន បីបាច់ថែរក្សា ចិញ្ចឹមបុត្រ ជាអ្នកឲ្យបុត្របានឃើញលោកនេះ " ។

(១៤៩) ( ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធវចនៈនេះ,

ព្រះសុគត ជាព្រះសាស្តា លុះទ្រង់ត្រាស់ព្រះពុទ្ធវចនៈនេះហើយ តមកខាងក្រោយ ទ្រង់បានត្រាស់និគមវចនៈឯទៀត បន្ថែមទៀត ថា ) ÷

**(១៤៨) " មាតាបិតា លោកហៅថា ព្រហ្មផង ថា បុព្វាចារ្យផង ថា អាហុនេយ្យបុគ្គលផង របស់បុត្រទាំងឡាយ ព្រោះជាអ្នកអនុគ្រោះនូវពពួកសត្វ " ។**

បណ្តាបទទាំងនោះ ក្នុងបទ ថា **"អាហុនេយ្យា"** គប្បីជ្រាបវិនិច្ឆ័យដូច្នេះ វត្ថុណាដែលបុត្រគប្បីនាំមកបូជា គឺកាលប្រាថ្នានូវផលវិសេស គប្បីនាំមកសូម្បីអំពីទីឆ្ងាយហើយ ឲ្យក្នុងមាតាបិតាទាំងឡាយ ដែលជាអ្នកមានគុណ ហេតុនោះ វត្ថុនោះ ឈ្មោះថា អាហុនៈ គឺបាយនិងទឹកជាដើម, មាតាបិតា រមែងសមគួរនូវវត្ថុដែលបុត្រគប្បីនាំមកបូជានោះ ព្រោះលោកទាំង ២ នោះ ជាខេត្តនៃឧបការៈ ហេតុនោះ ទើបឈ្មោះថា **អាហុនេយ្យ** ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ ដើម្បីនឹងទ្រង់សំដែងហេតុ ក្នុងភាវៈនៃមាតាបិតាទាំង ២ នោះ ជាព្រហ្មជាដើម ទើបទ្រង់ត្រាស់ ថា " ដំណើរនោះ ព្រោះហេតុអ្វី " ដូច្នេះ ។ បណ្តាពាក្យទាំងនោះ ពាក្យថា " **តំ កិស្ស ហេតុ** " មានសេចក្តីថា ដំណើរនោះ គឺឈ្មោះរបស់មាតាបិតាទាំងឡាយថា ព្រហ្ម ជាដើម ( តែងមាន )

ព្រោះហេតុអ្វី ? ។ បទ ថា “**ពហុការា**” បានដល់ មានឧបការៈច្រើន, ក៏ **ការ** ស័ព្ទ ក្នុងបទថា **ពហុការា** នេះ សូម្បីវៀរចាក **ឧប** ស័ព្ទ ក៏សំដៅយកសេចក្តីថា ឧបការៈ ។ ព្រះដ៏មានព្រះភាគ ដើម្បីនឹងទ្រង់សំដែងនូវភារៈនៃមាតាបិតាទាំងនោះ ជាអ្នកដែលមានឧបការៈច្រើន ដោយអាការផ្សេងៗ ទើបត្រាស់ ថា “**អាបាទកា**” ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទ ថា “**អាបាទកា**” មានសេចក្តីថា អ្នកបីបាច់ថែរក្សា គឺចិញ្ចឹមជីវិត ។ មែនពិត ជីវិតរបស់បុត្រទាំងឡាយ គឺមាតាបិតាទាំង ២ នោះ បីបាច់ថែរក្សា ចិញ្ចឹមបន្តភ្ជាប់ ឲ្យប្រព្រឹត្តទៅ ដោយជាប់ទាក់ទងគ្នា ។

(១៥០) ចំណែក ក្នុងអដ្ឋកថាទុកនិបាត អង្គុត្តរនិកាយ លោកពោល ថា “បទ ថា **អាបាទកា** គឺ ឲ្យចំរើន បានដល់ អ្នកដែលចិញ្ចឹម ។ ពិតមែន បុត្រទាំងឡាយ គឺមាតាបិតា ទាំងឲ្យចំរើនផង ទាំងចិញ្ចឹមផង” ។ បទ ថា “**បោសកា**” មានសេចក្តីថា អ្នកដែលញាំងដៃនិងជើងឲ្យចំរើនហើយ ឲ្យបៅលោហិត ក្នុងហឫទ័យចិញ្ចឹម ។ មែនពិត បុត្រទាំងឡាយ គឺមាតាបិតាទាំងនោះ បីបាច់រក្សា គឺចិញ្ចឹម បានដល់ ប្រតិបត្តិហើយ ដោយបាយនិងទឹកជាដើម ។

ក្នុងដីកាទុកនិបាត អង្គុត្តរនិកាយ លោកពោល ថា “បទ ថា **ហទយលោហិតំ**” បានដល់ ទឹកដោះ ។ មែនពិត ទឹកលោហិត

រមែងដល់នូវការប្រែប្រួលទៅ ដោយភាពជាទឹកដោះ"ៗ បទថា "**ទស្សេតារោ**" មានសេចក្តីថា ក៏ប្រសិនបើ មាតាបិតាគប្បីចាប់បុត្រ ត្រង់ជើងទាំង ២ ហើយ បោះចោលទៅ ក្នុងព្រៃ ក្នុងទឹក ឬក្នុងជ្រោះជ្រៅ ក្នុងថ្ងៃដែលបុត្រកើតហើយនុ៎ះឯង, បុត្រទាំងនោះ ក៏មិនគប្បីឃើញនូវអារម្មណ៍ដែលជាទីប្រាថ្នា និងមិនជាទីប្រាថ្នា ក្នុងលោកនេះ បានឡើយ, ការដែលបុត្រទាំងនោះ ឃើញនូវអារម្មណ៍នោះបាន កើតមាន ព្រោះអាស្រ័យមាតាបិតាទាំងឡាយ ព្រោះមាតាបិតាមិនបានធ្វើ យ៉ាងដូច្នោះហើយ ចិញ្ចឹម ហេតុនោះ មាតាបិតាទាំងនោះ ទើបឈ្មោះថា ជាអ្នកឲ្យបុត្របានឃើញលោកនេះ ៗ

២ បទ ថា "**បជាយ អនុកម្បកា**" មានសេចក្តីថា ជាអ្នកអនុគ្រោះបុត្រទាំងឡាយ របស់ខ្លួន ៗ មែនពិត មាតាបិតាទាំងនោះ ផ្តាច់នូវជីវិត របស់សត្វដទៃខ្លះ លះបង់នូវទ្រព្យណាមួយ ដែលជារបស់នៃខ្លួនខ្លះ ប្រណិបត្តិគ្រប់គ្រង នូវបជា (បុត្រ) របស់ខ្លួន ៗ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ព្រះពុទ្ធវចនៈនុ៎ះ ថា "**បជាយ អនុកម្បកា**" ៗ ក៏គាថានេះ មកហើយសូម្បីក្នុងសោណនន្ទជាតក ៗ

## ( ការតបគុណដល់មាតាបិតា )

(១៥១) ដូច្នោះ ភារៈនៃមាតាបិតាទាំងនោះ ជាអ្នកមាន

ឧបការៈច្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា ជាហេតុនៃការៈជា ព្រហ្មជាដើម ដែលជាហេតុគឺបុត្រមិនអាចនឹងធ្វើតប ដល់មាតាបិតាទាំងនោះ ឲ្យបានចប់សព្វគ្រប់ ដោយប្រការណាមួយ ដោយឧបការៈដែលជាលោកិយបានឡើយ ។ ក៏ប្រសិនបើ បុត្របញ្ចិះមាតា ពួដ៏ចុងស្មាខាងស្តាំ បិតាពួដ៏ចុងស្មាខាងឆ្វេង ដោយគិត ថា " អាត្មាអញ នឹងធ្វើតប ដល់មាតាបិតាទាំង ២ នោះ " ដូច្នេះហើយ គប្បីប្រណិបត្តិ ក្នុងអវយវៈគ្រប់យ៉ាងហើយ ធ្វើការទំនុកបំរុង មាតាបិតាទាំងនោះ ដែលស្ថិតនៅលើស្មាទាំង ២ នោះឯង ដោយកិច្ចមានការដុសជម្រះបំបាត់ក្លិនអាក្រក់ជាដើម, ឯមាតាបិតាទាំង ២ នោះ ក៏គប្បីអង្គុយ បន្ទោបង់មូត្រនិងករីស លើចុងស្មាទាំង ២ របស់បុត្រនោះឯង, បុត្រនោះ សូម្បីធ្វើយ៉ាងនេះ អស់រយៈវេលា ១០០ ឆ្នាំ ក៏មិនអាច ដើម្បីនឹងធ្វើតប ដល់មាតាបិតាទាំងនោះ បានឡើយ ។ ប្រសិនបើ បុត្រគប្បីលើកតម្កើងបិតា ក្នុងតំណែងចក្រពត្រាធិរាជ មាតាក្នុងតំណែង នៃព្រះអគ្គមហេសី របស់ស្តេចចក្រពត្តិ, សូម្បីជាធ្វើយ៉ាងដូច្នេះ ក៏មិនអាចធ្វើតប ដល់មាតាបិតាទាំង ២ នោះ បានឡើយ ។ ចំណែក បុត្រណាមួយ តាំងមាតាបិតា ដែលដល់ព្រម ដោយអធម៌ មានការមិនជឿជាដើម ក្នុងធម៌ទាំងឡាយ មានការដល់ព្រមដោយសទ្ធាជាដើម, បុត្រនោះ ឈ្មោះថា អាចដើម្បី

នឹងធ្វើតប ដោយហេតុមានប្រមាណប៉ុណ្ណោះ ៗ ដោយហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងមាតាបិតុគុណសូត្រ ក្នុងទុកនិបាត អង្គុត្តរនិកាយ ថា "ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្រ មិនងាយនឹងធ្វើការតបគុណ ដល់បុគ្គលពីរពួកបានឡើយ ៗ បុគ្គលពីរពួក តើនរណាខ្លះ ? ៗ គឺ មាតា ១ បិតា ១ ៗ ម្នាលភិក្ខុទាំងឡាយ បុត្រមានអាយុ ១០០ ឆ្នាំ រស់នៅ ១០០ ឆ្នាំ គប្បីបញ្ញិះមាតា ដោយស្មាម្ខាង, បញ្ញិះបិតា ដោយស្មាម្ខាង, ហើយបុត្រនោះ គប្បីបម្រើមាតាបិតាទាំង ២ នោះ ដោយការដុស ជម្រះបំបាត់ក្លិនអាក្រក់ រឹតអវៃ្កលដៃ ផ្ងូតទឹក គក់ច្របាច់ដៃជើង, ឯមាតានិងបិតាទាំង ២ នោះ ក៏គប្បី បន្ទោបង់នូវមូត្រនិងករីស លើស្មានៃបុត្រនោះឯង, ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណោះ គង់មិនទាន់ហៅថា បុត្រ ធ្វើ ឬធ្វើតប ដល់មាតាបិតាបានឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ក៏បុត្រគប្បីតម្កើងមាតានិងបិតា ឲ្យតាំងនៅក្នុងរាជសម្បត្តិ មានឥស្សរភាពជាអធិបតី លើផែនដីធំ ដែលមានកែវ ៧ ប្រការច្រើនសន្ធឹកនេះ, ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណោះ គង់មិនទាន់ហៅថា បុត្រធ្វើ ឬធ្វើតប ដល់មាតានិងបិតាបានឡើយ ៗ ដំណើរនោះ ព្រោះហេតុអ្វី ? ៗ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតានិងបិតា ជាអ្នកមានឧបការៈច្រើន

ព្រោះជាអ្នកថែរក្សា ចិញ្ចឹម បង្ហាញនូវលោកនេះ ដល់បុត្រទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ (បើ) បុត្រណាមួយ ដឹកនាំមាតាបិតា ដែលមិនទាន់មានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា, បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅ ក្នុងសីលសម្បទា, បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅ ក្នុងចាគសម្បទា, បើឥតប្រាជ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា, ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថា គឺបុត្រធ្វើ ធ្វើតប និងធ្វើឲ្យក្រៃលែងហើយ ដល់មាតានិងបិតាមែន " ។

(១៥២) បណ្តាបទទាំងនោះ ២ បទថា " **មាតុ ច បិតុ ច** " បានដល់ មាតាអ្នកបង្កើត និងបិតាអ្នកបង្កើត ។ បទថា " **បរិហរេយ្យ** " មានសេចក្តីថា គប្បីបញ្ជិះមាតា លើចុងស្មាម្ខាង គឺខាងស្តាំហើយ បម្រើ ប្រណិបត្តិ ។

ក្នុងដីកាទុកនិបាត អង្គុត្តរនិកាយ លោកពោលថា " បណ្តាមាតាបិតាទាំងឡាយ មាតាប៉ុណ្ណោះ ជាអ្នកមានឧបការៈច្រើនជាង ហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលចុងស្មាខាងស្តាំ សម្រាប់មាតានោះប៉ុណ្ណោះ ព្រោះមាតានោះ ជាអ្នក គឺបុត្រត្រូវធ្វើតបគុណ ដោយភាពជាប្រធាន " ។

ន័យមកក្នុងអដ្ឋកថា មាតាបិតុគុណសូត្រនោះ ថា "បទថា អំសេន មានសេចក្ដីថា បុត្រគប្បីបញ្ចិះបិតា លើចុងស្មាម្ខាង គឺខាងឆ្វេង ហើយ ប្រណិបត្តិ ។ បទ ថា "**វស្សសតាយុកោ**" មានសេចក្ដីថា មានអាយុប្រមាណ ១០០ ឆ្នាំ, អធិប្បាយថា កើតក្នុងកាលនៃមនុស្សដែលមានអាយុ ១០០ ឆ្នាំ ។ បទ ថា "**វស្សសតជីវី**" គឺ រស់នៅពេញ ១០០ ឆ្នាំ ។ ២ បទ ថា "**សោ ច នេសំ**" មានសេចក្ដីថា ក៏បុត្រនោះ គប្បីធ្វើការទំនុកបំរុង មាតាបិតានោះ ដែលស្ថិតនៅលើចុងស្មាទាំង ២ របស់ខ្លួនន៉ុះឯង ដោយការដុសជម្រះ បំបាត់ក្លិនអាក្រក់ចេញ ការរិតអង្អែល ការងូតទឹក ការគក់ច្របាច់ ។ ២ បទ ថា "**តេ ច តត្ថេវ**" មានសេចក្ដីថា ឯមាតាបិតានោះ គប្បីអង្គុយ បន្ទោបង់មូត្រនិងករីស លើចុងស្មាទាំង ២ ន៉ុះ របស់បុត្រន៉ុះឯង ។ ២ បទ ថា "**ឥស្សរាធិបច្ចេ រជ្ជេ**" មានសេចក្ដីថា ក្នុងភាពជាស្ដេចចក្រពត្តិ ។ បទ ថា "**សមាទបេតិ**" ប្រែថា ឲ្យកាន់យក ។ ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សទ្ធា សីល ចាគៈ និងបញ្ញា ដែលលាយគ្នា ទាំងលោកិយៈ ទាំងលោកុត្តរៈ ។ ភិក្ខុដូចជាព្រះធម្មសេនាបតីហ្នឹងឯង គប្បីជ្រាបថា "ឈ្មោះថា រមែងញុំាងមាតានិងបិតា ឲ្យតាំងនៅក្នុងធម៌ទាំងឡាយ មានសទ្ធាជាដើមនោះ" ។

(១៥៣) ការប្រណិបត្តិ ដោយគ្រឿងសក្ការៈ និងដោយការនមស្ការ ឈ្មោះថា ការទំនុកបំរុង ៗ ដោយហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងសព្រហ្មកសូត្រ និងសោណនន្ទជាតក ថា ÷

" ព្រោះហេតុនោះ បណ្ឌិតត្រូវតែនមស្ការ ធ្វើសក្ការៈ
មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ ទីដេក
គ្រឿងដុសលាង ទឹកងូតនិងទឹកលាងជើងទាំង ២"។

បណ្ដាបទទាំងនោះ បទ ថា "នមស្សេយ្យ" មានសេចក្ដីថា គប្បីធ្វើការនមស្ការ, អធិប្បាយថា គប្បីទៅកាន់បំរុង ក្នុងវេលាល្ងាច ក្នុងវេលាព្រឹកហើយ ធ្វើការនមស្ការ ដោយគិត ថា "មាតានិងបិតាទាំង គូនេះ ជាបុញ្ញក្ខេត្ត ដ៏ខ្ពង់ខ្ពស់ របស់យើង" ដូច្នេះ ៗ បទ ថា "សក្ករេយ្យាថ" បានដល់ គប្បីនមស្ការ ដោយសក្ការៈ ៗ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែងសក្ការៈនោះ ទើបត្រាស់ព្រះតម្រាស់ ថា "អន្នេន" ដូច្នេះជាដើម ៗ បណ្ដាបទទាំងនោះ បទ ថា "អន្នេន" គឺ ដោយយាគូ ភត្ត និងខាទនីយៈ ៗ បទ ថា "បានេន" គឺ ដោយទឹកបានៈ ៨ យ៉ាង ៗ បទ ថា "វត្ថេន" គឺ ដោយសំពត់សម្រាប់ស្លៀក-ដណ្ដប់ ៗ បទ ថា "សយនេន" គឺ ដោយគ្រែនិងកៅអី ៗ បទ ថា "ឧច្ឆាទនេន" គឺ ដោយការ

អប់ក្លិន គឺការកំចាត់ក្លិនស្អុយចេញហើយ ធ្វើឲ្យមានក្លិនក្រអូប ។

(១៥៤) ចំណែក ក្នុងដីកានៃវិសុទ្ធិមគ្គ លោកពោលថា “ការដុសខាត់ ឈ្មោះថា ការអប់ក្លិន” ។ បទថា “**នហាបនេន**” គឺ ដោយការស្រោចខ្លួនហើយ ឲ្យងូតដោយទឹកឧណ្ហ ក្នុងរដូវរងា ដោយទឹកត្រជាក់ ក្នុងរដូវក្ដៅ ។ បាទគាថាថា “**បាទានំ ធោវនេន ច**” គឺ ដោយការលាងជើង ដោយទឹកត្រជាក់និងទឹកក្ដៅឧណ្ហ និងដោយការលាបដោយប្រេង ។ គប្បីសង្គ្រោះការរឹតនួត និងការគក់ច្របាច់ ដែលព្រះដ៏មានព្រះភាគ មិនបានត្រាស់ក្នុងកន្លះគាថានេះ ដោយ ច ស័ព្ទ ។

ហេតុនោះ ក្នុងអដ្ឋកថាមាតាបិតុគុណសូត្រ លោកពោលថា “គប្បីធ្វើការបំរុង ដោយការរឹតនួតដៃ ដោយការគក់ច្របាច់ ពោលគឺការទាញទៅទាញមក នូវអវយវៈទាំងឡាយ មានដៃនិងជើងជាដើម ដើម្បីបំបាត់នូវការរយស្រពន់” ។

ចំណែក ក្នុងដីកាវិសុទ្ធិមគ្គ លោកពោលថា “ការគក់ច្របាច់ ឈ្មោះថា ការរឹតនួត” ។

(១៥៥) បណ្ដាគ្រហស្ថនិងបព្វជិតទាំងនោះ គ្រហស្ថគប្បីទំនុកបំរុងមាតាបិតា សូម្បីដោយការនមស្ការ, បព្វជិតគប្បីបំរុងដោយសក្ការៈតែម្យ៉ាង ។ មែនពិត សូម្បីភិក្ខុ ក៏គប្បីទំនុកបំរុង

មាតាបិតាផងដែរ, ព្រោះទោស ក្នុងការបំរុងនោះ មិនមានទេ ។

ដោយហេតុនោះ ក្នុងអដ្ឋកថាភេសជ្ជៈ ករណវត្ថុ ក្នុងតតិយ-បារាជិក លោកពោល ថា " ក៏បើភិក្ខុនាំមាតា ទៅកាន់វត្តហើយ ប្រណិបត្តិ, ភិក្ខុកុំចាប់ពាល់ គប្បីធ្វើបរិកម្ម គ្រប់យ៉ាង, គប្បីឲ្យគ្រឿងស៊ីចុកគ្រឿងបរិភោគ ដោយដៃខ្លួនឯង ។ ចំណែក បិតា ភិក្ខុគប្បីធ្វើកិច្ចទាំងឡាយ មានការឲ្យងូតទឹក និងការគក់ច្របាច់ ជាដើមហើយ ទំនុកបំរុង ដោយដៃខ្លួនឯង ដូចជាបំរុងសាមណេរយ៉ាងដូច្នោះឯង " ។

(១៥៦) ក៏ក្នុងអដ្ឋកថាភេសជ្ជៈ ករណវត្ថុនេះ ដើម្បីនឹងសំដែង ថា " ភិក្ខុសូម្បីចាបពាល់ ដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះសម្បែង ថា ' អ្នកនេះ ជាមាតារបស់អាត្មាអញ ' ត្រូវអាបត្តិទុក្កដ តែម្យ៉ាង " ដូច្នេះ លោកពោល ថា " **អនាមសន្តេន** " ។

ដោយហេតុនោះ ក្នុងអដ្ឋកថាកាយសំសគ្គសិក្ខាបទ លោកពោល ថា " បើភិក្ខុឃើញមាតា ត្រូវខ្សែទឹកកួចយកទៅ, ភិក្ខុមិនគួរចាប់មាតា ដោយដៃសោះឡើយ, គប្បីដាក់ទូក បន្ទះក្តារ គល់ចេក ឬក៏កំណាត់ឈើ ទៅខាងមុខ, កាលបើទូកជាដើមនោះមិនមាន, សូម្បីសំពត់កាសាវៈ ភិក្ខុក៏គប្បីបោះទៅដែរ, ក៏ប៉ុន្តែមិនត្រូវពោល ថា ' ចូរចាប់ ត្រង់សំពត់កាសាវៈនេះ ' ដូច្នេះឡើយ,

បើមាតាចាប់សំពត់កាសាវៈហើយ, គប្បីទាញមក ដោយធ្វើទុកក្នុងចិត្ត ថា ‘ អាត្មាអញចាប់បរិក្ខារ ’ ដូច្នេះ, ប្រសិនបើ មាតាភ័យ, គប្បីទៅខាងមុខ ៗ ហើយ ធ្វើឱ្យគាត់ស្រាលចិត្ត, បើមាតាត្រូវទឹកកួចយកទៅ ឡើងជិះក ឬចាប់ដៃបុត្រ ដោយប្រញាប់ប្រញាល់, ភិក្ខុមិនគួរលោស់ចេញ ដោយពោល ថា ‘ ម្នាលយាយចាស់ ចូរអ្នកគេចចេញទៅ ’ ដូច្នេះ, គប្បីជួយស្រង់ឱ្យបានដល់គោក, បើមាតាធ្លាក់ក្នុងភក់ ធ្លាក់ក្នុងអណ្តូង, ភិក្ខុគប្បីទំលាក់ខ្សែ ឬសំពត់ទៅក្នុងទីនោះ, បើមាតាចាប់ខ្សែ ឬសំពត់នោះហើយ, គប្បីយោងឡើងមកលើ, ប៉ុន្តែ ភិក្ខុមិនត្រូវប៉ះពាល់ឡើយ ” ៗ

(១៥៧) ភិក្ខុសូម្បីធ្វើភេសជ្ជៈ ដល់មាតាបិតាទាំងនោះ ក៏មិនឈ្មោះថាជាវេជ្ជកម្មឡើយ, សូម្បីក្នុងការឱ្យបិណ្ឌបាត ដែលភិក្ខុមិនទាន់បានចាប់ពាល់ជាដើម ក៏មិនមែនជាការធ្វើទាន ដែលគេគប្បីឱ្យដោយសទ្ធា ឱ្យធ្លាក់ចុះទៅឡើយ ៗ

ដោយហេតុនោះ ក្នុងអដ្ឋកថាភេសជ្ជករណវត្ថុ លោកពោលថា “ បើមាតាបិតា ជាឥស្សរជន មិនប្រាថ្នាការធ្វើតប, ភិក្ខុមិនធ្វើ (ការតបគុណ ) ក៏សមគួរ ៗ ប៉ុន្តែ បើមាតាបិតាទាំងនោះតាំងនៅ សូម្បីក្នុងរាជសម្បត្តិហើយ ប្រាថ្នាការធ្វើតប, ភិក្ខុមិនធ្វើ មិនសមគួរ ៗ បិណ្ឌបាតដែលភិក្ខុមិនទាន់ប៉ះពាល់ ភិក្ខុក៏គប្បីឱ្យ

ដល់មាតាបិតា, ទោះបីជាមានតម្លៃដល់មួយគហាបណៈ ក៏មិនមែនជាការញុំាងទាន ដែលគេគប្បីឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះឡើយ " ។

អនុដីកាវិមតិវិនោទនី ថា " ក្នុងពាក្យថា **អកាតុំ ន វដ្ដតិ** នេះ អាចារ្យពួកខ្លះ ពោលថា អាបត្តិទុក្កដ ។ គប្បីប្រកាន់យក ថា ' ក៏ការហាមដោយ **អ** អក្សរ ក្នុងពាក្យថា ' **អកាតុំ ន វដ្ដតិ** ' នេះ លោកប្រកប ដោយអំណាចភាវៈនៃកម្ម ដែលមិនគួរប៉ុណ្ណោះ, មិនមែនប្រកប ដោយអំណាចនៃអាបត្តិឡើយ " ។

ដីកាសារត្ថទីបនី ថា " បិណ្ឌបាតដែលភិក្ខុបានមកហើយ អំពីជនដែលមិនមែនជាបព្វជិត មានចុងគឺខ្លួន ឬភិក្ខុដទៃ មិនទាន់បានកាន់យកហើយ ឈ្មោះថា អនាមដ្ឋបិណ្ឌបាត " ។

(១៥៨) បាលីក្នុងចីវរក្ខន្ធកៈ ថា " ក៏សម័យនោះឯង ចីវរជាច្រើន កើតឡើងហើយ ដល់ភិក្ខុ ១ រូប ។ ក៏ភិក្ខុនោះ ជាអ្នកប្រាថ្នាចង់ឲ្យចីវរនោះ ដល់មាតាបិតា ។ ភិក្ខុទាំងឡាយ បានទៅក្រាបទូលរឿងនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទ្រង់អនុញ្ញាត ថា " ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឲ្យ ( វត្ថុជារបស់នៃខ្លួន ដល់មាតាបិតា ) ដោយគិត ថា ' មាតាបិតា ' ដូច្នេះឯង, តថាគត នឹងគប្បីពោលធ្វើអ្វី ?, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យ ( វត្ថុ

ជារបស់នៃខ្លួន ) ដល់មាតាបិតា, ម្នាលភិក្ខុទាំងឡាយ តែភិក្ខុមិនគួរធ្វើទានដែលគេឲ្យ ដោយសទ្ធាធ្លាក់ចុះឡើយ, ភិក្ខុរូបណាធ្វើសទ្ធាទេយ្យឲ្យធ្លាក់ចុះ, ភិក្ខុរូបនោះ ត្រូវអាបត្តិទុក្កដ "ដូច្នេះ ។

អដ្ឋកថាចីវរក្ខន្ធកៈនោះ ថា " គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា " **ន ច ភិក្ខវេ សទ្ធាទេយ្យំ** "នេះ, ភិក្ខុកាលឲ្យ ( វត្ថុជារបស់នៃខ្លួន ) ដល់ជនញាតិដ៏សេស (ក្រៅពីមាតាបិតា) នោះ ឈ្មោះថាធ្វើសទ្ធាទេយ្យៈឲ្យធ្លាក់ចុះពិត ៗ ឯមាតាបិតា ថាបើតាំងនៅក្នុងរាជសម្បត្តិហើយ ប្រាថ្នា (ការគបគុណ), ភិក្ខុគប្បីឲ្យ " ។

ន័យមកក្នុងអដ្ឋកថាកុលទូសកសិក្ខាបទ ថា " ក៏ភិក្ខុកាលឲ្យផ្លែឈើក្តី ផ្កាឈើក្តី ដែលជារបស់នៃខ្លួន ដល់មាតាបិតា នាំទៅឲ្យខ្លួនឯងក្តី ប្រើគេឲ្យនាំទៅឲ្យក្តី ហៅមកឲ្យខ្លួនឯងក្តី ប្រើគេឲ្យទៅហៅមកឲ្យក្តី ក៏សមគួរ, កាលនឹងឲ្យដល់ញាតិផ្សេងអំពីនោះឲ្យគេទៅហៅមកហើយឲ្យ ទើបគួរ ។ បណ្តាវត្ថុទាំងនោះ ភិក្ខុកាលនឹងឲ្យផ្កាឈើ ឲ្យដើម្បីបូជាព្រះរតនត្រ័យប៉ុណ្ណោះ ទើបគួរ ។ ប៉ុន្តែ ឲ្យសូម្បីដល់អ្នកណាមួយ ដើម្បីប្រយោជន៍ដល់ការប្រដាប់តាក់តែង ឬដើម្បីប្រយោជន៍ដល់ការបូជាវត្ថុ មានសិវលិង្គជាដើម មិនគួរឡើយ " ។

អនុដីកាវិមតិវិនោទនី ថា " ( ភិក្ខុ ) ឲ្យដល់មាតាបិតា ដោយ

គិត ថា 'មាតាបិតានឹងលក់នូវរបស់នេះ ចិញ្ចឹមជីវិត' ដូច្នេះ ក៏គួរ, តែ (ភិក្ខុ) ឲ្យរបស់ដល់ញាតិក្រៅពីនោះ ឲ្យជារបស់ខ្ចីប៉ុណ្ណោះ ទើបសមគួរ " ៗ

(១៥៩) ព្រោះហេតុនោះ សូម្បីភិក្ខុ ក៏គួរបំរុងមាតាបិតាទាំង ២ នោះ មែនពិត ដោយន័យដែលបានពោលមកហើយ ៗ សូម្បីក្នុងបាលី ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ដោយមិនខុសគ្នា ថា " **មាតាបិតុឧបដ្ឋាន** " ៗ

ប៉ុន្តែ ការបំរុងណា ដែលព្រះអដ្ឋកថាចារ្យទាំងឡាយពោលហើយ ដោយអំណាចគ្រហស្ថ ក្នុងទីបំផុត (នៃមង្គលត្ថទីបនី) ថា " បុត្រទាំងឡាយ មិនទាន់លះបង់ នូវភាពជាគ្រហស្ថ ដរាបណា, ដោះថ្លៃបំណុលចាស់ ដោយការបំរុងមាតាបិតា ដរាបនោះ " ៗ ការបំរុងនោះ គប្បីឃើញ ថា "លោកពោលហើយ ដើម្បីសំដែង ថា 'ធម្មតាការបំរុងមាតាបិតានោះ ជាវត្តរបស់គ្រហស្ថ' ដូច្នេះ, តែមិនគួរឃើញ ថា "លោកពោលហើយ ដើម្បីនឹងសំដែង ថា 'ការបំរុង (មាតាបិតា) គឺបព្វជិត មិនគប្បីធ្វើ' ដូច្នេះ សោះឡើយ " ៗ មួយទៀត គប្បីឃើញ ថា "ពាក្យនុ៎ះ លោកពោលហើយ ដើម្បីសំដែង ថា 'ធម្មតាបព្វជិត គប្បីជាអ្នកមិនមានបំណុល " ដូច្នេះ; ព្រោះហេតុនោះ មាតាបិតាទាំងឡាយ គឺបុត្រណាមួយ ក៏ដោយ

គប្បីបំរុងឲ្យបាន ។ ព្រោះថា បុត្រកាលប្រតិបត្តិខុស ក្នុងមាតាបិតា រមែងបានទុក្ខ ។ ក៏ក្នុងហេតុនេះ មានមិត្តវិន្ទកៈ ជាដើម ជាឧទាហរណ៍ ។

## ( រឿងមិត្តវិន្ទកៈ )

(១៦០) បានឮថា ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ បុត្រសេដ្ឋីអ្នកមានទ្រព្យ ៨០ កោដិ ក្នុងក្រុងពារាណសី ឈ្មោះថា មិត្តវិន្ទកៈ ជាអ្នកទ្រុស្តសីល មិនមានសទ្ធា ។ ឯមាតាបិតា របស់គេ ជាព្រះសោតាបន្ន ។ ក្នុងកាលក្រោយមក, កាលបើបិតាធ្វើមរណកាលហើយ, មិត្តវិន្ទកៈនោះ ពោល ថា " បពិត្រអ្នកម្ដាយ ខ្ញុំនឹងធ្វើនូវការជួញប្រែ តាមទូក " ។ មាតាពោល ថា " នែកូន កូនឯងជាកូនតូចតែមួយ (របស់ម្ដាយ) សូម្បីទ្រព្យសម្បត្តិ ក្នុងផ្ទះនេះ ក៏មានច្រើន, សមុទ្រ មានអន្តរាយ ក៏ច្រើនប្រការណាស់, ចូរកូនកុំទៅឡើយ " ។ មិត្តវិន្ទកៈ គិតនឹងទៅ តែម្យ៉ាង ពោល ថា " ម៉ែមិនអាចហាមឃាត់ខ្ញុំបានទេ " ដូច្នេះហើយ សូម្បីតែម្ដាយចាប់ត្រង់ដៃក៏រលាស់ដៃចេញហើយ វាយម្ដាយ ឲ្យដួលចុះ បានឱកាសហើយក៏ចេញទូកទៅកាន់សមុទ្រ ។ ក្នុងថ្ងៃទី ៧ នាវា ក៏បានឈប់នៅនឹងថ្កល់ ព្រោះអាស្រ័យមិត្តវិន្ទកៈ ។ ស្លាកដែលជនទាំងឡាយនាំគ្នាចាប់ ដោយគិត ថា "ក្នុងទូកនេះ នឹងមានមនុស្សកាឡកិណ្ណី "

ដូច្នេះ ក៏ធ្លាក់ទៅលើដៃនាយមិត្តវិន្ទុកៈនោះឯង អស់វារៈ ៣ ដង ។

គ្រានោះ មនុស្សទាំងឡាយ ក៏ឲ្យក្បូនដល់គេហើយ បានបោះគេចោលទៅ ក្នុងខ្ទង់នៃសមុទ្រ ។ នាយមិត្តវិន្ទុកៈនោះ អណ្តែតទៅតាមក្បូន ដល់កោះមួយ ដោយលំដាប់ បានឃើញនគរមួយមានទ្វារ ៤ លើកោះនោះ ។ បានឮថា ប្រទេសនោះ ឈ្មោះថា ឧស្សទនរក ជាទីកន្លែងដែលសត្វកើតក្នុងនរកជាច្រើន សោយកម្ម ។ តែនគរនុ៎ះ បានប្រាកដឡើង ដល់នាយមិត្តវិន្ទុកៈ ដូចជានគរ ដែលគេប្រដាប់តាក់តែងហើយ ដោយកម្លាំងនៃកម្ម គឺការវាយប្រហារដល់មាតា ។ នាយមិត្តវិន្ទុកៈនោះ គិត ថា "អាត្មាអញ នឹងបានជាស្តេច ក្នុងនគរនេះ" ដូច្នេះហើយ ទើបដើរចូលទៅ បានឃើញសត្វនរកមួយ មានកងចក្រដ៏មុត វិលលើក្បាល កំពុងស្រែកទ្ញញយំ ។

គ្រានោះ កងចក្រដ៏មុត លើក្បាលនៃសត្វនរកនោះ បានប្រាកដដល់មិត្តវិន្ទុកៈ ដូចជាផ្កាឈូក, គ្រឿងចំណង ៥ យ៉ាង ឮដ៏ទ្រូង (នៃសត្វនរក) បានប្រាកដដូចជាគ្រឿងប្រដាប់ទ្រូង, ឈាមដែលហូរចេញពីសរីរៈ (នៃសត្វនរក) បានប្រាកដ ដូចជាខ្លឹមច័ន្ទន៍សម្រាប់លាប, សំឡេងទ្ញញយំ (នៃសត្វនរក) បានប្រាកដ ដូចជាសំឡេងនៃដូរតន្ត្រី ។ នាយមិត្តវិន្ទុកៈនោះ ចូលទៅជិតសត្វនរកនោះហើយ ពោល ថា " ម្នាលបុរស ដ៏ចំរើន អ្នកបានសៀតផ្កាឈូក

យូរណាស់ហើយ, ចូរអ្នកឲ្យផ្កាឈូកនោះ ដល់ខ្ញុំមក”ៗ សត្វនរក ពោល ថា “សំឡាញ់អើយ នេះមិនមែនជាផ្កាឈូកទេ, នេះគឺជា កងចក្រដ៏មុតទេតើ”ៗ នាយមិត្តវិន្ទកៈ ពោល ថា “អ្នកពោល យ៉ាងនេះ ព្រោះជាអ្នកមិនប្រាថ្នាចង់ឲ្យដល់ខ្ញុំ”ៗ សត្វនរកគិត ថា កម្មរបស់អាត្មាអញ នឹងអស់ហើយ, ឯបុរសនេះ ក៏គប្បីជាអ្នកវាយ ប្រហារមាតា ដូចជាអញដែលហើយ បានជាមក, ព្រោះហេតុនោះ អញនឹងឲ្យកងចក្រដ៏មុត ដល់បុរសនោះ” ដូច្នេះហើយ ពោល ថា “ម្នាលអ្នកដ៏ចំរើន! សូមអ្នកអញ្ជើញមក, សូមអ្នកទទួលយក ផ្កាឈូកនេះចុះ”ដូច្នេះហើយ ក៏បានបោះកងចក្រដ៏មុតនោះ ទៅលើ ក្បាលនៃនាយមិត្តវិន្ទកៈនោះ ៗ កងចក្រនោះវិលទៅ ដូចជាកិន កំទេច នូវអំបែងក្បាល នៃនាយមិត្តវិន្ទកៈនោះ ៗ

ក្នុងខណៈនោះ នាយមិត្តវិន្ទកៈ ដឹងថារបស់នោះ ជាកងចក្រ ដ៏មុត ទើបពោល ថា “ចូរអ្នកទទួលយក នូវកងចក្រដ៏មុត របស់អ្នក វិញទៅ” ដូច្នេះហើយ ដល់នូវវេទនា ស្រែកទ្បូញយំហើយ ៗ សត្វនរកក្រៅនេះ ក៏អន្តរធានហើយ ៗ ឯនាយមិត្តវិន្ទកៈ សោយ ទុក្ខ ក្នុងឧស្សទនរកនោះ អស់កាលដ៏យូរ ដោយផលនៃអកុសលកម្ម គឺ ការឲ្យប្រហារដល់មាតា, កាលបើផលនៃកម្ម អស់ហើយ, ទើបទម្លាក់កងចក្រដ៏មុតចោលហើយ ទៅតាមយថាកម្ម ដូច្នេះ ៗ

រឿងមិត្តវិន្ទុកៈ មកក្នុងអដ្ឋកថាចតុទ្វារជាតក ក្នុងទសកនិបាត ។

## ( រឿងព្រះមហាមោគ្គល្លានត្ថេរ )

(១៦១) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី ជឿងពាក្យ របស់ភរិយាហើយ ប្រាថ្នាចង់សម្លាប់មាតាបិតា របស់ខ្លួន នាំមាតាបិតាទាំង ២ នោះ ទៅដោយយានតូច ក្នុងពេលទៅដល់ពាក់កណ្តាលព្រៃ ទើបពោល ថា " ពួកចោរ នៅក្នុងទីនេះ, ខ្ញុំនឹងចុះដើរទៅ " ដូច្នេះហើយ បានដាក់ខ្សែនឹងដៃបិតា ចុះដើរទៅ ធ្វើអាការៈ ដូចជាពួកចោរស្ទុះក្រោកឡើងហើយ ក៏បានវាយមាតាបិតា ។ មាតាបិតាទាំង ២ នោះ ប្រាសចាកការឃើញរូប ព្រោះជាអ្នកមានភ្នែកខ្វាក់ ចាំកូនមិនបាន ទើបស្រែកទួញយំ ដើម្បីប្រយោជន៍ ដល់កូននោះ តែម្យ៉ាង ថា " នែកូន ពួកចោរឯណោះ កំពុងតែចង់សម្លាប់យើងទាំង ២ នាក់, ចូរកូន គេចចេញទៅ " ។ កូននោះគិត ថា " មាតាបិតាទាំង ២ នេះ ត្រូវអញវាយ ក៏នៅតែស្រែកយំ ដើម្បីប្រយោជន៍ ដល់អញតែម្យ៉ាង, អញធ្វើកម្មមិនសមគួរហើយតើ " ដូច្នេះហើយ បានធ្វើឲ្យមាតាបិតាទាំង ២ នោះ សប្បាយចិត្ត ច្របាច់ដៃជើងហើយពោល ថា " បពិត្រលោកឪពុក និងអ្នកម្តាយ ពួកចោរ រត់ទៅអស់ហើយ " ហើយក៏នាំត្រឡប់

មកផ្ទះរបស់ខ្លួននុ៎ះឯង វិញទៀត ។ បុរសនោះ ឆេះនៅក្នុងនរក អស់កាលដ៏យូរ ព្រោះកម្មនោះ ដោយការសេសសល់នៃវិបាក ត្រូវចោរវាយកំទេច ឲ្យល្អិត ដល់នូវសេចក្ដីស្លាប់ អស់ ១០០ អត្តភាព ក្នុងអត្តភាពទីបំផុត ក៏បានមកកើតជាព្រះមហាមោគ្គល្លានៈ ត្រូវពួកចោរវាយប្រហារ ដោយកម្លាំងនៃកម្មនោះឯង និព្វានហើយ ។

រឿង ព្រះមហាមោគ្គល្លានៈ មកក្នុងអដ្ឋកថាសរភង្គជាតក ។

(១៦២) ចំណែក ការប្រតិបត្តិនោះ របស់បុត្រនោះ ជាអ្នកប្រតិបត្តិត្រូវ ដោយការប្រតិបត្តិ តាមដែលបានពោលមកហើយ ក្នុងមាតានិងបិតាទាំង ២ នោះ ជាការប្រតិបត្តិនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២, ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ក្នុងសព្រហ្មកសូត្រ និង សោណនន្ទជាតក ថា ÷

“ ព្រោះការប្រតិបត្តិ ក្នុងមាតាបិតា នោះឯង បណ្ឌិតទាំងឡាយ តែងសរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង, គេស្លាប់ទៅហើយ រមែងរីករាយនៅក្នុងស្ថានសួគ៌ ” ។

លោកពោលហើយ ក្នុងដីកាតិកនិបាត អង្គុត្តរនិកាយ ថា “ បណ្ដាបទទាំងនោះ បទ ថា ‘ តាយ នំ ’ គ្រាន់តែជានិបាត ។

អធិប្បាយថា ព្រោះការប្រតិបត្តិ ក្នុងមាតាបិតានោះ គឺព្រោះការប្រតិបត្តិជាហេតុ ។ ២ បទ ថា "នំ បសំសន្តិ" មានសេចក្តីថា មនុស្សទាំងឡាយ ជាបណ្ឌិត តែងសរសើរបុគ្គលនោះ គឺអ្នកបំរុងមាតាបិតា ក្នុងលោកនេះ ដោយន័យជាអាទិ៍យ៉ាងនេះ ថា "បុគ្គលនេះ ជាអ្នកឧបត្ថម្ភមាតា ជាអ្នកឧបត្ថម្ភបិតា រមែងបំពេញនូវការប្រតិបត្តិ ដែលញុំាងសត្វឲ្យប្រព្រឹត្តទៅ ក្នុងស្ថានសួគ៌" ។

បទ ថា "បេច្ច" មានសេចក្តីថា បុគ្គលអ្នកបំរុងមាតានិងបិតានោះ ទៅកាន់បរលោកហើយ ស្ថិតនៅក្នុងស្ថានសួគ៌ រមែងរីករាយសប្បាយ តាំងតែពីដើមមក រមែងប្រមោទ្ធ ត្រេកអរដោយប្រការផ្សេង ៗ ដោយសម្បត្តិទិព្វទាំងឡាយ ។

(១៦៣) ក៏ឈ្មោះថា អ្នកដែលបំរុងមាតាបិតា សូម្បីតែព្រះសាស្តា ក៏ទ្រង់ត្រាស់សរសើរហើយដែរ ។

ក្នុងសេចក្តីនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

## ( រឿងភិក្ខុអ្នកចិញ្ចឹមមាតាបិតា )

បានឮថា សេដ្ឋីបុត្រម្នាក់ ក្នុងក្រុងសាវត្ថី បានស្តាប់នូវព្រះធម៌ទេសនា របស់ព្រះសាស្តាហើយ ក៏បានបព្វជាឧបសម្បទ រៀនធម៌ អស់រយៈវេលា ៥ វស្សាហើយ រៀនកម្មដ្ឋាន ក្នុងសំណាក់

នៃព្រះឧបជ្ឈាយ៍ហើយ ចេញអំពីវត្តជេតពន ទៅកាន់បច្ចន្តគ្រាម អាស្រ័យស្រុកនោះហើយនៅក្នុងព្រៃ ។ ឯមាតាបិតារបស់ភិក្ខុនោះ ចាប់ដើមពីកាលដែលភិក្ខុនោះបួសហើយ ក៏អស់ទ្រព្យសម្បត្តិទៅជាលំដាប់ ដល់ភាពជាអ្នកគួរអាណិតអាសូរក្រៃលែង ដែកាន់ភាជន៍ដើរសុំទានគេ នៅអាស្រ័យសំយាបផ្ទះអ្នកដទៃ ។

ក៏ក្នុងកាលជាខាងក្រោយមក ភិក្ខុរូបនោះ បានឮថា មាតានិងបិតា របស់ខ្លួន ដល់នូវសេចក្ដីទុក្ខ ក៏គិត ថា "អាត្មាអញ សូម្បីព្យាយាមនៅក្នុងព្រៃ អស់រយៈពេល ១២ វស្សា ក៏មិនអាចបានសម្រេចមគ្គផលឡើយ, អាត្មាអញជាមនុស្សអភ័ព្វ, អាត្មាអញនឹងត្រូវការអ្វីទៀត ដោយបព្វជា, អាត្មាអញនឹងទៅជាគ្រហស្ថហើយ ចិញ្ចឹមមាតាបិតា និងឲ្យទាន ក៏នឹងជាអ្នកមានស្ថានសួគ៌នៅខាងមុខ" ដូច្នេះហើយ ចេញពីព្រៃ ទៅដល់ក្រុងសាវត្ថី ដោយលំដាប់ហើយគិត ថា "ថ្ងៃនេះ អាត្មាអញនឹង គាល់ព្រះសាស្ដាហើយ ស្ដាប់ព្រះធម៌ ស្អែកឡើង ព្រលឹមស្រាង នឹងទៅជួបមាតានិងបិតា" ហើយ ក៏ចូលទៅកាន់វត្តជេតពន ។

ក៏ក្នុងថ្ងៃនោះ ព្រះសាស្ដាទ្រង់ប្រមើលមើល សត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ទតព្រះនេត្រឃើញ នូវឧបនិស្ស័យនៃបឋមមគ្គនៃភិក្ខុនោះហើយ, កាលបើភិក្ខុនោះ និមន្តមកគង់ហើយ, ទើប

ត្រាស់ពណ៌នាគុណរបស់មាតាបិតា ដោយមាតាបិតុបោសកសូត្រ ។ ភិក្ខុនោះ បានស្តាប់ព្រះធម៌ទេសនានោះហើយ គិត ថា “ អាត្មាអញ មកហើយ ដោយតាំងចិត្ត ថា ‘ អាត្មាអញ នឹងជាគ្រហស្ថហើយ ចិញ្ចឹមមាតាបិតា ’ ប៉ុន្តែ ព្រះសាស្តាទ្រង់ត្រាស់ ថា ‘ បុគ្គលដែលជាបព្វជិត ក៏ឈ្មោះថា ជាអ្នកធ្វើឧបការគុណ ដល់មាតាបិតា បានដូចគ្នាដែរ ’ ដូច្នេះ, ប្រសិនបើ អាត្មាអញ មិនបានមកគាល់ព្រះសាស្តាហើយទៅ ក៏គប្បីសាបសូន្យចាកបព្វជ្ជានេះ, តែឥឡូវនេះ អាត្មាអញ នឹងនៅជាបព្វជិត ចិញ្ចឹមមាតាបិតាទាំង ២ នោះ ” ។

ស្អែកឡើង ភិក្ខុនោះ ទទួលស្លាកយាគូ និងស្លាកភត្ត ដែលដល់ខ្លួនហើយ និមន្តទៅផ្ទះ បានចាប់យកនូវយាគូនិងភត្ត ឲ្យដល់មាតាបិតា ឯខ្លួនឯងនិមន្តបិណ្ឌបាត ធ្វើភត្តកិច្ចហើយ ធ្វើទីលំនៅសម្រាប់មាតាបិតានោះ តាំងពីពេលនោះមក ក៏ប្រណិបត្តិ (មាតានិងបិតាទាំង ២ នោះ ) ជាប់ជានិច្ច ៗ ក៏ភិក្ខុនោះ ឲ្យបក្ខិកភត្តជាដើម ដែលខ្លួនបានមកហើយ ដល់មាតាបិតាទាំង ២ នោះ ហើយខ្លួនឯងក៏ដើររកបិណ្ឌបាត កាលបើបាន ក៏ឆាន់ កាលបើមិនបានក៏មិនឆាន់ ៗ ក៏ថ្ងៃដែលបានភិក្ខា របស់ភិក្ខុនោះ មានតិច, ឯថ្ងៃដែលមិនបានភិក្ខានោះ មានច្រើនជាង ៗ ភិក្ខុនោះ បានសំពត់ចំណាំវស្សាក្តី សំពត់ណាមួយដទៃក្តី ក៏ឲ្យដល់មាតាបិតាទាំងនោះ

នុ៎ះឯង ធ្វើការប៉ះកំណាត់សំពត់ចាស់ ៗ ដែលមាតាបិតាប្រើប្រាស់ហើយ ជ្រលក់ប្រើប្រាស់ ដោយខ្លួនឯង ។ ភិក្ខុនោះ ត្រូវសេចក្តីកង្វល់ព្រោះការប្រតិបត្តិមាតាបិតា គ្របសង្កត់ យ៉ាងដូច្នោះ ហើយកើតស្គាំងស្គម មានសម្បុរសៅហ្មង ។

ពួកភិក្ខុទាំងឡាយ ឃើញភិក្ខុនោះហើយ ក៏សួរបានស្តាប់នូវសេចក្តីនោះ ក៏តិះដៀលហើយ ក្រាបទូលដល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅភិក្ខុនោះមក សូម្បីតែទ្រង់ជ្រាប ក៏ទ្រង់ញ៉ាំងភិក្ខុនោះឲ្យក្រាបទូល នូវសេចក្តីនោះ ទ្រង់ប្រទាននូវសាធុការ ទ្រង់មានព្រះបំណងនឹងប្រកាស នូវបុព្វចរិយា របស់ព្រះអង្គ ទើបទ្រង់ត្រាស់សួរ ថា "ម្នាលភិក្ខុ អ្នកចិញ្ចឹមជនទាំងឡាយណានោះ, តើជនទាំងឡាយនោះ ត្រូវជាអ្វី ដល់អ្នក ? " ។ ភិក្ខុនោះ ក្រាបទូល ថា "បពិត្រព្រះអង្គដ៏ចំរើន ជនទាំងនោះ ត្រូវជាមាតាបិតារបស់ខ្ញុំព្រះករុណា " ។

គ្រានោះ ព្រះសាស្តាទ្រង់ប្រទាន នូវសាធុការ ៣ ដង ដល់ភិក្ខុនោះ ថា "សាធុ ៗ" ដូច្នេះហើយ ទើបទ្រង់ត្រាស់ ថា "អ្នកបានស្ថិតនៅក្នុងមាគ៌ា ដែលតថាគតបានប្រព្រឹត្តហើយ, សូម្បីតថាគតកាលប្រព្រឹត្តនូវបុព្វចរិយា ក៏បានចិញ្ចឹមមាតាបិតាហើយ " ដូច្នេះហើយ ទ្រង់ត្រាស់នូវសុវណ្ណសាមជាតក ក្នុងមហានិបាតហើយ ទ្រង់

ត្រាស់ ថា “ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា កិរិយាចិញ្ចឹម មាតាបិតា ជាប្រពៃណីនៃពួកបណ្ឌិត” ហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ។ នៅក្នុងទីបញ្ចប់នៃសច្ចៈ ភិក្ខុនោះ បានជាព្រះសោតាបន្ន ។

(១៦៤) បណ្ឌិតគប្បីពោល ក្នុងទីទាំងពួង ថា “សូម្បីភិក្ខុដទៃទៀត ក៏ប្រណិបត្តិ មាតាបិតា យ៉ាងដូច្នោះដែរ” ។ សូម្បីព្រះសាស្ដា ក៏ទ្រង់ប្រទានសាធុការ ដល់ភិក្ខុនោះ ទ្រង់ត្រាស់នូវសុតនជាតក ក្នុងសត្តកនិបាតហើយ ទ្រង់ប្រកាសសច្ចៈ ទាំងឡាយ ។ ក្នុងទីបញ្ចប់នៃសច្ចៈ ឯភិក្ខុនោះបានជាព្រះសោតាបន្ន ។ ព្រះសាស្ដាទ្រង់ប្រទាន នូវសាធុការ សូម្បីដល់ភិក្ខុមួយរូបទៀតហើយ ទ្រង់ត្រាស់ ថា “ម្នាលភិក្ខុ អ្នកបានរក្សានូវប្រពៃណីនៃបូរាណកបណ្ឌិតហើយ, ព្រោះថា បោរាណកបណ្ឌិតទាំងឡាយ សូម្បីកើតហើយក្នុងកំណើតនៃសត្វតិរច្ឆាន ក៏បានឲ្យជីវិត ដល់មាតាបិតា” ដូច្នេះហើយ ទ្រង់ត្រាស់នូវនន្ទិយមិគជាតក ក្នុងឆក្កនិបាត ។ ព្រះអង្គទ្រង់ប្រទានសាធុការ ដល់ភិក្ខុមួយរូបទៀតហើយ ត្រាស់គិជ្ឈជាតកក្នុងសត្តកនិបាត ។ ទ្រង់ប្រទានសាធុការ ដល់ភិក្ខុមួយរូបទៀតហើយត្រាស់ ថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំនាំគ្នាលើកទោស ភិក្ខុនេះឡើយ, សូម្បីបោរាណកបណ្ឌិតទាំងឡាយ ក៏បានធ្វើហើយ នូវឧបការៈ សូម្បីដល់ពួកជន ដែលមិនមែនជាញាតិ

ដោយអំណាចនៃគុណ, ក៏ការធ្វើឧបការៈដល់មាតាបិតាទាំងឡាយ ជាភារៈកិច្ច របស់ភិក្ខុនេះ ” ដូច្នេះហើយ ទ្រង់ត្រាស់គិជ្ឈជាតក ក្នុងទុកនិបាត ។ ទ្រង់ប្រទាននូវសាធុការ ដល់ភិក្ខុមួយរូបទៀត ហើយត្រាស់ ថា “ ម្នាលភិក្ខុ បោរាណកបណ្ឌិតទាំងឡាយ ជាសត្វតិរច្ឆាន ឲ្យមាតាបិតាដែលចាស់ជរាដេក នៅក្នុងសំបុកហើយ ពាំចំណីអាហារ ដោយចុងចំពុស មកចិញ្ចឹម ” ដូច្នេះហើយ ត្រាស់នូវកេទារជាតក ក្នុងបកិណ្ណកនិបាត ។ ទ្រង់ប្រទានសាធុការ ដល់ភិក្ខុមួយរូបទៀត ហើយត្រាស់ ថា “ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំនាំគ្នាលើកទោស ភិក្ខុនេះឡើយ, (ព្រោះថា) បោរាណកបណ្ឌិតទាំងឡាយ ជាសត្វតិរច្ឆាន ព្រាត់ប្រាស់ចាកមាតាហើយ ស្គាំងស្គម ព្រោះអត់អាហារ ៧ ថ្ងៃ សូម្បីបានភោជនៈ ដែលគួរដល់ព្រះរាជាហើយ ក៏គិត ថា ‘ យើងទាំងឡាយ វៀរចាកមាតា នឹងមិនព្រមបរិភោគ ’ ឃើញមាតាប៉ុណ្ណោះ ទើបទទួលយកចំណី ” ដូច្នេះហើយ ត្រាស់នូវមាតុបោសកជាតក ក្នុងឯកាទសកនិបាតហើយ ទ្រង់ប្រកាស នូវសច្ចៈទាំងឡាយ ។ ក្នុងទីបញ្ចប់នៃសច្ចៈ ពួកភិក្ខុទាំង ៥ រូបនោះ ក៏បានជាព្រះសោតាបន្ន ។ បុគ្គលអ្នកទំនុកបំរុងមាតាបិតា ជាអ្នកសូម្បីតែព្រះសាស្តា ក៏ទ្រង់ត្រាស់សរសើរហើយដែរ រមែងសម្រេចប្រយោជន៍របស់ខ្លួន ដោយប្រការៈដូច្នេះឯង ។

(១៦៥) ក៏ឈ្មោះថា បុគ្គលអ្នកបំរុងមាតាបិតា សូម្បីត្រូវគេបាញ់ហើយ ដោយកូនសរ ដែលត្រាំដោយថ្នាំពិស រមែងរួចផុតអំពីមរណទុក្ខទៅបាន ដូចជាព្រះសុវណ្ណសាមពោធិសត្វ, សូម្បីទៅដល់សំណាក់ នៃយក្សហើយ រមែងរួចផុត (អំពីមរណទុក្ខ) បាន ដូចជាព្រះពោធិសត្វ ជាទុគ៌តបុរស ឈ្មោះសុតនៈ, សូម្បីស្ថិតនៅក្នុងស្ថានទីដែលគេរក្សាហើយ ក៏រមែងរួចផុត (អំពីមរណទុក្ខ) ទៅបាន ដូចជាម្រឹគឈ្មោះនន្ទិយៈពោធិសត្វ, សូម្បីជាប់ នៅក្នុងអន្ទាក់ហើយ ក៏រមែងរួចផុត (អំពីមរណទុក្ខ) ទៅបាន ដូចជាស្តេចក្ងាតពោធិសត្វ និង ស្តេចសេកពោធិសត្វ, សូម្បីត្រូវគេចងដោយចំណងហើយ ក៏រមែងរួចផុត (អំពីមរណទុក្ខ) ទៅបាន ដូចជាស្តេចដំរីពោធិសត្វ យ៉ាងដូច្នោះ ។

ក្នុងសេចក្តីនោះ មានរឿងទាំងនេះ (ឧទាហរណ៍) ។

## (រឿងតាបសឈ្មោះសុវណ្ណសាម)

ក្នុងអតីតកាល ព្រះពោធិសត្វជាតាបស ឈ្មោះសុវណ្ណសាម នៅក្នុងអាស្រម ដែលសក្កទេវរាជទ្រង់ប្រទានឲ្យ ក្បែរឆ្នេរមាត់ស្ទឹងឈ្មោះមិគសម្មតា ក្នុងក្រុងពារាណសី ប្រណិបត្តិបម្រើ នូវមាតានិងបិតា របស់ខ្លួន ដែលខ្វាក់ភ្នែក ដោយសេចក្តីគោរព ។

ក្នុងកាលនោះ ព្រះរាជាព្រះនាមបិលយក្ស ក្នុងក្រុងពារាណសី ទ្រង់ប្រគល់រាជសម្បត្តិ ថ្វាយព្រះមាតា ដោយសេចក្ដីលោភក្នុងសាច់ម្រឹគ ស្ដេចតែមួយព្រះអង្គយាងទៅ កាន់ព្រៃហេមពាន្ត ទ្រង់សម្លាប់សត្វម្រឹគទាំងឡាយហើយ ស្ដេចសោយសាច់ យាងទៅដល់ស្ថានទីនោះ ទ្រង់ទតព្រះនេត្រឃើញគន្លងស្នាមជើងម្រឹគ ត្រង់កំពង់សម្រាប់ដងទឹកផឹក របស់សាមតាបស ទ្រង់ធ្វើស៊ុម ដោយមែកឈើហើយ ទ្រង់ពួនសម្ងំ ទ្រង់ទតព្រះនេត្រឃើញ នូវសាមតាបស ដែលពួកម្រឹគចោមរោម កំពុងតែដើរមកដួតទឹកហើយ ត្រឡប់ទៅវិញក្នុងវេលាល្ងាចហើយ ទើបទ្រង់បាញ់ទៅ ដោយកូនសរ ដែលត្រាំដោយថ្នាំពិស ។ ព្រះពោធិសត្វ ដួលដេកនៅ សំឡឹងរកអ្នកដែលធ្វើខុស បានពោលវាចាដែលគួរឲ្យអាណិតអាសូរ ។

ព្រះរាជាទ្រង់ស្ដាប់វាចានោះហើយ ទ្រង់ព្រះតម្រិះ ថា “អ្នកនេះ សូម្បីត្រូវអញបាញ់ឲ្យដួលហើយ ក៏មិនជេរ មិនប្រទេចអញដែរ, ត្រឡប់ទៅជាហៅរក ដោយវាចាគួរជាទីស្រឡាញ់វិញ” ដូច្នេះហើយ ស្ដេចយាងទៅកាន់សំណាក់ របស់សាមតាបសនោះ ទ្រង់ទតព្រះនេត្រឃើញសាមតាបសនោះ ដល់នូវសេចក្ដីទុក្ខហើយ ទ្រង់ព្រះកន្សែង ដោយព្រះអង្គឯង ។

ក្នុងកាលនោះ នាងទេពធីតាដែលនៅប្រចាំក្នុងភ្នំគន្ធមាទន៍

ឈ្មោះវសុន្ធរី ធ្លាប់កើតជាមាតា នៃព្រះមហាសត្វ ក្នុងអត្តភាពទី ៧ ដឹងហេតុនោះ ហើយគិត ថា "បើសិន អញនឹងមិនទៅ ក្នុងទីនោះទេ, សាមៈ បុត្ររបស់អញ នឹងស្លាប់, កាលបើសាមៈនោះ ស្លាប់ហើយ, មាតាបិតា របស់សាមៈ នឹងអត់អាហារ ស្ងាំងស្គមស្លាប់, ឯព្រះរាជាសោត ក៏នឹងទ្រង់បែកព្រះហឫទ័យ ទិវង្គត, ប៉ុន្តែ កាលបើអញទៅហើយ, ព្រះរាជានឹងទ្រង់យាងទៅអាស្រមហើយ ទ្រង់នាំមាតាបិតារបស់សាមៈមក, មាតាបិតារបស់សាមៈនោះ មកហើយ នឹងធ្វើនូវសច្ចកិរិយា, សូម្បីអញ ក៏នឹងធ្វើ; បុត្ររបស់អញ នឹងបានជីវិត ដោយប្រការដូច្នេះ, ចំណែក មាតាបិតា របស់សាមៈនោះ ក៏នឹងត្រឡប់បានចក្ខុវិញ, ឯព្រះរាជាសោត នឹងទ្រង់ស្តាប់ព្រះធម៌ទេសនា របស់សាមៈហើយ ស្តេចយាងទៅព្រះនគរ ទ្រង់បំពេញព្រះរាជកុសលទាំងឡាយ មានទានជាដើមហើយ ទ្រង់គ្រងរាជ្យសម្បត្តិ ដោយធម៌ ស្តេចនឹងទៅកើត ក្នុងស្ថានសួគ៌" ដូច្នេះហើយ ទៅក្នុងទីនោះ មានកាយមិនប្រាកដ ស្ថិតនៅ ឰដ៏អាកាសពោល ថា "បពិត្រព្រះមហារាជ សូមព្រះអង្គចិញ្ចឹមមាតាបិតារបស់សាមៈ ទាំង ២ ដែលខ្វាក់ភ្នែកនោះ ឲ្យដូចជាសាមៈចិញ្ចឹមចុះ, ទ្រង់ធ្វើយ៉ាងដូច្នេះ, ព្រះអង្គនឹងទ្រង់យាងទៅសុគតិ" ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ស្តេចយាងទៅ

កាន់អាស្រម ដើម្បីបំរុងមាតាបិតា របស់សាមៈនោះ ទ្រង់ត្រាស់ប្រាប់រឿងរ៉ាវទាំងអស់នោះ, កាលបើមាតាបិតា របស់សាមៈនោះក្រាបទូល ថា "បពិត្រព្រះមហារាជ បើដូច្នោះ សូមព្រះអង្គស្ដេចទ្រង់នាំទូលព្រះបង្គំទាំងឡាយ ទៅក្នុងទីនោះផងចុះ" ដូច្នេះហើយ, ទ្រង់បានធ្វើហើយ យ៉ាងដូច្នោះ ៗ មាតាបិតា របស់សាមៈនោះមកហើយ បានធ្វើសច្ចកិរិយា ដោយ ៧ គាថា មានជាអាទិ៍ ថា ÷

(១៦៦) " ក្នុងកាលមុន សាមៈជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា, សូមឲ្យពិសរបស់សាមៈសាបរលាបទៅ, ដោយការពោលសច្ចៈនុ៎ះ " ។

បណ្ដាបទទាំងនោះ បទ ថា " **សច្ចេន** " បានដល់ ដោយសភាពដែលពិត ៗ បទ ថា " **ធម្មចារី** " បានដល់ អ្នកមានប្រក្រតីប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ យ៉ាង ៗ

សាមតាបស ដេកប្រែខ្លួនហើយ ៗ គ្រានោះ សុម្ពីនាងទេពធីតា បានធ្វើសច្ចកិរិយា ដោយ ២ គាថានេះ មានជាអាទិ៍ ថា ÷

" ខ្ញុំនៅអាស្រ័យ លើភ្នំគន្ធមាទន៍ អស់កាលជាយូរហើយ, ឥតមាននរណាដទៃ ដែលជាទីស្រឡាញ់ដោយវិសេស របស់ខ្ញុំជាងសាមៈទេ, ដោយការ

ពោលសច្ចៈនុ៎ះ សូមឲ្យពិសរបស់សាមៈ សាបរលាប ទៅ, នៅភ្នំគន្ធមាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប, ដោយការពោលសច្ចៈនេះ សូមឲ្យពិស របស់សាមៈ សាបរលាបអស់ទៅ " ។

ក្នុងពេលចប់សច្ចកិរិយា របស់នាងទេវធីតានោះ សាមៈជាអ្នកមិនមានរោគ ក្រោកឡើងហើយ ។ សេចក្តីអស្ចារ្យទាំងពួងគឺ " ភាពជាអ្នកមិនមានរោគ ១ ការត្រឡប់បានចក្ខុ នៃមាតានិងបិតា (របស់សាមៈ) ១ អរុណរះឡើង ១ ភាពនៃជនទាំង ៤ នោះ ប្រាកដ ក្នុងអាស្រម ដោយអានុភាពនៃទេវតា ១ បានមានហើយ ក្នុងខណៈជាមួយគ្នានុ៎ះឯង ។

លំដាប់នោះ ព្រះពោធិសត្វ កាលសំដែងធម៌ ដល់ព្រះរាជា បានពោលគាថាទាំងឡាយ ២ ថា ÷

(១៦៧) " សត្វណា តែងចិញ្ចឹមនូវមាតានិងបិតា ដោយធម៌, សូម្បីទេវតាទាំងឡាយ តែងរក្សានូវនរជន អ្នកចិញ្ចឹមមាតានិងបិតានោះ, សត្វណា តែងចិញ្ចឹម នូវមាតានិងបិតា ដោយធម៌, បណ្ឌិតទាំងឡាយ ក្នុងលោកនេះឯង តែងសរសើរ

នូវនរជននោះ, នរជននោះ លុះលះបង់លោកនេះ
ទៅ រមែងរីករាយសប្បាយ ក្នុងឋានសួគ៌ ” ។

ក៏ ព្រះពោធិសត្វ លុះពោល យ៉ាងនេះរួចហើយ ទើបពោលបន្តទៀត ថា “បពិត្រព្រះមហារាជ បើសិនជាព្រះអង្គទ្រង់ប្រាថ្នាដើម្បីនឹងទ្រង់ស្តេចយាងទៅ កាន់ទេវលោក សោយទិព្វសម្បត្តិដ៏ច្រើន ក្នុងទេវលោកនោះ, សូមព្រះអង្គទ្រង់ប្រព្រឹត្ត ក្នុងការប្រព្រឹត្តិធម៌ទាំង ១០ នេះ ” ដូច្នេះហើយ កាលនឹងសំដែង ទើបបានពោលគាថាដែលពណ៌នា រាជធម្មចរិយា ១០ ប្រការ ថា ÷

(១៦៨) “ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គ
ប្រព្រឹត្តធម៌ ចំពោះមាតានិងបិតា, បពិត្រព្រះរាជា
លុះព្រះអង្គ បានប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ
ព្រះអង្គនឹងទៅកាន់ឋានសួគ៌ ។

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គ
ប្រព្រឹត្តធម៌ ចំពោះបុត្រ និងភរិយាទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គ
ប្រព្រឹត្តធម៌ ចំពោះមិត្រនិងអាមាត្យទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះសត្វពាហនៈនិងពលទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះស្រុក និង និគម ទាំងឡាយ. . .

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈនិងព្រាហ្មណ៍ទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគ និងបក្សីទាំងឡាយ...

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌, (ព្រោះ) ធម៌ដែលព្រះអង្គទ្រង់បានប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកប្រគល់ឲ្យ, បពិត្រព្រះរាជា លុះព្រះអង្គទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។

បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌, (ព្រោះ) ទេវតា ឥន្ទ្រ ព្រហ្ម ដែលបានទៅដល់ឋានសួគ៌ ក៏ព្រោះធម៌ដែលខ្លួនបានប្រព្រឹត្ត

ល្អហើយ, បពិត្រព្រះរាជា សូមព្រះអង្គ កុំប្រហែស
ធ្វេស នឹងធម៌ឡើយ " ។

(១៦៩) លោកបានពណ៌នាសេចក្តី នៃគាថាទាំងនុ៎ះ ក្នុង
អដ្ឋកថាសកុណជាតក ក្នុងចត្តាឡីសនិបាត យ៉ាងនេះ ថា ÷

"បណ្តាគាថាទាំងនោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទី ១ ។
បទ ថា " ធម្មំ " បានដល់ ធម៌គឺការបំរុងមាតាបិតា ។ ព្រះរាជា
កាលទ្រង់តើនឡើង តាំងពីព្រលឹម ទ្រង់ធ្វើការបរិហារ ព្រះសរីរៈ
គ្រប់យ៉ាង មានការថ្វាយទឹកខ្ពុលព្រះឱស្ឋ និងឈើជម្រះព្រះទន្តជា
ដើម ដល់ព្រះមាតាបិតា ឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះមាតា
និងបិតាទាំងនោះ ។

ចំណែក ក្នុងព្រះរាជឱរស និងព្រះជយា កាលទ្រង់ហាមព្រះ
រាជបុត្រនិងព្រះធីតា ចាកសេចក្តីអាក្រក់ហើយ ឲ្យតាំងនៅ ក្នុង
សេចក្តីល្អ ឲ្យសិក្សាសិល្បៈ ទ្រង់ធ្វើអាវាហៈវិវាហមង្គល ដោយ
អំណាចត្រកូលដែលសមគួរ ក្នុងពេលដែលព្រះរាជបុត្រាបុត្រី ទ្រង់
ចំរើនវ័យហើយ និងទ្រង់ព្រះរាជទាន នូវព្រះរាជទ្រព្យ ក្នុងសម័យ
ឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះរាជឱរសទាំងឡាយ ។ កាល
ទ្រង់លើកតម្កើង មិនទ្រង់មើលងាយ មិនទ្រង់ប្រព្រឹត្តក្បត់ ព្រះ

ទ័យព្រះជយា ព្រះរាជទានភាពជាធំ ទ្រង់តាមព្រះរាជទានគ្រឿងអលង្ការ ឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះជយាទាំងឡាយ ។

ក៏កាលទ្រង់សង្គ្រោះ នូវមិត្រអាមាត្យទាំងឡាយ ដោយសង្គហវត្ថុ ៤ យ៉ាង មិនទ្រង់ត្រាស់ឲ្យខុសផ្លាត ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងមិត្រអាមាត្យទាំងនោះ ។

កាលទ្រង់ព្រះរាជទាន នូវវត្ថុដែលគួរព្រះរាជទាន ទ្រង់បន្ថែមចំណីអាហារបៀវត្ស ដល់សត្វពាហនៈ មានដំរីនិងសេះជាដើម និងដល់ពលនិកាយ មិនទ្រង់ប្រើប្រាស់សត្វពាហនៈមានដំរីសេះជាដើម ក្នុងការងារទាំងឡាយ ក្នុងវេលាចាស់ ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងសត្វពាហនៈទាំងឡាយ ។

កាលមិនទ្រង់បៀតបៀន អ្នកស្រុកនិងអ្នកនិគម ដោយព្រះអាជ្ញានិងសួយអាករទាំងឡាយ ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងអ្នកស្រុកនិងអ្នកនិគមទាំងឡាយ ។

កាលទ្រង់ញាំងអ្នកដែន និង អ្នកជនបទ ឲ្យលំបាក ដោយមិនសមហេតុ មិនទ្រង់តាំងព្រះរាជហឫទ័យ ដែលប្រកបដោយប្រយោជន៍ ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តអធម៌ ក្នុងអ្នកដែននិងអ្នកជនបទទាំងឡាយនោះ ។ តែកាលមិនទ្រង់បៀតបៀន និងទ្រង់ផ្សព្វផ្សាយ ដោយព្រះរាជហឫទ័យ ដ៏ប្រកបដោយប្រយោជន៍

ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកដែន និង អ្នកនិគម ។

កាលទ្រង់ព្រះរាជទាននូវបច្ច័យ ៤ ដល់សមណៈនិងព្រាហ្មណ៍ទាំងឡាយនុ៎ះឯង ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងសមណៈ និង ព្រាហ្មណ៍ទាំងឡាយនោះ ។

កាលទ្រង់ព្រះរាជទានអភ័យ ដល់សត្វជើង ៤ និងសត្វស្លាបទាំងអស់ ទើបឈ្មោះថា ទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកម្រឹគនិងបក្សី ។

២ បទ ថា "**ធម្មោ ចិណ្ណោ**" បានដល់ ធម៌គឺការប្រព្រឹត្តត្រឹមត្រូវ ដែលបុគ្គលប្រព្រឹត្តល្អហើយ ។ បទ ថា "**សុខាវហោ**" មានសេចក្តីថា រមែងនាំមកនូវសេចក្តីសុខ ក្នុងកុលសម្បទា ៣ ក្នុងកាមាវចរស្ថគ៌ ៦ ជាន់ ។ បទ ថា "**សុចិណ្ណេន**" បានដល់ ព្រោះសុចរិត មានកាយសុចរិតជាដើម ដែលបុគ្គលប្រព្រឹត្តល្អហើយក្នុងលោកនេះ ។ ២ បទ ថា "**ទិវំ បត្តា**" មានសេចក្តីថា សម្រេចទិព្វ ពោលគឺទេវលោកនិងព្រហ្មលោក គឺ ជាអ្នកបានយសដែលជាទិព្វ ក្នុងទេវលោក និង ព្រហ្មលោកនោះ ។ បាទគាថា ថា "**មា ធម្មំ រាជ បាមទោ**" មានសេចក្តីថា បពិត្រមហារាជ ព្រោះហេតុនោះ ព្រះអង្គសូមឲ្យលះបង់នូវព្រះជន្ទ ក៏សូមកុំទ្រង់ប្រមាទនូវធម៌ឡើយ " ដូច្នេះ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ នូវពាក្យនោះហើយ ទ្រង់មានព្រះ

រាជហឫទ័យត្រេកអរ ទ្រង់ទទួលសីល ៥ ហើយ ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ ស្ដេចយាងទៅកាន់ព្រះនគររបស់ព្រះអង្គ ទ្រង់បំពេញបុញ្ញមានទានជាដើម និងទ្រង់រក្សាសីល ៥ ហើយ ស្ដេចគ្រងនូវរាជ្យសម្បត្តិ ដោយធម៌ ក្នុងទីបំផុតនៃព្រះជន្មាយុ ទ្រង់បានចូលទៅកាន់ស្ថានសួគ៌ ។ ឯព្រះពោធិសត្វ ញុំាងឈាននិងអភិញ្ញាឲ្យកើតឡើងហើយ បានចូលដល់ព្រហ្មលោក ជាមួយនឹងមាតាបិតា ។

រឿងសុវណ្ណសាម មកក្នុងអដ្ឋកថាសាមជាតក ក្នុងមហានិបាត ។

## ( រឿងបុរសកំសត់ឈ្មោះសុតនៈ )

(១៧០) ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតជាទុគ៌តបុរសឈ្មោះសុតនៈ ធ្វើការស៊ីឈ្នួលចិញ្ចឹមមាតាបិតា, កាលបើបិតា ធ្វើកាលកិរិយាហើយ, ក៏ចិញ្ចឹមមាតា ។

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសី ទ្រង់សព្វព្រះទ័យនឹងសាច់ម្រឹគ ថ្ងៃមួយ ទ្រង់ស្ដេចយាងចូលព្រៃហើយ ទ្រង់ព្រះបញ្ជា ថា “ម្រឹគបោលទៅ តាមទីកន្លែងដែលបុគ្គលណាឈរ, ពិន័យ នឹងមានដល់បុគ្គលនោះ” ។

គ្រានោះ ម្រឹគទ្រាយមួយ ដើរទៅកាន់ទីដែលព្រះរាជាទ្រង់គង់នៅ ។ ព្រះរាជា ទ្រង់ច្រកកូនសរ ដើម្បីនឹងទ្រង់បាញ់នូវ

ម្រឹគទ្រាយនោះ ៗ ម្រឹគទ្រាយនោះ មានមាយានៃម្រឹគដែលបាន សិក្សាហើយ ដឹងថាព្រួញកំពុងមក ត្រង់មុខឆ្ពឹងជំនីរហើយ ត្រឡប់ (ខ្លួន) ដួល ធ្វើដូចជាបាញ់ត្រូវ ដោយព្រួញ ៗ ព្រះរាជាទ្រង់ព្រះតម្រិះ ថា "ម្រឹគទ្រាយ អញបាញ់ត្រូវហើយ" ដូច្នេះហើយ ទើបស្ដេចរត់ទៅ ដើម្បីនឹងចាប់ ៗ ម្រឹគទ្រាយ ក្រោកឡើងហើយ ក៏បោលចេញទៅ ៗ ពួកអាមាត្យក៏បានសើចចំអក នឹងព្រះរាជា ៗ

ព្រះរាជាទ្រង់ដេញតាមម្រឹគទ្រាយនោះហើយ ទ្រង់កាត់ជាពីរកំណាត់ ដោយព្រះខ័ន ទ្រង់ព្យួរត្រង់ឈើពុនហើយ ទ្រង់នាំអម្រែកស្ដេចយាងមក ទ្រង់ព្រះបន្ទំនៅក្រោមដើមជ្រៃ ក្នុងចន្លោះនៃផ្លូវទ្រង់តើនឡើងហើយ ប្រារព្ធនឹងស្ដេចយាងទៅ ៗ

យក្សឈ្មោះថា មឃទេវៈ កើតលើដើមជ្រៃនោះ ចាប់ព្រះរាជាត្រង់ព្រះហស្ដ ដោយសម្លុត ថា "សូមព្រះអង្គស្ដេចឈប់សិន! សូមព្រះអង្គស្ដេចឈប់សិន!, ព្រះអង្គជាចំណី របស់ទូលព្រះបង្គំ" ៗ ព្រះរាជាទ្រង់ស្ដេចភ័យខ្លាច ត្រាស់សួរ ថា "អ្នកនឹងស៊ី តែក្នុងថ្ងៃនេះប៉ុណ្ណោះ ឬក៏ស៊ីជាប់រៀងរាល់ថ្ងៃ ?" ៗ យក្សពោល ថា "ទូលព្រះបង្គំ កាលបើបាន នឹងស៊ីជាប់ជានិច្ច" ៗ ព្រះរាជា ទ្រង់ត្រាស់ ថា "ក្នុងថ្ងៃនេះ ចូរអ្នកស៊ីសាច់ម្រឹគនេះហើយ លែងខ្ញុំទៅ, ចាប់ដើមពីថ្ងៃស្អែកទៅ ខ្ញុំនឹងបញ្ជូនមនុស្សម្ដងមួយ ៗ មក ជាមួយ

នឹងថាសចំណីមួយ ៗ ” ។ យក្សពោល ថា “ បើដូច្នោះ សូមព្រះអង្គកុំភ្លេចឡើយ, ក្នុងថ្ងៃដែលព្រះអង្គមិនបញ្ជូនមនុស្ស និងភ័ត្តមកទូលព្រះបង្គំ នឹងស៊ីនូវព្រះអង្គឯង ” ដូច្នេះហើយ ក៏ទទួលការប្តេជ្ញាហើយ បានលែងព្រះរាជាអង្គនោះទៅ ៗ ឯព្រះរាជាទ្រង់ត្រាស់ថា “ ខ្ញុំជាព្រះរាជាក្រុងពារាណសី, វត្ថុអ្វីៗ របស់ខ្ញុំ ឈ្មោះថាមិនមាន រមែងមិនមាន ” ហើយ ស្តេចយាងចូលទៅព្រះនគរ ចាប់ដើមពីថ្ងៃទី ២ មក ទ្រង់ត្រាស់បញ្ជាឲ្យនាំយកមនុស្ស ម្តងមួយ ៗ ចេញពីពន្ធនាគារហើយ ឲ្យកាន់យកថាសភ័ត្តនោះហើយ បញ្ជូនទៅឲ្យដល់យក្ស ៗ យក្សស៊ីភ័ត្តហើយ ទើបស៊ីមនុស្សនោះ ៗ

ពេលខាងក្រោយមក មនុស្សក្នុងពន្ធនាគារ បានអស់ហើយ ៗ ព្រះរាជាទ្រង់ភ័យខ្លាចចំពោះមរណភ័យ ទ្រង់ដាក់បង្វិចកហាបណៈ ១ ពាន់ លើកដំរីហើយ ទ្រង់ឲ្យដើរវាយស្គរប្រកាស ថា “ នរណាអាចយកភ័ត្ត ទៅឲ្យយក្សបាន ចូរយកកហាបណៈ ១ ពាន់នេះចុះ ” ៗ

ព្រះពោធិសត្វឮពាក្យប្រកាសនោះហើយ ក៏ទទួលយកបង្វិចនៃកហាបណៈ ១ ពាន់នោះទៅ ឲ្យដល់ម្តាយហើយ ចូលទៅគាល់ព្រះរាជា ក្រាបថ្វាយបង្គំហើយ ត្រូវព្រះរាជាត្រាស់សួរ ថា “ នែអ្នក អ្នកឯងនឹងនាំភ័ត្តទៅឬ ” ដូច្នេះហើយ ក្រាបទូល ថា “ បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ” ៗ ព្រះរាជាទ្រង់ត្រាស់សួរថា

"អ្នកបានអ្វី ទើបគួរ ?" ។ ព្រះពោធិសត្វ ក្រាបទូល ថា "ទូលព្រះបង្គំបានសុពិបាទុកមាស ឆត្រ និងព្រះខ័ន របស់ព្រះអង្គ ទើបសមគួរ" ។ ព្រះរាជាត្រាស់សួរ ថា "ព្រោះហេតុអ្វី ?" ។ ព្រះពោធិសត្វក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ធម្មតាអមនុស្សទាំងឡាយ តែងខ្លាចដល់មនុស្សដែលមានអាវុធនឹងដៃប៉ុណ្ណោះ, ព្រោះហេតុនោះ ទូលព្រះបង្គំ មានព្រះខ័ននឹងដៃ មិនឈរនៅ ត្រង់ស្ថានទីដែលជារបស់នៃយក្សនោះ នឹងឈរនៅលើសុពិបាទុកមាស, មិនឈរក្រោមម្លប់ឈើរបស់យក្សនោះ នឹងឈរនៅក្រោមម្លប់ឆ័ត្រ, ព្រោះថា យក្សនោះ តែងបានដើម្បីនឹងស៊ី នូវមនុស្សដែលឈរក្នុងស្ថានទីនិងម្លប់ឈើ ដែលជារបស់នៃខ្លួន" ។ ព្រះរាជា ត្រាស់សួរ ថា "អ្នកបានអ្វីទៀតទើបគួរ" ។ ព្រះពោធិសត្វក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ការនាំភោជនៈដែលសៅហ្មង ដោយថាសដី នឹងមិនគួរ ដល់បុរសជាបណ្ឌិត ឈ្មោះប្រាកដដូចជាទូលព្រះបង្គំឡើយ, ព្រោះហេតុនោះ ទូលព្រះបង្គំបានព្រះក្រយាហារ សម្រាប់សោយរបស់ព្រះអង្គ ពេញដោយថាសមាស របស់ព្រះអង្គ ទើបគួរ" ។ ព្រះរាជា ញ៉ាំងរាជបុរសឲ្យឲ្យវត្ថុទាំងអស់នោះហើយ ប្រគល់អ្នកបម្រើ ដល់ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វ ញ៉ាំងបុគ្គលឲ្យកាន់យកឧបករណ៍ទាំងឡាយ ទៅក្នុងសំណាក់ នៃយក្សនោះហើយ

ឲ្យពួកមនុស្សឈប់ នៅទីមិនឆ្ងាយពីដើមឈើហើយ ពាក់សុពិបាទុក៌មាស បាំងស្វេតច្ឆ័ត្រ លើក្បាល កាន់ថាសនៃភ័ត្ត ដើរទៅជិតគល់ឈើ យកចុងព្រះខ័នទ្រថាសភ័ត្តហើយ ឈរត្រង់ទីបំផុតនៃម្លប់ (ឈើ) ប៉ុណ្ណោះ បានឲ្យហើយនូវភ័ត្តដល់យក្ស ។

យក្សគិត ថា " អញនឹងបញ្ឆោតបុរសនេះហើយ ស៊ីវាដែលដើរចូលមក កាន់ម្លប់ឈើ " ដូច្នេះ ហើយពោល ថា " នែមាណពចូរអ្នកអញ្ជើញមកចុះ, យើងទាំង ២ នាក់ នឹងបរិភោគ (ជាមួយគ្នា) " ។ ព្រះពោធិសត្វ ពោល ថា " បើសិនជា អ្នកនឹងស៊ីខ្ញុំ, នរណា ក៏គិត ថា ' បុរសឈ្មោះសុតនៈ អ្នកចិញ្ចឹមនូវមាតា ត្រូវយក្សស៊ីហើយ ' ដូច្នេះ, ឈ្មោះថា អ្នកនាំនូវភ័ត្តមកឲ្យអ្នក នឹងមិនមាន, បើដូច្នោះ តាំងតែពីពេលនេះទៅ អ្នកនឹងបានភោជនៈដោយលំបាក, អ្នកនឹងមិនបានទទួលព្រះរាជា របស់យើងទាំងឡាយ, ព្រោះហេតុអ្វី ?, ព្រោះពួកយើងឈរនៅ ខាងក្រៅនៃដើមឈើ, អ្នកមិនអាច ដើម្បីនឹងស៊ីខ្ញុំបានឡើយ, ព្រោះថា ខ្ញុំមិនបានឈរនៅក្នុងទីកន្លែងរបស់អ្នក ឈរនៅលើសុពិបាទុក៌, ខ្ញុំមិនបានឈរនៅក្រោមម្លប់ឈើ របស់អ្នកទេ ឈរនៅក្រោមម្លប់ឆ័ត្រ, ក៏បើសិនជា អ្នកនឹងប្រយុទ្ធ ជាមួយនឹងខ្ញុំ, ខ្ញុំនឹងកាប់អ្នកនឹងព្រះខ័នជាពីរកំណាត់, ហេតុថា ក្នុងថ្ងៃនេះ ខ្ញុំបានត្រៀមស្រេចបាច់មក

ហើយ ដើម្បីរឿងនេះតែប៉ុណ្ណោះ "។ យក្សគិតថា "បុរសនេះ និយាយត្រឹមត្រូវ" ដូច្នេះហើយ មានចិត្តត្រេកអរ បរិភោគភ័ក្តរួចហើយ ទើបពោលថា ៖

**" នែមាណព អ្នកចូរកាន់យកព្រះខ័ន ឆ័ត្រ និងភាជន៍ទៅចុះ, មាតារបស់អ្នក ចូរឃើញនូវសេចក្តីចំរើន, អ្នកសោត ក៏ចូរទៅជួបនឹងមាតាចុះ "។**

ព្រះពោធិសត្វពោលថា "ម្នាលសំឡាញ់ សូម្បីក្នុងកាលមុន អ្នកបានធ្វើបាបហើយ ទើបបានមកកើតជាយក្ស, ចាប់ដើមពីពេលនេះទៅ ចូរអ្នកកុំធ្វើបាបទាំងឡាយ មានការសម្លាប់សត្វជាដើមឡើយ" ដូច្នេះហើយ ពោលអានិសង្ស ក្នុងសីល និងទោស ក្នុងការទ្រុស្តសីល ឲ្យយក្សនោះស្ថិតនៅក្នុងសីល៥ ហើយពោលថា "ប្រយោជន៍អ្វី ដោយការនៅក្នុងព្រៃ របស់អ្នក, ចូរអ្នកមកចុះ" ហើយ នាំយក្សនោះទៅ ឲ្យយក្សនោះឯង ជួយកាន់ព្រះខ័នជាដើម បានទៅកាន់ព្រះនគរហើយ ។

ព្រះរាជា ស្តេចទទួលព្រះពោធិសត្វហើយ ឲ្យយក្សអង្គុយត្រង់មាត់ទ្វារនគរ ធ្វើឲ្យជាអ្នកបានលាភ មានភ័ក្តដ៏ច្រើនជាដើម ស្តេចយាងចូលទៅកាន់ព្រះនគរហើយ ទ្រង់តែងតាំងនូវព្រះពោធិសត្វជា

សេនាបតី ទ្រង់តាំងនៅ ក្នុងឱវាទនៃព្រះពោធិសត្វនោះ ទ្រង់បាន ទៅកើតហើយ នៅក្នុងស្ថានសួគ៌ ។

រឿង សុគនៈ ចប់ ។

## ( រឿងម្រឹគឈ្មោះនន្ទិយៈ )

(១៧១) ក្នុងអតីតកាល ព្រះរាជាកោសល ក្នុងទីក្រុង សាកេត ក្នុងកោសលរដ្ឋ បានទ្រង់សព្វព្រះទ័យ ក្នុងសាច់ម្រឹគ ។ ព្រះអង្គមិនបានឲ្យពួកមនុស្ស ធ្វើការទាំងឡាយ មានកសិកម្មជាដើម ទ្រង់មានមនុស្សជាបរិវារ បានយាងទៅបាញ់សត្វ រៀងរាល់ថ្ងៃ ។

តមក ក្នុងថ្ងៃមួយ មនុស្សទាំងឡាយ បានប្រជុំប្រឹក្សាគ្នា ថា " ធ្វើដូចម្ដេចហ្ន៎ ? ពួកយើង គប្បីធ្វើរបងព័ទ្ធ ឧទ្យាន អញ្ជើញទ្រង់ ធ្វើទ្វារបិតហើយ គៀងម្រឹគទាំងឡាយ ចេញមកពីព្រៃ ឲ្យចូល ទៅ ក្នុងឧទ្យាននោះ បិតទ្វារអស់ហើយ ក្រាបទូលដល់ព្រះរាជា ហើយ ធ្វើការងារ របស់ខ្លួន " ដូច្នេះហើយ ចាត់ចែង ឧទ្យានរួច ហើយ ចូលទៅកាន់ព្រៃ ហ៊ុមព័ទ្ធទីកន្លែងប្រមាណ ១ យោជន៍ ។

ក្នុងកាលនោះ ព្រះពោធិសត្វ កើតជាម្រឹគ ឈ្មោះនន្ទិយៈ នាំមាតាបិតាទៅនៅ ក្នុងគុម្ពឈើតូច ៗ មួយគុម្ព បានឃើញពួក មនុស្សទាំងនោះហើយ ទើបគិត ថា " ក្នុងថ្ងៃនេះ អញលះបង់ជីវិត

ហើយ ឲ្យជីវិតដល់មាតាបិតា ទើបគួរ " ហើយពោល ថា " សូមអ្នកទាំងឡាយ គប្បីរស់នៅដោយឧបាយកលមួយ, ខ្ញុំនឹងឲ្យជីវិតដល់អ្នកទាំងឡាយ, កាលបើគុម្ពឈើ គ្រាន់តែត្រូវពួកមនុស្សវាយហើយប៉ុណ្ណោះ, ខ្ញុំនឹងរត់ចេញទៅ, កាលបើដូច្នោះ, មនុស្សទាំងនោះ នឹងសម្គាល់ ថា 'ក្នុងគុម្ពឈើតូចនេះ នឹងមានតែកូនម្រឹគតូចមួយប៉ុណ្ណោះឯង ' ដូច្នេះហើយ ក៏មិនចូលទៅ កាន់គុម្ពឈើហើយ មិនឃើញអ្នកទាំងឡាយ, សូមអ្នកទាំងឡាយ កុំធ្វេសប្រហែសឡើយ " ដូច្នេះហើយ ញ៉ាំងមាតាបិតាឲ្យអត់ទោសហើយជាអ្នកត្រៀមនឹងបោលទៅ, កាលបើគម្ពោតឈើ គ្រាន់តែត្រូវពួកមនុស្សវាយហើយ ប៉ុណ្ណោះ, ក៏ស្ទុះរត់ចេញ ពីគម្ពោតឈើនោះហើយ បានបោលចូលទៅ កាន់ចន្លោះនៃម្រឹគទាំងឡាយ ។ ពួកមនុស្សទាំងឡាយនោះឯង ក៏មានសេចក្ដីសម្គាល់ យ៉ាងដូច្នេះដែរមិនបានចូលទៅកាន់គម្ពោតឈើនោះ គៀងម្រឹគទាំងឡាយ ឲ្យចូលទៅកាន់ឧទ្យានហើយ ក្រាបទូលដល់ព្រះរាជា បានទៅកាន់ទីលំនៅឋាន របស់ខ្លួនហើយ ។

ចាប់ដើមតាំងពីថ្ងៃនោះមក ព្រះរាជា ទ្រង់ស្ដេចយាងទៅបាញ់ម្រឹគមួយ ដោយព្រះអង្គឯងតែម្ដងហើយ ទ្រង់នាំយកមក ឬក្នុងកាលខ្លះ ទ្រង់បញ្ជូនរាជបុរស ឲ្យទៅនាំមក ។ ម្រឹគទាំងនោះ

បានដាក់វេនគ្នាហើយ ៗ ម្រឹគដែលត្រូវដល់វេនហើយ បានឈរនៅ ក្នុងទីដ៏សមគួរមួយ ៗ ព្រះរាជា ទ្រង់បាញ់ម្រឹគនោះហើយ ទ្រង់ស្ដេចកាន់យកមក ៗ

ក្រោយមក ក្នុងថ្ងៃមួយ វេនរបស់ម្រឹគ ឈ្មោះនន្ទិយៈ ក៏បានមកដល់ហើយ ៗ ក៏ក្នុងថ្ងៃនោះ ព្រះរាជា ទ្រង់ស្ដេចយាងទៅដោយព្រះអង្គឯងតែម្ដង ទ្រង់ប្រារព្ធហើយ ដើម្បីនឹងបាញ់ ៗ ម្រឹគឈ្មោះនន្ទិយៈ ផ្សាយមេត្តា ឲ្យឆ្ពោះទៅខាងមុខហើយ បានឈរនៅស្ងៀម ៗ ព្រះរាជា ទ្រង់មិនអាច ដើម្បីនឹងលែងព្រួញទៅបាន ដោយអានុភាពនៃមេត្តា របស់ម្រឹគឈ្មោះនន្ទិយៈនោះ ទ្រង់បោះធ្នូចោលហើយត្រាស់ ថា " ធ្នូនេះ សូម្បីជារបស់គ្មានចិត្ត ជាកំណាត់ឈើ តែងដឹងគុណ របស់អ្នក ដោយពិត, ខ្ញុំ សូម្បីជាមនុស្ស មានចិត្តដែរ តែមិនដឹងគុណរបស់អ្នក, ចូរអ្នកអត់ទោសឲ្យដល់ខ្ញុំ, ខ្ញុំនឹងឲ្យអភ័យ ដល់អ្នក " ៗ ព្រះពោធិសត្វ ក្រាបទូល ថា " បពិត្រព្រះមហារាជ ព្រះអង្គទ្រង់ព្រះទានអភ័យ ឲ្យដល់ទូលព្រះបង្គំ ដោយពិត, ចំណែក ហ្វូងម្រឹគ ក្នុងឧទ្យាននេះ តើនឹងធ្វើ យ៉ាងដូចម្ដេចទៅ ? " ៗ ព្រះរាជា ទ្រង់ត្រាស់តប ថា " ខ្ញុំនឹងឲ្យអភ័យ ដល់ហ្វូងម្រឹគនុ៎ះផងដែរ " ៗ ព្រះពោធិសត្វបានឲ្យព្រះរាជា ទ្រង់ព្រះរាជទានអភ័យឲ្យដល់ ពួកសត្វគ្រប់យ៉ាង

គឺ ម្រឹគក្នុងព្រៃ សត្វបក្សីដែលហើរលើអាកាស និងសត្វត្រីដែលរស់នៅក្នុងទឹកហើយ ញុំាងព្រះរាជាឱ្យតាំងនៅ ក្នុងសីល ៥ ដូច្នេះហើយ ទើបក្រាបទូល ថា " បពិត្រព្រះមហារាជ ធម្មតាព្រះរាជាទ្រង់លះបង់ នូវការលុះក្នុងអគតិហើយ មិនទ្រង់ញុំាងធម៌នៃព្រះរាជា ១០ ប្រការ ឱ្យកម្រើកហើយ ទ្រង់គ្រប់គ្រងរាជ្យសម្បត្តិដោយធម៌ ទើបគួរ " ដូច្នេះហើយ កាលនឹងសំដែង នូវធម៌នៃព្រះរាជា ១០ ប្រការ ទើបបានពោល គាថាទាំងឡាយ ២ ថា ÷

(១៧២) " សូមព្រះអង្គ ទ្រង់ព្រះពិចារណាឃើញនូវធម៌ ដែលជាកុសល ដែលតាំងនៅ ក្នុងខ្លួននៃព្រះអង្គ ទាំងនេះគឺ ទាន ១ សីល ១ ការបរិច្ចាគៈ ១ ភាពជាអ្នកទៀងត្រង់ ១ ភាពជាអ្នកទន់ភ្លន់ ១ តបៈ ១ ការមិនពិរោធ ១ ការមិនបៀតបៀន ១ សេចក្តីអត់ធន់ ១ ការមិនប្រទូសរ៉ាយ ១, បន្ទាប់អំពីនោះមក បីតិ និងសោមនស្ស មិនមែនតិចតួចរមែងកើតមាន ដល់ព្រះអង្គ " ។

សេចក្តី នៃគាថាទាំងនេះ លោកពោលហើយ ក្នុងអដ្ឋកថាមហាហង្សជាតក យ៉ាងនេះ ថា "បណ្តាធម៌ទាំង ១០ យ៉ាងនោះ

ចេតនា ព្រមទាំងវត្ថុ ឈ្មោះថា ទាន ។ សីល ៥ សីល ១០ ឈ្មោះថា សីល ។ ការលះនូវទេយ្យធម៌ ឈ្មោះថា បរិច្ចាគៈ ។ ភាពជាអ្នកស្មោះត្រង់ ឈ្មោះថា អាជ្ជវៈ ។ ភាពជាអ្នកទន់ភ្លន់ ឈ្មោះថា មទ្ទវៈ ។ ឧបោសថកម្ម ឈ្មោះថា តបៈ ។ ធម៌មានមេត្តាជាបុព្វភាគ ឈ្មោះថា អក្កោធនៈ ។ ធម៌មានករុណាជាបុព្វភាគ ឈ្មោះថា អវិហឹសា ។ ការអត់ទ្រាំ ឈ្មោះថា ខន្តី ។ ការមិនប្រទូសរ៉ាយ ឈ្មោះថា អវិរោធនៈ" ។

ព្រះពោធិសត្វ នៅក្នុងសំណាក់ នៃព្រះរាជា ២-៣ ថ្ងៃហើយ ញុំាងបុគ្គលឲ្យវាយស្គរមាស ត្រេចទៅ ក្នុងនគរ ដើម្បីនឹងប្រកាសអភ័យទាន ដល់សព្វសត្វហើយ ក្រាបទូល ថា "បពិត្រព្រះមហារាជ សូមព្រះអង្គ កុំធ្វេសប្រហែសឡើយ" ដូច្នេះហើយ ទៅដើម្បីជួប នូវមាតាបិតា ដោយប្រការដូច្នេះ ។

រឿង ម្រឹគឈ្មោះនន្ទិយៈ ចប់ ។

## ( រឿងត្មាត )

(១៧៣) ក្នុងអតីតកាល ព្រះពោធិសត្វកើតជាត្មាត ឲ្យមាតាបិតា ដែលចាស់ជរា មានភ្នែកខ្វាក់នៅ ក្នុងគិជ្ឈគុហា បាននាំចំណីអាហារទាំងឡាយ មានសាច់គោជាដើម មកចិញ្ចឹម ។

ក្នុងកាលនោះ ព្រានម្នាក់ ឈ្មោះថា និលិយៈ ដាក់អន្ទាក់ក្នុងទីស្មសាន ក្បែរទីក្រុងពារាណសី មិនបានកំណត់ ( នូវសត្វណាមួយឡើយ ) ។ ព្រះពោធិសត្វ បានជាប់ ក្នុងអន្ទាក់នោះហើយ នឹករឭកដល់មាតាបិតា របស់ខ្លួន ស្រែកទ្រហ៊ូយំ ដោយភាសានៃមនុស្ស ថា " មាតាបិតា របស់អញ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងដូចម្ដេចហ្ន៎ ?, កាលបើមិនដឹងថា អញជាប់អន្ទាក់ នឹងជាអ្នកគ្មានទីពឹង មិនមានបច្ច័យ ឃើញថានឹងស្គាំងស្គមស្លាប់នៅក្នុងរូងភ្នំនុ៎ះឯង " ។ ព្រាន ឮពាក្យនោះហើយ ពោល ថា

" មនុស្សលោក និយាយគ្នា ថា ' ត្មាត រមែងមើលឃើញសាកសព ចម្ងាយ ១០០ យោជន៍បាន ពាក្យនោះ តើយ៉ាងដូចម្ដេចហ្ន៎, ចុះហេតុអ្វី បានជាអ្នកមកជាប់លប់ និងអន្ទាក់ហើយ ក៏មិនភ្ញាក់ខ្លួនសោះ ? " ។

បណ្ដាបទទាំងនោះ បទ ថា " យន្នុ " មានសេចក្ដីថា ពាក្យនេះណា ប្រជាលោក និយាយគ្នា ថា " ត្មាត រមែងមើលឃើញនូវសាកសព ដែលតាំងនៅហួស ១០០ យោជន៍បាន " ដូច្នេះពាក្យនេះនោះ តើដូចម្ដេចទៅហ្ន៎ ? ។ ចុះហេតុអ្វី បានជាអ្នកសូម្បីមកជិត លប់និងអន្ទាក់ហើយ ក៏មិនភ្ញាក់ខ្លួនសោះ គឺសូម្បី

មកជិតហើយ ក៏មិនដឹង ? ។ ព្រះពោធិសត្វ បានពោល ថា

" ពេលណា ដែលមានសេចក្ដីវិនាស (មកដល់)
ពេលនោះ សត្វដែលនឹងអស់ជីវិត បើទុកជាមក
ជាប់លប់ និងអន្ទាក់ ក៏គង់មិនអាចភ្ញាក់ខ្លួនបាន "។

បណ្ដាបទទាំងនោះ បទ ថា " **បរាភវោ** " បានដល់ សេចក្ដីវិនាស ។ បទ ថា " **បោសោ** " បានដល់ សត្វ ។

ព្រានស្ដាប់ធម្មកថា របស់ព្រះពោធិសត្វនោះហើយ ត្រេកអរ ថា " ស្ដេចត្មាតជាបណ្ឌិត កាលខ្សឹកខ្សួល ក៏មិនបានខ្សឹកខ្សួលដើម្បីខ្លួនឡើយ, តែងខ្សឹកខ្សួលដើម្បីមាតាបិតា, ស្ដេចត្មាតនេះ មិនគួរអញនឹងសម្លាប់ឡើយ" ដូច្នេះហើយ ក៏ស្រាយអន្ទាក់ចេញពីជើង ដោយចិត្តដែលប្រកបដោយសេចក្ដីស្រឡាញ់ហើយពោល ថា

" អ្នកចូរទៅ ចិញ្ចឹមមាតាបិតាចាស់ជរា ដែល
អាស្រ័យនៅ ពួដ៏ច្រកភ្នំចុះ, យើងបានបើកលែង
អ្នកហើយ, ចូរអ្នកទៅជួបពួកញាតិសន្តាន ដោយ
សុវត្ថិភាពចុះ " ។

ព្រះពោធិសត្វ រួចចាកមរណទុក្ខហើយ កាលធ្វើអនុមោទនា ទើបពោល ថា ÷

" ម្នាលព្រាន អ្នកចូររីករាយ ជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនេះចុះ, ខ្ញុំនឹងចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅ ឰដ៏ច្រកនៃភ្នំ "

ដូច្នេះហើយ ពាំសាច់ពេញមាត់ហើរទៅហើយ ឲ្យដល់មាតាបិតា ។

រឿង ត្មាត មកក្នុងសត្តកនិបាត ។

## ( រឿងត្មាត )

(១៧៤) ក្នុងអតីតកាល ព្រះពោធិសត្វកើតជាត្មាតចិញ្ចឹមមាតាបិតា នៅក្នុងគិជ្ឈបព៌ត ។ គ្រាមួយ កើតមានខ្យល់និងភ្លៀង ដ៏ច្រើន ។ ត្មាតទាំងឡាយ មិនអាចដើម្បីអត់ទ្រាំនឹងខ្យល់និងភ្លៀងនោះបាន ក៏ហើរទៅក្រុងពារាណសី ញាក់ញ័រព្រោះត្រជាក់ ទំលើទីជិតនៃកំពែងខ្លះ ទីជិតនៃស្នាមភ្លោះខ្លះ ។

ក្នុងកាលនោះ សេដ្ឋីក្រុងពារាណសី ចេញពីនគរ ឃើញពួកត្មាតទាំងនោះ កំពុងលំបាក ទើបឲ្យត្មាតទាំងនោះមកជុំគ្នា ក្នុងស្ថានទីមួយហើយ បានឲ្យដុតភ្លើង បញ្ជូនពួកបុរសទៅទីស្មសាន ឲ្យនាំយកសាច់គោមក ឲ្យត្មាតទាំងនោះហើយ ចាប់ផ្ដើមនូវការរក្សា ។

ត្មាតទាំងឡាយ, កាលបើខ្យល់និងភ្លៀងបាត់អស់ទៅហើយ, មានខ្លួនស្រស់បស់ហើយ ក៏ហើរទៅកាន់ភ្នំនុះឯង បានប្រឹក្សាគ្នា ថា

“ សេដ្ឋីក្រុងពារាណសី បានធ្វើឧបការៈ ដល់ពួកយើង, ក៏ពួកយើង ធ្វើឧបការៈតប ឈ្មោះថាដល់អ្នកដែលបានធ្វើឧបការៈហើយ ទើបគួរ, ព្រោះហេតុនោះ ចាប់ពីថ្ងៃនេះទៅ បណ្តាពួកយើង អ្នកណាបាននូវវត្ថុអ្វី ជាសំពត់ក្តី ជាគ្រឿងអលង្ការក្តី, អ្នកនោះ គប្បីញុំាងវត្ថុទាំងនោះ ឲ្យធ្លាក់ចុះ លើផ្ទះនៃសេដ្ឋី ” ។ តាំងពីពេលនោះមក ក្អែកទាំងនោះ ត្រួតមើលសេចក្តីប្រមាទ នៃមនុស្សទាំងឡាយ ដែលហាលសំពត់និងគ្រឿងអលង្ការទាំងឡាយ ក្នុងពេលថ្ងៃ ក៏ពាំយកដោយប្រញាប់ប្រញាល់ ទៅទម្លាក់ លើផ្ទះនៃសេដ្ឋី ។

សេដ្ឋី ដឹងថាវត្ថុទាំងនោះ គឺពួកក្អែកនាំមកហើយ ទើបរក្សានូវវត្ថុទាំងអស់នោះទុក ដោយឡែក ៗពីគ្នា ៗ ពួកមនុស្ស បានក្រាបទូល ដល់ព្រះរាជា ថា “ក្អែកទាំងឡាយ ប្លន់នគរ ” ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឲ្យរាជបុរស ដាក់លប់និងអន្ទាក់ ក្នុងទីនោះ ៗ ដើម្បីនឹងចាប់ក្អែក ។ ព្រះពោធិសត្វ ជាប់ហើយ ក្នុងអន្ទាក់ ។ ពួកមនុស្ស ចាប់ព្រះពោធិសត្វនោះបានហើយ ក៏បង្ហាញព្រះរាជា ។ ព្រះរាជា ទ្រង់ត្រាស់សួរ ទ្រង់ព្រះសណ្តាប់ នូវហេតុទាំងអស់នោះ ត្រាស់សួរម្តងទៀត ដោយន័យ ថា “**យន្នុ គិជ្ឈោ យោជនសតំ**” ដូច្នេះ ជាដើម ។ ឯក្អែកពោធិសត្វ សំដែងធម៌ ដោយន័យ ថា “ **យទា បរាភវោ ហោតិ** ” ដូច្នេះជាដើម ជាអ្នកគឺព្រះរាជា

ទ្រង់សព្វព្រះទ័យ ទ្រង់ដោះលែងទៅហើយ បានទៅហើយកាន់សំណាក់ នៃមាតាបិតា ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឲ្យសេដ្ឋី ឲ្យនូវរបស់ទាំងឡាយ ដល់អ្នកម្ចាស់របស់គ្រប់ៗគ្នាវិញអស់ហើយ ។

រឿង ត្មាត មកក្នុងទុកនិបាត ។

## ( រឿងស្តេចសេក )

(១៧៥) ក្នុងអតីតកាល ក្នុងទិសបូព៌ា និងទិសឧត្តរ អំពីទីក្រុងរាជគ្រឹះ បានមានផ្ទះរបស់ព្រាហ្មណ៍ ឈ្មោះថា សាលិន្ទិយៈ ។ ក្នុងទិសបូព៌ា និងទិសឧត្តរ អំពីសាលិន្ទិយគ្រាមនោះ ជាស្រែរបស់អ្នកដែនមគធៈ ។ ក្នុងទិសបូព៌ា និងទិសឧត្តរ អំពីស្រែរបស់អ្នកដែនមគធៈនោះ ជាព្រៃរកាដ៏ធំ ក្បែរសានុបព៌តមួយ ។ សត្វសេកជាច្រើន អាស្រ័យនៅ ក្នុងព្រៃរកានោះ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតជាស្តេចសេក មានខ្លួនធំប៉ុនដុំរទេះ នាំចំណីអំពីព្រៃហិមពាន្ត មកចិញ្ចឹមមាតាបិតា ។ គ្រានោះព្រាហ្មណ៍ម្នាក់ ឈ្មោះថា កោសិយគោត្រ នៅក្នុងសាលិន្ទិយគ្រាមឲ្យបុគ្គលព្រោះស្រូវសាលី ក្នុងស្រែ ប្រមាណ ១ ពាន់ករីស ដាក់មនុស្សឲ្យនៅចាំស្រែម្នាក់ ។ ស្តេចសេក ព្រមទាំងបរិវារ ចុះក្នុងស្រែនោះ ។ អ្នកថែរក្សាស្រែ មិនអាចហាមឃាត់ សត្វសេកទាំង

ឡាយ ដែលចុះ ក្នុងស្រែនោះ ៗ បានឡើយ ។ សត្វសេកទាំងឡាយ ដ៏សេស ស៊ីតាមត្រូវការហើយ ក៏ហើរទៅតែមាត់ទទេរ ៗ ចំណែក ស្តេចសេក ធ្វើកួរស្រូវសាលីជាច្រើន រួមចូលគ្នាហើយ ក៏ពាំ ដោយ ចំពុះហើយ ហើរទៅ ៗ បុរសអ្នករក្សាស្រែ បានទៅប្រាប់ ដល់ ព្រាហ្មណ៍ ៗ ព្រាហ្មណ៍ បានបញ្ជា ថា " បើដូច្នោះ ចូរអ្នកវេញ រោមកន្ទុយសេះ ដាក់អន្ទាក់ ក្នុងទីដែលស្តេចសេកចុះហើយ ចាប់ វាទាំងរស់ នាំយកមក " ៗ បុរសអ្នករក្សាស្រែ បានធ្វើយ៉ាងនោះ ចាប់បានស្តេចសេកហើយ សំដែង ដល់ព្រាហ្មណ៍ ៗ ព្រាហ្មណ៍ ឃើញស្តេចសេកនោះហើយ កើតមានសេចក្តីស្រឡាញ់ ជាកម្លាំង ឲ្យព្រះពោធិសត្វ ទំនៅក្នុងទ្រុងហើយ ក៏ពោល ថា " ម្នាលសេក អ្នកស៊ីស្រូវសាលី តាមសេចក្តីប្រាថ្នារួចហើយ ក៏ពាំយកស្រូវសាលី ដោយចំពុះ ហើរទៅទៀត, ជង្រុក របស់អ្នក មានឬ ? ឬក៏អ្នក ចងពៀរ នឹងយើង ? " ដូច្នេះ ៗ

ស្តេចសេក ស្តាប់ពាក្យនោះហើយ ពោលគាថានេះ ក្នុង កេទារជាតក ក្នុងបកិណ្ណកនិបាត ដោយសំដីមនុស្ស ដ៏ពិរោះ ថា ÷

(១៧៦) " ខ្ញុំមិនចងពៀរ ជាមួយនឹងអ្នកទេ,<br>
ជង្រុករបស់ខ្ញុំ ក៏មិនមានដែរ, ខ្ញុំដោះបំណុលផង

ឲ្យបុលផង, ខ្ញុំហើរទៅដល់ចុងរកា ក៏កប់កំណាប់ទុក ក្នុងព្រៃរកានោះ, បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ ” ។

បណ្ដាបទទាំងនោះ បទ ថា “ ឥណំ ” មានសេចក្ដីថា ខ្ញុំនាំស្រូវសាលី របស់អ្នកទៅហើយ តែងដោះបំណុលផង ឲ្យបុលផង ។ បទ ថា “ កោដិសិម្ពលី ” បានដល់ ព្រៃរកាដែលមានឈ្មោះយ៉ាងដូច្នោះ ។ បទ ថា “ និធឹបិ ” មានសេចក្ដីថា តែងកប់ គឺទុកនូវកំណាប់ទ្រព្យមួយ ដែលមានប្រក្រតីទៅតាម (ខ្លួន) ក្នុងទីនោះ គឺក្នុងព្រៃរកា ។

ក៏ព្រះពោធិសត្វ លុះពោលយ៉ាងនោះហើយ ត្រូវព្រាហ្មណ៍សួរ កាលធ្វើសេចក្ដីនោះ ឲ្យប្រាកដ ទើបពោល ថា ÷

“ បពិត្រកោសិយៈ ខ្ញុំមានកូនតូច ៗ មិនទាន់ដុះស្លាបនៅឡើយ, កូនតូចទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយ នឹងចិញ្ចឹមខ្ញុំវិញ, ហេតុនោះ ខ្ញុំត្រូវឲ្យបុលដល់កូនតូច ៗ ទាំងនោះ ។ ម្យ៉ាងទៀត ខ្ញុំមានមាតាបិតាចាស់គ្រាំគ្រា មានវ័យកន្លងហើយ, ខ្ញុំពាំ (ស្រូវសាលី) ដោយចំពុះ យកទៅជូនដល់មាតាបិតា

ទាំងនោះ, ខ្ញុំត្រូវដោះបំណុល ដែលគាត់ធ្វើហើយ ក្នុងកាលមុន ។ ក្នុងព្រៃរកានោះ មានបក្សីទាំងឡាយដទៃទៀត ដែលជ្រុះស្លាបអស់ហើយ ថមថយកម្លាំង, ខ្ញុំត្រូវការ ដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ, បណ្ឌិតទាំងឡាយ ពោលថា បុញ្ញកម្មនោះ ជាកំណប់ទ្រព្យ " ។

បណ្ដាបទទាំងនោះ បទ ថា " ហោតូន " ប្រែថា នាំទៅហើយ ។ ២ បទ ថា " តំ និធី " មានសេចក្ដីថា បណ្ឌិតទាំងឡាយ ពោល ថា បុញ្ញកម្មនោះ ឈ្មោះថា កំណប់ទ្រព្យ ដែលមានប្រក្រតីទៅតាម ( ខ្លួន ) ។

ព្រាហ្មណ៍ ស្ដាប់ពាក្យនោះហើយ មានចិត្តជ្រះថ្លា ពោល ថា " តាំងពីថ្ងៃនេះទៅ អ្នកព្រមទាំងពួកញាតិ ចូរកុំឲ្យមានភ័យ ស៊ីស្រូវសាលីចុះ " ដូច្នេះហើយ ប្រគល់ស្រែទាំងអស់ឲ្យហើយ ស្រាយចំណងចេញពីជើង ។ ព្រះពោធិសត្វ ព្រោះជាអ្នកដឹងប្រមាណ ក៏ទទួលយកត្រឹមតែ ៨ ករីស ប៉ុណ្ណោះហើយ ឲ្យស្រែដែលសេសសល់ដល់ព្រាហ្មណ៍នុ៎ះឯងទៀត បានឲ្យឱវាទ ថា " ម្នាលមហាព្រាហ្មណ៍ ចូរអ្នក កុំប្រមាទឡើយ " ដូច្នេះហើយ ក៏បានពាំកួរនៃស្រូវសាលី

ទៅកាន់សំណាក់ នៃមាតាបិតា ។ ឯព្រាហ្មណ៍ បោះនូវបង្គោល សសរ ក្នុងទីមានប្រមាណ ៨ ករីស ហើយ បានប្រាប់អ្នករក្សាស្រែ ថា “ ចូរអ្នកកុំហាមឃាត់ នូវសេកទាំងឡាយ ដែលពាំស្រូវសាលី ពីស្រែនោះឡើយ ” ។ តាំងពីពេលនោះមក សេកទាំងឡាយបាន ពាំ (ស្រូវសាលី ) ពីស្រែនោះឯង ។

រឿង ស្ដេចសេក ចប់ ។

## ( រឿងស្ដេចដំរី )

(១៧៧) ក្នុងអតីតកាល ព្រះពោធិសត្វ កើតជាស្ដេចដំរីស សុទ្ធ មានដំរីជាបរិវារចំនួន ៨ ម៉ឺន ចិញ្ចឹមមាតា ដែលខ្វាក់ ភ្នែក របស់ខ្លួន នៅក្នុងហេមវន្តប្រទេស ។ ក្រោយមក ស្ដេចដំរី នោះ លះបង់ហ្វូង នាំមាតាទៅ កាន់ជើងភ្នំ ឈ្មោះថា ចណ្ឌោរណៈ ឲ្យមាតានៅ ក្នុងរូងនៃភ្នំ ដែលស្ថិតនៅជាប់គ្នា នឹងស្រះបទុមមួយ ចិញ្ចឹមបីបាច់ហើយ ។

គ្រានោះ ថ្មើរព្រៃ អ្នកនៅក្នុងក្រុងពារាណសីម្នាក់ វង្វេងផ្លូវ អស់ ៧ ថ្ងៃ ស្រែកទ្រហោយំ ទៅដល់ទីនោះហើយ ។ ស្ដេចដំរី ឲ្យ អ្នកថ្មើរព្រៃនោះ ជិះលើខ្នងរបស់ខ្លួន ដោយសេចក្ដីអាណិតហើយ នាំទៅដាក់ ក្នុងទីកន្លែងនៃមនុស្សហើយ ទើបត្រឡប់មកវិញ ។

ឯអ្នកធ្វើវព្រៃអាក្រក់នោះ ទៅកាន់ក្រុងពារាណសីហើយ ក៏បាន ក្រាបទូលដល់ព្រះរាជា ។ ក៏ក្នុងកាលនោះ ដំរីមង្គល របស់ព្រះ រាជា ស្លាប់ហើយ ។ ព្រះរាជា ទ្រង់បញ្ជូនទម័កដំរីទៅ ជាមួយ នឹងអ្នកធ្វើវព្រៃនោះ ឲ្យនាំព្រះពោធិសត្វមកហើយ ទ្រង់ដាក់នៅក្នុង រោងនៃដំរីមង្គល ទ្រង់បញ្ជាឲ្យនាំយកចំណី ដែលមានរសជាតិ ផ្សេង ៗទៅឲ្យ ដល់ស្ដេចដំរីនោះ ។ ព្រះពោធិសត្វ គិត ថា " អញ ប្រាសចាកពីមាតា នឹងមិនទទួលចំណី " ដូច្នេះ, សូម្បីកាលបើ ព្រះរាជា ទ្រង់ត្រាស់ ថា " នែស្ដេចដំរី ចូរអ្នកទទួលនូវដុំស្មៅចុះ " ដូច្នេះហើយ, ក៏មិនទទួលបាច់ស្មៅ ក្រាបទូល ថា " បពិត្រព្រះមហា រាជ ទូលព្រះបង្គំ ចិញ្ចឹមមាតា ដែលខ្វាក់ភ្នែក, មាតា នៃទូលព្រះ បង្គំ ប្រាសចាកពីទូលព្រះបង្គំហើយ នឹងដល់នូវសេចក្ដីអស់ទៅនៃ ជីវិត, ទូលព្រះបង្គំ អត់អំពីមាតានោះហើយ ក៏មិនមានសេចក្ដីត្រូវ ការ ដោយឥស្សរិយយសដែរ, ថ្ងៃនេះ គឺជាថ្ងៃ ទី ៧ នៃមាតា នៃទូលព្រះបង្គំ អ្នកមិនបានចំណី " ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់ ពាក្យនោះហើយ ទ្រង់ត្រាស់ ថា ÷

" អ្នកទាំងឡាយ ចូរលែងមហានាគ ដែលចិញ្ចឹម
មាតា, សូមមហានាគ ចួបជុំមាតា ព្រមទាំង
ញាតិទាំងឡាយ ទាំងពួងចុះ " ។

បណ្ដាបទទាំងនោះ បទ ថា "**យោយំ**" កាត់បទជា **យោ អយំ** ។ បទ ថា "**សមេតុ**" បានដល់ ចូរមកព្រម ។

លំដាប់នោះ ព្រះពោធិសត្វ រួចផុតពីចំណងហើយ សំដែងធម៌ដល់ព្រះរាជា ដោយគាថាសំដែងអំពីទសរាជធម៌បន្តិចហើយ ថ្វាយនូវឱវាទ ថា "បពិត្រព្រះមហារាជ សូមព្រះអង្គស្ដេច កុំប្រហែសធ្វេសឡើយ" ដូច្នេះហើយ ជាអ្នកគឺមហាជន បូជាហើយ ដោយវត្ថុទាំងឡាយ មានផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ចេញអំពីនគរហើយ ទៅដល់សំណាក់នៃមាតា ក្នុងថ្ងៃនោះឯង ។

ព្រះរាជា ទ្រង់ជ្រះថ្លា ក្នុងគុណនៃព្រះពោធិសត្វ ទ្រង់ត្រាស់បញ្ជាឲ្យកសាងផ្ទះក្នុងទីមិនឆ្ងាយ នៃស្រះបទុម ទ្រង់តាំងវត្តិប្រតិបត្តិជាប់ជានិច្ច, ក្នុងកាលក្រោយមក កាលបើមាតានៃព្រះពោធិសត្វស្លាប់ហើយ, ទ្រង់ត្រាស់បញ្ជាឲ្យធ្វើសរីរកិច្ចមាតាព្រះពោធិសត្វនោះហើយទ្រង់ធ្វើអាស្រមឈ្មោះករណ្ឌកៈ ស្ដេចយាងទៅកាន់ព្រះនគរ ។

ក៏តាបសឥសីប្រមាណ ៥០០ ចុះអំពីព្រៃហេមពាន្ត មកនៅអាស្រ័យ ក្នុងទីនោះ ។ ព្រះរាជា ទ្រង់ត្រាស់ឲ្យព្រះរាជទាន នូវវត្តិប្រតិបត្តិ ដល់តាបសឥសីទាំងនោះ, កាលបើព្រះពោធិសត្វ ស្លាប់ហើយ, ទ្រង់ត្រាស់ឲ្យកសាង នូវរូបសីលា ទំហំប៉ុនរូប របស់ព្រះពោធិសត្វហើយ ទ្រង់ត្រាស់ឲ្យធ្វើនូវមហាសក្ការៈ ។

មនុស្សនៅក្នុងជម្ពូទ្វីប បានប្រជុំគ្នា ធ្វើការឆ្លងជំរឺ ជារៀងរាល់ឆ្នាំ ។

រឿង ស្តេចជំរឺ ចប់ ។

(១៧៨) ព្រះពោធិសត្វទាំងនោះ មានព្រះសុវណ្ណសាមជាដើម រួចផុតពីសេចក្តីទុក្ខនោះ ៗ ហើយ បានដល់នូវប្រយោជន៍សុខ ដោយឧបនិស្ស័យនៃកម្ម គឺការចិញ្ចឹមនូវមាតាបិតា ដោយប្រការៈដូច្នេះ, ព្រោះហេតុនោះ

" បុគ្គលកាលប្រាថ្នា នូវការរួចផុតចាកសេចក្តីទុក្ខ សំឡឹងឃើញនូវប្រយោជន៍ របស់ខ្លួន គប្បីធ្វើ នូវការចិញ្ចឹមព្រហ្ម ( គឺមាតាបិតា ) ដែលជា កិច្ចដ៏ប្រសើរបំផុត គ្រប់កាលទាំងពួង ដូចជា ព្រះពោធិសត្វទាំងនោះដែរ " ។

មួយ៉ាងទៀត ធម្មតា បុគ្គលអ្នកចិញ្ចឹមមាតាបិតា, កាលបើរដ្ឋធានី សូម្បីត្រូវពួកសត្រូវធ្វើឲ្យវិនាស, ក៏រមែងរួចផុតអំពីសេចក្តីអន្តរាយទៅបាន ៗ ក្នុងសេចក្តីនុ៎ះ មានរឿងនេះ (ជាឧទាហរណ៍) ។

( រឿងរាមៈ អ្នកចិញ្ចឹមមាតាបិតា )

(១៧៩) ក្នុងអតីតកាល ព្រះពោធិសត្វជាបុត្រ របស់

បុរោហិត នៃព្រះរាជាក្រុងពារាណសី បានឈ្មោះថា ជោតិបាល ព្រោះអាវុធគ្រប់យ៉ាង បានកើតឡើងភ្លឺរុងរឿង ក្នុងថ្ងៃដែលកូននោះកើតហើយ ។ ក្រោយមក ជោតិបាលនោះ បានសំដែងនូវសិល្បៈធ្នូ មានប្រការផ្សេង ៗ ថ្វាយដល់ព្រះរាជា ដោយន័យដែលបានពោលហើយ ក្នុងអដ្ឋកថាសរភង្គជាតក តាំងពីពេលនោះមក ទើបបានប្រាកដឈ្មោះថា "សរភង្គ" ។

ថ្ងៃមួយ សរភង្គពោធិសត្វនោះ មិនឲ្យអ្នកណាដឹង ចូលទៅព្រៃតែម្នាក់ឯងគត់ហើយ បួសជាតាបសឥសី ក្នុងអាស្រមដែលសក្កទេវរាជប្រទានឲ្យ ក្នុងព្រៃខិត្ត មានទំហំប្រវែង ៣០ យោជន៍ ក្បែរមាត់ស្ទឹងគោធាវរី បានញ៉ាំងឈាននិងអភិញ្ញា ឲ្យកើតឡើងហើយ ក្នុងថ្ងៃទី ៧ ។ ក្រោយមក ព្រះរាជាទាំងឡាយ មានព្រះរាជាក្រុងពារាណសីជាដើម ក៏បួសក្នុងសំណាក់ នៃសរភង្គ-តាបសនោះ ព្រមជាមួយនឹងអ្នកដែន ៗ អាស្រមព្រៃខិត្ត ពេញអស់ហើយ ។

គ្រានោះ អន្តេវាសិកជាចម្បង របស់សរភង្គតាបសម្នាក់ ឈ្មោះថា កិសវច្ឆៈ ប្រាថ្នានៅស្ងប់ស្ងាត់ ទើបទៅអំពីទីនោះហើយ អាស្រ័យនគរ នៃព្រះរាជាទណ្ឌកី ឈ្មោះកុម្ភវតីបុរៈ ក្នុងកលិង្គរដ្ឋ ជាអ្នកគឺសេនាបតីទំនុកបំរុងហើយ នៅក្នុងព្រះរាជឧទ្យាន ។

ក្នុងកាលនោះ ព្រះរាជាព្រះនាមទណ្ឌកី ទ្រង់ត្រាស់បញ្ជាឲ្យដកនូវឋានន្តរស័ក្តិ នៃស្រីពេស្យាម្នាក់ ។ តាំងពីពេលនោះមក ស្រីពេស្យានោះ ធ្វើសន្តវកិច្ច ជាមួយនឹងបុរសនោះៗ ស្វែងរកនូវឋានន្តរស័ក្តិ ថ្ងៃមួយ ទៅកាន់ព្រះរាជឧទ្យាន បានចួបនឹងតាបសនោះហើយ ពោល ថា "អញបានចួបបុរសកាឡកណ្ណីនេះ, អ្នកទាំងឡាយចូរនាំទឹកមក, ខ្ញុំនឹងលាងភ្នែកទាំង ២" ដូច្នេះហើយ ទំពារនូវឈើស្ទន់ហើយ ស្តោះដុំទឹកមាត់ លើសរីរៈនៃតាបស បោះឈើស្ទន់ទៅលើកំពូលនៃជដា ស្រោចស្ទូឡើទឹកខ្ចរមាត់ លើសិរសីនៃតាបសនោះហើយ ដើរចេញទៅ ។

ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់បញ្ជាឲ្យព្រះរាជទានឋានន្តរស័ក្តិដើមនោះឯង ដល់ស្រីពេស្យានោះ ។ នាងសម្គាល់នូវឋានន្តរស័ក្តិដែលនាងបានហើយ ព្រោះអាស្រ័យនូវកុសល ដែលខ្លួនបានធ្វើហើយក្នុងកាលមុន ថា "អាត្មាអញបានឋានន្តរស័ក្តិ ព្រោះការញ៉ាំងដុំទឹកមាត់ឲ្យធ្លាក់ លើសរីរៈនៃតាបស" ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ អំពីថ្ងៃនោះ ព្រះរាជាទ្រង់យកនូវឋានន្តរស័ក្តិ នៃបុរោហិត ។ បុរោហិតនោះ ចូលទៅរកស្រីពេស្យានោះហើយ សួរ ថា "នាងបានធ្វើកម្មអ្វី ទើបបានឋានន្តរស័ក្តិត្រឡប់មកវិញ ?" ដូច្នេះហើយ បានស្តាប់ ថា "ធ្វើកម្មឈ្មោះនេះ" ហើយ ទៅក្នុងទីនោះ បានធ្វើហើយ

យ៉ាងដូច្នោះឯង ក៏ត្រឡប់បាននូវឋានន្តរស័ក្តិជាប្រក្រតី ក្នុងថ្ងៃនោះដូចគ្នាដែរ ។ ឯបុរោហិតនោះ បានហើយនូវឋានន្តរស័ក្តិ ដោយផលនៃបុណ្យ ទើបសម្គាល់ ថា " ខ្លួនបានហើយ ព្រោះការញ៉ាំងទឹកមាត់ឲ្យធ្លាក់ចុះ " ។ ដោយកន្លងទៅ ២ - ៣ ថ្ងៃ អំពីថ្ងៃនោះទៅ បច្ចន្តជនបទនៃព្រះរាជាបះបោរហើយ ។ ព្រះរាជាទ្រង់មានព្រះបំណងនឹងបង្ក្រាប នូវបច្ចន្តជនបទឲ្យស្ងប់សុខ ទ្រង់ជឿពាក្យរបស់បុរោហិតហើយ ទ្រង់ត្រាស់បញ្ជា មនុស្សទាំងអស់ ថា " ពួកអ្នកទាំងឡាយ ចូរស្តោះទឹកមាត់ លើសរីរៈនៃជដិលកោងនុ៎ះ " ។ មនុស្សទាំងអស់នោះ ព្រមទាំងព្រះរាជា បានធ្វើហើយ ដូច្នោះឯង ។ របស់បដិកូលទាំងឡាយ មានទឹកមាត់ជាដើម បានស្រោចពាសពេញហើយ ទូទាំងសរីរៈ របស់តាបស ។ ឯសេនាបតីបានស្តាប់ ខាងក្រោយនៃជនទាំងពួង ទើបប្រញាប់ទៅកាន់ឧទ្យាន បោសនូវវត្ថុដែលមិនស្អាតទាំងអស់នោះចេញ ឲ្យតាបសងូតទឹកហើយពោល ថា "បពិត្រលោកម្ចាស់ កម្មមិនគួរដែលជនទាំងនោះធ្វើហើយ ផលបែបណា នឹងមានដល់ជនទាំងនុ៎ះ ? " ។ តាបសពោល ថា "សេចក្តីប្រទូសរ៉ាយនៃចិត្ត របស់អាត្មាភាព មិនមានឡើយ, ចំណែក ទេវតាក្រោធខឹងខ្លាំងណាស់, ក្នុងថ្ងៃទី ៧ អំពីថ្ងៃនោះទៅ ទេវតាទាំងឡាយ នឹងធ្វើនូវរដ្ឋទាំងមូល មិនឲ្យទៅជារដ្ឋ, ព្រោះហេតុនោះ

ចូរអ្នក ទៅខាងក្រៅរដ្ឋធានី ក្នុងរវាង ៧ ថ្ងៃចុះ" ។ សេនាបតីនោះ បានធ្វើហើយ យ៉ាងដូច្នោះ ។ ចំណែក ព្រះរាជាគ្រាន់តែស្ដេចយាងទៅដល់ប៉ុណ្ណោះ ក៏បង្ក្រាបជនបទឲ្យបានស្ងប់ហើយ ទើបស្ដេចយាងមកកាន់ព្រះនគរវិញ ។ ក្នុងថ្ងៃនោះឯង ទេវតាទាំងឡាយញុំាងភ្លៀងឲ្យធ្លាក់ចុះហើយ ។ មនុស្សទាំងឡាយ បានមានចិត្តរីករាយហើយ ថា " តាំងពីពេលដែលពួកយើងចៀសចៀន ចំពោះជដិលកោងមក សេចក្ដីចំរើន ក៏កើតមាន ដល់ព្រះរាជាតែម្យ៉ាង, ក្នុងថ្ងៃដែលព្រះអង្គស្ដេចបង្ក្រាបជនបទ ឲ្យបានស្ងប់សុខហើយ ស្ដេចយាងមកនុ៎ះឯង ភ្លៀងក៏បានធ្លាក់ចុះមកហើយ" ។ លំដាប់នោះ ពួកទេវតាទាំងឡាយ ញុំាងភ្លៀងផ្កាម្លិះ ភ្លៀងមាសក ភ្លៀងកហាបណៈ និងភ្លៀងគ្រឿងប្រដាប់ ដែលគេធ្វើហើយ សំរាប់ប្រដាប់ដៃ- ជើងជាដើម ឲ្យធ្លាក់ចុះហើយ ។ ព្រោះហេតុនោះ មនុស្សទាំងឡាយមានចិត្តត្រេកអរ យ៉ាងក្រៃលែង បញ្ចេញវាចា ដោយចិត្តរីករាយមានសេចក្ដីត្រេកអរគាម ក្នុងបាបដែលព្រះរាជាទ្រង់បានធ្វើហើយ ។

ក្នុងកាលនោះ ទេវតាទាំងឡាយ ញុំាងភ្លៀងសាស្ត្រាវុធដែលមុតតែម្ខាងជាដើម ភ្លៀងរងើកភ្លើង ដែលមិនមានផ្សែងភ្លៀងដុំថ្មប្រមាណប៉ុនផ្ទះកំពូល និងភ្លៀងដីខ្សាច់ ឲ្យធ្លាក់ចុះហើយធ្វើរដ្ឋធានី ឲ្យទួលកំពស់ ៨០ ហត្ថ ។ ក៏កាលបើរដ្ឋធានី មិន

ទាន់វិនាសសាបសូន្យនៅឡើយ, សរភង្គតាបស ដឹងរឿងនោះហើយ ក៏បញ្ជូនតាបសដែលក្មេង ៗ ២ រូបទៅ ឲ្យនាំកិសវច្ឆតាបសមក តាមផ្លូវអាកាស ដោយក្រែស្អែង ៗ ឯសេនាបតី ចេញទៅហើយ ដោយខ្លួនឯងតែម្តង ៗ ក៏ទឹកផឹកនិងស្មៅ សម្រាប់ពួកសត្តិរច្ឆាន ដែលមិនបាននិយមតាម ក្នុងកម្មនោះ មិនបានមានឡើយ ៗ សត្តិរច្ឆានទាំងនោះ ក៏ទៅតាមទីកន្លែង ដែលមានទឹកផឹកនិងស្មៅ, កាលបើថ្ងៃទី ៧ មិនទាន់មកដល់នុ៎ះឯង, ក៏បានទៅដល់ខាងក្រៅរដ្ឋធានី ៗ ក៏បុរសម្នាក់ ឈ្មោះរាមៈ គឺពួកទេវតា ជួយនាំចេញយកមក ខាងក្រៅនៃរដ្ឋធានីនោះ ៗ ដោយហេតុនោះ ក្នុងអដ្ឋកថាជយទិសជាតក ក្នុងតឹសនិបាត លោកពោលហើយ ថា "បានឮមកថា បុរសអ្នករស់នៅ ក្នុងក្រុងពារាណសីម្នាក់ ជាអ្នកចិញ្ចឹមមាតា ទំនុកបំរុងមាតាបិតា ទៅហើយដើម្បីលក់ដូរ ដល់នគរឈ្មោះកុម្ភវតីបុរៈ ក្នុងរដ្ឋធានី នៃព្រះរាជាទ្រង់ព្រះនាមទណ្ឌកីហើយ, កាលបើរដ្ឋធានីទាំងមូល ត្រូវភ្លៀងទាំង ៩ ប្រការ ធ្វើឲ្យវិនាស, ក៏បានរឭកដល់គុណនៃមាតាបិតា ៗ គ្រានោះ ទេវតាទាំងឡាយ បាននាំបុរសដែលចិញ្ចឹមមាតានោះ ទៅប្រគល់ឲ្យដល់មាតា ដោយសុវត្ថិភាព ព្រោះផលនៃកម្ម គឺការទំនុកបំរុងមាតា" ៗ ចំណែកជនដទៃទៀតក្រៅពីនោះ បានដល់ហើយ នូវសេចក្តីវិនាស ដូច្នេះឯង ៗ

រឿងបុរសឈ្មោះរាមៈ អ្នកចិញ្ចឹមមាតា មកក្នុងអដ្ឋកថាឧបាលីសូត្រ មជ្ឈិមបណ្ណាសកៈ និងក្នុងអដ្ឋកថាសរភង្គជាតក ។

(១៨០) ព្រោះហេតុនោះ ធម្មតាបុត្រ គប្បីជាអ្នកមានចិត្តរឹងប៉ឹងស្ថិតថេរ ក្នុងកម្ម គឺការទំនុកបំរុង ដូចជាឧបាសកអ្នកចិញ្ចឹមមាតា ។ មួយវិញទៀត បុត្រគប្បីប្រតិបត្តិ ដោយប្រការដែលខ្លួនគប្បីបាន ដើម្បីនឹងទំនុកបំរុង មាតាបិតា ឲ្យដូចជានន្ទបណ្ឌិត ។

## ( រឿងឧបាសកអ្នកចិញ្ចឹមមាតាបិតា )

បានឮមកថា ឧបាសកម្នាក់ ក្នុងក្រុងសាវត្ថី, កាលបើបិតាធ្វើមរណកាលហើយ, ជាអ្នកមានមាតាដូចជាទេវតា ប្រតិបត្តិនូវមាតា ដោយកិច្ចមានការឲ្យទឹកលាងមុខ និងឈើស្ទន់ជាដើម និងដោយវត្ថុ មានយាគូ និងភត្តជាដើម ។ ឯមាតា និយាយរឿយៗ ចំពោះបុត្រនោះ, កាលបើបុត្រនោះ មិនប្រាថ្នាចង់បាននុះឯង, ទើបនាំនាងកុមារិកាមកឲ្យ ។ បុត្រនោះ សម្រេចការនៅរួម ជាមួយនឹងស្ត្រីនោះ ។ ឯស្ត្រីនោះប្រតិបត្តិមាតា នៃបុរសនោះ ដោយសេចក្តីគោរព លុះក្រោយមក ជាអ្នកមានបំណងចង់ ឲ្យប្តីនាំយកមាតានោះ ចេញទៅខាងក្រៅ ថ្ងៃមួយ និយាយនឹងប្តី ថា " ម្នាលអ្នកប្តី កាលបើបងទៅខាងក្រៅ, មាតាបង តែងជេរស្តីខ្ញុំ " ។

បុរសជាប្ដីនោះ បាននៅស្ងៀម ៗ តាំងតែពីពេលនោះមក ភរិយានោះ កាលឲ្យបបរ តែងឲ្យបបរ ដែលក្ដៅពេក ឬត្រជាក់ពេក ប្រៃពេក ឬសាបពេក, កាលបើម្ដាយក្មេក ពោល ថា " នែនាងបបរក្ដៅពេក ប្រៃពេក " ដូច្នេះ, ក៏ថែមទឹកត្រជាក់ចូលទៅ, បើម្ដាយក្មេក ពោលទៀត ថា "ត្រជាក់ពេក មិនប្រៃសោះ" ដូច្នេះ, ក៏ស្រែកយ៉ាងខ្លាំង ថា "អម្បាញ់មិញនេះឯង ពោល ថា 'ក្ដៅពេក ប្រៃណាស់ ' ដូច្នេះហើយ នៅតែពោល (ទៀត) ថា 'ត្រជាក់ពេក មិនប្រៃសោះឡើយ ' ដូច្នេះ, នរណា នឹងអាចដើម្បី នឹងឲ្យយាយចាស់នេះត្រេកអរបាន " ដូច្នេះ, នាងធ្វើស្ងួម្បីទឹកសម្រាប់ងូត ក៏ឲ្យក្ដៅហួសពេកហើយ ស្រោចទៅលើខ្នង, កាលបើម្ដាយក្មេក ពោល ថា "ក្ដៅណាស់ " ក៏ចាក់ទឹកត្រជាក់ទៅ, បើម្ដាយក្មេក ពោល ថា "ត្រជាក់ណាស់ " ក៏ពោល ថា "អម្បាញ់មិញនេះឯង ពោល ថា 'ក្ដៅពេក ' ដូច្នេះហើយ នៅតែពោលទៀត ថា 'ត្រជាក់ពេក ' ដូច្នេះ, នរណា អាចដើម្បី នឹងអត់ទ្រាំ នឹងការមើលងាយរបស់ម៉ែឯងបាន " ។ ភរិយានោះ បានធ្វើការឈ្លោះប្រកែក ជាមួយនឹងម្ដាយក្មេកហើយ ពោលប្រាប់ប្ដី ថា "នាងខ្ញុំ មិនអាចនឹងនៅ ក្នុងផ្ទះជាមួយគ្នា នឹងម្ដាយក្មេកកាឡកណ្ណី រូបនេះបានឡើយ, សូមបង ឲ្យម្ដាយក្មេកនុ៎ះ នៅខាងក្រៅចុះ " ។ ប្ដីនោះ ពោល ថា

" នែនាងដ៏ចំរើន អូនឯងនៅក្មេង ទៅទីកន្លែងណាមួយហើយ នឹងអាចរស់នៅបានដោយពិត, ឯមាតារបស់បង ជាអ្នកទុព្វលភាព, បងប៉ុណ្ណោះ ជាទីពឹងរបស់មាតានោះ, អូនឯង ចូរចេញទៅកាន់ផ្ទះនៃត្រកូលរបស់អូនចុះ " ។ ភរិយានោះគិតថា " បើសិនជាអញនឹងទៅផ្ទះនៃត្រកូល, អញនឹងនៅជាស្រីមេម៉ាយ នឹងកើតទុក្ខ " ដូច្នេះហើយ ភ័យខ្លាច មិនបានទៅ ប្រតិបត្តិធ្វើឲ្យម៉ែក្មេកត្រេកអរដោយន័យមុនន៉ុះឯង ។

ក្រោយមក ថ្ងៃមួយ ឧបាសកបានទៅវត្តជេតពន ដើម្បីស្តាប់ធម៌ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរ ជាអ្នកគឺព្រះសាស្តាត្រាស់សួរ ថា " នែឧបាសក អ្នកមិនប្រមាទ ក្នុងបុញ្ញកម្ម, បំពេញកម្ម គឺការទំនុកបំរុងមាតា មែនឬ ? " ដូច្នេះហើយ ទើបក្រាបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន ពិតមែនហើយ " ហើយក្រាបទូលរឿងទាំងអស់ ។ ព្រះសាស្តាទ្រង់ត្រាស់ ថា " នែឧបាសក អ្នកមិនបានជឿតាមពាក្យ របស់ស្រីនោះ នៅក្នុងកាលឥឡូវនេះតែប៉ុណ្ណោះទេ, ប៉ុន្តែក្នុងកាលមុន អ្នកបាននាំមាតារបស់អ្នកចេញទៅក្រៅ ព្រោះតែពាក្យ របស់ស្រីនោះហើយ អាស្រ័យតថាគតទើបនាំមាតានោះ ត្រឡប់មកកាន់ផ្ទះវិញហើយ ប្រតិបត្តិ ដូចដើម " ដូច្នេះហើយ ទ្រង់ត្រាស់កច្ចានីជាតក ក្នុងអដ្ឋកនិបាត ទ្រង់ប្រកាស

ហើយ នូវសច្ចៈទាំងឡាយ ។ ក្នុងទីបញ្ចប់នៃសច្ចៈ ឧបាសកបាន សម្រេចជាព្រះសោតាបន្ន ។

រឿង ឧបាសកអ្នកចិញ្ចឹមមាតា ចប់ ។

## ( រឿងនាងកច្ចានី )

(១៨១) ក្នុងអតីតកាល បុរសម្នាក់ ក្នុងក្រុងពារាណសី កាលបើបិតាមរណកាលទៅហើយ, ជាអ្នកមានមាតាដូចជាទេវតា ប្រតិបត្តិមាតា ឈ្មោះកច្ចានី ដោយន័យដែលបានពោលមកហើយ នុ៎ះឯង ។ រឿងទាំងអស់ ដូចគ្នានឹងរឿងដែលបានពោលហើយ ។ ពេលនោះ បុរសនោះ ជឿពាក្យរបស់ភរិយាហើយ ពោលនឹងមាតាថា "សូមម៉ែចេញអំពីទីនេះទៅ, សូមម៉ែនៅ ក្នុងទីកន្លែងដែលម៉ែពេញចិត្តចុះ" ។ នាងកច្ចានីនោះ ក៏ស្រែកយំ ដើរចេញទៅអាស្រ័យត្រកូល ស្កុកស្គមមួយ ធ្វើការស៊ីឈ្នួលគេ មកចិញ្ចឹមជីវិតដោយសេចក្តីលំបាក ។ ក៏ក្នុងពេលដែលនាងកច្ចានីនោះ ចេញទៅហើយ កូនប្រសា ក៏មានផ្ទៃពោះ តមក ក៏សម្រាលបុត្រចេញមកហើយ ពោលនឹងស្វាមី ថា "កាលបើមាតា របស់បង នៅក្នុងផ្ទះ, នាងខ្ញុំមិនបានបុត្រ, ឥឡូវនេះ នាងខ្ញុំបានបុត្រហើយ, ដោយហេតុនេះ សូមបងដឹងថា មាតារបស់បងនោះ ជាស្រីកាឡកណ្ណី" ។

ឯនាងកច្ចានី បានស្ដាប់ ថា “បានឮថា ក្នុងពេលដែលអាត្មាអញត្រូវកូនយកចេញហើយ (អំពីផ្ទះ) កូនប្រសា បានបុត្រហើយ ” ដូច្នេះហើយ ទើបគិត ថា “ធម៌គឺការប្រព្រឹត្តិឱនលំទោន ចំពោះអ្នកដែលចំរើន និងធម៌គឺសេចក្ដីសុចរិត ៣ យ៉ាង ក្នុងលោកនេះ នឹងជាធម៌ដែលស្លាប់បាត់ទៅហើយ ដោយពិត, ព្រោះថា ប្រសិនបើ ធម៌មិនគប្បីស្លាប់ទេនោះ, បុគ្គល គប់ទះនាំមាតាចេញក្រៅហើយ ក៏មិនគប្បីបាននូវបុត្រ, មិនគប្បីនៅជាសុខ, អាត្មាអញ នឹងឲ្យមតកភត្តដល់ធម៌ ” ដូច្នេះហើយ កាន់យកនូវវត្ថុទាំងឡាយ មានល្ង ម្សៅនិងអង្ករជាដើម ទៅកាន់ទីស្មសានហើយ យកក្បាលមនុស្ស ៣ មកធ្វើជាជើងក្រានហើយ ដុតភ្លើង ប្រារព្ធដើម្បី នឹងលាងអង្ករ ៗ

ក្នុងខណៈនោះឯង សក្កទេវរាជ ទ្រង់ប្រមើលមើលសត្វលោក ឃើញនាងកច្ចានីនោះ បានសេចក្ដីទុក្ខ ប្រាថ្នានឹងឲ្យមតកភត្តដល់ធម៌ ដោយសេចក្ដីសម្គាល់ ថា “ធម៌ស្លាប់បាត់ហើយ ” ទើបក្រឡាខ្លួនជាព្រាហ្មណ៍ ចូលទៅរកនាង ហើយត្រាស់ ថា “ធម៌មិនស្លាប់ទេ” ដូច្នេះហើយ ស្ថិតនៅឰដ៏អាកាស ត្រាស់ ថា “នែនាងកច្ចានី ចូរនាង កុំបីភ័យខ្លាចឡើយ, កូន ចៅ និងកូនប្រសា របស់នាង នឹងមកហើយ នាំយកនាងទៅ ដោយអានុភាពនៃយើង ” ដូច្នេះហើយ ស្ដេចយាងទៅឋាន របស់ព្រះអង្គវិញតែម្ដង ៗ ជនទាំង ៣ នាក់

មានកូន ចៅ និងកូនប្រសានោះ រលឹកនូវគុណ របស់នាងកច្ចានីនោះ ដោយអានុភាពនៃសក្កទេវរាជ ទើបដើរទៅកាន់ផ្លូវ ដែលទៅកាន់ទីស្មសាន ចួបនាងកច្ចានីនោះ ក្នុងចន្លោះផ្លូវហើយ ក្រាបក្បែរជើងទាំងពីរ សុំខមាទោសហើយ នាំទៅផ្ទះ នៅរួមសាមគ្គីគ្នា តាំងតែពីពេលនោះមក ។

រឿង នាងកច្ចានី ចប់ ។

## ( រឿងតាបសបងប្អូនគ្នា ២ នាក់ )

(១៨២) ក្នុងអតីតកាល តាបសបងប្អូនគ្នា ២ នាក់ គឺ តាបសជាបង ឈ្មោះសោណបណ្ឌិត ប្អូនឈ្មោះនន្ទបណ្ឌិត ចិញ្ចឹមមាតាបិតា នៅក្នុងហិមវន្តប្រទេស ។ បណ្ដាតាបសទាំង ២ នាក់នោះ តាបសជាបង ទៅកាន់ទីឆ្ងាយក៏បាន ព្រោះបានអភិញ្ញា ៥ នាំផ្លែឈើដែលមានឱជារសមកឲ្យ ( ម្ដាយឪពុក ) ខាងក្រោយ ៗ ឯតាបសជាប្អូន នាំយកផ្លែឈើគ្រប់យ៉ាង ក្នុងទីជិត មកឲ្យមុន ៗ តាបសជាប្អូននោះ សូម្បីតាបសជាបងប្រាប់ ថា “សូមប្អូន កុំធ្វើយ៉ាងដូច្នេះឡើយ ”ដូច្នេះ ក៏នៅតែមិនស្ដាប់ពាក្យដែរ ។ គ្រានោះ តាបសជាបងពោល ថា “នែនន្ទៈ អ្នកជាបុគ្គល គឺគេមិនគប្បីនឹងប្រៀនប្រដៅ មិនធ្វើតាមពាក្យបណ្ឌិតឡើយ, ធម្មតាមាតានិងបិតា

ជាភារៈរបស់បង, បងម្នាក់ឯង នឹងប្រតិបត្តិនូវមាតាបិតា ទាំងពីរនាក់នោះ, សូមប្អូន កុំនៅក្នុងទីនេះ, ចូរទៅ ក្នុងទីដទៃទៅ" ។ នន្ទតាបស មិនអាចនឹងទ្រាំនៅបាន ទើបចូលទៅ កាន់បណ្ណសាលារបស់ខ្លួនហើយ ពិចារណាកសិណ ញ៉ាំងឈាននិងអភិញ្ញា ឲ្យកើតឡើងហើយ ក្នុងថ្ងៃនោះឯង ហើយគិត ថា "អាត្មាអញ នឹងនាំព្រះរាជា ១០១ ព្រះអង្គ មកហើយ ញ៉ាំងបងប្រុស ឲ្យអត់ទោសឲ្យហើយ សុំដើម្បីនឹងទំនុកបំរុងមាតាបិតា" ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះរាជាក្រុងពារាណសី ទ្រង់ព្រះនាមមនោជៈ ដោយឫទ្ធិហើយ ក្រាបទូល ថា "បពិត្រព្រះមហារាជ អាត្មាភាព នឹងយករាជសម្បត្តិ ក្នុងជម្ពូទ្វីបទាំងមូល ដោយកម្លាំង របស់អាត្មាភាពហើយ ថ្វាយដល់ព្រះអង្គ, សូមព្រះអង្គ ទ្រង់ស្ដេចយាងចេញទៅក្នុងថ្ងៃនេះ តែម្ដង" ។ ព្រះរាជា ទ្រង់បានធ្វើ ដូច្នោះហើយ ។ បើថ្ងៃក្ដៅមាន ដល់កងទ័ព, នន្ទតាបស ក៏ធ្វើម្លប់ហើយ ធ្វើឲ្យត្រជាក់, បើមានភ្លៀងធ្លាក់, ក៏ (ធ្វើ) មិនឲ្យភ្លៀងស្រក់មកលើ, ហាមឃាត់បានទាំងក្ដៅ ត្រជាក់ និងខ្យល់, ញ៉ាំងដង្គត់និងបន្លា ជាដើម ក្នុងមាគ៌ា ឲ្យអន្តរធានអស់ហើយ ធ្វើមាគ៌ាឲ្យរាបស្មើ ដូចជាមណ្ឌលនៃកសិណ ។ នន្ទតាបសនោះ ក្រាលកំណាត់ស្បែក ព្ធដ៏អាកាសហើយអង្គុយ មានសេនាចោមរោម បានទៅកាន់ទីក្រុង

កោសលមុនគេហើយ បញ្ជូនទូតទៅ ថា " ព្រះរាជាក្រុងកោសល នឹងឲ្យការប្រយុទ្ធ ដល់ពួកយើង ឬព្រមនៅក្នុងអំណាច របស់ពួកយើង " ។ ព្រះរាជាក្រុងកោសល ទ្រង់ព្រះពិរោធហើយ ស្តេចចេញទៅដើម្បីនឹងប្រយុទ្ធគ្នា ។ នន្ទតាបស លាតស្បែកខ្លាធ្វើឲ្យធំ ក្នុងចន្លោះនៃកងទ័ពទាំង ២ បក្ស ទទួលនូវកូនសរ ដែលគេបាញ់ចេញមកហើយ ៗ ។ បណ្តាទាហានទាំងនោះ សូម្បីទាហានម្នាក់ ឈ្មោះថា ត្រូវគេបាញ់ ដោយកូនសរ មិនមានឡើយ ។ ទាហានទាំងនោះ អស់កូនសរហើយ មិនមានសេចក្តីព្យាយាម បានឈរនៅហើយ ។ នន្ទតាបស ក្រាបទូលព្រះរាជាក្រុងកោសល ថា " សូមព្រះអង្គ កុំបីភ័យខ្លាចឡើយ, រាជសម្បត្តិ របស់ព្រះអង្គ នឹងនៅជារាជសម្បត្តិ របស់ព្រះអង្គដូចដើម, ប៉ុន្តែ សូមព្រះអង្គ ទ្រង់នៅក្នុងអំណាច នៃព្រះរាជា ព្រះនាមមនោជៈ តែម្យ៉ាង " ។ ឯព្រះរាជាក្រុងកោសលនោះ ទ្រង់យល់ព្រមហើយ ចោមរោមព្រះរាជា ក្រុងពារាណសី ទើបបានស្តេចយាងទៅកាន់ទីក្រុងអង្គៈ ។ ដោយន័យនេះ អស់រយៈពេល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ នន្ទតាបស ដណ្តើមយករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ថ្វាយដល់ព្រះរាជា ព្រះនាមមនោជៈ ធ្វើព្រះរាជាព្រះនាមមនោជៈនោះ ឲ្យជាប្រមុខនៃព្រះរាជាទាំង ១០១ ព្រះអង្គហើយ នាំព្រះរាជាគ្រប់ព្រះអង្គនោះ មកកាន់សំណាក់ នៃ

គាបសជាបង ញ៉ាំងគាបសជាបងនោះ ឲ្យអត់ទោសហើយ សូមនូវការចិញ្ចឹមមាតាបិតា ។ ចំណែក ព្រះពោធិសត្វ មានចិត្តត្រេកអរហើយ ពោល ថា “ឥឡូវនេះ បងអត់ទោសឲ្យប្អូន, ប្អូននឹងបានទំនុកបំរុងម្នាក់ ក្នុងចំណោមមាតាបិតា (ទាំង ២)” ។ គ្រានោះមាតា ប្រាប់ ដល់ព្រះពោធិសត្វនោះ ថា “នែសោណបណ្ឌិត កូន ! ប្អូនប្រុស របស់កូន បានចាកចេញទៅយូរហើយ, ប្អូនប្រុស របស់កូននោះ ចូរទំនុកបំរុងម្តាយ, កូនឯង ចូរទំនុកបំរុងបិតាចុះ” ។ ព្រះពោធិសត្វ ទទួលពាក្យមាតាហើយ ពោល ថា “នែនន្ទៈ ចំណែកដ៏ប្រសើរបំផុត គឺប្អូនបានហើយ, ប្អូនមិនគប្បីប្រមាទ ទំនុកបំរុង (មាតា) ចុះ” ដូច្នេះហើយ កាលប្រកាសគុណនៃមាតា ទើបបានពោលនូវគាថាទាំងឡាយ ២ ក្នុងសោណនន្ទជាតក ថា ÷

(១៨៣) “ម្នាលឥសី មាតាជាអ្នកឈើឆ្កាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ ទេវលោក ប្រាថ្នាចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ ទេវលោក ម្នាលឥសី មាតា ប្រាថ្នាចង់បានអ្នក” ។

បណ្ដាបទទាំងនោះ បទ ថា "**អនុកម្បកា**" បានដល់ ជាអ្នកមានហឫទ័យទន់ភ្លន់ ។ ២ បទ ថា "**បុព្វេ រសទទី**" បានដល់ ជាអ្នកឲ្យរសពោលគឺទឹកដោះ ដល់ខ្លួន ជាបឋមមែនពិត ។ បទ ថា "**វរតេ**" មានសេចក្ដីថា មាតាមិនប្រាថ្នាបងទេ, ប្រាថ្នាប្អូន ។ ពាក្យថា "**ឥសេ**" ជាអាលបនៈ ។ អធិប្បាយថា "ម្នាលនន្ទតាបស ដ៏ចំរើន" ។ បទ ថា "**គោត្តី**" ប្រែថា ជាអ្នកគ្រប់គ្រង ។ បទ ថា "**បុញ្ញូបសញ្ហិតា**" បានដល់ អ្នកចូលទៅអាស្រ័យបុណ្យ គឺអ្នកឲ្យបុណ្យ ។

(១៨៤) ឥឡូវនេះ ព្រះពោធិសត្វ កាលសំដែង (សេចក្ដីនេះ) ដល់បរិស័ទ ព្រមទាំងព្រះរាជា ថា "បុត្រកាលប្រតិបត្តិខុសក្នុងមាតាបិតា រមែងបាន នូវផលដែលមិនជាប្រយោជន៍នេះ, កាលប្រតិបត្តិត្រូវ ក្នុងមាតាបិតា រមែងបាន នូវផលដែលជាប្រយោជន៍នេះ" ដូច្នេះហើយ បានពោល នូវគាថានេះ ថា ÷

" សត្វដែលមាតាចិញ្ចឹម ដោយត្រដាបត្រដួស យ៉ាងនេះហើយ មិនបំរើមាតា, គេប្រព្រឹត្តខុស ក្នុងមាតា តែងទៅកើត ក្នុងនរក ។ សត្វដែលបិតា ចិញ្ចឹម ដោយត្រដាបត្រដួស យ៉ាងនេះហើយ មិនបំរើបិតា,

គេប្រព្រឹត្តខុស ក្នុងបិតា តែងទៅកើត ក្នុងនរក ។ យើងបានឮមកថា 'សូម្បីតែទ្រព្យ របស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ' ឬ កូននោះ រមែងដល់នូវភាពក្រីក្រលំបាក ព្រោះមិនបំរើ នូវមាតា ។ យើងបានឮមកថា 'សូម្បីតែទ្រព្យ របស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ' ឬ កូននោះ រមែងដល់នូវភាពក្រីក្រលំបាក ព្រោះមិនបំរើនូវបិតា(១) ។ បណ្ឌិតបំរើមាតា គប្បីបាននូវសេចក្ដីសុខ ៣ យ៉ាងនេះគឺ សេចក្ដីត្រេកអរ ១ សេចក្ដីរីករាយសប្បាយ ១ ការសើចលេងសព្វៗកាល ១ ។ បណ្ឌិតបំរើបិតា គប្បីបាន នូវសេចក្ដីសុខ ៣ យ៉ាងនេះ គឺ សេចក្ដីត្រេកអរ ១ សេចក្ដីរីករាយសប្បាយ ១ ការសើចលេងសព្វៗកាល ១ ។ សង្គហធម៌ទាំងឡាយនុ៎ះឯង គឺ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ ក្នុងលោកនេះ ១ ភាពនៃបុគ្គលជាអ្នកមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ រមែងប្រព្រឹត្តទៅ ក្នុងលោក ដូចជាភ្លៅនៃកង់រថ ដែលកំពុងវិលទៅ, ក៏បើសង្គហធម៌

ទាំងនុ៎ះ មិនមានទេ, មាតាមិនត្រូវបាន នូវសេចក្ដីរាប់អាន និងការបូជា ព្រោះហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្ដីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ។ ក៏ព្រោះ ពួកបណ្ឌិត រមែងឃើញដោយល្អ នូវសង្គហធម៌ទាំងនុ៎ះ ហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរផង " ។

(១៨៥) អដ្ឋកថាជាតក ថា " បណ្ដាបទទាំងនោះ បទ ថា កិច្ឆាភតោ ប្រែថា ជាអ្នក គឺមាតាចិញ្ចឹម គឺប្រតិបត្តិមកហើយដោយលំបាក ។ ពាក្យថា " មិច្ឆា ចរិត្វាន " គឺ មិនប្រតិបត្តិនូវមាតា ។ បទ ថា " ធនម្បិ " មានសេចក្ដីថា យើងបានឮមក ថា ' សូម្បីទ្រព្យដែលកើតឡើងហើយ របស់បុគ្គលអ្នកប្រាថ្នាចង់បានទ្រព្យ, បើពួកគេ មិនប្រណិបត្តិមាតា, រមែងវិនាសទៅវិញ ' ។ បទ ថា " កិច្ឆំ វា " មានសេចក្ដីថា ទ្រព្យរមែងវិនាសទៅ ឬ កូននោះ រមែងដល់នូវសេចក្ដីទុក្ខ ដោយប្រការដូច្នេះ ។ ២ បទ ថា " លព្ភមេតំ វិជានតា " មានសេចក្ដីថា បណ្ឌិតប្រតិបត្តិមាតាហើយ គប្បីបាននូវសេចក្ដីសុខ មានការត្រេកអរជាដើម ក្នុងលោក

នេះ និងក្នុងទេវលោកនុ៎ះ ៗ អធិប្បាយថា បុគ្គលដូច្នោះអាចបាន ៗ

បទ ថា "ទានញ្ច" មានសេចក្ដីថា បុត្រគប្បីឲ្យទាន ដល់មាតាបិតា គប្បីពោលពាក្យ ដែលជាទីស្រឡាញ់, គប្បីប្រព្រឹត្តប្រយោជន៍ ដោយអំណាចជួយកិច្ច ដែលកើតឡើងឲ្យសម្រេច គប្បីធ្វើភាពនៃបុគ្គលជាអ្នកមានខ្លួនស្មើ ក្នុងធម៌គឺការប្រព្រឹត្តិឱនលំទោន ដល់អ្នកដែលចំរើនដោយគុណទាំងឡាយ ដោយសាមីចិកម្មមានការក្រាបថ្វាយបង្គំជាដើម ដល់មាតាបិតាដែលទៅ ក្នុងទីនោះៗ គឺ ក្នុងទីជំនុំនៃបរិស័ទ ឬ ក្នុងទីស្ងាត់កំបាំង, ធ្វើសាមីចិកម្ម មានការក្រាបថ្វាយបង្គំជាដើម ក្នុងទីស្ងាត់កំបាំងហើយ នឹងមិនគប្បីធ្វើ ក្នុងបរិស័ទ ក៏ទេដែរ, ចាំបាច់ត្រូវតែជាអ្នកស្មើ ក្នុងទីទាំងពួងតែម្ដង" ៗ

អដ្ឋកថាសិគាលសូត្រ ថា "២ បទ ថា តត្ថ តត្ថ គឺក្នុងបុគ្គលនោះ ៗ ៗ បាទគាថា ថា "រថស្សាណីវ យាយតោ" មានសេចក្ដីថា កាលបើភ្លៅនៃកង់រថមាន, រថក៏បរទៅបាន, កាលបើភ្លៅនៃកង់រថ មិនមានទេ, រថក៏បរទៅមិនបានដែរ យ៉ាងណាមិញ, កាលបើធម៌គ្រឿងសង្គ្រោះទាំងនេះ មាននៅ, លោកទើបប្រព្រឹត្តទៅបាន, កាលបើសង្គហធម៌ទាំងនេះ មិនមាននៅទេ, លោកក៏ប្រព្រឹត្តទៅមិនបាន យ៉ាងដូច្នោះដែរ " ៗ

ដីកាសិគាលសូត្រនោះ ថា " ២ បទ ថា 'តស្មឹ តស្មឹ'

មានសេចក្ដីថា ក្នុងបុគ្គលនោះ ៗ គឺអ្នកដែលគួរសង្គ្រោះ ដោយសង្គហធម៌ទាំងឡាយ មានទានជាដើម ៗ កាលបើភ្លៅនៃកង់រថដែលនៅត្រង់ដើមភ្លៅ ៗ បទថា "**យាយតោ**" ប្រែថា ទៅ"ៗ

បាទគាថា ថា "**ឯតេ ច សង្គហា នាស្សុ**" មានសេចក្ដីថា បើសង្គហធម៌ ៤ យ៉ាងនេះ មិនគប្បីមានទេ ៗ បាទគាថា ថា "**ន មាតា បុត្តការណា**" មានសេចក្ដីថា ប្រសិនបើ មាតា មិនគប្បីធ្វើសង្គហធម៌ទាំងនុ៎ះ ដល់បុត្រទេ, ក៏មិនគប្បីបាន នូវការរាប់អាននិងការបូជា ព្រោះហេតុនៃបុត្រ ៗ ២ បទថា "**សង្គហា ឯតេ**" ជាបឋមាវិភត្តិ ចុះក្នុងទុតិយាវិភត្តិ ៗ បាលីថា "**សង្គហេ ឯតេ**" ដូច្នេះ ក៏មានដែរ ៗ

(១៨៦) ក្នុងដីកាសិគាលសូត្រ លោកពោល ថា "បទថា **បុត្តការណា** គឺ មានបុត្រជានិមិត្ត ៗ មែនពិត មាតាបិតា មិនគប្បីបាន នូវការរាប់អាន និងការបូជា មានបុត្រជាហេតុ គឺ ដែលបុត្រគប្បីធ្វើ ៗ បទថា "**ឧបយោគវចនេ**" ប្រែថា ក្នុងអត្ថនៃទុតិយាវិភត្តិ ៗ អត្ថៈ ឈ្មោះថា វចនៈ ព្រោះវិគ្រោះ ថា 'គឺបុគ្គលតែងពោល' ៗ ម្យ៉ាងទៀត បទថា "**ឧបយោគវចនេ**" ប្រែថា កាលបើទុតិយាវិភត្តិ គឺព្រះអង្គគប្បីសំដែង ៗ បទថា "**បច្ចត្តំ**" ប្រែថា បឋមាវិភត្តិ " ៗ

បទ ថា "សមវេក្ខិត្វា" មានសេចក្ដីថា ឃើញដោយល្អ គឺពិចារណាឃើញ នូវសង្គហធម៌ទាំងនុ៎ះ ដែលបុគ្គលគប្បីធ្វើ ដោយត្រឹមត្រូវតែម្ដង ៗ បទ ថា "មហត្តំ" គឺ នូវភាពជាធំ ៗ បទ ថា "បាសំសា" គឺ ដែលបណ្ឌិតគប្បីសរសើរ ៗ អធិប្បាយថា "បណ្ឌិតទាំងនោះ ត្រូវពួកជនសរសើរ យ៉ាងនេះ ថា 'រមែងប្រព្រឹត្តក្នុងបុគ្គលដែលគួរសង្គ្រោះនោះ ៗ តាមសមគួរ" ។

ព្រះរាជាទាំងឡាយ ព្រមទាំងបរិស័ទ ទ្រង់បានស្ដាប់ពាក្យនោះហើយ ទ្រង់ជ្រះថ្លា ត្រូវព្រះមហាសត្វឲ្យតាំងនៅ ក្នុងបញ្ចសីលហើយ ថ្វាយឱវាទ ថា "សូមព្រះអង្គ ទ្រង់ជាអ្នកមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ មានទានជាដើម" ដូច្នេះហើយ ទ្រង់ថ្វាយបង្គំព្រះមហាសត្វហើយ ស្ដេចយាងទៅកាន់ព្រះនគរ រៀងខ្លួន ៗ ទ្រង់គ្រប់គ្រងរាជសម្បត្តិ ដោយធម៌ហើយ ក៏ស្ដេចទៅកើត នៅក្នុងទេវលោក ៗ តាបសទាំង ២ នាក់ បងប្អូន ទំនុកបំរុងមាតាបិតារហូតមួយជីវិតហើយ ក៏បានទៅកើត នៅក្នុងព្រហ្មលោក ៗ

រឿង តាបស បងប្អូនគ្នា ២ នាក់ ចប់ ។

## ( បុត្រសង្គ្រោះមាតាបិតាដោយឋានៈ ៥ យ៉ាង )

(១៨៧) ការទំនុកបំរុង នូវមាតាបិតា ដូចបានពោលមក

ហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា " ជាមង្គល " ព្រោះនាំមកនូវឥដ្ឋផលទាំងឡាយ មានការសរសើរជាដើម ក្នុងលោកនេះ ដោយប្រការដូច្នេះឯង ។

ន័យមួយទៀត ។ ការទំនុកបំរុង ៥ យ៉ាង ដោយអំណាចការចិញ្ចឹម ការជួយធ្វើកិច្ចការងារ ការតាំងវង្សត្រកូល ការប្រព្រឹត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមត៌ក និងការតាមឲ្យនូវទក្ខិណានុប្បទាន ឈ្មោះថា កាទំនុកបំរុង ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគកាលទ្រង់សំដែងធម៌ ដល់គហបតីបុត្រ ឈ្មោះសិគាលកៈ ទើបទ្រង់ត្រាស់សំដែង ថា ៖

" ម្នាលគហបតីបុត្រ ទិសខាងកើត គឺមាតាបិតា បុត្រត្រូវទំនុកបំរុង ដោយស្ថាន ៥ យ៉ាង គឺ ៖ អាត្មាអញលោកចិញ្ចឹមមកហើយ ត្រូវចិញ្ចឹមលោកវិញ ១ នឹងជួយធ្វើកិច្ចការជំនួសលោក ១ នឹងតាំងវង្សត្រកូល ១ នឹងបដិបត្តិខ្លួនឲ្យសមគួរជាអ្នកទទួលមត៌ក ១ ម្យ៉ាងទៀត កាលបើមាតាបិតាទាំងនោះ ធ្វើមរណកាលលះលោកនេះទៅហើយ, នឹងបំពេញទក្ខិណាទាន ( ឧទ្ទិសផលដល់លោក ) ១, ម្នាលគហបតីបុត្រ ទិសខាងកើត គឺមាតាបិតា បុត្រត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាងនេះឯង " ។

(១៨៨) បណ្តាបទទាំងនោះ ក្នុងបទ ថា " ឋានេហិ " នេះ

គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ÷ ផលរមែង តាំងនៅ ក្នុងការណ៍នុ៎ះ ព្រោះភាវៈនៃផលនោះ ប្រព្រឹត្តទៅទាក់ទង ជាមួយនឹងការណ៍នោះ ព្រោះហេតុនោះ ការណ៍នោះ ឈ្មោះថា ជាទីតាំង គឺ ហេតុ, ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា "**ការណោហិ** " ។ ភាវៈនៃមាតាបិតា ជាទិសខាងមុខ ព្រោះបណ្ឌិតយល់ឃើញសមគ្នាដោយសេចក្ដី ។ ពិតមែនយ៉ាងនោះ មាតាបិតាទាំងនោះ ឈ្មោះថា ទិសខាងមុខ ព្រោះជាអ្នកស្ថិតនៅខាងមុខ នៃបុត្រទាំងឡាយ និងព្រោះសំដែងចេញ គឺ អាង ដោយភាពជាអ្នកមានឧបការគុណ (ដល់បុត្រទាំងឡាយ ) ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា "មាតាបិតា គឺបុគ្គលគប្បីជ្រាប ថា 'ជាទិសខាងមុខ' ព្រោះលោកជាអ្នកមានឧបការៈមុនគេ " ។

បទ ថា "**ភតោ**" ប្រែ ថា អាត្មាអញ គឺមាតាបិតាទាំង ២ នេះ ចិញ្ចឹមមកហើយ ។ ក៏ការចិញ្ចឹមនោះ ជាកិច្ច គឺមាតាបិតាឲ្យប្រព្រឹត្តទៅហើយ ដោយការនាំបច្ច័យ នៃសេចក្ដីសុខចូលមក និងដោយការនាំបច្ច័យ នៃសេចក្ដីទុក្ខចេញទៅ តាំងតែពីពេលដែលបុត្រកើតមកហើយ, ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ដើម្បីនឹងសំដែងនូវការចិញ្ចឹមនោះ ទើបពោល ថា "អាត្មាអញ គឺមាតានិងបិតា ឲ្យបៅទឹកដោះ ញុំាងដៃជើងឲ្យធាត់ធំ យកមាត់បឺតទឹកសម្បោរ

ឲ្យងូតទឹក តែងខ្លួនឲ្យ ចិញ្ចឹមថ្នាក់ថ្នមហើយ ”។ បទ ថា “ នេ ” មានសេចក្ដីថា អាត្មាអញ នឹងចិញ្ចឹមមាតាបិតាទាំងនោះ ដែលចាស់ជរា ដោយកិច្ចទាំងឡាយ មានការលាងជើង ឲ្យងូតទឹក ឲ្យបបរនិងភត្តជាដើម ។ ២ បទ ថា “ កិច្ចំ នេសំ ” មានសេចក្ដីថា អាត្មាអញ នឹងបញ្ឈប់កិច្ចការងារ របស់ខ្លួនហើយ ទៅជួយធ្វើកិច្ចការងារ ដែលកើតឡើង ក្នុងរាជត្រកូលជាដើម របស់មាតានិងបិតា ។ ក្នុងឋានៈ ថា “ កុលវំសំ បវេស្សាមិ ” នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ព្រោះហេតុ គឺកិរិយាមិនញ៉ាំងទ្រព្យសម្បត្តិ ដែលជារបស់នៃមាតាបិតា មានស្រែជាដើម ឲ្យវិនាសទៅ ថែរក្សាទុក ជាហេតុនៃការតាំងនៅគង់វង់ ជាបន្ត ៗ គ្នា របស់មាតា និងបិតាទាំងឡាយនោះ; ម្យ៉ាងទៀត ព្រោះហេតុ គឺការបន្តគ្នា (នៃវង្សត្រកូល ) របស់មាតាបិតាទាំងនោះ ជាកិច្ច គឺ បុត្រនាំទៅហើយ ដោយការនាំមាតាបិតាចេញ អំពីវង្សដែលមិនតាំងនៅ ក្នុងធម៌ ដែលប្រព្រឹត្តទៅ ដោយន័យជាអាទិ៍ យ៉ាងនេះ ថា “ ពួកយើងគប្បីសម្លាប់បុរសម្នាក់ ដែលស្មើនឹងខ្លួន ដោយសម្បត្តិមានត្រកូល និងប្រទេសជាដើមហើយ នាំយកនូវបន្តោងកែវមណី ដែលពាក់នៅនឹងក ឬនឹងដៃទៅ ” ដូច្នេះហើយ ឲ្យលះបង់នូវការប្រកាន់នោះចេញហើយ តម្កល់នៅ ក្នុងវង្សដែលប្រកបដោយធម៌ ដែល

ប្រព្រឹត្តទៅ ដោយកិរិយាវៀរចាកអកុសលកម្ម មានការបៀតបៀន គ្នាជាដើម និង ដោយកិរិយាមិនកាត់ផ្តាច់នូវទាន ដែលមាតាបិតាទាំងនោះឲ្យហើយ, ហេតុនោះ ដើម្បីនឹងសំដែងនូវសេចក្តីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា "បុត្រមិនញ៉ាំងទ្រព្យសម្បត្តិ ដែលជារបស់នៃមាតាបិតា មានដីស្រែ ប្រាក់ មាស ជាដើម ឲ្យវិនាសទៅ ថែរក្សាទុកក្តី នាំមាតាបិតាចេញ អំពីវង្សដែលមិនប្រកបដោយធម៌ហើយ តម្កល់នៅក្នុងវង្សដែលប្រកបដោយធម៌ក្តី មិនកាត់ផ្តាច់នូវភត្តទាំងឡាយ មានសលាកភត្តជាដើម ដែលវង្សត្រកូលនាំមកហើយ ឲ្យប្រព្រឹត្តទៅក្តី ឈ្មោះថា តាំងវង្សត្រកូល" ។

ក្នុងឋានៈ ថា "**ទាយជ្ជំ បដិបជ្ជាមិ**" នេះ គប្បីជ្រាបការវិនិច្ឆ័យ ដូចតទៅ ÷ ព្រោះហេតុ គឺបុត្រប្រព្រឹត្ត ដោយភាពជាអ្នកសមគួរ ដល់កិរិយាបាននូវភាពជាទាយាទ ឈ្មោះថា ប្រតិបត្តិនូវភាពជាអ្នកសមគួរទទួលមត៌ក ។ បុត្រផ្សេងអំពីនេះ មិនបានឈ្មោះថា ប្រតិបត្តិនូវភាពជាអ្នកសមគួរទទួលមត៌ក សោះឡើយ, ហេតុនោះ ដើម្បីនឹងសំដែងសេចក្តីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា "មាតាបិតា ដល់នូវការកាត់កាល់ចោលបុត្រទាំងឡាយ ដែលមិនប្រព្រឹត្ត ក្នុងឱវាទ របស់ខ្លួន ប្រតិបត្តិខុស មិនរាប់រកជាបុត្រ, បុត្រទាំងនោះ រមែងជាអ្នកមិនសមគួរទទួលមត៌ក, ប៉ុន្តែ

មាតាបិតា រមែងធ្វើបុត្រទាំងឡាយ ដែលប្រព្រឹត្ត ក្នុងឱវាទ ឲ្យជាម្ចាស់នៃទ្រព្យសម្បត្តិក្នុងត្រកូល" ។ បណ្តាបទទាំងនោះ បទ ថា " **វិនិច្ឆយំ បត្វា** " មានសេចក្តីថា ដល់នូវការកាត់កាល់ចោល ដែលមកហើយ យ៉ាងនេះ ថា " ក៏អាត្មាអញ កាត់កាល់បុត្រ" ។ បទ ថា " **ទក្ខិណំ** " មានសេចក្តីថា អាត្មាអញ នឹងធ្វើនូវការឲ្យចំណែកបុណ្យ ដល់មាតាបិតាទាំងនោះហើយ តាមឲ្យទាន តាំងអំពីថ្ងៃទី ៣ ទៅ ។ បើមានពាក្យចោទសួរ ថា "ដើម្បីអ្វី ?" ។ គប្បីឆ្លើយតប ថា "ដើម្បីឲ្យទាននោះ សម្រេចផល ដល់មាតាបិតាទាំងឡាយនោះ" ។ សួរ ថា " ក៏ទាននុ៎ះ រមែងសម្រេចផល ដល់មាតាបិតា ដែលលះលោកនេះទៅហើយឬ ?" ។ ក៏ក្នុងបញ្ហាសួរនេះ យើងខ្ញុំមិនត្រូវឆ្លើយទេ ព្រោះព្រះដ៏មានព្រះភាគនុ៎ះឯងទ្រង់ត្រាស់ព្យាករទុករួចហើយ ។

## ( រឿងជាណុស្សោណិព្រាហ្មណ៍ )

(១៨៩) បានឮថា ព្រាហ្មណ៍ម្នាក់ ឈ្មោះជាណុស្សោណី ចូលទៅគាល់ព្រះដ៏មានព្រះភាគហើយ ក្រាបទូលសួរ យ៉ាងនេះ ថា " បពិត្រព្រះគោតម ដ៏ចំរើន ពួកយើងខ្ញុំ ឈ្មោះថា ជាព្រាហ្មណ៍ តែងឲ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើ ដោយសេចក្តីជ្រះថ្លា

ហើយ ឧទ្ទិស ថា 'ទាននេះ សូមសម្រេចផល ដល់ប្រេតទាំងឡាយ ដែលជាញាតិសាលោហិត, ប្រេតទាំងឡាយ ជាញាតិសាលោហិត សូមបរិភោគនូវទាននេះ' ដូច្នេះ បពិត្រព្រះគោតមដ៏ចំរើន ចុះទាននោះ នឹងសម្រេចផល ដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ដែរឬទេ ?, ប្រេតទាំងឡាយ ដែលជាញាតិសាលោហិតនោះ នឹងបរិភោគនូវទាននោះ បានដែរឬទេ ?"។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផល ក្នុងទីគួរ, មិនសម្រេចផល ក្នុងទីមិនគួរ"។ ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចំរើន ទីដែលគួរ តើដូចម្តេច ?, ទីដែលមិនគួរ តើដូចម្តេច ?។

ព្រះដ៏មានព្រះភាគ. ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ ល ។ ជាអ្នកមានសេចក្តីយល់ខុស, បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងនរក ។ អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ ដែលកើតក្នុងនរក, សត្វនរកនោះ តែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយអាហារនោះ, សត្វនរកនោះ តែងស្ថិតនៅ ក្នុងនរកនោះ ដោយអាហារនោះ, ម្នាលព្រាហ្មណ៍ ទាននោះ រមែងមិនសម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ

ជាអ្នកសម្លាប់សត្វ ។ល។ មានសេចក្តីយល់ខុស, បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើត ក្នុងកំណើតនៃសត្វតិរច្ឆាន, អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ ជាអ្នកកើតក្នុងកំណើតតិរច្ឆាន, សត្វតិរច្ឆាននោះ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងកំណើតតិរច្ឆាននោះ ដោយអាហារនោះ ។ល។ ម្នាលព្រាហ្មណ៍ ទាននោះ រមែងមិនសម្រេចផល ដល់សត្វដែលស្ថិតក្នុងទីណា, ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកបុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ល។ ជាអ្នកមានសេចក្តីយល់ត្រូវ, បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងចូលដល់ភាពជាសំឡាញ់ នៃមនុស្សទាំងឡាយ, អាហារណា ជាអាហារ សម្រាប់ពួកមនុស្ស, បុគ្គលនោះ រមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងមនុស្សលោកនោះ ដោយអាហារនោះ, បុគ្គលនោះ រមែងស្ថិតនៅ ក្នុងមនុស្សលោកនោះ ដោយអាហារនោះ, ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត ។ល។ ជាអ្នកមានសេចក្តីយល់ត្រូវ, បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងចូលទៅដល់

ភាពជាសំឡាញ់ នៃទេវតាទាំងឡាយ, អាហារណា ជាអាហារសម្រាប់ពួកទេវតា, ទេវតានោះ តែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងទេវលោកនោះ ដោយអាហារនោះ ៗ ទេវតានោះ ស្ថិតនៅ ក្នុងទេវលោកនោះ ដោយអាហារនោះ, ម្នាលព្រាហ្មណ៍ ទាននោះ រមែងមិនសម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនេះឯង ហៅថា ទីមិនគួរ ៗ ម្នាលព្រាហ្មណ៍ ក៏បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ៗ ល ៗ ជាអ្នកមានសេចក្តីយល់ខុស, បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើត ក្នុងប្រេតវិស័យ អាហារណា ជាអាហារ សម្រាប់សត្វទាំងឡាយ ដែលកើតនៅ ក្នុងប្រេតវិស័យ, ប្រេតនោះ រមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយអាហារនោះ, ប្រេតនោះនៅក្នុងប្រេតវិស័យនោះ ដោយអាហារនោះ, ឬក៏ពួកមិត្រ អាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យ នូវទានណា ដល់ប្រេតនោះ អំពីលោកនេះ, ប្រេតនោះ រមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយអាហារនោះ, ប្រេតនោះ តែងស្ថិតនៅ ក្នុងប្រេតវិស័យនោះ ដោយអាហារនោះ, ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផល ដល់ សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនេះឯង ហៅថា ទីគួរ ៗ

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើ ប្រេត

ជាញាតិសាលោហិតនោះ មិនបានទៅកើត ក្នុងទីនោះទេ, តើអ្នកណា បរិភោគនូវទាននោះ ? ។

ព្រះដ៏មានព្រះភាគ. ម្នាលព្រាហ្មណ៍ ពួកប្រេត ដែលជាញាតិសាលោហិត ដទៃទៀត របស់គេ គង់ទៅកើត ក្នុងទីនោះមិនខាន, ប្រេតទាំងនោះឯង បរិភោគនូវទាននោះ ។

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើ ប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើត ក្នុងទីនោះទេ, ទាំងពួកប្រេត ជាញាតិសាលោហិត ដទៃទៀត របស់គេ ក៏មិនបានទៅកើតនៅក្នុងទីនោះដែរ, តើអ្នកណា បរិភោគទាននោះ ? ។

ព្រះដ៏មានព្រះភាគ ម្នាលព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិត ដោយកាល ជាយូរអង្វែងនេះ, ទីនុ៎ះឯង មិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ, ម្នាលព្រាហ្មណ៍ ទោះជាយ៉ាងនោះក៏ដោយធម្មតាអ្នកឲ្យទាន ក៏មិនមែនជាអ្នកគ្មានផលទេ ។

ជាណុស្សោណិសូត្រ មកក្នុងទសកនិបាត អង្គុត្តរនិកាយ ។

(១៩០) ន័យមកក្នុងអដ្ឋកថា ជាណុស្សោណិសូត្រនោះ ថា "បណ្ដាបទទាំងនោះ ពាក្យថា 'អស្ស' ក្នុងបទ ថា 'មយមស្ស' នេះ

គ្រាន់តែជានិបាត ៗ បទ ថា "**សទ្ធានិ**" ប្រែថា បុណ្យដែលគេគប្បីជឿហើយធ្វើ ៗ បទ ថា "**បេតានំ**" បានដល់ អ្នកស្លាប់ហើយ ៗ បទ ថា "**ឧបកប្បតុ**" បានដល់ នឹងដល់ ៗ បទ ថា "**ឋានេ**" បានដល់ ក្នុងឱកាស ៗ បទ ថា "**អដ្ឋានេ**" បានដល់ ក្នុងទីមិនសមគួរ ៗ កម្មជាហេតុឱ្យកើត ក្នុងនរកនោះនុ៎ះឯង ឈ្មោះថា អាហារ របស់សត្វទាំងឡាយ ដែលកើតក្នុងនរក ៗ ព្រោះសត្វទាំងឡាយនោះ រមែងញ៉ាំងអត្តភាព ឱ្យប្រព្រឹត្តទៅ ក្នុងនរកនោះ ដោយកម្មនោះឯង ៗ ចំណែក អាហារ របស់សត្វទាំងឡាយ ដែលកើតក្នុងកំណើតនៃសត្វតិរច្ឆាន គប្បីជ្រាប ដោយអំណាចវត្ថុ មានស្មៅនិងស្លឹកឈើជាដើម ៗ អាហារ របស់ពួកមនុស្ស គប្បីជ្រាប ដោយអំណាចបាយ និងនំកុម្មាសជាដើម ៗ អាហារ របស់ពួកទេវតា គប្បីជ្រាប ដោយអំណាចភោជនៈ ដ៏ប្រណិតជាដើម ៗ អាហារ របស់សត្វទាំងឡាយ អ្នកកើតក្នុងប្រេតវិស័យ គប្បីជ្រាប ដោយអំណាចរបស់ដែលមិនស្អាត មានទឹកមាត់ និងទឹកសម្បុរជាដើម ៗ ច្រើនបទ ថា "**យំ វា បនស្ស ឥតោ**" មានសេចក្តីថា មួយ៉ាងទៀត បិយជនទាំងឡាយ មានមិត្រជាដើម របស់គេ កាលឱ្យនូវទានណា អំពីមនុស្សលោកនេះ ឈ្មោះថា រមែងឧទ្ទិសទៅឱ្យ ៗ ក៏សត្វទាំងឡាយ អ្នកកើតក្នុងប្រេតវិស័យនុ៎ះឯង ជាអ្នកដែលចូល

អាស្រ័យទានដែលអ្នកដទៃឲ្យហើយរស់នៅ ។ ទានដែលអ្នកដទៃឲ្យដល់បុគ្គលដទៃ រមែងមិនសម្រេចផល (ដល់គេ) ។ ២ បទ ថា " **ទាយកោបិ អនិប្ផលោ** " មានសេចក្ដីថា ទាននោះ ដែលទាយក ឧទ្ទិសចំពោះបុគ្គលណាមួយ ឲ្យហើយ នឹងបានសម្រេចក្ដីមិនបានសម្រេចក្ដី ដល់បុគ្គលនោះ, ទាយក ក៏មិនអាច ជាអ្នកមិនមានផលដែរ, ទាយក រមែងបានទទួល នូវផលនៃទាននោះ ដោយពិតប្រាកដ ។ ក៏ព្រាហ្មណ៍ មានលទ្ធិ ថា "ទាយក តែងមិនបាននូវផល នៃទានដែលឲ្យហើយ យ៉ាងនោះ" ដូច្នេះ, ព្រោះហេតុនោះព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ យ៉ាងដូច្នេះ " ។

(១៩១) ក៏ប្រសិនបើ សូម្បីកាលបើញាតិ ទាំងឡាយពោល ថា "សូមទាននេះ សម្រេចផល ដល់ពួកញាតិ របស់យើងទាំងឡាយ" ដូច្នេះ, ប្រេតទាំងឡាយនោះ ទៅក្នុងទីនោះហើយទទួលអនុមោទនា, ទាននោះ រមែងសម្រេច ដល់ប្រេតទាំងនោះ, និងប្រេតទាំងនោះ រមែងបាននូវសម្បត្តិ ។ ក៏ក្នុងរឿងនេះ មានពួកប្រេតដែលធ្លាប់កើតជាញាតិ នៃព្រះបាទពិម្ពិសារ ជាឧទាហរណ៍ ។

## (រឿងប្រេតដែលជាព្រះញាតិនៃព្រះបាទពិម្ពិសារ )

បានឮថា ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះទៅ ព្រះសាស្ដា

ទ្រង់ព្រះនាមបុស្សៈ ទ្រង់ឧបត្តិឡើង ក្នុងនគរកាសីកៈ ។ ព្រះបិតា របស់ព្រះអង្គ ជាព្រះរាជា ទ្រង់ព្រះនាមជ័យសេន ។ ព្រះមាតា ជាព្រះរាជទេវី ទ្រង់ព្រះនាមសិរិមា ។ ព្រះកនិដ្ឋភាតា របស់ ព្រះអង្គ បានជាព្រះរាជឱរស ផ្សេងព្រះមាតាគ្នា ៣ ព្រះអង្គ ។ ក៏បុគ្គលអ្នកថែរក្សាឃ្លាំង របស់ព្រះរាជឱរសទាំង ៣ ព្រះអង្គនោះ ជាបុគ្គលតែមួយ ។ នាយស្មៀន ក្នុងជនបទ ក៏បុគ្គលតែមួយ ។

ក្នុងកាលនោះ ព្រះរាជបុត្រទាំងឡាយ មានព្រះបំណងនឹង ទ្រង់ទំនុកបំរុង នូវព្រះសាស្ដាដែលត្រូវជាព្រះជេដ្ឋភាតា របស់ព្រះ អង្គ អស់រយៈត្រៃមាស ទើបទ្រង់ក្រាបទូលសុំ នូវព្រះរាជា ។ សូម្បីព្រះរាជា ក៏ទ្រង់អនុញ្ញាតឱ្យហើយ ។ ព្រះរាជឱរសទាំងនោះ ទ្រង់បញ្ជូន នូវព្រះរាជហត្ថលេខាទៅ ដល់នាយស្មៀន ក្នុងជនបទ របស់ព្រះអង្គ មានឱ្យដឹង ថា "ចូរអ្នក កសាងព្រះវិហារ ដើម្បីព្រះ សាស្ដាហើយ ប្រាប់ដល់យើងទាំងឡាយ" ដូច្នេះ ។ នាយស្មៀន នោះ បានធ្វើហើយ យ៉ាងដូច្នោះ ទើបឱ្យបុគ្គលក្រាបបង្គំទូល ។

ព្រះរាជឱរសទាំងឡាយ ទ្រង់នាំព្រះសាស្ដា ទៅកាន់ជនបទ របស់ព្រះអង្គ ទ្រង់វេរព្រះវិហារថ្វាយហើយ ទ្រង់មានព្រះរាជឱង្ការ នឹងអ្នកថែរក្សាឃ្លាំង និង នាយស្មៀន ថា "ពួកអ្នកទាំងឡាយ ចូរ ទទួលយក នូវការចំណាយក្នុងទាន ដែលមានឈ្មោះប៉ុណ្ណោះទៅ

ហើយ ចាត់ចែងនូវខាទនីយៈ និងភោជនីយាហារ គ្រប់បែបយ៉ាង ថ្វាយ ដល់ព្រះដ៏មានព្រះភាគ ដែលមានភិក្ខុសង្ឃចំនួន ៩ ម៉ឺន អង្គ ជាបរិវារផង ដល់យើងទាំងឡាយ ព្រមទាំងបរិវារផង ជារៀងរាល់ថ្ងៃ, ព្រោះថា តាំងពីថ្ងៃនេះទៅ យើងទាំងឡាយ នឹងមិនពោលអ្វីឡើយ" ដូច្នេះហើយ ទ្រង់នាំយកបុរស ១ ពាន់នាក់ទៅ ហើយ សមាទានសីល ១០ ទ្រង់សំពត់កាសាវៈ ទ្រង់នៅក្នុងព្រះវិហារ នុ៎ះឯង អស់មួយត្រៃមាស ។

តាំងតែពីថ្ងៃនោះមក ជនទាំងឡាយ មានអ្នកថែរក្សាឃ្លាំង ជាដើម ដែលព្រះរាជឱរសទាំងនោះ ទ្រង់ត្រាស់បញ្ជាហើយ ក៏ទទួលយកការចំណាយក្នុងទានហើយ ថ្វាយទាន តាមវារៈ ។ ក៏បណ្ដាជនទាំងនោះ បុរសអ្នកថែរក្សាឃ្លាំង ព្រមទាំងភរិយា ជាអ្នកមានសទ្ធាជ្រះថ្លាហើយ បានថ្វាយ (ទាន) ដោយគោរព ។ ឯនាយស្មៀន ក៏បានថ្វាយហើយ ដោយគោរពដែរ មួយអន្លើនឹងបុរសអ្នកជនបទ ១១ នហុត ។ បណ្ដាបុរស ១១ នហុតនោះ បុរសអ្នកនៅក្នុងជនបទទាំងឡាយ ពួកខ្លះ មានប្រមាណ ៨ ម៉ឺន ៤ ពាន់នាក់ បានជាអ្នកមានចិត្ត ត្រូវលោភៈជាដើម ពាល់ត្រូវហើយ ។ ជនទាំងនោះ ធ្វើសេចក្ដីអន្តរាយដល់ទានហើយ បរិភោគទេយ្យធម៌ ដោយខ្លួនឯងខ្លះ បានឲ្យហើយ ដល់ពួកកូនទាំងឡាយខ្លះ និងយកភ្លើង

មកដុតរោងភត្តចោល ៗ ជនទាំងនោះ កើតហើយ ក្នុងនរក ៗ ចំណែក ព្រះរាជឱរសទាំងឡាយ ព្រមទាំងបរិវារ និងបុរសអ្នកថែរក្សាឃ្លាំងនិងនាយស្មៀន កើតហើយ ក្នុងឋានសួគ៌ ៗ កាលបើជនទាំង ២ ក្រុមនោះ ចេញពីឋានសួគ៌ា ចូលដល់ឋានសួគ៌ា ចេញពីនរក ចូលដល់នរក យ៉ាងដូច្នេះ, ៩២ កប្ប កន្លងផុតទៅហើយ ៗ

គ្រានោះ ក្នុងកាលនៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សបៈ ក្នុងកប្បនេះ ពួកជនដែលមានចិត្តត្រូវលោភៈជាដើម ពាល់ត្រូវហើយ នោះ កើតហើយ ក្នុងពួកប្រេត ៗ ក្នុងកាលនោះ មនុស្សទាំងឡាយថ្វាយទាន ដើម្បីប្រយោជន៍ ដល់ពួកប្រេតដែលត្រូវជាញាតិ របស់ខ្លួន ៗ ហើយឧទ្ទិស ថា "សូមទាននេះ សម្រេចផល ដល់ញាតិទាំងឡាយ របស់ពួកយើង" ៗ ប្រេតទាំងនោះ រមែងបាននូវសម្បត្តិ ៗ

គ្រានោះ ប្រេតទាំងឡាយនេះ ឃើញសម្បត្តិនោះហើយ ទើបក្រាបទូលសួរ នូវព្រះពុទ្ធព្រះនាមកស្សបៈ ថា "បពិត្រព្រះអង្គដ៏ចំរើន ធ្វើដូចម្ដេចហ្ន៎ ? ពួកយើងខ្ញុំ នឹងគប្បីបាន នូវសម្បត្តិយ៉ាងនេះខ្លះ" ដូច្នេះ ៗ

ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ទ្រង់ត្រាស់ ថា "ក្នុងកាលនេះ ពួកអ្នកទាំងឡាយ មិនទាន់បានទេ, ក្នុងអនាគតកាល ក្នុងកាលនៃព្រះពុទ្ធព្រះនាមគោតម ពួកញាតិ របស់អ្នកទាំងឡាយ នឹងបាន

ជាព្រះរាជាទ្រង់ព្រះនាមពិម្ពិសារ, ព្រះបាទពិម្ពិសារអង្គនោះ នឹងថ្វាយទាន ដល់ព្រះពុទ្ធអង្គនោះហើយ ទ្រង់ឧទ្ទិសផល ដល់ពួកអ្នកទាំងឡាយ, ក្នុងកាលនោះ ពួកអ្នកទាំងឡាយនឹងបាន (ទទួល) " ។ ប្រេតទាំងនោះ កាលប្រាថ្នាចំពោះ ព្រះបាទពិម្ពិសារ ញុំាងពុទ្ធន្តរ ១ ឲ្យកន្លងផុតទៅហើយ ។ ក៏ក្នុងពុទ្ធុប្បាទនេះ ព្រះរាជឱរសទាំង ៣ អង្គនោះ ព្រមទាំងបរិវារ បានច្យុតចាកឋានសួគ៌មកហើយ កើតក្នុងត្រកូលព្រាហ្មណ៍ ទីក្រុងមគធៈ បានជាជដិល មានឧរុវេលាកស្សបៈជាដើម ។ បុរសអ្នកថែរក្សាឃ្លាំង បានជាមហាសេដ្ឋី ឈ្មោះថាវិសាខៈ ។ ឯភរិយា របស់អ្នកថែរក្សាឃ្លាំងនោះ បានជាធីតាសេដ្ឋី ឈ្មោះថា ធម្មទិន្នា ។ នាយស្មៀន បានជាព្រះរាជា ទ្រង់ព្រះនាមព្រះបាទពិម្ពិសារ ។ បរិស័ទសេសសល់ ទាំងអស់ បានជាបរិវារនៃព្រះរាជា ។

គ្រានោះ ព្រះសាស្តា ទ្រង់សម្រេច នូវព្រះសព្វញ្ញុតញ្ញាណហើយ ស្តេចយាងទៅកាន់ឧទ្យានលដ្ឋិវ័ន ដោយលំដាប់ ទ្រង់ញុំាងព្រះបាទពិម្ពិសារ ដែលទ្រង់ចូលទៅគាល់ ក្នុងថ្ងៃនោះឯង មួយអន្លើដោយព្រាហ្មណ៍និងគហបតីទាំងឡាយ ដែលរស់នៅ ក្នុងដែនមគធៈ ១១ នហុត ឲ្យតាំងនៅ ក្នុងសោតាបត្តិផល ក្នុងឧទ្យានលដ្ឋិវ័ននោះត្រូវព្រះរាជាអារាធនានិមន្តហើយ ទ្រង់ទទួល នូវមហាទាន ក្នុងព្រះ

រាជវាំង ក្នុងថ្ងៃទី ២ ។ ប្រេតទាំងឡាយនោះ បានមកឈរលោមព័ទ្ធព្រះរាជវាំង ដោយសង្ឃឹម ថា "ឥឡូវនេះ ព្រះរាជា នឹងទ្រង់ឧទ្ទិសទាន ដល់ពួកយើងទាំងឡាយ, ឥឡូវនេះ ព្រះរាជា នឹងទ្រង់ឧទ្ទិសទាន ដល់ពួកយើងទាំងឡាយ "។ ព្រះរាជា លុះទ្រង់ថ្វាយទានហើយ រវល់តែទ្រង់ព្រះចិន្តា នូវទីគង់នៅ របស់ព្រះសាស្ដា ថា " ព្រះដ៏មានព្រះភាគ គប្បីគង់នៅ ក្នុងទីណាហ្ន៎ ? " ដូច្នេះហើយ ទើបមិនបានឧទ្ទិសទាននោះ ដល់នរណាមួយឡើយ ។ ពួកប្រេតជាអ្នកអស់សង្ឃឹមហើយ ក្នុងវេលារាត្រី បានធ្វើសំឡេងប្លែក ៗ គួរឲ្យភ័យខ្លាច យ៉ាងក្រៃលែង ក្នុងព្រះរាជវាំងនៃព្រះរាជា ។ ព្រះរាជា, កាលបើរាត្រី ភ្លឺស្វាងហើយ, ទ្រង់ស្ដេចយាងទៅគាល់ព្រះសាស្ដា ទ្រង់ក្រាបទូល ថា "ទូលព្រះបង្គំ បានស្ដាប់ នូវសំឡេងយ៉ាងនេះ, បពិត្រព្រះអង្គដ៏ចំរើន តើហេតុការណ៍អ្វី នឹងកើតមានដល់ទូលព្រះបង្គំ ? "។ ព្រះសាស្ដា ទ្រង់ត្រាស់ ថា " បពិត្រព្រះមហារាជ សូមព្រះអង្គ កុំទ្រង់ភ័យខ្លាចឡើយ, ហេតុការណ៍អ្វី ៗ ដ៏អាក្រក់ នឹងមិនកើតមាន ដល់ព្រះអង្គឡើយ " ដូច្នេះហើយ ទើបទ្រង់ត្រាស់ប្រាប់ នូវសេចក្ដីទាំងពួងនោះ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចំរើន ក៏បើទាន គឺទូលព្រះបង្គំថ្វាយហើយ ក្នុងពេលនេះ, តើប្រេតទាំងនោះ គប្បីបានទទួល

(ផល) ដែរឬទេ?"ៗ ព្រះសាស្ដា. បាន ព្រះមហាបពិត្រ ៗ ព្រះរាជា ទ្រង់និមន្តព្រះសាស្ដា ដើម្បីទ្រង់ទទួលចង្ហាន់ ក្នុងថ្ងៃនេះហើយ ស្ដេចយាងទៅព្រះរាជវាំង ទ្រង់ចាត់ចែងទានស្រេចហើយ ទ្រង់ត្រាស់បញ្ជា ឲ្យក្រាបទូល នូវពេលវេលា ៗ ព្រះសាស្ដា មានព្រះភិក្ខុសង្ឃចោមរោមហើយ ស្ដេចយាងទៅកាន់ព្រះរាជវាំង ទ្រង់គង់ហើយ ៗ

ប្រេតទាំងឡាយ ទាំងអស់នោះ សង្ឃឹម ថា " ថ្ងៃនេះ យើងទាំងឡាយ គប្បីបាន (វត្ថុអ្វីៗ) ខ្លះ មិនខាន " ដូច្នេះហើយ មកកាន់ព្រះរាជវាំងរបស់ព្រះបាទពិម្ពិសារ ដែលជាផ្ទះរបស់ញាតិ ក្នុងកាលមុន ដោយសម្គាល់ថាជាផ្ទះរបស់ខ្លួនហើយ បានឈរនៅ ក្នុងឋានទីទាំងឡាយ មានទីជិតខាងក្រៅជញ្ជាំងផ្ទះជាដើម ៗ ប្រេតទាំងនោះសោយនូវផល នៃសេចក្ដីឫស្យា និងសេចក្ដីកំណាញ់ ពួកខ្លះមានពុកមាត់ និងសក់វែងកន្ទ្រើង មានមុខមាត់ខ្មៅ មានសរសៃធូរ និងអវយវៈតូចធំ រយីករយាក ស្គាំងស្គម អាក្រក់អាក្រី និងខ្មៅ ដូចជាដើមត្នោត ដែលត្រូវភ្លើងព្រៃឆេះរោល ស្ថិតនៅ ក្នុងស្ថានទីនោះ ៗ, ពួកខ្លះ មានសរីរៈ ត្រូវអណ្ដាតភ្លើង ដែលតាំងឡើង អំពីពោះ ព្រោះការសង្អៀតនៃឈើសង្អៀតភ្លើង គឺសេចក្ដីស្រេកឃ្លានហើយ រាលចេញមកអំពីមាត់ឆាបឆេះ, ពួកខ្លះ មិនបានរសជាតិទៃ

ក្រៅអំពី រសគឺសេចក្ដីស្រេកឃ្លាន ព្រោះសូម្បីបាន (ទឹកនឹងភោជន) ហើយ ក៏ជាអ្នកមិនអាចនឹងបរិភោគ នូវទឹកនិងភោជន បានតាមសេចក្ដីចំណង់ ព្រោះភាពនៃខ្លួន ជាអ្នកមានបំពង់ក ប៉ុនចុងម្ជុល និងព្រោះជាអ្នកមានពោះ មានអាការៈដូចជាភ្នំ, ពួកខ្លះ បាននូវវត្ថុមិនស្អាត មានឈាម ខ្ទុះ និង ទឹករំអិល ជាដើម ដែលហូរចេញពីមុខដំបៅ នៃបូស និងកម រមាស់ ដែលបែកធ្លាយហើយ របស់គ្នាឯង ឬ របស់ពួកសត្វដទៃហើយ ក្រេបជញ្ជក់ ដូចទឹកអម្រឹត ។ ព្រះសាស្ដា ទ្រង់បានធ្វើហើយ ដោយប្រការដែលប្រេតទាំងឡាយទាំងពួងនោះ ដែលមានរូបរាងប្លែកៗ អាក្រក់មើល និងមានសរីរៈគួរឲ្យភ័យខ្លាច យ៉ាងក្រៃលែង បានប្រាកដហើយ ដល់ព្រះរាជា ។ ព្រះរាជា កាលទ្រង់ថ្វាយ ទឹកទក្ខិណោទក ទ្រង់ឧទ្ទិស ថា "សូមឲ្យទាននេះ បានសម្រេចផល ដល់ពួកញាតិទាំងឡាយ របស់យើង" ។

ក្នុងខណៈនោះឯង ស្រះបោក្ខរណីដែលពាសពេញ ដោយផ្កាបទុមជាតិ បានកើតឡើងហើយ ដើម្បីប្រេតទាំងឡាយនោះ ។ ពួកប្រេតទាំងនោះ ងូត និងផឹកហើយ ក្នុងស្រះបោក្ខរណីនោះ មានសេចក្ដីក្ដៅក្រហាយ សេចក្ដីលំបាក និងសេចក្ដីស្រេកឃ្លាន ស្ងប់រម្ងាប់អស់ហើយ មានសម្បុរដូចជាមាស ។ ព្រះរាជា ទ្រង់ថ្វាយនូវយាគូ របស់ដែលគួរទំពារស៊ី និងរបស់ដែលគួរបរិភោគហើយ

ទ្រង់ឧទ្ទិសឲ្យហើយ ៗ ក្នុងខណៈនោះដែរ យាគូរបស់ដែលគួរទំពារស៊ីនិងគ្រឿងបរិភោគដែលជាទិព្វទាំងឡាយ កើតឡើងហើយដើម្បីប្រេតទាំងឡាយនោះ ៗ ប្រេតទាំងឡាយនោះ បរិភោគនូវអាហារចំណី មានយាគូជាដើមនោះហើយ បានមានឥន្ទ្រិយ៍ស្រស់បស់ឆើតឆាយហើយ ៗ ព្រះរាជា ទ្រង់ថ្វាយ នូវសំពត់និងសេនាសនៈហើយ ទ្រង់ឧទ្ទិសឲ្យហើយ ៗ គ្រឿងប្រដាប់ផ្សេង ៗ មានយាន ប្រាសាទ សំពត់កម្រាល និងទីដេក ដែលជាទិព្វ ជាដើម កើតឡើងហើយ ដើម្បីប្រេតទាំងនោះ ៗ ក៏សម្បត្តិគ្រប់យ៉ាងនោះឯង តែងប្រាកដដល់ប្រេតទាំងនោះ ដោយប្រការណា, ព្រះសាស្តា ទ្រង់អធិដ្ឋាន ដោយប្រការនោះ ៗ ព្រះរាជា ទ្រង់ទតព្រះនេត្រឃើញសម្បត្តិនោះហើយ ទ្រង់មានព្រះហឫទ័យត្រេកអរក្រៃលែង ៗ

លំដាប់នោះ ព្រះសាស្តា ទ្រង់សោយភត្តាហារ រួចស្រេចហើយ កាលទ្រង់ធ្វើអនុមោទនា ទ្រង់សំដែងនូវភាពនៃប្រេតទាំងឡាយ ដែលមកហើយឈរនៅ ក្នុងទីនោះ ៗ ដល់ព្រះរាជា ទើបទ្រង់ត្រាស់ព្រះគាថាជាបឋម ថា ÷

(១៩២) " ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ
ដោយគិតថា ផ្ទះរបស់ខ្លួនហើយ ឈរនៅជិតខាង

ក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវ
បែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និង ទ្វារផ្ទះ
ទាំងឡាយខ្លះ " ។

បណ្ដាបទទាំងនោះ បទ ថា "**តិរោកុឌ្ឌេសុ**" មានសេចក្ដីថា ប្រេតទាំងនោះ ស្ថិតនៅ គឺសម្រេចការឈរនៅ ក្នុងស្ថានទីខាងក្រៅទាំងឡាយ ដែលជាចំណែកផ្សេង នៃកំពែងនិងជញ្ជាំងផ្ទះ ។ ក្នុងបទ ថា "**សន្ធិសិង្ឃាដកេសុ**" នេះ គប្បីជ្រាប ការវិនិច្ឆ័យដូចតទៅ ÷ ច្រកផ្លូវមានមុម ៤ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា **សន្ធិ** (ទីត), សូម្បីទីតនៃផ្ទះ ទីតនៃជញ្ជាំង ទីតនៃបង្អួច ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា **សន្ធិ**, ច្រកផ្លូវមានមុម ៣ ហៅថា **សិង្ឃាដកៈ** ។ បាទគាថា ថា "**ទ្វារពាហាសុ តិដ្ឋន្តិ**" មានសេចក្ដីថា ឈរផ្អែកពាហា នៃទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយ ។ ផ្ទះនៃញាតិ ក្នុងកាលមុនក្ដី ផ្ទះដែលខ្លួនធ្លាប់នៅអាស្រ័យមកហើយ ដោយភាពនៃខ្លួនជាម្ចាស់ក្ដី ផ្ទះទាំង ២ ប្រភេទនោះក្ដី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុង ២ បទនេះ ថា " **សកំ ឃរំ** "។ ប្រេតទាំងឡាយនោះ មក ដោយសម្គាល់ ថា ផ្ទះរបស់ខ្លួន ៗ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ យ៉ាងដូច្នោះ ៗ

(១៨៣) ឥឡូវនេះ ព្រះសាស្តា កាលទ្រង់សំដែងភារៈនៃញាតិណាមួយ, កាលបើបាយនិងទឹកជាដើម សូម្បីមានច្រើន, មិនមានសូម្បីគ្រាន់តែសេចក្តីនឹករលឹក ដល់ប្រេតទាំងឡាយនោះ ៗ ដែលដើរប្រាថ្នា ចំពោះពួកញាតិទាំងឡាយ ថា "ញាតិទាំងឡាយគប្បីឲ្យអាហារវត្ថុណាមួយ ឧទ្ទិសឲ្យពួកយើងទាំងឡាយខ្លះ" ដូច្នេះ ព្រោះបច្ច័យនៃកម្ម ដែលមានផលក្តៅក្រហល់ក្រហាយ ដ៏ក្រៃលែងដែលប្រេតទាំងនោះ បានធ្វើហើយ ទើបទ្រង់ត្រាស់គាថា ទី ២ ថា ÷

"កាលបើបាយ ទឹក បង្អែមនិងចម្អាប មានគ្រប់គ្រាន់ ដែលពួកញាតិ ចាត់ចែងទុកហើយ, មិនមានញាតិណាមួយ នឹករលឹកទៅ ដល់ប្រេតទាំងឡាយនោះ ព្រោះកម្ម របស់សត្វទាំងឡាយ ជាបច្ច័យ" ។

បណ្តាបទទាំងនោះ បទ ថា "**បហូតេ**" បានដល់ មិនតិច គឺ ច្រើន ៗ ព្រោះលោក ផ្លាស់ **ព** អក្សរ ឲ្យទៅជា **ប** អក្សរ ។ បទ ថា "**អន្នបានម្ហិ**" បានដល់ កាលបើគ្រឿងស៊ី និងគ្រឿងផឹកមាន ៗ បទ ថា "**ខជ្ជភោជ្ជេ**" បានដល់ កាលបើគ្រឿងទំពារស៊ី និងគ្រឿងស្រស់ស្រូប ៗ បទ ថា "**ឧបដ្ឋិតេ**" គឺ ពួកញាតិចូលទៅដម្កល់ទុកហើយ គឺចាត់ចែងទុកហើយ បានដល់

ត្រៀមទុកហើយ ។ បទ ថា " **ភោចិ** " មានសេចក្ដីថា មាតាក្ដី បិតាក្ដី បុត្រក្ដី របស់សត្វទាំងនោះ គឺ អ្នកដែលកើត ក្នុងប្រេតវិស័យ រមែងមិននឹករលឹកឃើញ ។ សួរ ថា " ព្រោះហេតុអ្វី ? " ។ ឆ្លើយ ថា " ព្រោះកម្មជាបច្ច័យ គឺ ព្រោះកម្ម គឺសេចក្ដីកំណាញ់ ផ្សេងដោយការហាមឃាត់ នូវបាយ និង ទឹកជាដើម ដែលខ្លួនធ្វើហើយ ជាហេតុ ។ មែនពិត កម្មនោះ របស់សត្វទាំងនោះ តែង មិនឲ្យញាតិទាំងឡាយ នឹករលឹកឃើញ ដូច្នេះឯង ។

(១៨៤) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ត្រាស់សរសើរ នូវទានដែលព្រះរាជាទ្រង់ថ្វាយឧទ្ទិស ឲ្យញាតិទាំងឡាយ ដែលស្លាប់ទៅហើយ ទើបទ្រង់ត្រាស់ព្រះគាថាទី ៣ ថា ÷

" **ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ, ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹកនិងភោជន ដ៏មិតចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដើម្បីញាតិទាំងឡាយ យ៉ាងដូច្នេះដែរ** " ។

បណ្ដាបទទាំងនោះ បទ ថា " **ឯវំ** " បានដល់ បពិត្រព្រះមហារាជ ទានដែលព្រះអង្គទ្រង់ថ្វាយហើយ ដោយប្រការណា, ដោយប្រការនោះ ។ បទ ថា " **ទទន្តិ** " មានសេចក្ដីថា បិយជន

ទាំងឡាយ មានបុត្រជាដើមនោះ តែងឲ្យ គឺឧទ្ទិស ប្រគល់ឲ្យ ថា " សូមទាននេះ សម្រេចផល ដល់ញាតិទាំងឡាយ របស់ពួកយើង" ។ បទ ថា "**ញាតីនំ**" បានដល់ ចូរសម្រេច ដល់ពួកញាតិ ដែលកើតក្នុងប្រេតវិស័យ ។ បទ ថា "**យេ**" គឺ ជនទាំងឡាយណាមួយ គឺបុត្រ ធីតា និងបងប្អូនប្រុស-ស្រី ។ បទ ថា "**អនុកម្បកា**" បានដល់ អ្នកដែលប្រាថ្នានូវប្រយោជន៍ គឺអ្នកដែលស្វែងរកនូវប្រយោជន៍ ។ បទ ថា "**សុចឹ**" បានដល់ ដ៏បរិសុទ្ធ គឺសមគួរដល់ចិត្ត ប្រកបដោយធម៌ បានមកដោយធម៌ ។ បទ ថា "**បណីតំ**" បានដល់ ដ៏ខ្ពង់ខ្ពស់ គឺដ៏ប្រសើរ ។ បទ ថា "**កាលេន**" បានដល់ ក្នុងទីដែលប្រេតទាំងឡាយ មកឈរនៅ ក្នុងទីទាំងឡាយ មានទីជិតខាងក្រៅជញ្ជាំងជាដើមខ្លះ ក្នុងកាលដែលគួរបរិភោគ នៃព្រះអរិយៈទាំងឡាយខ្លះ ។ បទ ថា "**កប្បិយំ**" បានដល់ ដ៏សមគួរ គឺដ៏គួរគួរសម ដល់ការបរិភោគ នៃព្រះអរិយទាំងឡាយ ។ បទ ថា "**បានភោជនំ**" បានដល់ ទឹក និង ភោជន ។ ក្នុងព្រះគាថាទី ៣ នេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ នូវទេយ្យធម៌គ្រប់បែបយ៉ាង ដោយប្រធាន គឺ ទឹកនិងភោជន ។

(១៩៥) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវប្រការដែលទាន គឺព្រះរាជាទ្រង់ព្រះរាជទានហើយ ជាទាន គឺ

ព្រះអង្គទ្រង់ព្រះរាជទានហើយ ដល់ប្រេតទាំងឡាយនោះ ទើបទ្រង់ត្រាស់កន្លះគាថាខាងដើម នៃព្រះគាថាទី ៤ ថា ÷

" ទាននេះ ចូរមានដល់ញាតិទាំងឡាយ, សូមឲ្យញាតិទាំងឡាយ បាននូវសេចក្តីសុខ " ។

បណ្តាបទទាំងនោះ បទ ថា " **ឥទំ** " ជាពាក្យសំដែងប្រាប់នូវទេយ្យធម៌ ។ ពាក្យថា " **វោ** " គ្រាន់តែជានិបាត ។ អាចារ្យពួកខ្លះ ពោល ថា " **នោ** " ដូច្នេះ ក៏មាន ។ អធិប្បាយថា របស់ពួកយើងទាំងឡាយ ។ បទ ថា " **ញាតីនំ** " មានសេចក្តីថា ចូរសម្រេច ដល់ញាតិទាំងឡាយ ដែលទៅកើតក្នុងប្រេតវិស័យ ។ បាទគាថា ថា " **សុខិតា ហោន្តុ ញាតយោ** " មានសេចក្តីថា សូមញាតិទាំងឡាយ ដែលទៅកើតក្នុងប្រេតវិស័យនោះ ចូរសោយនូវទាននេះ បានសេចក្តីសុខចុះ ។

(១៩៦) ឥឡូវនេះ កាលបើទាយក ពោល ថា " សូមឲ្យទាននេះ សម្រេចផល ដល់ញាតិទាំងឡាយ របស់ពួកយើង " ដូច្នេះ, កម្មដែលបុគ្គលដទៃធ្វើហើយ រមែងហុចផលឲ្យ ដល់បុគ្គលដទៃក៏គ្មានឡើយ, ប៉ុន្តែថា វត្ថុដែលទាយកឧទ្ទិសឲ្យ យ៉ាងដូច្នោះ រមែងជាបច្ច័យ នៃកុសលកម្ម របស់ប្រេតទាំងឡាយ ដោយគ្រប់

គ្រាន់, ព្រោះហេតុនោះ, កាលបើវត្ថុនោះឯង គឺទាយកឧទ្ទិសហើយឲ្យដល់ប្រេតទាំងឡាយនោះ, កុសលកម្ម នឹងញុំាងផលឲ្យកើត ក្នុងខណៈនោះ ដោយប្រការណា, ព្រះសាស្តា កាលទ្រង់សំដែងនូវប្រការនោះ ទើបទ្រង់ត្រាស់កន្លះគាថាខាងចុង នៃព្រះគាថាទី ៤ និងកន្លះគាថាខាងដើម នៃព្រះគាថាទី ៥ ថា ÷

" ចំណែក ប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកប្រជុំគ្នាហើយ ក្នុងមន្ទីរឲ្យទាននោះ, កាលបើបាយនិងទឹក មានល្មមគ្រាន់, ក៏អនុមោទនា ដោយគោរព " ។

បណ្ដាបទទាំងនោះ ២ បទ ថា " **តេ ញាតិបេ្បតា** " សម្ព័ន្ធនឹងគ្នា ។ បទ ថា " **តត្ថ** " បានដល់ ក្នុងទីជាទីដែលគេឲ្យទាននោះ ។ បទ ថា " **សមាគន្ត្វា** " មានសេចក្តីថា មកហើយដោយជុំវិញ គឺ ប្រជុំគ្នា បានដល់ ជាមួយនឹងគ្នា ។ បទ ថា " **សមាគតា** " មានសេចក្តីថា ជាអ្នកមកព្រមគ្នាហើយ ដើម្បីប្រយោជន៍នេះ ថា " ញាតិទាំងឡាយ របស់ពួកយើង ទាំងនេះនឹងឧទ្ទិសទាន ដើម្បីជាប្រយោជន៍ ដល់ពួកយើង " ។ បទ ថា " **អន្នបានម្ហិ** " មានសេចក្តីថា កាលបើបាយទឹក ដែលញាតិ

ទាំងឡាយឧទ្ទិសឲ្យ ដល់ខ្លួននោះ មានច្រើន ។ បាទគាថា ថា "**សក្កច្ចំ អនុមោទរេ**" មានសេចក្ដីថា ញាតិទាំងឡាយ ដែលលះលោកនេះទៅហើយ ជឿច្បាស់នូវកម្មនិងផល មិនលះបង់នូវសេចក្ដីគោរពក្រែង និងជាអ្នកមានចិត្តមិនរាយមាយ រមែងរីករាយ គឺ តែងអនុមោទនា បានដល់ ជាអ្នកកើតបីតិ និងសោមនស្ស ថា "សូមទាន របស់ពួកយើងនេះ កើតមាន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ" ដូច្នេះ ។

(១៩៧) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវអាការៈនៃសេចក្ដីលើកដម្កើង ប្រារព្ធញាតិ របស់ប្រេតទាំងនោះ ដែលសោយ នូវផលនៃកុសលកម្ម ដែលអាស្រ័យញាតិទាំងឡាយកើតឡើង ទើបត្រាស់កន្លះគាថាខាងចុង នៃគាថាទី ៥ និងកន្លះគាថាខាងដើម នៃគាថាទី ៦ ថា ÷

> "យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃ
> ញាតិទាំងឡាយណា, សូមពួកញាតិ របស់យើង
> ទាំងឡាយនោះ រស់នៅយឺនយូរ, ក៏ការបូជា គឺញាតិ
> ទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយ, ឯទាយក
> គឺអ្នកឲ្យទាន ក៏មិនមែន ជាអ្នកឥតផលឡើយ" ។

បណ្ដាបទទាំងនោះ ២ បទ ថា " **ចិរំ ជីវន្តុ** " មានសេចក្ដីថា ជាអ្នករស់នៅយឺនយូរ គឺ ចូរជាអ្នកមានអាយុវែង ។ ២ បទ ថា " **នោ ញាតី** " ប្រែថា ពួកញាតិ របស់ពួកយើង ។ បទ ថា " **ហេតុ** " បានដល់ ព្រោះហេតុនៃញាតិទាំងឡាយណា គឺ ព្រោះអាស្រ័យ ញាតិទាំងឡាយឯណា ។ បទ ថា " **លភាម សេ** " មានសេចក្ដីថា ពួកយើង បានសម្បត្តិដូច្នេះ ។

ក៏ប្រេតទាំងឡាយនោះ កាលអាងនូវសម្បត្តិ ដែលខ្លួនបានហើយ ក្នុងខណៈនោះ ទើបពោល យ៉ាងដូច្នោះ ដោយអំណាច នៃការលើកដម្កើង ។ មែនពិត ទក្ខិណា ( ទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ) ជាទានដែលញុំាងផលឲ្យកើត ក្នុងខណៈនោះឯង ដល់ប្រេតទាំងឡាយនោះ ក៏ព្រោះអង្គ ៣ យ៉ាង គឺ ព្រោះការអនុមោទនា របស់ខ្លួន ១ ព្រោះការឧទ្ទិស នៃទាយកទាំងឡាយ ១ ព្រោះការដល់ព្រម នៃព្រះទក្ខិណេយ្យបុគ្គល ១ ។ បណ្ដាហេតុ ៣ យ៉ាងនោះ ទាយក ជាហេតុដ៏វិសេស ។ ដោយហេតុនោះ ប្រេតទាំងនោះ ទើបពោល ថា " **ពួកយើងបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា ...** " ដូច្នេះ ជាដើម ។

បាទគាថា ថា " **អម្ហាកញ្ច កតា បូជា** " មានសេចក្ដីថា ក៏ការបូជា គឺ ទាយកទាំងឡាយ កាលឧទ្ទិស នូវទាននេះ យ៉ាងនេះ

ថា " សូមទាននេះ សម្រេច ដល់ញាតិទាំងឡាយ របស់ពួកយើង " ដូច្នេះ ឈ្មោះថា បានធ្វើហើយ ដល់យើងទាំងឡាយ ។ ឯទាយកទាំងឡាយនោះ ក៏ឈ្មោះថា ជាអ្នកមិនឥតផល ព្រោះកម្មឲ្យផល ក្នុងសន្តាន ជាទីកើតនៃកម្ម ដែលសម្រេចដោយការបរិច្ចាគ ។

(១៩៨) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវការមិនមាន នៃហេតុជាគ្រឿងបាននូវសម្បត្តិ មានកសិកម្ម និងគោរក្ខកម្មជាដើម ដទៃទៀត ក្នុងប្រេតវិស័យនោះ និងភាពគឺការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលទាយកឲ្យហើយ អំពីមនុស្សលោកនេះ របស់សត្វទាំងឡាយ ដែលកើត ក្នុងប្រេតវិស័យ ទើបត្រាស់គាថាទី ៧ ព្រមដោយកន្លះគាថាខាងចុងនៃគាថាទី៦ ថា

" កសិកម្ម ក៏មិនមាន ក្នុងភូមិនៃប្រេតនោះ, គោរក្ខកម្ម ក៏មិនមាន ក្នុងភូមិនៃប្រេតនោះ, ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិបែបដូច្នោះ ក៏មិនមាន, ការលក់ទិញផ្លាស់ប្តូរ ដោយប្រាក់ ក៏មិនមាន, បុគ្គលទាំងឡាយធ្វើកាលកិរិយា លះលោកនេះទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងប្រេតវិស័យនោះ ដោយផលទានដែលពួកញាតិ ឧទ្ទិសឲ្យហើយ អំពីលោកនេះ " ។

បណ្ដាបទទាំងនោះ បទ ថា “ **ន ហិ តត្ថ** ” មានសេចក្ដីថា បពិត្រព្រះមហារាជ ក៏ក្នុងប្រេតវិស័យនោះ កសិកម្ម មិនមានទេ ៗ ពាក្យថា “ **គោរក្ខេត្ថ** ” មានសេចក្ដីថា ក្នុងប្រេតវិស័យនោះ សូម្បីការរក្សាគោ ពោលគឺកម្មគ្រឿងចិញ្ចឹមជីវិត ដោយការរក្សាគោទាំងឡាយហើយ លក់បញ្ចគោរស ក៏មិនមាន ៗ អធិប្បាយថា ប្រេតទាំងឡាយ អាស្រ័យនូវកសិកម្ម និងគោរក្ខកម្ម ឯណា គប្បីបានសម្បត្តិ, សូម្បីកសិកម្មនិងគោរក្ខកម្មនោះ ក៏មិនមានដែរ ៗ បទ ថា “ **តាទិសី** ” មានសេចក្ដីថា ប្រេតទាំងនោះ អាស្រ័យនូវពាណិជ្ជកម្មបែបណា គប្បីបានសម្បត្តិ, សូម្បីពាណិជ្ជកម្មបែបនោះ ក៏មិនមានដែរ ៗ បទ ថា “ **កយាកយំ** ” មានសេចក្ដីថា ប្រេតទាំងនោះ អាស្រ័យការលក់ទិញផ្លាស់ប្ដូរឯណា គប្បីបាននូវសម្បត្តិ, សូម្បីការលក់ទិញផ្លាស់ប្ដូរ ដោយប្រាក់ គឺដោយកហាបណៈ បែបនោះ ក៏មិនមានដែរ ៗ បទ ថា “ **យាបេន្តិ** ” មានសេចក្ដីថា រមែងញ៉ាំងអត្តភាពឲ្យដើរទៅ គឺ ឲ្យប្រព្រឹត្តទៅ ដោយផលទានដែលញាតិទាំងឡាយ ឬ មិត្រនិងអាមាត្យទាំងឡាយ ឲ្យហើយ អំពីមនុស្សលោកនេះ ៗ បទ ថា “ **បេតា** ” បានដល់ សត្វទាំងឡាយដែលទៅកើត ក្នុងប្រេតវិស័យ ៗ បទ ថា “ **កាលគតា** ” បានដល់ អ្នកទៅហើយ ដោយមរណកាល របស់ខ្លួន ៗ បាលី ថា **កាលកតា**

ដូច្នេះ ក៏មាន ។ អធិប្បាយថា ធ្វើកាលកិរិយា គឺ ធ្វើមរណកាល ទៅហើយ ។ បទ ថា "តហឹ" បានដល់ ក្នុងប្រេតវិស័យនោះ ។

(១៩៩) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រកាស នូវសេចក្តី ដែលព្រះអង្គទ្រង់ត្រាស់ហើយ ដោយឧបមា ២ យ៉ាង ទើបទ្រង់ត្រាស់ ២ ព្រះគាថា ថា ÷

"ទឹកធ្លាក់ចុះ លើទីទួល រមែងហូរទៅកាន់ទំនាប ដូចម្តេចមិញ, ទានដែលបុគ្គលឲ្យហើយ អំពីលោក នេះ រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នេះ ដែរ ។ ផ្លូវទឹកមានទន្លេ និងស្ទឹងជាដើម ដ៏ពេញ រមែងញុំាងសាគរ ឲ្យពេញប្រៀប ដូចម្តេចមិញ, ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែង សម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ" ។

បណ្តាបទទាំងនោះ បទ ថា "ឧន្នតេ" បានដល់ លើទីទួល គឺ លើភូមិភាគដែលខ្ពស់ ។ បទ ថា "វុដ្ឋំ" បានដល់ ទឹក ដែល មេឃទាំងឡាយ ឲ្យធ្លាក់ចុះហើយ ។ ២ បទ ថា "និន្នំ បវត្តតិ" មានសេចក្តីថា រមែងហូរទៅ គឺ រមែងហូរធ្លាក់ទៅ កាន់ភូមិភាគ ដែលទំនាប ។ បទ ថា "ឧបកប្បតិ" បានដល់ រមែងកើត

គឺ រមែងប្រាកដ បានដល់ មិនប្រាសចាក អំពីការកើតផល ៗ ព្រោះថា ប្រេតលោក ជាទីតាំង នៃការសម្រេច នៃទាន ប្រៀបដូចជា ទីទំនាប ជាទីតាំងនៃការហូរធ្លាក់ចុះទៅ នៃទឹក ដូច្នេះឯង ៗ ហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនោះឯង ហៅថា ទីដ៏សមគួរ" ៗ ស្ទឹងធំ ហៅថា ផ្លូវទឹក ៗ បទ ថា "បូរា" បានដល់ ពេញដោយទឹក ដែលហូរមក អំពីជ្រោះភ្នំ ជ្រលង ព្រែក អូរ ប្រឡាយ បឹង ហើយញ៉ាំងសាគរឲ្យពេញ ៗ

(២០០) ប្រេតទាំងឡាយ ត្រូវសេចក្ដីសង្ឃឹម គ្របសង្កត់ហើយ ថា "ពួកយើង នឹងបានវត្ថុអ្វីមួយ អំពីផ្ទះនេះ" ដូច្នេះហើយ សូម្បីមកកាន់ផ្ទះ នៃពួកញាតិហើយ ក៏មិនអាច ដើម្បីនឹងសូម ថា "សូមអ្នកទាំងឡាយ ឲ្យនូវវត្ថុឈ្មោះនេះ ដល់យើងទាំងឡាយ" ដូច្នេះ បានឡើយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែង ថា "កុលបុត្រ កាលនឹករលឹក ដល់វត្ថុជាគ្រឿងនឹករលឹកទាំងឡាយនេះ គប្បីឲ្យទក្ខិណាទាន ដើម្បីប្រេតទាំងឡាយនោះ" ដូច្នេះ ទើបទ្រង់ត្រាស់ព្រះគាថាទី ១០ ថា ÷

"បុគ្គល កាលរឭកឃើញនូវឧបការគុណ ដែលលោក

ធ្វើទុកដល់ខ្លួន ក្នុងកាលមុន ថា 'អ្នកនេះ បានឲ្យរបស់នេះ ដល់អញ, អ្នកនេះ បានធ្វើគុណនេះដល់អញ, ជនទាំងឡាយនោះ ជាញាតិមិត្រ និងជាសំឡាញ់របស់អញ' ដូច្នេះហើយ គួរឲ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ " ។

បណ្ដាបទទាំងនោះ ២ បទ ថា " **ទក្ខិណំ ទជ្ជា** " មានសេចក្ដីថា កុលបុត្រ កាលនឹករឭក គឺ កាលតាមរឭក នូវឧបការគុណ ដែលលោកធ្វើហើយ ក្នុងកាលមុន គ្រប់យ៉ាង យ៉ាងនេះ ថា " អ្នកនោះបានឲ្យទ្រព្យ ឬ ស្រូវឈ្មោះនេះ ដល់អញ " ថា " អ្នកនោះបានធ្វើកិច្ចការឈ្មោះនេះ ដល់អញ " ថា " អ្នកឯនុ៎ះ ឈ្មោះថា ជាញាតិ របស់អញ ព្រោះជាអ្នកទាក់ទងគ្នា ខាងមាតា ឬខាងបិតា " ថា " អ្នកឯនុ៎ះឈ្មោះថា ជាមិត្រ ព្រោះជាអ្នកអាចជួយការពារ ដោយអំណាចនៃសេចក្ដីស្រឡាញ់ " ដូច្នេះ និង ថា " បុគ្គលឯណោះ ជាសំឡាញ់ដែលលេងដីជាមួយនឹងគ្នា " ដូច្នេះ គប្បីឲ្យ គឺគប្បីប្រគល់ឲ្យ នូវទាន ចំពោះប្រេតទាំងឡាយ ។ បាលី ថា " **ទក្ខិណា ទជ្ជា** " ដូច្នេះខ្លះ ក៏មាន ។ ក្នុងបទ ថា " **ទជ្ជា** " នោះ គប្បីជ្រាបវិគ្រោះ ដូចតទៅ ÷ សម្បត្តិណា ដែលបុគ្គលគប្បីឲ្យ ហេតុនោះ

សម្បត្តិនោះ ឈ្មោះថា **ទឞ្ឋា** សម្បត្តិដែលបុគ្គលគប្បីឲ្យ ។ សម្បត្តិដែលបុគ្គលគប្បីឲ្យនោះ គឺជាអ្វី ? ។ គឺទក្ខិណា ដើម្បីប្រេតទាំងឡាយ ។ ទក្ខិណានោះ អ្នកណា គប្បីឲ្យ ? ។ គឺ កុលបុត្រ អ្នកដែលនឹករឭក, អធិប្បាយថា អ្នកដែលតាមរឭក នូវឧបការគុណដែលលោកធ្វើហើយ ក្នុងកាលមុន ដោយន័យជាអាទិ៍ ថា " អ្នកនោះបានឲ្យនូវរបស់នេះ ដល់អញ..." ដូច្នេះ ។ ក៏បទ ថា " **អនុស្សរំ** " នេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថ នៃតតិយាវិភត្តិ ដូច្នេះឯង ។

(២០១) ព្រះសាស្តា កាលទ្រង់សំដែង ថា " ក៏សត្វទាំងឡាយណា រវល់តែជាអ្នកមានសេចក្ដីទុក្ខ មានការយំសោក និងការខ្សឹកខ្សួល ព្រោះញាតិស្លាប់ទៅជាដើម ជាប្រមុខ ស្ថិតនៅនុះឯង មិនឲ្យវត្ថុអ្វី ៗ ដើម្បីជាប្រយោជន៍ ដល់ប្រេតទាំងនោះ, ការយំនិងសេចក្ដីសោកសៅជាដើមនោះ របស់សត្វទាំងនោះ រមែងជាហេតុគ្រាន់តែ ញុំាងខ្លួនឲ្យក្ដៅក្រហាយ តែម្យ៉ាងប៉ុណ្ណោះឯង, ការយំជាដើមនោះ រមែងញុំាងប្រយោជន៍បន្តិចបន្តួចឲ្យសម្រេច ដល់ប្រេតទាំងឡាយ ពុំបានឡើយ " ដូច្នេះ ទើបត្រាស់គាថាទី ១១ ថា÷

" ការយំក្ដី ការសោកសៅក្ដី ការខ្សឹកខ្សួល ឯណា
ដទៃក្ដី នរណា ក៏មិនគប្បីធ្វើ ដោយពិត, ព្រោះការយំ

ជាដើមនោះ មិនសម្រេចប្រយោជន៍ ដល់ប្រេត
ទាំងឡាយឡើយ, ញាតិទាំងឡាយ រមែងឋិតនៅ
យ៉ាងនោះឯដែល ឥតបានដឹង បានឮឡើយ " ។

កិរិយាហូរចេញ នៃទឹកភ្នែក របស់បុគ្គលអ្នកយំទាំងឡាយ ឈ្មោះថា ការយំ ក្នុងគាថានោះ ។ គប្បីសម្ពន្ធពាក្យដែលសេសសល់ ថា " **ន ហិ កាតព្វំ** "។ ការសោយសោក គឺ ការក្តៅចិត្តបានដល់ ការក្រៀមក្រំ ឰដ៏ខាងក្នុង ឈ្មោះថា ការសោកសៅ ។ ២ បទ ថា " **យា វញ្ញា** " គឺ ឯវេទនា អំពីការយំនិងការសោកសៅទាំងឡាយក្តី ។ ការស្រងេះស្រងោច គឺការរើរវាយ ដោយវាចាដោយន័យ ថា " ម្នាលបុត្រតូចតែមួយ អ្នកទៅក្នុងទីណា ? " ដូច្នេះជាអាទិ៍ របស់បុគ្គល ដែលសេចក្តីវិនាសនៃញាតិ ពាល់ត្រូវហើយ ឈ្មោះថា ការខ្សឹកខ្សួល ។ អធិប្បាយថា សូម្បីការរើរវាយដោយវាចានោះ នរណា ក៏មិនត្រូវធ្វើឡើយ ។ វា សព្ទ ក្នុងទីទាំងពួង ជាវិកប្បត្ថៈ ។ បាទគាថា ថា " **ន តំ បេតានមត្ថាយ** " មានសេចក្តីថា ការស្រែកយំជាដើមនោះ ទាំងពួង រមែងមិនប្រព្រឹត្តទៅ ដើម្បីឧបការៈ ដល់បុគ្គលទាំងឡាយ ដែលធ្វើកាលកិរិយាទៅហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ការស្រែកយំជាដើម

នោះ នរណា ក៏មិនគួរធ្វើឡើយ ។ មែនពិត ញាតិទាំងឡាយ រមែងស្ថិតនៅ យ៉ាងដូច្នោះ អធិប្បាយថា ឥតបានដឹងឡើយ ។

(២០២) ព្រះដ៏មានព្រះភាគ លុះត្រាស់ នូវភាវៈ នៃការយំជាដើម ជាការឥតប្រយោជន៍ ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹងទ្រង់សំដែង នូវភាពនៃទក្ខិណា ដែលព្រះរាជាទ្រង់ព្រះរាជទានហើយ មានប្រយោជន៍ ទើបទ្រង់ត្រាស់គាថាទី ១២ ថា ÷

" លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ
ដម្កល់ទុកប្រពៃហើយ ក្នុងព្រះសង្ឃ ទើបសម្រេច
ផល ដោយរួសរាន់ ដើម្បីប្រយោជន៍ ដល់ប្រេត
នោះ អស់កាលជាយូរអង្វែង " ។

ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សំដែងនូវទានដែលព្រះរាជាទ្រង់ព្រះរាជទានហើយ ក្នុងពេលនោះ ដោយច្បាស់លាស់ ទើបទ្រង់ត្រាស់ ដោយពាក្យថា " អយំ " ក្នុងគាថានោះ ។ ច ស័ព្ទ ចុះក្នុងព្យតិរេកជោតកៈ ។ ដោយ ច ស័ព្ទនោះ ព្រះអង្គទ្រង់សំដែងបំភ្លឺ នូវសេចក្ដីប្លែកផ្សេងគ្នា ដែលនឹងទ្រង់ត្រាស់នុះឯង ថា " ការស្រែកយំជាដើម មិនមានប្រយោជន៍ បន្តិចបន្តួច ដល់បុគ្គលដែលស្លាប់ទៅហើយឡើយ យ៉ាងណាមិញ, ឯទក្ខិណាទាននេះ

នឹងមិនមានប្រយោជន៍ ដល់បុគ្គលដែលស្លាប់ទៅហើយ យ៉ាងដូច្នោះ ក៏ទេដែរ, ទក្ខិណាទាននេះ រមែងមានប្រយោជន៍ ដល់បុគ្គលដែលស្លាប់ទៅហើយនោះ អស់កាលជាយូរអង្វែង" ។ សព្ទ ថា **ខោ** ចុះក្នុងអវធារណៈ ។ ២ បទ ថា "**ទក្ខិណា ទិន្នា**" មានសេចក្ដីថា បពិត្រព្រះមហារាជ ទានដែលព្រះអង្គទ្រង់ឧទ្ទិសឲ្យហើយ ដល់ពួកញាតិ របស់ព្រះអង្គ ក្នុងថ្ងៃនេះ ។ ព្រះសង្ឃជាស្រែបុណ្យដ៏ខ្ពង់ខ្ពស់ របស់សត្វលោក ព្រោះហេតុណា, ព្រោះហេតុនោះ ទក្ខិណាទាន ឈ្មោះថា គឺព្រះអង្គទ្រង់ដម្កល់ទុកប្រពៃហើយ ក្នុងព្រះសង្ឃ ។ ពាក្យថា "**ហិតាយស្ស**" គឺ ដើម្បីជាប្រយោជន៍ដល់ជននោះ គឺ ជនដែលលះលោកនេះទៅហើយ អស់រាត្រីដ៏យូរ គឺអស់កាលជាយូរអង្វែង ។ បាទគាថា ថា "**ឋានសោ ឧបកប្បតិ**" មានសេចក្ដីថា រមែងមាន គឺរមែងសម្រេច បានដល់ រមែងឲ្យផលក្នុងខណៈនោះនុ៎ះឯង ។ មានពាក្យអធិប្បាយថា "ដោយកាលមិនយឺតយូរ" ដូច្នេះ ។ ប្រៀបដូចជា ការព្យាករណ៍បញ្ហា រមែងជាក់ច្បាស់ ក្នុងខណៈនោះនុ៎ះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ក៏ការព្យាករណ៍បញ្ហានុ៎ះ រមែងជាក់ច្បាស់ ចំពោះតថាគតដោយរួសរាន់" ដូច្នេះ យ៉ាងណាមិញ, សូម្បីក្នុងគាថានេះ ទក្ខិណាកាលសម្រេចផល ក្នុងខណៈនោះនុ៎ះឯង ព្រះអង្គទ្រង់ត្រាស់ហើយ

ថា "ទក្ខិណារមែងសំរេចផល ដោយរួសរាន់" ដូច្នេះ យ៉ាងនោះ ។ ម្យ៉ាងទៀត ឋានៈណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយថា " ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផល ដល់សត្វដែលស្ថិតនៅ ក្នុងទីណា, ទីនេះឯង ជាទីដ៏គួរ " ដូច្នេះ, ទក្ខិណាទានសម្រេចផល ក្នុងទីនោះ ផ្សេងដោយឋានៈ មានខុប្បិបាសិកវន្តប្រេត បរទត្តូបជីវីប្រេត និង និជ្ឈាមតណ្ហិកប្រេត ជាដើម ព្រះអង្គទ្រង់ត្រាស់ ថា " រមែងសម្រេច ដោយឋានៈ" ដូច្នេះ, ប្រៀបដូចជា បុគ្គលអ្នកឲ្យនូវកហាបណៈ គេហៅ ក្នុងលោក ថា " បុគ្គលនោះតែងឲ្យនូវកហាបណៈ" ដូច្នេះ យ៉ាងនោះឯង ។ ក៏ក្នុងអត្ថវិកប្បនេះ បទ ថា "ឧបកប្បតិ " បានដល់ រមែងប្រាកដ, មានពាក្យអធិប្បាយថា " រមែងកើតឡើង " ដូច្នេះ ។

(២០៣) ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សរសើរព្រះរាជា ដោយគុណតាមសេចក្តីពិត ទើបត្រាស់គាថាទីបញ្ចប់ ថា÷

" ញាតិធម៌នោះ ឈ្មោះថា មហាបពិត្រ បានសំដែងជាបែបយ៉ាងហើយ, ការបូជា ដ៏ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ ឈ្មោះថា ព្រះអង្គ បានធ្វើហើយ និងកម្លាំងកាយ នៃភិក្ខុទាំងឡាយ ឈ្មោះថា ព្រះអង្គ

បានបំពេញឲ្យហើយ, បុណ្យមិនមែនតិច ឈ្មោះថា ព្រះអង្គ បានសន្សំទុកហើយ " ។

ការធ្វើកិច្ច ដែលពួកញាតិគប្បីធ្វើ ដើម្បីញាតិទាំងឡាយ ឈ្មោះថា ញាតិធម៌ ក្នុងគាថានោះ ។ បទ ថា "**និទស្សិតោ**" មានសេចក្ដីថា បពិត្រមហារាជ ញាតិធម៌ គឺព្រះអង្គកាលថ្វាយនូវទក្ខិណានេះ ឈ្មោះថា ទ្រង់សំដែងជាបែបយ៉ាងហើយ គឺ ទ្រង់ធ្វើជាបែបយ៉ាងហើយ បានដល់ ឲ្យប្រាកដ ដល់ជនច្រើន យ៉ាងនេះ ថា " ញាតិធម៌ សូម្បីព្រះអង្គ គប្បីបំពេញ ដោយការធ្វើកិច្ច ដែលញាតិទាំងឡាយ គប្បីធ្វើ ដើម្បីពួកញាតិ យ៉ាងដូច្នោះឯង, មិនគប្បីធ្វើខ្លួន ឲ្យក្ដៅក្រហាយ ដោយការយំជាដើម ដែលមិនមានប្រយោជន៍ឡើយ " ។ បទ ថា "**ឧឡារា** "មានសេចក្ដីថា ការបូជា ដើម្បីប្រេតទាំងឡាយ បរិបូណ៌ គឺ សម្រេចហើយ បានដល់ គឺព្រះអង្គញ៉ាំងប្រេតទាំងឡាយ នោះ ឲ្យបាននូវទិព្វសម្បត្តិ ឈ្មោះថា ទ្រង់បានធ្វើហើយ ។ បទ ថា " **ពលំ** " មានសេចក្ដីថា កម្លាំងកាយនៃភិក្ខុទាំងឡាយ គឺព្រះអង្គ ទ្រង់ញ៉ាំងសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតឆ្អន់ ដោយអាហារ មានបាយនិងទឹកជាដើម ឈ្មោះថា បានបំពេញឲ្យហើយ ។ បទ ថា " **បសុតំ** " មានសេចក្ដីថា បុណ្យ គឺព្រះអង្គទ្រង់ ញ៉ាំងចេតនា

ជាហេតុលះបង់មានគុណា មានការអនុគ្រោះជាដើម ជាបរិវារ ឲ្យកើតឡើង ឈ្មោះថា ទ្រង់បានសន្សំទុកហើយ ។

(២០៤) ព្រះសាស្តាទ្រង់បញ្ចប់ទេសនា ដោយគាថានេះ ។ ក្នុងពេលចប់ទេសនា សត្វ ៨ ម៉ឺន ៤ ពាន់ អ្នកកើតសេចក្តីសង្វេគ ព្រោះការពណ៌នានូវទោស នៃការកើតក្នុងប្រេតវិស័យហើយ ប្រារព្ធសេចក្តីព្យាយាម ដោយយកចិត្តទុកដាក់ បានសម្រេចធម៌ហើយ ។ ព្រះសាស្តា ទ្រង់ត្រាស់ទេសនាតិរោកុឌ្ឌសូត្រនេះឯង ដល់ទេវតា និងមនុស្សទាំងឡាយ តាំងពីថ្ងៃទី២ រហូតដល់ថ្ងៃទី៧ ។ ការបានសម្រេចធម៌ បានមានហើយ យ៉ាងដូច្នោះដែរ ។ គាថាទាំង ១៣ គាថានេះ ព្រះធម្មសង្គាហកាចារ្យ ចងក្រងហើយ ក្នុងបេតវត្ថុ ដោយឈ្មោះថា "តិរោកុឌ្ឌបេតវត្ថុ" ក្នុងខុទ្ទកបាឋៈ ដោយឈ្មោះថា "តិរោកុឌ្ឌសូត្រ" ដោយប្រការដូច្នេះ ។

តិរោកុឌ្ឌសូត្រ ចប់ ។

(២០៥) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងតិរោកុឌ្ឌសូត្រនេះ និងក្នុងសិគាលសូត្រ ថា "បុគ្គលគប្បីឲ្យទាន ឧទ្ទិសដល់ញាតិដែលលះលោកនេះទៅហើយ" យ៉ាងដូច្នេះ ។ ប៉ុន្តែ បុគ្គលអ្នកត្រូវការបុណ្យ មិនគួរគិត ថា "ជនទាំងនេះ ជាញាតិក្តី មិនមែន

ផាញ្ញាតិក្តី "ដូច្នេះ, គប្បីឧទ្ទិសឲ្យ អ្នកណាមួយ ដោយពិត គប្បីដូចជាមហាជន មានអនាថបិណ្ឌិកសេដ្ឋីជាដើម ។

## ( រឿងបិដ្ឋធីតលិកប្រេត )

បានឮមកថា ស្រីមេនំ របស់ក្មេងស្រី នៃនាងធីតានៃកូនស្រី របស់អនាថបិណ្ឌិកសេដ្ឋី បានយកម្សៅ មកធ្វើរូបតុក្កតាហើយ បានប្រគល់ឲ្យ ដោយពោល ថា "ចូរនាង យករូបតុក្កតានេះ លេងចុះ" ។ ក្មេងស្រី ធ្វើសេចក្តីសម្គាល់ ក្នុងរូបតុក្កតានោះ ថាជាកូនស្រី ឲ្យកើតឡើងហើយ ទើបលេង ។ ក្រោយមក ថ្ងៃមួយ កាលបើក្មេងស្រីនោះ កំពុងលេង, រូបតុក្កតានោះ ធ្លាក់បែក ព្រោះសេចក្តីប្រហែស ។ ក្មេងស្រី ស្រែកយំ ថា " កូនស្រីរបស់នាងខ្ញុំ ស្លាប់ហើយ " ។

ក្នុងកាលនោះ ព្រះបរមសាស្តា ទ្រង់ស្តេចគង់នៅ លើផ្ទះ ។ ឯសេដ្ឋី ក៏អង្គុយនៅ ក្បែរព្រះសាស្តា ។ នាងមេនំ ពក្មេងស្រី ដែលកំពុងតែយំ ទៅកាន់សំណាក់ នៃសេដ្ឋី ប្រាប់រឿងនោះហើយ ។ សេដ្ឋី បានឲ្យក្មេងស្រីនោះអង្គុយលើភ្លៅហើយ ក៏បានលួងលោម ថា " ជីតា នឹងឲ្យទាន ដើម្បីកូនស្រី របស់ចៅ " ដូច្នេះហើយ ក្រាបទូលសេចក្តីនោះ ដល់ព្រះសាស្តាហើយ ក្រាបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំ ប្រាថ្នានឹងថ្វាយទានឧទ្ទិសឲ្យរូបតុក្កតាម្សៅ

ដែលជាកូនស្រីរបស់ចៅស្រី នៃទូលព្រះបង្គំ, សូមព្រះអង្គ មានភិក្ខុ ៥០០ អង្គជាបរិវារ ទ្រង់ទទួល ដើម្បីនឹងឆាន់ ក្នុងថ្ងៃស្អែក" ។

ព្រះសាស្តា ទ្រង់ទទួលហើយ ក្នុងថ្ងៃទី ២ ស្តេចយាងទៅក្នុងផ្ទះនោះ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ កាលទ្រង់ធ្វើអនុមោទនា ទើបបានត្រាស់ នូវគាថាទាំងឡាយនេះ ថា ÷

(២០៦) "កុលបុត្រ ជាអ្នកមិនកំណាញ់ គប្បីធ្វើហេតុណាមួយ ឲ្យជាអារម្មណ៍ហើយ ប្រារព្ធមាតាបិតាទាំងឡាយ ដែលលះលោកនេះទៅហើយ ក្នុងកាលមុន ឬនូវទេវតាទាំងឡាយ ឬនូវទេវតាជាលោកបាលទាំងឡាយ ដែលជាស្តេចធំ ៤ ដែលជាអ្នកមានយស គឺ ព្រះបាទកុវេរៈ ១ ព្រះបាទធតរដ្ឋៈ ១ ព្រះបាទវិរូបក្ខៈ ១ ព្រះបាទវិរុឡ្ហកៈ ១ ហើយ គប្បីថ្វាយទាន ។ បុព្វជន និងស្តេចទេវតាទាំងឡាយ ជាដើមនោះ រមែងជាអ្នក គឺ គេបានបូជាហើយ, ឯបុគ្គលអ្នកឲ្យទាន ក៏មិនមែនជាអ្នកឥតផលឡើយ ។ ការយំក្តី ការសោកសៅក្តី ការខ្សឹកខ្សួល ឯណាដទៃក្តី នរណា ក៏មិនគប្បីធ្វើដោយពិត, ព្រោះការយំជាដើមនោះ មិនសម្រេច

ប្រយោជន៍ ដល់អ្នកដែលលះលោកនេះ បានឡើយ, ញាតិទាំងឡាយ រមែងស្ថិតនៅយ៉ាងនោះ ឥតបាន ដឹង បានឮឡើយ ៗ លុះតែទក្ខិណាទាននេះ ដែល បុគ្គលបានឲ្យហើយ ដម្កល់ទុកប្រពៃហើយ ក្នុងសង្ឃ ទើបសម្រេចផល ដោយរួសរាន់ ដើម្បីជាប្រយោជន៍ ដល់អ្នកដែលស្លាប់ទៅនោះ អស់កាលយូរអង្វែង"ៗ

បណ្ដាបទទាំងនោះ បទ ថា "**យត្កិញ្ចារម្មណំ កត្វា**" មាន សេចក្ដីថា ប្រារព្ធ គឺឧទ្ទិស នូវហេតុឯណានីមួយ បណ្ដាហេតុទាំង ឡាយ មានមង្គលជាដើម ឈ្មោះថា ហេតុណានីមួយ ៗ បទ ថា "**ទជ្ជា**" ប្រែថា គប្បីឲ្យ ៗ បទ ថា "**អមច្ឆរី**" មានសេចក្ដី ថា ឈ្មោះថា ជាអ្នកមិនកំណាញ់ ព្រោះមិនមានសេចក្ដីកំណាញ់ ដែលមានកិរិយាអត់ទ្រាំមិនបាន នូវភារៈ នៃសម្បត្តិ របស់ខ្លួន ទូទៅ ដោយជនដទៃ ជាលក្ខណៈ ៗ អធិប្បាយថា ជាអ្នកមានការលះ បង់ជាប្រក្រតី ធ្វើមន្ទិលនៃចិត្ត មានមច្ឆរិយៈនិងលោភៈជាដើម ឲ្យ នៅឆ្ងាយហើយ គប្បីឲ្យទាន ៗ បាទគាថា ថា "**បុព្វេ បេតេ វ អារព្ភ**" មានសេចក្ដីថា ឧទ្ទិសនូវមាតាបិតា ដែលជាបុព្វជន ឬ ៗ បទ ថា "**វត្ថុទេវតា**" មានសេចក្ដីថា ប្រារព្ធទេវតា ដែលស្ថិតនៅ

ក្នុងទីទាំងឡាយមានទីផ្ទះជាដើម ។ ដោយពាក្យថា " **អថវា** " នេះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែង ថា " បុគ្គលគប្បីប្រារព្ធ នូវជនទាំងឡាយ ឯណានីមួយ មានទេវតានិងមនុស្សជាដើម សូម្បីដទៃហើយថ្វាយនូវទាន " ។ បណ្ដាទេវតាទាំងនោះ ព្រះដ៏មានព្រះភាគកាលទ្រង់សំដែង នូវទេវតាពួកខ្លះ ដែលប្រាកដមុន ទើបទ្រង់ត្រាស់ថា " **ចត្តារោ វ មហារាជេ** " ដូច្នេះ កាលនឹងបញ្ជាក់នូវទេវតាទាំងនោះ ដោយឈ្មោះទៀត ទើបត្រាស់ថា " **កុវេរំ** " ជាដើម ។

បណ្ដាបទទាំងនោះ បទ ថា " **កុវេរំ** " គឺ ព្រះវេស្សវ័ណ ។ បទ ថា " **ធតរដ្ឋំ** " ជាដើម ជាឈ្មោះ នៃស្ដេចលោកបាល ទាំង ៣ ដែលសេសសល់ ។ បាទគាថា ថា " **តេ ចេវ បូជិតា ហោន្តិ** " មានសេចក្ដីថា ស្ដេចធំទាំងឡាយ និង បុព្វជនដែលលះលោកនេះទៅហើយ និងទេវតាទាំងឡាយនោះ រមែងជាអ្នក គឺទាយករាប់អានហើយ ដោយកិរិយាគឺការឧទ្ទិស ។ បាទគាថា ថា " **ទាយកា ច អនិប្ផលា** " មានសេចក្ដីថា ឯទាយកទាំងឡាយណា តែងឲ្យទាន, ទាយកទាំងឡាយនោះ រមែងជាអ្នកមិនឥតផលឡើយ គឺ ជាអ្នកមានចំណែក នៃផលទាន របស់ខ្លួន ដោយពិត ដោយកិច្ចគ្រាន់តែការឧទ្ទិសឲ្យ ដល់ជនទាំងឡាយដទៃ ។ ២ គាថា ថា " **ន ហិ រុណ្ណំ វា សោកោ វា** " គប្បីជ្រាប ដោយន័យ នៃពាក្យដែលបាន

ពោលមកហើយ ក្នុងតិរោកុឌ្ឌសូត្រ ។

(២០៧) ចំណែក ក្នុងអដ្ឋកថាបិដ្ឋធីតលិកបេតវត្ថុ លោកពោល ថា " ក៏ទាននោះ រមែងសម្រេចផល ដោយរួសរាន់ គឺរមែងកើតផល ក្នុងខណៈនោះឯង អធិប្បាយថា មិនមែនក្នុងកាលផ្សេង ៗ មែនពិត កាលបើទាយក ថ្វាយទានឧទ្ទិសឲ្យប្រេតទាំងឡាយ, បើសិនជា ប្រេតទាំងឡាយ អនុមោទនា, ប្រេតទាំងឡាយ ក៏នឹងសោយ ( នូវសម្បត្តិ ) ដោយផល នៃទាននោះ ក្នុងពេលមួយរំពេចនុ៎ះឯង ឯណា, ការសម្រេចនៃទាន ដែលទាយកថ្វាយឧទ្ទិសឲ្យដល់ប្រេតទាំងឡាយនេះ ជាធម្មតាទេ ក្នុងការឧទ្ទិសឲ្យនោះ ។

ព្រះសាស្តា លុះទ្រង់សំដែងធម៌ យ៉ាងនេះហើយ ទ្រង់ធ្វើនូវមហាជន ឲ្យមានចិត្តត្រេកអរក្រៃលែង ក្នុងទានឧទ្ទិសឲ្យ ពួកប្រេតហើយ ទើបទ្រង់ក្រោកចាកពីអាសនៈ ស្តេចគេចចេញទៅហើយ ។ លុះព្រឹកឡើង ភរិយានៃសេដ្ឋី និងពួកញាតិក្រៅពីនោះ ក៏ប្រព្រឹត្តតាមសេដ្ឋី ៗ ជនទាំងនោះ បំពេញមហាទាន ឲ្យប្រព្រឹត្តទៅ យ៉ាងនោះ ប្រមាណ ១ ខែ ។ ព្រះសាស្តា ត្រូវព្រះបាទបសេនទិកោសលក្រាបទូលសួរ ថា " បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុអ្វី បានជាភិក្ខុទាំងឡាយ មិននិមន្តមក កាន់ផ្ទះ នៃទូលព្រះបង្គំ អស់រយៈពេលប្រមាណ ១ ខែ ? " ដូច្នេះ ទ្រង់ត្រាស់សេចក្តីនោះហើយ ។

ឯព្រះរាជា កាលទ្រង់ប្រព្រឹត្តតាម នូវសេដ្ឋី ទ្រង់បំពេញមហាទាន ឲ្យប្រព្រឹត្តទៅហើយ ។ ចំណែក ប្រជាជនទាំងឡាយ កាលប្រព្រឹត្តតាមព្រះរាជានោះ បានបំពេញមហាទាន ឲ្យប្រព្រឹត្តទៅ ប្រមាណជា ១ ខែ ។ មហាទាន ដែលមានរូបតុកតាម្សៅជាមូលហេតុ ប្រព្រឹត្តទៅហើយ យ៉ាងដូច្នោះ អស់រយៈពេល ២ ខែ ។

រឿងបិដ្ឋធីតលិកប្រេត ចប់ ។

(២០៨) ចេតនាជាហេតុអនុមោទនា សូម្បីរបស់ប្រេតទាំងឡាយ រមែងជាគុណជាតិឲ្យផល ក្នុងខណៈនោះបាន, មិនបាច់ពោលធ្វើអ្វី ដល់ចេតនាជាហេតុអនុមោទនា របស់ពួកមនុស្សឡើយ ? ។

ក្នុងសេចក្តីនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងឧបាសកម្នាក់ )

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធ ទ្រង់ព្រះនាមកស្សបៈ មានឧបាសកម្នាក់ ជាសោតាបន្ន បានចុះទូក ជាមួយនឹងកុដុម្ពី ជាងកាត់សក់ម្នាក់ ។ ក្នុងថ្ងៃទី ៧ នាវា ក៏បានកឿង នៅត្រង់កណ្តាលនៃសមុទ្រ ។ ជនទាំង ២ នាក់នោះឯង ដេកលើបន្ទះក្តារមួយ ហើយក៏បានទៅដល់កោះមួយ ។ បណ្តាជនទាំង ២ នាក់នោះ ជាងកាត់សក់ សម្លាប់សត្វទាំងឡាយហើយ អាំងស៊ី ឲ្យដល់ឧបាសកខ្លះ ។

ឧបាសកពោល ថា “ខ្ញុំគ្រប់គ្រាន់ហើយ” ដូច្នេះ មិនបរិភោគ ហើយ គិត ថា “ក្នុងទីនេះ ក្រៅអំពីព្រះត្រ័យសរណៈ ចេញហើយ ទីពឹងដទៃ របស់អាត្មាអញ មិនមានឡើយ”។ កាលបើឧបាសកនោះ រឮក នូវគុណ នៃព្រះរតនត្រ័យ យ៉ាងនេះ, ស្ដេចនាគរាជ ក៏កើតឡើង ហើយ ក្នុងកោះនោះ និមិត្តសរីរៈ របស់ខ្លួន ធ្វើជាទូកយ៉ាងធំ ពេញ ដោយរតនៈ ៧ ប្រការ ។ សមុទ្រទេវតា បានជាអ្នកកាន់ចង្កូតទូក ឋិតនៅលើទូក ស្រែកប្រកាស ថា “បុគ្គលអ្នកទៅកាន់ជម្ពូទ្វីប មាន ដែរឬទេ ?”។ ឧបាសកប្រាប់ ថា “យើងទាំងឡាយ នឹងទៅ” កាលបើទេវតាពោល ថា “ចូរអ្នកមក ចុះទូក” ដូច្នេះ, កំពុងតែចុះ ទូក បានហៅជាងកាត់សក់ (ឲ្យចុះទូកផង) ។ ទេវតាពោល ថា “បុគ្គលនុ៎ះ មិនមានគុណគឺសីលនិងមារយាទឡើយ, ព្រោះហេតុ នោះ បុគ្គលនុ៎ះ ជាអ្នកមិនគួរ ដើម្បីនឹងចុះទូកនេះទេ”។ ឧបាសក ពោល ថា “ហេតុនុ៎ះ ចូរស្លេះសិនចុះ, ខ្ញុំនឹងឲ្យនូវចំណែកបុណ្យ អំពីទានដែលខ្លួនខ្ញុំ បានឲ្យហើយ ពីសីលដែលខ្លួនខ្ញុំ បានរក្សាហើយ និងអំពីភាវនាដែលខ្លួនខ្ញុំបានអប់រំហើយ ដល់បុរសនុ៎ះ”។ ជាង កាត់សក់ពោល ថា “ខ្ញុំសូមអនុមោទនា”។ ក្នុងពេលនោះ ទេវតា ឲ្យបុរសនោះ ស្ថិតនៅលើទូកហើយ បានអុំទូកនោះ សំដៅទៅទីក្រុង ពារាណសី ញុំាងទ្រព្យឲ្យតាំងនៅ ក្នុងផ្ទះនៃជនទាំង ២ នាក់នោះ

ស្រេចហើយ ក៏បានត្រឡប់ទៅវិមានរបស់ខ្លួនវិញ ។

រឿង ឧបាសក មកក្នុងអដ្ឋកថាសីលានិសង្សជាតក ក្នុងចតុក្កវគ្គ ទុកនិបាត ។

## ( រឿងសង្ខព្រាហ្មណ៍ )

(២០៩) ក្នុងអតីតកាល ទីក្រុងពារាណសី មានឈ្មោះថា មោឡិនី ។ ក្នុងកាលនោះ ព្រះពោធិសត្វ បានជាព្រាហ្មណ៍ នាមថាសង្ខៈ ក្នុងទីក្រុងមោឡិនី ទៅដើម្បីលក់ដូរ តាមទូក ជួបនឹងព្រះបច្ចេកពុទ្ធជាម្ចាស់មួយអង្គ ក្នុងចន្លោះផ្លូវ លោកកំពុងតែជាន់នូវដីខ្សាច់ដ៏ក្តៅធំ ដូចជារងើកភ្លើង ព្រោះខ្យល់ និងកំដៅថ្ងៃក្តៅពន្លឹកនិមន្តមក មានចិត្តត្រេកអរ ថា " ស្រែបុណ្យ របស់អាត្មាអញ មកដល់ហើយ " ទើបទូល ថា " បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គពាក់ស្បែកព្រះបាទនេះ ហើយបាំងឆ័ត្រ និមន្តទៅ " ដូច្នេះហើយ ក៏ប្រគេនឆ័ត្រនិងស្បែកព្រះបាទហើយ ទៅកាន់កំពង់ ហើយចុះទូក ៗ ក្នុងថ្ងៃទី ៧ នាវា បានលិចហើយ ៗ ព្រះពោធិសត្វ នាំបុរសជាឧបដ្ឋាកម្នាក់ទៅ យកប្រេងលាបពេញទាំងសរីរៈហើយ បរិភោគលំអិតស្ករក្រួស ជាមួយនឹងទឹកដោះរាវ តាមត្រូវការហើយ ឲ្យបុរសឧបដ្ឋាកនោះបរិភោគផងហើយ ឡើងកាន់កំពូល នៃសសរក្តោងជាមួយនឹងបុរសឧបដ្ឋាកនោះ ផ្លោះលោតឡើងធ្លាក់ទៅ ក្នុងទីបំផុត

ប្រមាណ ១ ឧសភៈ ប្រារព្ធដើម្បីនឹងឆ្លងសមុទ្រ ។ កាលបើឧបាសក នោះ កំពុងតែឆ្លង (សមុទ្រ) នុ៎ះឯង, ៧ ថ្ងៃ កន្លងទៅហើយ ។ ក្នុងគ្រានោះ នាងទេវធីតា ឈ្មោះថា មណីមេខលា អ្នកថែរក្សានូវសមុទ្រ ប្រាថ្នានឹងជួយស្រង់ព្រះពោធិសត្វ ទើបនិមិត្តនាវាសម្រេចដោយរតនៈ ពេញទៅដោយរតនៈ ៧ ប្រការ លើកព ព្រះពោធិសត្វនោះ ដាក់លើនាវា មិនឲ្យក្រឡេកមើលបុរស ជាឧបដ្ឋាកឡើយ ។ ព្រះពោធិសត្វ បានឲ្យនូវចំណែកបុណ្យ អំពីកល្យាណកម្ម ដែលខ្លួនបានធ្វើហើយ ដល់ឧបដ្ឋាកនោះ ។ ឧបដ្ឋាកនោះ អនុមោទនាហើយនូវចំណែកបុណ្យនោះ ។ គ្រានោះ ទេវតា បានឲ្យឧបដ្ឋាកនោះស្ថិតនៅលើនាវា នាំនាវានោះ ឆ្ពោះទៅកាន់ទីក្រុងមោឡិនី ញុំាងទ្រព្យឲ្យតាំងនៅលើផ្ទះ របស់ព្រះពោធិសត្វហើយ ក៏បានវិលត្រឡប់ទៅកាន់វិមានរបស់ខ្លួនវិញភ្លាម ។

រឿងនេះ លោកពោលហើយ ក្នុងអដ្ឋកថាសង្ខព្រាហ្មណជាតក ក្នុងទសកនិបាត ។

## ( បត្តិទាន និង បត្តានុមោទនា )

(២១០) ព្រោះហេតុនោះ កុលបុត្រ កាលនឹងសន្សំ នូវបុញ្ញកិរិយា ដែលឈ្មោះថា បត្តិទាន ដោយខ្លួនឯង និងញុំាងបុញ្ញ-កិរិយា ដែលឈ្មោះថា បត្តានុមោទនា ឲ្យកើតឡើង ដល់បុគ្គល

ទាំងឡាយដទៃ គប្បីធ្វើទានឧទ្ទិសឲ្យប្រេតទាំងឡាយ ដោយពិត, មួយទៀត កុលបុត្រ ធ្វើបុណ្យឯណាមួយ តាមប្រក្រតី របស់ខ្លួនហើយ គប្បីឧទ្ទិសចំណែកបុណ្យ ដល់ពួកជនឯទៀតផងដែរ ដូចជាស្តេចចក្រពត្តិ ព្រះនាមតិលោកវិជ័យ ជាព្រះពោធិសត្វ យ៉ាងដូច្នោះៗ

បានឮថា ព្រះរាជាព្រះនាមតិលោកវិជ័យអង្គនោះ កាលនឹងទ្រង់ញ៉ាំងជនទាំងឡាយ ឲ្យទទួលយក នូវបុញ្ញសម្បត្តិ ដែលព្រះអង្គបានធ្វើហើយ ទើបទ្រង់ត្រាស់គាថាទាំងឡាយ ៤ ក្នុងពុទ្ធាបទាន ថា៖

(២១១) " អំពើជាកុសលណាមួយ ដែលខ្ញុំគប្បីធ្វើ ដោយកាយ វាចា ចិត្ត, អំពើជាកុសលទាំងអស់នោះ ជាកុសល គួរដល់ការកើតក្នុងសុគតិ ក្នុងត្រៃត្រឹង្ស ខ្ញុំបានធ្វើហើយ ។ សត្វទាំងឡាយណា មានសញ្ញា និងសត្វទាំងឡាយណា ឥតមានសញ្ញា, សត្វទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ ។ សត្វទាំងឡាយណា បានដឹងច្បាស់ នូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ, សត្វទាំងឡាយនោះ ចូរបានទទួល នូវផលនៃបុណ្យ ដែលខ្ញុំបានឲ្យហើយ,ម្យ៉ាងទៀត បណ្តាសត្វទាំងនោះ សត្វទាំងឡាយណា

មិនបានដឹង, សូមទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះផង ។ សត្វទាំងអស់ណា ក្នុងលោក ដែលអាស្រ័យអាហារហើយរស់នៅ, សត្វទាំងអស់នោះ ចូរបាននូវភោជន ជាទីគាប់ចិត្ត តាមចិត្តនៃខ្ញុំចុះ " ។

(២១២) ន័យមកក្នុងអដ្ឋកថាអបទាន ថា "បណ្ដាបទទាំងនោះ បទ ថា 'មយា' ប្រែថា គឺខ្ញុំ ។ បាទគាថា ថា " **កាយេន វាចាមនសា** " មានសេចក្ដីថា កុសលកម្មណាមួយ ជាកិរិយាពោលគឺកុសលកម្ម ដែលគួរធ្វើ ដោយត្រៃទ្វារ រមែងមាន ។ បទ ថា " **តិទសេ** " បានដល់ ភពត្រៃត្រឹង្ស ។ បទ ថា " **សុគតំ** " បានដល់ គួរដល់ការកើតឡើងក្នុងសុគតិ ។ អធិប្បាយថា កុសលកម្មទាំងអស់នោះ គឺខ្ញុំបានធ្វើហើយ ។

បានឮថា ព្រះរាជាព្រះអង្គនោះ ច្យុតចាកអត្តភាព នៃស្ដេចចក្រពត្តិ ព្រះនាមតិលោកវិជ័យហើយ នឹងកើត ក្នុងពួកទេវតាជាន់តាវតឹង្ស ។ ហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ព្រះតម្រាស់នោះថា " **សុគតំ** " ។ ២ បទ ថា " **សញ្ញិនោ អត្ថិ** " មានសេចក្ដីថា សត្វទាំងឡាយណា មានឈ្មោះថា "មនុស្ស ទេវតា ឬព្រហ្ម" មាន ។

បទ ថា "**អសញ្ញិនោ**" មានសេចក្តីថា និង សត្វទាំងឡាយណា ប្រាសចាកសញ្ញា គឺ ជាសត្វដែលមិនមានសញ្ញា ក៏មាន ។ បទ ថា "**មយ្ហំ**" មានសេចក្តីថា សត្វទាំងឡាយ ទាំងអស់នោះ ចូរជាអ្នក មានចំណែក សោយផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ, អធិប្បាយ ថា ចូរជាអ្នកមានចំណែកបុណ្យ បរិភោគចុះ ។

បទ ថា "**យេ**" មានសេចក្តីថា បុណ្យដែលខ្ញុំបានធ្វើហើយ នោះ ជាបុណ្យដែលសត្វទាំងឡាយណា បានដឹងច្បាស់ហើយ គឺ ដឹង ល្អហើយ, សត្វទាំងឡាយនោះ ចូរមានចំណែក បរិភោគនូវផលនៃ បុណ្យដែលខ្ញុំបានឲ្យហើយនោះចុះ ។ ២ បទ ថា "**យេ ច តត្ថ**" មានសេចក្តីថា ម្យ៉ាងទៀត បណ្តាសត្វទាំងនោះ សត្វទាំងឡាយ ឯណា មិនបានដឹង នូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ ។ បទ ថា "**និវេទយុំ**" មានសេចក្តីថា សូមពួកទេវតា គប្បីអញ្ជើញទៅឲ្យ ដំណឹងដល់សត្វទាំងឡាយនោះ ឬ គប្បីប្រាប់ ដល់សត្វទាំងឡាយនោះ ផង ថា "បុគ្គលឯណោះ បានធ្វើបុណ្យ ឈ្មោះនេះហើយ បានឲ្យនូវ ចំណែកបុណ្យមក ដល់អ្នកទាំងឡាយ" ។

បាទគាថា ថា "**ជីវន្តាហារហេតុកា**" មានសេចក្តីថា សត្វ ទាំងឡាយ ទាំងពួងណា ក្នុងលោក ដែលតាំងនៅបាន ព្រោះអាហារ គឺ អាស្រ័យអាហារហើយរស់នៅ ។ បទ ថា "**សព្វេ**" បានដល់

សត្វទាំងឡាយទាំងពួងនោះ ។ បទ ថា "ចេតសា" មានសេចក្ដីថា ចូរបាននូវភោជនជាទីគាប់ចិត្ត តាមចិត្ត គឺតាមបុញ្ញប្បទិ្ធ នៃខ្ញុំចុះ" ។

## ( ប្រយោជន៍នៃការប្រើប្រាស់ភោគៈ )

(២១៣) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវទានដែលបុគ្គលគប្បីថ្វាយ ដល់ព្រះទក្ខិណេយ្យបុគ្គល ដើម្បីជាប្រយោជន៍ ដល់មាតានិងបិតាទាំងឡាយ ដែលធ្វើកាលកិរិយាទៅហើយ ក្នុងសិគាលសូត្រ ដោយប្រការដូច្នេះ, មិនមែនទ្រង់ត្រាស់ ដោយអំណាចនៃពលីកម្ម ដើម្បីមាតានិងបិតា ទាំងនោះឡើយ ។ សូម្បីព្រះដ៏មានព្រះភាគ មិនបានត្រាស់ ដោយអំណាច នៃពលីកម្ម ដើម្បីមាតាបិតាទាំងនោះ ក៏ពិតមែនហើយ, ទោះបីជាយ៉ាងនោះក៏ដោយ បុត្រនឹងធ្វើសូម្បីពលីកម្ម ដើម្បីមាតាបិតាទាំងឡាយ ដែលធ្វើកាលកិរិយាទៅហើយ ក៏សមគួរ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់ឱវាទ នូវអនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ (គាថាទាំងនេះ) ក្នុងអាទិយសូត្រ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ថា ÷

" នរជន អ្នកមានសេចក្ដីស្ងាប់ជាធម្មតា កាលរលឹកឃើញ នូវប្រយោជន៍នុះ ថា ' ភោគៈទាំងឡាយ

អាត្មាអញ បរិភោគហើយ, មិត្រអាមាត្យ អាត្មាអញ ចិញ្ចឹមហើយ, អាត្មាអញ ឆ្លងអន្តរាយទាំងឡាយបាន ហើយ, ទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ អាត្មា អញបានឲ្យហើយ, ឯពលីទាំង ៥ យ៉ាង អាត្មាអញ បានធ្វើហើយ, អ្នកមានសីល មានសេចក្តីសង្រួម មានព្រហ្មចរិយធម៌ អាត្មាអញ បានទំនុកបំរុងហើយ, បណ្ឌិតកាលនៅគ្រប់គ្រងផ្ទះ គប្បីប្រាថ្នាភោគៈ ដើម្បី ប្រយោជន៍ណា, ប្រយោជន៍នោះ អាត្មាអញ ក៏បាន សម្រេចហើយ, កម្មដែលមិននាំ ឲ្យកើតសេចក្តីក្តៅ ក្រហាយ អាត្មាអញ បានធ្វើហើយ ' ដូច្នេះ ឋិតនៅ ក្នុងអរិយធម៌, បណ្ឌិតទាំងឡាយ រមែងសរសើរនរជន នោះ ក្នុងលោកនេះ ដោយពិត, នរជននោះ លុះលះ លោកនេះទៅហើយ រមែងត្រេកអរ ក្នុងឋានសួគ៌ "។

(២១៤) បណ្តាបទទាំងនោះ បទ ថា " **ភុត្តា** " មានសេចក្តី ថា ភោគៈទាំងឡាយ អាត្មាអញបរិភោគហើយ ។ បទ ថា " **ភតា** " មានសេចក្តីថា បុគ្គលដែលគួរចិញ្ចឹម គឺ មាតាបិតា បុត្រ ភរិយា ខ្ញុំបំរើ កម្មករ និងមិត្រអាមាត្យ អាត្មាអញចិញ្ចឹមហើយ គឺ បំរុង

ហើយ បានដល់ ឧបត្ថម្ភហើយ ។ សុ អក្សរ ក្នុងបទ ថា "អាបទាសុ" នេះ គ្រាន់តែជានិបាត ។ មានពាក្យអធិប្បាយថា "សេចក្តីអន្តរាយទាំងឡាយ គឺ សេចក្តីចង្រៃទាំងឡាយ ដែលកើត អំពីភ្លើង ទឹក ស្តេច ចោរ និងបុគ្គលអ្នកទទួលមត៌ក ដែលមិនជាទីស្រឡាញ់ អាត្មាអញបានឆ្លងផុតហើយ គឺ អាត្មាអញបានរារាំងហើយ បានដល់អាត្មាអញ បានហាមឃាត់ហើយ ដោយកិរិយាបិទនូវផ្លូវ នៃសេចក្តីអន្តរាយទាំងនោះ ដោយភោគៈទាំងឡាយ" ។ មែនពិត បើសេចក្តីអន្តរាយទាំងឡាយ កើតឡើងហើយ អំពីភ័យមាន ភ្លើងជាដើម, កុលបុត្រ កាលធ្វើ នូវការបរិច្ចាគទ្រព្យ ដើម្បីជាប្រយោជន៍ ដល់ហេតុទាំងឡាយ មានការជួយពន្លត់ភ្លើង ដែលឆេះផ្ទះជាដើម ឈ្មោះថា តែងបិទ គឺ ហាមឃាត់ នូវផ្លូវនៃសេចក្តីអន្តរាយ ទាំងឡាយនោះ ដោយភោគៈទាំងឡាយ ។ ក្នុងបទ ថា "ឧទ្ធគ្គា" គប្បីជ្រាបវិគ្រោះ ដូចតទៅ÷ ផលនៃទក្ខិណានោះ (ទៅ) ក្នុងទីដ៏ខ្ពង់ខ្ពស់ ដោយអំណាចនៃការឲ្យផល ក្នុងភូមិដែលខ្ពង់ខ្ពស់ទាំងឡាយ ពោលគឺ កាមាវចរសួគ៌ ៦ ជាន់ ហេតុនោះ ទក្ខិណានោះ ឈ្មោះថា ឧទ្ធគ្គា មានផល ដ៏ខ្ពង់ខ្ពស់ប្រសើរ ។ ក៏ផលនៃកម្ម ឈ្មោះថា អគ្គៈ, ផលនោះ ក្នុងទក្ខិណានេះ មានប្រក្រតីទៅ ព្ធដ៏ខាងលើ ហេតុនោះ ទើបលោកពោល ថា "ឧទ្ធមគ្គមស្សា" ដូច្នេះ ។ បទ ថា "ទិន្នា"

បានដល់ អាត្មាអញ បានឲ្យហើយ ដោយភោគៈទាំងឡាយ ។ ២ បទ ថា " **បញ្ច ពលី** " មានសេចក្ដីថា ពលី ៥ យ៉ាង អាត្មាអញបានធ្វើហើយ ដោយភោគៈទាំងឡាយ ។

(២១៥) ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះតម្រាស់នេះក្នុងចុណ្ណិយបទ ថា " ម្នាលគហបតី ពាក្យដែលតថាគត គប្បីពោលនៅមានទៀត, អរិយសាវក ជាអ្នកធ្វើពលី ៥ យ៉ាង គឺ ញាតិពលិ ( សង្គ្រោះញាតិ ) អតិថិពលិ ( ទទួលភ្ញៀវ ) បុព្វបេតពលិ ( ធ្វើបុណ្យឧទ្ទិសកុសលឲ្យអ្នកដែលស្លាប់ ) រាជពលិ ( បង់ពន្ធដារដល់រាជការ ) ទេវតាពលិ ( ធ្វើបុណ្យឧទ្ទិសទេវតា ) ដោយភោគៈទាំងឡាយ ដែលខ្លួនបានមក ដោយសេចក្ដីព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ " ។

(២១៦) អដ្ឋកថាចុណ្ណិយបទនោះ ថា " បទ ថា **ឧដ្ឋានវីរិយាធិគតេហិ** បានដល់ ដែលខ្លួនបានមកហើយ ដោយសេចក្ដីព្យាយាម ពោលគឺការខ្នះខ្នែង ។ បទ ថា " **ពាហាពលបរិចិតេហិ** " បានដល់ ដែលខ្លួនបានប្រមូលមកហើយ ដោយកម្លាំងដៃ ។ បទ ថា " **សេទាវក្ខិត្តេហិ** " បានដល់ ដែលខ្លួនញាំងញើស ឲ្យហូរហើយហូរទៀត ឲ្យកើតឡើងហើយ ។ បទ ថា " **ធម្មិកេហិ** " បានដល់

ដែលប្រកបដោយធម៌ ។ បទ ថា “**ធម្មលទ្ធេហិ**” បានដល់ ដែល ខ្លួនបំពេញកុសលធម៌ ១០ ប្រការ ហើយទើបបានមក ។ បទ ថា “ **ញាតិពលី** ” បានដល់ សង្គ្រោះ ញាតិទាំងឡាយ ។ បទ ថា “**អតិថិពលី**”បានដល់ ការទទួលភ្ញៀវ ។ បទ ថា “**បុព្វបេ្បតពលី**” បានដល់ ការធ្វើបុណ្យឧទ្ទិសឲ្យ ដល់ញាតិទាំងឡាយ ដែលទៅកាន់ បរលោកហើយ ។ បទ ថា “**រាជពលី** ” បានដល់ ការបង់ពន្ធ ដារដែលគួរធ្វើដល់ព្រះរាជា ។ បទ ថា “ **ទេវតាពលី** ” បានដល់ ការធ្វើបុណ្យ ឧទ្ទិសកុសល ដែលគួរធ្វើ ដល់ទេវតាទាំងឡាយ ។ ពាក្យថា “ **ពលី** ” ទាំងអស់នោះ ជាឈ្មោះ នៃទានដែលបុគ្គលគប្បី ឲ្យ ដល់មនុស្សនិងអមនុស្សទាំងឡាយនោះ ។ ដោយអំណាច នៃ ទាន តាមសមគួរ ” ។

(២១៧) បទ ថា “ **ឧបដ្ឋិតា** ” បានដល់ ដែលអាត្មាអញ បានបំរុងហើយ ដោយភោគៈទាំងឡាយ ។ បទ ថា “ **យទត្ថំ** ” បានដល់ ដើម្បីប្រយោជន៍ណា មានការបរិភោគ ខ្លួនឯងជាដើម ។ បទនេះ ជាចតុត្ថីវិភត្តិ,ម្យ៉ាងទៀត អធិប្បាយថា ដើម្បីធ្វើនូវ ប្រយោជន៍ណា ។ ២ បទ ថា “ **ឃរមាវសំ** ” បានដល់ នៅ គ្រប់គ្រងផ្ទះ ។ បទ ថា “**អននុតាបិយំ** ” មានសេចក្តីថា កម្មដែល ឈ្មោះថា ប្រាសចាកសេចក្តីក្តៅក្រហាយ ព្រោះធ្វើប្រយោជន៍នោះ

អាត្មាអញបានធ្វើហើយ ៗ បទ ថា " ឯតំ " មានសេចក្តីថា បុគ្គល ជាឧបាសក ដែលមានសេចក្តីស្លាប់ជាធម្មតា កាលរឭក គឺ កាលនឹក ឃើញប្រយោជន៍នេះ គឺ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ដោយ ន័យ ថា " ភុត្តា ភោគា " ដូច្នេះ ជាដើម ដោយប្រការដូច្នេះ ៗ បទ ថា " អរិយធម្មេ " បាដល់ តាំងនៅហើយ ក្នុងធម៌ គឺសីល ៥ ៗ មែនពិត សីល ៥ ឈ្មោះថា អរិយធម៌ ព្រោះជាធម៌ដែលព្រះអរិយៈ ទាំងឡាយប្រាថ្នា គឺ ព្រោះជាទីស្រឡាញ់នៃព្រះអរិយៈទាំងឡាយ ៗ

ក៏ព្រះអរិយៈទាំងឡាយ សូម្បីទៅកាន់ភពដទៃ ក៏មិនលះចោល នូវសីល ៥ នោះឡើយ ៗ មានព្រះតម្រាស់អធិប្បាយ យ៉ាងនេះ ថា " ម្នាលគហបតី ឧបាសកឈ្មោះប្រាកដដូចអ្នក កាលកាន់យកភោគៈ ទាំងឡាយ គប្បីកាន់យកភោគៈទាំងឡាយ ដោយហេតុ ៥ យ៉ាង គឺ ' អាត្មាអញ នឹងធ្វើខ្លួន និងមាតាបិតា បុត្រ ភរិយា ទាសៈ កម្មករ និងបុរសទាំងឡាយ ឲ្យបានទទួលសេចក្តីសុខ ដោយភោគៈទាំង ឡាយនេះ ' ដូច្នេះ ប្រការមួយ, ' អាត្មាអញ នឹងធ្វើមិត្ត អាមាត្យ ទាំងឡាយ ឲ្យបានទទួលសេចក្តីសុខ ដោយភោគៈទាំងឡាយនេះ " ដូច្នេះ ប្រការមួយ, ' អាត្មាអញ, កាលបើសេចក្តីអន្តរាយទាំង ឡាយ កើតឡើងហើយ អំពីភ័យទាំងឡាយ មានភ្លើងជាដើម, នឹង បិទនូវផ្លូវ នៃសេចក្តីអន្តរាយទាំងនោះ ដោយភោគៈទាំងឡាយហើយ

ធ្វើខ្លួន ឲ្យមានសិរីសួស្តី ' ដូច្នេះ ប្រការមួយ, ' អាត្មាអញ នឹងញុំាងទក្ខិណា ដែលមានផលខ្ពង់ខ្ពស់ប្រសើរ ឲ្យតាំងនៅស៊ប់ ក្នុងសមណៈ ព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ទាំងឡាយ ដោយភោគៈទាំងឡាយនេះ ' ដូច្នេះ ប្រការមួយ, ' អាត្មាអញ នឹងធ្វើនូវពលីទាំង ៥ យ៉ាង ដោយភោគៈទាំងឡាយនេះ ' ដូច្នេះ ប្រការមួយ ។ ឧបាសកនោះ ជាអ្នកមានភោគៈកាន់យកហើយ យ៉ាងនេះ កាលនឹងធ្វើប្រយោជន៍ ដែលខ្លួនប្រាថ្នាភោគៈទាំងឡាយ ឈ្មោះថា រមែងលះបង់សេចក្តីក្តៅក្រហាយ ស្តាយក្រោយ ដែលមានវិបដិសារី ជាលក្ខណៈចោលបាន ។ ក៏សូម្បីតែសីល របស់ឧបាសក អ្នកលះបង់សេចក្តីក្តៅក្រហាយស្តាយក្រោយបានហើយ រមែងបរិសុទ្ធស្អាត ។ មួយទៀត សូម្បីទេវតាទាំងឡាយ ក៏សរសើរ នូវបុគ្គលនោះ ដែលប្រតិបត្តិ យ៉ាងដូច្នោះ, បុគ្គលនោះ លះលោកនេះទៅហើយ រមែងរីករាយសប្បាយ ក្នុងស្ថានសួគ៌ " ។

ព្រោះហេតុនោះ គ្រហស្ថ អ្នករឭកឃើញឱវាទ នៃព្រះសុគតនេះ គប្បីធ្វើសូម្បីពលិកម្ម ដើម្បីញាតិ ដែលធ្វើកាលកិរិយាទៅហើយទាំងឡាយ ដោយកិរិយាវៀរចាកបាណាតិបាតជាដើម ដោយពិត ។

## ( មាតាបិតាសង្គ្រោះបុត្រ ដោយស្ថាន ៥ យ៉ាង )

(២១៨) ដូច្នោះ ការទំនុកបំរុង មានការចិញ្ចឹមជាដើម

ឈ្មោះថា ជាមង្គល ព្រោះជាហេតុ នៃប្រយោជន៍សុខ ក្នុងបច្ចុប្បន្ន ៥ យ៉ាង ដោយកិរិយាហាម ចាកសេចក្ដីអាក្រក់ ឲ្យតាំងនៅក្នុងសេចក្ដីល្អ ឲ្យសិក្សាសិល្បៈ ចាត់ការដោយភរិយាដែលសមគួរ និងប្រគល់ទ្រព្យមត៌កឲ្យ ។

ដោយហេតុដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា " ម្នាលគហបតីបុត្រ ទិសខាងមុខ គឺ មាតាបិតា ដែលបុត្រធីតាទំនុកបំរុងហើយ ដោយស្ថាន ៥ យ៉ាងនេះឯង រមែងអនុគ្រោះ នូវបុត្រ (ធីតា) ដោយស្ថាន ៥ យ៉ាង គឺ : រមែងហាមប្រាមចាកអំពើអាក្រក់, ឲ្យតាំងនៅក្នុងអំពើល្អ, ឲ្យសិក្សាសិល្បៈ, ចាត់ចែងដោយភរិយាដែលសមគួរ, ប្រគល់ទ្រព្យមត៌កឲ្យ ក្នុងសម័យដ៏គួរ ។ ម្នាលគហបតីបុត្រ ទិសខាងមុខ គឺមាតាបិតា ដែលបុត្រទំនុកបំរុងហើយ ដោយស្ថាន ៥ យ៉ាងនេះ រមែងអនុគ្រោះបុត្រធីតាដោយស្ថាន ៥ យ៉ាងនេះឯង " ។

## ( ហាមប្រាមបុត្រធីតាចាកអំពើអាក្រក់ )

(២១៩) បណ្ដាស្ថាន ៥ យ៉ាងនោះ ក្នុងស្ថានទី ១ នេះ ថា " បាបា និវារេន្តិ " គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ ឈ្មោះថាការហាមចាកអំពើអាក្រក់ មានអនាគត ជាអារម្មណ៍ ។ ព្រោះថា

ការហាមចាកវត្ថុដែលខ្លួនចួបប្រទះគប្បីមានជាមុន កាលបើ (បុត្រ) មិនទាន់បានធ្វើខុសនុ៎ះឯង, កុំចាំដល់បុត្រមានការប្រព្រឹត្តិខុសទើបបានហាមប្រាមឡើយ, ប៉ុន្តែការធ្វើអំពើអាក្រក់ ដែលបុត្របានបង្កើតឡើងហើយ មានកិរិយាត្រឹមតែការតិះដៀល ជាគ្រឿងតបស្នងមកវិញ ។ ហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោល ថា "មាតាបិតា ប្រាប់ទោសដែលមានក្នុងបច្ចុប្បន្ន និងសម្បរាយិកភពនៃបាបធម៌ទាំងឡាយ មានបាណាតិបាតជាដើមហើយ ហាមប្រាម ថា ថា 'នែកូនសំឡាញ់ ចូរអ្នកកុំធ្វើបាបកម្ម យ៉ាងនេះឡើយ' ដូច្នេះ, រមែងតិះដៀលសូម្បីនូវបាបកម្ម ដែលបុត្រធ្វើហើយ " ។

( ឲ្យបុត្រធីតាតាំងនៅក្នុងអំពើល្អ )

(២២០) ក្នុងស្ថានទី ២ ថា " កល្យាណេ និវេសេន្តិ " គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ មាតាបិតា សូម្បីឲ្យរង្វាល់ហើយ ញុំាងបុត្រធីតាឲ្យតាំងនៅ គឺ ឲ្យតាំងនៅស៊ប់ ក្នុងកុសលទាំងឡាយ មានការសមាទានសីលជាដើម ដូចជាអនាថបិណ្ឌិកៈ និងមាតា របស់នាយមិត្តវិន្ទកៈ ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ។

( រឿងកាឡកុមារ )

(២២១) បានឮមកថា អនាថបិណ្ឌិកសេដ្ឋី មិនអាចហាម

កុមារឈ្មោះកាឡៈ ជាកូនប្រុសរបស់ខ្លួន ដែលមិនធ្វើកម្ម គឺការចូលគាល់ព្រះពុទ្ធ ការស្តាប់ធម៌ និងការខ្វល់ខ្វាយបំរើព្រះសង្ឃ ទាំងឡាយ ទើបពោល ថា " នែកូន ចូរកូន ជាអ្នករក្សាឧបោសថសីល ស្តាប់ធម៌ ក្នុងព្រះវិហារហើយ ចាំមក, ឳពុក នឹងឲ្យទ្រព្យ ១០០ កហាបណៈ ដល់អ្នក "ៗ នាយកាឡៈនោះ ជាអ្នករក្សាឧបោសថសីល ព្រោះលោភលន់ក្នុងទ្រព្យ ទៅកាន់វិហារហើយ ជាអ្នកមិនត្រូវការដោយការស្តាប់ធម៌ ក៏ដេកលក់ ក្នុងទីដែលសប្បាយហើយ ទៅផ្ទះទាំងព្រឹកព្រលឹម កាលមិនបានទ្រព្យ ១០០ កហាបណៈ ក៏មិនបរិភោគភ័ត្ត កាលបាននុ៎ះឯង ទើបបរិភោគ ៗ ព្រឹកថ្ងៃមួយ សេដ្ឋី ពោល ថា " នែកូន ចូរអ្នករៀនបទនៃធម៌ មួយបទ នៅក្នុងសំណាក់នៃព្រះសាស្តាហើយ ចាំមក, ឳពុក នឹងឲ្យទ្រព្យ ១.០០០ កហាបណៈដល់អ្នក " ៗ នាយកាឡៈនោះ ប្រាថ្នា ដើម្បីនឹងរៀនតែមួយបទប៉ុណ្ណោះហើយ គេចចេញ ៗ ព្រះសាស្តា ទ្រង់បានធ្វើហើយ នូវអាការៈ មិនឲ្យនាយកាឡៈនោះ កំណត់បាន ៗ នាយកាឡៈនោះ កំណត់បទនោះមិនបាន ទើបគិត ថា " អាត្មាអញ នឹងរៀនបទ ថ្មី ៗ ទៀត " ដូច្នេះហើយ កំពុងតែឈរស្តាប់ ក៏ស្រាប់តែបានសម្រេចសោតាបន្ន លុះព្រឹកឡើង បានមកផ្ទះវិញ ជាមួយនឹងព្រះសាស្តាតែម្តង បានខ្មាសអៀនហើយ ព្រោះសេដ្ឋីឲ្យទ្រព្យ

ចំពោះព្រះភក្ត្រព្រះសាស្តា មិនប្រាថ្នា ដើម្បីនឹងទទួលនូវកញ្ចប់ទ្រព្យសម្បីដែលឪពុកឲ្យហើយ ។

រឿងកាឡៈកុមារ មកក្នុងអដ្ឋកថាគាថា ថា " បឋព្យា ឯករជ្ជេន " ជាដើម ក្នុងលោកវគ្គ ធម្មបទ ។

## ( រឿងមិត្តវិន្ទកៈ )

(២២២) ឯម្តាយនៃមិត្តវិន្ទកៈ ពោល ថា " នែកូន ការបានកើតជាមនុស្ស ដែលគេបានដោយកម្រ កូនឯងក៏បានហើយ, ចូរអ្នកឲ្យទាន, ចូររក្សាសីល, ចូររក្សាឧបោសថ, ចូរស្តាប់ធម៌ " ដូច្នេះកាលបើនាយមិត្តវិន្ទកៈ ពោល ថា " បពិត្រម៉ែ ខ្ញុំមិនត្រូវការបុណ្យមានទានជាដើមទេ, សូមម៉ែកុំពោលពាក្យអ្វីៗនឹងខ្ញុំឡើយ, ខ្ញុំនឹងទៅតាមយថាកម្ម " ដូច្នេះ, ទើបពោល ថា " នែកូន ថ្ងៃនេះ ចូរកូនឯងរក្សាឧបោសថ ស្តាប់ធម៌ ក្នុងវិហារ រហូតមួយយប់ហើយ ចាំមក, ម្តាយនឹងឲ្យទ្រព្យ ១.០០០ កហាបណៈ ដល់អ្នក "ៗ ឯនាយមិត្តវិន្ទកៈ ជាអ្នករក្សាឧបោសថ ព្រោះតែសេចក្តីលោភលន់ក្នុងទ្រព្យញ៉ាំងពេលថ្ងៃឲ្យកន្លងទៅហើយ ក្នុងវិហារ បានដេកលក់ ក្នុងកន្លែងមួយ ក្នុងរាត្រី ដោយប្រការដែលសូម្បីបទនៃធម៌មួយបទ មិនប៉ះពាល់ត្រចៀកបាន ហើយក៏បានទៅផ្ទះ តាំងពីព្រឹកព្រលឹមស្រាង ៗ

ឯមាតា របស់មិត្តវិន្ទកៈនោះ គិត ថា " ថ្ងៃនេះ កូនរបស់អាត្មាអញ នឹងស្តាប់ធម៌ហើយ នាំព្រះធម្មកថិកមក " ដូច្នេះហើយ បានចាត់ចែង យាគូនិងភ័ត្តជាដើម ទនឹងមើលផ្លូវមក របស់កូននោះ ឃើញកូននោះ មកហើយតែម្នាក់ឯង ទើបសួរ ថា " នែកូន ព្រះធម្មកថិក កូនឯង នាំមកហើយឬ ? " ។ មិត្តវិន្ទកៈតបវិញ ថា " ខ្ញុំមិនត្រូវការ ដោយ ព្រះធម្មកថិក " ដូច្នេះ កាលមិនបានកញ្ចប់ទ្រព្យ ១.០០០ កហាបណៈ ក៏មិនបរិភោគភ័ត្ត កាលបាននុំះឯង ទើបបរិភោគ ។ ក្រោយមក មិត្តវិន្ទកៈនោះ ធ្វើការលក់ដូរ តាមទូក ត្រូវពួកមនុស្សបណ្តែតចោល លើខ្នងសមុទ្រ ដោយន័យដែលពោលហើយ ពួដ៏ខាងក្រោយ ទៅ ដោយពោងពាយ ថ្ងៃមួយ បានឃើញពួកនាងវេមានិកប្រេត ៤ នាក់ ក្នុងវិមានកែវផ្លឹក ៨ នាក់ ក្នុងវិមានប្រាក់ ១៦ នាក់ ក្នុងវិមាន កែវមណី បានឃើញនាងប្រេត ៣២ នាក់ ក្នុងវិមានមាស តាម លំដាប់ ព្រោះផលនៃឧបោសថកម្ម ដែលមានផលគឺសត្វត្រូវសោយ ក្នុងបច្ចុប្បន្ន ដែលគេបានធ្វើហើយ សោយហើយ នូវទិព្វសម្បត្តិ ជាមួយនឹងនាងប្រេតទាំងនោះ ។

រឿង មកក្នុងអដ្ឋកថាចតុទ្វារជាតក ។

មាតាបិតាទាំង ២ នាក់នោះ ញុំាងបុត្រឲ្យតាំងនៅ ក្នុងអំពើ ល្អ ដោយសេចក្តីអនុគ្រោះបុត្រ ដោយប្រការដូច្នេះ ។

( ញ៉ាំងបុត្រធីតាឲ្យសិក្សាសិល្បៈ)

(២២៣) ក្នុងស្ថានទី ៣ ថា " សិប្បំ " នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ មាតាបិតា ដឹងថា បុត្រធីតាស្ថិតនៅ ក្នុងឱវាទ របស់ខ្លួនហើយ ទើបឲ្យសិក្សាសិល្បៈ មានមុទ្ទា និងគណនាជាដើម ដែលទៅតាមវង្សត្រកូល ។ ក៏សេចក្ដីប្លែកផ្សេងគ្នានៃសិល្បៈទាំងឡាយ មានមុទ្ទានិងគណនាជាដើម លោកពោលហើយក្នុងគម្ពីរដទៃទៀត ។ ពិតយ៉ាងនោះ លោកពោលហើយ ក្នុងអដ្ឋកថាមហាទុក្ខក្ខន្ធសូត្រ ថា "ការតាំងសញ្ញាទុក ពួដ៏ខាងដើមនៃម្រាមដៃហើយ រាប់ដោយចុងនៃម្រាមដៃ ឈ្មោះថា មុទ្ទា ។ កិរិយារាប់ដោយមិនដាច់រយៈ ឈ្មោះថា គណនា ។ មនុស្សទាំងឡាយ ក្រឡេកមើលស្រែហើយ ដឹងបាន ថា 'ក្នុងស្រែនេះ នឹងមានស្រូវ ប្រមាណប៉ុណ្ណោះ' ក្រឡេកមើលដើមឈើហើយ ក៏ដឹងបាន ថា 'លើដើមឈើនេះ នឹងមានផ្លែឈើ ប្រមាណប៉ុណ្ណោះ' ក្រឡេកមើលអាកាសហើយ ក៏ដឹងបាន ថា 'ពួដ៏អាកាសនេះ នឹងមានសត្វស្លាប ប្រមាណប៉ុណ្ណោះ' ដូច្នេះ ដោយកិរិយារាប់រួបរួមឯណា, កិរិយារាប់រួបរួមនោះ ឈ្មោះថា សង្ខ្យា " ។

(២២៤) ដីកានៃមហាទុក្ខក្ខន្ធសូត្រនោះ ថា " ២ បទ ថា **សញ្ញំ បវេត្វា** មានសេចក្ដីថា ការធ្វើសញ្ញា ដោយន័យ ថា

‘ បើដើមនៃម្រាមដៃនេះ អាត្មាអញចាប់ហើយ, ត្រូវជា ១០០, បើដើមនៃម្រាមដៃនេះ អាត្មាអញចាប់ហើយ, ត្រូវជា ១.០០០’ ដូច្នេះ ជាដើម ហើយទើបរាប់ ៗ កិរិយារាប់ ទៅតាមលំដាប់លំដោយ ដោយវិធី មាន ១, ២, ជាដើម មាន ៩ ជាទីបញ្ចប់ ឈ្មោះថា កិរិយារាប់ដោយមិនដាច់រយៈ ៗ កិរិយារាប់ដោយរួបរួម ដោយវិធីមានបូកនិងគុណជាដើម ឈ្មោះថា **បិណ្ឌគណនា** ៗ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាអាទិ៍ ថា “**ខេត្តំ ឱលោកេត្វា**” ដូច្នេះ ៗ

អដ្ឋកថានិស្សគ្គិយសិក្ខាបទ ថា “កិរិយារាប់ ដោយចុងនៃម្រាមដៃ ឈ្មោះថា **មុទ្ទា** ៗ កិរិយារាប់ដោយការរាប់មិនឲ្យដាច់រយៈជាដើម ឈ្មោះថា **គណនា**” ៗ

ដីកានៃនិស្សគ្គិយសិក្ខាបទនោះ ថា “កិរិយារាប់ដោយ ការបត់ម្រាមដៃឲ្យកោងចូលក្នុង ដូចជាជនទាំងឡាយ មានជនជាតិបាសិកៈ និងជនជាតិមិលក្ខៈជាដើម ឈ្មោះថា **ហត្ថមុទ្ទាគណនា** ៗ កិរិយារាប់ ដោយអំណាចមាន ៩ ជាទីបញ្ចប់ ឈ្មោះថា កិរិយារាប់ដោយមិនឲ្យដាច់រយៈ ៗ កិរិយារាប់ដោយរួបរួម ដែលប្រព្រឹត្តទៅ ដោយអំណាចវិធី មានបូក, គុណ, សង, ចែក ជាដើម លោកកំណត់យក ដោយអាទិស័ព្ទ ៗ កិរិយារាប់ ដោយរួបរួមនោះ

ជាធម្មជាតិស្ទាត់ជំនាញហើយ ដល់បុគ្គលណា, បុគ្គលនោះ ឃើញសូម្បីដើមឈើហើយ ក៏ដឹងបាន ថា " លើដើមឈើនេះ មានស្លឹកប្រមាណប៉ុណ្ណោះ " ។

ន័យមកក្នុងអដ្ឋកថាអង្គុត្តរនិកាយ ថា " ការរាប់ដោយមិនឲ្យដាច់រយៈ ឈ្មោះថា **មុទ្ទា** ។ កិរិយារាប់ដោយរួបរួម ឈ្មោះថា **គណនា** " ។

ដីកានៃអដ្ឋកថាអង្គុត្តរនិកាយនោះ ថា " ម្យ៉ាងទៀត ការតាំងសញ្ញា ត្រង់ដើមនៃម្រាមដៃទាំងឡាយ ហើយរាប់ដោយចុងនៃម្រាមដៃ ឈ្មោះថា **មុទ្ទា** ។ កិរិយារាប់ដោយមិនឲ្យដាច់រយៈដោយអំណាចវិធីមាន ១, ២, ៣, ជាដើម ឈ្មោះថា **គណនា** " ។

អាទិស័ព្ទ ថា " **អច្ឆិទ្ទកាទិ** " ព្រះអដ្ឋកថាចារ្យ ដាក់បញ្ចូលហើយ ក្នុងអដ្ឋកថាឱមសវាទសិក្ខាបទនោះ ក៏ដើម្បីកំណត់យក នូវកិរិយារាប់ដោយរួបរួម ព្រោះកិរិយារាប់ដោយរួបរួមនោះ មិនបានមកហើយ ក្នុងព្រះវិន័យ ដោយឡែក ។

មាតាបិតា ញុំាងបុត្រធីតាឲ្យសិក្សាតែសិល្បៈ មិនមានទោសប៉ុណ្ណោះ ដែលមានប្រការដូចពោលហើយ ដោយប្រការដូច្នេះ ។

**( រកភរិយាស្វាមីដ៏សមគួរឲ្យ )**

(២២៥) ក្នុងស្ថានទី ៤ ថា " **បដិរូបេន** " គប្បីជ្រាប

វិនិច្ឆ័យ ដូចតទៅនេះ ៖ ដោយកិរិយាដែលសមគួរ គឺ ដែលត្រូវគ្នាដោយត្រកូល, មារយាទ, រូប, ភោគៈ និងបរិវារ ជាដើម ។

## ( ប្រគល់ទ្រព្យមត៌កឲ្យក្នុងសម័យ )

(២២៦) ក្នុងស្ថានទី ៥ ថា " **សមយេ ទាយជ្ជំ និយ្យាទេន្តិ** " គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖ មាតានិងបិតាតែងប្រគល់ទ្រព្យសម្បត្តិឲ្យ ក្នុងសម័យ ។ ក៏ក្នុងពាក្យថា **សមយេ** នោះ សម័យ មាន ២ យ៉ាង គឺ និច្ចសម័យ ១ កាលសម័យ ១ ។ បណ្ដាសម័យទាំង ២ យ៉ាងនោះ សម័យជានិច្ច ឈ្មោះថានិច្ចសម័យ គឺ កាលដែលធ្វើឲ្យជារឿយៗ ។ ក៏ **និច្ច** ស័ព្ទនេះ មាន **អភិណ្ហ** ជាអត្ថ ដូចជា **និច្ច** ស័ព្ទ ក្នុងប្រយោគទាំងឡាយ ថា "កាំបិតកោរ គឺ ជាងកាត់សក់ ត្រូវបេះហើយ ជារឿយៗ " ដូច្នេះ ជាដើម ។ សម័យគឺកាលដ៏សមគួរដែលមកដល់ហើយ ឈ្មោះថាកាលសម័យ ។ មាតាបិតា កាលឲ្យឱវាទ ថា "ចូរអ្នក ក្រោកឡើង ក្រោកឡើងព្រម កាន់យកភោគៈនេះ, ភោគៈនេះ ចូរជាដើមទុន របស់អ្នក, អ្នកចូរធ្វើកុសល ដោយភោគៈនេះ" ដូច្នេះ ឈ្មោះថា ប្រគល់ឲ្យក្នុងនិច្ចសម័យ បណ្ដាសម័យទាំង ២ នោះ ។ មាតាបិតា កាលឲ្យក្នុងសម័យ មានសម័យទុកនូវជុក, សម័យអាវាហមង្គល និងសម័យ

វិវាហមង្គលជាដើម ឈ្មោះថា ប្រគល់ឲ្យ ក្នុងសម័យ ៗ បណ្ដាកាលសម័យទាំងនោះ ការទុកនូវជុក តែងមាន ក្នុងវេលានៅក្មេង ៗ អាវាហមង្គលនិងវិវាហមង្គល តែងមាន ក្នុងវេលាដែលបុត្រធីតាពេញវ័យកំទ្បោះ ក្រមុំហើយ ៗ ម្យ៉ាងទៀត មាតាបិតា សូម្បីកាលឲ្យឱវាទ ដល់បុត្រ(ធីតា) ដែលដេក លើគ្រែដែលជាកន្លែងមរណៈ ក្នុងបច្ឆិមកាល ថា "ចូរអ្នក ធ្វើកុសល ដោយភោគៈនេះ" ដូច្នេះ ឈ្មោះថា ប្រគល់ឲ្យ ក្នុងសម័យ ៗ បុត្រធីតា កាលទំនុកបំរុង នូវមាតាបិតាទាំង ២ នាក់នោះ ដោយអំណាចកិច្ច មានការចិញ្ចឹមជាដើម រមែងគ្រទ្បប់បាន នូវប្រយោជន៍សុខ មានការហាមចាកអំពើអាក្រក់ជាដើម ដោយប្រការដូច្នេះ, ព្រោះហេតុនោះ មាតានិងបិតា ទាំង ២ នាក់នោះ គឺបុត្រធីតា គប្បីទំនុកបំរុងយ៉ាងដូច្នោះ ដោយពិត ៗ

## ( មាតាបិតាឃើញហេតុ ៥ យ៉ាង ទើបចង់បានបុត្រ )

(២២៧) មែនពិត សូម្បីមាតាបិតា កាលសំទ្បឹងឃើញនូវហេតុទាំងឡាយ មានការចិញ្ចឹមជាដើម ទើបប្រាថ្នាចង់បានបុត្រ ៗ ហេតុនោះ ព្រះដ៏មានព្រះភាគ កាលសំដែងធម៌ ដល់ពួកភិក្ខុ ទើបត្រាស់ (គាថាទាំងនេះ) ក្នុងបុត្តសូត្រ បញ្ចកនិបាត អង្គុត្តរនិកាយ ថា

បណ្ឌិតទាំងឡាយ (មាតាបិតា) កាលបើពិចារណា ឃើញហេតុទាំង ៥ យ៉ាង រមែងចង់បាននូវបុត្រ គឺ បុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងជួយធ្វើកិច្ចការ ដល់យើង ១ វង្សត្រកូលនឹងស្ថិត នៅយូរអង្វែង ១ នឹងប្រតិបត្តិគួរ ដើម្បីទទួលយក មត៌ក ១ មួយទៀត បុត្រនឹងតាមឧទ្ទិសទក្ខិណាទាន ឱ្យដល់ពួកយើង ដែលទៅកាន់លោកខាងមុខហើយ, បណ្ឌិតទាំងឡាយ កាលបើពិចារណាឃើញហេតុ ទាំង ៥ យ៉ាងនេះ ទើបប្រាថ្នាចង់បាននូវបុត្រ ។ ព្រោះហេតុនោះ បុត្រទាំងឡាយ ជាសប្បុរស អ្នក ស្ងប់រម្ងាប់ ជាកតញ្ញូកតវេទីបុគ្គល កាលរឭកឃើញ នូវឧបការគុណ ដែលលោកធ្វើហើយ ក្នុងកាលមុន រមែងចិញ្ចឹមមាតាបិតា រមែងជួយធ្វើកិច្ចការ របស់ បុព្វការីជនទាំងឡាយនោះ តាមសមគួរ បុត្រអ្នកធ្វើ តាមឱវាទ អ្នកចិញ្ចឹមមាតា និងបិតា ដែលលោក ចិញ្ចឹមកហើយ មិនញុំាងវង្សត្រកូល ឱ្យសាបសូន្យ ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល ជាអ្នកដែល បណ្ឌិតទាំងឡាយគប្បីសរសើរ " ។

(២២៨) អដ្ឋកថាបុត្តសូត្រនោះ ថា “បណ្ដាបទ ទាំងនោះ ២ បទ ថា ‘**ភតោ វា នោ**’ មានសេចក្ដីថា បុត្រ ដែលយើងទាំងឡាយ ចិញ្ចឹមហើយ គឺ ទំនុកបំរុងហើយ ដោយការឧបត្ថម្ភទាំងឡាយមានឲ្យបៅដោះ ញាំងដៃ - ជើងឲ្យធាត់ធំជាដើម នឹងចិញ្ចឹមយើងទាំងឡាយ នៅពេលដែលពួកយើងចាស់ជរាហើយ ដោយការឧបត្ថម្ភទាំងឡាយមានការលាងជើង ងូតទឹកឲ្យ ឲ្យយាគូ និងភ័ត្តជាដើម ៗ ២ បទ ថា “**កិច្ចំ វា នោ**” មានសេចក្ដីថា បុត្រនឹងបញ្ឈប់ការងារ របស់ខ្លួន ហើយទៅជួយធ្វើកិច្ចការងារ របស់យើងទាំងឡាយ ដែលកើតឡើងហើយ ក្នុងទីទាំងឡាយផ្សេង ៗ មានរាជត្រកូលជាដើម ៗ បទ ថា “**កុលវំសោ**” មានសេចក្ដីថា កាលបើបុត្រ រក្សាទ្រព្យសម្បត្តិ ដែលជារបស់យើង មានស្រែចំការ ប្រាក់ និង មាស ជាដើម មិនឲ្យសាបសូន្យទៅ, វង្សត្រកូលគប្បីស្ថិតនៅ អស់កាលជាយូរអង្វែង ៗ អធិប្បាថា នឹងតាំងនៅ ៗ ម្យ៉ាងទៀត បុត្រ នឹងមិនកាត់ផ្ដាច់ភ័ត្តទាំងឡាយ មានសលាកភ័ត្តជាដើម ដែលយើងទាំងឡាយ ឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅ ( តាមប្រក្រតី ) ៗ វង្សត្រកូល របស់ពួកយើង នឹងស្ថិតនៅអស់កាលដ៏យូរ ដោយប្រការដូច្នេះឯង ៗ បទ ថា “**ទាយជ្ជំ**” មានសេចក្ដីថា បុត្រ កាលធ្វើខ្លួន ឲ្យជាអ្នកសមគួរ ដើម្បីទទួលយក

មតិក ដោយការប្រតិបត្តិតាមសមគួរ ដល់វង្សត្រកូល ទើបឈ្មោះថា ប្រតិបត្តិគួរដល់ការទទួលមតិក របស់យើងទាំងឡាយ ។ បទ ថា " **ទក្ខិណំ** " មានសេចក្តីថា បុត្រនឹងធ្វើបត្តិទានហើយ តាមឲ្យទាន ចាប់ដើមតាំងពីថ្ងៃ ទី ៣ ទៅ ។ ក្នុងហេតុនេះ បុត្រទាំងឡាយ បណ្ឌិតគប្បីជ្រាប ថា "ជាអ្នកស្ងប់រម្ងាប់ ជាសប្បុរស" ព្រោះការ ប្រតិបត្តិត្រូវ ក្នុងមាតាបិតាទាំងឡាយ ។ បាទគាថា ថា " **បុព្វេ កតមនុស្សរំ** " មានសេចក្តីថា កាលរលឹកគុណ ដែលមាតាបិតា ធ្វើហើយមុនគេ ។ បទ ថា " **ឱវាទការី** " បានដល់ ជាអ្នកធ្វើ តាមឱវាទ ដែលមាតាបិតាឲ្យហើយ ។ បទ ថា " **ភតបោសី** " បានដល់ អ្នកចិញ្ចឹមមាតានិងបិតា ដែលចិញ្ចឹមខ្លួនមកហើយ ។ បទ ថា " **បសំសិយោ** " មានសេចក្តីថា បុត្រ រមែងជាអ្នក គឺមហាជនគួរសរសើរហើយ ក្នុងបច្ចុប្បន្ននេះ ដោយពិត" ។

ការពណ៌នាអំពីកិរិយាទំនុកបំរុងមាតាបិតា ចប់ ។

⁂

ប្រែចប់ថ្ងៃសុក្រ ២ កើត ខែបុស្ស ឆ្នាំវក ចត្វាស័ក ព.ស.២៥៣៥
២៥ ធ្នូ ១៩៩២

# ពណ៌នាអំពីការសង្គ្រោះបុត្រនិងភរិយា

---------

## ( បុត្រ ៣ ពួក )

(២២៩) ធម្មតាបុត្រ មាន ៣ ពួក ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា " ម្នាលភិក្ខុទាំងឡាយ បុត្រ ៣ ពួកនេះ រមែងមានប្រាកដ ក្នុងលោក ។ បុត្រ ៣ ពួក តើដូចម្ដេចខ្លះ ? ។ គឺ អតិជាតបុត្រ ១ អនុជាតបុត្រ ១ អវជាតបុត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ក៏អតិជាតបុត្រ តើដូចម្ដេច ? ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតា របស់បុត្រ ក្នុងលោកនេះ ជាអ្នកមិនដល់ព្រះពុទ្ធជាទីរឭក មិនដល់ព្រះធម៌ជាទីរឭក មិនដល់ព្រះសង្ឃជាទីរឭក មិនវៀរចាកបាណាតិបាត ចាកអទិន្នាទាន កាមេសុមិច្ឆាចារៈ មុសាវាទ, មិនវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ, ជាអ្នកទ្រុស្ដសីល មានធម៌ដ៏លាមក, ចំណែក បុត្ររបស់មាតាបិតាទាំងនោះ ជាអ្នកដល់នូវព្រះពុទ្ធ ជាទីរឭក ដល់នូវព្រះធម៌ ជាទីរឭក ដល់នូវព្រះសង្ឃជាទីរឭក, ជាអ្នកវៀរចាកបាណាតិបាត ។ល។ ជាអ្នកវៀរចាកហេតុជាទីតាំង នៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ, ជាអ្នកមានសីល មានកល្យាណធម៌, ម្នាលភិក្ខុទាំងឡាយ

បុត្រនេះឯង ឈ្មោះថា អតិជាតបុត្រ ។ ម្នាលភិក្ខុទាំងឡាយ ក៏អនុជាតបុត្រ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្រ ក្នុងលោកនេះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ។ ល ។ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌, ចំណែក បុត្រ របស់មាតាបិតាទាំងនោះ ក៏ជាអ្នកដល់នូវព្រះពុទ្ធជាទីរឭកដែរ ។ ល ។ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌, ម្នាលភិក្ខុទាំងឡាយ បុត្រនេះឯង ឈ្មោះថា អនុជាតបុត្រ ។ ម្នាលភិក្ខុទាំងឡាយ ក៏អវជាតបុត្រ តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្រ ក្នុងលោកនេះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ។ ល ។ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌, ឯបុត្រ របស់មាតាបិតាទាំងនោះ ជាអ្នកមិនដល់ នូវព្រះពុទ្ធជាទីរឭកទេ ។ ល ។ ជាអ្នកទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក, ម្នាលភិក្ខុទាំងឡាយ បុត្រនេះឯង ឈ្មោះថា អវជាតបុត្រ ។ ម្នាលភិក្ខុទាំងឡាយ បុត្រ ៣ ពួកនេះឯង រមែងមានប្រាកដនៅ ក្នុងលោក " ។ (លុះព្រះដ៏មានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងតយោបុត្តសូត្រនោះ ថា ÷ )

" បណ្ឌិតទាំងឡាយ តែងប្រាថ្នា នូវអតិជាតបុត្រនិង

អនុជាតបុត្រ មិនប្រាថ្នាអវជាតបុត្រ ដែលជាកូនផ្ដាច់បង់ត្រកូលឡើយ ។ បុត្រទាំងនេះឯង តែងមាន ក្នុងលោក, បុត្រទាំងឡាយណា ជាឧបាសក ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល ជាអ្នកដឹងពាក្យពេចន៍ ជាអ្នកប្រាស ចាកសេចក្ដីកំណាញ់, បុត្រទាំងឡាយនោះ រមែងរុងរឿង ក្នុងពួកបរិស័ទ ដូចជាព្រះច័ន្ទ ដែលផុតស្រឡះហើយ ចាកដុំពពក ដូច្នោះឯង " ។

តយោបុត្តសូត្រ ក្នុងឥតិវុត្តកៈ ចប់ ។

(២៣០) ន័យមកក្នុងអដ្ឋកថាតយោបុត្តសូត្រនោះ ថា "បុត្រដែលកើតអំពីខ្លួន បុត្រដែលកើតអំពីទ្រូង ឬសូម្បីបុត្រដែលគេឲ្យជាដើម ឈ្មោះថា បុត្រ ។ បុត្រដែលកើតកន្លងមាតាបិតា ដោយគុណទាំងឡាយ របស់ខ្លួន, អធិប្បាយថា មានគុណខ្ពង់ខ្ពស់ជាងមាតាបិតាទាំងនោះ ឈ្មោះថា អតិជាតបុត្រ ។ បុត្រដែលកើតហើយសមគួរ ដល់មាតាបិតាទាំងឡាយ ដោយគុណទាំងឡាយ, អធិប្បាយថា មានគុណស្មើ ដោយមាតាបិតាទាំងឡាយនោះ ឈ្មោះថា អនុជាតបុត្រ ។ បុត្រដែលកើតហើយមិនស្មើ ដល់មាតាបិតាទាំងឡាយ ដោយគុណទាំងឡាយ, អធិប្បាយថា មានគុណថោកទាប

ជាងមាតាបិតាទាំងឡាយនោះ ឈ្មោះថា អវជាតបុត្រ ។ ក៏បុត្រ រមែងជាអ្នកខ្ពង់ខ្ពស់ ជាអ្នកស្មើ និងជាអ្នកថោកទាប ជាងមាតានិង បិតាទាំងឡាយ ដោយគុណទាំងឡាយណា, ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "**កថញ្ច ភិក្ខវេ**" ដូច្នេះ ជាដើម ដើម្បីនឹងទ្រង់ សំដែងវែកញែក នូវគុណទាំងឡាយនោះ ។ បណ្ដាបទទាំងនោះ បទ ថា "**អប្បដិវិរតា**" បានដល់ ឈ្មោះថា ជាអ្នកមិនវៀរចាក ព្រោះមិនមានសមាទានវិរតិ និងសម្បត្តវិរតិ ។ បទ ថា "**ទុស្សីលា**" បានដល់ ឈ្មោះថា ជាអ្នកមិនមានសីល ព្រោះមិនមានគុណសូម្បី ត្រឹមតែសីល ៥ ព្រោះមិនមានសមាទានវិរតិ និងសម្បត្តវិរតិនោះ នុ៎ះឯង ។ បទ ថា "**បាបធម្មា**" បានដល់ ជាអ្នកមានធម៌ដ៏លាមក គឺ ជាអ្នកមានមារយាទថោកទាប ។ បទ ថា "**បដិវិរតោ**" បាន ដល់ ឈ្មោះថា ជាអ្នកវៀរចាក គឺ ជាអ្នកស្ថិតនៅឆ្ងាយ ព្រោះការ សមាទានសិក្ខាបទ ។ ក្នុងបទទាំងពួងដែលសេសសល់ ក៏ន័យនេះ ។ បទ ថា "**សីលវា**" បានដល់ ជាអ្នកមានសីល ៥ ដូចបានពោល មកហើយ ។ បទ ថា "**កល្យាណធម្មោ**" បានដល់ ជាអ្នកមាន ធម៌ដ៏ប្រសើរ អធិប្បាយថា ឈ្មោះថា ជាអ្នកដល់ព្រមដោយបញ្ញា ព្រោះដល់ព្រមដោយទិដ្ឋិ ដែលជាហេតុសំដែង ដល់សរណគមន៍ ។ ក៏បុត្រណា, កាលបើមាតាបិតា ជាអ្នកគ្មានសទ្ធា និង គ្មានសីល,

ឯខ្លួនឯង ក៏ជាអ្នកដូច្នោះដែរ, បុត្រនោះឯង គប្បីជ្រាប ថា " ជាអវជាតបុត្រមែនពិត " ។ ព្រោះ សភាពមិនមែនជាធម៌ទាំងឡាយ មានការមិនជឿជាដើម ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងលក្ខណៈនៃភាពជាអវជាតបុត្រ ក្នុងតយោបុត្តសូត្រនេះ, ក៏សភាពមិនមែនជាធម៌ទាំងឡាយ មានការមិនជឿជាដើមនោះ រមែងមានព្រម ក្នុងអវជាតបុត្រនេះ ។ ក៏ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ភាវៈនៃបុត្រជាអ្នកឈ្មោះថា អតិជាតបុត្រ ជាដើម ព្រោះប្រៀបធៀបនឹងមាតាបិតាទាំងឡាយ ។ បទ ថា " **កុលគន្ធនោ** " ប្រែថា ជាអ្នកកាត់ផ្តាច់ត្រកូល គឺ ជាអ្នកធ្វើត្រកូលឲ្យវិនាស ។ ក៏ **គន្ធ** ស័ព្ទ ក្នុងបទ ថា " **កុលគន្ធនោ** " នេះ មានកិរិយាកាត់ជាអត្ថ ដូច **គន្ធ** ស័ព្ទ ក្នុងប្រយោគទាំងឡាយ មានប្រយោគ ថា " **ឧប្បលគន្ធបច្ចត្ថិកា** " ប្រែថា សត្រូវដែលកាត់បេះដូង ដូចជាផ្កាឧប្បល ដូច្នេះ ជាដើម ។ បទ ថា " **លោកស្មឹ** " មានសេចក្តីថា បុត្រទាំងឡាយនេះឯង មានអតិជាតបុត្រជាដើម ឈ្មោះថា បុត្រ ក្នុងសត្វលោកនេះ ។ បុត្រក្រៅផ្សេង អំពីបុត្រ ៣ ពួកនេះ តែងមិនមាន ។ ក៏បណ្តាបុត្រទាំង ៣ ពួកនេះ បុត្រទាំងឡាយណា ឈ្មោះថា ជាឧបាសក ព្រោះដល់ព្រម ដោយសរណគមន៍, ជាអ្នកឆ្លាត ក្នុងកម្ម ដោយញាណជាគ្រឿងដឹងភាវៈនៃសត្វជាអ្នកមានកម្មជារបស់រៀងៗខ្លួន, ក៏បុត្រ

ទាំងនោះ ជាបណ្ឌិត គឺជាអ្នកមានបញ្ញា ដល់ព្រម គឺបរិបូណ៌ ដោយសីល ៥ សីល ១០ ។ បុគ្គលទាំងឡាយណា ដឹងពាក្យពេចន៍ របស់ពួកយាចក គឺ ដឹងនូវសេចក្តីត្រូវការ របស់ពួកយាចកទាំងឡាយនោះ ដោយកិរិយាឃើញអាការៈ នៃមាត់ប៉ុណ្ណោះឯង ហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា វទញ្ញូ ។ ម្យ៉ាងទៀត បុគ្គលទាំងឡាយណា ឮពាក្យពេចន៍ របស់យាចកទាំងនោះ ថា " ចូរអ្នកឱ្យ (ទាន) " ដូច្នេះ ហើយគិត ថា " ជនទាំងនេះ មិនបានឱ្យទាន ក្នុងកាលមុនទើបបានជា យ៉ាងដូច្នេះ, ឯអាត្មាអញ មិនគប្បី យ៉ាងដូច្នេះឡើយ " ដូច្នេះហើយ រមែងដឹងនូវសេចក្តីនោះ ដោយការបរិច្ចាគ ដល់ពួកយាចកទាំងឡាយនោះ ហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា វទញ្ញូ ។ ម្យ៉ាងទៀត បុគ្គលទាំងឡាយណា ដឹងនូវពាក្យពេចន៍ ដែលជាគ្រឿងសំដែងនូវគុណ មានភាពនៃសត្វ ជាអ្នកមានកម្មជារបស់រៀងៗខ្លួន ជាដើម របស់បណ្ឌិតទាំងឡាយ ហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា វទញ្ញូ ។ ឯអាចារ្យពួកខ្លះ សូត្រ ថា " **បទញ្ញូ** " ដូច្នេះ ក៏មាន ។ អធិប្បាយថា ជាអ្នកប្រគល់ឱ្យស្មើៗ គឺ ជាអ្នកបរិច្ចាគជាប្រក្រតី ។ បទ ថា " **អព្ភយនា** " មានសេចក្តីថា បុគ្គលទាំងឡាយនោះ រមែងរុងរឿង គឺ ភ្លឺស្វាង បានដល់ រមែងត្រចះត្រចង់ ក្នុងបរិស័ទទាំងឡាយ មានឧបាសកបរិស័ទជាដើម

និង ក្នុងបរិស័ទទាំងឡាយមានខត្តិយបរិស័ទជាដើម ដូចជាព្រះច័ន្ទផុត ស្រឡះអំពីដុំពោលគឺពពក ឬស្រទាប់នៃមេឃ ភ្លឺស្វាង ដូច្នោះ" ។

(២៣១) បាលីបណ្ឌរកជាតក ក្នុងតឹសនិបាត ថា "ក៏បុត្រ មាន ៣ ពួក គឺ បុត្រអ្នកមានប្រក្រតីនៅខាងក្នុង ១ ( កូនសិស្ស ) បុត្រដែលគេឲ្យ ១ បុត្រដែលអាស្រ័យខ្លួនកើត ១ បុត្រក្រៅអំពីនេះ មិនមានឡើយ " ។

អដ្ឋកថាបណ្ឌរកជាតកនោះ ថា "បទ ថា **អញ្ញោ** មានសេចក្តីថា ឈ្មោះថា បុត្រក្រៅអំពីនេះ គឺ ទី ៤ មិនមានឡើយ ។ បទ ថា "**អន្តេវាសី**" បានដល់ បុត្រដែលសិក្សាសិល្បៈខ្លះ ស្តាប់បញ្ហាខ្លះ នៅហើយក្នុងសំណាក់ ។ បទ ថា "**ទិន្នកោ**" បានដល់ បុត្រដែលជនទាំងឡាយឯទៀត ឲ្យហើយ ដោយប្រាប់ ថា 'បុរសនេះ ចូរជាបុត្រ របស់អ្នកចុះ " ។

( បុត្រ ៤ ពួក )

(២៣២) អដ្ឋកថាកដ្ឋហារកជាតក ឯកនិបាត ថា "ក៏ឈ្មោះថា បុត្រ នេះ មាន ៤ ពួក គឺ បុត្រដែលកើតក្នុងខ្លួន បុត្រដែលកើតក្នុងខេត្ត បុត្រដែលនៅខាងក្នុងជាប្រក្រតី បុត្រដែលគេឲ្យ ។ បណ្តាបុត្រទាំង ៤ នោះ បុត្រដែលអាស្រ័យខ្លួនកើត ឈ្មោះថា

**អត្រជៈ** ។ បុត្រដែលកើត ក្នុងទីទាំងឡាយ មានលើកម្រាលដេក ឈើបល្ល័ង្ក ពូថៅដើមទ្រូងជាដើម ឈ្មោះថា **ខេត្រជៈ** ។ បុត្រដែលសិក្សាសិល្បៈ ក្នុងសំណាក់ ឈ្មោះថា **អន្តេវាសិកៈ** ។ បុត្រដែលគេឲ្យហើយ ដើម្បីប្រយោជន៍ដល់ការចិញ្ចឹម ឈ្មោះថា **ទិន្នកៈ**" ។

ប៉ុន្តែ ក្នុងមង្គលកថានេះ លោកតែងបានចំពោះតែបុត្រដែលអាស្រ័យខ្លួនកើត ដែលផ្សេងដោយប្រភេទ មានអតិជាតបុត្រជាដើមប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោល ក្នុងអដ្ឋកថា ថា 'បុត្រក្តី ធីតាក្តី ដែលកើតអំពីខ្លួន រមែងដល់ការរាប់ ថា 'បុត្រ' ទាំងអស់" ។

## ( ភរិយា ២០ ពួក )

(២៣៣) ភរិយា ២០ ពួក ព្រះឧបាលី ពោលហើយ ក្នុងសញ្ចរិត្តវិភង្គ យ៉ាងនេះ ថា " ស្ត្រីដែលមាតារក្សា ស្ត្រីដែលបិតារក្សា ស្ត្រីដែលមាតានិងបិតារក្សា ស្ត្រីដែលបងប្អូនប្រុសរក្សា ស្ត្រីដែលបងប្អូនស្រីរក្សា ស្ត្រីដែលពួកញាតិរក្សា ស្ត្រីដែលជនមានគោត្រវង្សស្មើគ្នារក្សា ស្ត្រីដែលជនអ្នកមានធម៌ស្មើគ្នារក្សា ស្ត្រីដែលមានការរក្សា ស្ត្រីដែលមានអាជ្ញាដោយជុំវិញ ស្ត្រីដែលបុរសលោះនឹងទ្រព្យ ស្ត្រីដែលនៅរួមដោយសេចក្តីពេញចិត្ត ស្ត្រី

ដែលនៅដោយភោគៈ ស្ត្រីដែលនៅដោយកំណាត់សំពត់ ស្ត្រីដែលពួកញាតិទាំងឡាយចាប់ដៃផ្គុំ ជាមួយនឹងបុរស ជ្រលក់ក្នុងភាជន៍ទឹក ស្ត្រីដែលបុរសដាក់ទ្រនូលឱ្យ ស្ត្រីដែលប្រើប្រាស់ជាខ្ញុំផង ជាភរិយាផង ស្ត្រីដែលធ្វើការឈ្នួលផង ជាភរិយាផង ស្ត្រីដែលគេចាប់ពីកងទ័ពយកមកធ្វើជាភរិយា ស្ត្រីដែលប្រុសបាននៅរួមគ្នាតែមួយរំពេចនោះ" ឈ្មោះថា ភរិយា ។

(២៣៤) អដ្ឋកថាវិភង្គនៃសញ្ចរិត្តសិក្ខាបទនោះ ថា "បណ្ដាបទទាំងនោះ បទ ថា 'មាតុរក្ខិតា' បានដល់ ស្ត្រីដែលមាតារក្សា គឺ មាតារក្សា ដោយប្រការដែលនាងនឹងសម្រេចការនៅរួម ដោយបុរសមិនបាន ។ ហេតុនោះ សូម្បីក្នុងបទភាជនៈនៃសញ្ចរិត្តវិភង្គនោះ ព្រះឧបាលី ពោល ថា 'មាតា រមែងរក្សា គ្រប់គ្រង ញុំាងខ្លួនឱ្យធ្វើនូវភាពជាធំ គឺញុំាងអំណាចឱ្យប្រព្រឹត្តទៅ' ។

បណ្ដាបទទាំងនោះ បទ ថា '**រក្ខតិ**' មានសេចក្ដីថា រមែងមិនឱ្យទៅ ក្នុងទីកន្លែងណាមួយ ។ បទ ថា '**គោបេតិ**' មានសេចក្ដីថា រមែងដាក់ទុក ក្នុងទីដែលឃុំគ្រង ដោយប្រការដែលពួកបុរសដទៃ មើលមិនឃើញ ។ ២ បទ ថា '**ឥស្សរិយំ ការេតិ**' មានសេចក្ដីថា រមែងហាមនូវការនៅតាមអំពើចិត្ត នៃស្ត្រីនោះ ប្រព្រឹត្តកន្លង ។ ២ បទ ថា '**វសំ វត្តេតិ**' មានសេចក្ដីថា ញុំាង

អំណាច របស់ខ្លួនឲ្យប្រព្រឹត្តទៅ ពួដីខាងលើនៃស្ត្រីនោះ យ៉ាងនេះថា 'ចូរអ្នកធ្វើនូវកិច្ចនេះ, ចូរកុំធ្វើនូវកិច្ចនេះឡើយ' ។ សូម្បីស្ត្រីទាំងឡាយមានស្ត្រីដែលបិតារក្សាជាដើម គប្បីជ្រាប ដោយឧបាយនុ៎ះ ។ គោត្រ ឬ ធម៌ តែងរក្សាមិនបាន ។ តែថា ស្ត្រីដែលពួកជនអ្នកមានគោត្រស្មើគ្នា និងជនអ្នកប្រព្រឹត្តធម៌ស្មើគ្នា គឺ ជនដែលបួសឧទ្ទិសព្រះសាស្តាព្រះអង្គជាមួយគ្នា និងជនអ្នករាប់បញ្ចូល ក្នុងគណៈជាមួយគ្នា រក្សាហើយ លោកហៅ ថា 'ស្ត្រីដែលគោត្រវង្សរក្សា ស្ត្រីដែលធម៌រក្សា' ។ ស្ត្រីដែលប្រព្រឹត្តទៅ ព្រមដោយការរក្សា ឈ្មោះថា ស្ត្រីដែលមានការរក្សា ។ ស្ត្រីដែលប្រព្រឹត្តទៅ ព្រមដោយអាជ្ញាជុំវិញ ឈ្មោះថា ស្ត្រីដែលមានអាជ្ញា ដោយជុំវិញ" ។

(២៣៥) ដីកាវិភង្គនៃសញ្ចរិត្តសិក្ខាបទនោះ ថា "បទ ថា '**សេរិវិហារិ**' បានដល់ នូវកិរិយាប្រព្រឹត្តិ តាមសេចក្តីពេញចិត្តរបស់ខ្លួន ។ បទ ថា '**វសំ**' បានដល់ ញាំងអាជ្ញា ។ គោត្រមានគោតមគោត្រជាដើម ឈ្មោះថា គោត្រ ។ ធម៌ របស់ជនទាំងឡាយ មានជនអ្នកស្លៀកពាក់ស និងបរិព្វាជក ជាដើម ឬ របស់ត្រកូលទាំងឡាយនោះ ។ ឈ្មោះថា ធម៌ ។ **គោត្ត** ស័ព្ទ រមែងប្រព្រឹត្តទៅ ក្នុងជនអ្នកមានគោត្រទាំងឡាយ និង **ធម្ម** ស័ព្ទ រមែង

ប្រព្រឹត្តទៅ ក្នុងជនអ្នកមានប្រក្រតីប្រព្រឹត្តធម៌ទាំងឡាយ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យ ថា **'សគោត្តេហិ'** ជាដើម ។ បណ្តាទបទាំងនោះ បទ ថា **'សគោត្តេហិ'** បានដល់ អ្នកមានគោត្រស្មើគ្នា អធិប្បាយថា អ្នកកើតក្នុងត្រកូលជាមួយគ្នា ។ បទ ថា **'សហធម្មិកេហិ'** មានសេចក្តីថា អ្នកមានធម៌ដែលគប្បីប្រព្រឹត្តរួមគ្នា ក្នុងសាសនារបស់ព្រះសាស្តាព្រះអង្គជាមួយគ្នា ឬអ្នកមានធម៌ ក្នុងត្រកូលស្មើគ្នា ។ ដោយហេតុនោះឯង ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យ ថា **'ឯកំ សត្ថារំ'** ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ ដោយបទ ថា **'ឯកំ សត្ថារំ ឧទ្ទិស្ស បព្វជិតេហិ'** នេះ ព្រះអដ្ឋកថាចារ្យពោលហើយ ដល់ជនទាំងឡាយមានជនដែលស្លៀកសំពត់ស និងបរិព្វាជកជាដើម ។ បទ ថា **'ឯកគណ-បរិយាបន្នេហិ'** បានដល់ គឺជនដែលរាប់បញ្ចូល ក្នុងពួកគណៈជាមួយគ្នា មាននាយមាលាការជាដើម " ។

ដីកាសង្គីតិសូត្រនិងសម្មាទិដ្ឋិសូត្រថា "ស្រ្តីដែលជនអ្នកមានគោត្រស្មើគ្នា រក្សាហើយ ឈ្មោះថា **គោត្តរក្ខិតា**, ស្រ្តីដែលជនអ្នកមានធម៌ប្រព្រឹត្តរួមគ្នា រក្សាហើយ ឈ្មោះថា **ធម្មរក្ខិតា**, ស្រ្តីដែលមានស្វាមី ឈ្មោះថា **សារក្ខា**, ព្រះរាជាទ្រង់តាំងព្រះរាជអាជ្ញាព្រោះការល្មើសនូវស្រ្តីណា, ស្រ្តីនោះ ឈ្មោះថា **សបរិទណ្ឌា**" ។

(២៣៦) ន័យមកក្នុងអដ្ឋកថា សញ្ចរិត្តសិក្ខាបទ ថា “ ស្ត្រីដែលគេលោះមក ដោយទ្រព្យតិចខ្លះ ច្រើនខ្លះ ឈ្មោះថា **ធនក្កីតា** ។ ក៏ព្រោះស្ត្រីនោះ គ្រាន់តែគេលោះមក ដោយទ្រព្យប៉ុណ្ណោះ មិនទាន់ឈ្មោះថា ជាភរិយាទេ, តែស្ត្រីដែលឈ្មោះថា ជាភរិយា ក៏ព្រោះជាស្ត្រីដែលគេលោះមក ដើម្បីប្រយោជន៍ដល់ការនៅរួម, ហេតុនោះ ក្នុងនិទ្ទេសនៃបទ ថា ‘**ធនក្កីតា**’ នោះ ព្រះឧបាលី ទើបពោល ថា ‘បុរសលោះមក ដោយទ្រព្យហើយ ឲ្យនៅរួមជាមួយ’ ។ ស្ត្រីណា រមែងនៅ ដោយសេចក្តីពេញចិត្ត គឺ ដោយសេចក្តីចូលចិត្តរបស់ខ្លួន ហេតុនោះ ស្ត្រីនោះ ឈ្មោះថា **ឆន្ទវាសិនី** ។ ក៏ស្ត្រីនោះរមែងជាភរិយា ដោយហេតុត្រឹមតែសេចក្តីពេញចិត្ត របស់ខ្លួនតែម្យ៉ាង ក៏មិនមែនទេ, ប៉ុន្តែ ឈ្មោះថាជាភរិយា ព្រោះជាអ្នកដែលបុរសយល់ព្រមហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃមហាវិភង្គ ថា ‘**ឆន្ទវាសិនី**’ នោះ ព្រះឧបាលី ទើបពោល ថា ‘បុរសជាទីស្រឡាញ់ ឲ្យស្ត្រីជាទីស្រឡាញ់នៅរួម’ ។ ស្ត្រីណា រមែងរស់នៅដោយភោគៈ ហេតុនោះ ស្ត្រីនោះ ឈ្មោះថា **ភោគវាសិនី** ។ ពាក្យថា ‘**ភោគវាសិនី**’ នេះ ជាឈ្មោះនៃស្ត្រីក្នុងជនបទ ដែលបាននូវគ្រឿងឧបករណ៍សម្រាប់ផ្ទះ មានត្បាល់និងអង្រែជាដើមហើយ ចូលដល់ភាពជាភរិយា ។ ស្ត្រីណា រមែង

រស់នៅ ដោយកំណាត់សំពត់ ហេតុនោះ ស្ត្រីនោះ ឈ្មោះថា **បដវាសិនី** ។ ពាក្យថា '**បដវាសិនី**' នុ៎ះ ជាឈ្មោះ នៃស្ត្រី អ្នកក្រខ្សត់ ដែលបានវត្ថុត្រឹមតែសំពត់ស្លៀក ឬសំពត់ដណ្តប់ហើយ ចូលដល់ភាពជាភរិយា ។ ពាក្យថា '**ឱទបត្តកិនី**' នុ៎ះ គឺជា ឈ្មោះ នៃស្ត្រីដែលពួកញាតិញ៉ាំងដៃទាំងឡាយ នៃកូនកំលោះ និង កូនក្រមុំទាំង ២ នាក់ ឲ្យធ្លាក់ចុះទៅ ក្នុងភាជន៍ទឹកជាមួយគ្នាហើយ ពោល ថា 'អ្នកទាំងឡាយ ចូរជាអ្នកព្រមព្រៀងគ្នា មិនបែកបាក់គ្នា ដូចជាទឹកនេះ' ដូច្នេះហើយ កំណត់កាន់យក ។ ទ្រនូល របស់ស្ត្រី នោះ គឺបុរសដាក់ចុះ គឺ ទម្លាក់ចុះហើយ ហេតុនោះ ស្ត្រីនោះ ឈ្មោះ **ឱភដចុម្ពដា** គឺ ក្នុងចំណោមស្ត្រីទាំងឡាយ មានស្ត្រីអ្នករែក ឧសជាដើម ស្ត្រីណាមួយ ។ បុរសញ៉ាំងទ្រនូល ឲ្យធ្លាក់ចុះ ចាក ក្បាលរបស់ស្ត្រីណាហើយឲ្យនៅក្នុងផ្ទះ, ពាក្យថា '**ឱភដចុម្ពដា**' នុ៎ះ គឺជាឈ្មោះ នៃស្ត្រីនោះ ។ បទ ថា '**ទាសី ច**' បានដល់ ស្ត្រី ដែលប្រើប្រាស់ជាខ្ញុំផង ជាភរិយាផង របស់ខ្លួននុ៎ះឯង ។ ស្ត្រីណា ធ្វើការងារ ដើម្បីថ្លៃឈ្នួល ក្នុងផ្ទះ, ស្ត្រីនោះ ឈ្មោះថាស្ត្រីអ្នកធ្វើ ការឈ្នួល, បុរសខ្លះ មិនមានសេចក្តីត្រូវការ ដោយភរិយា របស់ ខ្លួន សម្រេចការនៅគ្រប់គ្រងផ្ទះ ជាមួយនឹងស្ត្រីនោះ, ស្ត្រីនេះ លោក ហៅថា 'ស្ត្រីដែលប្រើប្រាស់ជាខ្ញុំផង ជាភរិយាផង' ។ ស្ត្រីដែល

ទង់នាំមកហើយ ឈ្មោះថា ធជាហដា ។ មានពាក្យអធិប្បាយថា 'ស្ត្រីដែលកងទ័ព លើកទង់ឡើងហើយ ទៅប្លន់ដណ្តើមនូវខេត្តដែនគូប្រឆាំង ហើយនាំមក' ។ បុរសខ្លះ ធ្វើស្ត្រីនោះជាភរិយា, ស្ត្រីនេះឈ្មោះថា ធជាហដា ។ ស្ត្រីណា ដែលបុរសគប្បីនៅរួម ក្នុងកាលមួយរំពេចនោះ, ស្ត្រីនោះ ឈ្មោះថា មុហុត្តិកា អធិប្បាយថា ស្ត្រីដែលបុរសនៅរួមគ្នា ក្នុងខណៈនោះ " ។

(២៣៧) ដីកាសញ្ចរិត្តសិក្ខាបទនោះ ថា " ២ បទ ថា 'ធនេន កីតា' បានដល់ ស្ត្រីដែលបុរសលោះមក ដោយទ្រព្យដើម្បីប្រយោជន៍ជាភរិយា ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលពាក្យ ថា 'យស្មា បន' ដូច្នេះ ជាដើម ។ បទ ថា 'ភោគេន' បានដល់ ព្រោះភោគៈជាហេតុ ។ មែនពិត ស្ត្រីអ្នករស់នៅ ដើម្បីភោគៈ លោកហៅថា ភោគវាសិនី ។ បទ ថា 'ឈភិត្វា' បានដល់ បុរសណាឲ្យស្ត្រីនោះនៅ, បានហើយអំពីដៃនៃបុរសនោះ ។ ស្ត្រីដែលបុរសចាប់ភាជន៍ទឹកហើយ នាំយកមកឈ្មោះថា ឱទបត្តកិនី ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលពាក្យ ថា 'ឧភិន្នំ' ដូច្នេះ ជាដើម ។ ក្នុងពាក្យ ថា 'ធជេន អាហដា' នុ៎ះ ព្រះអដ្ឋកថាចារ្យ ពោលកងទ័ពនុ៎ះឯង ដោយធជ ស័ព្ទ ព្រោះប្រកបដោយទង់ ។ មានពាក្យអធិប្បាយ ថា

'ស្ត្រី គឺសេនា ដែលលើកទង់ឡើងហើយ នាំយកមក' ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា '**ឧស្សិតទ្ធជាយា**' ដូច្នេះ ជាដើម" ។

ភរិយាទាំងអស់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ថា "**ទារ:**" ក្នុងមង្គលកថានេះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា "ភរិយា ២០ ពួក ភរិយាណាមួយ ឈ្មោះថា ភរិយា" ។

## ( ការសង្គ្រោះភរិយា ដោយស្ថាន ៥ យ៉ាង )

(២៣៨) បុត្រ និង ភរិយា ឈ្មោះថា **បុត្តទារ:** ។ ការសង្គ្រោះ នូវបុត្រនិងភរិយានោះ ។ បណ្ដាបុត្រនិងភរិយានោះ កិរិយាធ្វើឧបការៈ ដោយការសង្គ្រោះទាំងឡាយ មានការហាមចាកអំពើអាក្រក់ជាដើម ឈ្មោះថា ការសង្គ្រោះបុត្រទាំងឡាយ, ការសង្គ្រោះបុត្រនោះ ខ្ញុំបានពោលហើយ ក្នុងទិសខាងក្រោយនុ៎ះឯង ។

ការធ្វើឧបការៈ ដោយការសង្គ្រោះទាំងឡាយ មានកិរិយាលើកដម្កើងជាដើម ឈ្មោះថា ការសង្គ្រោះ ភរិយាទាំងឡាយ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ ថា " ម្នាលគហបតីបុត្រ ទិសខាងក្រោយ គឺភរិយា ស្វាមីគប្បីទំនុកបំរុង

ដោយស្ថាន ៥ យ៉ាង គឺ÷ ដោយកិរិយារាប់អានលើកដម្កើង ១ ដោយកិរិយាមិនមើលងាយ ១ ដោយកិរិយាមិនប្រព្រឹត្តិក្បត់ចិត្ត ១ ដោយប្រគល់ភាពជាធំឲ្យ ១ ដោយការឲ្យគ្រឿងតាក់តែងខ្លួន ១, ម្នាលគហបតីបុត្រ ទិសខាងក្រោយ គឺភរិយា ស្វាមីគប្បីទំនុកបំរុង ដោយស្ថាន ៥ យ៉ាងនេះឯង " ។

(២៣៩) បណ្តាទិសទាំង ៦ នោះ បុត្រនិងភរិយា គប្បីជ្រាប ថា "ទិសខាងក្រោយ" ដោយអំណាច នៃកិរិយាតាមជាប់មកខាងក្រោយ ។

( កិរិយារាប់អានលើកដម្កើង )

ក្នុងឋានៈ ទី ១ ថា "សម្មាននាយ" នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ÷ កិរិយាលើកដម្កើង ឈ្មោះថា កិរិយារាប់អាន ។ កិរិយាលើកដម្កើងនោះ មាន ៣ យ៉ាង គឺ÷ មានកិរិយាប្រព្រឹត្តិប្រយោជន៍ជាលក្ខណៈ ១ មានការឲ្យជាលក្ខណៈ ១ មានការពោលពាក្យជាទីស្រឡាញ់ជាលក្ខណៈ ១ ។ បណ្តាការលើកដម្កើងទាំង ៣ យ៉ាងនោះ ២ យ៉ាងក្រៅអំពីនេះ លោកសង្គ្រោះហើយ ដោយឋានៈ ទី ៤ ទី ៥ នុ៎ះឯង ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ ដើម្បីនឹងសំដែងការលើកដម្កើង មានកិរិយាពោលពាក្យដែលជាទីស្រឡាញ់ជាលក្ខណៈ ទើបពោលហើយ ក្នុងអដ្ឋកថាថា "ដោយការ

ពោលពាក្យលើកដម្កើង យ៉ាងនេះ ថា 'នែម៉ែទេព នែម៉ែតិស្សៈ!"ៗ

( ការមិនមើលងាយ )

ក្នុងឋានៈ ទី ២ ថា "**អវិមាននាយ**" នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ សេចក្ដីរាប់អាន ទៅប្រាសហើយ ឈ្មោះថា សេចក្ដីមើលងាយ ៗ ការមើលងាយមិនមាន ឈ្មោះថា កិរិយាមិនមើលងាយ គឺ មិនធ្វើនូវការមើលងាយ ៗ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថា ថា "ជនទាំងឡាយ វាយតប់ បៀតបៀន នូវជនទាំងឡាយ មានខ្ញុំបម្រើនិងកម្មករជាដើមហើយ ជេរស្ដី ដោយប្រការណា, ដោយកិរិយាមិនពោលបៀតបៀន មើលងាយមើលថោក ដោយប្រការដូច្នោះ" ៗ ដោយហេតុថា ជនអ្នកជិតខាងទាំងអស់ រមែងមើលងាយមើលថោកនូវជន គឺស្ត្រី ដែលស្វាមីមើលងាយហើយ ដោយពិត ៗ

( ការមិនប្រព្រឹត្តិក្បត់ចិត្ត )

ក្នុងឋានៈ ទី ៣ ថា "**អនតិចរិយាយ**" នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ស្វាមីប្រព្រឹត្តកន្លង នូវភរិយានោះហើយ ស្និទ្ធស្នាល ជាមួយនឹងស្ត្រីដទៃ ខាងក្រៅ ឈ្មោះថា ប្រព្រឹត្តកន្លងភរិយានោះ, ព្រោះការប្រព្រឹត្តិមើលងាយ មិននាំយកស្ត្រីជាមេផ្ទះ

របស់ខ្លួននោះ, ដោយកិរិយាមិនធ្វើ ដោយប្រការដូច្នោះឡើយ” ។

## ( ប្រគល់ភាពជាធំឲ្យ )

ក្នុងឋានៈ ទី ៤ ថា “ ឥស្សរិយវោស្សគ្គេន ” នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ក៏ស្ត្រីទាំងឡាយ បាននូវគ្រឿងប្រដាប់សូម្បីដូចជាគ្រឿងប្រដាប់មហាលតាហើយ កាលមិនបានចាត់ចែងភត្ត ក៏ក្រោធខឹង, អធិប្បាយថា កាលបើស្វាមី ដាក់វែកលើដៃហើយ ប្រគល់រោងភត្តឲ្យ ដោយប្រាប់ ថា “ចូរអូនធ្វើ តាមសេចក្តីពេញចិត្ត របស់អូនចុះ” ដូច្នេះ, ឥស្សរិយភាព គ្រប់យ៉ាង រមែងឈ្មោះថា គឺស្វាមីប្រគល់ឲ្យហើយ, ដោយកិរិយាធ្វើយ៉ាងដូច្នោះ ។ ក៏ការងារមានកសិកម្ម និងពាណិជ្ជកម្មជាដើម សូម្បីដែលស្វាមីអ្នកស្ថិតនៅ ក្នុងផ្ទះនុ៎ះឯង គប្បីចាត់ចែង, មិនមែនជាភារកិច្ច របស់ស្ត្រីក្នុងត្រកូលឡើយ, គឺជាភារកិច្ច របស់ស្វាមី តែម្យ៉ាង, ក៏ប៉ុន្តែទ្រព្យសម្បត្តិ ដែលស្វាមីរកបានមកហើយ អំពីការងារនោះ រមែងជាទ្រព្យដែលភរិយានោះ ត្រូវទុកដាក់ ធ្វើឲ្យជារបស់ដែលគ្រប់គ្រងដោយប្រពៃ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យ កាលសំដែងនូវការប្រគល់ឥស្សរិយភាព ដែលសមគួរ ដល់ស្ត្រីមេផ្ទះ ទើបបានពោល ថា “ កាលបើស្វាមី ប្រគល់រោងភត្តឲ្យហើយ ” ។

អធិប្បាយថា ក៏បើយ៉ាងដូច្នោះ ស្ត្រីមេផ្ទះទាំងនុ៎ះ រមែងសម្គាល់ថា "បើរោងភត្តនោះ ដែលស្វាមីប្រគល់ឲ្យហើយ, ឥស្សរិយភាពគ្រប់យ៉ាង រមែងឈ្មោះថា ស្វាមីបានប្រគល់ឲ្យហើយ " ។

## ( ការឲ្យគ្រឿងប្រដាប់តាក់តែងខ្លួន )

ក្នុងឋានៈ ទី ៥ ថា " **អលង្ការានុប្បទានេន** " នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ធម្មតាស្ត្រីទាំងឡាយ តែងមិនត្រេកអរសប្បាយដោយការបានគ្រឿងប្រដាប់ ដែលមានតម្លៃ ដ៏ច្រើនលើសលប់ ដូចជាការបានបុត្រឡើយ ហេតុនោះ កិរិយាញុាំងស្ត្រីទាំងនោះ ឲ្យត្រេកអរ មិនមែនជាហេតុឡើយ, ព្រោះហេតុនោះ កិរិយាឲ្យនូវគ្រឿងប្រដាប់ ដែលសមគួរដល់សម្បត្តិនុ៎ះឯង សមគួរហើយ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា "ដោយការឲ្យគ្រឿងប្រដាប់ ដែលសមគួរដល់ទ្រព្យសម្បត្តិ របស់ខ្លួន" ។

(២៤០) ក្នុងមាតិកា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "បុត្រនិងភរិយា គប្បីជ្រាប ថា 'ជាទិសខាងក្រោយ (ខាងលិច)' ក៏ពិតមែនហើយ, ទោះជាដូច្នោះក៏ដោយ ការសង្គ្រោះបុត្រ ព្រះអង្គទ្រង់សំដែងហើយ ដោយព្រះតម្រាស់ ថា " **បាបា និវារេន្តិ** " ដូច្នេះ ជាដើម, ហេតុនោះ ការសង្គ្រោះបុត្រនោះ គប្បីឃើញ ថា

“ព្រះអង្គមិនទ្រង់ធ្វើនិទ្ទេស ដោយអំណាចនៃបុត្រឡើយ ទ្រង់ធ្វើដោយអំណាចនៃភរិយា ពោលគឺទារៈតែម៉្យាង”។ ដោយហេតុក្នុងដីកាសិគាលសូត្រ លោកពោល ថា “ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគ សូម្បីទ្រង់ឧទ្ទេស ថា ‘បុត្រនិងភរិយា ជាទិសខាងក្រោយ’ ដូច្នេះ (ប៉ុន្តែ) ទ្រង់វិសជ្ជនា ទិសខាងក្រោយ ដោយអំណាចនៃភរិយា តែម៉្យាង, មិនទ្រង់វិសជ្ជនា ដោយអំណាចនៃបុត្រឡើយ ។ ព្រោះហេតុអ្វី ?។ ព្រោះហេតុថា បុត្រទាំងឡាយរមែងជាអ្នក គឺបិតាកាលលោកអនុគ្រោះនូវមាតា របស់ខ្លួន ក្នុងពេលដែលខ្លួននៅក្មេងនុ៎ះឯង ឈ្មោះថា អនុគ្រោះហើយ សង្គ្រោះហើយ ។ ចំណែក ក្នុងពេលដែលបុត្រដល់ភាពជាអ្នកដឹងក្តីហើយ បុត្រទាំងឡាយនោះ គឺបិតាគប្បីអនុគ្រោះ ដោយវិធីណា, វិធីនេះនោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រាស់សំដែងពិតហើយ ក្នុងវារៈនៃទិសទី ១ ដោយន័យ ថា “**បាបា និវារេន្តិ**” ដូច្នេះ ជាដើម ហេតុនោះ មានប្រយោជន៍អ្វី ដោយការវិសជ្ជនាម្តងទៀត” ។

ចំណែក ក្នុងគម្ពីរអដ្ឋកថា ក្នុងមង្គលកថានេះ ព្រះអាចារ្យទាំងឡាយ សរសេរទុកហើយ ថា “ព្រះដ៏មានព្រះភាគ ទ្រង់បានសង្គ្រោះនូវបុត្រនិងភរិយា ដែលទ្រង់លើកឡើងមកសំដែង ក្នុងមាតិកានេះ ថា ‘បុត្រនិងភរិយា គប្បីជ្រាបថា ជាទិសខាងលិច’

ដោយភរិយាស័ព្ទ ៗ បុត្ត ស័ព្ទ ក្នុងពាក្យថា "បុត្តទារំ" នោះ លោកសរសេរ ដោយសេចក្តីធ្វេសប្រហែស ៗ អធិប្បាយថា "ព្រះអង្គទ្រង់សង្គ្រោះ ទារៈ ដោយ ភរិយា ស័ព្ទ" ដូច្នេះ វិញទើបសមគួរ ៗ ក៏បុត្រនិងភរិយា គប្បីជ្រាប ថា "ទិសខាងក្រោយ (ទិសខាងលិច) ដោយអំណាចការជាប់តាមមកខាងក្រោយ" ៗ

## (ភរិយាសង្គ្រោះស្វាមីដោយស្ថាន ៥ យ៉ាង)

(២៤១) ដូច្នោះ ការសង្គ្រោះ ដោយឋានៈទាំងឡាយ មានកិរិយារាប់អានលើកដម្កើងជាដើម ទើបឈ្មោះថា ជាមង្គល ព្រោះជាហេតុ នៃប្រយោជន៍សុខ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន មានភាពជាអ្នកចាត់ចែងការងារ ដោយប្រពៃជាដើម ៗ

ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលគហបតីបុត្រ ទិសខាងក្រោយ គឺភរិយា ដែលស្វាមីទំនុកបំរុងដោយស្ថាន ៥ យ៉ាងនេះហើយ រមែងអនុគ្រោះស្វាមី ដោយស្ថាន ៥ យ៉ាងវិញ គឺ ជាអ្នកចាត់ចែងការងារដោយប្រពៃ ១ ជាអ្នកជួយសង្គ្រោះញាតិខាងស្វាមីដោយប្រពៃ ១ ជាអ្នកមិនប្រព្រឹត្តក្បត់ចិត្ត (ស្វាមី) ១ រក្សាទ្រព្យសម្បត្តិ ដែលស្វាមីរកបានមកហើយ ១ ជាស្ត្រីឧស្សាហ៍ មិនខ្ជិលច្រអូស ក្នុងកិច្ចការងារគ្រប់បែបយ៉ាង ១,

ម្នាលគហបតីបុត្រ ទិសខាងក្រោយ គឺភរិយា ដែលស្វាមីទំនុកបំរុង ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីវិញ ដោយស្ថាន ៥ យ៉ាងនេះឯង " ។

( ចាត់ចែងការងារដោយប្រពៃ )

(២៤២) បណ្ដាឋានៈទាំង ៥ យ៉ាងនោះ ក្នុងឋានៈទី ១ ថា " **សុសំវិហិតកម្មន្តា** " នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ÷ ការងារនៃការចាត់ចែងនូវចំណីអាហារនិងការគ្រួតត្រា ឈ្មោះថា ការងារ ដែលស្រ្តីក្នុងត្រកូល គប្បីចាត់ចែង ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ក្នុងអដ្ឋកថា ថា " ជាអ្នកចាត់ចែងការងារដោយប្រពៃហើយ ដោយកិរិយាមិនកន្លង នូវវេលានៃការចម្អិនយាគូនិងភត្តជាដើមហើយ ធ្វើកិច្ចការនោះៗ ឲ្យបានសំរេច " ។

( សង្គ្រោះជនជាញាតិខាងស្វាមី )

ក្នុងឋានៈ ទី ២ ថា " **សុសង្គហិតបរិជនា** " នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ ÷ ព្រះអដ្ឋកថាចារ្យ ពោលហើយ ថា " ជាអ្នកសង្គ្រោះនូវជនជិតខាង ដោយឋានៈទាំងឡាយ មានការរាប់អានគ្នាជាដើម និង ដោយសង្គហពិធីទាំងឡាយ មានបញ្ជូនបញ្ញើទៅឲ្យជាដើម " ដូច្នេះ ដើម្បីសំដែង ថា " ជនខាងក្នុងផ្ទះ គឺស្រ្តីមេផ្ទះ

គប្បីសង្គ្រោះ ជាប់ជានិច្ចមែនពិត ព្រោះហេតុណា, ព្រោះហេតុនោះ ជនខាងក្នុងផ្ទះនោះ ទើបលោកមិនបានអធិប្បាយហើយ ក្នុងឋានៈនេះទេ, ប៉ុន្តែ ជនដែលជាញាតិ របស់ស្វាមី និង របស់ខ្លួន ឈ្មោះថា បរិជន ក្នុងឋានៈនេះ, បរិជននោះ គឺស្ត្រីមេផ្ទះនោះ គប្បីសង្គ្រោះ ដោយការពោលពាក្យពិរោះ ដោយការឲ្យភោជនជាដើម និងដោយការបញ្ជូនរបស់ ដែលជាទីស្រឡាញ់ទៅឲ្យ ក្នុងថ្ងៃមង្គលទាំងឡាយ មានថ្ងៃមង្គលការជាដើម ដើម្បីជាបណ្ណាការ ដែលកើតឡើងហើយ ក្នុងទីនោះឯង អំពីទីដទៃ តាមសមគួរ " ។

( មិនប្រព្រឹត្តក្បត់ចិត្ត )

ក្នុងឋានៈ ទី ៣ ថា "**អនតិចារិណី**" បានដល់ ភរិយាមិនលះបង់ចោលនូវស្វាមីហើយ ប្រាថ្នាបុរសដទៃ សូម្បីដោយចិត្ត ។

( រក្សាទ្រព្យដែលស្វាមីរកបានមក )

ក្នុងឋានៈ ទី ៤ ថា "**សម្ភតំ**" បានដល់ ទ្រព្យដែលស្វាមីធ្វើការងារមានកសិកម្ម និង ពាណិជ្ជកម្មជាដើម នាំយកមកហើយ អធិប្បាយថា ទ្រព្យដែលស្វាមីបញ្ចូលទៅខាងក្នុងផ្ទះ អំពីខាងក្រៅ ។

( ឧស្សាហ៍មិនខ្ជិលច្រអូស )

ក្នុងឋានៈ ទី ៥ ថា "**ទក្ខា**" នេះ គប្បីជ្រាបវិនិច្ឆ័យ

ដូចតទៅ ÷ ធម្មតាស្ត្រីមេផ្ទះ គប្បីប្រាថ្នាភាពជាអ្នកឈ្លាសវៃ ក្នុងកិរិយាចាត់ចែងអាហារជាមុន, ហើយនិងគប្បីប្រាថ្នាការប្រកបខ្វល់ខ្វាយ ក្នុងកិច្ចការចាត់ចែងអាហារនោះ, តអំពីនោះ គប្បីប្រាថ្នាការប្រកបខ្វល់ខ្វាយក្នុងកិច្ចការតូច-ធំទាំងឡាយ ដែលទាក់ទងនឹងជនគឺស្រ្តី របស់ស្វាមី, តអំពីនោះ គប្បីប្រាថ្នាការប្រកបខ្វល់ខ្វាយក្នុងកិច្ចដែលគួរធ្វើទាំងឡាយ ដល់បុត្រទាំងឡាយ និង បរិជន ។ ដោយហេតុនោះ ទើបលោកពោល ក្នុងអដ្ឋកថា ថា "ជាអ្នកឆ្លាតស្ទាត់ជំនាញ ក្នុងកិច្ចការទាំងឡាយ មានការចាត់ចែងយាគូ និងភត្តជាដើម " ។

បទ ថា "**អនលសា**" គឺ មិនមានសេចក្តីខ្ជិលច្រអូស ។ ក្នុងអដ្ឋកថា លោកពោលហើយ ថា "ស្ត្រីដទៃទៀត ជាអ្នកខ្ជិលច្រអូស ជាអ្នកអង្គុយកៀច ក្នុងទីដែលខ្លួនអង្គុយនុ៎ះឯង, ជាអ្នកឈរកៀច ក្នុងទីដែលខ្លួនឈរនុ៎ះឯង យ៉ាងណាមិញ, ឯភរិយាមិនជាអ្នកដូច្នោះទេ មានចិត្តត្រេកអររីករាយ ញុំាងកិច្ចការគ្រប់បែបយ៉ាង ឲ្យសម្រេច "ដូច្នេះ ដើម្បីនឹងសំដែង នូវភាពជាអ្នកមិនខ្ជិលច្រអូសនោះឯង ដោយអត្ថដែលវិប្បលាសផង ដោយអត្ថដែលអនុលោមតាមផង ។

(២៤៣) ន័យមួយបែបទៀត ។ ការសង្គ្រោះ ដោយ

ការឲ្យ ការពោលពាក្យដ៏ពិរោះ និងការប្រព្រឹត្តិប្រយោជន៍ ដែលប្រកបដោយធម៌ ឈ្មោះថា ការសង្គ្រោះ ។ ការសង្គ្រោះនេះ តើយ៉ាងដូចម្ដេច ? ។ គឺការឲ្យស្បៀង ក្នុងថ្ងៃឧបោសថ ការឲ្យមើលនូវនក្ខត្តឫក្ស ក្នុងថ្ងៃនៃនក្ខត្តឫក្ស ការធ្វើមង្គល ក្នុងថ្ងៃនៃមង្គល ការឲ្យដំបូលទូន្មាននិងការអប់រំ ក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងក្នុងសម្បរាយិកភព ។ ការសង្គ្រោះនោះ គប្បីជ្រាប ថា "ជាមង្គល" ព្រោះជាហេតុនៃប្រយោជន៍សុខ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ព្រោះជាហេតុនៃប្រយោជន៍សុខ ដែលប្រព្រឹត្តទៅក្នុងសម្បរាយិកភព ព្រោះភាវៈនៃការសង្គ្រោះនោះប្រកបដោយធម៌ និង ព្រោះជាហេតុនៃភាពជាអ្នក សូម្បីពួកទេវតា គប្បីនមស្សការ ដោយន័យមុននុ៎ះឯង" ។

(២៤៤) ពិតមែនដូច្នោះ សក្កទេវរាជ ស្ដេចមានបំណងយាងទៅកាន់ឧទ្យាន ទ្រង់យាងចុះអំពីវេជយន្តប្រាសាទ ទ្រង់ធ្វើនូវអញ្ជលី នមស្សការ ទិស ទាំង ១០ ។ មាតលី ឃើញនូវអាការៈយ៉ាងដូច្នោះហើយ ទូលសួរ ថា "បពិត្រព្រះសម្មតិទេព តើព្រះអង្គទ្រង់នមស្សការអ្នកណា ? " ។ សក្កទេវរាជនោះ កាលទ្រង់ត្រាស់ប្រាប់ ដល់មាតលីនោះ ទើបទ្រង់ត្រាស់ហើយ នូវគាថានេះក្នុងបឋមសក្កនមស្សនសូត្រ ក្នុងទុតិយវគ្គ សក្កសំយុត្ត ថា ÷

"ម្នាលមាតលី គ្រហស្ថទាំងឡាយណា ជាអ្នកធ្វើបុណ្យ មានសីល ជាឧបាសក ចិញ្ចឹមនូវភរិយាដោយធម៌, យើងនមស្សការគ្រហស្ថទាំងនោះ" ។

អដ្ឋកថាបឋមសក្កនមស្សនសូត្រនោះ ថា "បណ្តាបទទាំងនោះ បទ ថា 'បុញ្ញករា' គឺ ជាអ្នកធ្វើបុណ្យជាអាទិ៍ យ៉ាងដូច្នេះ ថា 'ការឲ្យចតុប្បច្ច័យ ការបូជាដោយផ្ការាត្រី និងដោយផ្កាម្ទិះនិងការទ្រោលប្រទីប ១.០០០' ។ បទ ថា 'សីលវន្តោ' បានដល់ស្ថិតនៅ ក្នុងភាពជាឧបាសកហើយ ដល់ព្រម ដោយសីល ៥ ខ្លះ សីល ១០ ខ្លះ ។ បាទគាថា ថា 'ធម្មេន ទារំ បោសេន្តិ' បានដល់ មិនធ្វើអំពើទុច្ចរិតទាំងឡាយ មានកិរិយាជីកទម្លាយរូងជាដើម ហើយចិញ្ចឹមបុត្រនិងភរិយា ដោយការងារមានកសិកម្ម គោរក្ខកម្ម និងពាណិជ្ជកម្មជាដើម ដែលប្រកបដោយធម៌ " ។

ដីកាបឋមសក្កនមស្សនសូត្រនោះ ថា " ព្រះអដ្ឋកថាចារ្យសង្គ្រោះ នូវវត្ថុជាទីតាំងនៃកិរិយាធ្វើបុណ្យដែលសេសសល់ ដោយ **អាទិ** ស័ព្ទថា '**ឯវមាទិ**" ។ ដោយសីល ៥ ដោយអំណាចនៃនិច្ចសីល, ដោយសីល ១០ ដោយអំណានៃនិយមសីល ។ ព្រះអដ្ឋកថាចារ្យ សំដែង ដោយ **បិ** ស័ព្ទ ថា 'ដោយសីល ៨ ដោយ

អំណាចឧបោសថសីល ដែលតូចជាងសីល ១០ នោះ ៗ បទ ថា 'ធម្មិកេហិ' បានដល់ មិនប្រាសចាកធម៌ គឺ ដោយធម៌"។

(២៤៥) មាតលី ស្តាប់ពាក្យនោះហើយ កាលនមស្សការគ្រហស្ថទាំងនោះឯង ទើបពោលគាថានេះ ថា ÷

"បពិត្រសក្កទេវរាជ ព្រះអង្គនមស្សការ នូវគ្រហស្ថទាំងឡាយណា, បានឮថា គ្រហស្ថទាំងឡាយនោះ ជាអ្នកប្រសើរពិត ក្នុងលោក, បពិត្រស្តេចវាសវៈ ព្រះអង្គ ទ្រង់មនស្សការ នូវគ្រហស្ថទាំងឡាយណា, ឯទូលបង្គំ ក៏នមស្សការនូវគ្រហស្ថទាំងនោះដែរ"។

សេចក្តីសង្ខេប ក្នុងមង្គលត្ថទីបនីនេះ មានត្រឹមតែប៉ុណ្ណេះ ៗ ឯសេចក្តីពិស្តារ គប្បីត្រួតមើល ក្នុងព្រះសូត្រ ៗ ការសង្គ្រោះបុត្រនិងភរិយា ឈ្មោះថា ជាមង្គល ព្រោះជាហេតុ នៃភាពជាអ្នកដែលទេវតាទាំងឡាយ ក៏គប្បីនមស្សការ ដោយប្រការដូច្នេះឯង ៗ

(២៤៦) បណ្តាមាតាបិតា និង បុត្រទាំងនោះ បុត្រទាំងឡាយ ឈ្មោះថា **គហបតគ្គិ** របស់មាតាបិតាទាំងឡាយ, ចំណែកមាតាបិតាទាំងឡាយ ឈ្មោះថា **អាហុនេយ្យគ្គិ** របស់បុត្រទាំងឡាយ ៗ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែង

នូវធម៌ ដល់ឧគ្គតសរីរព្រាហ្មណ៍ ទើបទ្រង់ត្រាស់ ក្នុងទុតិយគ្គិសូត្រ ក្នុងសត្តកនិបាត អង្គុត្តរនិកាយ ថា "ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺអាហុនេយ្យបុគ្គល តើដូចម្តេច ? ។ ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាមាតា ឬ បិតា របស់បុគ្គលណា ក្នុងលោកនេះ, ម្នាលព្រាហ្មណ៍ ជនគឺមាតាបិតានេះ តថាគតហៅថា ភ្លើងគឺអាហុនេយ្យបុគ្គល ( របស់បុគ្គលនោះឯង ) ។ ដំណើរនោះ តើព្រោះហេតុអ្វី ? ។ ម្នាលព្រាហ្មណ៍ ព្រោះបុគ្គលនេះ មកហើយកើតហើយ ដោយសារមាតាបិតានេះ, ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ភ្លើងគឺអាហុនេយ្យគ្គិនេះ គឺបុត្រ គួរធ្វើសក្ការៈ គោរពអាប់អាន បូជា រក្សាបម្រើឲ្យជាសុខស្រួល ដោយប្រពៃ ។ ម្នាលព្រាហ្មណ៍ ចុះភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ តើដូចម្តេច ? ។ ម្នាលព្រាហ្មណ៍ ជនទាំងឡាយនោះ ត្រូវជាបុត្រ ឬជាប្រពន្ធ ឬជាខ្ញុំ ឬជាអ្នកបម្រើ របស់បុគ្គលណា ក្នុងលោកនេះ, ពួកជនមានបុត្រនិងភរិយាជាដើមនេះ តថាគតហៅថា ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ ( របស់បុគ្គលនោះ ), ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ គឺមាតាបិតា គួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សាបម្រើឲ្យជាសុខស្រួល ដោយប្រពៃ" ។

(២៤៧) អដ្ឋកថាទុតិយគ្គិសូត្រនោះ ថា "បណ្តាបទទាំងនោះ

២ បទ ថា 'អតោ ហាយំ' មានសេចក្តីថា ក៏ជននេះ (មកហើយ កើតហើយ) អំពីមាតាបិតានេះ ។ បទ ថា 'អាហុតោ' ប្រែថា មកហើយ ។ បទ ថា 'សម្ភូតោ' ប្រែថា កើតឡើងហើយ" ។

អដ្ឋកថាបឋមគ្គិសូត្រ ក្នុងសត្តកនិបាត អង្គុត្តរនិកាយនោះឯង ថា "បុត្រទាំងឡាយ អ្នកប្រតិបត្តិខុស ក្នុងមាតាបិតាទាំងឡាយនោះ រមែងកើត ក្នុងអបាយទាំង ៤ មាននរកជាដើម, ព្រោះហេតុនោះ មាតាបិតាទាំងឡាយ រមែងមិនគាមដុត ក៏ពិតមែនហើយ, ទោះបីជាដូច្នោះក៏ដោយ ក៏រមែងជាបច្ច័យ នៃការគាមដុតដែរ, មាតានិងបិតា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា 'ភ្លើងគឺអាហុនេយ្យបុគ្គល' ដោយអត្ថថា គាមដុតនុ៎ះឯង ដោយប្រការដូច្នេះឯង" ។

ដីកាបឋមគ្គិសូត្រ ថា "កិរិយាគំនាប់ គឺ ការបូជា ដោយគោរព ឈ្មោះថា អាហុនៈ បានដល់ សក្ការៈ" ។

អដ្ឋកថាបឋមគ្គិសូត្រ ថា "ជនទាំងឡាយណា រមែងសមគួរនូវកិរិយាគំនាប់ ហេតុនោះ ជនទាំងឡាយនោះ ឈ្មោះថា អាហុនេយ្យៈ ។ មែនពិត មាតាបិតា រមែងសមគួរនូវកិរិយាគំនាប់ ព្រោះជាអ្នកមានឧបការៈច្រើន ដល់បុត្រទាំងឡាយ" ។

អដ្ឋកថាទុតិយគ្គិសូត្រ ថា "បទ ថា 'គហបតគ្គិ' បានដល់ ពួកជនមានបុត្រនិងភរិយាជាដើមនេះ ។ ព្រោះហេតុតែពួកជន

មានបុត្រនិងភរិយាជាដើមនោះ ប្រៀបចូជាគហបតី គឺ ប្រៀបដូចជាបុគ្គលជាម្ចាស់ផ្ទះ រមែងទៅ គឺ ត្រាច់ចរទៅ, ដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ហៅថា " គហបតគ្គិ " ។

## ( ភ្លើង ៧ ប្រការ )

(២៤៨) ចំណែក ក្នុងអដ្ឋកថាបឋមគ្គិសូត្រ ដែលព្រះមានព្រះភាគ ទ្រង់មិនចំណែកសំដែង យ៉ាងនេះ ថា " ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះ មាន ៧ ប្រការ ។ ភ្លើង ៧ ប្រការ តើដូចម្តេចខ្លះ ? ។ គឺ ភ្លើង គឺរាគៈ ភ្លើង គឺទោសៈ ភ្លើង គឺមោហៈ ភ្លើង គឺអាហុនេយ្យបុគ្គល ភ្លើង គឺ ទក្ខិណេយ្យបុគ្គល ភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះ ភ្លើងដែលកើតពីឧស, ម្នាលភិក្ខុទាំងឡាយ ភ្លើង មាន ៧ ប្រការ នេះឯង " ដូច្នេះ លោកពោលហើយ ថា " ក៏បុគ្គលជាម្ចាស់ផ្ទះ ព្រះដ៏មានព្រះភាគហៅថា " គហបតគ្គិ " ។ បុគ្គលជាម្ចាស់ផ្ទះនោះ ឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់មាតុគ្រាម ព្រោះប្រគល់ឲ្យ នូវវត្ថុមានទីដេក, សំពត់ និងគ្រឿងប្រដាប់ជាដើម, មាតុគ្រាម កាលប្រព្រឹត្តកន្លង បុគ្គលជាម្ចាស់ផ្ទះនោះ រមែងកើត ក្នុងអបាយទាំង ៤ មាននរកជាដើម, ព្រោះហេតុនោះ បុគ្គលជាម្ចាស់ផ្ទះនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់

ថា 'គហបតិគ្គិ' ដូច្នេះ ដោយអត្ថថា តាមដុត ដោយន័យមុនន៉ុះឯង" ។

## ( រឿងស្ត្រីប្រព្រឹត្តក្បត់ចិត្តស្វាមី )

(២៤៩) សូម្បីក្នុងអដ្ឋកថាសង្គីតិសូត្រ លោកក៏ពោលយ៉ាងដូច្នោះដែរ ហើយពោលទៀត ថា "ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ភរិយា របស់ឧបាសក ជាសោតាបន្ន ប្រព្រឹត្តក្បត់ចិត្ត (ស្វាមី) ។ ឧបាសកនោះ ឃើញភរិយានោះ ដោយជាក់ច្បាស់ ទើបពោល ថា "ហេតុអ្វី បានជាអូនធ្វើ យ៉ាងដូច្នេះ ? " ។ ភរិយានោះ ពោល ថា "បើនាងខ្ញុំ ធ្វើកម្មយ៉ាងដូច្នេះ, សុន័ខនេះ ចូរចោមរោម ខាំនាងខ្ញុំចុះ " ដូច្នេះហើយ ក៏ធ្វើកាលកិរិយាទៅកើតជានាងវេមានិកប្រេត ក្បែរស្រះឈ្មោះកណ្ណមុណ្ឌៈ ពេលថ្ងៃ សោយសម្បត្តិ, ពេលយប់ សោយនូវសេចក្តីទុក្ខ ។

ព្រះរាជាក្រុងពារាណសី កាលស្តេចយាងទៅដេញម្រឹគ ទ្រង់ចូលទៅកាន់ព្រៃ ស្តេចយាងទៅដល់ស្រះកណ្ណមុណ្ឌៈ ដោយលំដាប់ ទ្រង់សោយសម្បត្តិ ជាមួយនឹងនាងវេមានិកប្រេតនោះ ។ នាងប្រេតនោះ បញ្ឆោតនូវព្រះរាជាអង្គនោះហើយ ក៏សោយនូវសេចក្តីទុក្ខ ក្នុងវេលាយប់ ។ ព្រះរាជាក្រុងពារាណសីនោះ ទ្រង់ជ្រាបហើយ ទ្រង់ព្រះតម្រិះ ថា "នាងនេះ តើទៅ ក្នុងទីណាហ្ន៎ ? "

ដូច្នេះហើយ ទើបស្តេចយាងទៅ ខាងក្រោយ ៗ ទ្រង់គង់នៅក្នុងទីមិនឆ្ងាយ ទ្រង់ទតព្រះនេត្រឃើញ នូវសុនខមួយ ចេញអំពីស្រះកណ្ណមុណ្ឌៈ កំពុងខាំស៊ីនាងប្រេតនោះ ព្រួសរ " បជៈបជៈ " ហើយទ្រង់យកដាវកាប់ នូវសុនខនោះ ជាពីកំណាត់ ៗ សុនខ ២ បានកើតហើយ ៗ សុនខដែលព្រះរាជាទ្រង់កាប់ ម្តងទៀតហើយ ក៏បានទៅជាសុនខ ៤ ៗ ទ្រង់កាប់ ម្តងទៀត ក៏បានទៅជាសុនខ ៨ ៗ ទ្រង់កាប់ ម្តងទៀត ក៏បានទៅជាសុនខ ១៦ ៗ នាងប្រេតនោះក្រាបទូលសួរ ថា " បពិត្រព្រះស្វាមី តើព្រះអង្គទ្រង់ធ្វើអ្វី ? " ៗ ព្រះរាជាអង្គនោះ ទ្រង់ត្រាស់សួរ ថា " នេះជាអ្វីទៅ ? " ៗ នាងប្រេតនោះ ក្រាបទូល ថា " សូមព្រះអង្គ កុំទ្រង់ធ្វើ យ៉ាងដូច្នេះ សូមទ្រង់ស្តោះទឹកមាត់ លើផែនដីហើយ យកព្រះបាទជាន់ឈ្លីវិញ " ៗ ព្រះរាជាអង្គនោះ ទ្រង់បានធ្វើហើយ យ៉ាងនោះ ៗ សុនខទាំងឡាយក៏បានអន្តរធានបាត់អស់ហើយ ៗ ក្នុងថ្ងៃនោះ កម្មរបស់នាងប្រេតនោះ បានអស់ហើយ ៗ ព្រះរាជា ទ្រង់កើតវិប្បដិសារី ទ្រង់ប្រារព្ធដើម្បីស្តេចយាងទៅ ៗ នាងប្រេតនោះ ក្រាបទូលថា " បពិត្រព្រះស្វាមី កម្មរបស់ទូលព្រះបង្គំ អស់ហើយ, សូមព្រះអង្គ កុំយាងទៅឡើយ " ៗ ព្រះរាជា មិនទ្រង់ស្តាប់ ស្តេចយាងទៅហើយ ៗ

(២៥០) ដីកាសន្តិតិសូត្រនោះ ថា " បទ ថា ' សោ '

បានដល់ បុគ្គលជាម្ចាស់ផ្ទះ គឺ ភស្តា ។ បទ ថា 'បុរិមនយេនេវ' បានដល់ ព្រោះជាបច្ច័យ នៃការតាមដុត ។ បទ ថា 'អតិចារំ' បានដល់ ប្រព្រឹត្តកន្លងស្វាមី គឺ ប្រព្រឹត្តខុស ។ ២ បទ ថា 'វត្តំ ទុក្ខំ' មានសេចក្តីថា ឈ្មោះថា ទុក្ខ ព្រោះភាពជាអ្នក ត្រូវសុនខ ដែលប្រាកដឡើង ដោយអានុភាពនៃបាបកម្មរបស់ខ្លួន គប្បីខាំស៊ី ។ បទ ថា 'វញ្ចេត្វា' លោកបានពោលសំដៅយកហើយ នូវការមិន ឲ្យព្រះរាជាអង្គនោះ ទ្រង់ជ្រាបហើយ ទៅកាន់កន្លែងធ្វើ (កិច្ច) ។ បទ ថា 'បជបជំ' បានដល់ ធ្វើសំឡេងព្ញបជៈបជៈ ។ បទ ថា 'បជបជំ' នុ៎ះ ជាពាក្យសម្រាប់សំដែងចេញ នូវកិរិយាគ្រហឹម ។ បានព្ញថា ក៏កិរិយាស្តោះទឹកមាត់ លើផែនដីហើយ យកបាទជើងឈ្លី នេះឯណា, នេះ គឺជាការប្រកប ក្នុងការស្តោះ (ទឹកមាត់) (ជាពាក្យឧបកិច្ច) ដើម្បីការអន្តរធានទៅ នៃសុនខនោះឯង ។ ហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា 'ព្រះរាជាអង្គនោះ ទ្រង់បានធ្វើហើយដូច្នោះ, សុនខទាំងឡាយ ក៏អន្តរធានហើយ" ។

រឿង ស្ត្រីប្រព្រឹត្តក្បត់ចិត្តស្វាមី ចប់ ។

(២៥១) រឿងនេះ មកហើយ ក្នុងដីកាបឋមគ្គិសូត្រខ្លះ ក្នុង អដ្ឋកថា និងដីកាសង្គីតិសូត្រខ្លះ ដោយអំណាចការធ្វើរួមតែមួយ ។

ចំណែក ដែលមកក្នុងអដ្ឋកថាកណ្ហាមុណ្ឌាបេតវត្ថុ ក្នុងបេត្តវត្ថុ ដោយពិស្តារ មានការខុសប្លែកពីគ្នាបន្តិចបន្តួច ៗ ក៏រឿងនេះមកហើយក្នុងអដ្ឋកថាកណ្ហាមុណ្ឌាបេត្តវត្ថុនោះ ថា " ព្រះរាជាទ្រង់ព្រះតម្រិះ ថា 'សត្វសុនខនេះ នឹងជាសត្រូវ របស់ស្ត្រីនុ៎ះ' ដូច្នេះហើយ ទើបទ្រង់បាញ់ហើយ ដោយកូនសរ ដែលត្រាំដោយថ្នាំពិស ទ្រង់សម្លាប់សត្វសុនខ ចាកជីវិតហើយ " ព្រោះហេតុដូច្នេះ ក្នុងរឿងនេះគប្បីដល់នូវការយល់ព្រម ថា " ដោយន័យ ដែលមកក្នុងអដ្ឋកថា-សង្គីតិសូត្រ និង បឋមគ្គិសូត្រ បុគ្គលជាម្ចាស់ផ្ទះ ឈ្មោះថាគហបតគ្គិរបស់ភរិយា ៗ ដោយន័យ ដែលមកក្នុងអដ្ឋកថា ទុតិយគ្គិសូត្រ បុត្រនិងភរិយា ឈ្មោះថា គហបតគ្គិ របស់បុគ្គលជាម្ចាស់ផ្ទះ " ។

ការពណ៌នាអំពីកិរិយាសង្គ្រោះបុត្រនិងភរិយា ចប់ ។

❀ ❀ ❀

ប្រែចប់ យប់ថ្ងៃព្រហស្បតិ៍ ៨ កើត ខែបុស្ស ព.ស. ២៥៣៥

៣១ ធ្នូ ១៩៩២

## ពណ៌នាអំពីការងារ ដែលមិនច្របូកច្របល់

-------------

(២៥២) លោកពោល ក្នុងអដ្ឋកថាមង្គលសូត្រនេះ ថា " ឧបាយគ្រឿងចិញ្ចឹមជីវិត មានកសិកម្ម គោរក្ខកម្ម និង ពាណិជ្ជកម្ម ជាដើម ឈ្មោះថា **ការងារ** " ។

អដ្ឋកថាមហាទុក្ខក្ខន្ធសូត្រ ក្នុងមូលបណ្ណាសកៈ ថា " ការងារ គឺការភ្ជួររាស់ ឈ្មោះថា **កសិកម្ម** ។ ផ្លូវនៃការលក់ដូរ មានការលក់ដូរ ដោយស្មងជើង និង ការលក់ដូរ ដោយរទេះជាដើម ឈ្មោះថា **ពាណិជ្ជកម្ម** ។ កម្ម គឺការរស់នៅ ដោយកិរិយារក្សាគោទាំងឡាយ របស់ខ្លួន ឬ របស់អ្នកដទៃហើយ លក់បញ្ចុគោរស ឈ្មោះថា **គោរក្ខកម្ម** " ។

ដីកាមហាទុក្ខក្ខន្ធសូត្រនោះ ថា " ការភ្ជួររាស់ ឈ្មោះថា **កសិ** ហេតុនោះ ឧបាយគ្រឿងចិញ្ចឹមជីវិត ដែលជាប់ទាក់ទងនឹងការភ្ជួររាស់ គ្រប់បែបយ៉ាង ព្រះដ៏មានព្រះភាគ ទ្រង់កំណត់យកដោយ **កសិ** ស័ព្ទ ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា " កម្ម គឺការភ្ជួររាស់ ឈ្មោះថា **កសិកម្ម** " ។ លោកពោលការជួញប្រែ ដោយអំណាចនៃពួកឈ្មួញអ្នកទៅ ដោយកម្លាំងនៃស្មង ដោយបទ ថា " **ជង្ឃវណិជ្ជា** " ។ លោកពោល

នូវការលក់ដូរ ដោយអំណាចនៃពួកឈ្មួញដែលទៅ ដោយរទេះ ដោយបទ ថា "សកដវណិជ្ជា" ។ ការលក់ចេញ ទិញចូល ដោយអំណាច នៃការជំនួញជួញប្រែ តាមផ្លូវនានាជាដើម គប្បីសង្គ្រោះ ដោយ **អាទិ** ស័ព្ទ ។ ផ្លូវនៃការជួញប្រែ ឈ្មោះថា **វណិជ្ជបថោ** ។ អធិប្បាយថា ការលក់ចេញទិញចូល គប្បីសង្គ្រោះ ដោយអំណាចនៃការឲ្យ និងការទទួលយក" ។

(២៥៣) ប៉ុន្តែ ក្នុងវាសេដ្ឋសូត្រ ក្នុងមជ្ឈិមបណ្ណាសកៈ **គោរក្ខ** ស័ព្ទ មកហើយ ក្នុងទីនៃ **កសិ** ស័ព្ទ ។ ដូចជាព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក ក្នុងវាសេដ្ឋសូត្រនោះ ថា

> "ម្នាលវាសេដ្ឋៈ អ្នកចូរដឹង យ៉ាងនេះ ថា បណ្ដាមនុស្សទាំងឡាយ មនុស្សណាមួយ រមែងអាស្រ័យនូវគោរក្ខកម្ម ចិញ្ចឹមជីវិត, មនុស្សនោះ ជាកសិករ, មិនមែនជាព្រាហ្មណ៍ឡើយ" ។

អដ្ឋកថាវាសេដ្ឋសូត្រនោះ ថា "បទ ថា '**គោរក្ខំ**' បានដល់ នូវការរក្សានូវស្រែ ។ មានពាក្យអធិប្បាយ ថា 'កសិកម្ម' ។ ព្រោះពាក្យ ថា '**គោ**' ជាឈ្មោះ នៃផែនដី, ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ យ៉ាងដូច្នោះ" ។

ដីកាវាសេដ្ឋសូត្រនោះ ថា “ កិរិយាជាគ្រឿងចោទ នូវភារៈនៃ **គោរក្ខ** សត្វ និង **កសិ** សត្វ ជាសត្វមានសេចក្ដីស្មើគ្នា រមែងជាកិរិយាដែលសម្រេចចុះដោយផ្សេងគ្នា ហេតុនោះ ព្រះអដ្ឋកថាចារ្យ ទើបពោល ថា ‘បទ ថា ‘ **គោរក្ខំ** ’ បានដល់ នូវការរក្សានូវស្រែ’ ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោល ថា ‘ព្រោះពាក្យថា ‘ **គោ** ’ ជាឈ្មោះ នៃផែនដី ” ។

ព្រោះហេតុនោះ **គោរក្ខ** សត្វ និង **កសិ** សត្វទាំង ២ មករួមគ្នាហើយ ក្នុងទីណា, ក្នុងទីនោះ **គោរក្ខ** សត្វ គប្បីជ្រាប ថាជាសត្វផ្សេង អំពី **កសិ** សត្វ, **គោរក្ខ** សត្វ ប៉ុណ្ណោះ មកហើយក្នុងទីណា, ក្នុងទីនោះ **គោរក្ខ** សត្វនោះ គប្បីជ្រាប ដោយកិរិយាធ្វើទូទៅ ។

(២៥៤) ក៏ហេតុមានការកន្លងពេលវេលាជាដើម ឈ្មោះថាភារៈនៃការងារទាំងនោះ ជាការងារច្របូកច្របល់ ។ ហេតុនោះក្នុងអដ្ឋកថា ទើបលោកពោល ថា “ការងារទាំងឡាយ ឈ្មោះថាប្រាសចាកភារៈ នៃការងារដែលច្របូកច្របល់ មានកិរិយាកន្លងនូវពេលវេលា កិរិយាធ្វើមិនសមគួរ កិរិយាមិនធ្វើ និងកិរិយាធ្វើធូរថយសើៗ ជាដើម ព្រោះភារៈនៃបុគ្គលជាអ្នកដឹង នូវពេលវេលាជាអ្នកធ្វើដោយសមគួរ ជាអ្នកមិនខ្ជិលច្រអូស និងព្រោះភារៈ

នៃការងារមិនជាទីតាំង នៃសេចក្ដីសាបសូន្យទៅ ព្រោះសេចក្ដីដល់ព្រមនៃសេចក្ដីព្យាយាម គឺសេចក្ដីប្រឹងប្រែងខ្នះខ្នែង"។ បណ្ដាហេតុទាំងឡាយមានភាពជាអ្នកដឹងពេលវេលាជាដើមនោះ អ្នកណាមិនញុំាងពេលវេលាដែលខ្លួនគប្បីធ្វើ ឲ្យវិនាសសាបសូន្យទៅហើយធ្វើនូវការងារ, អ្នកនោះ ឈ្មោះថា ជាអ្នកដឹងកាល ។ មួយទៀត បុគ្គលអ្នកធ្វើ (នូវការងារ) ឲ្យសមគួរដល់ទ្រព្យ ដែលខ្លួនគប្បីបាន ឈ្មោះថា ជាអ្នកធ្វើសមគួរ ។ ព្រោះថា បុគ្គលអ្នកប្រាកដដូច្នោះ រមែងបាននូវទ្រព្យ ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដល់អាឡវកយក្ស ទើបត្រាស់ ក្នុងយក្ខសំយុត្ត ថា

(២៥៥) "បុគ្គលអ្នកមានធុរៈ ជាអ្នកប្រឹងប្រែង ខ្នះខ្នែង ជាអ្នកធ្វើសមគួរ រមែងរកទ្រព្យបាន"។

អដ្ឋកថាយក្ខសំយុត្តនោះ ថា "ក្នុងកន្លះគាថានោះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅ÷ បុគ្គលណា មិនញុំាងឱកាសមានប្រទេស និងពេលវេលាជាដើម ឲ្យវិនាសសាបសូន្យទៅ រមែងធ្វើសមគួរ គឺឲ្យជាឧបាយនៃការបានសម្រេចទ្រព្យដែលជាលោកិយៈនិងលោកុត្តរៈ ហេតុនោះ បុគ្គលនោះឈ្មោះថាជាអ្នកធ្វើសមគួរ។ បទ ថា 'ធុរវា' បានដល់ ជាអ្នកមិនលះបង់ធុរៈចោល ដោយអំណាចនៃសេចក្ដី

ព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ។ បទ ថា " **ឧដ្ឋាតា** " មានសេចក្ដីថា ជាអ្នកដល់ព្រមដោយសេចក្ដីប្រឹងប្រែងខ្នះខ្នែង គឺជាអ្នកមានសេចក្ដីព្យាយាមមិនធូរថយ ដោយអំណាចនៃសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ដោយន័យ ថា ÷

" ក៏បុគ្គលណា មិនសម្គាល់ នូវរងា និង ក្ដៅ ក្រៃលែងជាងស្មៅ " ដូច្នេះ ជាដើម ។

២ បទ ថា ' **វិន្ទតេ ធនំ** ' មានសេចក្ដីថា បុគ្គលនោះរមែងបាននូវទ្រព្យជាលោកិយៈ ដូចជាកូនឈ្មួល របស់ចូឡកសេដ្ឋី បានទ្រព្យរាប់បាន ៤ សែន ក្នុងរយៈវេលាមិនយូរប៉ុន្មាន ព្រោះសត្វកណ្ដុរមួយ និងរមែងបាននូវទ្រព្យដែលជាលោកុត្តរៈ ដូចជា ដូចជាព្រះមហាល្លកមហាតិស្សត្ថេរ ដូច្នោះ " ។

(២៥៦) ដីកាយក្ខសំយុត្តនោះថា " ក្នុងពាក្យជាអាទិ៍ ថា ' **ទេសកាលាទីនិ អហាបេត្វា** ' គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ក្នុងប្រទេសណា ក្នុងកាលណា បុគ្គលអាស្រ័យនូវជនដែលមានវ័យស្មើគ្នាជាដើម ហើយគប្បីពិចារណា នូវកិច្ចរបស់ខ្លួន, បុគ្គលអ្នកប្រាថ្នាសេចក្ដីចំរើនដល់ខ្លួន មិនកន្លងនូវប្រទេសនិងកាលជាដើមនោះ ហើយពិចារណា នូវកិច្ចរបស់ខ្លួនទាំងអស់ ថា ' ក្នុងពេល

ឥឡូវនេះ អាត្មាអញរស់នៅក្នុងប្រទេសណា, ប្រទេសនោះឈ្មោះថាយ៉ាងនេះ, កាលឈ្មោះថាយ៉ាងនេះ, ជនទាំងឡាយនេះ ត្រូវជាមិត្ររបស់អាត្មាអញ, ជនទាំងនេះត្រូវជាសំឡាញ់ របស់អាត្មាអញ, និងអាត្មាអញ ជាអ្នកប្រាកដដូច្នេះ ដោយជាតិ ត្រកូល ប្រទេស កម្លាំង ភោគៈ និងបរិវារជាដើម, ឥឡូវនេះ អាត្មាអញគប្បីចាប់ផ្តើមកិច្ចការរបស់ខ្លួន, ឥឡូវនេះ អាត្មាអញ មិនគប្បីចាប់ផ្តើមកិច្ចការរបស់ខ្លួនទេ ’ ដូច្នេះ ហើយគប្បីប្រតិបត្តិការ ។ ព្រោះថាបុគ្គលកាលប្រតិបត្តិ ដូច្នោះ ឈ្មោះថា រមែងធ្វើដោយសមគួរ គឺឲ្យជាឧបាយ ដល់កិរិយាបានសម្រេចនូវទ្រព្យ ដែលជាលោកិយៈ ។ ចំណែក ឧបាយដែលជាគ្រឿងបានសម្រេច នូវទ្រព្យជាលោកុត្តរៈ គប្បីជ្រាប ដោយអំណាចហេតុមានកិរិយាជម្រះនូវសីលជាដើម ។ ដែលឈ្មោះថា ធុរៈ ព្រោះប្រៀបដូចជានឹម ដោយភារៈជារបស់ដែលបុគ្គលគប្បីនាំទៅ បានដល់ **ភារៈ** ។ ក៏ប៉ុន្តែ ក្នុងបទ ថា ‘ **ធុរវា** ’ នេះ សេចក្តីព្យាយាម ឈ្មោះថា ធុរៈ ព្រោះជាគ្រឿងលើកស្ទួយនូវធុរៈនោះ របស់បុគ្គលអ្នកកំពុងទទួលធុរៈ ។ ធុរៈដ៏ល្អក្រៃលែងនោះ រមែងមាន ដល់បុគ្គលនុ៎ះ ហេតុនោះ បុគ្គលនោះឈ្មោះថា មានធុរៈ ។ ព្រះអដ្ឋកថាចារ្យ ពោលឲ្យប្លែកផ្សេងគ្នា ថា ‘ ដោយអំណាចសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវចិត្ត ’

ព្រោះភាវៈនៃសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ដោយបទ ថា 'ឧដ្ឋាតា' ។ បុគ្គលឈ្មោះថា ជាអ្នកមានធុរៈមិនទម្លាក់ចោល ព្រោះភាវៈជាអ្នកកាន់យកធុរៈ ។ ឈ្មោះថា ជាអ្នកមានសេចក្ដីប្រឹងប្រែងខ្នះខ្នែង មិនធូរថយ ព្រោះភាវៈជាអ្នកមិនខ្ជិលច្រអូស ។ បទ ថា 'ន ចិរស្សេវ' បានដល់ ក្នុងរវាង ៤ ខែតែប៉ុណ្ណោះ ។ បទ ថា 'ចតុស្សតសហស្សសង្ខ្យំ' មានសេចក្ដីថា ខ្ញុំបម្រើរបស់ចូឡកសេដ្ឋី រមែងបានទ្រព្យរាប់បាន ៤ សែន ដោយដើមទុន គឺសត្វកណ្ដុរ ១ ដោយការរាប់យ៉ាងនុ៎ះគឺ ÷ ២ សែន ដោយលំដាប់នៃការបូក (តាំងពី) ១ កាកណិក, ៨ កហាបណៈ, ១៦ កហាបណៈ, ២៤ កហាបណៈ, និង ១ ពាន់ កហាបណៈ, ២ សែនទៀត ដោយអំណាចបានធីតារបស់ចូឡកមហាសេដ្ឋី យ៉ាងណាមិញ, សូម្បីបុគ្គលដទៃទៀតជាអ្នកធ្វើសមគួរ មានធុរៈ ជាអ្នកប្រឹងប្រែងខ្នះខ្នែង រមែងរកទ្រព្យបាន ក៏ដូច្នោះដែរ" ។

ក្នុងសេចក្ដីនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងចូឡកសេដ្ឋី )

(២៥៧) ក្នុងអតីតកាល ព្រះពោធិសត្វជាសេដ្ឋី ឈ្មោះថា

ចូឡកៈ ក្នុងទីក្រុងពារាណសី បានចេះដឹងនូវនិមិត្តគ្រប់យ៉ាង ។ ថ្ងៃមួយ ចូឡកសេដ្ឋីនោះ កាលទៅកាន់រាជសំណាក់ បានឃើញសត្វកណ្ដុរស្លាប់ ក្នុងចន្លោះផ្លូវ ត្រូតឃើញនូវនក្ខត្តឫក្ស ក្នុងខណៈនោះ ហើយពោល ថា "កុលបុត្រអ្នកមានចក្ខុ រើសយកសត្វកណ្ដុរនេះហើយ អាចដើម្បីនឹងធ្វើការចិញ្ចឹមភរិយា និង ប្រកបការងារទាំងឡាយបាន" ។ បុរសទីទល់ក្រម្នាក់ ជាអ្នកបម្រើ របស់សេដ្ឋីនោះ បានឮពាក្យនោះហើយ ទើបរើសយកសត្វកណ្ដុរ ទៅចំណាយក្នុងទីផ្សារ ដើម្បីប្រយោជន៍ដល់សត្វឆ្មា ក៏បានទ្រព្យ ១ កាកណិកហើយ យកទ្រព្យ ១ កាកណិកនោះ ទៅទិញទឹកអំពៅ បាននាំយកនូវពាងទឹកផឹកទៅហើយ ក៏បានឲ្យទឹកអំពៅ និង ទឹកសម្រាប់ផឹកដល់ពួកនាយមាលាការ ដែលកំពុងដើរចេញមកអំពីព្រៃ ។ ពួកនាយមាលាការទាំងនោះ ក៏បានឲ្យផ្កា ១ បាច់ម្នាក់ៗ ដល់បុរសនោះ ។ បុរសនោះ យកដើមទុន គឺផ្កា ទៅទិញទឹកអំពៅហើយ បាននាំយកនូវពាងទឹក ទៅហើយកាន់សួនផ្កានុ៎ះឯង ក្នុងថ្ងៃព្រឹកឡើង ។ ក្នុងថ្ងៃនោះ ពួកនាយមាលាការ បានឲ្យហើយ នូវគុម្ពបាច់ផ្កាទាំងឡាយដែលបានជ្រើសហើយពាក់កណ្ដាល ដល់បុរសនោះ ។ បុរសនោះ បានហើយនូវទ្រព្យ ៨ កហាបណៈ ដោយឧបាយនេះ ក្នុងពេលមិនយូរប៉ុន្មាននុ៎ះឯង ។ ក្នុងថ្ងៃដែលមានខ្យល់និងភ្លៀង មួយថ្ងៃ

មកទៀត ឈើស្ងួត មែកឈើ និងសន្លឹកឈើចាស់ ជាច្រើន ក្នុងព្រះរាជឧទ្យាន ជ្រុះធ្លាក់ហើយ ព្រោះខ្យល់ ។ បុគ្គលអ្នកថែរក្សាឧទ្យាន មិនអាចដើម្បីនឹងយកទៅចោលបាន ។ បុរសកំសត់នោះទៅក្នុងទីនោះ ហើយពោល ថា "បើអ្នកនឹងឲ្យ នូវឧសនិងស្លឹកឈើទាំងនេះ ដល់ខ្ញុំ, ខ្ញុំនឹងនាំយកចេញទៅ" ។ បុគ្គលអ្នកថែរក្សាឧទ្យាន បានឲ្យហើយ ដល់បុរសនោះ ។ បុរសនោះទៅកាន់កន្លែងលេង របស់ពួកកូនក្មេង បានឲ្យទឹកអំពៅ (ក្មេងៗ ផឹក) ហើយក៏ឲ្យក្មេង ៗ ជួយយកឈើទាំងនោះចេញ មួយរំពេច ហើយឲ្យធ្វើជាគំនរត្រង់មាត់ទ្វារឧទ្យាន ។ ពេលនោះ ជាងធ្វើឆ្នាំងនៃព្រះរាជាឲ្យទ្រព្យ ១៦ កហាបណៈនិងភាជនៈ មានពាងជាដើម ដល់បុរសនោះ ហើយនាំយកឧសទាំងនោះទៅ ដើម្បីប្រយោជន៍ ដល់ការដុតនូវភាជនៈដីទាំងឡាយ ។ ទ្រព្យ ២៤ កហាបណៈ កើតមានហើយដល់បុរសនោះ ដោយប្រការដូច្នេះឯង, បុរសនោះ ដាក់ពាងទឹកសម្រាប់ផឹក ក្បែរទ្វារព្រះនគរ ហើយទំនុកបំរុង នូវបុរសអ្នករែកស្មៅ ៥០០ នាក់ ដោយទឹកសម្រាប់ផឹក ។ ពួកអ្នករែកស្មៅទាំងនោះ ពោល ថា "ម្នាលសំឡាញ់ ! អ្នកមានឧបការៈជាច្រើន ដល់ពួកខ្ញុំ, ពួកខ្ញុំ នឹងធ្វើអ្វី ដល់អ្នក ?" ។ បុរសនោះ ពោល ថា "អ្នកទាំងឡាយ នឹងជួយធ្វើ កាលបើកិច្ចការ របស់ខ្ញុំ កើតឡើង"

ដូច្នេះហើយ ពិចារណាមើលខាងនេះផង ខាងនុ៎ះផង បានធ្វើការស្និទ្ធស្នាលដូចជាមិត្រ ជាមួយនឹងពួកពាណិជទាំងផ្លូវទឹក ផ្លូវគោក ។

គ្រានោះ នាយពាណិជអ្នកប្រកបការងារ ខាងផ្លូវគោកម្នាក់ ប្រាប់ ថា " ក្នុងថ្ងៃស្អែកនេះ ឈ្មួញអ្នកលក់សេះ នឹងនាំសេះ ៥០០ ក្បាល មក " ។ បុរសនោះ បានឮពាក្យនោះហើយ ក៏បានប្រាប់ពួកអ្នករែកស្មៅ ថា " ក្នុងថ្ងៃនេះ អ្នកទាំងឡាយ ចូរឲ្យបាច់ស្មៅ ដល់ខ្ញុំ ម្នាក់មួយបាច់ៗ, មួយទៀត បើខ្ញុំមិនទាន់បានលក់ស្មៅទេ, សូមអ្នកទាំងឡាយ កុំទាន់លក់ស្មៅរបស់ខ្លួនឡើយ " ។ ពួកអ្នករែកស្មៅទាំងនោះ ពោល ថា "ប្រពៃណាស់" ដូច្នេះហើយ ក៏ទម្លាក់បាច់ស្មៅ ៥០០ បាច់ ក្បែរផ្ទះ របស់បុរសកំសត់នោះ ។ ឈ្មួញលក់សេះ មិនបានហើយនូវស្មៅ ក្នុងទីដទៃ ក៏ឲ្យទ្រព្យ ១០០០ ដល់បុរសនោះ ហើយនាំយកស្មៅទៅ ។ តាំងតែពីពេលនោះមក ដោយកន្លងហួសទៅ ២-៣ ថ្ងៃ នាយពាណិជអ្នកប្រកបការងារខាងផ្លូវទឹក ប្រាប់ ដល់បុរសនោះ ថា " នាវា បានមកចត នៅកំពង់ផែហើយ " ។ បុរសកំសត់នោះ បានជួលរថ ជួលព្រមទាំងបរិវារទាំងអស់ ដោយទ្រព្យ ៨ កហាបណៈ ដើរទៅកាន់កំពង់ផែ ដោយយសស័ក្តិដ៏ធំ បានឲ្យចិញ្ចៀនមួយវង់ ជាខសន្យាគ្នា ដល់អ្នកទូក ហើយអង្គុយ ខាងក្នុងសាលា ។

ក្នុងដីកាឯកនិបាត អង្គុត្តរនិកាយ លោកពោល ថា "បទ ថា 'សច្ចការំ' បានដល់ ការធ្វើឲ្យជាកិរិយានាំមក នូវភាពជាសច្ចៈ គឺថ្លៃឈ្នួលដែលគេពោល ថា 'បើខ្លួនទទួលយកភណ្ឌៈហើយ, មិនគួរលក់ឲ្យ ដល់ពួកជនដទៃទៀតឡើយ' ដូច្នេះហើយ គប្បីឲ្យ" ។

គ្រានោះ ពួកឈ្មួញប្រមាណ ១០០ នាក់ មកហើយ បានឲ្យទ្រព្យ ១ សែន ដល់បុរសនោះ គឺ បានឲ្យម្នាក់ ១ ពាន់ៗ ជាអ្នកធ្វើដំណើរ តាមនាវា ជាមួយនឹងបុរសនោះ បានឲ្យទ្រព្យ ១ សែន ទៀត ដល់បុរសនោះ ហើយបានទទួលយកភណ្ឌៈក្នុងទូក ទាំងអស់ ។ បុរសនោះ ទទួលយកទ្រព្យ ២ សែន ហើយបានឲ្យទ្រព្យ ១ សែន ដល់ចូឡកសេដ្ឋី ដោយគិត ថា "អាត្មាអញ គួរជាអ្នកមានកតញ្ញូ" ហើយ ប្រាប់រឿងរ៉ាវទាំងអស់នោះ ។ សេដ្ឋី គិត ថា "ឥឡូវនេះ ការដែលអាត្មាអញ ឲ្យក្មេងប្រាកដដូច្នេះ ធ្វើការស៊ីឈ្នួល មិនសមគួរសោះឡើយ" ដូច្នេះហើយ ក៏បានលើកកូនស្រី របស់ខ្លួនឲ្យ ដល់បុរសកំសត់នោះ ។ បុរសកំសត់នោះ បានទទួលតំណែងជាសេដ្ឋី ដោយកាលកន្លងទៅ នៃសេដ្ឋី ។ បុគ្គលអ្នកប្រឹងប្រែងខ្នះខ្នែង ធ្វើសមគួរ រមែងបាន នូវទ្រព្យជាលោកិយៈ ដោយប្រការដូច្នេះ ។

រឿងអ្នកបម្រើរបស់ចូឡកសេដ្ឋី មកក្នុងអដ្ឋកថាចូឡកសេដ្ឋី-ជាតក ក្នុងបឋមវគ្គ ឯកនិបាត ក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ

និង ក្នុងអដ្ឋកថាអប្បមាទវគ្គ ។

## ( រឿងព្រះមហាតិស្សត្ថេរ )

(២៥៨) បានឮមកថា ព្រះមហល្លកមហាតិស្សត្ថេរ បានធ្វើវត្តប្រតិបត្តិ ថា "អាត្មាអញ នឹងនៅ ដោយឥរិយាបថ ៣" ដូច្នេះហើយ ក្នុងពេលដែលថីនមិទ្ធៈគ្របសង្កត់ ជ្រលក់ទ្រនួលចំបើង ឲ្យទទឹក ហើយដាក់លើសិរសី ចូលត្រាំទឹកប្រមាណត្រឹមក កាលហាមឃាត់នូវថីនមិទ្ធៈ ក៏បានសម្រេចព្រះអរហត្ត ដោយ ១២ ឆ្នាំ ។

រឿងនេះ មកក្នុងអដ្ឋកថាអាឡវកសូត្រ ។

(២៥៩) មួយទៀត បុគ្គលណា ដេកលក់រហូតពេញមួយថ្ងៃ មិនធ្វើនូវការងារទាំងឡាយ, សូម្បីក្នុងរាត្រី ក៏មិនក្រោកធ្វើការងារទាំងនោះដែរ, ជាអ្នកស្រវឹងសុរា ជាប់ជានិច្ច និងជាអ្នកលេងក្នុងស្ត្រីជាដើម, បុគ្គលនោះ រមែងធ្វើការងារទាំងឡាយឲ្យច្របូកច្របល់ ព្រោះភាពនៃខ្លួនជាអ្នកខ្ជិលច្រអូស ។ មែនពិតកិរិយាមិនធ្វើការងារទាំងឡាយនុ៎ះឯង ឈ្មោះថា ភារៈនៃការងារទាំងឡាយនោះ ច្របូកច្របល់ ។ ក៏បុគ្គលប្រាកដដូច្នោះ រមែងមិនអាច ដើម្បីញ៉ាំងការគ្រប់គ្រងផ្ទះសម្បែង ឲ្យតាំងនៅបានឡើយ ។

ហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ក្នុងសិគាលសូត្រ ថា

"បុគ្គលដេក ក្នុងវេលាថ្ងៃ ជាប្រក្រតី មិនក្រោក ឡើងពីយប់ ជាប្រក្រតី ជាអ្នកស្រវឹង ជានិច្ច ជាអ្នក លេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះ បានឡើយ"។

(២៦០) អដ្ឋកថាសិគាលសូត្រនោះ ថា "បណ្ដាបទទាំងនោះ បទ ថា 'រត្តិំ ឧដ្ឋានទេស្សិនា' បានដល់ ជាអ្នកមិនក្រោកឡើង ក្នុងពេលយប់ ជាប្រក្រតី" ។

ដីកាសិគាលសូត្រនោះ ថា "កាលបើព្រះអាទិត្យ មិនទាន់ រះឡើងនុ៎ះឯង, ក៏មិនប្រារព្ធ ធ្វើការងារទាំងឡាយ ក្នុងវេលាយប់ ក៏មិនក្រោកឡើង ជាប្រក្រតី" ។

២ បទ ថា "និច្ចំ មត្តេន" បានដល់ ជាអ្នកស្រវឹងហើយ ដោយទឹកស្រវឹង គឺ សុរា អស់កាលជានិច្ច ។ បទ ថា 'សោណ្ឌេន' បានដល់ ជាអ្នកលេង ក្នុងស្ត្រីជាដើម ។ មែនពិត ព្រះអដ្ឋកថា- ចារ្យ ពោលហើយ ក្នុងអធិការនៃចុណ្ណិយបទ យ៉ាងនេះ ថា "បទ ថា 'សោណ្ឌា' បានដល់ ជាអ្នកលេងស្រី អ្នកលេងភត្ត អ្នកលេងនំ អ្នកលេងមើមឈើ ។ បទ ថា 'បិបាសា' បានដល់ អ្នកលេង ស៊ីផឹក ។ ព្រោះហេតុនោះ ក្នុងទីនេះ ទើបមិនបានពោលពាក្យអ្វីៗ ទុកឡើយ ។

ដីកាចុណ្ណិយបទនោះ ថា “បទ ថា ‘ឥត្ថីសោណ្ឌា’ មានសេចក្តីថា ជាអ្នកលេង ក្នុងស្រីទាំងឡាយ គឺ ជាអ្នកក្តៅក្រហាយ មានការគប់រកនូវស្ត្រីជានិមិត្ត ។ អ្នកលេងភ័ត្តជាដើម គប្បីជ្រាប យ៉ាងដូច្នោះដែរ ។ បទ ថា ‘បិបាសា’ បានដល់ ជាអ្នកស្រេកឃ្លាន ក្នុងការផឹកសុរា ខ្លាំងឡើងៗ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោល ថា ‘ជាអ្នកលេងផឹក” ។

(២៦១) ព្រោះហេតុនោះ គ្រហស្ថអ្នកនៅគ្រប់គ្រងផ្ទះ មិនគួរជាអ្នកត្រេកអរក្នុងការដេកលក់និងជាអ្នកលេងល្បែងឡើយ” ។ ព្រោះថា បុគ្គលប្រាកដដូច្នោះ រមែងជួបប្រទះ នូវសេចក្តីទុក្ខ ។

ក្នុងសេចក្តីនោះ មានរឿងទាំងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងមាណពអ្នកខ្ជិលច្រអូស )

ក្នុងអតីតកាល អន្តេវាសិក របស់អាចារ្យទិសាបាមោក្ខ ម្នាក់ ក្នុងទីក្រុងតក្កសីលា ជាអ្នកខ្ជិលច្រអូស ជាអ្នកចូលចិត្តដេកលក់ ។ ថ្ងៃមួយ មាណពនោះ ទៅកាន់ព្រៃ ដើម្បីប្រយោជន៍ដល់ឧសទាំងឡាយ ជាមួយនឹងពួកមាណពដទៃៗទៀត ឃើញដើមថ្ងាន់ យ៉ាងធំសម្គាល់ ថា “ដើមឈើនុ៎ះ ជាឈើងាប់” ដូច្នេះហើយ ទើបគិត ថា “អាត្មាអញ នឹងដេកលក់ មួយស្របក់សិន ចាំកាន់យក ជាខាង

ក្រោយ” ដូច្នេះហើយ ដេកស្រមុក ចុះកាន់ការដេកលក់ហើយ ។ មាណពទាំងឡាយ ក្រៅពីនេះ កាលយកឧសដើរទៅ ក៏បានយកជើងទាត់ មាណពនោះ ត្រង់ខ្នង បានទៅហើយ ។ មាណពនោះក្រោកឡើង ឃើភ្នែកទាំងសងខាងហើយ មិនទាន់អស់ងងុយផងក៏ឡើងដើមថ្នាន់ បានទាញនូវមែកឈើ ដែលនៅចំពោះមុខរបស់ខ្លួន មកកាច់ ញាំងចុងនៃមែកឈើ ដែលកាច់ហើយ តាំងឡើងឲ្យប្រចំភ្នែកទាំងសងខាង យកដៃមួយបិទភ្នែកទាំងទ្វេនោះ ដៃមួយទៀត កំពៀកនូវឧសស្រស់ ចុះអំពីដើមឈើ បានដើរទៅកាន់ផ្ទះហើយ យ៉ាងប្រញាប់ប្រញាល់ ។

រឿង មាណពអ្នកខ្ជិលច្រអូស មកក្នុងអដ្ឋកថាវរុណជាតក
ក្នុងអដ្ឋមវគ្គ ឯកនិបាត ។

## ( រឿងអ្នកលេងសុរា )

(២៦២) ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី មាណពម្នាក់ ជាបុត្រ របស់ត្រកូលព្រាហ្មណ៍អ្នករក្សាសីល ៥ បានដើរលេងជាប្រក្រតី ជាមួយនឹងអ្នកលេងក្មេងៗ ដែលមានវ័យស្មើៗគ្នា ។ មាណពនោះ, កាលបើពួកអ្នកលេងទាំងនោះ ផឹកសុរា, ខ្លួនឯងមិនផឹកឡើយ ។ ពួកអ្នកលេងទាំងឡាយ គិតគ្នា ថា “មាណពនេះ

កាលមិនផឹកនូវសុរា នឹងមិនឲ្យថ្លៃសុរា ដល់ពួកយើង" ដូច្នេះហើយ ប្រាថ្នានឹងញ៉ាំងមាណពនោះ ឲ្យផឹកសុរា ដោយឧបាយ ក្នុងថ្ងៃដែលមានមហោស្រព បានខ្ចប់សុរា យ៉ាងខ្លាំង ក្នុងស្លឹកឈូកទាំងឡាយ ក្នុងឧទ្យាន ពេលផឹក ក៏បានឲ្យថែមទឹកដោះស្រស់ ដល់មាណព ហើយបានឲ្យបុរសទាំងឡាយ នាំយកមក ដោយប្រាប់ថា "អ្នកទាំងឡាយ ចូរនាំទឹកស្លឹកឈូកផ្អែមមក" ហើយធ្វើកញ្ចប់ស្លឹកឈូក ឲ្យជាប្រហោងខាងក្រោម ដាក់ហើយ ក្នុងមាត់ ៗ មាណពសុំសុរានោះ ដោយសម្គាល់ថា ជាទឹកស្លឹកឈូកផ្អែម ផឹកនិងស៊ីសាច់ បានជាអ្នកស្រវឹងហើយ ៗ មាណពទាំងឡាយ ប្រាប់ថា "ទឹកនុ៎ះ មិនមែនជាទឹកស្លឹកឈូកផ្អែមទេ, នុ៎ះ គឺជាសុរា" ៗ មាណពនោះពោលថា "អាត្មាអញ មិនដឹងរសជាត (នៃសុរា) ដែលផ្អែម អស់កាលប្រមាណប៉ុណ្ណោះ, ម្នាលអ្នកដ៏ចំរើនទាំងឡាយ ចូរពួកអ្នកនាំយកសុរាមក" ៗ ពួកមាណព បានឲ្យហើយ ជាថ្មីម្តងទៀត ៗ សេចក្តីស្រេកឃ្លាន បានកើតមានហើយ យ៉ាងខ្លាំងក្លា ៗ គ្រានោះកាលបើមាណពនោះ សុំហើយសុំទៀតញយៗ, ពួកមាណពទាំងនោះ ក៏បានប្រាប់ថា "សុរាអស់រលីងហើយ" ៗ មាណពនោះបានឲ្យចិញ្ចៀន ដល់អ្នកលេងសុរាទាំងនោះ ហើយផឹកសុរា ដែលពួកអ្នកលេងទាំងនោះ នាំយកមក រួមជាមួយគ្នានឹងពួកគេ ស្រវឹងហើយ

ទៅកាន់ផ្ទះ បានដេកលក់ហើយ ។ បិតាសូម្បីហាមប្រាម កូននោះញយ ៗ ក៏មិនអាចនឹងហាមឃាត់បាន ដល់ការកាត់កាល់ចោល ធ្វើកូននោះ មិនឲ្យជាកូន ហើយក៏បណ្តេញចេញ ។ សូម្បីកាលបើដូច្នេះ ក៏ដោយ, កូននោះ ក៏មិនឈប់ អំពីការផឹកសុរា មិនធ្វើហើយនូវការងារទាំងឡាយ ក្រោយមក មានដៃកាន់ត្រឡោក ដើរទៅសុំទានគេ អាស្រ័យជញ្ជាំងផ្ទះអ្នកដទៃ បានធ្វើកាលៈហើយ ។

រឿង អ្នកលេងសុរា មកក្នុងអដ្ឋកថាមហាសុតសោមជាតក ។

(២៦៣) មួយទៀត បុគ្គលណា សំដែងអាងនូវហេតុមានត្រជាក់ពេកជាដើម តែងមិនធ្វើការងារទាំងឡាយ ។ សំដែងអាងដូចម្តេច ? ។ បើមនុស្សទាំងឡាយ ក្រោកឡើងហើយ អំពីព្រឹកព្រលឹម ហើយពោល ថា " ម្នាលអ្នកដ៏ចំរើនទាំងឡាយ អ្នកទាំងឡាយ ចូរមក, ពួកយើង នឹងទៅ (ធ្វើ) ការងារ" ដូច្នេះហើយ, អ្នកនោះ ពោលអាង ថា "ត្រជាក់ខ្លាំងណាស់ ឆ្អឹងទាំងឡាយ នឹងបាក់អស់, អ្នកទាំងឡាយ ទៅចុះ, ខ្ញុំនឹងដឹង ជាខាងក្រោយ" ហើយអង្គុយអាំងភ្លើង មិនទៅដើម្បីធ្វើការងារ ។ ន័យ សូម្បីក្នុងហេតុទាំងឡាយ មានអាងថាក្តៅពេកជាដើម ក៏ន័យនេះដែរ ។ បុគ្គលនោះ ឈ្មោះថា រមែងធ្វើការងារទាំងឡាយ ឲ្យច្របូកច្របល់ ព្រោះភាវៈ នៃខ្លួនជាអ្នកខ្ជិលច្រអូស ។ មែនពិត បុគ្គលប្រាកដ

ដូច្នោះ រមែងវិនាសសាបសូន្យ អំពីភោគៈ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ត្រាស់ ថា "បុគ្គលណា មិនធ្វើការងារ ដោយសំដែងអាង ថា "ត្រជាក់ពេក... ក្តៅពេក... ល្ងាចពេក... ព្រឹកពេក... ឃ្លានពេក"... មិនធ្វើការងារ ដោយសំដែងអាង ថា "ស្រេកពេក" ដូច្នេះ, កាលបើបុគ្គលអ្នកខ្ជិលច្រអូសនោះ ច្រើនទៅដោយការសំដែងអាងកិច្ច យ៉ាងដូច្នេះ ស្ថិតនៅ, ភោគៈទាំងឡាយ ដែលមិនទាន់កើតឡើងហើយ រមែងមិនកើតឡើង និង ភោគៈទាំងឡាយ ដែលកើតឡើងហើយ រមែងដល់ នូវការអស់ទៅ" ។ មែនពិត ទ្រព្យទាំងឡាយ រមែងកន្លងហួស នូវបុគ្គលបែបនោះ ។

ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ÷

(២៦៤) " ប្រយោជន៍ទាំងឡាយ រមែងកន្លងហួស នូវមាណព ដែលលះបង់ចោល នូវការងារ ដោយពោលអាងថា 'វេលានេះ ត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ " ។

អដ្ឋកថាសិគាលសូត្រនោះ ថា "បណ្តាបទទាំងនោះ បាទគាថា ថា 'អតិសាយមិទំ អហុ' មានសេចក្តីថា បុគ្គលទាំងឡាយណា ពោលអាង យ៉ាងនេះ ថា 'វេលានេះ ជាវេលាល្ងាចណាស់ហើយ'

ដូច្នេះ ជាដើម ហើយមិនធ្វើនូវការងារ ។ បាទគាថា ថា 'ឥតិ វិស្សជ្ជកម្មន្តេ' បានដល់ អ្នកពោល យ៉ាងនោះហើយ លះបង់ការងារចោល ។ បាទគាថា ថា 'អត្ថា អច្ចេន្តិ មាណវេ' មានសេចក្ដីថា ប្រយោជន៍ទាំងឡាយ រមែងកន្លងហួស នូវបុគ្គលទាំងឡាយនេះ គឺ រមែងមិនតាំងនៅ ក្នុងបុគ្គលទាំងឡាយនោះ" ។

ដីកាសិគាលសូត្រនោះ ថា " ទ្រព្យទាំងឡាយ ឈ្មោះថា ប្រយោជន៍ ។ បទ ថា 'អតិក្កមន្តិ' បានដល់ រមែងទៅប្រាស ។ មួយទៀត ។ កិច្ចទាំងឡាយ ឈ្មោះថា ប្រយោជន៍ ។ បទ ថា 'អតិក្កមន្តិ' បានដល់ ជាកិច្ចមានកាលកន្លងទៅហើយ ។ សូម្បីការកន្លងហួស នូវកិច្ចទាំងឡាយនោះ ដោយសេចក្ដី ក៏គឺកិរិយាកន្លងហួសទៅ នៃទ្រព្យទាំងឡាយនុ៎ះឯង" ។

(២៦៥)ម្យ៉ាងទៀត បុគ្គលណា មិនគិតដល់ហេតុមានក្ដៅជាដើម រមែងមិនធ្វើ នូវការងារទាំងឡាយ ឲ្យច្របូកច្របល់ព្រោះភាវៈនៃខ្លួនជាអ្នកមិនខ្ជិលច្រអូស, បុគ្គលនោះ ញុំាងទ្រព្យដ៏ច្រើន ឲ្យកើតឡើងហើយ រមែងបាន នូវសេចក្ដីសុខ ។

ក៏ក្នុងរឿងនេះ មានព្រះរាជាទ្រង់ព្រះនាមថា អឡមាសកៈ ជាដើម ជាឧទាហរណ៍ ។

(២៦៦) ក្នុងអតីតកាល បានមានបុរសធ្វើការឈ្នួល ម្នាក់

នៅក្បែរទ្វារនៃទិសឧត្តរ នៃទីក្រុងពារាណសី ។ បុរសអ្នកធ្វើការឈ្នួលនោះ កប់ទ្រព្យកន្លះមាសក ដែលខ្លួនធ្វើការឈ្នួលដងទឹកបានមកហើយ ក្នុងចន្លោះឥដ្ឋនៃកំពែង ធ្វើការងារស៊ីឈ្នួល ដល់ទ្វារនៃទិសទក្សិណហើយ សម្រេចការនៅរួម ជាមួយនឹងស្ត្រីកំព្រា ដែលធ្វើការស៊ីឈ្នួលរែកទឹកហើយ រស់នៅក្នុងទីនោះដូចគ្នាដែរ ។ សូម្បីស្ត្រីកំព្រានោះ ក៏បានទ្រព្យកន្លះមាសកដូចគ្នាដែរ ។ គ្រានោះក្នុងថ្ងៃមានមហោស្រពថ្ងៃមួយ នាងពោលនឹងស្វាមី ថា “អ្នកបង មហោស្រព លេងក្នុងនគរ, បើទ្រព្យណាមួយមាន, ពួកយើងសោត ក៏គប្បីលេង” ។ ស្វាមីនោះ ពោល ថា “បងមានទ្រព្យកន្លះមាសក, ទ្រព្យនោះ បងដាក់ទុក ក្នុងចន្លោះឥដ្ឋ ក្បែរទ្វារនៃទិសឧត្តរ, កន្លែងកប់ទ្រព្យ របស់បង នៅក្នុងទីបំផុត ១២ យោជន៍ អំពីទីនេះទៅ, ក៏ទ្រព្យតិចតួច ក្នុងដៃរបស់អូន មានខ្លះដែរឬទេ ?” ។ ភរិយានោះ ពោល ថា “អ្នកបង អូនមានទ្រព្យកន្លះមាសក” ដូច្នេះហើយ ពោល ថា “ទ្រព្យរបស់បង មានកន្លះមាសក, ទ្រព្យអូនមានកន្លះមាសក បូករួមទៅ ត្រូវជាមួយមាសក, ពួកយើង នឹងទិញយក នូវផ្កាភ្ញី ដោយទ្រព្យមួយចំណែក នូវគ្រឿងក្រអូប ដោយទ្រព្យមួយចំណែក នូវសុរា ដោយទ្រព្យមួយចំណែក អំពីទ្រព្យមួយមាសកនោះ ហើយចាំលេង, សូមអ្នកបងអញ្ជើញទៅ

យកទ្រព្យដែលបងមានមកចុះ" ។ ស្វាមីនោះ ត្រេកអររីករាយហើយ ច្រៀងបណ្ដើរ គេចចេញទៅហើយ ។ ក៏បុរសនោះ មានកម្លាំងដូចជាដំរី ឆ្លងផ្លូវ ៦ យោជន៍ ដើរជាន់ដីខ្សាច់ដ៏ក្ដៅ ដូចគេក្រាលដោយរងើកភ្លើងដែលគ្មានផេះ ក្នុងវេលាថ្ងៃត្រង់ជាក់ ទៅដល់ទីព្រះលាននៃព្រះរាជាហើយ ។

ក្នុងកាលនោះ ព្រះរាជាក្រុងពារាណសី ទ្រង់ព្រះនាមឧទ័យ ទ្រង់គង់នៅ ក្បែរព្រះបញ្ជរ (បង្អួច) ទ្រង់ទតព្រះនេត្រឃើញបុរសនោះ កំពុងដើរទៅ យ៉ាងដូច្នោះ ទើបទ្រង់ព្រះតម្រិះ ថា "តើដូចម្ដេចហ្ន៎ ? បុរសនុ៎ះ មិនគិតដល់ថ្ងៃក្ដៅ យ៉ាងនេះ ត្រេកអររីករាយសប្បាយ ដើរច្រៀងបណ្ដើរ, អាត្មាអញនឹងសួរបុរសនោះលមើល" ដូច្នេះហើយ ទ្រង់ត្រាស់បញ្ជាឱ្យរាជបុរសទៅហៅនូវបុរសនោះមកហើយ ទ្រង់ត្រាស់សួរ ។ បុរសនោះ ក្រាបទូលនូវរឿងរ៉ាវទាំងអស់ហើយ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេពសេចក្ដីក្ដៅរោលរាលព្រោះកាម រមែងដុតកំដៅ នូវទូលព្រះបង្គំដែលនឹករឭក ដល់ពាក្យរបស់ភរិយា, កំដៅដែលអាស្រ័យនូវព្រះអាទិត្យ រមែងដុតរោល នូវទូលព្រះបង្គំ ពុំបានឡើយ" ។

ព្រះរាជា. ព្រោះហេតុអ្វី ? បានជាអ្នកមិនគិតដល់កំដៅថ្ងៃត្រេកអរហើយ ស្រែកច្រៀងលេង" ។

បុរស. បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ គិត ថា "អាត្មាអញ នឹងទៅនាំយកទ្រព្យដែលកប់ទុកនោះមក ហើយអភិរម្យ ជាមួយនឹង ភរិយានោះ" ដូច្នេះ ដោយហេតុនេះ បានជាទូលព្រះបង្គំ ត្រេកអរ រីករាយ ស្រែកច្រៀងលេង ៗ

ព្រះរាជា. កំណប់ទ្រព្យរបស់អ្នក មានតម្លៃដល់ទៅ មួយ សែនឬ ? ៗ បុរស. បពិត្រព្រះសម្មតិទេព មិនមានទេ ៗ ព្រះរាជា ទ្រង់បញ្ចុះមក ដោយលំដាប់ ហើយទ្រង់ត្រាស់សួរ ថា "ទ្រព្យរបស់អ្នក មាន ១ មាសកឬ ?" ៗ បុរសនោះ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព មិនមានទេ" ៗ ព្រះរាជា ទ្រង់ត្រាស់ សួរ ថា "ទ្រព្យរបស់អ្នក មានកន្លះមាសកឬ ?" ៗ បុរសនោះ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ពិតមែនហើយ" ៗ ព្រះរាជា ទ្រង់ត្រាស់ ថា "នែអ្នកដ៏ចំរើន បើដូច្នោះ ចូរអ្នកកុំទៅ ក្នុងទីនោះ ក្នុងថ្ងៃក្តៅ យ៉ាងនេះឡើយ, ខ្ញុំនឹងឲ្យទ្រព្យកន្លះមាសក ដល់អ្នក" ៗ បុរសនោះ ក្រាបទូល ថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ សូម្បី ទទួលយកទ្រព្យដែលព្រះអង្គទ្រង់ព្រះរាជទានហើយ ក៏នឹងមិនញុំាង ទ្រព្យក្រៅអំពីនេះ ឲ្យវិនាសឡើយ, ទូលព្រះបង្គំ នឹងមិនបញ្ឈប់ នូវការធ្វើដំណើរ របស់ទូលព្រះបង្គំ ហើយ (ទៅ) នាំយកទ្រព្យ នោះមក ឲ្យទាល់តែបាន" ៗ ព្រះរាជា ទ្រង់ដំឡើង (ទ្រព្យ)

ដោយលំដាប់ ហើយទ្រង់ត្រាស់ ថា " នែបុរសដ៏ចំរើន ចូរអ្នកត្រឡប់ទៅវិញចុះ, ខ្ញុំនឹងឲ្យទ្រព្យ ១ មាសក ២ មាសក ។ល។ ទ្រព្យ ១០០ កោដិ ទ្រព្យដែលកំណត់មិនបាន " ដូច្នេះហើយ, កាលបើបុរសនោះ ក្រាបទូល យ៉ាងដូច្នោះដដែល, ទើបទ្រង់លួងលោមហើយ ដោយឋាននូវស័ក្តិ មានដំណែងសេដ្ឋីជាដើម, កាលបើបុរសនោះ ក្រាបទូល យ៉ាងដូច្នោះដដែល, ទើបទ្រង់ត្រាស់ ថា " ខ្ញុំនឹងឲ្យរាជសម្បត្តិពាក់កណ្តាល ដល់អ្នក" ដូច្នេះ, កាលបើបុរសនោះ ព្រមទទួល, ទើបទ្រង់ត្រាស់បញ្ជា ពួកអាមាត្យថា "អ្នកទាំងឡាយ ចូរទៅ, ចូរកាត់សក់ កោរពុកមាត់នៃសំឡាញ់របស់យើង ឲ្យងូតទឹក ប្រដាប់ប្រដាហើយ នាំយកមក " ។ ពួកអាមាត្យទាំងឡាយ ធ្វើហើយ យ៉ាងដូច្នោះ នាំមកហើយ ។ ព្រះរាជា ទ្រង់ចែករាជសម្បត្តិ ជា ២ ចំណែក ទ្រង់បានព្រះរាជទានហើយ នូវរាជសម្បត្តិពាក់កណ្តាល ដល់បុរសនោះ ។ បុរសនោះបានឈ្មោះថា ព្រះរាជាអឌ្ឍមាសក ។

រឿង ព្រះរាជាអឌ្ឍមាសក មកក្នុងអដ្ឋកថាគង្គមាលជាតក ក្នុងអដ្ឋកនិបាត ។

(២៦៧) រឿងក្រៅ អំពីនោះ នឹងមានប្រាកដ ក្នុងបទ ថា " ខន្តិ " ។ ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា

“ បុគ្គលណាមួយ ធ្វើនូវកិច្ចការ របស់បុរស មិនអើពើ នូវត្រជាក់ និង ក្ដៅ ក្រៃលែងជាងស្មៅ, បុគ្គលនោះ រមែងមិនសាបសូន្យ ចាកសេចក្ដីសុខឡើយ ” ។

អដ្ឋកថាសិគាលសូត្រ ថា “ បណ្ដាបទទាំងនោះ ពាក្យថា ‘ តិណា ភិយ្យោ ’ បានដល់ ឲ្យក្រៃលែង សូម្បីជាងស្មៅ” ។

ដីកាអាឡវកសូត្រ ថា “បាទគាថា ថា ‘ តិណា ភិយ្យោ ន មញ្ញតិ ’ មានសេចក្ដីថា បុរសនោះ កាលមើលងាយ ដូចស្មៅ ប្រព្រឹត្តញាំញី ” ។

អដ្ឋកថាសិគាលសូត្រ ថា “បាទគាថា ថា ‘ សោ សុខា ន វិហាយតិ ’ មានសេចក្ដីថា បុរសនោះ រមែងមិនលះបង់ចោល នូវសេចក្ដីសុខ គឺ ជាអ្នកដល់ព្រម ដោយសេចក្ដីសុខនុ៎ះឯង ” ។

(២៦៨) ព្រោះហេតុនោះ អ្នកនៅគ្រប់គ្រងផ្ទះសម្បែង មិនគប្បីអើពើ នូវហេតុមានត្រជាក់ជាដើម ហើយសន្សំភោគៈទាំងឡាយ ដោយលំដាប់ ។ ព្រោះថា កាលបើបុគ្គលធ្វើ យ៉ាងនេះ ភោគៈ រមែងមានច្រើន ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា ÷

“ កាលបើបុគ្គល រួបរួមសន្សំ នូវភោគទាំងឡាយ

ធ្វើឲ្យចំរើនឡើង ដូចជាសត្វឃ្មុំ, ភោគៈទាំងឡាយ របស់បុគ្គលនោះ រមែងដល់ នូវការចំរើនឡើង ដូច ជាដំបូក ដែលកណ្ដៀរទាំងឡាយ ពូនឡើងដូច្នោះ" ។

អដ្ឋកថាសិគាលសូត្រនោះ ថា "បណ្ដាបទទាំងនោះ បទ ថា 'សំហរមានស្ស' មានសេចក្ដីថា អ្នកមិនបៀតបៀន ទាំងខ្លួនឯង ទាំងអ្នកដទៃ រួបរួមភោគៈទាំងឡាយ គឺ ធ្វើឲ្យជាដុំកំភួនឡើង ដោយធម៌ ។ បាទគាថា ថា 'ភមរស្សេវ ឥរីយតោ" មាន សេចក្ដីថា ធ្វើនូវគំនរនៃភោគៈដ៏ច្រើន ដោយលំដាប់ ប្រៀបដូច ជាសត្វឃ្មុំ មិនបៀតបៀន នូវពណ៌និង ក្លិន នៃបុប្ផាទាំងឡាយ ពាំ យកកេសរផ្កាទៅ ដោយទ្រនិចខ្លះ ដោយស្លាបខ្លះ ហើយធ្វើសំបុក ឃ្មុំ ទំហំប៉ុនកង់ចក្រ ដោយលំដាប់ដូច្នោះឯង ។ បាទគាថា ថា 'ភោគស្ស និចយំ យន្តិ' មានសេចក្ដីថា ភោគៈទាំងឡាយ របស់បុគ្គលនោះ រមែងដល់ នូវកិរិយាចំរើនឡើង ដូចជាដំបូក ដែលពួកសត្វកណ្ដៀរ ពូនឡើង ដោយលំដាប់ យ៉ាងនោះឯង ។

ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា 'វម្មិកោវុបចីយតិ' ។ អធិប្បាយថា 'រមែងដល់ នូវកិរិយា ចំរើនឡើង ដូចជាដំបូក ដែលសត្វកណ្ដៀរ ពូនឡើងដូច្នោះ" ។

ដីកាសិគាលសូត្រនោះ ថា "ព្រះអដ្ឋកថាចារ្យ កាលសំដែងនូវសេចក្ដីនោះ នៃគាថានោះ ថា 'កិរិយាសន្សំនូវភោគៈ របស់បុគ្គលនោះ ប្រកបដោយធម៌ គឺ ចូលដល់ញាណ' ដូច្នេះ ដោយបាទគាថានេះ ថា '**ភមរស្សេវ ឥរីយតោ**' ដូច្នេះ ទើបពោលនូវពាក្យថា '**អត្តានម្បិ**' ដូច្នេះ ជាដើម ។ ២ បទ ថា '**វាសីករោន្តស្ស**' មានសេចក្ដីថា អ្នកបង្កបង្កើត គឺ រួបរួម ដោយប្រការដែលភោគៈ មានទ្រព្យនិងធញ្ញជាតជាដើម របស់បុគ្គលនុ៎ះ នឹងជាដុំជាគំភួន គឺ ជាពំនូក គរនៅ ៗ បទ ថា '**ចក្កប្បមាណំ**' បានដល់ ទំហំស្មើនឹងកង់រទេះ ។ បទ ថា '**និចយំ**' បានដល់ សេចក្ដីចំរើន គឺ ការលូតលាស់ ។ អាចារ្យពួកខ្លះ ពោល ថា '**ភោគា សន្និចយំ យន្តិ**' ដូច្នេះ" ។

(២៦៩) បណ្ដាការងារទាំងនោះ កសិកម្ម ដែលបុគ្គលប្រកបត្រូវហើយ រមែងនាំប្រយោជន៍សុខមកឲ្យក្នុងលោកទាំង ២ ។ ក្នុងសេចក្ដីនោះ មានរឿងនេះ ( ជាឧទាហរណ៍ ) ។

## ( រឿងមេណ្ឌកសេដ្ឋី )

ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី សេដ្ឋីម្នាក់ កាលទៅកាន់ដំណាក់ នៃព្រះរាជា ជួបប្រទះនឹងបុរោហិត ក៏សួរនក្ខត្តឫក្ស

ហើយដឹងបាន ថា "ដោយកន្លងទៅ ៣ ឆ្នាំ អំពីឆ្នាំនេះទៅ ភ័យអំពីសេចក្ដីអត់ឃ្លាន នឹងមាន ក្នុងជម្ពូទ្វីបទាំងមូល" ដូច្នេះហើយ ក៏បានឲ្យពួកមនុស្ស ធ្វើកសិកម្ម ជាច្រើន ហើយឲ្យធ្វើជង្រុកចំនួន ១.២៥០ ខ្នង ។

(ក្នុងអដ្ឋកថាសេលសូត្រ លោកពោលសេចក្ដី ថា "ដប់បីរយខ្វះកន្លះ ឈ្មោះថា ដប់បីរយខ្វះកន្លះ គឺ ១.២០០ និង ៥០" ។)

សេដ្ឋីនោះ ញាំងជង្រុកទាំងនោះ និង ពាងជាដើម ឲ្យពេញហើយ ដោយស្រូវ កប់នូវចំណែកដែលសល់ពីនោះ ក្នុងអន្លង់ទាំងឡាយហើយ ច្របាច់ផ្សំ នូវចំណែកដែលសល់ពីនោះ ចូលជាមួយគ្នានឹងដីស្អិតហើយ ឲ្យបូកជញ្ជាំង, កាលបើវេលានៃភ័យ មកដល់ហើយ, កាលបើស្រូវដែលដាក់ទុក ក្នុងជង្រុក និង ពាងជាដើមអស់រលីងហើយ, ក៏ប្រាប់ ថា "ម្នាលអ្នកទាំងឡាយ ពួកអ្នកចូរទៅចុះ, មនុស្សទាំងឡាយ ចូររស់នៅ តាមសេចក្ដីប្រាថ្នាចុះ" ។ មនុស្សទាំងឡាយ គេចជៀសទៅហើយ តាមសេចក្ដីប្រាថ្នា ។

ក៏ក្នុងផ្ទះ (របស់សេដ្ឋី) បានមានមនុស្សនៅសល់ ៥ នាក់ គឺ សេដ្ឋី ១ ភរិយា ១ កូនប្រុស ១ កូនប្រសា ១ អ្នកបម្រើឈ្មោះបុណ្ណៈ ១ ។ ជនទាំងនោះ, កាលបើស្រូវ ក្នុងអន្លង់ទាំងឡាយ អស់ហើយ, ញាំងដីស្អិតដែលបូកជញ្ជាំង ឲ្យទទឹកហើយ

ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយស្រូវដែលបានហើយ អំពីដីស្អិតបួកជញ្ជាំងនោះ ៗ ចំណែក ភរិយានៃសេដ្ឋី ញ៉ាំងដីស្អិតដែលនៅសល់ ក្នុងកន្លែងនៃជញ្ជាំងទាំងឡាយ ឲ្យទទឹកហើយ បានស្រូវកន្លះអាឡ្ហកៈ បុកហើយ បានអង្ករមួយនាឡិ ដាក់អង្ករមួយនាឡិនោះ ក្នុងឆ្នាំងហើយ កប់ទុកក្នុងផែនដី ព្រោះភ័យអំពីចោរលួច, ថ្ងៃមួយ កាលបើសេដ្ឋី ទៅកាន់ដំណាក់ នៃព្រះរាជាហើយ បានត្រឡប់មកវិញ ពោល ថា " នែនាងដ៏ចំរើន បងឃ្លានហើយ, តើមានវត្ថុអ្វី ញ៉ាំឬទេ ?" ដូច្នេះហើយ, ទើបយកអង្ករនោះមកដាំបាយ ហើយចែកជា ៥ ចំណែក ឲ្យ ១ ចំណែក ដល់សេដ្ឋី ។

ក្នុងខណៈនោះ ព្រះបច្ចេកពុទ្ធមួយអង្គ ចេញពីនិរោធ កាលត្រួតមើល ដោយទិព្វចក្ខុ ដឹងហើយ ថា "ឆាតកភ័យ កើតឡើងហើយ ក្នុងជម្ពូទ្វីបទាំងមូល, បាយនៃអង្ករមួយនាឡិ គេបានចំអិនហើយ ដើម្បីជន ៥ នាក់ ក្នុងផ្ទះរបស់សេដ្ឋី, ក៏ជនទាំង ៥ នាក់នោះ ជាអ្នកមានសទ្ធា នឹងធ្វើនូវការសង្គ្រោះ ដល់អាត្មាអញ" ដូច្នេះហើយ ទើបនិមន្តមកអំពីភ្នំគន្ធមាទន៍ហើយ បង្ហាញខ្លួន ដល់ជនទាំង ៥ នាក់នោះ ៗ ជនទាំងអស់នោះ បានប្រគេនចំណែកនៃភត្តរបស់ខ្លួន ៗ ហើយពោល ថា "បពិត្រព្រះអង្គដ៏ចំរើន ចាប់ដើមពីថ្ងៃនេះទៅ យើងខ្ញុំទាំងឡាយកុំគប្បីជួបប្រទះនូវឆាតកភ័យ

យ៉ាងនេះឡើយ" ដូច្នេះហើយ ក៏បានធ្វើសេចក្តីប្រាថ្នា ដ៏សមគួរដល់សេចក្តីប្រាថ្នា ។ ក៏បណ្តាជនទាំងនោះ សេដ្ឋីប្រាថ្នា ថា "តាំងអំពីថ្ងៃនេះទៅ យើងខ្ញុំ គប្បីជាអ្នកអាច ឲ្យនូវពូជ និងធញ្ញជាតដល់ជនអ្នកនៅក្នុងជម្ពូទ្វីបទាំងអស់, មិនគប្បីធ្វើការងារ ដោយដៃរបស់ខ្លួនហើយរស់នៅ, គំនរនៃស្រូវសាលីពណ៌ក្រហម គប្បីធ្លាក់ចុះមកពេញជង្រុកទាំងអស់ ក្នុងខណៈដែលយើងខ្ញុំ ឲ្យគេសំអាតជង្រុក ១.២៥០ ខ្នងហើយ ជម្រះសិរសី អង្គុយត្រង់ទ្វារនៃជង្រុកទាំងនោះ ហើយងើយមើលទៅខាងលើនុ៎ះឯង, អ្នកនេះប៉ុណ្ណោះ ចូរជាភរិយា, អ្នកនេះប៉ុណ្ណោះ ចូរជាកូនប្រុស, អ្នកនេះប៉ុណ្ណោះ ចូរជាកូនប្រសា, អ្នកនេះប៉ុណ្ណោះ ចូរជាអ្នកបម្រើ ក្នុងកន្លែងដែលយើងខ្ញុំកើតហើយ ៗ នុ៎ះឯង" ។ ឯភរិយា ប្រាថ្នា ថា "កាលបើនាងខ្ញុំ ដាក់ស្រូវសាលីកន្លះអាឡ្ហកៈ នៅចំពោះមុខហើយ ឲ្យភ័ត្ត ដល់ជនក្នុងជម្ពូទ្វីបទាំងអស់, នាងខ្ញុំ នៅមិនទាន់ក្រោកឡើង ដរាបណា, ទីកន្លែង (នៃស្រូវសាលី) ដែលនាងខ្ញុំកើបយកហើយ ៗ ចូរពេញបរិបូរដូចដើម ដរាបនោះ, ជនទាំងឡាយនេះប៉ុណ្ណោះ ចូរជាស្វាមី កូនប្រុស កូនប្រសា និង អ្នកបំរើរបស់នាងខ្ញុំ" ។ ឯកូនប្រុស ប្រាថ្នា ថា "កាលបើខ្ញុំ កាន់យកនូវបង្វេចទ្រព្យ ១ ពាន់ សូម្បីឲ្យទ្រព្យ ដល់ជនក្នុងជម្ពូទ្វីបទាំងអស់

ហិបសម្រាប់បញ្ចុះទ្រព្យ ចូរនៅពេញបរិបូណ៌, ជនទាំងអស់នេះប៉ុណ្ណោះ ចូរជាមាតា បិតា ភរិយា និង អ្នកបម្រើ របស់ខ្ញុំ" ។ ឯកូនប្រសា ប្រាថ្នា ថា "កាលបើនាងខ្ញុំ ដាក់កញ្ជើ នៃស្រូវមួយនៅចំពោះមុខ សូម្បីឲ្យពូជនិងស្រូវ ដល់ជនក្នុងជម្ពូទ្វីបទាំងអស់, ភាពអស់ទៅនៃពូជនិងស្រូវ កុំបីប្រាកដឡើយ, ជនទាំងនេះប៉ុណ្ណោះ ចូរជាមាតា បិតា ស្វាមី និង អ្នកបម្រើ របស់នាងខ្ញុំ" ។ ឯអ្នកបម្រើ ប្រាថ្នា ថា "កាលបើខ្ញុំ កំពុងភ្ជួរស្រែ, គន្លងភ្ជួរទាំងឡាយ ៧ គន្លង ទំហំប៉ុនរង្វាស់ឈើ គឺ ខាងនេះ ៣ គន្លង ខាងនេះ ៣ គន្លង ត្រង់កណ្តាល ១ គន្លង ចូរទៅ, ជនទាំងនេះប៉ុណ្ណោះ ចូរជាចៅហ្វាយនាយ របស់ខ្ញុំ" ។ ក្នុងថ្ងៃនោះ អ្នកបម្រើនុ៎ះអាចដើម្បីប្រាថ្នា នូវដំណែងនៃសេនាបតី ហើយបាន ក៏ពិតមែន, ទុកជាដូច្នោះ អ្នកបម្រើនុ៎ះ ប្រាថ្នាហើយ យ៉ាងនេះ ព្រោះសេចក្តីស្រឡាញ់ ចំពោះចៅហ្វាយនាយទាំងឡាយ ។

ក្នុងទីបញ្ចប់ នៃពាក្យពោល របស់ជនទាំងអស់នោះ ព្រះបច្ចេកពុទ្ធ ពោល ថា "សេចក្តីប្រាថ្នារបស់អ្នកទាំងឡាយ ចូរបានសម្រេច យ៉ាងនេះចុះ" ដូច្នេះហើយ ទើបធ្វើនូវការអនុមោទនាដោយគាថានៃព្រះបច្ចេកពុទ្ធទាំងឡាយ ហើយអធិដ្ឋាន ថា "ជនទាំងនេះ ចូរឃើញ នូវអាត្មាអញ" ហើយក៏និមន្តទៅ ចែកភ័ត្តនោះ

ធ្វើឲ្យបានគ្រប់គ្រាន់ ដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដោយអានុភាព នៃព្រះអង្គ ៗ ជនទាំងនោះ បានឈរមើលព្រះបច្ចេកពុទ្ធនោះហើយ ៗ

គ្រានោះ ភរិយារបស់សេដ្ឋី គិត ថា "ភត្ត អស់ហើយ" បាន លាងឆ្នាំង គ្របទុកហើយ ៗ ឯសេដ្ឋី ត្រូវសេចក្ដីឃ្លានបៀតបៀន ហើយដេកលក់ ភ្ញាក់ឡើង ពោល ថា "នែនាងដ៏ចំរើន បងឃ្លាន បាយណាស់, បាយក្ដាំង ក្នុងឆ្នាំង មានដែរឬទេ ?" ៗ ភរិយានោះ ក៏បានក្រោកទៅបើកឆ្នាំងបាយ ៗ ក្នុងខណៈនោះឯង ឆ្នាំងបាយ បានពេញប្រៀប ដោយបាយមានសម្បុរដូចជាផ្កាម្លិះក្ដោប ៗ នាង បានឃើញបាយនោះហើយ ពោល ថា "បពិត្រអ្នកប្ដី សូមបងក្រោក ឡើង, អញ្ជើញពិសាចុះ" ហើយបានឲ្យបាយ ដល់បិតានិងកូនទាំង ២ នាក់, កាលបើអ្នកទាំងនោះ បរិភោគរួចស្រេចហើយ ក្រោក ឡើង, ទើបបរិភោគ ជាមួយនឹងកូនប្រសា ហើយបានឲ្យបាយដល់ នាយបុណ្ណៈ ៗ ស្នាម នៃភត្តដែលគេដួសហើយ ៗ មិនចេះអស់ទៅ ឡើយ, ស្នាមនៃភត្តដែលគេយកវែកដួសហើយ តែម្ដង ប៉ុណ្ណោះឯង រមែងប្រាកដ ៗ ក្នុងថ្ងៃនោះឯង ជង្រុកជាដើម បានពេញហើយ ដោយទំនងដែលពេញហើយ ក្នុងពេលមុនន៉ុះឯង ៗ គ្រានោះ សេដ្ឋី បានឲ្យហើយនូវពូជនិងស្រូវ ដល់ជនជម្ពូទ្វីបទាំងអស់ ៗ សេដ្ឋីនោះ ច្យុតពីមនុស្សលោកនោះហើយ បានទៅកើតក្នុងទេវលោក អន្ទោល

ទៅមក ក្នុងសុគតិ ឥឡូវនេះ បានមកកើតជាមេណ្ឌកសេដ្ឋី នៅក្នុងភទ្ទិយនគរ ។ ឯភរិយារបស់សេដ្ឋីនោះ ក៏មកកើត ក្នុងត្រកូលដែលមានភោគទ្រព្យច្រើន ។ ស្នាមនៃផ្កាបទុម កើតហើយ ត្រង់បាទដៃនិងបាទជើងខាងឆ្វេង របស់នាង, ស្នាមនៃព្រះច័ន្ទ កើតហើយ ត្រង់បាទដៃនិងបាទជើងទាំងឡាយម្ខាងទៀត, ដោយហេតុនោះ ទើបនាង បានឈ្មោះថា "ចន្ទបទុមា" ។ នាង ធំពេញវ័យហើយ ក៏បានទៅកាន់ផ្ទះនៃមេណ្ឌកសេដ្ឋី ។ សូម្បីបុត្រ កូនប្រសានិងអ្នកបម្រើ ក៏បានជាបុត្រ កូនប្រសានិង អ្នកបម្រើ របស់ជនទាំង ២ នាក់នោះហើយ មែនពិត ។ បណ្ដាជនទាំងនោះ កូនប្រុសឈ្មោះថាធនញ្ជ័យ ជាឪពុក របស់នាងវិសាខា, កូនប្រសា ឈ្មោះថា នាងសុមនទេវី ជាម្ដាយ របស់នាងវិសាខា ។ ជនទាំងអស់នោះ តែងពិចារណា នូវបុណ្យរបស់ខ្លួន ។ បុណ្យទាំងអស់នោះរមែងសម្រេច តាមសេចក្ដីប្រាថ្នារបស់ឯងហើយ ។

រឿងមេណ្ឌកសេដ្ឋី មកក្នុងអដ្ឋកថា នៃគាថា ថា "សុទស្សំ វជ្ជមញ្ញេសំ" ដូច្នេះ ជាដើម ក្នុងមលវគ្គ នៃធម្មបទ ។

(២៧០) កសិកម្ម ដែលបុគ្គលប្រកបត្រឹមត្រូវហើយ រមែងនាំប្រយោជន៍សុខមកឲ្យ ក្នុងលោកទាំង ២ ដល់ជនទាំងនេះ ដោយប្រការដូច្នេះ ។ ក្នុងការងារក្រៅពីកសិកម្មនោះ ក៏ន័យនេះដែរ ។

ក៏ការងារទាំងនេះ ឈ្មោះថាជាមង្គល ព្រោះនាំប្រយោជន៍សុខមកប្រគល់ឲ្យ ក្នុងលោកទាំង ២ ។

ចំណែក ក្នុងអដ្ឋកថា លោកពោល នូវពាក្យមានប្រមាណប៉ុណ្ណេះឯង ថា " ការងារទាំងឡាយនុ៎ះ ដែលបុគ្គលប្រកបបានហើយ យ៉ាងដូច្នេះ ក៏ព្រោះភាវៈនៃខ្លួន កូនប្រុស និងភរិយា ឬកម្មករទាំងឡាយ ជាអ្នកឆ្លាតវាងវៃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃកិរិយាបាន នូវសេចក្ដីចំរើន នៃទ្រព្យសម្បត្តិនិងធញ្ញជាត ក្នុងបច្ចុប្បន្ននេះមែនពិត " ។ ក៏ភាវៈនៃការងារទាំងឡាយ ជាហេតុនៃកិរិយាបាន នូវប្រយោជន៍សុខ ក្នុងបរលោក រមែងមាន ដោយពិតប្រាកដ ។

មង្គល ៤ ប្រការ គឺ ការទំនុកបំរុងមាតា, ការទំនុកបំរុងបិតា, កិរិយាសង្គ្រោះបុត្រ និងភរិយា, ការងារដែលមិនច្របូកច្របល់ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ដោយគាថានេះឯង ដោយប្រការដូច្នេះ ។ សូម្បីពាក្យជាគាថានេះ ក៏ឈ្មោះថា បឋ្យាវត្ត ដូច្នេះឯង ។

ការពណ៌នាសេចក្ដីនៃគាថាទី ៤ ចប់ ។

---

**( មង្គលត្ថទីបនី ប្រែ ភាគទី ២ ចប់ ។ )**

ប្រែចប់ថ្ងៃសៅរ៍ ២ រោច ខែបុស្ស ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៦
ត្រូវនឹងថ្ងៃទី ៩ មករា ១៩៩៣

សូមខេមរជនគ្រប់ៗរូប ជួយនាំគ្នាស្តារនិងលើកស្ទួយនូវសាមគ្គីធម៌, ព្រហ្មវិហារធម៌, សង្គហធម៌ ដែលយើងធ្លាប់មានមកពីកាលមុន ជាយូរអង្វែងហើយ ឱ្យស្ថិតនៅជាប់ក្នុងដួងចិត្តយើងគ្រប់ៗគ្នាឡើងវិញ ហើយនាំគ្នាកំចាត់ចោលនូវការចងក្រោធទុក, ការចងកម្មចងពៀរវេរានឹងគ្នា, ការចងគំនុំគុំគួនគ្នា និងការព្យាបាទបៀតបៀនដល់គ្នានឹងគ្នា មិនចេះឈប់ឈរ ឱ្យប្រាសចាកពីខន្ធសន្តានរបស់យើង ដើម្បីទទួលយកនូវសេចក្ដីសុខសន្តិភាពទាំងផ្លូវកាយ-ផ្លូវចិត្ត ដ៏ពិតប្រាកដតាមមាគ៌ានៃព្រះពុទ្ធសាសនា ។ មែនពិតអំពើអាក្រក់ទាំងប៉ុន្មានខាងលើនេះ ពុំដែលធ្វើឱ្យមនុស្សចម្រើនឡើយ មានតែធ្វើឱ្យមនុស្សយើងវិនាសតែម្យ៉ាងប៉ុណ្ណោះ ។

**វត្តខេមរពុទ្ធិការាម សហរដ្ឋអាមេរិក**

១៥កើត ខែវិសាខ ឆ្នាំមមែត្រីស័ក ព.ស.២៥៣៤

**ភិក្ខុវិនយធរោ មហាយិន-នឿន**

## វត្តនានានៃពុទ្ធិកសមាគមន៍ព្រះសង្ឃខ្មែរដែលបាន ជួយឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅ មង្គលត្ថទីបនីប្រែ ទាំង៤ ភាគ ដើម្បីចែកផ្សាយ ជាធម្មទាននេះ មានដូចតទៅ

-------------

១- វត្តខេមរពុទ្ធិការាម ទីក្រុងឡុងប៊ិច

២- វត្តវិបស្សនារាម ទីក្រុងឡុងប៊ិច

៣- វត្តពុទ្ធវង្ស ទីក្រុងហុស្តុន តិចសាស់

៤- វត្តជេតពន ទីក្រុងដាល់ឡាស់ តិចសាស់

៥- វត្តខេមររតនារាម ទីក្រុងសាន់ឌីកូ

៦- វត្តសុវណ្ណគិរី ទីក្រុងសាន់ឌីកូ

៧- វត្តសាន់តាអាណា ទីក្រុងសាន់តាអាណា

៨- វត្តពុទ្ធសាសនវង្ស ទីក្រុងប្រេះស្នូ

៩- វត្តសាន់ហូសេ ទីក្រុងសាន់ហូសេ

១០- វត្តប៉ូម៉ូណារាម ទីក្រុងប៉ូម៉ូណា

១១- វត្តត្រៃកូដ ទីក្រុងអិលអេ

១២- វត្តធម្មិការាម ទីក្រុងប្រូវីដង់

១៣- វត្តធម្មចក្ការាម ទីក្រុងស៊ីអាថុល

១៤- វត្តសាមគ្គីរតនារាម ទីក្រុងតាក់កុមា

កិច្ចការទាំងឡាយទាំងពួង គឺពិតជាមានការភ្លេចភ្លាំងជាធម្មតា ហេតុនេះ បើមានការធ្លាក់ឬបាត់ឈ្មោះអស់លោក ញាតិញោម ពុទ្ធបរិស័ទដែលបានជួយឧបត្ថម្ភ ក្នុងការបោះពុម្ពសៀវភៅនេះ សូមមេត្តាខន្តីអភ័យទោសដល់ខ្ញុំផងចុះ ។

ម្យ៉ាងទៀត ខ្ញុំសូមទទួលការរិះគន់ គ្រប់ពីមជ្ឈដ្ឋានទាំងអស់ ដែលបានឃើញនូវកំហុស ឬការភ្លាំងភ្លាត់ត្រង់កន្លែងណានីមួយនោះ ហើយសូមផ្តល់ជាយោបល់ទៅខ្ញុំអ្នកធ្វើកុំបីខាន ។

សូមអរគុណ

------------

| | | |
|---|---|---|
| អក្សរ | : | សិល្បៈប្រពៃណី |
| រលុប | : | ខ្មោចខ្មីគ្មានសល់សោះ |
| ជាតិ | : | ក៏រលំខ្ទេចខ្ទាំអស់ |
| រលាយ | : | បាត់ឈ្មោះពីផែនលោក ។ |
| ខ្មែរ | : | យើងប្រុសស្រីខំខ្មីឃ្មាត |
| ត្រូវ | : | ប្រឹងប្រែងឆ្លៀតខំរៀនយក |
| វេចស្តាយ | : | អក្សរបន្តរក |
| គ្រប់វិជ្ជា | : | មកទើបជាតិគង់ ។ |

**កវីនិពន្ធ ឈៀម-គៀន**

## រាយនាមព្រះសង្ឃនិងពុទ្ធបរិស័ទដែលមានសទ្ធាជួយបោះពុម្ព សៀវភៅមង្គលត្ថទីបនីប្រែនេះ មានដូចតទៅនេះ

| *ឈ្មោះ* | *ចំនួនបច្ច័យ* |
|---|---|
| ព្រះតេជះគុណ គង់-សុជាន | ៥០០ ដុល្លា |
| ភិក្ខុមហាចន្ទមុនី | ១៣២ " |
| ភិក្ខុ អ៊ុង-អុន | ១៣០ " |
| ភិក្ខុមហា ជួន-ប៊ុនឈើន | ១២០ " |
| ភិក្ខុ ម៉ែន-កុសល | ១២០ " |
| ភិក្ខុជុន-ប៊ុនឬទ្ធិ សិក្ខាចារធម្មោ | ១០០ " |
| ភិក្ខុឡោ-ហោ | ១០០ " |
| ភិក្ខុ អ៊ុក-ជា ជយោ | ៥០ " |
| ភិក្ខុតាន់-ភោគ កិត្តិសារោ | ៥០ " |
| ភិក្ខុរក្ខិតោ អ៊ុន-វិន | ៥០ " |
| ភិក្ខុពហ្ម-សុវណ្ណ | ៥០ " |
| ភិក្ខុព្រហ្ម-ជួប | ៥០ " |
| ភិក្ខុវីរិយធរោ ស៊ុន-សុវត្ថា | ៥០ " |
| ភិក្ខុមាស-ហៃ | ៤០ " |
| ភិក្ខុអាប-ភាវ | ៤០ " |
| ភិក្ខុធម្មសារោ អួក-សាម៉ន | ៣៥ " |
| ភិក្ខុគោវិទោ គង់-បាន | ៣៥ " |
| ភិក្ខុ ឈុន-យឿន | ៣០ " |
| ភិក្ខុ សេង-ប៊ុនហាក់ | ៣០ " |

| | |
|---|---|
| ភិក្ខុដោក-សាន | ៣០ ដុល្លា |
| ភិក្ខុ ដាញ់-ហឹងរិលៀម | ២៥ " |
| ភិក្ខុ ង៉ោ-ហៀង | ២១ " |
| ភិក្ខុ ហ្គារី-សីវសុិនតុន | ២១ " |
| ភិក្ខុ នីយម កិត្តិកោ | ២០ " |
| ភិក្ខុ មហាបាន់ ធម្មបញ្ញោ | ២០ " |
| ភិក្ខុ ពុទ្ធរក្ខិតោ កេង-ងិន | ១៥ " |
| ភិក្ខុ ម៉ី-សុធា | ១០ " |
| ភិក្ខុ ណាំ-សុផល | ១០ " |
| ភិក្ខុ ហុក-វ៉ារុធ | ១០ " |
| ឧបាសកសៅរ៍-ឡៀប ឧបាសិកាសៅរ៍-ចាន់ធូ | |
| និង ឧបាសិកា សៅរ៍-ចិន្តា | ៥០០ " |
| ឧបាសកសៀន-ខ័នឌី អ្នកស្រីពោតឹម-សៀ | |
| លោកម៉ៅ-អួង អ្នកស្រីសៀន-ចិតសិរី | |
| កុមារ ដូណាល់-ម៉ៅ | |
| លោកសៀន កុលបញ្ញា | |
| លោកសៀន-ធីរវិបុល | |
| លោក-សិរីវង្ស អ្នកស្រីបែន-វណ្ណបុប្ផ | |
| លោកវ៉េត-សារីយ អ្នកស្រីអជិតានី និងបុត្រ | ៥០០ " |
| ឧបាសកហុក-ចាយ ឧបាសិកាតាន់-ប៊ុនច័ន្ទ | ៣៥០ " |
| ឧបាសកឡុង-យូហួត ឧបាសិកាជា-ស៊ីម | ៣០០ " |
| ឧបាសិកា រស់-សុខ វើន-លួន់ | ២៨០ " |
| ឧបាសិកា តៃ-គឹមហ៊ួ | ២១២ " |
| លោក ភិន-សាវ៉ា | ៣៥ " |

នាងអ៊ឹម-កៀត កុមារីកុសល កុមារចំរើន ២១០ ដុល្លា
ឧបាសក វង់-ឌួង ២០០ "
ព្រះភិក្ខុ សោភណត្ថេរោ ម៉ង់-មិន ១១៤ "
លោក វង្ស-សុភ័ត អ្នកស្រីវណ្ណៈ ១៤០ "
ព្រះភិក្ខុប៉ាន-ម៉ាយ ១០០ "
លោកឆែម-សាយ អ្នកស្រីសារុំ-ហ៊ុយ ១០០ "
ពុទ្ធបរិស័ទវត្តឈើរ ១០០ "
អ្នកស្រី ពិន-នាម អ្នកស្រីកែវ-វង្សា
និងកុមារីនីរ៉ាដែត លឹមគឹមស្រ៊ ១០៥ "
អ្នកស្រី គង់-សម័យ ព្រមទាំងបុត្រ ១០៥ "
ឧត្តមសេនីទោ យួន-ហ្វេង់ និងលោកស្រី
ជួន-កល្យាណ ព្រមទាំងបុត្រ ១០៥ "
ឧបាសិកាតោ-គឹមសួរ ១០៥ "
អ្នកស្រីសន-យ៉ាត និងគ្រួសារ ១០០ "
លោកយុន-យឿន និងគ្រួសារ ១០០ "
លោកសៀ-សុងវ៉ាន ១០០ "
លោកសៀន-ដារ៉ុង អ្នកស្រីសុខេត្ត-សាំង
និងបុត្រ ៧០ "
លោក រស្មី-តេជធម្មោ ៧០ "
កម្លោះ នីវ-ចំរើន ៧០ "
ឧបាសិកាឌិក-ចំរើន នីវ និងបុត្រ ៧០ "
អ៊ុង-ម៉ាលី ៧០ "
អ៊ុង-អ៊ាម ស៊ាម ៧០ "
លោកភិន-សាវណ្ណ អ្នកស្រីតាន់-សុនថាន ៣៥ "

| | | |
|---|---|---|
| ឧបាសកព្រហ្ម-យឿន ឧបាសិកាព្រហ្ម-ស៊ុម | ៥០ | ដុល្លា |
| អ្នកស្រីចាប-សុជាត ព្រមទាំងគ្រួសារ | ១៤ | " |
| ឧបាសកសេក-ញ៉ែម | | |
| ឧបាសិកាសៅ-ញៀវ | ៧០ | " |
| លោកយ៉ាន់-សារឿត អ្នកស្រីសុខន-សាំង | | |
| និងបុត្រ | ៣៥ | " |
| ឧបាសកអ៊ុម-នៅ | ៣៥ | " |
| ឧបាសកឃ្លោក-ផុន | ៣៥ | " |
| ឧបាសក អ៊ុម-សំផុន (ឃ្លោកទូច) | | |
| អ្នកស្រីតាន់-សារ៉ម និងបុត្រ | ៣៥ | " |
| លោកប៉ុនណារី អ្នកស្រីដែល-ជនណារិទ្ធិ | ៣៥ | " |
| លោកប៉ែន-ឃុំ អ្នកស្រីស៊ីសុវត្ថិ-បុប្ផារត្ន | ៣៥ | " |
| អ្នកស្រីប៉ាន-ចំណាន ស្វាមី និងបុត្រ | ៥០ | " |
| លោកមុក-រ៉ុប លោកឃឹម-បុណ្ណា អ្នកស្រី | | |
| សុគន្ធទនី និងបុត្រ | ៣៥ | " |
| លោកតាមុក-រ៉ុប | ២១ | " |
| ជាមណោន-មុក ម៉ុក | ៥០ | " |
| មុក-ម៉េន ហុក-សុខឡេង | ៧០ | " |
| មុក-សាមោន-ចន្ធី | ៥០ | " |
| អន-សុផល មុក-សាមឿន | ២១ | " |
| មុក-ផាន់ មុក-ផា | ២១ | " |
| មុក-សាមឿត សុជា | ២១ | " |
| មុក-ចន្ថា ឡាត-សារី | ៤៩ | " |

| | | |
|---|---|---|
| ឡាត-សិត | ២១ | ដុល្លា |
| លោកអ៊ុសមៀលរ៉ាឌូ អ្នកស្រីចាប-សិនឌី | ៣៥ | " |
| លោកសេក-វណ្ណថាត អ្នកស្រីសារឿន.បុត្រ | ៣៥ | " |
| ឧបាសិកា សែត-ស៊ុន | ៣៥ | " |
| ឧបាសិកា អោ-អិត | ៣៥ | " |
| ឧបាសកទីវឡាក់នរ៍ ឧបាសិកាគីម-យាន | ៣៥ | " |
| លោកតាសាន លោកយាយវឿ | ៣៥ | " |
| លោកពត-ភួង | ៣៥ | " |
| ឧបាសិការ៉ា-រ៉ាន | ៣០ | " |
| ឧបាសិកាអោ-ព្រឿង ឧបាសកអិត-ទុំ | ៣០ | " |
| លោកចាប-កញ្ញៀង អ្នកស្រីប៉ែន-សំណា | | |
| ព្រមទាំងកូនចាប-នាងនារី | ២១ | " |
| អាចារ្យជើត-សាញ់ និងភរិយា | ២១ | " |
| អ្នកស្រីស៊ូវ-ឆេង | ២១ | " |
| ម៉ាកាំង-ខ្វេង | ២១ | " |
| ឧបាសកស្រី-ម៉េត ឧបាសិកាធូ-អូន | ២១ | " |
| លោកយាយសាន់-សែន | ២១ | " |
| លោកតាសុខ-សាំង និងភរិយា | ២១ | " |
| ឧបាសិកា ណាំ-គីមហួយ | ២១ | " |
| Ridel Sambur | 40 | " |
| Plong, Sisovan | 20 | " |
| SouchaY, Sisovan | 20 | " |
| លោកទូច-ឈឹត | ២០ | " |

| | |
|---|---|
| Khen, Ray | 20 ដុល្លា |
| Sambun, Heak | 20 " |
| Champy, Soyt | 20 " |
| អ្នកស្រីឈុំ-រង និងបុត្រ | ២០ " |
| ឧបាសក សោម-សាំ | ២០ " |
| ឧបាសិកា ឆៃ-តាំង | ២០ " |
| ឧបាសកស៊ុន-វ៉ា ឧបាសិកាថៃ-យាន | ២០ " |
| ឧបាសិកាឡុង-អ៊ុម | ២០ " |
| ឧបាសិកាង៉ែត-ស៊ុប | ២០ " |
| លោកយាយ ឯក-ជឿន | ២០ " |
| ឧបាសិកា នន់-ញាញ់ | ២០ " |
| ឧបាសិកា សេង-គួយ | ១៥ " |
| លោកឈុត-ហ៊ត អ្នកស្រីសាន់-សែត | ១៥ " |
| លោកយ៉ុងបាន អ្នកស្រីហ៊ីម | ១៥ " |
| ឧបាសិកា មិន-ណាង | ១៥ " |
| នាងស៊ួន-សារី | ១៥ " |
| លោកយាយជួរ-ចន្ទី | ១៤ " |
| លោកយាយម៉ៅ-អេង | ១៤ " |
| លោកលីវ៉ាន់ដារ៉ា អ្នកស្រីរីណា | ១៤ " |
| លោកយាយហ៊ិន-ទាប | ១៤ " |
| សៀត-ស៊ន | ១៤ " |
| លី-គាង | ១៤ " |

| | | |
|---|---|---|
| អ្នកស្រីកែម-ស៊ីវន | ១៤ | ដុល្លា |
| លោកឈយ៍ ជិហ៊ត អ្នកស្រីកាំង-អាវហុយ | ១៤ | " |
| ឧបាសិកាផើត-ស៊ុម | ១៤ | " |
| ឧបាសកមាស-ឆាំ ឧបាសិកាប៊ូ-មៀន | ១៤ | " |
| ឧបាសិកា សួន-ម៉ែន | ១៤ | " |
| ឧបាសិកា ឌួង-គេន | ១៤ | " |
| ឧបាសិកា អ៊ុម-អង់ | ១៤ | " |
| លោកយាយថែម-ផល | ១៤ | " |
| លោកតាសាញ់ និងយាយគង | ១៤ | " |
| លីគិត ឈុំ-ឃឿម | ១០ | " |
| លោកគឹម-ចន្ទវង្ស | ១០ | " |
| ឧបាសកម៉ម-សំកុល ឧបាសិកាលើះ-សាត | ១០ | " |
| អ្នកស្រី សោម-ស៊ី | ១០ | " |
| លោកយាយ យូ-វ៉ាន | ១០ | " |
| លោកតាមី-ឈឿម យាយ ប្រើច | ១០ | " |
| ឧបាសិកា ជា-យ៉ម | ១០ | " |
| លោកភុយ-វ៉ា ភរិយា ព្រមទាំងបុត្រ | ១០ | " |
| ឧបាសិកា គុ-ណាង | ១០ | " |
| ឧបាសកមាស់-ឆាំ ឧបាសិកាប៊ូ-មឿន | ១០ | " |
| ឧបាសិកា គង់-ជីហោ | ១០ | " |
| ឧបាសិកាប្រដាប់ | ១០ | " |
| ប៉ាន់-សារិត | ១០ | " |
| ហ៊ុន-ឈីវលី | ៧ | " |
| អ្នកស្រី វ៉ារី-គាំ | ៧ | " |

| | | |
|---|---|---|
| អៀម-ឡេងឆេង | ៧ | ដុល្លា |
| បាក់វេង-ថូរ | ៧ | " |
| ម៉ាស៊ូលី | ៧ | " |
| មាស-ប៊ូ | ៧ | " |
| លោកយាយឈាវ-យក់ | ៧ | " |
| លោកយាយលឹម-លាង | ៧ | " |
| ឃីម-មាន | ៧ | " |
| លោកយាយម៉ៅ-អេង | ៧ | " |
| នាងម៉េង-សុខ និងគ្រួសារ | ៧ | " |
| កញ្ញា មិន-សាន | ៧ | " |
| លោកម៉េង-ស៊ាវ និងភរិយា ហ៊ាង | ៧ | " |
| លោកប៉ុល្លីហៅជេត អ្នកស្រីនួន-ណាន | ៧ | " |
| លោកយាយឡាយ -ហ៊ាង | ៧ | " |
| លោកយាយ កាំង-គីម | ៧ | " |
| លោកយាយ ស៊ុម-ជុំ | ៧ | " |
| នាងប្រាក់-សាមឿន | ៧ | " |
| លោក លី-ធីង៉ន | ៧ | " |
| លោកយាយរៀម | ៥ | " |
| នាង សន | ៥ | " |
| ហួន-សឿ | ៥ | " |
| សុណាន់ | ៥ | " |
| ប្រាក់-ផន | ៥ | " |
| មិត្ត-វុទ្ធី | ៥ | " |

| | | |
|---|---|---|
| លោកស្រីអ៊ិត-សាម៉ីន(សាម៉ុន) | ២៨០ | ដុល្លា |
| ភិក្ខុសីរចន្ទោ ប៊ូ-ហួយ | ១៥០ | " |
| ណាត-លីហ៊ុន មង្គលសិរីវង្ស | ៧០ | " |
| ភិក្ខុ តេជវរោ ភូ-ផន | ៣៥ | " |
| ឧបាសកចាប-កង ឧបាសិកាពិន-ណម | ៣៥ | " |
| ឧបាសិកាពិន-ណាត | ៣៥ | " |
| លោកពើង-យឿម(សុមេធ) អ្នកស្រីសុខុម | ៧០ | " |
| កុមារ ពើង-ចិរតេជ (កោវិទ) | ២០ | " |
| កុមារី ពើង-ចិរវណ្ណ (ម៉ាលិសា) | ២០ | " |
| លោក យ៉ាំង-ស៊ុង អ្នកស្រី ថង-ស៊ួយ | ៣០ | " |
| លោក យ៉ាំង-វិង អ្នកស្រី ថៃ្ល-ប៊ុន | ១០ | " |
| លោកមាស-ឌឹម លោកស្រីស្លាក់ជី | ៧០ | " |
| លោកតាំ-សាតុំ លោកស្រីនឹម-នួន | ៣៥ | " |
| កុមារី វ៉ាមសួ | ៧ | " |
| កុមារីហ៊ុន-សុគន្ធា និង កុមារហ៊ុល<br>អភិរម្យ | ១៤ | " |
| ណាត-សុវណ្ណ នាងឃុន-សាណម និង<br>កុមារីសុគន្ធា កុមារអភិរម្យ | ១៤ | " |
| លោកវិនឌី-ទេព អ្នកស្រីនារី-ទេព<br>និងកុមារី ជូណា-ទេព | ២១ | " |
| លោកម៉ាស់ស៊ី-ម៉ីន ចន អ្នកស្រី ឌុច-<br>សារ៉ុម និងកុមារី រ៉ុន | ៧ | " |
| លោកយាយ ចាំ-សូភិន | ៧ | " |
| កុមារ ឆាត-សួ | ៧ | " |

**សៀវភៅដែលខ្ញុំបានចម្លងប្រែរៀបរៀងហើយ**
**បានបោះពុម្ពផ្សាយជាធម្មទានមានដូចតទៅនេះគឺៈ**

000

១- គាថាធម្មបទប្រែ ព.ស.២៥២៩
២- អនុពុទ្ធប្បវត្តិ ព.ស.២៥២៩
៣- ពង្សាវតារខ្មែរ ព.ស.២៥២៩
៤- បុណ្យភ្ជុំបិណ្ឌ ព.ស.២៥២៩
៥- មង្គលជីវិត ព.ស.២៥៣០
៦- កម្មកថា ព.ស.២៥៣០
៧- សីមាវិនិច្ឆ័យ ព.ស.២៥៣២
៨- គិហិសង្ខេប ព.ស.២៥៣២,២៥៣៦
៩- គិហិពិស្តារ ព.ស.២៥៣៣,២៥៣៦
១០- មហាវេស្សន្តរជាតកពិស្តារ ព.ស.២៥៣៤
១១- មហាវេស្សន្តរជាតកសង្ខេប ព.ស.២៥៣៥
១២- សាមណេរវិន័យ ព.ស.២៥៣៥
១៣- វេយ្យាករណ៍បាលី ព.ស.២៥៣៥
១៤- ពិធីប្រែបាលី ព.ស.២៥៣៥
១៥- សម្ពុទ្ធមាលា ព.ស.២៥៣៥
១៦- ចតុបារិសុទ្ធិសីល ព.ស.១៥៣៥
១៧- មង្គលត្ថទីបនីប្រែភាគ១-៤ ព.ស.២៥៣៨
និងសៀវភៅផ្សេងៗទៀត ។

××××××